ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា នឹងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ហ្លួងនិពន្ធមន្ត្រី ញុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា: ព្រះគ្រូបញ្ញាលិក្ខិត កៅ-ស៊ុម អ្នកគ្រូតព្រា
សិស្ស នៅសាលាបាលីជាន់ខ្ពស់

## បញ្ជីរឿង

*ផ្នែកអក្សរសាស្ត្រ* — ទំព័រ

ឃុនបញ្ញាសោភ័ន គាំ-ខុម . . . ពតិមាន ថ្លែងសេចក្ដីកាលទៅនាំយកព្រះពុទ្ធរូបនឹងបល្ល័ង្ក នៅឃុំអង្គរបូរី (តាកែវ) ១
ហ្លួងនិពន្ធមន្ត្រី ញុក-ថែម. . . . រឿងរ៉ាវរបស់លោកធុតង្គ ជាតិចិន ១ រូប ឈ្មោះ ហ៊ូន-ផាង . . . . . . . . . ១៥
. . . . . . . . . . . . . . ច្បាប់ព្រះបន្ទូលថែង . . . . . . . . . . ២៥
ព្រះគ្រូមុនីសោភ័ន សោម-ឡុច ធម្មភាសិត . . . . . . . . . . . . ៣៣

*ផ្នែកសាសនា*

ដំណឹងអំពីក្រសួងធម្មការ. . . . . ការប្រជុំលោកមេគណនឹងអនុគណ នៅវត្តសារាវ័ន . . . . . . . . . . . . . ៣៩
លោកគ្រូអាចារ្យ ប៉ាង-ខាត់. . . . អរិយសច្ច ជាពុទ្ធភាសិត. . . . . . . . . ៤២

ឆ្នាំទី ១៧ — លេខ ១ ខែយ៉ាំងវិយេរ ឆ្នាំ ១៩៤៥ — ដំឡៃជាវៈ ១ ឆ្នាំ ១៥ រៀល ។

# KĂMPUCHĔASŎRĬYA

Revue religieuse et littéraire éditée par l'Institut Bouddhique.
Rédacteur en chef de la partie littéraire : Luong Nibandhamantr NHOK-THÊM, Pandit à l'Institut Bouddhique.
Rédacteur en chef de la partie religieuse : Preah kru Paññalikhito KAO-SIM, Surveillant général de l'École Supérieure de Pāli.

## TABLE DES MATIÈRES

### Partie littéraire:


| | | Pages |
|---|---|---|
| K'ŭn Panhnha sòp'ĕaa Kam-Doum . . . . . | Rapport sur le transfert des statues de Bouddha d'Angkorborei (Takèv) à Phnôm-Penh. . . . | 1 |
| Luong Nĭponmontrei Nhok-Thêm. . . . . . | Récit d'un Pèlerin chinois Huoun-Tsang tiré du livre " Religieux et Pèlerins en Terre d'Asie " . . | 15 |
| . . . . . . . . . . . | Chbăp prĕah băntul chèng, poème | 25 |
| Prĕah kru mŭnisòp'ĕan Sòm-Loch. . . . . . | Neaneap'easĕt. . . . . . . . . . . . . | 33 |


### Partie religieuse:


| | | |
|---|---|---|
| Communiqné du Département des Cultes. . . . | Réunion des Mékons et des Anŭkons à Vĕat Saravĕan (P. Penh) | 39 |
| Vén. Achar Pang-Khat. . . | Ariyasaccā — Buddhabhāsitā . . . | 52 |


17e Année — N° 1. Janvier 1945 — Abonnement: un an 15$00.

ពាក្យមានថ្លែងសេចក្ដី

កាលទៅនាំយកព្រះពុទ្ធរូបចម្លាក់នៅឃុំអង្គរបុរី ស្រុកព្រៃកប្បាស

ខែត្រកា ខែសេបតេម្ប៍ ១៩៤៤

# ឃុន បញ្ញាសោភ័ណ គាំ-ឌុម រៀបរៀង

គ្រប់ប្រទេសក្នុងលោកសន្និដ្ឋាន រមែងមានសារមន្ទីរ ១ ឬ ២ ជាដើមទៅ សម្រាប់ប្រមូលយកបុរាណវត្ថុទាំងប៉ុន្មានដែលមានក្នុងស្រុករបស់ខ្លួន ឬក៏ទិញយកមកអំពីប្រទេសក្រៅខ្លះ មកដំកល់ទុកជាទីទស្សនា-ការដល់ពួកបច្ឆាជនការផង (ជនដែលកើតមានក្រោយ) ក្នុងប្រទេសនោះៗ ទាំងជនជាតិប្រទេសដទៃ ដែលត្រូវការចូលទៅមើលដោយប្រាថ្នាចង់ដឹង-ស្គាល់ អស់ទាំងបុរាណវត្ថុក្នុងប្រទេសនោះៗផង ដើម្បីរក្សាទុកកុំឲ្យវិនាសបាត់បង់ទៅ អស់ទាំងបុរាណវត្ថុដែលជាកេរ្តិ៍ដំណែលនៃបុព្វ-បុរសរបស់ប្រទេសនោះៗ ដែលបានធ្វើទុកជាយូរអង្វែងមកហើយផងៗ

អាស្រ័យដោយហេតុដូចនិយាយមកខាងលើនេះហើយ បានជាលោក ឌុយប៉ុងត៍ ជាអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ ជាអធិបតីនៃសារមន្ទីរអ័លបែរសារ៉ូត៍ ភ្នំពេញ ដែលជាមេគ្រប់គ្រងរក្សា អស់ទាំងបុរាណវត្ថុក្នុងស្រុកខ្មែរទាំងប៉ុន្មាន បានចាត់ប្រើយើងខ្ញុំទាំង ៤ នាក់គឺ: គាំ-ឌុម, គឹ-គឹមស៊ុំ, អ៊ុក-សេន, សៅ-សឿន ឲ្យធ្វើដំណើរចេញពី

កំណាត់ត្រាប់ ១ ការុង  ប្រាក់ ១ កន្ទុយថែមទៀត  ព្រមទាំងយកដែក
ដំអឹកទៅដុតដំឲ្យស្រួចខ្លះឲ្យសំប៉ែតខ្លះដម្រូវតាមការដែលត្រូវធ្វើ ៗ

ថ្ងៃ៤ សេបតេម្ប្រ៍ វេលាម៉ោង៩ ព្រឹក ព្រះបាទម្ចាស់ទៅហាយវ័ត្រ
ទីនិងលោកឡឺរេស៊ីដង់  គាត់ប្រើឲ្យពួកអ្នកទោសជញ្ជូនគ្រឿងដែកទីង
ឈើពីសាលារណការស្ថានទៅផ្ទុកក្នុងទូក ១ ដែលជួលពីចិនម្នាក់នៅផ្សារ
តាកែវប៉ុន្តែនឹងយកទៅនាំយកព្រះពុទ្ធរូបជាដើម  ដល់ថ្ងៃល្ងាចម៉ោង៦
ទើបផ្ទុកហើយជាស្រេច ៗ ចំណែកលោកវិស្សុកនឹងពួកវិស្សុកម្ម៨នាក់
ក្រោមបង្គាប់របស់លោក ដែលបំរុងនឹងទៅជួយគាត់ការយកព្រះពុទ្ធរូប
ជាដើម  ជាមួយនឹងពួកយើងខ្ញុំដែរនោះ  បាននិយាយថាឲ្យយើងខ្ញុំ
ចេញទៅយកកាមុនចុះ  ដល់ថ្ងៃ៨ សេបតេម្ប្រ៍  ទើបលោកនាំគ្នាទៅ
ជាខាងក្រោយ  ឯយើងខ្ញុំទាំង៤នាក់ព្រមទាំងទាហាន៤នាក់ផងដែល
លោកឡឺរេស៊ីដង់តាកែវ ហាត់ឲ្យជូនដំណើរទៅនឹងអ្នកថែវ៤នាក់ព្រម
ទាំងចិនម្ចាស់ទូកម្នាក់ទៀតជា ១៣ នាក់ ក៏បានចេញដំណើរទៅពីតាកែវ
ដោយទូកនោះក្នុងវេលាម៉ោង ១០ យប់ថ្ងៃនោះឯង  ដោយហេតុយប់
ងងឹតណាស់ពិបាកនឹងមើលឲ្យឃើញផ្លូវទូលាយ  ដាយនឹងថែវទូកទៅ
ឲ្យបានស្រួល  ព្រោះទីវាលបឹងបឹងតែដុះដេរដាសដោយត្រកៀត ត្រ-
កួន ព្រលិត កំពីងពួយ កះថ្លាក ត្រែង ស្រងែ ក្រចាប់ គាន់គាប់ពាស
ពេញបឹង  ឯអ្នកថែវទូកក៏បេះតែទំព្រីងថែវផងដោលផងពុំមានឈប់

ដោយពួកចោរសុទ្ធតែប្រសប់ ហើយស្គាល់ផ្លូវច្បាស់ច្រើនស្រុកក្រៃ
ណាស់ក៏បានទៅដល់ក្បាលពោធិ៍ នៅវេលាម៉ោង ២ រំលងអធ្រាត្រ
យើងខ្ញុំទាំងអស់គ្នាក៏ជ្រៀតជ្រកចកខ្លួនប្របខ្ទះក្នុងសួនបិទស្រា ហើយ
នាំគ្នាចូលតាមដំណេកនៅទីនោះ ។

លុះព្រឹកព្រាងស្វាងព្រះសុរិយារុណរាជ័យ ពេលម៉ោង ៨ ថ្ងៃ ៥
សេបតមប្រើក៏ចេញខ្លួនពីក្បាលពោធិ៍តាមព្រែកទៅច្បុក (ទាក់ជ្រូក)
ដល់ម៉ោង ១១ ព្រឹកឈប់សម្រាកចូលទានបាយនៅកណ្ដាលបឹងទាង
នាយគ្រូមិនព្រៃផ្តៅបន្ទិច រួចហើយក៏ចេញខ្លួនគេចពីព្រែកវែកស្រែនៃទឹង
ស្មៅដំរីសំដៅទៅលើភ្នំបុរីទឹកបានខ្ញុំឃើញគោសង្ខ័គឲ្យឆាប់ដល់ភ្នំជា ទ !
គួរឲ្យអស្ចារ្យពន់ពេក ដោយក្រឡេកមើលទៅការបើងសន្ទឹងវែងឆ្ងាយផុត
ចូលាយដាប់អន្ទុយក្នែក ឃើញតែចួលក្ដុមទឹងភ្នំដែលនៅឆ្ងាយជាអនេក
ឯណោះ១ ឯណោះ១ ដូចជាកោះនៅក្នុងកណ្ដាលសមុទ្រធំ ព្រៃអាក់
សង្ឃឹមយកន្លែងព្រៃត្រង បើមានឈើណាមួយដុះកែងផុតពីទឹក ព្រៃ
សន្ទឹកខាត់សត្វប្រែក កុក ក្រសារ ចង្កៀលខ្យង ត្រយង កុកក្រក
ហើរក្លៀលគ្នាត់ប្រជុំគ្នាទាំងណែនណាន់តាន់តាប់ មានទាំងសត្វស្មោញ
ហាលស្លាបសម្រាកកំឡាំង ហើយក៏តាំងហើរទៅរកមុជចាប់ត្រីជាចំណី
ទៀត ចំណែកមនុស្សអ្នកស្រុកឃើញតែអុំទូកព្រោងព្រាតពីភូមិ ១ ទៅ
ភូមិ ១ ខ្លះទៅរកកាត់ស្មៅឲ្យគោស៊ី មានទូកខ្លះទៀតដាក់ប្រក-ស្មៅ

គេចាប់ខ្សែដកព្រលិត បើប្រទះទីងសក្តុកណ្ដាលប្រែងប្ដូតស់រីកស្រូវតែង នៅជិតគេកំពាក់-ពួយដោយស្នូ-ប្ដូប្ញកសម្លាប់ហើយកាត់ក្បាលពន្ទាត់ ស្បែក ហេតុនោះហើយបានជាកន្លែងមួយៗ ដែលអ៊ុំមកជិតៈឃើញតែ សាច់ពស់, កណ្ដាប់ប្រែង, ខ្សែង, ព្រលិត ន! ពុទ្ធោអើយ? គួរឲ្យ អាណិតសត្វទាំងនោះណាស់ ដូចសត្វខ្សែងទាំប្រឹងបណ្ដែតប្រាណព្រោង ព្រាតក្នុងទឹកបឹង បញ្ចេញខ្លួននៅស្ពឺងប្រឹងជញ្ជក់អ៊ែលទឹងកំអែលដែល ជាប់នៅទីងស្ទៅមើលទៅហាក់ដូចជាគ្មានទុកព្រួយអ្វីសោះ តែមិនដូច្នោះ មនុស្សគេចាប់ដាក់ទូកយកទៅស្ងោរដោយទឹកក្ដៅគួរឲ្យអនិច្ចា ៗ លៗ

លុះដល់រសៀលព្រះសុរិយា ម៉ោងពីរកន្លះថ្ងៃ ថសេបតមប្រឹក៏បាន ដល់ទៅកំពង់ យើងខ្ញុំក៏ចូលចតទូកនៅជើងកំពង់ផ្លូវដែលឡើងទៅវត្ត យួន ( ដូចាប់សិង ) ដែលផ្ទើជាប់ទឹងគុហាពី ១ នៅជើងកំពង់ជើង ៦ ខ្លួនខ្ញុំនឹងលោកអ៊ុក-សែន បានឡើងពីទូកហើយចូលទៅក្នុងវត្តយួនទាំង រព្ធ នៅក្នុងនោះដែលមានព្រះពុទ្ធរូបត្រូវយកក្នុងពេលនោះ បាននិយាយ ប្រាប់លោកយួនទីងជាតិចេនជាម្ចាស់វត្តទាំងពីរ នោះថា យើងដែលមក នេះគឺកដតារកាងក្រសួងពុទ្ធសាសនបណ្ឌិត្យក្នុំពេញ ប្រើឲ្យមកជីកនាំ យកព្រះពុទ្ធរូបក្នុងវត្តទាំង ៣ ទៅដំកល់ទុកនៅសាមន្ទីរខែ្មរឯក្រុង ភ្នំពេញ រឿងនេះប្រហែលជាលោកស្ហេប៉ុស្ដិ៍ទីងលោកមេឃុំបាន ជំកបឲ្យដឹងពីថ្ងៃមុនហើយដែរឬ?

ចំណែកប្អូនទាំងអម្បាលម៉ាន លុះបានឮខ្ញុំនិយាយយ៉ាងនេះទៅ ហើយក៏ប្រែទឹកមុខគ្រប់គ្នា ឯពួកស្រីៗ ក្រែងតែចេញទឹកភ្នែករលីង ហោងនិយាយរអាក់រអួលថា ព្រោះអាល័យស្តាយព្រះពុទ្ធរូប លើកដៃសំពះហើយនិយាយថា យើងបានដឹងគ្រប់គ្នាហើយ ប៉ុន្តែយើងសុំអង្វរបងសុំឲ្យបង្អង់ចាំ ២ ថ្ងៃសិន ព្រោះបានជាឲ្យដំណឹងទៅប្រាប់បងប្អូនដែលនៅឆ្ងាយៗ ហៅគេដល់ចុងដុក. បានយី, ភ្នំបុរី, តាកែវ ។ល។ ដែលទៅហើយថាថ្ងៃ ៧ សេចគម្រប់ ក្រោយនេះនឹងឲ្យមកជួបជុំគ្នាធ្វើបុណ្យនមស្ការជូនដំណើរព្រះពុទ្ធរូប ដែលនឹងឃ្លាតចាកចោលស្ថាន ជាកិច្ចដ៏សមគួរដល់សេចក្តីកបកានរបស់យើងដែលធ្លាប់គោរពប្រណិប័តន៍ព្រះអង្គមកជាយូរអង្វែងហើយ បើជការមកយកទៅហើយ យើងក៏ពុំហ៊ានកំណត់ តាមសំដីពួកប្អូនដែលអង្វរនោះគួរឲ្យអាណិតណាស់ ព្រោះនិយាយផងហូរទឹកភ្នែកផង ដោយជាតិប្អូនជាអ្នកប្រសប់ទាងធ្វើឲ្យអាណិត ប៉ុន្តែខ្លួនខ្ញុំគិតឃើញថា បើទទួលអង្វរតាមពាក្យប្អូនសុំ មុខជាយកមិនទាន់ដល់ពេលប្រជុំធ្វើបុណ្យនោះឃុំអង្គរបុរី ថ្ងៃ ១២ សេចកម្រប់នោះទេ ព្រោះពិចិត្យមើលទៅព្រះពុទ្ធរូប ១ អង្គៗ មិនងាយនឹងយកទៅដាក់ទូកបានដោយងាយឡើយ ម្ល៉ោះហើយខ្ញុំក៏ប្រាប់តបទៅពួកប្អូនវិញថា ខ្ញុំទទួលអង្វរបងប្អូនទាំងនេះសគ្នាមិនបានទេ ព្រោះជាហេតុនាំឲ្យយឺតយូរមិនទាន់ពេលបុណ្យថ្ងៃ ១៤ នាំឲ្យទៅហួសឃុំមាយ

ខ្ញុំស្តាប់ឆ្ងាស់ បើអ្នកទាំងអស់បានសេចក្តីអនុញ្ញាតយល់ព្រមពីលោក ឡឺស្ស៊ីផង់ និងចៅហ្វាយខេត្តតាកែវមក ទើបខ្ញុំទទួលព្រមបាន វេលាព្រឹកស្អែកថ្ងៃ៦សេចតម្រើ ខ្ញុំនឹងប្រមូលពួកគ្រូលីមកឲ្យនិមន្តព្រះពុទ្ធរូបទៅដាក់ទុកជាមុនខាន ។ តពីនេះទៅខ្ញុំបាននិយាយពន្យល់ពួកយួនទាំងនោះទៀតថា រាជការដែលត្រូវការយករូបទាំងប៉ុន្មាននោះ ពុំមែនយករូបដែលអ្នកទាំងអស់គ្នាធ្វើខាងក្រោយនោះទេ រាជការត្រូវការយកតែរូបណាដែលជារបស់ខ្មែរពីបុរាណប៉ុណ្ណោះ ឯព្រះពុទ្ធរូបរបស់អ្នកទាំងអស់គ្នាដែលរាជការបំរុងនឹងយកក្នុងពេលនេះ ព្រោះតែអ្នកទាំងអស់គ្នាយករូបរបស់ខ្មែរពីបុរាណមកបូកប៉ះស៊ីម៉ងត៍កែប្រែធ្វើជាព្រះពុទ្ធរូបឡើង ដោយបំណងថានឹងជួសជុលរូបនោះរក្សាទុកឲ្យបានគង់ល្អតទៅ ឬក៏ដោយចេតនាដូចម្តេចរបស់អស់អ្នកក្នុងពេលដែលធ្វើនោះ តែតាមយោបល់ផ្លូវរាជការក្រសួងរក្សាបុរាណវត្ថុវិញយល់ថា ការធ្វើបែបនេះមិនឲ្យឈ្មោះថាស្រឡាញ់-រក្សាបុរាណវត្ថុ ដោយល្អបានទេ ដោយពិតនោះបើឃើញមានបុរាណវត្ថុនៅក្នុងទីណាមិនត្រូវទៅគាស់កកាយយកអ្វី បើថារូបឬក្បាច់មិនត្រូវពុះបំបែកបំបាក់តាមបំណងចិត្ត ឬដែលបាក់បែកហើយមិនត្រូវយកទៅប៉ះជួសជុលបូកស៊ីម៉ងត៍បំពេញធ្វើឲ្យប្លែកពីភាពដើមឡើយ សូម្បីធ្វើដោយចិត្តជ្រះថ្លាប្រាថ្នាបុណ្យកុសលយកមាសទៅបិទលាបឲ្យល្អឡើងក៏ពុំគួរដែរ បើធ្វើតាមទំនងដូច

និយាយខាងលើនេះ ទើបបានឈ្មោះថាបេះស្រឡាញ់-វត្តបុកណាវត្ត ដោយល្អបានសេចក្តីសរសើរគ្រប់ក្រសួងវត្តបុកណាវត្តផង វេលាដែលពលការត្រូវការយកទៅឃើងក៏ពុំមានសេចក្តីសោកស្តាយប៉ុន្មានផង ដែលខ្ញុំនិយាយដូច្នេះមកពីខ្ញុំបានដើរមើលបុកណាវត្តដោយកន្លែងខ្លះបានសង្កេតទៅយល់ច្បាស់ភាពនឹងនៅបានថា បុកណាវត្តក្នុងស្រុកខ្មែរទាំងមូលដែលវិនាសទៅដោយកុសលចេតនារបស់អ្នកស្រុក:ស្ទើរតែទាំងអស់ គឺដោយហេតុទៅគាស់រំលាយទីបុកណាវត្តចោលហើយកសាងវត្ថុអាគារសង្កត់ពីលើ ឬក៏ទៅជីកគាស់កកាយយកឥដ្ឋ-ថ្មផ្សេងៗយកទៅធ្វើជាខឿនវិហារនិងជណ្តើរជាដើមក្នុងទីជិតនៃ ដោយប្រាថ្នាយកបុណ្យពីការសាងថ្មី ឯសេចក្តីដែលធ្វើឲ្យវិនាសកេរ្តិ៍ដំណែលរបស់បុព្វបុរសមិនគិតផងសោះ ដូចពាក្យបុរាណថា "បានថ្មីបោះបង់ចាស់ពុំទុកនា" រឿងនេះ យើងជាពុទ្ធ-សាសនិកជនគួរគាត់សេចក្តីថាដូចម្តេចៗ រួចហើយខ្ញុំនឹងលោកអ៊ុក-សេន ក៏លាពួកយួនត្រឡប់ទៅកន្លែងទូកវិញ បានជញ្ជូនឈើទាំងគ្រឿងដែកចេញពីទូកដាក់លើគោកជាស្រេច ដល់ម៉ោង ៦ ល្ងាចខ្ញុំតែម្នាក់ឯងក៏ជួលទូក ១ ជិះទៅអង្គរបុរី ដល់ហើយក៏ប្រាប់មេឃុំនឹងសេហ្វុំស្តឲ្យរកគូលីឲ្យ ៣០ នាក់ ឯមេឃុំក៏បានចាត់មនុស្សឲ្យទៅកេណ្ឌបណ្តាស្រុកដែលនៅក្នុងភូមិព្រែកដាជិតភ្នំដាទឹងភ្នំបាខេង បំរុងនឹងឲ្យទៅធ្វើការជាមួយនឹងខ្ញុំបានចំនួន ៣០ នាក់ពីល្ងាចថ្ងៃ ៥ សេចគម្រប់ទុកជាស្រេចៗ

# អំពីយកព្រះនារាយណ៍ ភ្នំដា)

ថ្ងៃ ៦ សេបតេមប្រឹមោង ១០ ព្រឹក ពួកគូលីមកគាស់ជួបជុំគ្នា ឯពួកខ្ញុំក៏បានទទួលទានអាហាររួចជាស្រេច ឯពួកយួនអ្នកស្រុកសឹងតែបានយកស្គរគងឃ្មោះទៅនៅប្រចាំគោះជួយហៅហោមផងព្រមគ្នាទាំងអស់តែម្តងចូលទៅកន្លែងហាវគ្គព្រះនារាយណ៍ តាមពាក្យយួនទាំងឡាយហៅថាជួអុនថៃយឿង ហើយក៏គាំងប្រណម្យដៃទាំងអស់គ្នាឡើងចំពោះព្រះនារាយណ៍ ទំយាយសុំខមាទោសថា យើងខ្ញុំទាំងឡាយមកអញ្ជើញព្រះនារាយណ៍ សូមឲ្យបានសុខសប្បាយទាំងអស់គ្នា អាក្រក់ល្អក៏ទេពាក្យអ្នកតាសូមកុំប្រកាន់ទោសា ព្រោះយើងខ្ញុំទាំងអស់គ្នាដែលមកនេះពុំមែនដោយចិត្តក្លែងប្រមាទពាលាញាញឹមឲ្យអន្តរាយ គឺធ្វើតាមបង្គាប់នាយទៅហ្វាយម្ចាស់ផែនដី សូមអញ្ជើញព្រះនារាយណ៍ទេវតាដោយមេត្រីសោះព្រមទាំងកំណាត់រូបធំ-តូចទាំងអស់ ទៅសណ្ឋិតនៅសារ-មន្ទីរក៏ពេញ ។ រួចហើយទើបឲ្យពួកគូលីយកពួរចងរុំព្រះនារាយណ៍សែងរំកិលចុះពីលើបល្ល័ង្ក មានទាំងស្គរគងឃ្មោះគោះតាំងកាយដំគ្រែកគគ្រេងពីខាងមុខ ឯព្រះនារាយណ៍ក៏អញ្ជើញទៅគ្រប់ជាសុខសប្បាយដរាបដល់ទូកនិងទូកហើយជាស្រេច ទើបគេត្រឡប់ទៅប្រមូលយកកំណាត់រូបផ្សេងទៀតមានចំនួនទាំងអស់ដូចតទៅនេះ គឺ :

រូបព្រះនារាយណ៍ឈរដៃបួន ១, កំណាត់ខ្លួន ៤, កំណាត់ជើងនិងកំណាត់ផ្សេងទៀត ៨-រួមទាំងអស់ជា ១៣ ។

ឯព្រះនារាយណ៍ជាទីគោរពរាប់អានបំផុតរបស់យួននឹងខ្មែរ គេទុក ថាជាព្រះឫទ្ធិសម្រាប់បន់ស្រន់ការអាសន្នគ្រប់ប្រការ បើបានសម្រេច ដូចប្រាថ្នានឹងថ្វាយអង្ក្រៈ, ស្វាយមិដូង, គ្រឿងសៀម, ឬទិមទូកក្តុសង្ស្រោះ ថ្វាយ, ធ្វើបុណ្យផ្កាថ្វាយ, ធ្វើកឋិនថ្វាយជាដើម ហេតុនោះបានជា លោកគ្រូ អុងដាំង អាយុ ២៨ ឆ្នាំជាមេវត្តនឹងយាយជីម្នាក់ឈ្មោះ ប៉ាកូ អាយុ ៧៥ ឆ្នាំដែលជាអ្នកនៅរក្សាវត្តនោះជានិច្ច តែងបានកំរើបញ្ចូមដាំរែ នឹងរក្សាវត្តដោយសារផ្សាយដែលកើតអំពីអានុភាពរបស់ព្រះនារាយណ៍ នោះឯង ។

ព្រះនារាយណ៍នេះ កាលពីដើមរាង ៤០ ឆ្នាំហើយ មាន យាយចាស់ជាតិយួនម្នាក់បានធ្វើវិហារប្រក់គ្រឿង ១ ថ្វាយ ដោយជឿ ជាក់ថា ព្រះនារាយណ៍នោះឲ្យអំណោយផលស័ក្តិសិទ្ធិជាទីអស្ចារ្យដល់ខ្លួន ដល់ខាងក្រោយមក អំណោះឥតអំពីយាយនោះទៅ វិហារក៏ដល់នូវ ការបាក់បែកអស់ទៅព្រោះគ្មានគេថែរក្សា ទើបតែក្នុងរាង ៨ - ៩ ឆ្នាំ កន្លងមកនេះ ទើបមានពួកយួនមកធ្វើវិហារប្រក់ស័ង្កសី ១ ថ្វាយ ឯរូប ព្រះនារាយណ៍ដែលបាក់បែកនោះបានបូកបិទភ្ជាប់ដៃជើងនឹងក្បាលធ្វើជារូប ឈរមានដៃ ៤ តាមទំនងដើមតែកែប្រែជារបៀបបែបរូបខាងយួន - ចិន វិញ សម្រាប់មានអាសន្នចូលទៅបន់ស្រន់ម្តងៗ ប៉ុន្តែការដែលបន់នោះ ទុកជាសម្រេចក្តីមិនសម្រេចក្តី ក៏គេត្រូវតែលាបំណន់ថ្វាយផ្សាយតាម

ពាក្យដែលគេបន់នោះជាធម្មតា ឯព្រះនាកយណ៍នេះពូកែឬមិនពូកែពុំប្រាកដ ប៉ុន្តែត្រង់ដែលអ្នកស្រុកចុះចូលរាប់អានឃើញពិតជាច្រើនមែន ព្រោះវេលាដែលយកព្រះនាកយណ៍ទៅដល់អគ្គរបុរីចតទូកទុកនៅមុខវត្តកំពង់ហ្លួងក្នុង ១ ថ្ងៃៗ ឃើញមានខ្មែរចិនយួនជាច្រើន ចូលទៅលាបំ-ណាន់ដែលបានបន់ទុកយូរហើយ ដោយថ្វាយអង្ករខ្លះ ស្លាធម៌ជូនខ្លះ ភ្លេងសៀមខ្លះ ឬគ្រាន់តែអុជធូបទៀនថ្វាយនោះក៏មានច្រើនជាអនេក ឯព្រះពុទ្ធរូបមែននោះ ឃើញច្រើនតែអុជធូបទៀនថ្វាយបង្គំជាធម្មតាប៉ុណ្ណោះ ឯព្រះនាកយណ៍នោះសូម្បីកាលចេញទូកពីអគ្គរបុរីទៅចូផុក (មាត់ជ្រូក) ពីចូផុកមកដល់ភ្នំពេញ លោកអ៊ុក-សេន និងសៅ-សឿង ដែលនៅក្បែរទូកបាននិយាយប្រាប់ខ្ញុំថា មានចិន-យួនចូលទៅថ្វាយបង្គំបន់ស្រន់និងថ្វាយធូបទៀនស្លាធម៌ជូនជាដរាប មានទាំងថ្វាយប្រាក់ ១រ.០០ ឬ ៥០ :សេន ២០ សេនជាច្រើនគ្នាផង ប៉ុន្តែការថ្វាយដោយប្រាក់ច្រើន តែមិនទទួលឲ្យទិញជាធូបទៀនថ្វាយវិញ លុះមកដល់ភ្នំពេញដាក់ទុកក្នុងសា-រមន្ទីរហើយ ក៏នៅតែមានជាតិយួនចូលទៅគោរពប្រណិប័តន៍ជាហូរហែទៀត ដោយហេតុពិតយ៉ាងនេះហើយ បានជាលោកគ្រូ អុងជាំង នៅវត្តព្រះនាកយណ៍ (ជួអុងដៃយឿង) និងជាតិយួនខ្មែរសោកស្ដាយរូបនេះណាស់ ទុកជាធ្វើសងវិញក៏មិនពេញចិត្តស្មោះអស់ពីពោះដូចជារូបមុនដែរ ។

# អំពីយកព្រះពុទ្ធរូបក្នុងគុហាទី ១ (ភ្នំដា)

លុះយករូបក្នុងវត្តព្រះនាគបេណ៌រួចជាស្រេច ក្នុងវេលាម៉ោង ៣ រសៀលហើយ ដោយខាតពេលវេលាច្រើន យើងខ្ញុំក៏នាំគ្នាចូលទៅយក ព្រះពុទ្ធរូបក្នុងគុហាទី ១ យួនហៅថា ជួថាប់សឹង ជាវត្តយួន ១ មាន តែលោកយួន ១ រូបឈ្មោះឈើង អាយុ ៨០ ឆ្នាំ យួនហៅថាអុងជូទី និង យាយជីម្នាក់ឈ្មោះបាខា អាយុ ៦០ ឆ្នាំនៅចាំរក្សាតទៅទៀត ចំណែក ឯយាយបាខា លុះបានឃើញយើងខ្ញុំចូលទៅប្រាប់ថាមកយកព្រះពុទ្ធរូប កាលណា ក៏ឆកមុខចេញពុំមានឈាម មាននេត្រាស្រក់សស្រោក យំត្រូកត្រាក់សោកស្ដាយព្រះពុទ្ធរូបដែលប្រាស់ចេញពីកន្លែង។ ទុក ជាខ្ញុំថ្លែងប្រាប់ថាឆាយទៅហ្វាយខ្ញុំនឹងធ្វើលងវិញក៏នៅតែមិនបាត់ស្ដាយ បរិយាយតបមកវិញថា មិនពេញចិត្តសោះអស់ពីពោះពុងដូចគន្ធពុទ្ធរូប ដែលធ្លាប់ប្រណិប័តន៍មកហើយទេ រួចហើយយើងខ្ញុំនឹងពួកគូលីចូល ទៅក្នុងគុហា ខមស្រាការថ្វាយបង្គំសុំខមាទោសដូចមុន ហើយក៏យកដែក ជំទឹកទៅគាស់ខ្ទះបល្ល័ង្កនិមន្តព្រះពុទ្ធរូបដង្ហែចេញមកពីគុហា មានស្ដូ ឃ្មោះ រាយដំគគ្រិកគគ្រែងដកបងល់ដំកល់ទុកក្នុងទូកហើយជាស្រេចក្នុង វេលាម៉ោង ៤ កន្លះល្ងាចថ្ងៃ ៦ សេបតមប្រ៍ ។

ព្រះពុទ្ធរូបនេះឯង កាលដែលពួកយួនបួកបះរូបចាស់ពីបុកណាជា រូបឈើ តែធ្វើជាព្រះពុទ្ធរូបទង់តែនតាមរបៀបយួនទៀតនោះ ឃើញ

ជាមានគំនិតល្អណាស់ បេះក្រចកអស់ទាំងកំណាត់ដៃជើងដែលបែក បាក់ទៅសល់ប៉ុន្មានទៀតនៅ ដោយយកកំណាត់ចុងជើងទៅក្រាប់ធ្វើជា បល្ល័ង្កទេវក្លូនខាងមុខ. កំណាត់ចុងដៃញាត់ចុកពីខាងក្រោមក្លូន ២ កំណាត់ខ្លះទៀតត្រៀតផ្អប់សំពែងមពោះទាំងសងខាង សំអាងជាព្រះ-ហស្តជំរុតលើគ្នាត្រូវឲ្យសរសើរថា ជាអ្នកបេះក្រចកដោយល្អបាន ។

លុះដល់ម៉ោង ៦ កន្លះល្ងាចថ្ងៃនោះឯង ទើបឃើញពួកថៃយូនចំនួន ៤ នាក់ជាវិស្វកម្មក្រសួងសាធារណការតាក់តែងមកដល់ក្នុងជាជួបនឹង យើងខ្ញុំទាំងអស់គ្នា ហើយប្រគល់សំបុត្រ ១ ច្បាប់ដែលលោកឡឺរេស៊ីដង់ត៍ ទ.ន ព្រះបាទម្ចាស់ចៅហ្វាយខែត្រតាកែវ ផ្ញើទៅលោកឌេយ៉ុនីងលាំត សេហ៊ុំស្ដិ៍ សេចក្ដីថា... លោកវិស្វករមិនបានមកទេ ព្រោះមានសំបុត្រ វិលរួសពីព្រៃនគរផ្ញើមកថា ម្ដាយលោកអនិច្ចធម្ម សុំឲ្យតែពួកវិស្វកម្ម ទាំង ៤ នាក់នេះមកជំនួស ព្រោះជាអ្នកចេះការស្ទាត់ប្រាកដដូចជាលោក វិស្វករដែរ ។ លុះយើងខ្ញុំមានសេចក្ដីត្រេកអរឥតឧបមា ដោយបានឃើញ ពួកវិស្វកម្មក្រសួងសាធារណការទៅដល់ ព្រោះកាលមុនខ្វល់ចិត្តក្រែង មិនបានធ្វើការរួច ឯថៃយូនទាំងអស់ក៏សុទ្ធតែមានចិត្តសប្បុរសរួសរាយ ដោយពុំហាមមិនធ្វើដៃបាំហា សញ្ញាដាក់ពួកយើងខ្ញុំឡើយ ... ហើយ វេលាបរិភោគបាយ ប្រញាយគ្នាលូកប្រឡូកប្រឡល់ទៅមកតាមត្រូវការ សប្បាយគ្រប់គ្នាគ្រប់វេលានោះហោង ។ (មានត)

## រឿងក៏របស់លោកគុតង្គ ជាតិចិន ១រូប

### ឈ្មោះហ៊ួន-ឆាង

### ពាក្យផ្តើម.

ក្នុងការប្រែសេចក្តីរឿងក៏វគ្គទីមួយជាភាសាបារាំង ដែលលោកអ្នកប្រាជ្ញធំៗ នៅសាលាបារាំងសេសចុងបូព៌ាប្រទេស បានតែងឬរៀបរៀងឡើងនោះ ជាការៈយ៉ាងធ្ងន់លើអ្នកប្រែ ដែលមានចំណេះចេះដឹងតិចក្នុងវិជ្ជាភាសានេះ ដែលជាភាសាក្រប់ផុតមួយក្នុងលោក ៗ ហេតុនេះអ្នកប្រែរឿងនេះមកជាខេមរភាសា សូមបញ្ជាក់ដល់អ្នកមើលទាំងឡាយថា អ្នកប្រែមិនមែនជាអ្នកមានចំណេះចេះដឹងជ្រៅជ្រះ ក្នុងវិជ្ជាភាសាបារាំងសែសទេ ការប្រែរបស់យើងគង់មានភ្លាំងភ្លាត់ខ្លះជាពុំខាន តែយើងមានសង្ឃឹមថា គង់បានទទួលអភ័យទោសអំពីសំណាក់អ្នកមើលទាំងឡាយ ៗ

បំណងធំរបស់យើងក្រែងចេះឲ្យបណ្តាញាតិជាតិខ្មែរផងគ្នា ដែលមិនបានចេះភាសាបារាំងសែសនោះ បានដឹងរឿងក៏ប្លែកៗរបស់នានាប្រទេសខ្លះ ដើម្បីជាគ្រឿងប្រដាប់ចំរើនបញ្ញាទីចំណេះចេះដឹងទៅប៉ុណ្ណោះ ៗ

មួយវិញទៀត រឿងក៏របស់លោកគុតង្គជាតិចិនឈ្មោះហ៊ួន-ឆាង នេះគួរទុកជាគោលការណ៍មួយរបស់ក្បួនសាស្ត្រ ទីន្តប្រវត្តិសាស្ត្រខែកខាង ពុទ្ធសាសនាបានខ្លះ ក្នុងរវាងសករាជដ៏មួយពាន់ឆ្នាំកន្លងមកហើយ ព្រោះ

រឿងរ៉ាវទាំងនោះ ជាគ្រឿងចុះបំភ្លឺឲ្យឃើញសេចក្ដីចំរើនរុងរឿងនៃព្រះពុទ្ធសាសនា ដែលតាំងនៅក្នុងភាគផែនដីផ្សេងៗ ក្នុងប្រទេសឥណ្ឌា ក្នុងប្រទេសចិន និងក្នុងប្រទេសនានានៅទ្វីបអាស៊ីកណ្ដាល ក្នុងសម័យព្រេងនាយនោះផង ៗ ក្រៅអំពីនេះរឿងរ៉ាវដែលលោកហ្វូន-ឆាំងបានកត់ត្រាទុកមកតាំងអំពីកាលនោះ រមែងមានប្រយោជន៍ជាសំខាន់ ដល់ភូមិសាស្ត្រនិងប្រវត្តិសាស្ត្រ សម្រាប់ស្រុកទេសដោយឡែកទៀតផង ៗ

ហេតុដូច្នេះ ការប្រែរឿងនេះមកជាខេមរភាសា គង់មានប្រយោជន៍ដល់ពួកពុទ្ធសាសនិកជនជាខេមរជាតិយើងខ្លះជាពុំខាន ព្រោះតាមសេចក្ដីនៃរឿងនោះ បានបង្ហាញបំភ្លឺឲ្យយើងបានឃើញសេចក្ដីជ្រះថ្លាយ៉ាងមុតមាំណាស់និងសេចក្ដីព្យាយាមយ៉ាងសំបើមអស្ចារ្យ របស់ពុទ្ធសាសនិកបព្វជិតជាតិចិន១រូប ដែលបានធ្វើដំណើរដើរធុតង្គទៅកាន់បូជនីយដ្ឋាននានារបស់ពុទ្ធសាសនា ក្នុងប្រទេសឥណ្ឌា សម័យបុរាណ ៗ សម័យនោះហើយ ដែលមានផ្លូវគមនាគមលំបាកជាបំផុត ព្រោះត្រូវតែដើរកាត់ឡើងផងក្នុងព្រៃដ៏ដេរដាសទៅដោយហិមៈ មានភ្នំខ្ពស់ត្រដែតជាប់ពពក គ្មានប្រឡាយទឹកហូរធ្លាក់ពីលើភ្នំចុះមក ឬ ឬតគុកគគាក ឥតស្រាក មានភាពសសើមត្រជាក់ដូចជាទឹកកកហើយដួលតាលត្រូវ

ដើរកាត់ឆ្លងព្រៃព្រឹក្សាដ៏ធំធេង  គួរឲ្យស្ញែងខ្លាចក្រែងអន្តរាយដល់ជីវិត អំពីសត្វសាហាវយង់ឃ្នងនានា  ជួនកាលត្រូវដើរឆ្លងសមុទ្រខ្សាច់ដ៏សំ-បើមល្វឹងល្វើយ មើលទៅឃើញតែដីនឹងមេឃនៅឆ្ងាយលប់លិច ឥតមានឃើញរុក្ខជាតិ១ដើមឬស្មៅ១គុម្ពសោះ  ហើយមានអាកាសក្តៅហែងស្ទើរឆេះគ្រប់វេលាថ្ងៃ ទាល់តែព្រះអាទិត្យជ្រៀងជ្រេអស្តង្គតទៅ  ទើបសម្រាលកំដៅខ្សាច់ឲ្យបានត្រជាក់បន្តិចឡើងៗ លុះដល់យប់សន្ធ្យាទើបគេអាចធ្វើដំណើរដើរឆ្លងកាត់ទៅពីតំបន់មួយទៅតំបន់មួយបាន  ហើយទៅតាមរកផ្លូវតាំងនោះសោតទៀត  សឹងប្រទះឃើញតែឆ្អឹងសដេរដាស  គឺសុទ្ធតែជាឆ្អឹងខ្មោចមនុស្សឬសត្វ  ដែលដល់នូវមរណៈតាមរយៈផ្លូវដាច់ស្រយាលនោះ ដោយហេតុវិបត្តិអន្តរាយផ្សេងៗ សឹងមានច្រើនជាអនេកណាស់ ។

ហេតុដូច្នេះ ទើបគួរឲ្យស្ញើច, គួរឲ្យស្ញប់ស្ញែងជាពន្ទឹក  ចំពោះការធ្វើដំណើរដើរធុតង្គកាត់ផ្លូវឆ្ងាយដាច់ស្រយាល  របស់លោកធុតង្គហួន-ឆាង  ដូចយើងបានពណ៌នាមកនេះ ។ យើងយល់ថា  លោកហួន-ឆាងនេះគួរទុកដាក់ជាមនុស្សមួយ  ដែលប្រកបដោយលក្ខណៈរបស់មហាបុរសៈច្រើនប្រការគឺ  មានបញ្ញាស្មារតីខ្ជាប់ខ្ជួន, មានព្យាយាមធំ, មានសេចក្តីក្លាហានអង់អាចមិនខ្លាចស្លាប់ មានសេចក្តីជ្រះថ្លាក្នុងព្រះពុទ្ធសាសនាយ៉ាងមាំមួនជាបំផុត...។ មនុស្សបែបនេះ ទើបអាចធ្វើ

ការធំៗបានសម្រេច ទុកជាកេរ្តិ៍មតកដល់ជនជាន់ក្រោយតៗមកជាច្រើន សតវត្សរ៍ មនុស្សបែបនេះហើយដែលគេបានកត់ត្រាឈ្មោះ និងរឿងរ៉ាវរបស់លោកទុកក្នុងពង្សាវតាររបស់សាសនាឬរបស់ជាតិ អស់កាលដ៏លង់អន្លង់វែងឆ្ងាយជាប្រាកដ ។

ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម
បណ្ឌិត នៅពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

---

## រឿងរ៉ាវរបស់លោកធុតង្គជាតិចិន ១ រូប

### ឈ្មោះ ហ្វួន-ឆាង.

ហ្លួងនិពន្ធមន្ត្រីញ៉ុក-ថែម ស្រង់និងប្រែចេញអំពីសៀវភៅ, Religieux et Pèlerins en Terre d'Asie របស់លោក Victor Golaubew សមាជិកសាលាបារាំងសែសនៅចុងបូព៌ាប្រទេស ។

— ១ —

កាលពីឆ្នាំ ៦១ នៃគ្រិស្តសករាជនោះ, ព្រះចៅកដាឯកជព្រះនាម មិង-ទី ជាតិចិន ទ្រង់ព្រះសុបិនឃើញព្រះ ១ ព្រះអង្គដែលទ្រង់មិនដែលស្គាល់សោះ ព្រះកាយរបស់ព្រះអង្គនោះមានរស្មីភ្លឺ ដូចជាមាសយ៉ាងបរិសុទ្ធ ហើយអណ្ដែតទៅតាមអាកាសបាន ដូចជាពួកមនុស្ស ព្រះបាទមិនប៉ះពាល់ដល់ដីឡើយ ៗ លុះដល់ព្រឹកឡើង ទ្រង់

តើនចាកទីព្រះក្រឡាបន្ទំ ទើបទ្រង់សាកសួរពួកមន្ត្រីទីប្រឹក្សារបស់ព្រះអង្គ អំពីសុបិននិមិត្តនោះ ។ មានក្រុមប្រឹក្សាម្នាក់ក្រាបបង្គំទូលព្រះអង្គថា :

"ព្រះករុណាថ្លៃវិសេស ខ្ញុំព្រះបង្គំជាខ្ញុំម្ចាស់ដឹងមកថា នៅប្រទេសឥណ្ឌាមានមនុស្សម្នាក់គេហៅថា ព្រះពុទ្ធ ។ មនុស្សនោះបានសម្រេចជា "តៅ" គឺប្រាជ្ញាត្រាស់ដឹងដ៏ខ្ពង់ខ្ពស់ ។ ព្រះកាយរបស់ព្រះអង្គនោះស្រាលណាស់ អាចអណ្ដែតទៅតាមអាកាសបាន ។ សូមទ្រង់ព្រះមេត្តាប្រោស, ប្រហែលជាព្រះអង្គនោះហើយទេដឹង ដែលទ្រង់បានទតឃើញក្នុងព្រះសុបិន ?

ទើបព្រះចៅរាជាធិរាជ ទ្រង់ចាត់បញ្ជូនរាជទូត ១ ក្រុមទៅប្រទេសឥណ្ឌាក្នុងខណៈនោះឯង ។ លុះកន្លងទៅជាច្រើនឆ្នាំ ទើបក្រុមរាជទូតនោះត្រឡប់មកដល់ស្រុកចិនវិញ ព្រមទាំងបាននាំយកគម្ពីររួចដែលចេះស្អាតក្នុងគម្ពីរសំស្ក្រឹតហើយមានទាំងសេះស ១ សម្រាប់ផ្ទុកគម្ពីរដីកាពីខាងលើខ្នង ព្រមទាំងព្រះរូបឆ្លាក់ពីឈើខ្លឹមច័ន្ទន៍និងគំនូរទាំងឡាយ ។ មានគំនូរមួយនោះ ជាគំនូរព្រះពុទ្ធសាក្យមុនី គេបានលាត្រដាងគំនូរនេះថ្វាយចំពោះព្រះភ័ក្ត្រព្រះចៅរាជាធិរាជ ហើយទ្រង់បានស្គាល់ជាក់ជាមនុស្សនោះស្មើប្លែកយ៉ាងអស្ចារ្យ ដូចដែលទ្រង់បានទតឃើញក្នុងព្រះសុបិននោះឯង ។ ព្រះចៅរាជាធិរាជ មានព្រះរាជហឫទ័យត្រេកអរ

ខ្ទាំងណាស់ ទើបទ្រង់ចាត់ឲ្យគេសាងវត្តមួយនៅជិតទ្វារក្រុងរបស់ទ្រង់ លុះដល់ទ្រង់សោយព្រះទិវង្គតទៅ គេបានដំកល់ព្រះពុទ្ធរូប ១ ព្រះអង្គ នៅក្បែរផ្នូររបស់ទ្រង់ ។

តាមដោយពិតនោះ មានរឿងក៏រដំណាលទុកថា ក្នុងកំឡុងសតវត្សរ៍ទី ២ នៃគ្រិស្តសករាជនោះ នៅប្រទេសចិនមានគណសង្ឃពុទ្ធសាសនាកើតប្រាកដឡើងហើយជាដំបូង ។ កាលពីក្នុងរជ្ជព្រះចៅកជាធិរាជហ្វេន-ទី នៅក្នុងឆ្នាំ ១៦០ នៃគ្រិស្តសករាជនោះ មានភិក្ខុហិណ្ឌូពីររូបដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញ បានចាត់កសាងអារាមពុទ្ធសាសនា ១ ឡើង នៅជិតស្រុកឈោ-យ៉ាងជាទីក្រុងរបស់ហានក្នុងជាន់ក្រោយ ។ គំរូរបស់ភិក្ខុទាំងពីររូបនោះ នាំឲ្យលោកពសង្ឃពុទ្ធសាសនារូបឯទៀតៗ ដែលមានកំណើតនៅប្រទេសឥណ្ឌា ឬនៅដែនភាសុកណ្ណាលយកតម្រាប់តាមរឿងៗមក ។ ដល់មកខាងចុងសតវត្សរ៍ទី ៣ គួរកប់ថា មានគណសង្ឃក្រុះករចំរើនឡើងហើយនៅប្រទេសចិន ។ ក្នុងសតវត្សរ៍តៗមក ព្រះពុទ្ធសាសនាជាសាសនាចំរើនឡើងតាមសម័យនិយម ដែលទុំនៅអស់ ឧឹងសីលធម៌របស់ខុងជឺបែរជាវៀវពេយទៅវិញ ។ នៅប្រទេសចិនខាងត្បូង នៅក្នុងអំណាចគ្រប់គ្រងរបស់ព្រះរាជាធិរាជពួកលាង ដែលតាំងទីក្រុងនៅណង់គាំងចំណែកភាគខាងជើង ព្រះពុទ្ធសាសនាក៏ចំរើនឡើងនោះ

មកពីការជួយឧបត្ថម្ភដោយសទ្ធាជ្រះថ្លារបស់ពួក "ស្តេចកជវង្ស្រី" (ROI DE WEI) ជាកជវង្សរបស់ជាតិមញ្ជូ ដែលបានតាំងទៅក្រុងយ៉ាង ខ្ជាប់ខ្លួននៅស្រុកចាន់-ស៊ី និងហូ-ណាន ។ សេចក្តីចំរើនដែលសាសនាដែលនាំចូលទៅក្នុងស្រុកចិន ចាប់តាំងពីសតវត្សរ៍ទី ៣ មកនោះមិនជាយឺតយូរទេ ដោយការផ្សាភ្ជាប់ខាងលទ្ធិសាសនាជាមួយនឹងប្រទេសឥណ្ឌា ជាដែនស័ក្តិសិទ្ធិរបស់ព្រះពុទ្ធសាសនា ។ គឺជាប្រទេសឥណ្ឌាដែនពុទ្ធសាសនាហ្នឹងឯង បានផ្ញើបញ្ចូលវិញ្ញាណគុណរបស់ខ្លួនទៅក្នុងប្រទេសចិន ។ ហេតុនេះរវាងប្រទេសទាំងពីរក៏រីកចំរើនឡើងក្នុងដែនទ្វីបអាស៊ីដ៏មានទំហំបណ្តោយទទឹងយ៉ាងធំសំបើម, ក្នុងការយឺតយោនគ្នាទៅវិញទៅមក ឲ្យបានចំរើនខាងផ្លូវចិត្តគំនិតនោះ មិនមានទៀតភេទដោះទេឡើយ ។ មិនត្រឹមតែប៉ុណ្ណោះ ថែមទាំងសម្ពន្ធភាពរវាងប្រទេសឥណ្ឌានឹងប្រទេសចុងទ្វីបអាស៊ី ខាងរបៀបចិត្តវិជ្ជាក៏កាន់តែដុះដាលចំរើនឡើងទៀតនឹងខ្ជាប់ខ្លួនឡើងទៀតជាច្រើន ។

— ២ —

នៅខាងចុងឆ្នាំសតវត្សរ៍ទី ៤ នោះ មានពួកលោកសង្ឃចិន ១ ក្រុម នាំគ្នាចេញដើរទៅប្រទេសឥណ្ឌា ដើម្បីស្វែងរកចម្លងគម្ពីរដីកានិងសិក្សាសិក្ខាវិន័យ ក្រោមការត្រួតត្រាពួកគ្រូដែលមានឈ្មោះល្បី

ល្បាញ ៗ ក្នុងចំណោមលោកទាំងនោះ មានលោកសង្ឃ ១ អង្គ ឈ្មោះហ្វា-ហៀន ដែលមានបញ្ញាដ៏មុតមាំ ព្រមទាំងមានចំណេះចេះដឹងអក្សរសាស្ត្រយ៉ាងចំណាប់ ហើយជាអ្នកមានសន្តានចិត្តចេះពិនិត្យការយ៉ាងហ្មត់ចត់ផង ។ ការធ្វើដំណើររបស់លោកហ្វា-ហៀន អស់វេលាជាង ១៥ ឆ្នាំ ទើបត្រឡប់មកស្រុកចិនវិញតាមផ្លូវនាវា ហើយបានចូលសំចតនៅកោះស៊ីឡង់និងកោះជ្វា ដល់ចេញដំណើរតមកដល់ស្រុកចិនទៀត ទើបលិចនាវានៅជិតឈូងសមុទ្រតាន់-ចុង ។ លោកបានរៀបរៀងជាសេចក្ដីរាយការ ១ អំពីពុទ្ធសាសនាដែលលោកបានឃើញទាំងប៉ុន្មាននោះ លោកនេះហើយដែលបើកផ្លូវឲ្យពួកក្រុមអ្នកដំណើរទៅកាន់ចូជនីយដ្ឋានដែលជាជាតិចិន ១ ក្រុមធំ (នាំគ្នាធ្វើដំណើរទៅកាន់ប្រទេសឥណ្ឌាក្នុងកាលតមក) នៅក្នុងចំណោមលោកទាំងនោះ មានលោក ១ រូបឈ្មោះហ្វួន-ឆាង ជាធម្មសាមី ជាអ្នកមានកេរ្តិ៍ឈ្មោះល្បីបំផុត ។

លោកហ្វួន-ឆាង កើតនៅចុងសតវត្សរ៍ទី ៦ ប្រហែលជាក្នុងឆ្នាំ ៥៩៦ ជាប្រាកដ. ក្នុងត្រកូលអ្នកប្រាជ្ញហើយជាពួកមន្ត្រីជាន់ខ្ពស់ ហើយមានចំនួនមន្ត្រីជាច្រើនបានទទួលដំណែងខ្ពស់ ៗ ក្នុងរជ្ជកាលព្រះរាជាធិរាជហានទីងស៊ុំ ។ ឪពុករបស់ហ្វួន-ឆាង ជាមនុស្សស្លូតបូតទៀងត្រង់ណាស់ហើយជាអ្នកប្រាជ្ញផង ។ លោកហ្វួន-ឆាងលះបង់ផ្លូវលោក ហើយចេះដឹងស្ទាត់ជំនាញក្នុងការមើលគម្ពីរ និងបកប្រែសេចក្ដី

ជាទីពាស់ៗផង ។ ហេតុនេះបានជាហួន-ឆាង មាននិស្ស័យសន្តាន ចិត្តលំអៀងទៅខាងសាសនា តាំងពីក្មេងមក (ដូចសន្តានចិត្តរបស់ ឪពុក) ។ លោកមានអាយុមិនទាន់គ្រប់ ១៣ ឆ្នាំផង ក៏បានសុំចូល ទៅស្នាក់នៅវត្តឃាយជីពុទ្ធសាសនា នៅស្រុកលោយ៉ាង ។ លោក នៅទីនោះបានសិក្សាធម៌ដែលត្រូវនឹងសន្តានចិត្តរបស់ខ្លួន គឺលទ្ធិនាម- ធម៌ក្នុងមហាយាន ហើយបិតនៅស្មោះត្រង់ក្នុងលទ្ធិនេះរហូតអស់ ១ ជីវិត ។ ដល់អាយុ ២០ ឆ្នាំ គេទទួលឲ្យទៅនៅក្នុងស្រុកចេង-ទូ ទីក្រុង របស់ខេត្តសេ-ឈួន ដើម្បី "បំពេញសិក្ខាវិន័យ" ។ តាំងពីនោះ មក ក៏មានកេរ្តិ៍ឈ្មោះល្បីល្បាញធំឡើង ។ ការល្បីឈ្មោះនោះ នាំឲ្យជឿថា ក្នុងប៉ុន្មានឆ្នាំដែលលោកហួន-ឆាងបានបួសហើយនោះ គេមិនដែលហៅលោកដទៃក្រៅពីពាក្យថា "ធម្មសាមី" ឡើយ ។ លោកហួន-ឆាងជាអ្នកចេះពិនិត្យពិចារណាយ៉ាងហ្មត់ចត់ ហើយជាអ្នក ស្ទាត់ជំនាញក្នុងភាសាអ្នកស្រុកយ៉ាងពូកែផង លោកមានសិស្សគណ និងសាវកជាចំនួនច្រើន ។ លោកមានចំណេះចេះដឹងមុតមាំខាងវិន័យ, សាស្ត្រា និងព្រះសូត្រទាំងឡាយហើយ ក៏នៅតែមិនទាន់ពេញចិត្ត លោកនៅឡើយ ។ សេចក្តីសង្ស័យផ្សេងៗនោះនាំឲ្យលោកដឹងខ្លួនជា និច្ច ។ លោកចេះដឹងនានាទិដ្ឋិៗ ក្នុងលទ្ធិសាសនាទាំងឡាយ ដែល

លោកបានសិក្សាយ៉ាងជ្រៅជ្រះហើយយល់ថា ដើម្បីនឹងបញ្ចប់បំផុតត្រង់ការយល់ប្លែកៗគ្នានោះ ត្រូវតែលោកសិក្សាដល់ដើមកំណើតនៃលទ្ធិទាំងនោះ នឹងរបៀបការរៀនសូត្រនៅក្នុងប្រទេសដែលជាដើមកំណើតនៃលទ្ធិទាំងនោះផង ។ លោកសម្រេចដាច់ចិត្តថា ត្រូវតែចូលទៅក្នុងប្រទេសឥណ្ឌា ដូចជាលោកធុតង្គឈ្មោះហ្វា-ហៀនធ្លាប់ធ្វើមកហើយកាលពី ២ សតវត្សរ៍មុនលោក ។

កាលពីក្នុងឆ្នាំ ៦២៩ នោះ លោកហួន-ឆាងសម្រេចដាច់ស្រេចថានឹងចូលទៅគាល់ ( ព្រះរាជាធិរាជចិន ) ដើម្បីសុំព្រះរាជានុញ្ញាតធ្វើដំណើរចេញទៅ ។ គ្រានោះ ព្រះរាជាធិរាជដែលគ្រងរាជសម្បត្តិប្រទេសចិន មិនគឺអ្នកដទៃក្រៅអំពីព្រះមហាតៃ-ឈុង ដែលទ្រង់មានជ័យជំនះឈ្នះពួកតួរក៍ ហើយទ្រង់ជាអ្នកតាំងរាជវង្សដ៏រុងរឿងឡើងហៅថា ពួកវង្សតាំង ។ ការទូលសុំអនុញ្ញាតរបស់ភិក្ខុពុទ្ធសាសនាបែរជានាំឲ្យមានការរំខានដល់ទ្រង់ទៅវិញ ទើបទ្រង់ធ្វើយតបដោយចេញជាព្រះរាជបញ្ញត្តិ ១ ហាមប្រាមយ៉ាងដាច់ខាត ។ ឯលោក ហួន-ឆាង គឺមិនមានរួញរាទេ តែលោកលួចខ្លួនចេញទៅនៅក្នុងប្រាសាទមួយតែឯកឯង ហើយចំរើនមេត្តាភាវនាជាវេលាយូរនៅទីនោះ មានពពួកសត្វដែលគេមើលមិនឃើញចោមរោមជុំវិញទាំងយប់ទាំងថ្ងៃ (មានត)

# ច្បាប់ព្រះរាជសំដែង

## បទកាកគតិ

ទើបតែងជាច្បាប់ ខ្ញុំនានមហាគាប់ តែងជានិទាន តាមដោយគន្ធ ព្រេងព្រឹទ្ធបុរាណ ប្រាជ្ញលោកនិពាន ប្រដៅបុត្រា ។ ហៃកូនពន្លក ស្ងួនអើយចាំយក បណ្ដាំបិតា ជំពូកនេះចាស់ ឥតអ្វីឲ្យបា ស្ងួនាអើយរក្សា ពាក្យជំពូកនៅ ។ ឲ្យកូនកុំសត់ រៀនខុនរៀនអត់ រៀនគិតគំនិតជ្រៅ រៀនខុនលំពាន កុំឲ្យការសៅ-ហ្មងដល់ខ្លួនទៅ កើតដល់ជនក ។ ជីនជើយជ្រិតជន កូនសោតវៃឆ្គង-ជ្រិតតែអាពុក ទ្រព្យធន់ជ្រិតស្រី បេះរៀបដាក់ទុក ប្រះដេកឆាប់លក់ ជ្រិតឥតបើគិត ។ ចំណង់ចាំងឡាយ[1] កិច្ចកល់ដោះស្រាយ ជ្រិតតែគំនិត ជីងកិច្ចជីងកល់ ជីងឆ្ងាយជីងជិត ដូចកល់គាំបិត កាប់ក្ដាចំណាយ ។ ល្មមទៅល្មមខាន ល្មមដើរបំពាន កុំគិតត្រង់ឆ្ងាយ ល្មមឈប់បង្អង់ ល្មមខាននៅឆាយ ក្ដីក្រកុំស្រាយ ក្ដីឆាយកុំភ្លេស ។ ស្ងួនដើរកុំដេក ស្ងួនឈប់កុំត្រេក សេចក្ដីប្រហែស ស្ងួនខានកុំពារ ចះចើងចះចេស ស្ងួនចូលកុំចៀស កសរួចសីមន្ទូរ ។ លឿនកុំបំបោល ពាក្យព្រេងកុំចោល ខឹងកុំខ្ញូរ ស្រាយបញ្ចេញឲ្យផាប់ កុំឲ្យទុកយូរ សេចក្ដីនោះធ្ងូរ ខឹងជីងខុសត្រូវ ។ ដេកកុំដំណើប តេក្រកុំសើច តេភ័យកុំព្យាប់ ទោះទីង

---

១. ច្បាប់ខ្វះថា ចំណេះចាំងឡាយ ។

ប៉ុន្មាន ធ្វើបានឲ្យគួរ គឺគិតគិតឲ្យគួរ យូរពេកឲ្យឆាប់ ៗ សេចក្ដីសំរុង ពាក្យដើមពាក្យចុង ប្រកាន់ឲ្យខ្ជាប់ សូវទៀងឯខ្លួន កុំឲ្យបង់ទ្រព្យ សូវបង់ក្ដីអាប់ កុំឲ្យខ្លួនស្លាប់ ។ សូវស្លាប់ទៅជា កុំបង់ធម្មា ភរិយា សីលអាប់ ឲ្យគិតជញ្ជឹង រំពឹងឲ្យសព្វ ពាក្យស្លូនកុំស្អប់ ពាក្យគាប់ឲ្យយក ៗ ពន់ជូនឲ្យទុក(១) ចង់បានក្ដីសុខ ឲ្យស្វែងដើររក ឃើញច្បាប់នមិនផង ឲ្យយកខ្លួនជ្រក ក្ដីសោកមហោក ឲ្យចៀសចេញឆ្ងាយ ៗ កូនអើយលោកិយ នេះឲ្យរៀនក្ដី រៀនច្បាប់ទាំងឡាយ រៀនទាំងសំដី កុំបកយកមាយ ក្ដីក្រក្ដីងាយ ក្ដីគួរក្ដីសម ៗ ទុកូនពុំងា ធម្មតាអ្នកជា រៀនថែរៀនខាំ រៀនដាក់រៀនទុក រៀនរៀបរៀនចំ រៀនរកសន្សំ លក់ចេញទិញចូល ៗ មួយទៀតឯច្បាប់ បើបានមានទ្រព្យ មនុស្សផងមកមូល ពឹងពាក់បានណា បានយកប្រមូល សន្សំផ្សំប្រមូល យកមកជាគ្នា ៗ

កូនអើយឯម្លប់ មនុស្សផងចូលឈប់ សម្រាន្តអាត្មា ព្រោះឈើមានម្លប់ ត្រសុំសាខា ម្ដេចឡើយប្រែជា ក្ដៅជ្រកពុំបាន ៗ មនុស្សផងរម្ងន់ ក្រម្លប់ទៀតហោង ចូលចតសម្រាន្ត ម្លប់នេះត្រជាក់ ត្រសាក់ត្រសៀមក្សាន្ត មនុស្សផងចូលបាន មិនមានហៅអាក ៗ ឧបមាដូចទឹក ជាលជ្រៅពន្លឹក ជាទីសំណាក់ មច្ឆាទាំងឡាយ ចេញ

១ ច្បាប់ខ្លះថា ចង់មានឲ្យទុក ។

ចូលពីងពាក់ ព្រោះទឹកត្រជាក់ មិនមានហ្វូងសៅ ។ ពុំដឹងឡើយឯង ទឹកម្ដេចមកថែ ប្រែទៅជាក្ដៅ មច្ឆាពាំងឡាយ ព្រាត់ព្រាយរត់ទៅ រកទឹកទៀតនៅ សំណាក់គាត្នា ៗ កូនអើយបើហ្នោះ អស្សារកើតឈ្មោះ ត្រូវត្រង់ខ្លួនបា ព្រៀងលានទាំងឡាយ គេនឹងទន្ទា ដំទៀលដៀលថា បាឯងពុំបេះ ៗ ស័ព្ទឥតប្រាជ្ញា ស័ព្ទទាំងឥរិយា ពោលលប់ពេកៈ ស័ព្ទទាំងមារយាទ ស័ព្ទអាំងជម្រិះ ដង្រិតបាឯងនេះ ពុំបេះរក្សា ៗ គួរនាដូចទឹក កូនអើយបើល្អក ពុំមានមច្ឆា គួចមួយឈប់ជ្រក ទៅ កង្គុត្ធា ពុំកប់ហៅថា ប្រែសើរឡើយហោង ៗ មួយសោតអ្នកណា គេមកប្រាប់ថា ដង្រិតបាធ្វើឆ្គង បាតិតជញ្ជីង រំពឹងដើមទង កុំបាន្ដោះ ផ្ដង ផ្ដៀងផ្អូនពុំស្ដាប់ ៗ ទូកហួសកំពង់ កកែវបង្អង់ ថយមកចូល តាប់ ពាក្យលឿនហួសខ្នាត ហៅឥតកំនាប់ ថយមករកគាប់ ពុំបាន ឡើយណា ៗ អង្គុយហួសស័ក្តិ ស្រដីហួសថ្នាក់ ចង់បោយហួសស្នា ពុំមើលប្រមាណ ទឹងប្រាណអាត្មា ហាហួសបង្ក ថាហួសសេចក្ដី ៗ វង្កកក្ដៃ មុខដូចគេពេច ហាឡើងស្រដី អ្នកឯងកំឡាំង ដល់ ទីងដំរី ពោះទាំងកជសើហ៍ កឹសញ្ញមិនខ្វាច ៗ មួយសោតបបក ដក ក្របកអក(១) អ្នកឯងអំណាច ទឹនៃដកប្រើបតី ទៅទាំងទាតកជ ដណ្ដើម

---

១ ច្បាប់ខ្លះថា ឥក្កក្រងក់ ។

យកកព្យ កូម៉ិកពនាគា ៗ រសេត្វអណ្ដើក វារឡើងរើកៗ មកសួត គាត្នា ថាអញនឹងលោត រលេងបព្ជា ហេតុក្ដីមោហា ពុំដឹងខុស នាប់ ៗ រឯគីឆ្គក់ លោតឡើងពីគត់ មើលទៅគួរស្អប់ សួតខ្លួនថាល្អ ដូចមាសទឹកដប់ ពន្លអញចំប្រប់[១] ដូចរាជសីហា ៗ ហាឡើង មិនបាន ស្ដីមិនប្រមាណ នឹងអង្គគាត្នា សូវនៅកុំដើប សូវស្ងៀម កុំថា សូវគេចកុំការ សូវគាប់កុំច្រូស ៗ

ខ្ញុំកូនពន្ធឹក ច្បាប់នេះបាយក សូនកុំប្រហែស ច្បាប់នេះប្រសើរ ហៅមហាពិសេស កូនអោយកុំច្រូស នឹងច្បាប់នេះណា ៗ មួយសោត ឯល្បែង សប្បាយបង់លេង នឹងមានកយា នឹងកើតទុក្ខក្រោយ នឹង បង់ទ្រព្យ នឹងកើតខន្តា ។ បង់មារយាទគាប់ ៗ សប្បាយភ្លើស្រែ បម្រាំជួញប្រែ នោះមានគេពប់ សប្បាយមានធី សប្បាយមានទ្រព្យ សប្បាយនោះគាប់ សប្បាយយ៉ីនយូរ ៗ មួយសោតឯស្រែ បេះលើក បេសប្ដី បេះគិតបេះគួរ បេះរៀបបេះចំ ឲ្យសមនឹងគួរ អ្នកផងនឹង សួរ វកឈ្មោះពុំខាន ៗ នាងនោះឈ្មោះស៊ី មុខមាត់ប្រិមប្រិយ៍ សមជាអ្នកមាន ម្ទោះហើយនឹងកើត ទ្រព្យធនមិនខាន ព្រោះពាក្យ សន្ដាន ព្រៀងលាននគេតាយ ៗ

---

១ ច្បាប់ខ្វះថា រាគអញចំប្រប់ ៗ

៚ រីឯពាក្យមនុស្ស ពុំដែលនឹងខុស ហួសពីទំនាយ ពុំដែលនឹង
ល្អៀង មិនជិតមិនឆ្ងាយ អ្នកផងពាំងឡាយ គួរគិតកុំឆ្គល់ ។ ពាក្យ
ព្រេងលោកថា លោកមានឧបមា ឲ្យគិតឲ្យយល់ ពាក្យលោកទំនឹម
មិនមានឲ្យសល់ កូនអើយកុំឆ្គល់ នឹងពាក្យនេះណា ។ កុំអួតកុំអាង
ដើរកុំមើលកង មើលអន្ធការា កុំដើរផ្ទះគេ ហួសពេលវេលា កុំទៅ
ជានា ទ្រព្យគេពាំងឡាយ ។ កុំដេកផ្កាប់មុខ កុំដើរពានថ្នក ថាឯង
សប្បាយ មានទោសនឹងគេ កុំឲ្យនិយាយ ដើមគេពាំងឡាយ នឹង
កើតទោសធំ ។ ខ្លួនទាបកុំគោង ដៃខ្វីកុំឈោង ប្រាំឧបក្ខ ពាស់
គោងកាន់ប្រែត អ្នកអាងប្រែត ក្រងអួតធ្ងុំ បុំពកយកខ្យល់ ។ ខ្លាក់ផ្ទុះ
កញ្ចក់ ដកកក្រងក់ ហាក់ឯងមើលយល់ ខ្ញុំអួតនឹងផ្ទោះ រលង
លើគល់ ទំពែកគេគល់ ចង់បានប្រែងលាប ។ ក្រដែងបង់កំ ក្រោក
ឡើងទន្ទាំ ងងគោងអាបឡាប ថ្ងង់ចង់ស្តាប់ប្រៀង ផ្គងផ្លៀងទន្ទាប
ខែកូបខ្លួនទាប ចង់ឈោងចាប់ផ្កាយ ។ កូនអើយចូរស្តាប់ ពាក្យនេះ
មហាគាប់ គ្រប់ទាំងពាំងឡាយ បាគិតផញ្ជើង រពឹងឲ្យឆ្ងាយ កុំធ្វើកាយ
មាយ នឹងច្បាប់នេះណា ។ មួយសោតគេប្រាប់ ថាបាពុំគាប់
ទោសដល់គាត្នា កុំបាក្តិតភ្លាំង ស្ទន់ស្ទាំងកាយា ប្រែងប្រាណឥរិយា
ស្មាគ័ឲ្យនឹង ។ រីរគេគំនិត ផុំឃោបល់គិត ទងតាញស្ទឹង ប្រាជ្ញា
មួយគិត ថាឡើងឲ្យជឹង ដម្រិះមួយរឹង ធ្វើហាក់មិនភ្លឹក ។

កូនអើយលោកថា ពាក្យលោកប្រមា ដូចគជសីហ៍សឹក កាំភ្លើងជ័យធំ កុំដែលទីងភ្លឹក ចិញ្ចឹមគតឹក ឥតុកបោលចូល ៗ ធម្មតាអ្នកជា អ្នកមានប្រាជ្ញា សន្តានត្រកូល ឲ្យគិតឲ្យដឹង រំពឹងឲ្យមូល ប្រាជ្ញាមួយចូល បង់ចាំទុកនៅ ៗ កុំអួតកុំអាង កុំក្អួតបំព្រាង កុំឲ្យថែថូវ កុំកាប់កុំកិន រអើរអូវ កុំនាំពាក្យទៅ ប្រាប់ឲ្យកើតទោស ៗ កុំវេះកុំវៀន កុំបៀតកុំបៀន កុំស្តីតោសម៉ោស គ្នាបានជាខុស ឲ្យមានសន្តោស កុំហាឲ្យហួស ផ្តេសពាក្យទៅមុន ៗ ចូលសឹកកុំញោបដំពាក់កុំបោប ខ្វល់កុំបង់ពន្ធ ទីងត្រសាគ្រា កុំឲ្យលោភអន់ សេចក្តីចម្ងន់ សន្សឹមកុំបោល ៗ កុំអួតកំឡាំង កុំអាងខ្លួនខ្លាំង រកនឹងស្រមោល កុំអាងខ្លួនធំ កុំរាយពាក្យពោល ពាក្យព្រេងកុំហោល កុំក្រោលទោសសង្ស ៗ កុំហោលផ្លូវវៀច កុំអាងអំណាច ដើរកាត់ដម្រង់ វង្វែងបង់អរិយា សក្តាពុំគង់ លោកហៅថាល្ងង់ អប្បឥតប្រាជ្ញា ៗ

កូនកើយចូរស្តាប់ ពាក្យនេះឪហាគាប់ មានមិត្រស្នេហា ឲ្យមើលអាយោគ មើលសព្ទកិរិយា ឲ្យដឹងជាក់ជា កាចឬវៀចត្រង់ ៗ ឲ្យសមឲ្យសួន ឲ្យល្មមនឹងខ្លួន ឲ្យជួននឹងគត្ត សំមយកជាមិត្រ ស្និទ្ធស្នេហ៍ដល់ ទៅមកដម្រង់ ចេញចូលចំពុក ៗ មិត្រមួយសោតណា ទៅមកកាន់គ្នា បង់ឲ្យកើតសុខ មិត្រមួយឲ្យទោស បង់ឲ្យកើតទុក្ខ

មិត្រមួយឲ្យទុក ឲ្យបាត់បង់ទ្រព្យ ៗ ទុកកូនពីស៊ី កូនប្រុសកូនស្រី កូនហើយបាស្លាប់ ទំនឹមទំនង គន្ធងផ្លូវច្បាប់ ទុកជាសណ្តាប់ នៃនរជនជាតិ ៗ មួយៈសោតលោកថា បុគ្គលអាត្មា មាន៣ពុំឃាត មួយធីមួយៈដេក មួយដើរជាខ្នាត ធីតកកោរយាទ ពុំត្រូវសណ្តាប់ ៗ ដើរផុតបើគិត ដើរផុតគំនិត ហៅខុសនឹងច្បាប់ ដេកដល់ថ្ងៃរះ ហៅតតគំនាប់ ចង្រៃអភ័ព្វ នឹងជាប់អាត្មា ៗ នឹងស្នេងរកទ្រព្យ ចង្រៃអភ័ព្វ មិនឲ្យជំនា ឲ្យកើតតែទោស នឹងបង់ទ្រព្យា នឹងរក ក៏រហោ ហាក់ដូចគេណាយ ៗ ព្រោះគ្មីអភ័ព្វ ចង្រៃនូវអព-មង្គលទាំងឡាយ ចូលក្នុងអាត្មា មិនមានទៅឆ្ងាយ ជ្រួតជ្រាបក្នុងកាយ ក្នុងអង្គអាត្មា ៗ ទោះប្រុសទោះស្រី បើមានបុគ្គ៣ ដូចច្បាប់លោកថា បុគ្គដើរបុគ្គដេក បុគ្គធីអាហារ ជាអ្នករក្សា ភរិយាមារយាទ ៗ ខ្លាចមេខ្លាចបា ទោះបំពើការ មិនមានឲ្យឃ្លាត ទោះបីនឹងលើក មិនលេងមានខ្នាត ជាអ្នកសង្វាត ខ្មីឃ្មាតធ្វើការ ៗ អ្នកផងទាំងឡាយ ទោះជិតទោះឆ្ងាយ គេយកភរិយា គេយកចំណោះ ជាអ្នកសៀវសា គេចង់បានបា ចងពន្ធជាញាតិ ៗ មានទ្រព្យពុំគិត យកតែគំនិត ភរិយាមារយាទ. យកតែរបៀប របៀបជាខ្នាត សម្រាហ៍សង្វាត រកទ្រព្យា ៗ វង្វាយអាពុក និង

បានលើកមុខ ឲ្យកូនពុំឆា តាំងអស់បងប្អូន ជីដូនជីតា ម្តាយ

មីងនូវមា ហើងស្រលេចូលចិត្ត ។ ដ្បិតកូនសុភាព ជាអ្នកពបទាប

គ្រប់ទីងគំនិត គ្រប់អស់បងប្អូន ទោះឆ្ងាយទោះជិត សរសើរគំនិត

បាននេះឯងណា ។

កូនអើយចូរស្តាប់ ចូរចាំឲ្យខ្ជាប់ ទុកនៅអាត្មា ទំនឹមទំនង

គន្លងឧបមា ព្រះពុទ្ធទេសនា ទូន្មានសត្វលោក ។

ចប់ច្បាប់ព្រះបន្ទូលចែងតែប៉ុណ្ណោះ

ព្រះគ្រូមុនីសោភ័ន សោម-ឡុច ក្រុមជំនុំព្រះត្រៃបិដក

នៅពុទ្ធសាសនបណ្ឌិត្យ រៀបរៀង

# អំពីរបស់ពីរនាំបំផ្លាញរបស់ច្រើន

ក្នុងលោកនេះ មានជនបំពួកខ្លះ ច្រើនប្រកបដោយសេចក្តីលោភ ដែលជ្រុលហួសប្រមាណ ចង់មាន ចង់បានខ្លាំងពេក ឥតគិតមុខគិតក្រោយ ឥតយល់មុខទរណាជាទរណា ឲ្យតែប្រទះដៃត្រង់ណាយកត្រង់ណឹង គិតខាងឲ្យបានតែចំណូលនឹងចំណេញ ត្រង់ចំណាយ ឬក៏វិនាសអន្តរាយចង់ខាតទៅវិញ មិនគិតផងសោះ ជនបែបនេះលោកហៅថា ឆ្អិនក្បាល ស៊ីក្បាល ឆ្អិនកន្ទុយ ស៊ីកន្ទុយ ទំនងយកជាការប្រមាណមិនបាន ។

មួយទៀត ក្នុងត្រៃភព ទោះវត្ថុមានវិញ្ញាណក្តី ឥតវិញ្ញាណក្តី មានរូបក្តី ឥតរូបក្តី សុទ្ធតែមានហេតុមានទំនង ល្មមឲ្យគិតឃើញបានទាំងអស់ ព្រោះរបស់ទាំងនោះសឹងមានជាគូៗ ទំនងគ្នាហូរហែមកជាធម្មតា ដូចពាក្យថា "បុណ្យគូនឹងបាប គុណគូនឹងទោស សុខគូនឹងទុក្ខ ល្អគូនឹងអាក្រក់ បានគូនឹងបង់ឬបាត់ទៅវិញ" រួមខ្លីថា បុណ្យបាប គុណទោស សុខទុក្ខ ល្អអាក្រក់ បានបង់ ឬបាត់ទៅវិញ ប៉ុណ្ណោះជាដើម ។

ជនអ្នកមានបញ្ញា ត្រូវត្រិះរិះគិតរបស់ទាំងនោះ កុំឲ្យជាប់ចិត្ត ដើម្បីការពារកុំឲ្យទុក្ខគ្របសង្កត់ខ្លាំងពេក បើមិនបានគិតទុកជាមុនទេ ដល់ពេលមានគ្រោះថ្នាក់ធ្លាក់មកដល់ខ្លួនម្ដង ៗ ចិត្តរំញាប់ញ័ររន្ធត់តក់ស្លុតស្លន់ស្លោស្រែងស្រៃ អាឡោះអាល័យសោកស្ដាយពេកណាស់ បើបានបុណ្យយសស័ក្ដិជាធំហើយ កុំស្រវឹងស្រវើងភ្លេចខ្លួនពេក ត្រូវគិតដល់បាបកម្មអំពើលាមកណាមួយដែលជាហេតុនាំខ្លួនឲ្យសាបសូន្យទៅវិញផង មានគុណធម៌ល្អក្នុងខ្លួនហើយ ត្រូវគិតដល់ទោសផង បានសុខស្រួលហើយ ត្រូវគិតដល់ទុក្ខផង បានល្អហើយ ត្រូវគិតដល់អាក្រក់ផង រកទ្រព្យសម្បត្តិបានហើយ ត្រូវគិតដល់ការណ៍វិនាសបង់ខាតទៅវិញផង ហេតុបានជាឲ្យគិតដូច្នោះនោះ ព្រោះវត្ថុទាំងមានវិញ្ញាណ ឥតវិញ្ញាណដែលកើតមានក្នុងលោក សុទ្ធតែជារបស់មិនទៀង រមែងផ្អៀងក្រឡាប់ផ្កាប់ចុះចូលមកនៅក្នុងផ្លូវព្រះត្រៃលក្ខណ៍ទាំង ៣ គឺអនិច្ចំ ទុក្ខំ អនត្តា ទាំងអស់ គ្មានសល់ ១ ឡើយ លើកតែឋានព្រះនិព្វានចេញ ក្រៅពីឋានព្រះនិព្វានហើយ កុំសង្ឃឹមថាបានសុខស្រួលល្អនោះ គ្មានទេ តែងតែប្រែប្រួលវិនាសសាបសូន្យទៅវិញជាធម្មតា បើជនណាមិនបានគិតគូររបស់ទាំងនោះទេ ត្រូវរាប់ទៅជាបណ្ដែតបណ្ដោយឲ្យចិត្តជ្រុលលង់ទៅក្នុងអារម្មណ៍ណាមួយហើយ ជននោះឯងមិនអាចនឹងទាញចិត្តឲ្យបានផុតស្រឡះមកវិញឡើយ ត្រូវតាំងចិត្ត

ជាកណ្តាលៈទើបបានល្អ គឺថាកុំស្រឡាញ់ពេក កុំមិនស្រឡាញ់ពេក កុំអរពេក កុំមិនអរពេក កុំសប្បាយពេក កុំមិនសប្បាយពេក ការបើស្រឡាញ់របស់ណាខ្លាំង ទុក្ខក៏ខ្លាំង ស្រឡាញ់យ៉ាងល្មម ទុក្ខក៏ល្មម ស្រឡាញ់បន្តិចបន្តួច ទុក្ខក៏បន្តិចបន្តួច បើមិនស្រឡាញ់សោះ ទុក្ខក៏គ្មានដែរ ។

អធិប្បាយថា: ដូចជាមាតាបិតាស្រឡាញ់បុត្តណាមួយដែលជាទីពេញចិត្ត ស្ទើរតែបាត់ពីមុខមិនបាន វេលាណា បុត្តនោះមានជម្ងឺឈឺចាប់ ស្លាប់បាត់បង់ទៅ ឬមួយក៏ព្រាត់ប្រាសទៅនៅទីណា ៗ បាត់ទៅ ក៏កើតទុក្ខទួញយំសោកស្តាយខ្លាំងពេកណាស់ ១០ឆ្នាំ ២០ឆ្នាំទៀតទៅ ក៏មិនងាយនឹងបាត់ទុក្ខនោះឡើយ នេះហៅថាស្រឡាញ់ខ្លាំង ទុក្ខក៏ខ្លាំង ព្រោះហេតុនោះ បានជាពោលថា ត្រូវឲ្យដំកល់ចិត្តជាកណ្តាល បើមិនដំកល់ចិត្តជាកណ្តាលទេ ពេលណាតែមានគ្រោះថ្នាក់ប៉ះមកដល់ម្តងៗ ក៏កើតទុក្ខយ៉ាងខ្លាំង ដែលរកអ្វីមកប្រៀបផ្ទឹមពុំបាន ដូចស្វានឹងក្រាប់ពោត ។

## អំពីរឿងស្វានឹងក្រាប់ពោត

សូមដំណាលរឿងនោះ ដោយសង្ខេប តាមសេចក្តីក្នុងកា-ឡាយមុដ្ឋជាតក ឯកនិបាតថា "ក្នុងអតីតកាល កាលកន្លងទៅហើយ

គ្រានោះមានស្តេចមួយព្រះអង្គ ទ្រង់ព្រះនាមព្រហ្មទត្ត សោយរាជ្យក្នុងក្រុងពារាណសី ។

វេលានោះ ព្រះពោធិសត្វទៅជាអាមាត្យគាល់បំរើទ្រង់ប្រដៅធម៌ថ្វាយស្តេចនោះ ។ មានកាលសម័យថ្ងៃមួយ ព្រះបាទព្រហ្មទត្តស្តេចលើកពួកពលសេនាយោធាចេញទៅបង្ក្រាបស្រុកដែលនាំបណ្តាលហេតុបះបោរធ្វើជាចោរលួចប្លន់កាប់សម្លាប់ពួកអ្នកស្រុកបច្ចន្តគ្រាម ព្រះពោធិសត្វក៏បានជាប់ទៅជាមួយទ្រង់ស្តេចផងដែរ ពេលនោះ ខែមានភ្លៀងធ្លាក់ពុងធ្លាក់ជោកជាំជោរជន់ ពេញស្ទឹងពេញអូរហៀរហូរសាយលិចទួលតូចធំ ព្រះបាទព្រហ្មទត្តទ្រង់ស្តេចធ្វើព្រះរាជដំណើរទៅ ក៏លំបាកពេកណាស់ ទើបទ្រង់ស្តេចនាំពួកពលនោះទៅឈប់ក្នុងសួនឧទ្យានដើម្បីនឹងប្រជុំពួកពលឲ្យដឹងចំនួនតិចច្រើន ។

ចំណែកខាងពួកទាហានសេះក៏នាំគ្នាស្ងោរគ្រាប់ពោតឆ្អិនស្រួបជួស ស្រង់ដាក់ទៅក្នុងស្នូកដើម្បីឲ្យពួកសេះស៊ី ។ ក្នុងសួនឧទ្យាននោះមានពួកស្វានៅជាច្រើន មានស្វា ១ រិលខ្លួនជាងគេរេះរាំមកដល់ឯចំណី គ្រវៀកមើលទៅឃើញគ្រាប់ពោតស្ងោរឆ្អិន ក៏មានសេចក្តីចង់ស៊ីខ្លាំងពេកណាស់ អត់ទ្រាំមិនបាន ក៏ស្រមតខ្លួនចុះពីដើមឈើទៅលួចគ្រាប់ពោតនោះពមពេញក្នុងមាត់ ហើយក្រសោបចាប់ក្តាប់ពេញ ១ ដៃទាំងពីរថែមទៀត ហើយបោលត្រឡប់ឡើងទៅលើដើមឈើនោះវិញ

ក៏អង្គុយទំពាស៊ីគ្រាប់ពោតនោះ លុះទំពាស៊ីមិនទាន់បានជាប៉ុន្មាន ក៏ស្រាប់តែគ្រាប់ពោត ១ របូតជ្រុះពីដៃម្ខាង ធ្លាក់រហូតដល់ដី ឯស្វាកាឡកណ្ណីក៏មានសេចក្តីស្តាយៈពេកណាស់ ស៊ូខ្ជាក់គ្រាប់ពោតពីមាត់ ទាំងបាចសាចគ្រាប់ពោតពីដៃទាំងពីរចោលចេញអស់ ហើយចុះពីដើមឈើជាប្រញាប់តាមទៅអើតឈ្ងោករកមើលលើផែនដី ក៏រកមិនឃើញ នេះហៅថា សត្វល្ងង់ឥតបញ្ញា សត្វចង្រៃ មិនដែលមាន បានគ្រាប់ពោតពេញមាត់ ពេញដៃ មិនស្តាយ- ត្រឡប់ទៅស្តាយពោត ១ គ្រាប់វិញ ត្រូវនឹងពាក្យចាស់លោកថា "ការប៉ុនក្អម មិនគិត ទៅគិតសព្វ បើស្គរកំប៉ុកមាត់" យ៉ាងណាមិញ ឯស្វាក៏យ៉ាងនោះដែរ ត្រង់គ្រាប់ពោតច្រើនដែលខ្លួនបាចសាចចោលអស់ មិនគិតស្តាយ ទៅគិតស្តាយពោត ១ គ្រាប់ដែលរបូតជ្រុះពីដៃទៅវិញ ក្រុះចំពុះរកតែត្រង់ណេះ ត្រង់ណោះមិនឃើញ ទើបត្រឡប់ឡើងទៅលើដើមឈើវិញ ក៏អង្គុយសំកុកកើតទុក្ខស្ទើរតែនឹងដាច់ខ្យល់ស្លាប់ ។ វេលានោះ ព្រះបាទព្រហ្មទត្តស្តេចទ្រង់ទតអាការឃើញកិរិយាស្វាដូច្នោះហើយ ក៏ទ្រង់ត្រាស់សួរពោធិសត្វថា "ហេតុអ្វីបានជាស្វានោះវាអង្គុយសំកុកកើតទុក្ខខ្លាំងម៉្លេះ"? ពោធិសត្វក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ធម្មតាមនុស្សល្ងង់ឥតបញ្ញា ច្រើនបួលចិត្តសំឡឹងមើលរបស់ណាដែលតិចៗ ត្រង់របស់ដែលច្រើនៗ មិនសំឡឹងមើលសោះ ដូចជាស្វានោះឯង

កុំសំឡឹងមើលតែគ្រាប់ពោត ១ គ្រាប់ត្រង់ពោតច្រើន នៅពេញមាត់ពេញដៃ មិនសំឡឹងមើលទេ ត្រឡប់ជាបោចបោលពេញអស់រលីង ធ្លាក់ទៅកខាងណោះក៏បាត់ ធ្លាក់មកកខាងណេះក៏បាត់ ព្រោះហេតុនោះ បានជាកកើតទុក្ខព្រួយចិត្តខ្លាំងយ៉ាងនេះឯង សូមទ្រង់ព្រះមេត្តាប្រោស ដូចក្នុងពេលនេះ ទឹកនៅក្នុងជោរជន់ខ្លាំងពេកណាស់ មិនងាយនឹងស្រកទៅវិញទេ ព្រោះភ្លៀងធ្លាក់មករាល់ថ្ងៃៗ, បើព្រះករុណាស្ដេចធ្វើព្រះរាជដំណើរទៅបង្ក្រាបត្រូវពេលនេះ អស់ពួកពលមុខជានឹងវិនាសដោយទឹកពុំខាន សូមទ្រង់ព្រះមេត្តាប្រោស ចុះដំណឹងមកថាពួកខ្មាំងសត្រូវនោះតិចដែរទេ ពួកពលឯណេះច្រើនពេកណាស់ សូមព្រះករុណាកុំស្ដេចសំឡឹងមើលទៅរបស់តិច សូមទ្រង់ស្ដេចសំឡឹងមើលមករបស់ច្រើនវិញ ទើបបានសេចក្ដីចំរើនល្អ ។ ស្ដេចបានទ្រង់ព្រះសណ្ដាប់ពាក្យពោធិសត្វនោះហើយ ក៏ស្ដេចទ្រង់អនុវត្តតាម ហើយនាំពួកពលត្រឡប់ចូលមកក្នុងក្រុងវិញ ។ ចំណែកខាងពួកខ្មាំងសត្រូវកាលដែលឮថាស្ដេចលើកពួកពលទៅ ក៏មានសេចក្ដីភ័យភិតខ្លាចអំណាចបារមីនៃស្ដេចនោះពេកណាស់ ទើបនាំគ្នារត់ចូលទៅក្នុងព្រៃបាត់អស់ទៅ" ។

ចប់ កាទុក្ខយមុន្តិជាតក ប៉ុណ្ណេះ ។

(មានត)

# ការប្រជុំលោកមេគណ និងអនុគណ

ក្នុងថ្ងៃ សុក្រ ១០ កើត និងសៅរ៍ ១១ កើត ខែកត្តិក ឆ្នាំវកឆស័ក ព.ស. ២៤៨៧

ត្រូវនឹងថ្ងៃ ១០ និង ១១ ណូវែម្ប្រ៍ ១៩៤៤

(ប្រជុំក្នុងវិហារវត្តសារាវ័ន ឃុំលេខ ៣ ក្រុងភ្នំពេញ)

## ការប្រជុំលើកទី ១

ថ្ងៃសុក្រ ១០ កើត ខែកត្តិក ឆ្នាំវកឆស័ក ព.ស. ២៤៨៧ ត្រូវនឹងថ្ងៃ ១០ ខែណូវែម្ប្រ៍ ឆ្នាំ ១៩៤៤ សម្តេចព្រះមហាសុមេធាធិបតី (ព្រាក់--ហ៊ិន) សង្ឃនាយកគណៈមហានិកាយ បាននិមន្តអស់លោកជាគណៈព្រមទាំងលោកចៅអធិការវត្តគណៈមហានិកាយក្នុងក្រុងភ្នំពេញ និងលោកមេគណ - អនុគណជាច្រើនដែលមកពីខេត្តក្រៅ មកប្រជុំព្រមនៅក្នុងវិហារវត្តសារាវ័ន ក្រុងភ្នំពេញ (ជាវត្តលំនៅរបស់សម្តេចព្រះសង្ឃនាយក) ។

វេលាម៉ោង ១៥ គឺម៉ោង ៣ រសៀល លោកឧកញ៉ាឧត្តមមហាសេនា (អ៊ិន-អ៊ី) សេនាបតីក្រសួងព្រះបរមរាជវាំង ព្រះឃ្លាំង និងធម្មការ បានអញ្ជើញទៅកាន់ទីប្រជុំនោះដែរ មានព្រះពិភក្តិធម្មការ (តុង-ហាន់) នាយកមន្ទីរក្រសួងធម្មការទៅជាមួយផង ។ លោកឧកញ៉ាឧត្តមមហាសេនាបានសំដែងសេចក្តីគោរពព្រះពុទ្ធរូបរួចទើបគោរពចំពោះសម្តេចព្រះសង្ឃនាយក និងអស់លោកព្រះថេរានុត្ថេរៈទាំងឡាយតាមលំដាប់រួចហើយ មានប្រសាសន៍សួរចំពោះទៅលោកមេគណនិងអនុគណ

ទាំងអស់ អំពីការដែលទាំងអស់បានទទួលព្រះរាជក្រមលេខ ១៦៦ និងព្រះសង្ឃប្រកាសលេខ ១៦២ ហើយគឺអស់លោកគ្រូមេគណ, អនុគណ និងអស់លោកចៅអធិការព្រមទាំងភិក្ខុសាមណេរគ្រប់វត្តបាន ទទួលប្រតិបត្តិតាមដោយសេចក្តីព្រមព្រៀង ឥតមានបព្វជិតណារឹង ទទឹងដោយហេតុណាមួយទេឡើយ។- លោកមេគណនិងអនុគណទាំងអស់ ឆ្លើយជំរាបថា ... ឥតមានរឹងទទឹងទេ ... ។ លោកអ្នកឧកញ៉ាអគ្គ-មហាសេនាបានមានប្រសាសន៍ ពន្យល់តាមដំណើរកិច្ចការយ៉ាង សង្ខេបដោយវាចាដ៏សុភាពគួរជាទីពេញចិត្ត លុះព្រះថេរានុត្ថេរៈទាំង អស់នោះស្តាប់យល់បានដោយងាយ ។

បន្ទាប់ពីនោះមក សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយក មានថេរវាចាចំពោះទៅព្រះថេរានុត្ថេរៈ មេគណ អនុគណ ទាំងអស់ បញ្ជាក់ហើយបញ្ញត្តឲ្យអស់លោកមេគណនិងអនុគណទាំងអស់ប្រតិបត្តិ តាមព្រះរាជក្រមលេខ ១៦៦ និងព្រះសង្ឃប្រកាសលេខ ១៦២ កុំបីធ្វេស ប្រហែស កាលបើវិលត្រឡប់ពីក្រុងភ្នំពេញទៅវិញ ត្រូវពន្យល់លោក ចៅអធិការគ្រប់វត្តដែលនៅក្នុងខេត្ត របស់ខ្លួនឲ្យបានយល់ដោយសព្វ គ្រប់ កុំឲ្យមានសន្ទេះសង្ស័យដោយហេតុណាមួយ ទាំងត្រូវឲ្យប្រតិបត្តិ តាមកុំឲ្យរឹងទទឹង ... ។ សម្តេចព្រះសង្ឃនាយកមានថេរវាចាតទៅ ទៀតថា ក្នុងវេលាប្រជុំនេះ ខ្ញុំត្រូវការនិយាយដាស់តឿនក្រើនរំលឹក

អស់លោកកល់អគ្គ អំពីវត្តប្រតិបត្តិខ្លះដែលខ្ញុំយល់ឃើញថាមានប្រ-
យោជន៍ ត្រូវតែបព្វជិតកល់រូបប្រព្រឹត្តកាន់ឲ្យបានត្រឹមត្រូវតាមវិន័យ
ទីឯខាងតំបូង, ប៉ុន្តែខ្ញុំតម្រូវឲ្យលោកព្រះពោធិវង្សនិយាយជាជំនួសខ្ញុំ
តាមខសេចក្តីដែលខ្ញុំរៀនឲ្យកត់ត្រាទុកហើយជាស្រេច ។ លុះសម្តេច
មានបវរកថាដូច្នេះរួចហើយ បានចាត់ឲ្យព្រះសាក្យវង្ស (វែន-ប៊ុល)
សូត្រសេចក្តីព្រះរាជក្រមទី៥ព្រះសង្ឃប្រកាស ឲ្យព្រះថេរានុត្ថេរៈទាំង
អស់ស្តាប់១ចប់ រួចហើយសម្តេចប្រគល់ភារៈឲ្យព្រះពោធិវង្ស (ជួន-
ណាត). និយាយសេចក្តីជាសំនៀនវត្តជាតំណាងព្រះអគ្គលោក ។
ព្រះពោធិវង្សទទួលថេរបញ្ជាសម្តេចហើយ ក៏ថ្លែងសេចក្តីតាមខទាំង១៧
ដែលសម្តេចបានឲ្យកត់ត្រា ត្រាំតែជាគោលៗនោះ និយាយពង្រីក
សេចក្តីតាមដំណើរវត្តប្រតិបត្តិ ដែលមានក្នុងគម្ពីរវិន័យព្រះពុទ្ធសាសនា
ឲ្យពិស្តារបន្តិចឡើងល្មមស្តាប់បានងាយយល់ ដូចមានពាក្យជាគោលៗ
រៀងៗតទៅនេះ:

១- ត្រូវឲ្យយកចិត្តទុកដាក់ខំប្រឹងរៀនសូត្រ, ត្រូវដាស់តឿនប៉ុន
ប្រៀនប្រដៅសិស្សគណឲ្យខំប្រឹងរៀន អក្សរសាស្ត្រតាមសម័យនិយម
ឲ្យសមនឹងសេចក្តីទុកបំរុងរបស់រាជការ កុំចំពាស់ កុំរឹងទទឹង, ត្រូវ
ណែនាំបង្ហាត់ឲ្យសិស្សគណ ប្រឹងប្រែងរៀនធម៌វិន័យព្រះពុទ្ធសាសនា កុំ
ធ្វេសប្រហែស កុំបណ្តែតបណ្តោយឲ្យល្ងង់ខ្លៅ, បួសហើយត្រូវតែខំ

ប្រឹងរៀន បើមិនរៀនធ្វើម្ដេចនឹងចេះ? គួរបំពេញកិច្ចស្រាប់អ្នកបួស ឲ្យល្មមដល់ការទំនុកបំរុងរបស់ពួកគ្រហស្ថដែលគេគោរពយើង:... ។

២- ត្រូវឲ្យមានអភិសមាចារិកវត្ត ăp'ĭsămacharĭkăvĕat គឺឲ្យមាន វៃបបទសណ្ដាប់ធ្នាប់ល្អ, ត្រូវស្លៀកដណ្ដប់ឃ្លុំត្រងស្បង់ចីពរឲ្យត្រឹមត្រូវតាមច្បាប់វិន័យ កុំឲ្យរយីករយាកខ្ជីខ្ជា, ត្រូវឲ្យមានសេចក្ដីគោរពគ្នាតាមចាស់តាមក្មេង, ត្រូវប្រព្រឹត្តការទំឲ្យទៀងទាត់តាមច្បាប់ក្នុងវិន័យវត្តក្ខន្ធក: Vĕatŭăkk'ănt'ĕakă, ត្រូវឲ្យមានការសង្រួមឥន្ទ្រិយឲ្យស្រគត់ស្រគំតាមច្បាប់វិន័យ :.. ។

---

៣- កិច្ចត្រូវសំរាប់សំដែងអាបត្តិ តាមកាលដែលគួរសំដែងកាលបើមានកំហុស ពោះបើបន្តិចបន្តួច ត្រូវពិតត្រូវបដ្ឋាយ៍ អាចារ្យឬគ្រប់កិច្ចផងគ្នាឲ្យបានដឹង កុំលាក់បិទបាំងទោសរបស់ខ្លួនឲ្យសង្ឃកើតមានសេចក្ដីរង្កៀសកុំឲ្យសមគំនិតគ្នាប្រព្រឹត្តធ្វើអំពើអាក្រក់; ត្រូវឲ្យមានសាមគ្គីសេស្មោះស្មើគ្នាតាមច្បាប់ធម្មវិន័យជានិច្ច ។

៤.- ក្នុងវត្តនិមួយៗ, ដល់ថ្ងៃឧបោសថ (ក្នុង ១ ខែ ៤ ដង), ត្រូវប្រជុំគ្នាធ្វើឧបោសថកម្ម កុំខានឲ្យសោះ បើមានកិច្ចធុរៈផ្ទាល់ខ្លួន ត្រូវប្រាប់ជំនុំសង្ឃក្នុងវត្តឲ្យដឹង ។ ក្នុងវត្តមួយៗបើវត្តតូច ត្រូវឲ្យមានភិក្ខុអាចចេះសូត្របាដិមោក្ខបាលីមាត់ទទេ យ៉ាងតិចណាស់ឲ្យបាន ៣ រូប (គ្រាន់នឹងសូត្រផ្លាស់គ្នាម្ដងៗ), គួរតែលោកទៅអធិការនិងលោក

ត្រូវចេះសូត្របាលីបាដិមោក្ខមាត់ទទេ ទើបសមគួរដល់ឋានៈជាគ្រូគ្រប់គ្រងវត្តនីមួយៗ ។ ភិក្ខុទាំងអស់ គួរតែឲ្យដឹងសេចក្ដីគ្រប់សិក្ខាបទទាំង ២២៧ ក្នុងបាដិមោក្ខ ព្រោះជាសិក្ខាបទសម្រាប់ភិក្ខុ, បើមិនដឹងសេចក្ដី ធ្វើម្ដេចនឹងរក្សាសិក្ខាបទទាំង ២២៧ នោះកើត . . . . . ។

៥.- ត្រូវបញ្ញត្តហាមប្រាមឲ្យយ៉ាងតឹង កុំឲ្យភិក្ខុ-សាមណេរដើរលេងឬដើរមើលដើរក្នុងទីតំបន់ដែលពុំគួរដើរទៅ ដូចយ៉ាងទីផ្សារ ផ្សារជាដើម វៀរលែងតែការវេលាពិសេស គឺវេលាណាដែលមានចំនងគួរទៅមួយផង មួយការដែលនឹងខានទៅសោះពុំបាន ។

៦.-ត្រូវបញ្ញត្តហាមប្រាមឲ្យយ៉ាងតឹង កុំឲ្យភិក្ខុ-សាមណេរមានសេចក្ដីប្រកួតប្រកាន់គ្នា បើមានហេតុប៉ះប៉ាក់អាក់អន់ចិត្តនឹងគ្នាបន្តិចបន្តួច ត្រូវលោកដែលជាអ្នកគ្រប់គ្រង រម្ងាប់ហេតុទាំងនោះឲ្យបានស្ងប់ស្ងាត់បាត់ភ្លាមៗទៅ ទើបសាមគ្គីធម៌អាចនឹងកើតមានជានិច្ចបាន ។ ព្រោះភិក្ខុ-សាមណេរដែលនៅវត្តផ្សេងពីគ្នាក៏ដោយ តាំងដើមតាំងពីថ្ងៃនេះតរៀងទៅ ត្រូវតែមានសាមគ្គីធម៌ស្មោះស្ម័គ្រស្រឡាញ់រាក់ទាក់គ្នាជាដរាប ។ ក្នុងវត្តមួយៗត្រូវប្រឹក្សាទៅអធិការចាត់ការប្រជុំសង្ឃឲ្យរឿយៗ ដើម្បីពិគ្រោះគ្នាពីធម្មវិន័យព្រះពុទ្ធសាសនា ។

៧.- បើមានភិក្ខុណាមួយជាមនុស្សប្រព្រឹត្តអនាចារ Anachar សង្ឃស្ដីប្រដៅមិនស្ដាប់ កំហុសនោះក៏មិនទាន់ដល់ថ្នាក់គួរផ្សឹកទេ គួរ

ត្រឹមតែបញ្ជាជនីយកម្ម គឺគួរដល់ការបណ្ដេញចេញ ហើយសង្ឃបានបណ្ដេញចេញពីវត្តម្ដងទៅហើយ លោកចៅអធិការវត្តឯទៀតមិនត្រូវទទួលភិក្ខុអាក្រក់នោះឲ្យនៅក្នុងវត្តរបស់ខ្លួនឡើយ ដើម្បីឲ្យភិក្ខុអាក្រក់នោះគ្មានទីលំនៅហើយ ទើបពេញចិត្តសឹកលែងធ្វើជាអ្នកបួសតទៅទៀត ។ ឯការទទួលភិក្ខុ-សាមណេរឲ្យនៅនោះ បើលុះតែមានលិខិតព្រមទាំងសំបុត្របរិសុទ្ធិកាន់មកជាសំគាល់នោះ ទើបគួរទទួលឲ្យនៅបាន, បើមិនដូច្នោះទេ មិនត្រូវទទួលឲ្យនៅឡើយ ។

ការប្រជុំនៅថ្ងៃសុក្រ ១០ ណូវែម្ប្រ៍ ១៩៤៤ បានតែត្រឹមខទី ៧ នេះ ដល់វេលាល្ងាចឈប់ ក៏បញ្ឈប់ការ ១ លើកត្រឹមប៉ុណ្ណោះសិនទុកឱកាសចាំដល់វេលារសៀលថ្ងៃស្អែកទើបប្រជុំម្ដងទៀត ។

## ការប្រជុំលើកទី ៣

ថ្ងៃសៅរ៍ ១១ ណូវែម្ប្រ៍ ១៩៤៤ វេលាម៉ោង ១៥ បានប្រជុំម្ដងទៀត (ដូចថ្ងៃទី ១) ក្នុងឱកាសនោះ លោកអ្នកឧកញ៉ាអគ្គមហាសេនាក៏បានអញ្ជើញមកកាន់ទីសន្និបាតនោះទៀតដែរ ។ វេលាម៉ោង ១៧ និង ៤៥ នាទី ព្រះពោធិវង្សបានថ្លែងសេចក្ដីត្រឹមខទី ៨ រៀងទៅ ដូចមានតទៅនេះ :

៨.- នៅគង់វត្តតែមួយជាមួយគ្នា, បើមានគេឲ្យសាមណេរដែលនៅជាសិស្សលោកចៅអធិការឬលោកគ្រូសូត្រ ឬបើវត្តធំ ទោះនៅជាសិស្សលោកគ្រូគុណាមួយក៏ដោយ, កាលបើសិស្សនោះ មានវិវាទទាស់ទែងនឹងគ្រូរបស់ខ្លួន ឬមាតាបិតារបស់សិស្សនោះទាស់អារម្មណ៍គ្នានឹងលោកជាគ្រូរបស់ខ្លួនខ្លួននោះ ដោយហេតុណាមួយ ហើយសិស្សនោះពុំសុខចិត្តនៅនឹងគ្រូដើម ថែរដោយតាំសុំនៅគង់សំណាក់លោកគ្រូណាមួយគង់វត្តជាមួយនោះវិញ, កាលបើដូច្នេះមិនត្រូវលោកគ្រូណាមួយហាមទទួលឲ្យសិស្សនោះនៅឡើយ; ត្រូវលោកចៅអធិការនឹងលោកគ្រូសូត្រនិយាយផ្សះផ្សាសម្រុះសម្រួលយ៉ាងណាឲ្យគ្រាតែបានសុខចិត្តសះជានឹងគ្នាដូចដើមវិញ ។

៩.- តែងតែមានខ្លះមកហើយ, គង់វត្តមួយជាមួយគ្នា, លោកគ្រូឬគ្រូមិនត្រូវអធ្យាស្រ័យគ្នានឹងលោកចៅអធិការ មិនព្រមយកលោកចៅអធិការនោះធ្វើជាឧបជ្ឈាយ៍បំបួសសិស្សរបស់ខ្លួន គឺនាំយកសិស្សនោះទៅបំបួសឯវត្តដទៃ ហើយនាំយកសិស្សនោះមកឲ្យនៅគង់វត្តខ្លួននោះវិញ សិស្សនោះមិនទទួលស្គាល់បង្គាប់លោកចៅអធិការ; ដូច្នេះមិនត្រូវទេ ត្រូវហាមផ្ដាច់កុំឲ្យមានកិរិយាយ៉ាងនេះតទៅទៀត ។ ការបំបួសកុលបុត្រនេះ ត្រូវតែបញ្ញត្តិបើតឲ្យយ៉ាងតឹង កុំឲ្យខុសអំពីច្បាប់វិន័យបព្វជ្ជាខន្ធក: Bäj pëachhea K'ânt'ëak ទឹងកជបញ្ញត្តិ ។

១០ — លោកមេគណនិងអនុគណ ត្រូវយកចិត្តទុកដាក់ ចាត់ការត្រួតត្រាឲ្យម៉ឺងម៉ាត់ ទៅលើវត្តទាំងប៉ុន្មានដែលនៅក្រោមបង្គាប់ខ្លួន កុំបណ្តែតបណ្តោយឲ្យមានអធិករណ៍កើតឡើងរឿយៗ, បើមានអធិករណ៍ណាមួយកើតឡើង ត្រូវបញ្ចប់រម្ងាប់អធិករណ៍នោះឲ្យស្ងប់ភ្លាមៗ ទៅ កុំឲ្យមានការប៉ះពាល់ដល់ពុទ្ធសាសនាគណបក្ស វៀរលែងតែហេតុឬអធិករណ៍ណាមួយធំធំ ដែលទាក់ទងដោយច្បាប់គណបក្ស ហើយបើបញ្ចប់ពុំអាចនឹងរម្ងាប់បាន ។

១១.- ត្រូវហាមប្រាមឲ្យលោកចៅអធិការគ្រប់វត្តបេះថែរក្សា របស់ជាគរុភណ្ឌផ្សេងៗ ដែលជាវត្ថុសម្រាប់វត្តមួយៗ កុំឲ្យវិនាសអន្តរាយ ដោយហេតុធ្វេសប្រហែស, ត្រូវមានបញ្ជីកត់ត្រា របស់សម្រាប់វត្តឲ្យទៀងទាត់, ត្រូវប្រើប្រាស់វត្ថុជាគរុភណ្ឌកុំឲ្យឥតសណ្តាប់ធ្នាប់ កុំឲ្យរដាត់រទាំង កុំឲ្យខុសអំពីច្បាប់វិន័យសេនាសនក្ខន្ធកៈ Senasănăk-k'ănt'ĕakă ជាដើម ។

១២.- ត្រូវហាមប្រាមកុំឲ្យភិក្ខុ-សាមណេរលក់ដូររបស់ដែលមានទំនងខុសនឹងវិន័យបញ្ញត្តិ, កុំឲ្យជាវរបស់ដែលពុំគួរទិញ ដូចយ៉ាងរបស់ចោរជាដើម កុំឲ្យប្រកបកិច្ចការធ្វើរបស់លក់ដូរដូចគ្រហស្ថ, កុំឲ្យចិញ្ចឹមសត្វពាហនៈខុសទំនងពីវិន័យបញ្ញត្តិ ។

១៣.- ត្រូវហាមប្រាមឃាំងមិនអោយ កុំឲ្យភិក្ខុ-សាមណេរ ទទួលបញ្ញើរបស់គ្រហស្ថ ទុកដាក់ថែរក្សាក្នុងកុដិលំនៅ កុំឲ្យហាមបំបាត់មុខពន្ធព្រះរាជធានី មានការលើកលែងការបំបាំងមុខពន្ធនៃព្រៃព្រឹក្សាជាដើម ។

១៤.- កាលណាបើមានកិច្ចការអ្វីមួយដែលត្រូវប្រស្រ័យទាក់ទងនឹង-- ការគណៈចក្រ ត្រូវចាត់គណៈចារ្យសម្រាប់វត្តឲ្យទៅជួបឬឲ្យទៅនិយាយការជំនួស មិនត្រូវចេញដើរទៅដោយខ្លួនឯងទេ វៀរលែងតែការធម្មតា ដែលមិនទាស់ខុសនឹងបញ្ញត្តិ ។

១៥.- ត្រូវហាមប្រាមកុំឲ្យភិក្ខុ-សាមណេរផ្ញើសំបុត្រស្នេហាទៅវិញទៅមកនឹងគ្នា ដោយសំបុត្រនោះនាំឲ្យសេចក្តីទាស់ខុសនឹងច្បាប់បញ្ញត្តិ ។

១៦.- ត្រូវឲ្យលោកចៅអធិការគ្រប់វត្តយកចិត្តទុកដាក់ចាត់ការសំអាតវត្តអារាមមានវិហារជាដើមឲ្យស្អាតជានិច្ច កុំបណ្តែតបណ្តោយឲ្យទីវត្តមិនស្អាតមិនរុងរឿង, ត្រូវចាត់ការរៀបចំទីវត្តទាំងមូលឲ្យមានរបៀបរៀបរយល្អ ឲ្យត្រូវបែបបទតាមច្បាប់សុខាភិបាលព្រមទាំងរបៀបដែលគួរជាទីពេញចិត្តកើតសេចក្តីជ្រះថ្លានៃជននានាជាតិ ឲ្យសមនឹងពាក្យដែលហៅថា "អារាម" ឬ "វត្តអារាម" ដែលប្រែថា "សួន-ច្បារ" ឬថា "វត្តជាទីរីករាយសប្បាយនៃមហាជន" ។

១៧. – មានលោកចៅអធិការទីដ៏លោកគ្រូសូត្រខ្លះ ខំប្រឹងរៀនសូត្រព្រមទាំងប្រព្រឹត្តប្រតិបត្តិកាន់តាមលំអានធម៌វិន័យនិងច្បាប់បញ្ញត្តិ ចំណេះបានតែខ្លួនមួយប៉ុណ្ណោះ បណ្ដែតបណ្ដោយឲ្យភិក្ខុ-សាមណេរ ដែលនៅក្នុងវត្តខ្លួនខ្ជិលច្រអូស ប្រព្រឹត្តខ្ជីខ្ជាតាមតែបាន ឥតសណ្ដាប់ធ្នាប់ ចង់ធ្វើអ្វី បេះតែធ្វើទៅតាមអំពើចិត្ត ៗ ការបណ្ដែតបណ្ដោយនោះតើយ៉ាងនេះ ចូលក្នុងដំណើរធ្វេសប្រហែស ចូលក្នុងបទល្មើសច្បាប់ ចូលក្នុងបទស៊ីគ្រលុក, មិនប្រសើរទេ មិនពេញនាទីជាអ្នកគ្រប់គ្រងសិស្សគណទេ ៗ ត្រូវលោកមេគណទីដ៏អនុគណទាំងអស់រំឭកដាស់តឿនឲ្យបោះបង់កិរិយាដូច្នោះចេញ ៗ

លុះព្រះពោធិវ័ង្សថ្លែងសេចក្ដីដាស់តឿនក្រើនរំឭកទាំងនេះចប់ហើយ, សម្ដេចព្រះមហាសុមេធាធិបតីសង្ឃនាយក មានថេរដីកាបញ្ជាក់ថែមទៀតថា សេចក្ដីដែលលោកព្រះពោធិវ័ង្សនិយាយមកហើយនេះ គឺនិយាយតាមកំណត់កត់ត្រាដែលខ្ញុំជាសង្ឃនាយកបានចាត់ឲ្យរៀបរៀងទុកពីថ្ងៃមុនគ្រាន់តែឲ្យគេជាគោលៗ (រៀងតាមលំដាប់លេខពីខទី ១ ដល់ខទី ១៧) ចំពោះពីគំនិតយល់ឃើញរបស់ខ្ញុំ, ត្រូវលោកមេគណអនុគណនិងចៅអធិការទាំងអស់ប្រតិបត្តិតាម, កាលបើអស់លោកបានប្រតិបត្តិកាន់តាមហើយ ខ្ញុំសូមប្រគេនពរដល់អស់លោក សូមឲ្យអស់

លោកបានប្រកបដោយពរ ៤ ប្រការ គឺ អាយុ, វណ្ណៈ, សុខៈ, ពលៈ, ayŭ vĕanna, sŏk'ă, pĕalĕa, ព្រមទាំងឲ្យមានសេចក្ដីលូតលាស់ចំរើនកន្លុំមិវិទ័យព្រះពុទ្ធសាសនាតវៃងឆ្ងាយទៅ! ព្រះថេរានុត្ថេរៈទាំងអស់ក៏ទទួលថេរ៉ាកាសម្ដេចថា សាធុ! ព្រមគ្នា ៗ

លំដាប់បន្ទាប់ពីនោះមក សម្ដេចព្រះមហាសុមេធាធិបតី សង្ឃនាយកនឹងព្រះសង្ឃទាំងអស់ក្នុងទីប្រជុំនោះ បានតាំងសច្ចាធិដ្ឋានផ្សាយព្រះរាជកុសលថ្វាយចំពោះព្រះករុណាជាម្ចាស់ជីវិត ព្រះបាទសម្ដេចព្រះនរោត្តម-សីហនុ វរ្ម័ន ធម្មិកមហារាជាធិរាជ ព្រះចៅក្រុងកម្ពុជាធិបតី ព្រមទាំងជូនកុសលចំពោះលោក ហ្សង់-ដឺគូ ឡឺតូវេរណ័រហ្សេណេរ៉ាល់ប្រទេសឥណ្ឌូស៊ីន និងលោក ហ្សក-គោបេរ ឡឺរេស៊ីដង់សុបេរីយើរប្រទេសខ្មែរ សូមព្រះករុណាជាម្ចាស់ជីវិតនិងលោក ឥស្សរាធិបតីទាំង ២ បានប្រកបដោយសេចក្ដីចំរើននិងសុវត្ថិភាពគ្រប់ប្រការ!

តមកទៀត បានប្រកាសសេចក្ដីសច្ចាធិដ្ឋានសំបូងសន្និងសូមឲ្យមហានគរបារាំងសែសបាននូវស្រឡះពាក់គ្រោះថ្នាក់ទុក្ខភ័យ, សូមឲ្យបានលូតលាស់ចំរើនដោយឆាប់រហ័សរួសរាន់ទាន់សម័យ! សូមឲ្យសហរដ្ឋឥណ្ឌូស៊ីន បានសេចក្ដីសុខក្សេមក្សាន្ត! សូមឲ្យកម្ពុជរដ្ឋរួចផុតពាក់គ្រោះថ្នាក់ភ័យអន្តរាយ កុំបីប្រឡះប៉ះពាល់ឧបសគ្គណាមួយឡើយ!

បន្ទាប់មកទៀត ព្រះសង្ឃទាំងអស់បានជូនពរចំពោះលោកអ្នកឧកញ៉ា អគ្គមហាសេនា (អ៊ិន-អ៊ី) ថា សូមឲ្យលោកបានប្រកបដោយសិរីសួស្តីទាំង ៤ ប្រការគឺៈ អាយុ, វណ្ណៈ, សុខៈ, ពលៈ!

បន្ទាប់ពីនោះមកទៀត ព្រះសង្ឃទាំងអស់បានសូត្រធម៌ ជយន្តោ chĕayĕantô បំរើនសិរីសួស្តីជយមង្គលតាមទំនៀមទំលាប់នៃពុទ្ធសាសនិកជន ។

ជាស្រេចនៃការប្រជុំទាំង ២ លើកតែប៉ុណ្ណោះ ។

---

សម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយក ។

ហត្ថលេខាៈ ប៉ាក់-ហ៊ិន

## ព្រះរាជាគណៈជាក្រុមជំនុំ

ព្រះពោធិវង្ស
ហត្ថលេខាៈ ជួន-ណាត

ព្រះអរិយវង្ស
ហត្ថលេខាៈ អ៊ិត-គុប

ព្រះមហាវិមលធម្ម
ហត្ថលេខាៈ ហួត-តាត

ព្រះសមាធិធម្ម
ហត្ថលេខាៈ អ៊ុំ-ស៊ូ

ព្រះធម្មឃោសាចារ្យ
ហត្ថលេខាៈ មឿង

ព្រះញាណសំវរ
ហត្ថលេខាៈ ផន់ គុយ

ព្រះសាក្យវង្ស                ព្រះធម្មវង្ស

ហត្ថលេខា: ខែម-ប៊ុល        ហត្ថលេខា: ពៅ-ហ៊ិន

ព្រះពុទ្ធវង្ស

ហត្ថលេខា: ឈុន

ព្រះវន្ទមុនី

ហត្ថលេខា: ពៅ-នេត

បានចំឡងត្រឹមត្រូវហើយ

ព្រះពិតក្កធម្មការ ។

## អរិយសច្ចជាពុទ្ធភាសិត

លោកគ្រូអាចារ្យ ប៉ាំង-ខាត់ ស្រង់ប្រែចេញពីបាលីព្រះត្រៃបិដក

## កថាមុខ

ព្រះពុទ្ធសាសនាទាំងមូល មានចតុរារិយសច្ចជាកំពូល, ធម៌គ្រប់យ៉ាង សុទ្ធតែសង្គ្រោះរួមចុះក្នុងចតុរារិយសច្ចទាំងអស់, សេចក្តីប្រតិបត្តិគ្រប់បែបដែលមានប្រាកដក្នុងគម្ពីរទាំងឡាយ ក៏តែងមានឡើងដើម្បីសេចក្តីចេះដឹងអរិយសច្ចដោយប្រាជ្ញា ។ កាលណាបុគ្គលចេះដឹងអរិយសច្ចដោយប្រាជ្ញាដល់ទីបំផុតហើយ បុគ្គលនោះក៏ដោះរួចចាកអាសវៈ បានជាអ្នកធ្វើទីបំផុតនៃសេចក្តីទុក្ខឲ្យប្រាកដបាន ហើយរួចចាកសេចក្តីទុក្ខយ៉ាងដាច់ខាត មិនត្រឡប់កើតមានសេចក្តីទុក្ខតទៅទៀត ព្រោះចិត្តរួចស្រឡះចាកសភាវធម៌ដែលធ្លាប់ប្រកាន់ស្អិតមតយូរយារហើយ ។ អរិយសច្ចជាកំពូលធម៌ ការចេះដឹងអរិយសច្ច ជាកំពូលនៃព្រហ្មចរិយៈ ការប្រព្រឹត្តដើម្បីឲ្យត្រាស់ដឹងអរិយសច្ចដោយប្រាជ្ញា ជាកំពូលនៃការប្រព្រឹត្តទាំងមូល ។

ពាក្យថា "អរិយសច្ច" ប្រែថា សេចក្តីពិតដ៏ប្រសើរ, ជាសេចក្តីពិតដែលមិនចេះប្រែប្រួល ជាសេចក្តីពិតដែលធ្វើអ្នកចេះដឹងឲ្យរួចស្រឡះចាកទុក្ខបាន ។ ឯសេចក្តីពិតនោះមានសេចក្តីសំគាល់ច្រើន

ប្រការ សេចក្ដីពិតបែបខ្លះ ដូចលោកនេះមានព្រះអាទិត្យរះឡើង ឬ មានថ្ងៃមានយប់ សេចក្ដីពិតនេះមិនទៀងទាត់ឋិតថេរទេ ជួនកាលយុគខ្លះអាចផ្លាស់ប្ដូរទៅជាបែបដទៃ ៗ ដោយប្រព្រឹត្តកន្លងទៅនៃកាលវែង ៗ សេចក្ដីពិតដទៃ ៗ ក្រៅពីអរិយសច្ច ជាសេចក្ដីពិតដោយសន្មតនៃលោក សូម្បីសេចក្ដីពិតដែលអ្នកវិទ្យាសាស្ត្រខាងវិត្តកន៍បច្ចុប្បន្ន-កាលគេរកឃើញឡើងបាន ក៏សុទ្ធតែជាសេចក្ដីពិតដែលនៅក្រោមអំណាចសេចក្ដីទុក្ខនៃវដ្តសង្សារ ៗ ចំណែកសេចក្ដីពិតគឺអរិយសច្ចនោះ មិនផ្លាស់ប្ដូរគ្រប់យុគគ្រប់កាលនៃលោក ជាធម្មជាតិត្រូវនឹងជីវិតដែលស្វះស្វែងរកសេចក្ដីសុខជាក់ខ្លួន ហើយមិនមានផ្លូវដទៃដែលនាំឲ្យបានសមតាមសេចក្ដីប្រាថ្នា ក្រៅពីការស្វែងរកសេចក្ដីពិតនេះទេ, លក្ខណៈទាំងអស់នេះឈ្មោះថា " សេចក្ដីពិតដ៏ប្រសើរ " ៗ

ក្នុងលោកនេះ ឬ លោកឯណា ៗ រាប់ចំនួនដោយពាន់នៃលោកក៏ដោយ មិនមានអ្វីឲ្យប្រសើរជាង សេចក្ដីរួចចាកទុក្ខ" ៗ ការរួចចាកសេចក្ដីទុក្ខបាន ក៏ព្រោះដឹងសេចក្ដីពិតដ៏ប្រសើរ គឺដឹងរូបទុក្ខ រូបហេតុដែលនាំឲ្យកើតទុក្ខ រូបធម៌ដែលរលត់ហេតុនៃទុក្ខ នឹងរូបវិធីដែលនាំឲ្យរលត់ហេតុនៃសេចក្ដីទុក្ខ ៗ ធម៌ទាំង ៤ ប្រការនេះហៅថា "ចតុរារិយសច្ច" ដែលព្រះពុទ្ធជាម្ចាស់គ្រប់ព្រះអង្គ មិនទ្រង់ប្រាប់ក្ដីដែលប្រសើរក្រៃលែងជាងសេចក្ដីពិត ៤ ប្រការនេះឡើយ ហើយសត្វ

គ្រប់រូប មិនមានការដឹងសេចក្ដីពិតស៊ីជម្រៅ ទៀតក្រៃលែងជាងសេចក្ដីពិតនេះទៅទៀតទេ ។

ដោយហេតុដូចបានពោលមកនេះ ខ្ញុំយល់ឃើញថា អរិយសច្ចជាវិជ្ជាដែលត្រូវសិក្សា សម្រាប់ជាសម្បត្តិប្រចាំជីវិត ប្រសើរជាងការបេះដឹងអ្វីៗដទៃទាំងអស់ ដែលគ្រាន់តែជាការលលួងឲ្យជីវិតកើតកើនទៅក្នុងមួយថ្ងៃៗទទេប៉ុណ្ណោះ ។ មែនពិត, សេចក្ដីពិតគឺអរិយសច្ចនោះមានតែមួយគឺ "ការរួចទុក្ខ" ដោយការរលត់តណ្ហាដែលជាហេតុនៃទុក្ខចេញបានដោយមជ្ឈិមាបដិបទា, តែថាពាក្យអធិប្បាយរបស់សេចក្ដីពិតទាំងអស់នេះ មានចរិកសេចក្ដីដែលជាប់ទាក់ទងគ្នាទៅវិញទៅមកជាច្រើនដើម្បីឲ្យដឹងសេចក្ដីពិតដ៏ត្រឹមត្រូវ ហើយល្អិតល្អន់ច្បាស់លាស់ ។ ដើម្បីឲ្យសម្រេចប្រយោជន៍ទាំងអស់នេះ ខ្ញុំទើបព្យាយាមរួបរួមអរិយ-សច្ចចំពោះព្រះពុទ្ធភាសិត ដែលទ្រង់ត្រាស់ដោយព្រះអង្គឯង ឬពាក្យជាបរិករផ្សេងៗ ចេញពីគម្ពីរព្រះត្រៃបិដក ដែលជាគួបាលីសុទ្ធ ពាស់ជានគត្តីឯទៀតទាំងអស់ បើអ្នករៀនត្រូវការពាក្យអធិប្បាយដើងភាសាឬបរិយាយសេចក្ដីផ្សេងៗ អាចស្វះស្វែងទៅរកក្នុងគម្ពីរនោះៗដោយខ្លួនឯងបានដោយស្រួល ។

សូមខ្ញុំបានតាំងចិត្តចាប់ធ្វើការនេះមកយូរហើយ ដោយសេចក្ដីប្រយ័ត្នប្រយែងយ៉ាងម៉ឺងម៉ាត់ ក៏គង់នឹងមានការភ្លាំងភ្លាត់ខ្លះមិនខាន

ដោយសតិបញ្ញាខ្ញុំមិនគ្រប់គ្រាន់ ។ ជាបើមាន ខ្ញុំសូមគាំងសុភាសិតមួយបទថា "ការភ្លាំងភ្លាត់ជាធម្មតារបស់អ្នកសរសេរ ការទៀតភ័យជាធម្មតារបស់អ្នកមើល" ប៉ុណ្ណោះក៏ចប់ ។

ខ្ញុំមានសេចក្ដីបំណងយ៉ាងធំថា បើអស់លោកទាំងឡាយបានមើលធម៌អរិយសច្ចនេះហើយ សូមជួយស្វះស្វែងរកសេចក្ដីពិតក្នុងរឿងនេះមកសរសេរថែមទៀតឲ្យបានរឿងនេះសម្បូណ៌ក្រៃលែងតរៀងទៅរហូតទាល់តែឲ្យការបែបនេះដល់ទីបំផុតបាន ។

សម្រាប់ពុទ្ធភាសិតដែលទ្រង់ត្រាស់ដល់រឿងនេះ ដែលមានប្រាកដនៅក្នុងគម្ពីរព្រះត្រៃបិដក ខ្ញុំបានរួបរួមចងក្រង បានរៀបរៀងរឿងនិយាយសុទ្ធតែសេចក្ដីដែលទាក់ទងដោយចតុរារិយសច្ច ដូចតទៅនេះ:

១– ទុក្ខអរិយសច្ច សេចក្ដីពិតដ៏ប្រសើរគឺទុក្ខ ។

២– សមុទយអរិយសច្ច សេចក្ដីពិតដ៏ប្រសើរគឺហេតុប្រជុំកើតឡើងនៃទុក្ខ ។

៣– និរោធអរិយសច្ច សេចក្ដីពិតដ៏ប្រសើរគឺធម៌ជាគ្រឿងរលត់ទុក្ខ ។

៤. មគ្គអរិយសច្ច សេចក្ដីពិតដ៏ប្រសើរគឺសេចក្ដីប្រតិបត្តិជាដំណើរទៅកាន់ទីរលត់ទុក្ខ ។

អរិយសច្ចទាំង ៤ ប្រការនេះ ចែកជា ៥ បទគឺ ១– សត្វលោកនឹងចតុរារិយសច្ច ២– ជីវិតមនុស្សនឹងចតុរារិយសច្ច ៣– ព្រះពុទ្ធ-

អត្ថទីបនទុក្ខអរិយសច្ច ៤- ការត្រាស់ដឹងអរិយសច្ចមិនមែនជាការផុតវិស័យ ៥- ប្រភេទអរិយសច្ច ។

ក្នុងទីនេះ ខ្ញុំពេញចិត្តនិយាយសុទ្ធតែអរិយសច្ចដែលជាពុទ្ធភាសិតតីប្រែត្រង់តាមគម្ពីរបាលី បើមានតួអក្សរប្លែកគ្នា គឺជាសេចក្ដីរបស់ខ្ញុំ ជាអ្នកសរសេរ គឺត្រង់សេចក្ដីណាមួយដែលខ្ញុំពន្យល់ដើម្បីឲ្យជាប់គ្នាជាសេចក្ដីប៉ុណ្ណោះ ហើយខ្ញុំឲ្យឈ្មោះសៀវភៅនេះថា "អរិយសច្ចជាពុទ្ធភាសិតឬអរិយសច្ចតថាគត" មួយទៀតខ្ញុំយល់ឃើញថាសំនួនភាសាឬមួយរបៀបប្រយោគដែលមាននៅក្នុងព្រះត្រៃបិដក មិនមែនជាពុទ្ធភាសិតដែលទ្រង់ត្រាស់ទេសនាបែបជាប្រយោគដូច្នេះៗទេ ឯដែលហៅថាពុទ្ធវចនៈ សំដៅយកត្រង់តែសេចក្ដីដែលទ្រង់ត្រាស់ទេសនាប៉ុណ្ណោះឯង ហេតុនោះដែលខ្ញុំថា "អរិយសច្ចជាពុទ្ធភាសិតឬអរិយសច្ចតថាគត" នោះ ចំពោះតែរូបសេចក្ដីដែលព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ទេសនាហើយខ្ញុំមិនបានផ្លាស់ប្ដូរទៅយ៉ាងណាឡើយ ខ្ញុំទុកឲ្យនៅតាមសភាពដើមទាំងអស់ ។

សូមឧទ្ទិសកុសលដែលកើតអំពីការផ្សាយធម៌នេះ ជាបដិបត្តិបូជាចំពោះព្រះដ៏មានព្រះភាគ អស់កាលទាំងពួងហោង ។

វត្តប្រាង្គណ៍ថ្ងៃអង្គារ ៧ រោចខែភទ្របទ ឆ្នាំមមែបញ្ចស័ក ព. ស. ២៤៨៦ ត្រូវនឹង
ថ្ងៃ ២៨ សេបតេមប្រ៍ ឆ្នាំ ១៩៤៣ ភិក្ខុ ប៉ំ. ខាត់ (មហាខត)

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ ហ្លួងនិពន្ធមន្ត្រី ញុក-ថែម, បណ្ឌិត នៅពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនាៈ ព្រះគ្រូបញ្ញាលិង្គិត កៅ-ស៊ុម អ្នកគ្រួតត្រាសិស្ស នៅសាលាបាលីជាន់ខ្ពស់

## បញ្ជីរឿង

ទំព័រ

### ផ្នែកអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ . . . . . ព្រះរាជប្រវត្តិសម្ដេចព្រះរាជអយ្យកោ នរោត្តម-សុទ្ធារស . . . . . . . . . . ៥៣

ហ្លួងនិពន្ធមន្ត្រី ញុក-ថែម . . . . រឿងរ៉ាវរបស់លោកធុតង្គជាតិចិន ១រូបឈ្មោះ ហួន-ឆាង ស្រង់ប្រែពីសៀវភៅ Religieux et pèlerins en terre d'Asie (តមក) . . . . . . . . ៦៨

ឃុនបញ្ញាសោភ័ន គាំ-ឌុម . . . ពតិមាន ថ្លែងសេចក្ដីកាលទៅនាំយកព្រះពុទ្ធរូបនឹងបល្ល័ង្ក នៅអង្គរបូរី ស្រុកព្រៃកប្បាស (តាកែវ) (តមក) . . . . . . ៧៩

ព្រះគ្រូមុនីសោភ័ន សោម-ឡុប នានាភាសិត (តមកនិងចប់) . . . . . . ៩៤

### ផ្នែកសាសនា

ឃុនបណ្ណានុរក្ស ប៊ូ-ប៊ូ . . . . . ប្រវត្តិព្រះពុទ្ធ ៣ ព្រះអង្គ . . . . . . . . ១០០

លោកគ្រូអាចារ្យ ប៉ាង-ខាត់ . . . . អរិយសច្ច ជាពុទ្ធភាសិត (តមក) . . . . ១០៤

# KĂMPŬCHĔASŎRĬYA

Revue religieuse et littéraire éditée par l'Institut Bouddhiqu
Rédacteur en chef de la partie littéraire : Luong Nibandhamantr
NHOK-THÊM, Pandit à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Preah kru Pannalikhit
KAO-SIM, Surveillant général de l'École Supérieure de Pāli.

## TABLE DES MATIÈRES

**Partie littéraire**:



| | | Pag |
|---|---|---|
| Institut Bouddhique . . | Biographie de S. A. R. le Sămdech Prĕah Reach ayyakŏ Norodom Sottharoth . . . . . . . . . . | 57 |
| Luong Nĭponmontrei Nhok-Thêm. . . . . . | Récit du pèlerin chinois Hiuen-tsang ( extrait de *Religieux et Pèlerins en Terre d'Asie*)(suite) | 68 |
| K'ŭn Panhnha sŏp'ĕan Kam-Doum . . . . . | Rapport sur le transfert des statues de Bouddha d'Angkorborei (Takév) à Phnôm-Penh (suite) | 79 |
| Prĕah kru mŭnisŏp'ĕan Sŏm-Loch. . . . . . | Neaneap'casăt (suite et fin). . . . | 94 |



**Partie religieuse**:



| | | |
|---|---|---|
| K'un Pannanŭrak Bou Po | Biographie des sept Bouddhas passés . . . . . . . . . . . . | 100 |
| Vén. Achar Pāng-Khat. . | Ariyasaccā - Buddhabhāsitā (suite) | 104 |



17e Année — N° 2. Février 1945 — Abonnement: un an 15$00.

ព្រះរាជប្រវត្តិ

សម្តេចព្រះរាជអយ្យកោ វរក្សត្រិយ៍ នរោត្តម-សុរាមរិត

កុម្មង់ដ័រ ដឺឡាលេស្យុងដូណ្ណេរ ក្រុងបារាំងសេស

មហាសិរីវឌ្ឍ ក្រុងកម្ពុជាធិបតី

សម្តេចព្រះរាជអយ្យកោ ព្រះអង្គនេះ ជាព្រះរាជបុត្រព្រះបាទ សម្តេចព្រះនរោត្តមបរមរាមទេវាវតារ ព្រះចៅក្រុងកម្ពុជាធិបតីនឹងចៅ ចមមាតាអៀម-ពុម្ព ។ ទ្រង់ព្រះប្រសូតនៅថ្ងៃសុក្រមួយកើតខែ អស្សុជ ឆ្នាំវកចត្វាស័ក ពុទ្ធសករាជ ២៤១៥ ត្រូវគ្នានឹងថ្ងៃ ១៨ អុកតូប្រ៍ ឆ្នាំ ១៨៧២ វេលាម៉ោង ១ ជាងអធ្រាត្រ នៅក្នុងព្រះបរមរាជវាំង ចតុមុខ ក្រុងភ្នំពេញនេះ ។

សម្តេចព្រះវររាជបិតា ជាម្ចាស់ជីវិតលើត្បូង ទ្រង់ប្រោស ឲ្យធ្វើព្រះរាជពិធីចំរើនព្រះកេសាកំណើត នៅថ្ងៃ ៨ កើតខែមិគសិរក្នុង ឆ្នាំនោះឯង មានព្រះនាមក្នុងព្រះសុវណ្ណបដ ហារិកនឹងដែលមានថា "ព្រះរាជបុត្រាព្រះអង្គម្ចាស់ សុរាមរិត" ។ លុះព្រះជន្មបាន ៦ វស្សា ព្រះបាទសម្តេចជាម្ចាស់ជីវិតលើត្បូងព្រះវររាជបិតា ត្រាស់ឲ្យចៅ ឃុនព្រះបរមស្រីកញ្ញាដែលជាបាទបរិចារិកា ព្រះបាទសម្តេចព្រះ ករុណាព្រះបរមកោដ្ឋឲ្យទទួលព្រះអង្គមកបីបាច់រក្សា ទ្រង់ស្តេចមកគង់ នឹងចៅឃុនព្រះបរមស្រីកញ្ញា នៅវាំងកែវព្រះភ្លើង នៅថ្ងៃ ១ កើត ខែបុស្ស ឆ្នាំខាលនពស័ក ព.ស. ២៤២០ ចៅឃុនបានឲ្យទ្រង់រៀន

អក្សរខ្មែរ ព្រះជន្មបាន ៩ ព្រះវស្សា ទ្រង់ចេះអក្សរកាត់សរសេរកើតល្អ ប្រើការបាន ។ លុះព្រះជន្មបាន ១១ ព្រះវស្សា មានព្រះរាជពិធីសោកន្ត នៅថ្ងៃ ១៥ រោចខែផល្គុន ឆ្នាំមមីចត្វាស័ក ព.ស. ២៤២៥ ។

កាលព្រះជន្មបាន ១២ ព្រះវស្សា ព្រះបាទសម្តេចអម្ចាស់ជីវិតលើត្បូង ជាព្រះវររាជបិតា ត្រាស់ប្រើឲ្យទ្រង់ព្រាយលាជ ក្នុងក្បួនហែព្រះសពសម្តេចព្រះអនុជភាព ជាព្រះរាជមាតាសម្តេចម្ចាស់ហ្វា-បន្ទុះអគ្គ ។

កាលព្រះជន្មបាន ១៣ ព្រះវស្សា ទ្រង់បានចូលទៅថ្វាយព្រះអង្គជាសិស្សសម្តេចព្រះសុគន្ធាធិបតី "ប៉ាន" ជាសង្ឃនាយកគណៈធម្មយុត្តិ មានសម្តេចព្រះមង្គលទេពាចារ្យ អៀម កាលនៅជាព្រះគ្រូ ជាអ្នកបីបាច់ថែរក្សាបង្រៀនពុទ្ធសាសនធម៌ និងស្រាបអក្សរ ។

កាលព្រះជន្មបាន ១៥ ព្រះវស្សា មានព្រះរាជពិធីខាន់នាគបព្វជ្ជា ទ្រង់ព្រះផ្នួសជាសាមណេរ នៅថ្ងៃ ១៥ កើតខែអាសាឍ ឆ្នាំចអដ្ឋស័ក ព.ស. ២៤២៩ បានទ្រង់រៀនព្រះត្រៃបិដកនឹងសម្តេចព្រះសុគន្ធាធិបតី ជាឧបជ្ឈាចារ្យ ទ្រង់ព្រះផ្នួសគង់នៅវត្តបទុមវតីរាជវរារាម បាន ១ ព្រះវស្សា ទ្រង់លាចាកសិក្ខាបទនៅខែបុស្សឆ្នាំនោះ ។

កាលទ្រង់លាចាកព្រះផ្នួសមក ព្រះករុណាមានព្រះរាជឱង្ការត្រាស់ឲ្យទ្រង់សិក្សាសិល្បវិទ្យាក្នុងក្រុមកងទាហានសេះ ហើយទ្រង់

បានតាមហែស្ដេចព្រះរាជដំណើរទៅស្រុកព្រៃនគរ ដោយវិធីផលមាតិ ជាច្រើនផង ។

លុះព្រះជន្មបាន ២១ ព្រះវស្សា បានព្រះរាជពិធីទ្រង់ឧបស-ម្បទជាភិក្ខុភាវៈក្នុងព្រះពុទ្ធសាសនា ក្នុងព្រះវិហារវត្តបទុមវតីរាជវរារាម មានសម្ដេចព្រះសុគន្ធាធិបតីជាព្រះឧបជ្ឈាយ៍ មានសម្ដេចព្រះមង្គល-ទេពាចារ្យ អៀម (កាលនៅជាព្រះរាជាគណៈ) ជាកម្មវាចា ទ្រង់ព្រះផ្នួស នៅថ្ងៃ ១៤ កើតខែអាសាឍ ឆ្នាំរោងចត្វាស័ក ព.ស. ២៤៣៥ ។ ទ្រង់សិក្សាធម្មវិន័យបាន២ វស្សា ទ្រង់លាចាកសិក្ខានៅថ្ងៃ ១០ កើត ខែកត្តិក ឆ្នាំម្សាញ់បញ្ចស័ក ព.ស. ២៤៣៦ ។

លុះព្រះជន្មបាន ២៣ ព្រះវស្សា ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ជាព្រះវររាជបិតា ទ្រង់ព្រះមេត្តាប្រោសព្រះរាជទានទឹកសច្ចារ៉ា-ហមង្គលម៉ងព្រះអង្គម្ចាស់ជាព្រះរាជបុត្រី ហើយជាព្រះរាជបុត្រីនៃចៅពញាមាតាសុជាតបុប្ផា ព្រះស្នំឯក ជាព្រះជាយា នៅខែអាសាឍ ឆ្នាំមមែសស័ក ព.ស. ២៤៣៧ ត្រូវនឹងឆ្នាំ ១៨៩៤ ។

កាលនៅថ្ងៃ ១៣ ហ្វេវ្រីយេឆ្នាំ ១៨៩៧ បានទ្រង់ព្រះករុណាប្រោសព្រះរាជទានគ្រឿងឥស្សរិយយសឈ្មោះអូប៊ុស៊ីយេ ឌឺម៉េ-ដៃយមាសនៃក្រុងកម្ពុជា ។ ក្នុងរដូវកាលនោះ បានត្រាស់ប្រើឲ្យថ្វាយទៀនព្រះវស្សា ផ្កាពុម្ព ខ្ទុំព្រះកឋិនតាមព្រះអារាមហ្លួងរាល់ឆ្នាំ ។

លុះមកដល់ថ្ងៃអាទិត្យ ១០ កើតខែពិសាខឆ្នាំរោងឆស័ក ព.ស. ២៤៤៧ វេលាម៉ោង ១៧ និង ៥ មិនុត ត្រូវនឹងថ្ងៃ ២៤ ខែអាព្រិល ឆ្នាំ ១៩០៤ ។ ព្រះបាទសម្ដេចអម្ចាស់ជីវិតលើត្បូង ជាព្រះវររាជបិតា ទ្រង់សោយព្រះទិវង្គត ដោយព្រះរោគជរាភាព ព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ ឡើងគ្រងរាជសម្បត្តិស្នងព្រះបរមជេដ្ឋាធិរាជ បានទ្រង់រាប់អានព្រះអង្គតាមទំនៀមព្រះបរមរាជវង្សានុវង្ស ។

កាលនៅថ្ងៃ ៤ ខែណូវែម្ប៊្រ ឆ្នាំ ១៩០៤ មានការកេតលោកឡឺរេស៊ីដង់ស៊ុបេរីយើរ តាំងព្រះអង្គជាក្រុមកុំមីស្យុងពិនិត្យនាទីដី ក្នុងក្រុងភ្នំពេញ មានម៉ុងស៊ីយើហាន់ រេស៊ីដង់មែរជាប្រេស៊ីដង់ ។

កាលនៅថ្ងៃ ២៤ ដេសំប្រ៊ឆ្នាំ ១៩០៤ ព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ ទ្រង់គ្រងរាជសម្បត្តិថ្មី បានត្រាស់ប្រើព្រះអង្គជាព្រះរាជអាជ្ញាទៅស្រុកក្រាត ជាមួយនឹងម៉ុងស៊ីយើរម៉ូរ៉េល រេស៊ីដង់ស៊ុបេរីយើរ ទៅទទួលខែត្រដែនអំពីរាជការសៀម មកជាខបខណ្ឌសីមានៃក្រុងកម្ពុជាធិបតី ក្នុងខណៈនោះ បានទ្រង់ព្រះករុណាប្រោស ព្រះរាជទានគ្រឿងឥស្សរិយយសឈ្មោះក្រង់អូហ្វីស៊ីយេរ របស់ក្រុងកម្ពុជា ។

កាលនៅថ្ងៃ ១ ខែមេឆ្នាំ ១៩០៥ មានការកើតរាជការប្រតិកតូប៉័រតាំងឲ្យទ្រង់ធ្វើក្រុមកុំមីស្យុង ជំនុំអំពីសេចក្ដីដែលនឹងបង្កើតសាលា

រៀន បង្រៀនវិជ្ជាផ្សេងៗ ឲ្យចំរើនក្នុងក្រុងកម្ពុជា មានដុកទ័រឌុរសេ ជាប្រេសុីដង់ ។

កាលនៅថ្ងៃ ៣ ខែសេបតមប្រ៍ឆ្នាំ ១៩០៥ មានអារ៉េតតាំងឲ្យទ្រង់ធ្វើជាក្រុមកុម្ម៉ីស្យុងតែងច្បាប់ខ្មែរ មានម៉ុងស៊ីយើរស្វេ អ័ដមីនីស្ត្រាទ័រ ជាប្រេសុីដង់ ។

កាលនៅថ្ងៃ ២៧ ខែអាវ្រីលឆ្នាំ ១៩០៦ ប្រេសិតគូប៉ាក់បានថ្វាយគ្រឿងឥស្សរិយយស ឈ្មោះអូហ្វីស៊ីយេរ ក្រាកុងដ័ណាម ។ ព្រះបាទសម្តេចព្រះសុីសុវត្ថិ ព្រះចៅក្រុងកម្ពុជា បានទ្រង់ព្រះរាជទានគ្រឿងឥស្សរិយយសឈ្មោះមុនីសុភករណៈ ។

កាលនៅថ្ងៃ ៧ ខែមេឆ្នាំ ១៩០៦ មានអារ៉េតអំពីប្រេសិតគូប៉ាក់ តាំងឲ្យទ្រង់ធ្វើជាប្រេសុីដង់ ដ៏ដេលេគេនៃក្រុងកម្ពុជា ស្តេចទៅបុណ្យអិកស្ប៉ូស៊ីយុង ស្រុកម៉ាសេ ប្រទេសបារាំងសែស ហើយបានស្តេចយាងទៅក្រុងប៉ារីសផង ។ ខណៈដែលស្តេចទៅដល់ ទ្រង់បានទទួលគ្រឿងឥស្សរិយយសឈ្មោះម៉ៃដេសិរីសុវត្ថិ អំពីព្រះចៅក្រុងកម្ពុជាធិបតី បានទទួលគ្រឿងឥស្សរិយយសអំពីរដ្ឋបាលបារាំងសែស ឈ្មោះអូហ្វីស៊ីយេរមេរិតអាគ្រីកុល ១ មេដៃយកុម្មេមូរទីវ ១ ទ្រង់គង់នៅក្រុងបារាំងសែស ៤០ ថ្ងៃ ស្តេចវិលមកក្រុងកម្ពុជាវិញ ។

ទ្រង់បានបង្កើតរោងរៀនកុមារ ១ ធ្វើនៅខាងជើងជិតកំពង់ដែលទ្រង់គង់ រោងរៀននេះម៉ុងស៊ីយើរអ៊ុត្រេស៊ីដង់សុប៉េរីយើរ និងម៉ុងស៊ីយើរក្លូឡា រេស៊ីដង់ម៉ែរ និងម៉ុងស៊ីយើរមូលីយេរ អាំងស្ប៉ិកទ័រជួយយកចិត្តឈើផ្កាលម្អឲ្យបន្ទប់ដោយក្រៃពេក កាលនៅវេលាដែលឆ្លងរោងរៀននោះសោត មានម៉ុងស៊ីយើរសារ៉ូ គូវែរណ័រហ្សេណេរ៉ាល់និងម៉ុងស៊ីយើរអ៊ុត្រេស៊ីដង់សុប៉េរីយើរជាប្រធាន ចូលសេនាបតីមន្ត្រីបារាំង-ខ្មែរទាំងឡាយបានប្រជុំសន្និបាត ម៉ុងស៊ីយើរឡឺគូវែរណ័រហ្សេណេរ៉ាល់ បានថ្លែងសុន្ទរកថៈជាអនេកប្រការ ។

កាលនៅថ្ងៃ ១២ ខែសីហា ឆ្នាំ ១៩០៦ ទ្រង់បានស្តេចទៅស្រុកបារាំងដោយផ្លូវកជការ ទៅទទួលគ្រឿងឥស្សរិយយសៈឈ្មោះស៊ីក-លិយេដឺឡាលេស្យុងដូណ្ណ័រ អំពីលោកឡឺគូវែរណ័រហ្សេណេរ៉ាល់ ហើយទ្រង់បានកុម្ម៉ង់ឌ័រ ប្រទេសជប៉ុនផង ។

កាលឆ្នាំ ១៩១៦ ទ្រង់បានស្តេចទៅទន្លេធំ ៣ ជើង ក្នុងកិច្ចការជ-ការរើសមនុស្ស ដែលស្ម័គ្រចិត្តទៅជួយក្នុងការសង្គ្រាមប្រទេសបារាំង-សែស បានមនុស្សជាង ៤០០ នាក់ ។

កាលឆ្នាំ ១៩១៧ ទ្រង់បានទទួលគ្រឿងឥស្សរិយយស ឈ្មោះអូហ្វីស៊ីយេដឺឡាលេស្យុងដូណ្ណ័រ ក្នុងបារាំងសែសតមកទៀត ទ្រង់បានធ្វើជាក្រុមជំនុំក្នុងព្រះរាជបណ្ណាល័យ ហើយរដ្ឋបាលបានតាំងឲ្យ

ទ្រង់ធ្វើជាក្រុមជំនុំឲ្យជនានុជនដែលមានចំណេះវិជ្ជាធ្វើតរៀងៗ នាំគ្នានោះមកប្រឹងតាំងតាមកាល ។

លុះមកដល់ឆ្នាំថោះនព្វស័ក ព. ស. ២៤៧០ ត្រូវនឹង គ. ស. ១៩០៧ ព្រះបាទសម្តេចព្រះស៊ីសុវត្ថិ ព្រះចៅក្រុងកម្ពុជាធិបតី ទ្រង់សោយព្រះទិវង្គត សម្តេចព្រះកែវហ៊ុមុនីវង្សជាព្រះរាជបុត្រឡើងគ្រងរាជសម្បត្តិស្នងព្រះរាជបិតាអម្ចាស់ផែនដីៗ ក្នុងនេះ ទ្រង់បានព្រះរាជទានគ្រឿងឥស្សរិយយសៈឈ្មោះក្រង់ក្បាខៃក្រុងកម្ពុជា ។

កាលនៅថ្ងៃ ៣០ យ៉ុងវិយេឆ្នាំ ១៩២៨ ទ្រង់បានទទួលគ្រឿងឥស្សរិយយសឈ្មោះ កុម្មង់ឌរដឺឡាលេស្យុងដូណ័រអំពីរដ្ឋបាលក្រុងបារាំងសែស ។

លុះមកដល់ថ្ងៃអាទិត្យ ១២ កេតខែស្រាពណ៍ឆ្នាំម្សាញ់ឯកស័ក ព. ស. ២៤៧២ ត្រូវនឹងថ្ងៃ ១ សេបតមប្រ៍ ១៩២៩ មានព្រះរាជ-ប្រកាសឲ្យទ្រង់ឡើងព្រះយសជាសម្តេចក្រុមព្រះវរចក្រណារិទ្ធិ អធិបតីក្រុមសង្ឃហៈព្រះបរមរាជវាំងខុះង្ស ហើយទ្រង់បានកុម្មង់ដ៍រស្រុកហ្លួងព្រះបាង អំពីព្រះចៅស៊ីសាវ៉ាងវង្ស ដែលទ្រង់បានផ្ញើមកថ្វាយ ។

លុះមកដល់ថ្ងៃពុធ ៣ កើតខែពិសាខ ព. ស. ២៤៧៣ ត្រូវនឹងថ្ងៃ ៣០ ខែអាព្រិលឆ្នាំ ១៩៣០ មានអាររេតតាំងឲ្យទ្រង់ធ្វើជាអធិបតីពុទ្ធសាសនបណ្ឌិត្យ ។

លុះមកដល់ជំនាន់បច្ចុប្បន្ននេះ ទ្រង់បានឡើងព្រះយសយ៉ាងខ្ពង់ខ្ពស់បំផុត ជាសម្តេចព្រះរាជអយ្យកោវររាជក្រណរិទ្ធ (នរោត្តម-សុធារស) ព្រះអង្គម្ចាស់ក្សត្រីធំ ជាព្រះជាយាបានឡើងព្រះយសដ៏ខ្ពង់ខ្ពស់ ជាសម្តេចព្រះរាជអយ្យិកា ខត្តិយកល្យាណរាជសុភាគវតី ។

សម្តេចព្រះរាជអយ្យកោនិងសម្តេចព្រះរាជអយ្យិកា ទាំងពីរព្រះអង្គនេះ ទ្រង់មានព្រះរាជបុត្រ ព្រះបុត្រី ដែលមានព្រះជន្មគង់នៅសព្វថ្ងៃនេះ ២ ព្រះអង្គគឺ:

១) ព្រះអង្គម្ចាស់ក្សត្រសុរាម្រិត ប្រសូតនៅថ្ងៃសៅរ៍ ៨ កេត ខែផល្គុន ឆ្នាំមមែ សប្តស័ក ព.ស. ២៤៣៨ បានសម្តេចព្រះរាជធីតាកុសុមៈ ជាព្រះរាជបុត្រីព្រះបាទសម្តេចព្រះស៊ីសុវត្ថិមុនីវង្ស ព្រះចៅក្រុងកម្ពុជា ជាព្រះជាយា ដែលជាសម្តេចព្រះវររាជមាតា-បិតា នៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូងសព្វថ្ងៃនេះ ។

២) ព្រះអង្គម្ចាស់ក្សត្រីរស្មីសោភ័ណ ប្រសូតនៅថ្ងៃអង្គារ ១២ កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស. ២៤៤២ ។ សព្វថ្ងៃនេះ បានឡើងព្រះយសជាសម្តេចព្រះបិតុច្ឆារស្មីសោភ័ណ ។

## ព្រះបរិយាសម្បត្តិនិងព្រះគុណសម្បត្តិ

សម្តេចព្រះរាជអយ្យកោនេះ ទ្រង់បានប្រកបករណីយកិច្ចផ្សេងៗ ដែលជាប្រយោជន៍ទាំងខាងផ្លូវអាណាចក្រ និងខាងពុទ្ធចក្រជាច្រើន

ប្រការ ដូចយើងបានពោលពណ៌នាមកខាងលើនេះ ។ មុនក្រសួងសំខាន់ខាងក្រោយបង្អស់ដែលទ្រង់បានទទួល គឺជាអធិបតីនៃពុទ្ធសាសនបណ្ឌិត្យ តាំងអំពីកាលនោះមក ទ្រង់យកព្រះទ័យឈឺឆ្អាលជួយផ្ទៀងផ្ទាត់ព្រះត្រៃបិដក ដែលពុទ្ធសាសនបណ្ឌិត្យបានបោះពុម្ពផ្សាយ ដរាបមកដល់ថ្ងៃទ្រង់ប្រឈួនជាទម្ងន់ ។ សម្តេចព្រះពជគយ្យកោព្រះអង្គនេះ ទ្រង់ជាមហាសប្បុរស មានព្រះរាជអធ្យាស្រ័យទន់ភ្លន់គួរជាទីគារព មានព្រះមេត្តាករុណាដល់បណ្ដាជនទូទៅមិនរើសមុខ ជាក្សត្រទ្រង់ធម៌ដ៏ហ្មត់ចត់តែងទ្រង់និច្ចសីលនិងឧបោសថសីលផងដែលជាប់ ទ្រង់ព្រះសណ្ដាប់ធម៌ទេសនារាល់ ៗ ថ្ងៃឧបោសថ ទ្រង់តែងទ្រង់សាកច្ឆាធម៌ជាមួយនឹងព្រះថេរៈជាធម្មកថិក ឬបណ្ឌិតឧបាសក ក្នុងថ្ងៃធម្មស្សវនៈជារឿយ ៗ រៀង ៗ មក ទ្រង់មានសទ្ធាជ្រះថ្លាមាំមួនណាស់ក្នុងវរពុទ្ធសាសនា ហេតុនេះហើយបានជារាជការជាធំ បានតាំងទ្រង់ឲ្យធ្វើជាអធិបតីនៃពុទ្ធសាសនបណ្ឌិត្យក្នុងកម្ពុជរដ្ឋនេះ ។

ក្រៅអំពីការដែលទ្រង់បានជួយផ្ទៀងផ្ទាត់ព្រះត្រៃបិដក ជាមួយនឹងក្រុមជំនុំពិសេសមួយ ដូចបានពោលមកហើយ ទ្រង់បាននិពន្ធរឿងផ្សេង ៗ ដែលពុទ្ធសាសនបណ្ឌិត្យបោះពុម្ពផ្សាយក៏មាន បោះពុម្ពផ្សាយក្រៅអំពីពុទ្ធសាសនបណ្ឌិត្យក៏មាន ដូចមានរាយឈ្មោះខាងក្រោមនេះគឺ ១- អនុត្តរិយសូត្រ, ២- មនោបុព្វកថា, ៣- អនត្តលក្ខណៈ

សូត្រ, ៤- បញ្ញាអភិញ្ញាបញ្ចវគ្គណា:, ៥- បរមត្ថពុទ្ធសាសនកថា, ៦- បរម-ពុទ្ធភាសិត, ៧- ពុទ្ធសាសនកិច្ច, ៨- តិលក្ខណានុបស្សនា, ៩- ត្រៃសិក្ខា ១០- ចំរៀងការផ្កាលំទួន, ១១- ទ្រង់បានជួយរៀងផ្គាត់ក្បួនរាជស័ព្ទនឹងសៀវភៅបក្ខគណនាវិធីជាដើម ។

សម្ដេចព្រះរាជអយ្យកោ ទ្រង់ព្រះប្រឈួនដោយព្រះរោគជរា-ភាពមកជាវេលាយូរ អាការព្រះរោគជួនធូនជួនស្រាល ហើយតមកមិនយូរប៉ុន្មាន សម្ដេចព្រះរាជអយ្យិកា ជាព្រះអគ្គជាយា ទ្រង់ព្រះប្រឈួនជាមុន ហើយទ្រង់ព្រះវិលាល័យទៅមុន ។ តអំពីនោះមក អាការព្រះរោគសម្ដេចព្រះរាជអយ្យកោធូរធ្ងន់ចុះស្រាលមិនជាទីកំណត់ លុះមកដល់ថ្ងៃ ៧ ១៤ ៣ ឆ្នាំរកាសប្ដស័ក ពុទ្ធសករាជ ២៤៨៨ (តាមប្រក្រតិទិនបច្ចុ) ទ្រង់សោយទិវង្គតដោយព្រះរោគជរាភាព គិតកំណត់ព្រះជន្មាយុ ៧៣ ព្រះវស្សា (ត្រូវនឹងថ្ងៃ ២៧ ខែយ៉ាំងវីយេ ឆ្នាំ ១៩៤៥ វេលាម៉ោង ១៨ និង ១០ មិនុត ។

ដំណឹងសោយទិវង្គតនៃសម្ដេចព្រះរាជអយ្យកោនេះ នាំឲ្យកើតវិយោគសោកសោកជាយ៉ាងក្រៃលែង ចំពោះដល់ព្រះរាជវង្សានុវង្ស ព្រមទាំងនាហ្មឺនសព្វមុខមន្ត្រីធំ-តូចទាំងពួង ដរាបដល់ប្រជាជនកម្ពុជរដ្ឋទាំងមូល ។ តាមដោយពិត នៅក្រុងភ្នំពេញទើបតែទទួលវិប្បយោគទុក្ខថ្មីៗ មិនទាន់ជាស្រាកស្រាលស្រយាលចិត្ត ដោយសម្ដេច

ព្រះរាជអយ្យិកា សោយព្រះវិលាល័យទៅថ្មីៗកន្លងពីរបីខែមុននេះ ស្រាប់តែមកពើបប្រទះលើទុក្ខថ្មីនេះថែមទៀត ។ នៅវេលាមុនសោយព្រះទិវង្គតនោះ អាការព្រះរោគមិនជាធ្ងន់ប៉ុន្មានទេ ហេតុនេះបានជានៅវេលាសោយទិវង្គត ហាក់ដូចជាទ្រង់មិនបានសោយទុក្ខវេទនាឡើយ មានព្រះដំណើរដោយស្រួលក្ដី តាំងនេះដោយព្រះរាជ-កុសលបុញ្ញរាសី ដែលទ្រង់បានអប់រំមកជាអនេកប្រការ ជួយឧបត្ថម្ភឲ្យទ្រង់មានព្រះរាជដំណើរយាងទៅកាន់បរលោកនាយ ដោយក្សេមក្សាន្តសម្រាន្តព្រះហឫទ័យ ។

ក្រសួងពុទ្ធសាសនបណ្ឌិត្យដែលមានទ្រង់ជាអធិបតី សូមបង្អោនកាយ-វាចា-ចិត្ត ចូលកាន់មរណសញ្ញាដោយសេចក្ដីគោរព ចំពោះព្រះសពទ្រង់ព្រមទាំងនឹករលឹកឃើញ ព្រះឧបការគុណរបស់ទ្រង់យ៉ាងជាក់ច្បាស់ ទើបថ្វាយសៀវភៅផ្សេងៗ ដែលទ្រង់បាននិពន្ធមានចំនួនជាង ១ ពាន់សៀវភៅ ជាអំណោយរបស់ក្រសួងដោយសេចក្ដីគោរព សម្រាប់ចែកជាធម្មបណ្ណាការ ថ្វាយព្រះរាជកុសលក្នុងឱកាសបុណ្យព្រះមេរុ ពីថ្ងៃ ២ ដល់ថ្ងៃ ៩ រោចខែមាឃ ព.ស. ២៤៩៨ ត្រូវនឹងថ្ងៃអង្គារ ៣០ ហ្សង់វីយេ ដល់ថ្ងៃអង្គារ ៦ ហ្វេវ្រីយេ ឆ្នាំ ១៩៥៥ នេះ ។

# រឿងរ៉ាវរបស់លោកភិក្ខុ ជាតិចិន១រូប

## ឈ្មោះហ្វួន-ឆាង

## ហ្សង់និពន្ធម្រ៉ាញ៉ាក-ប៉ែម

ស្រង់នឹងប្រែចេញអំពីសៀវភៅ Religieux et pelerins en terre d'Asie របស់លោក Goloubew សមាជិកសាលាបារាំងសែសនៅចុងបូព៌ាប្រទេស

(តមក)

តែខ្លួនលោកមើលឃើញតែម្នាក់ឯងយ៉ាងជាក់ស្តែង ។ ឯពួកសត្វទាំងនោះគឺប្រាកដជាពួកព្រះអរហន្តក្នុងព្រះពុទ្ធសាសនាហ្នឹងឯង រួចលោកស្រែកហៅឲ្យពួកព្រះអរហន្តទាំងនោះជួយលោក អំពីបំណងចង់ធ្វើដំណើរទៅនោះ ហើយលោកសុំឲ្យកើតមានជាប្រផ្នូលល្អមួយឡើងឲ្យប្រាកដជាក់ស្តែងដល់ខ្លួនលោក ។ តមកមិនយូរប៉ុន្មានក៏កើតមានប្រផ្នូលនោះឡើង គឺក្នុងយប់មួយ លោកយល់សប្តិឃើញភ្នំព្រះសុមេរុ ដែលជាព្រះភ្នំដ៏ស័ក្តិសិទ្ធិរបស់ពុទ្ធសាសនិកជនទាំងឡាយ ។ ភ្នំនោះប្រដាប់តាក់តែងទៅដោយពេជ្រនិងរតនៈមានដំរៀងទាំងអស់ ដុះកើតឡើងយ៉ាងរុងរឿងមានរស្មីភ្លឺព្រោងព្រាតនៅកណ្តាលមហាសមុទ្រ ។ ឯខ្លួនលោកហ្វួន-ឆាង ក៏ខំព្យាយាមទឹងទៅឲ្យដល់ទៅភ្នំនោះ តែនៅក្នុងសមុទ្រមានរលកធំៗ ដេរដាសដោយពពុះទឹកបោកបែកផ្កាត្រែង គួរឲ្យស្ញែងខ្លាចជាពន្លឹក លោកនឹកគិតដាច់ស្រេចក្នុងចិត្តក៏លោតចុះទៅ ។ ក្នុងមួយរំពេចនោះ ស្រាប់តែមានផ្កាឈូក១ ដុះដុលឡើងទ្រជើងលោក

ប្រែតមកបន្តិចក៏ស្រាប់តែបានទៅដល់ជើងភ្នំនោះ ហើយមានខ្យល់កំបួច ១ កើតឡើងភ្លាម កួចនាំយកខ្លួនលោកទៅដាក់លើកំពូលភ្នំសុមេរុ ដែលខ្ពស់ជាងគេ ។ លោកហ្វូន-ឆាង បានក្រឡេកមើលអំពីទីនោះទៅសព្វទិសទាំងពួង ឥតមានកំបាំងទីនៃភ្នែកលោកឡើយ ក្នុងយល់សប្តិនោះជាលោកមានសេចក្ដីត្រេកអរពេកណាស់ ក៏ភ្ញាក់រលឹកឡើង ។ តពីពេលនោះមកបន្តិច លោកហ្វូន-ឆាង ក៏ចេញដំណើរទៅប្រទេសទិសខាងលិច ។

— ៣ —

មានពួកមន្ត្រីនិងមេទាហានជាច្រើន ដែលមានសទ្ធាជ្រះថ្លាជួយលាក់លៀបចំបិទបំបាំង ដើម្បីជួយឲ្យលោកពុតន្ត (ហ្វូន-ឆាង) ចូលតំបន់ដែលមានអំណាចចិនត្រួតត្រាក្បាទៅបានមិនពិបាកពេក ដល់តែបានចូលផុតពីកំពែងធំទៅ ។ លោកខំដើរទៅស្រាប់តែប្រទះមហាសមុទ្រខ្សាច់មួយ មើលទៅឃើញធំល្វឹងល្វើយដាច់កន្ទុយភ្នែក ។ លោកខំដើរកាត់ទៅមុខតែម្នាក់ឯង ដោយមានសេះពាស់ ១ មានរោមក្រហមជាយានជំនិះ ។ ត្រាច់យាត្រាកាត់ទៅតាមចំរុយផ្លូវ ដែលមានតែគំនរឆ្អឹងរបស់មនុស្សនិងឆ្អឹងរបស់សត្វឧដ្ឋទាំងឡាយ កាយកាយខ្ចាត់ខ្ចាយនៅតាមផ្លូវដែលពួកការ៉ាវ៉ាន[១] តែងត្រាច់ដើរទៅ ។ លោកហ្វូន-ឆាង

---

១ ការ៉ាវ៉ាន គឺពួកក្រុមអ្នកដំណើរឬអ្នកជំនួញ ដែលតែងដើរឆ្លងកាត់សមុទ្រខ្សាច់ហៅថាពួកការ៉ាវ៉ាន ។

លោកប្រែមួយប្រមោលលោកដៅត្រៃល័យ ខ្លួនលោកស្ទើរតែនឹងក្សិណក្ស័យជីវិត ដោយការប្រែកឃ្លានជាច្រើនលើកច្រើនគ្រា ហើយដូចជាពួកអ្នកដំណើរដែលត្រូវទៅមកនោះ តែពុំបានជួបនឹងពួកបិសាចក្នុងសមុទ្រខ្សាច់យ៉ាងណា ឯលោកហ្វូន-ឆាង ក៏បានឃើញនិមិត្តប្លែកៗ ដែលនាំឲ្យលោកព្រួយចិត្តជាខ្លាំងដូចជាប៉ះដែរ ។ នៅវេលាយប់ ពួកបិសាចកំណាច ក៏នាំគ្នាដុតភ្លើងភ្លឺព្រោងព្រាតនៅជុំវិញខ្លួនលោកដូចជាភ្លើងចន្លុះ មានចំនួនច្រើនណាស់ដូចជាផ្កាយនៅលើមេឃ ។

--ដល់វេលាថ្ងៃ លោកបានសង្កេតទៅ ឃើញពួកមនុស្សកាន់អាវុធជាច្រើនអំពីចម្ងាយ ហើយសុទ្ធតែស្លៀកពាក់សំពត់ស័ក្លាត នឹងសំពត់រោមសត្វ មនុស្សទាំងអស់នោះដូចជាពួកចោរពេដេបរ (ឥតចំសំ-ណាក់) ដែលនាំឲ្យលោកមានសេចក្ដីភ័យខ្លាចជាច្រើននៅវេលាដែលជួបប្រទះ ។ ពួកចោរៗ ពួកនោះ ហាក់ដូចជាឈានជើងដោយជំហានវែងៗ នៅក្នុងពពកខ្សាច់ (គឺគំនរខ្សាច់ដែលត្រូវខ្យល់បក់គួចឡើងទៅអាកាសដូចជាពពក) ចោរមួយពួកទៀត ឈរនៅស្ងៀមមិនកំរើកខ្លួនសោះ តែក្រឡេកមើលទៅចំអ្នកដំណើរ គួរឲ្យស្ញប់ស្ញែង ចាំគន់មើលអំពីចម្ងាយដោយកិរិយានឹងថ្កល់ ។ មានដាវលំពែងភ្លឺផ្លេកចាប់ពន្លឺថ្ងៃ មានទង់ជ័យបក់រវិចៗ ដោយខ្យល់បក់ ។ មានពួកឧដ្ឋ

ដើរទៅជាជួរៗ ហើយមានពួកសេះសុទ្ធតែខ្លាយកំឡាំង ស្រែកកេង ក្រវែសក់របស់វា... ហើយមួយពួកទៀតនោះ មានជារូបពងសុទ្ធៗ មួយពួកទៀត ជារូបស្រមោលរបៀបអមយ៉ាងចំឡែក ។ លុះពួកនោះ កាឡាដំណែងខ្លួនជាច្រើនយ៉ាង ផ្លាស់ប្រែរូបជាច្រើនយ៉ាងបានដាច់ ហើយ គួរឲ្យខ្លាចពន់ពេក ហើយនៅទីបំផុតពួកនោះក៏សន្ធប់បាត់អស់ទៅ ។ នៅវេលានោះក្រាប់តែឮសូរសំឡេងចេញមកអំពីផ្ទៃមេឃម្ដងសំណើទៀតថា "អ្នកកុំខ្លាចឡើយ, អ្នកកុំខ្លាចឡើយ" ។ ហើយលោក ហួន—ឆាង ក៏មានសង្ឃឹមជួបចិត្តតាំងគំនិតមានកំឡាំង កំហែងមាំមួនឡើងវិញភ្លាម ហើយចាប់ផ្ដើមចេញដំណើរដើរទៅតែម្នាក់ឯង នៅកណ្ដាលវាលដីរំពេចដ៏ហួតហែងគួរខ្លាច លោកដើរសំដៅទៅទិសខាងលិច ដោយដំណើរយឺតៗ និងលំបាកជាច្រើន ។

លុះដើរទៅតាមឆ្នេរសមុទ្រខ្សាច់ក្បែរទិសខាងត្បូង លោកក៏បានដល់ទៅប្រទេសរបស់ស្ដេចគួហ្វាន ។ ប្រទេសនេះ មានឈ្មោះតាមភាសាចិនហៅថា កាវ-ចាង ជាប្រទេស ១ ដល់មកសតវត្សទី ៧ ជាកាលណាចក្រមានវឌ្ឍនភាព និងមានសេចក្ដីរុងរឿងជាច្រើន ។ ពួកអ្នកស្រុកក្នុងប្រទេសនោះ សុទ្ធតែជាកូនស្ដេចជាតិតួគ (ណ្ហ)- ទុរុប ជាខ្សែស្រឡាយជាមួយនឹងជាតិតូខារៀន កស្ដេចទាំងនោះច្រើនជាអ្នក

បានសម្បត្តិស្តុកស្តម្ភ ដោយធ្វើជំនួញជាមួយនឹងចិន និងប្រទេសប៉ែរ្ស-
សាសព្វទិស ។ ជនទាំងនោះមានចំណេះចេះដឹងខាងភាសាសំស្ក្រឹត
និងកាន់ព្រះពុទ្ធសាសនាដែលបានទទួលមកអំពីប្រទេសឥណ្ឌា ហើយ
ជាអ្នកគោរពប្រតិបត្តិតាមព្រះពុទ្ធសាសនាដោយសទ្ធាជ្រះថ្លាផង ។ នៅ
វេលាដែលស្តេចត្រឹកឲ្យប្រទេសគួហ្វាន ទ្រង់បានជ្រាបថា មានភិក្ខុ
ព្រះពុទ្ធសាសនានិមន្តមកពីប្រទេសចិន ដើរកាត់ប្រទេសរបស់ទ្រង់
ដើម្បីទៅប្រទេសឥណ្ឌា ទ្រង់ចាត់ឲ្យមានក្បួនហែទទួល ដោយទ្រង់ហែ
ខាងក្បាលក្បួន នៅខាងមុខលោកពុទ្ធគ្គនោះ ហើយនិមន្តលោកចូល
ទៅឲ្យគង់ក្នុងវាំងរបស់ទ្រង់ ។ លោក ហ៊ួន-ឆាង ក៏ទទួលបដិ-
សណ្ឋារៈនោះ ប៉ុន្តែក្សត្រគួហ្វានដោយទ្រង់សព្វព្រះទ័យនឹងចំណេះ
ចេះដឹងដ៏ធំទូលាយរបស់លោក ព្រមទាំងកិរិយាវាចាដ៏សមរម្យគួរ
ជាទីជ្រះថ្លានោះ ទ្រង់មានប្រាថ្នាចង់ល្បងបង្ខំឲ្យលោកហ៊ួន-ឆាងគង់
នៅជិតក្បែរទ្រង់ ប៉ុន្តែលោកបានតាំងចិត្តដាច់ស្រេចថា ទោះបីស្លាប់
ដោយអត់បាយក្តី អត់ទឹកក្តី ក៏មិនត្រូវបោះបង់បំណងដើមរបស់លោក
ឡើយ ។ លោក "ស៊ូតែគង់នៅ ដោយវាចាប្រកាន់នឹងថ្កល់
ឥតកម្រើកបន្តិចរហូតដល់ ៣ ថ្ងៃ ឥតមានទឹក ១ ដំណក់ឬបាយ ១
ស្លាបព្រា ជ្រាបចូលទៅក្នុងបំពង់កលោកឡើយ ។ ទើបព្រះ

មហាក្សត្រតួរហ្វាន ទ្រង់ឃ្លានសេចក្តីភិតភ័យនឹងវៀនខ្លាសជាច្រើន ហើយទ្រង់ក្រាបថ្វាយបង្គំដល់ដីចំពោះមុខលោក នឹងទ្រង់បង្គំសុំខមាទោសលោកដោយសេចក្តីគោរពផង" ។

— ៤ —

លោកហួន-ឆាងនោះ ក្រោយដែលបានថ្វាយព្រះពរលាព្រះរាជា ជាមិត្រនឹងជាព្រះឧបត្ថម្ភហើយ ក៏ចេញចាកតំបន់ដ៏ស្តុកស្តម្ភនៃរៀងអំពីនគរតួរហ្វាន ហើយចាប់ដើរសំដៅទៅទិសខាងលិច ។ រយៈសំបតលើកទី ២ នៅកុតឆា ជាទីក្រុងសំខាន់មួយទៀតនៃទ្វីបអាស៊ីកណ្តាល ហើយជាទីប្រជុំប្រតិបត្តិតាមច្បាប់នៃព្រះពុទ្ធសាសនា ។ លោកហួន-ឆាងបានឈប់សំណាក់នៅក្នុងនគរនោះជាង ៦០ ថ្ងៃ ដើម្បីរង់ចាំឲ្យហិមៈនៅភ្នំរលាយអស់ពីស៊ិន ដែលជាគ្រឿងទំនាស់ដល់ដំណើរដើរកាត់ភ្នំទៀន-ចាន ។ នៅវេលាដែលលោកចេញដំណើរទៅនោះ ស្តេចក្រុងកដ្សនគរកុតឆា ស្វាគណា តិចបានទ្រង់ព្រះរាជទានពួកមនុស្សបំរើដល់លោក ព្រមទាំងឧដ្ឋ សេះសម្រាប់ផ្ទុកគ្រឿងបណ្តាការជាច្រើនផង ។ ក្រោយដែលលោក ហួន-ឆាង បានដើរកាត់ភ្នំទៀន-ចានដ៏វែងឆ្ងាយទៅដោយហិមៈរួចលោកនិមន្តដើរទៅតាមមាត់បឹងអ៊ីស្សុកគូលទាំងដើង ក៏បានចូលទៅសំណាក់នៅតក់ម៉ុកជាវេលាយូរ ជាទីដែល

ស្តេចគុនីស៊ីបតូ ក៏គង់នៅដែលជាស្តេចធំរបស់ពួកជនជាភ័គ្លកទិស ខាងលិច ។ ស្តេចអង្គនេះមានរឿងអំណាចគួរឲ្យស្ញប់ស្ញែង ជាងាយក របស់ពួកជន ទ្រង់កើតមកមុនជាយូរ នៃពួកកាម៉ៃឡាន និងពួក សង្ឃិស-ទា ទ្រង់បានធ្វើឲ្យលោកហ្វូន-ធាង ស្ញប់ស្ញែងកក់ស្លុត ដោយឫកពាជាអ្នកចម្បាំង ហើយពួកបរិវារក៏សំដែងការការគោរពយ៉ាងអឹកធឹក ណាស់ដែរ ។ ក្សត្រអង្គនេះ មិនមែនជាអ្នកកាន់ពុទ្ធសាសនាទេ តែទ្រង់ចូលចិត្តឲ្យពួកលោកសង្ឃធំៗ អធិប្បាយ ពន្យល់អំពីរបៀប ប្រាប់ធម៌ដែលល្អ ហើយចូលចិត្តជជែកជាមួយនឹងលោកទាំងនោះ ។ ស្តេចនេះក៏បានយកទាំងកំដរលោក ដោយបង្ខំឲ្យលោកគង់នៅជិតៗ ទ្រង់ មានចំនងដូចជាស្តេចគួហ្វានបានធ្វើមកហើយ ។ ទ្រង់មាន ព្រះបន្ទូលថា "លោកគ្រូ មិនត្រូវលោកនិមន្ត ទៅប្រទេសឥណ្ឌា ឡើយ ដ្បិតប្រទេសនោះអាកាសក្តៅខ្លាំងណាស់ ក្នុងរដូវរងាអាកាស ក្តៅខ្លាំងជាងប្រទេសយើង ក្នុងរដូវក្តៅទៀត.. ។ ខ្ញុំមើលទៅ មុខលោកខ្ញុំខ្លាចបក់លោយទៅនៅវេលាទៅដល់នោះឯង ។ ឯពួក អ្នកស្រុកលោកទៀត សុទ្ធតែជាមនុស្សខ្មៅៗ ដើរខ្លួនទទេ ហើយ ដោយប្រែននោះជាមនុស្សមិនចេះបង់សណ្ដារៈគួរសមគួរទេ ជនទាំង នោះមិនសមគួរលោកនិមន្តទៅមើលគេឡើយ" ។ ប៉ុន្តែលោកហ្វូន-ធាង

ញញឹមយ៉ាងទន់ភ្លន់ឆ្លើយតបទៅវិញថា "ដូចទ្រង់គង់ឃើញស្រាប់ អាត្មាភាពមិនគាប់ចិត្តបំបាត់បំណងយ៉ាងខ្លាំងក្លារបស់អាត្មាភាពបានទេ, គង់ការទៅស្វះស្វែងរកព្រះធម៌ ដ៏បរិសុទ្ធរបស់ព្រះពុទ្ធជាម្ចាស់ ហើយពិនិត្យមើលគម្ពីរណាទាំងឡាយ ដែលគង់នៅហើយ ដើម្បីធ្វើដំណើរដើរទៅតាមស្នាមព្រះបាទ របស់ព្រះពុទ្ធ ដោយសេចក្ដីស្មោះស្ម័គ្រ" ទើបក្សត្រជានាយកជាតិតួរក៍ ក៏តាំងខ្លួនព្រះសិរបំពោះមុខលោកគូគង់ ថ្វាយបង្គំដោយសេចក្ដីគោរពយ៉ាងខ្ពង់ខ្ពស់ ហើយបណ្ដោយឲ្យលោកនិមន្តចេញទៅ ព្រមទាំងបានរៀបចំបម្រុងទុកជាមុន អស់ទាំងគ្រឿងប្រដាប់ប្រដា ដើម្បីជូនដំណើរលោកនិមន្តចេញទៅបានដោយស្រួល ។

— ៥ —

លោកហួន-តាង ជាខាងក្រោយដែលបានដើរចូលទៅមើលស្រុកគាប់ចេន្តហើយ លោកក៏ចាប់ផ្ដើមដើរកាត់តំបន់ស៊ុល-គុម គឺ "សមុទ្រខ្សាច់ក្រហម" ដែលគួរខ្លាចស្ញប់ស្ញែងណាស់ ។ សមុទ្រនេះឯងហើយ ដែលប្រកបដោយសេចក្ដីវេទនាជាក្រៃលែង ដែលលោកឆ្លងដំណើរទំដើរធ្ងន់ជាយូរអង្វែង ។ លោកបានកត់ត្រាទុកដោយខ្លួនលោកថា "ស-មុទ្រខ្សាច់នេះ ជាវាលខ្សាច់យ៉ាងធំសំបើម ហើយជាទីឥតទឹកឥតស្មៅ

ផង ៗ ត្រូវក្រឡេកមើលទៅកូខ្ពស់ ៗ ពីរបី ដែលនៅឆ្ងាយបន្តិចនោះ ហើយត្រូវគន់គេមើលគំនរឆ្អឹងខ្មោចដែលស្លាប់ចោលទៅ ទើបកំណត់ទីដីស្គាល់ផ្លូវដែលត្រូវដើរទៅនោះបាន" ៗ ទុកដោយលំបាកយ៉ាងណាក៏ដោយ លោកហ្វូន-ឆាង ក៏បានដល់ទៅស្រុកសាមារកន្ទដោយសួស្តី ស្រុកនោះជាទីក្រុងម៉ាសង្យែខ ជាទីកុះករដោយអ្នកជំនួញទំនិញពួកគាក-កាន ជាស្រុកប្រើដោយភាសាស្កុកដៀន ៗ លោកចំដើរសំដៅត្រង់ទៅទិសខាងត្បូង ៗ លោកចំដើរកាត់ភ្នំកួតាំងកុះដែលនៅខាងចំណែកស្រុកបាមៀ ហើយឆ្លងកាត់ទន្លេ អាមូ-ដារយ៉ា តាមពាក្យបុរាណហៅថាទន្លេវក្ស៊ុ ត្រង់កន្លែងភ្នំហៅថាបាំតា-គេសារ ហើយលោកចូលទៅស្រុកប៉ាក់ទ្រៀហាន់ ជាទីក្រុងដ៏ថ្កុំថ្កើង ១ របស់ជាតិអ៊ីរ៉ង់ តាំងពីសម័យស្ដេចអាលេក្សង់ដ្រឺមហារាជចូលលុកលុយរាយយកពុំបាន ៗ កាលពីក្នុងជំនាន់លោកហ្វូន-ឆាងនោះ ប្រទេសនោះ នៅខាងក្ដីដំណែលពុទ្ធ-សាសនាជាច្រើននៅឡើយ ៗ គេបង់ទៅឃើញមានចំនួនវត្តច្រើនជាដរាបរហូតទៅ ជាទីចរិយពណ៌ដោយព្រះសារីរិកធាតុតាំងឡាយ ហើយមានចំនួនភិក្ខុជិតដល់ ៣,០០០ អង្គផង ៗ នៅស្រុកបល្ខ ដែលជាទីក្រុងរបស់បាក់ទ្រៀយ៉ាននោះ លោកហ្វូន-ឆាងបានជួបប្រទះលោកអ្នកប្រាជ្ញធំ ១ រូប កាន់ពុទ្ធសាសនាបែកខាងហីនយាន ឈ្មោះលោក

ប្រាជ្ញករ ។ លោកអ្នកប្រាជ្ញនេះបានធ្វើយដោះស្រាយអំពីសេចក្ដីប្រែស្នាខ្ទះក្នុងព្រះអភិធម្ម ដែលលោកហ្វូន-ឆាងបានចោទសួរលោក ព្រមទាំងសេចក្ដីព្រះសូត្រឯទៀត ដែលបានជ្រើសរើសយកត្រង់កន្លែងដែលពិបាកណាស់ ។

កាលលោកហ្វូន-ឆាងបានដើរកាត់ស្រុកប៉ុកទ្រយ៉ាន តាំងពីដើមហេតុដល់ចុងហើយ លោកក៏ដើរកាត់ភ្នំឈ្មោះហ៊ិណ្ឌូ-គូស ដែលជាភ្នំមានកំពូលជាប់ដោយសាយហិមៈជានិច្ច ហើយមើលទៅខ្ពស់ត្រ-ដែតទៅទល់មេឃនៅចំពោះមុខលោក ។ លោកត្រូវតែឡើងកាត់ភ្នំដែលមានកំពស់ខ្ពស់ត្រដែត ដើម្បីឲ្យបានដល់ទៅផ្លូវ ដែលគេតែងដើរទៅកាត់ចកភ្នំខ្ពស់ៗ (ជាតំរុយផ្លូវ) នៅស្រុកអាហ្វហ្គានីស្ថង់ ។ លោកហ្វូន-ឆាងក៏បានជួបប្រទះនឹងសេចក្ដីលំបាកវេទនា ប្រកបដោយសេចក្ដីអន្តរាយជាច្រើនទៀត ។ លោកគោងដើរកាត់ដុំពពកហ៊ោងក្រាស់ដែលចាប់គ្នានឹងដូចជាទឹកកក ហើយមានខ្យល់អាកាសនោះស្ទើរតែផុតដង្ហើមមិនរួច ។ នៅផ្លូវដើរដែលលោកដើរទៅនោះ ខ្ពស់ៗ ទាបៗ ក្រហេងក្រហូង មានហិមៈជាន់ទៅផុងស្រុះ មុខគួរឲ្យស្ញប់ស្ញែងខ្លាចជាពេក ហើយលាន់ឮសូរទឹកឈូរ និងប្រទាយទឹកហូរ ឮសូរគគ្រុកគគ្រាកគគអាក់ ។ មួយទៀត ដោយហេតុមានអន្តរាយពីគ្រាប់ថ្មមក

ទៀត កើតមកពីបិសាចកំណាចទាំងឡាយ ដែលក៏មកនៅជិតប្រកិតជា-និច្ច ក៏តែងធ្វើឲ្យមានអន្តរាយគ្រោះថ្នាក់ដល់អ្នកដំណើរ ដោយប្រាន ទម្លាក់ដុំទឹកកកសង្កត់ ឬធ្វើឲ្យវង្វេងវង្វាន់ក្នុងចំណោមអ័ព្ទហិមៈនោះឯង ។ លោកហ្វេន-ឆាំងបាននិយាយលើកជាច្រើនដង នៅក្នុងសៀវភៅរាយការកត់ត្រារបស់លោក ហើយលោកបានទូន្មានយ៉ាងស្មោះត្រង់ អំពីគ្រោះថ្នាក់អន្តរាយទាំងនោះ ចំពោះពួកអ្នកដែលប៉ុនប៉ងនឹងដើរផ្លូវទីនោះទៅ នៅវេលាជាខាងក្រោយអំពីលោកមក ។

— ៦ —

លោកពុគ្គន៍និងគណៈអ្នករួមដំណើររបស់លោក បានទំរំឃ្លាតដើរផ្លូវយ៉ាងលំបាកវេទនា ត្រាតែផុតឬដើរវែងនឹងទីសំចតដែលលំបាកទៅបាន លោកអស់នោះ ក៏បានដល់ទៅជើងភ្នំនៅទិសខាងត្បូងភ្នំហិណ្ឌូ គូស ហើយក៏នាំគ្នាដើរចុះទៅរកប្រកផ្លូវដែលល្អនិងស្រួលនៅស្រុកបាមយ៉ាន លោកអស់នោះក៏សឹងមានបតិភាគយកលើគ្នាជាពន្លឹក ។ កាលបានដល់ទៅស្រុកបាមយ៉ានហើយ លោកហ្វេន-ឆាំងក៏បាត់នឿយហត់អស់កំឡាំងក្លាម ។ នៅខាងជើងទីក្រុងនោះ មានញកភ្នំខ្ពស់ៗ លយចេញពីភ្នំទៅ នៅពីខាងក្រោមមានរោងជាចំនួនច្រើន ជាទីស្នាក់អាស្រ័យនៅនៃពួកភិក្ខុពុទ្ធសាសនា ។ (មានត)

### ពត៌មានថ្លែងសេចក្ដី

### ពិធីទៅនាំយកព្រះពុទ្ធរូបនិងបល្ល័ង្កនៅឃុំអង្គរបុរី ស្រុកព្រៃកប្បាស

(តាកែវ)

ឃុនបញ្ញាសោភ័ន គាំ-ឌុម រៀបរៀង

(តមក)

ក្នុងវេលាល្ងាចថ្ងៃ៦ នោះឃើញតែមូកចូលទៅក្នុងផាផាំហូរហែពីពួក យួនដែលមកពីភូមិឆ្ងាយៗ ចូលទៅចំរុងចំនងធ្វើបុណ្យជួបជុំគ្នានៅវត្តព្រះនាគយណ៍ កាលបើទៅដល់ឃើញបាត់ព្រះនាគយណ៍ពីកន្លែងដូច្នោះ ហើយ ក៏នាំគ្នាធ្វើមុខស្រពោនស្រងូតស្រងាត់គួរមានចិត្តអាណិតអាសូរណាស់ៗ

## អំពីយកព្រះពុទ្ធរូបក្នុងគុហាទី ២ (ភ្នំដា)

ថ្ងៃ ៧ សេបតមប្រ៍ ពេលម៉ោង ១០ ព្រឹកចាប់ប្រារព្ធទៅយក ព្រះពុទ្ធរូបក្នុងគុហាទី ២ យួនហៅថា ជ្ញាំកសឹងព្រឹកពៅទៀត ឯរបៀបចាត់ចែងនិមន្តព្រះពុទ្ធរូបចេញពីគុហាចុះទៅដាក់លើក្នុងទូក ជាភារៈលើថៅយួនជាវិស្វកម្មទាំង ៤ នាក់ជាមេចាត់ការ ឯយើងខ្ញុំគ្រប់គ្នាគ្រាន់តែជួយហៅហាមចុំណោះ ដោយហេតុក្រសួងសាធារណការចាត់ការមានរបៀបគ្រប់តែងកែបងបង្អួចទ្រញើកញ៉ាក់ច្រើនពេក ការនិមន្តព្រះពុទ្ធរូបត្រឡប់ទៅជាយឺតយូរបន្តិច ស្មើរតែ ១ ថ្ងៃទើបហើយ ឯពួកយួនអ្នកស្រុក

កាលដែលយករូបបុរាណមកចាក់ស៊ីម៉ងត៍ ប៉ះប៉ុនកែកុខជាព្រះពុទ្ធរូបឡើងវិញនោះរាប់ជាង ២០ ឆ្នាំហើយ ដល់កន្លងមកខាងក្រោយ មានជាតិបារាំងម្នាក់ជាមេត្រួតត្រាបុរាណវត្ថុកាលដែលទៅជួសជុលប្រាសាទភ្នំដា និងអាស្រមមហាឫស៊ីបានយកកំណាត់ដៃជើងពីទីនោះ ប្រហែលជាទុកនៅក្នុងសារមន្ទីរភ្នំពេញផង? ឯបុរាណវត្ថុដទៃក្រៅអំពីព្រះពុទ្ធរូបនេះទៅ មានកំណាត់ចុងជើងស្តាំ ១ ត្រូវធ្វើអំពីសំរិទ្ធ ទម្ងន់ ៣៤ ក្រាមបានយកមកជាមួយផងដែរ ។

លុះនិមន្តព្រះពុទ្ធរូបទៅសណ្ឋិតនៅក្នុងឡានរួចជាស្រេច ក្នុងវេលាម៉ោង ៤ រសៀលហើយយើងខ្ញុំក៏នាំគ្នាទទួលទានអាហារ ហើយហៅពួកយួនចេញពីភ្នំដានៅវេលាម៉ោង ៥ រសៀលថ្ងៃ ៧ ប្រញាប់ចង់វិលទៅយកបល្ល័ង្ក (ស្ពានព្រាណ) ពីលើភ្នំបាទេពក្នុងវេលាព្រឹកស្អែកថ្ងៃ ៨ សេបតមប្រែកទៅទៀត ឯពួកយួនភ្នំដាឃាត់យើងគ្រប់គ្នាឱ្យនៅចាំមើលបុណ្យក្នុងវេលាល្ងាចថ្ងៃ ៧ នោះសិន តែយើងខ្ញុំពុំព្រមនៅហើយក៏ចេញចូកទៅសំដៅភ្នំបាទេព ដែលនៅទិសឦសានភ្នំដាចម្ងាយប្រ-ហែល ៣.០០០ម. លុះទៅដល់ពាក់កណ្ដាលផ្លូវទើបព្រះសូរ្យស្រពោនោះជំគ្រោកគ្រេងដែលពួកយួនចាស់គេប្រជុំគ្នា ធ្វើបុណ្យនៅទីវត្តព្រះនាគយណ៍ ឮសូរពីចម្ងាយគួរឱ្យសប្បាយរីករាយអណ្ដែតអណ្តូងក្នុងចិត្ត លុះជិតដល់ទៅភ្នំបាទេពស្រាប់តែពពកខ្មៅខ្ទួលខ្ទាញ់ មេឃងងឹតជិត

ស៊ុំនាក់ក្មេងៗផ្ទះទេះលើភាកាសស្ពាន ពិបាកនឹងរកផ្លូវចូលឲ្យដល់ភ្នំបា-
ទេពបាន ព្រោះទឹកកក់ពេកកំបាំងសត្វកប្ចូលទៅបកទួលពានដំណេក
នៅទួលផ្ទះសេហ៊ុបស៊ិ ឯពួកជយូនវិស្វកម្មក្រសួងសាធារណការគាតែ
កំបែរទូកទៅសំណាក់នៅឯទីអគ្គរបុរ ។

## អំពីយកបល្ល័ង្កស្ពានទ្រោណីពីលើភ្នំបាទេព

ថ្ងៃ ៨ សេបតមប្រ៍ វេលាម៉ោង ៨ ព្រឹកបានចេញទូកទៅជួបជុំគ្នា
នៅភ្នំបាទេព ប៉ុន្តែដោយហេតុទឹកដែលឡើងទៅដល់ជើងភ្នំនៅពក់
ណាស់ ក៏បានចតទូកឆ្ងាយស្រឡះចម្ងាយប្រហែល ២០០ ម. ពីជើង
ភ្នំ ហើយឲ្យពួកគូលីដញ្ជូនចេកត្រៀងអន្ទងគឺដែកទីងឈើឡើងទៅ
លើភ្នំដាប់ផ្គុំឈើធ្វើជាឃ្នាបតាបបល្ល័ង្ក ប៉ាំងកុំឲ្យប៉ះទង្គិចបេះក្បាច់
ស្រេចហើយ ទើបគ្រីបលើកបល្ល័ង្កឡើងអន្ទងដាក់ចុះទៅលើរទេះដែក
ដែលដំកល់លើផ្លូវដែករៀបបន្តដំរង់ទៅក្បាលជណ្តើរ ដែលចុះពីលើភ្នំ
រហូតទៅដល់ជើងភ្នំ ដោយហេតុបល្ល័ង្កនោះមានទំហំធំណាស់កង ៤
ជ្រុងស្រាប់លើគ្នាជា ២ កំណាត់ ១ ខាងលើទំហំ ១ ជ្រុង ១ ម. ៤០ កំពស់
០ ម. ៤៨, កំណាត់ទ្រនាប់ខាងក្រោមទំហំ ១ ជ្រុង ១ ម, ៥០ កំពស់
០ ម, ៣០, រួមកំពស់ទាំង ២ កំណាត់កំពស់ ០ ម, ៧៨ ដែលលើកយក
មកនោះបានតែកំណាត់ខាងលើជាមុន, បល្ល័ង្កនេះឯងចេះមពាក្យ

លោកវិស្វករតាកែវទិយាយថា លោកនឹងយកកែ ១ ថ្ងៃឲ្យហើយជាស្រេច តែសម្រេចដល់ទៅលើកយកគ្រាន់តែកំណាត់ខាងលើ ៤ ថ្ងៃទើបនាំទៅដាក់ដល់ទួតបាន ហើយដោយថ្ងៃទី ៣ វេលាដែលកំពុងចុះពីលើភ្នំមកតាមផ្លូវដែកទាញទប់ដោយហោតទាញ ។ មិនឈ្នះបាក់ដាច់ក្តៅហោតនោះធ្លាក់ចុះមកពីលើភ្នំតាមផ្លូវកំពស់ ៣០ ម, ០០ ទាំងវម៉ាំងរទោករហូតទៅដល់ជើងភ្នំផង ឲពុទ្ធោ! ពុទ្ធោអើយ! នឹកទៅព្រឺសព្វសាច់ ហើយភ័យ-អរ ។ ដោយបានរួចជីវិតអំពីបល្ល័ង្កដែលធ្លាក់ពីលើភ្នំនោះឯង ព្រោះកាលដែលកំពុងបល្ល័ង្កសំយុងចុះពីកំពូលភ្នំបានប្រហែល ១ ម. ប៉ុណ្ណោះ រទេះដែក ក៏ធ្លាក់ចេញពីផ្លូវដែកទៅបានវ៉ៃហោតទាញ ទប់ទុកសិន ជ័យនុន្នាក់បានយកដែកគ្រប់ទៅគ្រប់លើកពីខាងក្រោមដើម្បីដាំងឲ្យត្រូវតាមផ្លូវដែក ចំណែកខ្ញុំក៏ចុះទៅតាមផ្លូវដែកបំណោងខ្ញុំនឹងមើលទំនងផ្លូវពីក្រោមទៅ លុះជ័យនុនោះគ្រប់ឡើកដំរង់ផ្លូវពុំបាន ហើយក៏ថយចេញទៅខ្លួនខ្ញុំទើបចុះទៅដល់ជើងភ្នំហើយដើរចេញពីផ្លូវដែកប្រហែល ២ ម. ប៉ុណ្ណោះ វេលានោះឯងក៏ដាច់ក្តៅហោតទាញធ្លាក់បល្ល័ង្កចុះមកក្បែរខ្លួនខ្ញុំនិងជ័យនុនោះ បានជាខ្ញុំនិងជ័យនុនរៀគទ្រន់ហើយទះដៃផងភ័យហើយត្រេកអរដោយបានរួចអំពីសេចក្តីស្លាប់ សមដូចពាក្យបុរាណថា "អាយុមិនទាន់ ព្រោះគ្មានពន់ខានទេតែជួយពុំឲ្យស្លាប់" ឯបល្ល័ង្កដែលធ្លាក់មកនោះមានរបេះក្បាច់

បន្តិចបន្តួច ដល់ថ្ងៃ ១១ សេបតេមប្រ៍ម៉ោង ៣ រសៀលទើបបាននាំទៅ រៀបដាក់ទុកក្នុងទូករួចជាស្រេច ឯទ្រនាប់បល្ល័ង្កខាងក្រោមពុំទាន់បាន យកទុកដល់ថ្ងៃក្រោយ ព្រោះប្រញាប់ចេញទូកទៅអគ្គបុរី ដើម្បីរៀបចំ ទុកតែងគ្រឿងសក្ការៈរបស់ព្រះពុទ្ធរូបដោយល្អ ថ្ងៃ ១៤ សេបតេមប្រ៍នោះ ជាថ្ងៃចំរើនព្រះជន្ម ធ្វើបុណ្យសម្ពោធិ៍ជូនព្រះពុទ្ធរូបទាំងប៉ុន្មានដែលបំរុង នឹងនាំមកដាក់ក្នុងទូកនៅសាលាខេត្តកំពត បានចេញទូកទៅចតនៅមាត់ ស្ទឹងក្បែរវិហារវត្តកំពង់ហ្លួង ផ្លូវដែលទើបនឹងធ្វើកាត់មុខវិហារពីសាលា បារាំងសំដៅទៅមាត់ស្ទឹង ។

## អំពីពិធីបុណ្យនៅកំពង់ហ្លួងថ្ងៃ ១២-៩-៥៤

ពិធីបុណ្យនេះ មានរបៀបរៀបចំអ៊ឹកធឹកពន់ក្រៃពេកណាស់ដោយ បេសកភាពរបស់លោក ឡេស៊ុយឌឺត៍ ចំពោះព្រះបាទ ខ្ពស់ទៅហើយ នៃក្រុមការ តាត់ឲ្យទៅហៅស្រុកនៃព្រែកបង្ហាសបង្អាប់ផលលោក សេហ្វ៊ីស៊ូខ្មែរមេឃុំ ១ អគ្គបុរីគេណ្ឌបណ្ដាកស្រុកឲ្យមកបាក់រៀបចំពិ បុណ្យ តាំងពីវេលា ៤ ខែមុន គឺបានធ្វើផ្លូវ ១ ជាថ្មីទៀត កាត់ពីវត្តកំពង់ ហ្លួងសំដៅទៅវត្តផ្ទាយចម្ងាយប្រហែល ៣០០ ម. ព្រោះផ្លូវចាស់តាម មាត់ស្ទឹងកែលិចធ្វើការមិនបានត្រូវផ្ទុំ, បានរៀបចំសែនក្នុងវត្តកំពង់ ហ្លួង ៣ ខ្ទង់ដែលធ្វើអំពីគមាររបៀបរៀបដាក់ផ្កាទាន់អួរឡើងហើយ ធ្វើផ្លូវខ្វាក់ខ្វែងក្នុងវត្តទាំងមានគល់ដើមពោធិ៍ជាចំណាំវត្តពោលចេញជា

ច្រើនផង បានតុបតែង សាលាបង្រៀនវត្តកំពង់ហ្លួង ធ្វើសម្រាប់ជាទីប្រជុំបុណ្យ ឯក្នុងទីវត្តជ្រោយបានរៀបចំសាលាវត្តសម្រាប់ទទួលអស់លោកធំៗ ដែលអញ្ជើញទៅពីតាកែវនិងភ្នំពេញ ឯខាងស្ទឹងមុខវត្តជ្រោយបានរៀបធ្វើជាផែបេតាដោយស្នូកឈើសម្រាប់អស់លោកធំៗ ចូលទៅចតទូកហើយឡើងទៅប្រជុំបុណ្យ ។

ថ្ងៃ ១១ សេបតម្ប្រ៍ វេលាម៉ោង ៨ ល្ងាច និមន្តភិក្ខុសង្ឃចំរើនព្រះបរិត្ត ម៉ោង ១០ និមន្តលោកគ្រូអាចារ្យធំជាធម្មកថិកសំដែងធម៌ទេសនា រួចហើយមានល្បែងពួកយុវជន ១ វង់និងភ្លេងសៀម ១ វង់ ភ្លេងខៃយ៉ាំ ១ វង់ លេងសម្រាប់ទស្សនាការកំសាន្តនៅទីវត្តកំពង់ហ្លួង ឯទីវត្តជ្រោយមានពួកភាប៉ី ១ វង់និងភ្លេងសៀមសម្រាប់វត្ត ១ វង់ លេងសម្រាប់ទស្សនាកំសាន្ត ។ បុណ្យនោះគួរឲ្យសប្បាយណាស់ក្នុងវេលាយប់ថ្ងៃ ១១ នោះ ប៉ុន្តែតាស់ទឹងមានភ្លៀងពីក្បាលល្ងាចធ្វើឲ្យទីបុណ្យទាំងអស់ក្រខ្វក់ក្រខ្វាច់ដោយភក់បន្តិចផង ទាំងគ្រឿងបំភ្លឺក៏ពុំសូវមានគ្រប់គ្រាន់ផង ។

ថ្ងៃ ១២ សេបតម្ប្រ៍វេលាម៉ោង ៩ ព្រឹក ពួកភិក្ខុសង្ឃចំនួន ២០០ អង្គនិមន្តទៅភ្ជន់ប្រជុំចាំទទួលអស់លោកធំៗ នៅសាលាបង្រៀន វត្តកំពង់ហ្លួងនិងរៀបឲ្យពួកយុវជនចំនួន ៨០០ ឈរចាំគំនាប់ ជាជួរតាមផ្លូវដែលធ្វើថ្មីពីវត្តកំពង់ហ្លួងរហូតទៅដល់វត្តជ្រោយផង ដល់ម៉ោង ១១ ព្រឹក

ទើបអស់លោកធំៗ អញ្ជើញទៅដល់មានក្មេងសៀម ការប៉េ ទិនទូកប្រ-ណាំងជាច្រើន ហៃហាមតក្រែកតក្រែងអមផង អស់លោកធំៗ ដែលអញ្ជើញទៅនោះមានចំនួនច្រើន ប៉ុន្តែដែលខ្ញុំបានស្គាល់ប្រាកដនុះគឺ:

លោកឡឹបា ម៉្សឺរេស៊ីដង់ តាកែវ ព្រមទាំងលោកស្រីនិងបុត្រ-ធីតា របស់លោក ។

លោក ប្រាក់-សារិន ព្រះបាទម្ចាស់ចៅហ្វាយខែត្រតាកែវ ។

លោក ឌុយ-ប៊ុន អគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ

លោក ទាស-ណាល់ ឧកញ៉ាមហាវិទ្យាធិបតី សេនាបតីក្រសួងសិក្សាធិការ ។

លោក ក្រុស មេត្រប់ត្រង់បុរាណវត្ថុនៅអង្គរ (សៀមរាប) ព្រមទាំងភរិយារបស់លោក ។ ល ។

លុះទៅដល់ហើយក៏ចូលចតទូកអែបខឿនដៃ ដែលរចនាដោយស្លឹកទន្សែនៅមុខវត្តជ្រយ ហើយរៀងពីទូកតម្រង្គាការដោយបាតាបង្ហូសទៅវត្តកំពង់ហ្លួង សឹងមានក្មេងសៀមនិងពួកយុវជនឈរលើកដៃគំនាប់ជាប់គ្នាជាលំដាប់រៀងទៅ ដល់វត្តកំពង់ហ្លួងចូលទៅក្នុងទីប្រជុំថ្វាយបង្គំសំ-ណេះសំណាលនឹងភិក្ខុសង្ឃ ហើយថ្វាយការសុំព្រះពុទ្ធរូបបុរាណក្នុងវត្តកំពង់ហ្លួងចំពោះលោកគ្រូឃី-នុតជាចៅអធិការវត្តនោះ ទើបលោកអ្នកឧកញ៉ាមហាវិទ្យាធិបតី (ទាស-ណាល់) ប្រគេនគ្រឿងឥស្សរិយយស

ឈ្មោះអស្សរិទ្ធ (ម៉ៃដយ៍សឹកល័យ៉េ) ក្រុមកម្ពុជា ចំពោះលោកត្រឹយ-នុត ចៅអធិការវត្តកំពង់ហ្លួង ព្រមទាំងសំពត់ទេសឯក ២ ផាប់ ឈើគូស ១០ ហោទីងសៀវភៅធម៌ជាច្រើនទៀតផង រួចហើយទើបលោកឱ្យឃុំ-ប៊ុន អគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ បំពាក់គ្រឿងឥស្សរិយយសឈ្មោះមុនីសារគុណ ចំពោះលោកម៉ុ-ឈឹម មេឃុំអន្ទរពុរ ព្រមទាំងឱ្យឈើគូស ១ ហោផង ក្រៅពីនេះឃើញមានប្រគេនសំពត់ទេសឯក, ឈើគូសនិងសៀវភៅធម៌ខ្លះចំពោះលោកគ្រូចៅអធិការវត្តជ្រៃរូបហើយ ទើបព្រះសង្ឃសូត្រជយន្តោចំរើនពរជ័យមង្គលចប់ហើយទើបចេញពីទីប្រជុំ ចូលទៅទស្សនាមើលព្រះពុទ្ធរូបដែលដាក់តាំងនៅក្នុងទីធ្លាព្រះពុទ្ធរូប ក្នុងវិហារវត្តកំពង់ហ្លួងរួចស្រេចទើបត្រឡប់ទៅពិសារភោជនាហារឯសាលាវត្តជ្រៃរូបវិញ ដល់ម៉ោង ២ រសៀលត្រឡប់ពីវត្តជ្រៃរូបអញ្ជើញទៅវត្តកំពង់ហ្លួងទៀតដើម្បីទស្សនា-ការតួយុវនៃហែលទឹកនិងទូកង ២ គូ ប្រណាំងគ្នាដល់ម៉ោង ៤ រសៀលទើបឈប់ ហើយព្រះអង្គម្ចាស់ចៅហ្វាយខែត្រតាកែវ បែកផ្អាំងជាប្រាក់ដល់ពួកហែលទឹកនិងប្រណាំងទូក រួចហើយទើបអស់លោកធំៗចេញពីអន្ទរពុរនៅវេលាម៉ោង ៥ រសៀល ក្រោយទូកកំពង់ ១ ដែលបេនាភោយស្លឹកឈើមានលំអផ្សេងៗ សំដៅទៅសាលាស្រុកព្រៃល្វាខាងរថយន្តនៅចាំទទួលក្នុងទីនោះស្រេចការបុណ្យត្រឹមប៉ុណ្ណេះ ។

ក្នុងវេលាល្ងាចថ្ងៃ ១២ សេបតេមប្រ៍នោះលោកមេឃុំៗ អង្គរបុរីនិង ឧបាសកខ្លះជំនុំគ្នានិងនិមន្តព្រះសង្ឃសូត្រព្ធមន្តក្នុងវេលាយប់នោះព្រឹកនិមន្តព្រះសង្ឃឆាន់ជាកិច្ចបង្ហើយបុណ្យតទៅទៀត  ព្រោះកាលដែលជួបជុំធ្វើបុណ្យថ្ងៃ ១៤ នោះធ្វើតាមរបៀបរាជការ យើងរវល់គ្នាពុំទាន់បានគោរពប្រណិប័តន៍ព្រះពុទ្ធរូបជូនដំណើរឲ្យសមគួរនៅឡើយ  ចំណែកខ្លួនខ្ញុំក៏បានចូលទៅក្នុងវិហារដើម្បីស្តាប់ព្រះសង្ឃសូត្រព្ធមន្តជាមួយនឹងលោកមេឃុំក្នុងវេលាយប់នោះដែរ  ប៉ុន្តែចំណែកឧបាសក-សិកាពុំសូវឃើញទៅច្រើនទេ  មានចំនួនប្រហែល ២០ នាក់ប៉ុណ្ណោះ  ហើយច្រើនតែស្រីៗផង ឯលោកគ្រូចៅអធិការកាលដែលឮដំណឹងថារាជការនឹងប្រគេនម៉េដៃយ ១ លោកពុំមានព្រះទ័យត្រេកអរត្រូវការនឹងចង់បានប៉ុន្មានទេ  ប៉ុន្តែដល់បានឃើញរូបម៉េដៃយយកមកពិនិត្យមើលរឿយៗក៏កើតមានឆន្ទៈជាប់ចិត្តស្រឡាញ់ឡើង  ថែមទាំងវេលាដែលខ្ញុំចូលទៅលេងនឹងលោកៗ បានឲ្យខ្ញុំមើលសេចក្តីក្នុងក្រដាសសញ្ញាប័ត្រឲ្យស្តាប់ លុះឮសេចក្តីក្នុងសញ្ញាប័ត្រមានពាក្យថា . . . ព្រះករុណាជាម្ចាស់ជីវិតលើត្បូង ទ្រង់សព្វព្រះរាជហឫទ័យទ្រង់ព្រះរាជទានគ្រឿងឥស្សរិយយស . . .ដោយមានគុណបំណាច់ក្នុងរាជការ  ក៏រឹតតែមានចិត្តជ្រះថ្លាច្រើនឡើង ហើយឲ្យខ្ញុំមើលជាញយៗ ដើម្បីឲ្យពួកឧបាសក-សិកាដែលមកទាំងក្រោយបានស្តាប់ផង  ហើយលោកមានថេរដីកាប្រាប់ពួកឧបាសក

តាំងប៉ុន្មានថា បើព្រះករុណាម្ចាស់ជីវិតមានព្រះរាជឧង្ការប្រាប់ត្រា ច្បាស់មកយ៉ាងនេះហើយ យើងនឹងរង់ចាំព្រះឧង្ការពុំព្រមឲ្យព្រះពុទ្ធរូប ឯណាបាន ហើយបញ្ជាញរូបម៉ៃដែយឲ្យមើលឃើញគ្រប់គ្នាដល់វេលា ដែលលោកនិមន្តចូលទៅសូត្រព្រះធម៌ក្នុងវិហារជួបជុំឧបាសក-សិកាក្នុង យប់ថ្ងៃ ១២ សេបតម្ប៍នោះ លោកក៏ពាក់ម៉ៃដែយនោះជាប់នឹងជា-ក្រាបទៅផងដែរ ។

វត្តកំពង់ហ្លួងនេះបានពិនិត្យទៅឃើញថាប្រកាន់តាមទំនៀមទម្លាប់ ច្រើនណាស់នៅឡើយ ឯលោកគ្រូ ឃ៉-នុក ចៅអធិការវត្តនោះ លោកកាន់ទន្ដឹកនឹងតែងណាស់ ខ្ញុំពួកអ្នកស្រុកអន្ដរបុរីនិយាយប្រាប់ថា កាលពីដើមលោកកាន់វត្តប្រតិបត្តិ ១ ឆ្នាំស្រង់ទឹកតែម្ដង តទ្ទងមកសព្វ ថ្ងៃនេះលោកបន្ធូរបន្ថយច្រើនណាស់ ហើយនៅកើន ១ ខែ ២ ខែស្រង់ ពីកម្ដង បើសិនជាយ៉ាងនោះពិតមែនគួរឲ្យអស្ចារ្យណាស់ ព្រោះមើល ទៅសាច់លោកក៏ហើយឡើងរលើប ជាត់ទ្រលុកទ្រលន់ពុកមាត់ពុក ចង្កាលោកទ្រើនទុកវែងៗ លោកជាអ្នកស្លូតស្លូតភាពមានមេត្តាករុណា ដល់អ្នកស្រុកទាំងក្មេងវត្តណាស់ ព្រមទាំងសត្វឆ្កែឆ្មាជាដើមដែលនៅ ក្នុងវត្តទៀតផង លោកមានពុទ្ធដីកាម្ដងៗ ទំនងដូចជាកំហុតៗ មិនអស់ ហើយធ្វើឲ្យអ្នកស្ដាប់ស្គាល់ព្រះទ័យលោកមិនអស់ទេ ប៉ុន្តែរបៀបរៀប ចំវត្តអារាមវិហារកុដិសាលាពុំបានរៀបរយស្អាតល្អទេ។ ដោយអំណាច

មេឃុំទិនសេញ្ញប៉ុស្តិ៍ ខំប្រឹងខ្នះខ្នែងរៀបចំក៏បានទៅជាទីវត្តមានរបៀប ករុបត្តិបឡើង បើតាមព្រះទ័យរបស់លោកគ្រូចៅអធិការមិនចង់រៀប បំរើរុះគ្រឿងដែលណែលរបស់លោកគ្រូព្រះសភាមុនទេ ឯធម៌វិន័យសេចក្តី ប្រតិបត្តិទៀតលោកបាននិយាយទៅខ្ញុំថា វត្តអាត្មាមិនទាន់បានឲ្យរៀន សូត្រធម៌វិន័យប្រែប្រួលតាមសម័យដូចគេនៅឡើយទេ ក្រែងតែឥត អំពីអាត្មាទៅ ។

វត្តកំពង់ហ្លួងនេះ ប្រសិនបើលោកខំប្រឹងខ្នះខ្នែងតាក់តែងរៀបចំឲ្យ មានរបៀបល្អឡើង មុខជានឹងទៅជាវត្តស្អាតស្អំបំផុតរបៀងមួយល្អ ណាស់ ព្រោះវត្តនេះតាំងនៅចំផ្លូវថ្នល់ពីសាលាស្រុកពញាឮទៅផង ចំកំពង់ផ្លូវស្ទឹងទៅក្រោយផ្ទាំងដែលហៅថាកំពង់ហ្លួងផង មានវ៉ានង គួរឲ្យអ្នកពាណិជ្ជការធំ-តូច ឬអ្នកដំណើរតាំងពួងចូលទៅសំណាក់អាស្រ័យ ម្តង ៗ ជាទីសប្បាយណាស់ ប៉ុន្តែសព្វថ្ងៃនេះអ្នកពាណិជ្ជការធំ-តូចចូលទៅ អង្គរបុរីម្តង ៗ ច្រើនតែបង្ហួសទៅសំណាក់អាស្រ័យនៅឯវត្តផ្សេងទៅ វិញ ព្រោះវត្តនោះសប្បាយជាទីពេញចិត្តដល់អ្នកពាណិជ្ជការដោយលោក គ្រូចៅអធិការវត្តនោះប្រសប់រៀបចំទីវត្តកុដិសាលាវិហារឲ្យមាន របៀបរៀបរយស្អាតល្អ បើមានពួកអ្នកពាណិជ្ជការឬអ្នកដំណើរណាចូល ទៅលោករមែងធ្វើបដិសណ្ឋារៈតាមសមគួរដល់សមណភាពល្អឲ្យគេ ស្រឡាញ់រាប់អានលោក ឯធម៌វិន័យសេចក្តីប្រតិបត្តិក៏នៅជារបៀប

បុណ្យណាដែរ ប៉ុន្តែកិច្ចសាមណេរនិងក្មេងមានរបៀបរៀបរយហើយគោរពខ្លាចលោកណាស់ ឯខាងការរៀនសូត្រលោកបានបង្កើតឲ្យមានសាលាបង្រៀនអក្សរខ្មែរនិងបារាំងមួយហើយ លោកនិយាយនឹងខ្ញុំថានឹងខំ-ប្រឹងបង្កើតឲ្យមានសាលាសំណាក់សម្រាប់អ្នកធំ ៗ និងបង្កើតឲ្យមានគ្រឿងប្រដាប់វិធីហាត់ប្រាណសម្រាប់ពួកយុវជននិងក្មេងសាលារៀនទៀតផង ដែលលោកនិយាយទាំងប៉ុន្មានគួរឲ្យចូលចិត្តនិងកោតលោកពេកណាស់ ៗ

## អំពីយកទ្រនាប់បល្ល័ង្កនៅភ្នំបាខេងតទៅទៀត

លុះព្រឹកឡើងថ្ងៃ ១៣ សេបតំប្រ៍ ខ្ញុំមិនបាននៅមើលអ្នកស្រុកចាត់ចែងប្រគេនចង្ហាន់លោកទេ ព្រោះប្រញាប់នឹងត្រឡប់ទៅយកបល្ល័ង្កនៅភ្នំបាខេងដែលសល់នៅទ្រនាប់ខាងក្រោមមិនទាន់បានយកដែលមានទំ-ហំ ៤ ជ្រុង ៗ ជ្រុង ១ ម៉ែ ៩០ កំពស់ ០ ម៉ែ ៣០ តទៅទៀត បំណែកពួកជីវិស្វកម្មក្រសួងសាធារណការតាកែវ ដែលទៅជួយចាត់ចែងអន្ទង់យករូបនឹងបល្ល័ង្កពីថ្ងៃមុនទាំងប៉ុន្មានបានអនុញ្ញាតពីលោកឡឺវេស៊ុំផងតែនឹងព្រះបាទម្ចាស់ហៅហ្វាយទៃត្រតាកែវឲ្យឈប់ធ្វើត្រឡប់ទៅតាកែវវិញតាំងពីល្ងាចថ្ងៃ ១២ នៅតែពួកខ្ញុំឲ្យទៅតាត់ការយកតទៅទៀត បំណែកខ្ញុំនិងលោកអ៊ុក-សេន ក៏នាំពួកគូលីទៅដាក់យកទ្រនាប់បល្ល័ង្កនោះពីលើភ្នំបាខេងមកដោយប្រើរបៀបផ្សេងពីក្រសួងសាធារណការដែល

បាត់ការមុន ប៉ុន្តែដោយហេតុថាបល្ល័ង្កនោះធ្លាក់ជា ២ កំណាត់ពាក់កណ្តាល ស្មើគ្នាក៏ស្រាលណាយនឹងធាក់ចុះមកជាន់មុនបន្តិចតែ ២ ថ្ងៃប៉ុណ្ណោះ គឺ វេលាម៉ោង ៨ ល្ងាចថ្ងៃ ១៤ សេបតេមប្រ៍ បានធាក់កន្ទុកនាំទៅទុកនៅ អន្តរពុំជាស្រេច ប៉ុន្តែធាក់កន្ទុក ១ ដែលដួលក្រោយទៀតដោយទូក មុនអស់ចំណុះនឹងធាក់ទៅទៀតពុំបាន ឯរបស់ដែលយកពីក្នុងបាទេពមក ក្នុងវេលានោះគឺ៖ បល្ល័ង្កធ្វើជា ២ កំណាត់ៗ ខាងលើធ្វើជាស្ពានព្រោណី ផ្ទះមាលោនី ១, ព្រះពុទ្ធរូបទង់ក្អែន ៣ កំណាត់ ១ ។ ឯការយក បល្ល័ង្កនៅក្នុងបាទេពនេះពុំមានរឿងអ្វីគួរនិយាយទេ ព្រោះនៅលើក្នុងមាន តែតាចាស់ម្នាក់ជាតិយួនអាយុ ៧០ ឆ្នាំចាំរក្សាហើយមិនជាត្រូវការដោយ បល្ល័ង្កនោះផង ១ ទៀតលើក្នុងនោះជាវត្តពួកគេជាយដែលចុះចោលយូរ ហើយ ប៉ុន្តែមានរបស់ដែលគួរឲ្យស្តាយនោះដោយក្រសួងសាធារណ-ការបាត់ការដាក់បល្ល័ង្ក (ស្ពានព្រោណី) ធ្វើឲ្យខូចខ្ទេចខ្ទី ដល់ផណ្តើរ ដែលឡើងទៅលើក្នុងនោះអស់ជាច្រើន ហាក់ដូចជាមិនគិតដល់ការឡើង ចុះតទៅទៀត ។

## អំពីយកព្រះពុទ្ធរូបវត្តកំពង់ហ្លួង (អង្គរបុរី)

កាលពីថ្ងៃមុនខ្ញុំបានចូលទៅជួបលោកគ្រូចៅអធិការវត្តកំពង់ហ្លួង និងជំទបលោកមេឃុំផងថា ដល់ថ្ងៃ ១៧ សេបតេមប្រ៍ ត្រូវនឹងថ្ងៃបុណ្យ

(មានត)

ព្រះគ្រូមុនីសោភ័ណ សោម-ឡុច

ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ រៀបរៀង

(តមកនិងចប់)

## អំពីការសង្គ្រោះគ្នាក្នុងវេលាមានទុក្ខ

ក្នុងលោកនេះ មនុស្សទាំងអស់ ទោះប្រុសក្តី ស្រីក្តី ក្មេងក្តី ចាស់ក្តី រមែងប្រកបដោយទុក្ខច្រើន សុខតិច កម្រមាននរណានឹងរួចផុតអំពីទុក្ខបានឡើយ កាលបើត្រូវទុក្ខជាទម្ងន់ណាមួយមកបៀតបៀនម្តងៗ ហើយក៏ភ័យកិតតក់ស្លុតញាប់ញ័រ ដូចជាស្លឹកឈើដែលត្រូវខ្យល់បក់ ទំរែស្រែកអំពាវនាវគេឲ្យជួយ នេះព្រោះតែជីវិតមួយនាំឲ្យព្រួយលំបាកដល់គេឯង ប្រសិនបើជនជាគ្នីគ្នាមានទុក្ខធុរៈគ្រោះថ្នាក់ជាទម្ងន់ហើយ ពួកមិត្តសំឡាញ់មិនត្រូវធ្វើគោះតើយព្រងើយទេ គឺត្រូវតែឈឺឆ្អាលយកចិត្តទុកដាក់ជួយដោះទុក្ខគ្នា ឲ្យបានធាប់ស្រាកទាន់ពេលវេលា ទោះបីរស់ស្លាប់យ៉ាងណា ក៏ត្រូវតែជួយសង្គ្រោះគ្នាឲ្យពេញបន្ទុក កុំមើលបំណាំ កុំរត់ចោលគ្នា ទើបបានហៅថាស្រឡាញ់កប់អានគ្នី ដោយចិត្តស្មោះត្រង់មែន ៗ

មួយយ៉ាងទៀត ក្នុងលោកនេះ មានជនខ្លះស្រឡាញ់កប់អានគ្នា ត្រង់តែទ្រព្យរបស់ដែលឲ្យគ្នាទៅវិញទៅមកប៉ុណ្ណោះ ពេលណាគ្នាមានទុក្ខធុរៈជាទម្ងន់ ក៏រេះគេចបាត់ លែងនឹកនា លែងជួយ លែង

វាសនោះ ជនបែបនេះមិនត្រូវយកធ្វើជាមិត្តសំឡាញ់ទេ ។ ការដែលរាប់អានស្រឡាញ់គ្នាដោយស្មោះត្រង់ល្អពិតប្រាកដនោះ មិនមែនបានតែត្រឹមឲ្យរបស់អ្វីៗ ដល់គ្នាទៅវិញទៅមកប៉ុណ្ណោះទេ គឺសំដៅយករហូតដល់គ្នាមានទុក្ខធុរៈគ្រោះថ្នាក់យ៉ាងធ្ងន់ ស្ទើរតែនឹងក្សិណក្ស័យជីវិត ហើយបេះគិតគូររកឧបាយជួយដោះទុក្ខគ្នាបាន យ៉ាងនេះឯង ទើបបានហៅថា រាប់អានស្រឡាញ់គ្នា ដោយចិត្តស្មោះត្រង់ពិតមែន រឿងនេះត្រូវគ្នានឹងភាសិតបុរាណដែលលោកបានពោលទុកមកថា "ដឹងគ្នាទាន់គ្រាក្រ សម្បូរល្អទាន់ខែកត្តិក" ពាក្យនេះមិនចាំបាច់អធិប្បាយទុកឲ្យពួកលោកអ្នកមានបញ្ញាទាំងឡាយពិចារណាមើលចុះ ។ ឥឡូវនេះទៅ យើងសូមនាំនិទានមកដាក់បន្ទាប់ចុះសេចក្ដី ដើម្បីគ្រាន់បានជាមេត្តចិត្តរបស់អស់លោកអ្នកគ្រប់គ្នា ។

## អំពីរឿងសត្វបីប្អូនជួយសង្គ្រោះគ្នា

សូមដំណាលរឿងនោះ ដោយសង្ខេប តាមសេចក្ដីក្នុងគម្ពីរ-ជាតកទុកនិបាតថា "ក្នុងអតីតកាលកន្លងទៅហើយ គ្រានោះ មានសត្វប្រើស ១ អណ្ដើក ១ បក្សីត្រសក់ ១ សត្វទាំង ៣ នេះជាសំឡាញ់នឹងគ្នា នៅអាស្រ័យក្នុងព្រៃហិមពាន្ត អណ្ដើកនៅក្នុងស្រះ ប្រើសទៅក្នុងព្រៃក្បែរស្រះនោះ ត្រសក់នៅលើចុងឈើក្បែរស្រះនោះដែរ ។ ក្នុងសម័យមួយ មានព្រានម្នាក់ដើរស្វែងរកបាញ់សត្វក្នុងព្រៃ បាន

ប្រទះឃើញស្នាមជើងប្រើសចុះផឹកទឹកស្រះនោះថ្មីៗ ក៏យកអន្ទាក់ព្រ័ត្រ ៣ ធ្នង់ទៅដាក់ក្បែរកំពង់ទឹកនោះ លុះដល់បឋមយាមក្តី ប្រើសនោះចុះទៅផឹកទឹក ក៏ជាប់ក្នុងអន្ទាក់នោះប្រាសចាកមិនរួច ក៏យកគិតខ្លាំងពេកណាស់ ក៏ស្រែកសម្រែកយ៉ាងខ្លាំងឮដល់ទៅអណ្ដើកនិងក្អែ-កកជាសំឡាញ់ សត្វទាំងពីរនោះក៏បានមកចួបជុំគ្នាគិតរកឧបាយជួយដោះ ឯក្អែកកនិយាយទៅនឹងអណ្ដើកថា "នែអណ្ដើក ឥឡូវប្រើសសំឡាញ់យើងមានគ្រោះថ្នាក់ជាប់អន្ទាក់គេហើយ តើឯងគិតដូចម្ដេច? អណ្ដើកថា "អញពាល់តែគិតមិនដឹងគិតដូចណាទេវើយ" ក្អែកថា "បើដូច្នោះ សំឡាញ់ឯងសុខចិត្តធ្វើតាមអញឬទេ" អណ្ដើកថា "បើសំឡាញ់ឯងនិយាយត្រូវ អញធ្វើតាម បើនិយាយខុស អញមិនធ្វើតាមទេ" ក្អែកថា "ឯងចាំស្ដាប់ចុះ អញប្រាប់ឧបាយឲ្យយ៉ាងស្រួលថា អណ្ដើកឯងមានធ្មេញរឹងប៉ុនគ្រាន់បើ អើចូរឯងទៅខាំខ្សែអន្ទាក់នោះចុះ ឯខ្លួនអញគ្មានធ្មេញទេ មានតែចំពុះ ព្រោះហេតុនោះ ខាងឯធ្វើដំណើរមិនឲ្យព្រានមកដល់ទាន់ ស្រេចលើរូបអញទាំងអស់ តើឯងយល់ព្រមឬទេ?" អណ្ដើកថា "អើឯងគិតនេះពេញជាត្រូវណាស់ហើយ អញឥតយល់ទាស់ទេ ប៉ុន្តែថប់ក្រែងចួនជាខាំខ្សែអន្ទាក់នោះទៅកក្រដាច់ក្រ-ឲបើក ហើយស្រាប់តែពេលព្រាននោះមកដល់ថ្មើរ ខ្លួនអញជាអណ្ដើកម្ទះជានឹងស្លាប់ក្នុងកណ្ដាប់ដៃព្រាននោះមិនខានឡើយ ក្អែកថា

សំឡាញ់ឯងខំប្រឹងប្រែងទៅចុះ កុំរួញរា ពោះបើមិនសម្រេចដូចប្រាថ្នា ក៏គង់តែការនោះបានធូរខ្លះមិនខាន" អណ្តើកនោះក៏ព្រមធ្វើតាមហើយ ក៏ដើរទៅខាំខ្សែអន្ទាក់នោះ ៗ ចំណែកខាងក្អែក ក៏ហើរសំដៅទៅផ្ទះព្រាន លុះទៅដល់ក៏ទំលើចុងឈើក្បែរផ្ទះព្រាននោះ ដើម្បីឃ្លាំចាំមើលព្រាននោះគេចេញទៅតាមផ្លូវណា ៗ លុះវេលាបច្ចូសសម័យ ព្រានក៏ភ្ញាក់អំពីដំណេក ក្រោកឡើងលុបមុខមាត់រួចស្រេចបាច់ហើយក៏លូកដៃចាប់ យកលំពែងចេញដើរតាមទ្វារខាងកើតផ្ទះ ដើម្បីនឹងទៅមើលអន្ទាក់ ឯក្អែកឃើញហើយក៏ហើរស្កាត់ឆាបមុខមាត់ព្រាននោះ មិនឲ្យធ្វើដំណើរទៅបានឡើយ ព្រានកើតមួម៉ៅក្តៅចិត្តក៏និយាយស្តីថា "អាសត្វកាឡកណ្ណី ហេតុអីបានជាឯងហើរមកស្កាត់មុខអញទំនងជានឹងមានគ្រោះថ្នាក់ដល់អញទេដឹង ឬមួយយ៉ាងណា"? ថាដូច្នោះហើយក៏ត្រឡប់វិលទៅដេកឯផ្ទះវិញ លុះដេកមួយស្របក់ភ្ញាក់ក្រោកឡើងទាញលំពែងកាន់ដើរចេញតាមទ្វារខាងលិចផ្ទះវិញ ឯក្អែកឃើញហើយក៏ហើរទៅស្កាត់ឆាបមុខមាត់ព្រាននោះទៀត ព្រានក្តៅចិត្តខ្លាំងពេកដើរទៅមិនរួច ក៏ត្រឡប់វិលទៅដេកឯផ្ទះម្តងទៀត ៗ ឈប់ស្ទើរប៉ុណ្ណោះ ខាងនិយាយអំពីអណ្តើកឯណោះវិញ កាលក្រោយក្អែកមកនោះ អណ្តើកក៏ខំប្រឹងខាំខ្សែអន្ទាក់ជាប់ពាល់តែឈាមធ្មេញអស់ដាច់បានតែត្រឹម ២ ធ្នុង នៅសល់ ១ ធ្នុង ក៏ទៀយហាក់អស់កំឡាំងនឹងខំប្រឹងខាំត

ទៅទៀតមិនបាន ឈើខ្ទន់ប្រាណខ្លាំងពេកក៏ក្រាបដេកក្បែរអន្ទាក់នោះ ឯង ៗ លុះដល់វេលាព្រះអាទិត្យរះភ្លឺច្បាស់មេឃា ព្រានភ្ញាក់ក្រោកឡើងម្ដាប្រញាប់យកលំពែងកាន់ដើរចេញអំពីផ្ទះ ប្រាថ្នានឹងទៅមើលអន្ទាក់ម្ដងទៀត ៗ វេលានោះក្អែកក៏ឈប់ហើរទៅចាំមុខមាត់ព្រានទៀតហើយ ព្រោះគិតថាពេលថ្មើរណេះ សូមអណ្ដើកខាំខ្សែអន្ទាក់ដាច់អស់ហើយ ក៏ហើរទៅមុខព្រានដោយឆាប់ប្រញាប់ លុះទៅដល់ហើយទើបសួរទៅអណ្ដើកថា រួយសំឡាញ់ ឯងខាំខ្សែអន្ទាក់ដាច់អស់ហើយឬនៅ មិនទាន់បានដាច់អស់ទេសំឡាញ់ដាច់បានតែ ២ ធ្នង់ នៅសល់ ១ធ្នង់ទៀត ឥឡូវឈាមហូរចេញអំពីធ្មេញអំពីមាត់អញ ៗ ខំប្រឹងខាំតទៅទៀតមិនបានទេ ណាមួយនឿយព្រួយអស់កំឡាំងពេកណាស់ អញឈប់សម្រាកបន្តិចសិន សំឡាញ់ឯងឈប់សម្រាកឯណាក៏បាន មិនបានទេ ព្រោះព្រានគាត់មកកាន់តែជិតដល់ហើយ ក្រែងក់ស្លាប់ទាំងអស់គ្នាហ្នឹងទៅ ស្លាប់ក៏ស្លាប់ចុះមិនដឹងធ្វើម៉េចទេ ឲ្យអញខាំខ្សែអន្ទាក់ទៀត ឯណាក៏បាន បើគ្នាឈាមធ្មេញអស់ទៅហើយ បើអាសំឡាញ់ឯងគ្រាន់បើ មុចក៏មិនទៅលបបន្តិចមើល ៗ សត្វទាំងពីរកំពុងតែនិយាយជជែកគ្នា មិនយូប៉ុន្មាន ក៏ស្រាប់តែលេចព្រាននោះទៅដល់ ព្រាននោះក្រឡេកមើលទៅឃើញប្រើសជាប់អន្ទាក់ដូច្នោះ ក៏កាន់លំពែងស្ទុះទៅប្រុងនឹងចាក់ ប្រើសភ័យពេកណាស់ក៏ប្រឹងលើក

ជើងក្អែក ខ្សែអន្ទាក់ក៏ដាច់អស់ឬពោះពេប ហើយបោលរះគេចចូលទៅក្នុងព្រៃ ព្រានក៏ទឹកតូចចិត្តពេក ក្រឡេកមើលទៅឃើញអណ្តើកដេកក្បែរទំនោះ ក៏ស្ទុះទៅចាប់រើសដាក់ក្នុងស្បោងហើយយកទៅពាក់លើដង្គត់ឈើ ឯប្រើសនោះងាកមើលមកក្រោយវិញ ឃើញព្រានកំពុងតែចាប់អណ្តើកដាក់ក្នុងស្បោង យកទៅពាក់លើដង្គត់ឈើដូច្នោះ ក៏មានចិត្តអាណិតពេកណាស់ គិតថា ទុំសំឡាញ់អញ កាលអញមានទុក្ខទោស បេះជួយដោះទុក្ខអញបាន ឥឡូវសំឡាញ់អញមានទុក្ខត្រូវតែអញជួយដោះទុក្ខគេវិញ គិតដូច្នោះហើយក៏ធ្វើហាក់ដាំបោលតិចៗ ព្រានក៏រត់ដេញតាមប្រើសៗ បោលចូលក្នុងព្រៃជ្រៅ ព្រានតាមជ្រុលទៅខាងមុខ ប្រើសវះគេចមកខាងក្រោយបោលវិលត្រឡប់មករង ស្បោងនោះដាច់ធ្លុះធ្លាយធ្លាក់អណ្តើកមកដល់ដី ហើយនាំយកអណ្តើកចេញរះគេចចូលទៅក្នុងព្រៃបាត់ លុះព្រាននោះតាមរកប្រើសមិនឃើញក៏ត្រឡប់វិលមកវិញ ដល់មកកន្លែងហើយក្រឡេកមើលទៅស្បោងលើដង្គត់ឈើ ក៏ធ្លាក់ដាច់ដាចអស់ ទាំងអណ្តើកក៏បាត់រកមើលមិនឃើញក៏កើតតោមនស្សអន់ចិត្តវិលត្រឡប់ទៅផ្ទះវិញ ។

គ្រាក្រោយមក សត្វទាំង៣ ក៏បានមកជួបជុំគ្នា ស្រឡាញ់កប់អានគ្នា គ្រាតែអស់ជីវិតរៀងខ្លួន ។

ចប់រឿងការសង្គ្រោះគ្នា ប៉ុណ្ណេះ ។

# ប្រវត្តិព្រះពុទ្ធ ៧ ព្រះអង្គ[១]

## ១- ព្រះពុទ្ធវិបស្សី

កប់អំពីកប្បនេះថយក្រោយទៅបាន ៩១ កប្ប ព្រះពុទ្ធវិបស្សី ទ្រង់បានត្រាស់ក្នុងលោក ព្រះអង្គជាខត្តិយជាតិ ជាកោណ្ឌញ្ញគោត្រ មានព្រះជន្មាយុ ៨ ម៉ឺនឆ្នាំ ត្រាស់ក្រោមដើមបាដលិព្រឹក្ស (ដើមផ្ទៀង) មានគូសាវកឈ្មោះខណ្ឌ ១ តិស្ស ១ មានសាវកសន្និបាត ៣ ដង គឺ សាវកសន្និបាតមានភិក្ខុ ៦ លាន ៨ សែនរូបម្ដង សាវកសន្និបាតមានភិក្ខុ ១ សែនរូបម្ដង សាវកសន្និបាតមានភិក្ខុ ៨ ម៉ឺនរូបម្ដង សាវកសន្និបាតទាំង ៣ ដងនេះសុទ្ធតែជាព្រះខីណាស្រពទាំងអស់ មានភិក្ខុឈ្មោះអសោកជាឧបដ្ឋាក ព្រះបិតាជាព្រះរាជាទ្រង់ព្រះនាមពន្ធុម: ព្រះមាតាទ្រង់ព្រះនាមពន្ធុមតីជាព្រះជនេត្តី (ព្រះមាតាបង្កើត) នគរឈ្មោះពន្ធុមតី ។

## ២- ព្រះពុទ្ធសិខី

កប់អំពីកប្បនេះថយក្រោយទៅបាន ៣១ កប្ប ព្រះពុទ្ធសិខី ទ្រង់បានត្រាស់ក្នុងលោក ព្រះអង្គជាខត្តិយជាតិ ជាកោណ្ឌញ្ញគោត្រ មានព្រះជន្មាយុ ៧ ម៉ឺនឆ្នាំ ត្រាស់ក្រោមដើមបុណ្ឌរិកព្រឹក្ស (ដើមស្វាយស) មានគូសាវកឈ្មោះអភិភូ ១ សម្ភវៈ ១ មានសាវកសន្និបាត ៣ ដង គឺមានភិក្ខុ ១ សែនរូបម្ដង មានភិក្ខុ ៨ ម៉ឺនរូបម្ដង មានភិក្ខុ ៧ ម៉ឺនរូបម្ដង សាវកសន្និបាតទាំង ៣ ដងនេះ សុទ្ធតែជាព្រះខីណាស្រព

---

១ ស្រង់យកអំពីសៀវភៅព្រះត្រៃបិដកខ្មែរ ភាគទី ១៦ ត្រង់មហាបទានសូត្រទំព័រ ២៩... ។

ទាំងអស់ មានភិក្ខុឈ្មោះខេមង្ករៈជាឧបដ្ឋាក ព្រះបិតាជាព្រះរាជាទ្រង់ព្រះនាមអរុណ ព្រះមាតាទ្រង់ព្រះនាមបភាវតី ជាព្រះជនេត្តិ នគរឈ្មោះអរុណវតី ។

## ៣- ព្រះពុទ្ធវេស្សភូ

រាប់អំពីកប្បនេះថយក្រោយទៅបាន ៣១ កប្ប ព្រះពុទ្ធវេស្សភូទ្រង់បានត្រាស់ក្នុងលោក ព្រះអង្គជាខត្តិយជាតិ ជាកោណ្ឌញ្ញគោត្រ មានព្រះជន្មាយុ ៦ ម៉ឺនឆ្នាំ ត្រាស់ក្រោមដើមសាលព្រឹក្ស (ដើមរាំងភ្នំ) មានគូសាវកឈ្មោះសោណៈ១ ឧត្តរៈ១ មានសាវកសន្និបាត ៣ ដង គឺមានភិក្ខុ ៨ ម៉ឺនរូបម្តង មានភិក្ខុ ៧ ម៉ឺនរូបម្តង មានភិក្ខុ ៦ ម៉ឺនរូបម្តង សាវកសន្និបាតទាំង ៣ ដងនេះ សុទ្ធតែជាព្រះខីណាស្រពទាំងអស់ មានភិក្ខុឈ្មោះឧបសន្តៈ ជាឧបដ្ឋាក ព្រះបិតាជាព្រះរាជាទ្រង់ព្រះនាមសុប្បតីតៈ ព្រះមាតាទ្រង់ព្រះនាមយសវតី ជាព្រះជនេត្តិ នគរឈ្មោះអនោមៈ ។

## ៤- ព្រះពុទ្ធកកុសន្ធ

ក្នុងកប្បនេះ ព្រះពុទ្ធកកុសន្ធបានត្រាស់ក្នុងលោក ព្រះអង្គជាព្រាហ្មណជាតិ ជាកស្សបគោត្រ មានព្រះជន្មាយុ ៤ ម៉ឺនឆ្នាំ ត្រាស់ក្រោមដើមសិរីសព្រឹក្ស (ដើមប្រែស) មានគូសាវកឈ្មោះវិធុរៈ១ សញ្ជីវៈ១ មានសាវកសន្និបាតតែម្តង មានភិក្ខុ ៤ ម៉ឺនរូប សុទ្ធតែជា

ព្រះខីណាស្រពទាំងអស់ មានព្រះភិក្ខុឈ្មោះវុឌ្ឍិជៈជាឧបដ្ឋាក ព្រះបិតាជាព្រាហ្មណ៍នាមអគ្គិទត្ត ព្រះមាតាជាព្រាហ្មណីនាមវិសាខា ជាព្រះជនេត្តិសម័យនោះ មានព្រះរាជាព្រះនាមខេមៈ នគរឈ្មោះខេមវតី ។

## ៥- ព្រះពុទ្ធកោនាគមន

ក្នុងកប្បនេះ ព្រះពុទ្ធកោនាគមនបានត្រាស់ក្នុងលោក ព្រះអង្គជាព្រាហ្មណជាតិ ជាកស្សបគោត្រ មានព្រះជន្មាយុ ៣ ម៉ឺនឆ្នាំ ត្រាស់ក្រោមដើមឧទុម្ពរព្រឹក្ស (ដើមល្វា) មានគូសាវកឈ្មោះភិយ្យោសៈ ១ ឧត្តរៈ ១ មានសាវកសន្និបាតតែម្ដង មានភិក្ខុ ៣ ម៉ឺនរូប សុទ្ធតែជាព្រះខីណាស្រពទាំងអស់ មានភិក្ខុឈ្មោះសោត្ថិជៈ ជាឧបដ្ឋាក ព្រះបិតាជាព្រាហ្មណ៍នាមយញ្ញទត្ត ព្រះមាតាជាព្រាហ្មណីនាមឧត្តរា ជាព្រះជនេត្តិសម័យនោះ មានព្រះរាជាព្រះនាមសោភៈ នគរឈ្មោះសោភវតី ។

## ៦- ព្រះពុទ្ធកស្សប

ក្នុងកប្បនេះ ព្រះពុទ្ធកស្សបបានត្រាស់ក្នុងលោក ព្រះអង្គជាព្រាហ្មណជាតិ ជាកស្សបគោត្រ មានព្រះជន្មាយុ ២ ម៉ឺនឆ្នាំ ត្រាស់ក្រោមដើមនិគ្រោធព្រឹក្ស (ដើមជ្រៃ) មានគូសាវកឈ្មោះតិស្សៈ ១ ភារទ្វាជៈ ១ មានសាវកសន្និបាតតែម្ដង មានភិក្ខុ ២ ម៉ឺនរូប សុទ្ធតែជាព្រះខីណាស្រពទាំងអស់ មានភិក្ខុឈ្មោះសព្វមិត្តជាឧបដ្ឋាក ព្រះបិតាជា

ព្រាហ្មណ៍នាមព្រហ្មទត្ត ព្រះមាតាជាព្រាហ្មណីនាមធនវតី ជាព្រះជនេត្តី សម័យនោះ មានព្រះរាជាព្រះនាមកិកី នគរឈ្មោះពារាណសី ។

## ៣- ព្រះពុទ្ធគោតម

ក្នុងកប្បនេះ ព្រះពុទ្ធគោតមបានត្រាស់ក្នុងលោក ព្រះអង្គជាខត្តិយជាតិ ជាគោតមគោត្រ មានព្រះជន្មាយុ ៨០ ឆ្នាំ ត្រាស់ក្រោមដើមអស្សត្ថព្រឹក្ស (ដើមពោធិ៍បាយ) មានគូសាវ័កឈ្មោះសារីបុត្ត ១ មោគ្គល្លាន ១ មានសាវ័កសន្និបាតតែម្តង មានភិក្ខុ ១ ពាន់ ២ រយ ៥០ រូប សុទ្ធតែជាព្រះខីណាស្រពទាំងអស់ មានភិក្ខុឈ្មោះអានន្ទជាឧបដ្ឋាក ព្រះបិតាជាព្រះរាជាទ្រង់ព្រះនាមសុទ្ធោទនៈ ព្រះមាតាទ្រង់ព្រះនាមមហាមាយា ជាព្រះជនេត្តី ព្រះនគរឈ្មោះកបិលវត្ថុ ។

ចប់

# អរិយសច្ចជាពុទ្ធភាសិត

បទទី ១

## សត្វលោកនិងចតុរារិយសច្ច

បើមិនដឹងច្បាស់នូវអរិយសច្ច នឹងធ្វើនូវទីបំផុតទុក្ខមិនបាន ។

ម្នាលភិក្ខុទាំងឡាយ! បុគ្គលណាមួយនិយាយថា: "ខ្ញុំមិនដឹងច្បាស់នូវសេចក្ដីពិតដ៏ប្រសើរគឺទុក្ខ, នូវសេចក្ដីពិតដ៏ប្រសើរគឺហេតុប្រជុំកើតឡើងនៃទុក្ខ, នូវសេចក្ដីពិតដ៏ប្រសើរគឺធម៌ជាគ្រឿងរំលត់ទុក្ខ, នូវសេចក្ដីពិតដ៏ប្រសើរគឺសេចក្ដីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខតាមសេចក្ដីពិតទេ, ប៉ុន្តែខ្ញុំនឹងធ្វើនូវទីបំផុតនៃសេចក្ដីទុក្ខ ដោយប្រពៃឲ្យបាន" សេចក្ដីនេះមិនមែនជាឋានៈ គឺមិនត្រឹមត្រូវតាមគន្លងធម៌ទេ ។ សេចក្ដីនេះគួរឧបមាដូចជាបុគ្គលណាមួយនិយាយថា: "ខ្ញុំមិនបាច់ធ្វើនូវគ្រឿងផ្ទះខាងក្រោម (ដូចសសរ រត បន្ទល់ជាដើម) ទុកជាមុនសិនទេ ប៉ុន្តែខ្ញុំនឹងសង់គ្រឿងផ្ទះខាងលើបាន" សេចក្ដីនេះមិនមែនជាឋានៈ គឺមិនត្រឹមត្រូវតាមទំនងយ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ! រីឯបុគ្គលណាមួយនិយាយថា: "ខ្ញុំមិនដឹងច្បាស់នូវសេចក្ដីពិតដ៏ប្រសើរគឺទុក្ខ នូវសេចក្ដីពិតដ៏ប្រសើរគឺហេតុប្រជុំកើតឡើងនៃទុក្ខ នូវសេចក្ដីពិតដ៏ប្រសើរគឺធម៌ជាគ្រឿងរំលត់ទុក្ខ នូវសេចក្ដីពិតដ៏ប្រសើរ គឺសេចក្ដីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខ តាមសេចក្ដីពិតទេ ប៉ុន្តែ

ខ្ញុំនឹងធ្វើនូវទីបំផុតនៃសេចក្តីទុក្ខ ដោយប្រពៃឲ្យបាន សេចក្តីនេះ
មិនមែនជាឋានៈ គឺមិនត្រឹមត្រូវតាមគន្លងធម៌យ៉ាងនោះដែរ" ។

ម្នាលភិក្ខុទាំងឡាយ! បុគ្គលណាមួយនិយាយថា: "ខ្ញុំគប្បីដឹងច្បាស់នូវសេចក្តីពិតដ៏ប្រសើរគឺទុក្ខ, នូវសេចក្តីពិតដ៏ប្រសើរគឺហេតុប្រជុំកើតឡើងនៃទុក្ខ, នូវសេចក្តីពិតដ៏ប្រសើរគឺធម៌ជាគ្រឿងរំលត់ទុក្ខ, នូវសេចក្តីពិតដ៏ប្រសើរគឺសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខ, តាមសេចក្តីពិត, ទើបខ្ញុំនឹងធ្វើនូវទីបំផុតនៃសេចក្តីទុក្ខ ដោយប្រពៃបាន" សេចក្តីនេះជាឋានៈ គឺត្រឹមត្រូវតាមគន្លងធម៌ ។ សេចក្តីនេះដូចជាបុគ្គលណាមួយនិយាយថា: "ខ្ញុំគប្បីធ្វើគ្រឿងផ្ទះខាងក្រោមទុកមុនសិន ទើបសង់គ្រឿងផ្ទះខាងលើ" សេចក្តីនេះជាឋានៈ គឺត្រឹមត្រូវតាមគន្លងធម៌យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ! រីឯបុគ្គលណាមួយនិយាយថា: "ខ្ញុំគប្បីដឹងច្បាស់នូវសេចក្តីពិតដ៏ប្រសើរគឺទុក្ខ នូវសេចក្តីពិតដ៏ប្រសើរគឺហេតុប្រជុំកើតឡើងនៃទុក្ខ នូវសេចក្តីពិតដ៏ប្រសើរគឺធម៌ជាគ្រឿងរំលត់ទុក្ខ នូវសេចក្តីពិតដ៏ប្រសើរគឺសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខ តាមសេចក្តីពិតទុកជាមុនសិន ទើបខ្ញុំគប្បីធ្វើនូវទីបំផុតនៃសេចក្តីទុក្ខ ដោយប្រពៃបាន សេចក្តីនេះជាឋានៈ គឺត្រឹមត្រូវតាមគន្លងធម៌ យ៉ាងនោះដែរ" ។ ម្នាលភិក្ខុទាំងឡាយ! ព្រោះហេតុនោះ អ្នកទាំងឡាយគប្បីធ្វើសេចក្តីព្យាយាម ដើម្បីឲ្យដឹងថា:

" នេះទុក្ខ ? នេះហេតុប្រជុំកើតឡើងនៃទុក្ខ ? នេះធម៌ជាគ្រឿងរំលត់ទុក្ខ ? នេះសេចក្ដីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខ ? ដូច្នេះបុះ ។

មហាវារៈ សំ. ១៩-៥៦៤-១៧៣៤

ព្រោះមិនដឹងច្បាស់នូវសេចក្ដីពិតដ៏ប្រសើរ ៤ ប្រការ បានជាសត្វលោកអន្ទោលទៅក្នុងពលវដ្ដសង្សារមិនឈប់ ។

ព្រះដ៏មានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយ ក្នុងទីនោះហើយត្រាស់ថា:

ម្នាលភិក្ខុទាំងឡាយ ! អ្នកទាំងឡាយក្ដី តថាគតក្ដី ដែលបេះតែត្រាច់ស្ដោត់ទៅ បេះតែអន្ទោលបេរិលវិលទៅ (ក្នុងពលសង្សារវដ្ដ) អស់កាលយូរដល់ម៉្លេះ ព្រោះតែមិនដឹងច្បាស់ មិនយល់នូវអរិយសច្ចសេចក្ដីពិតដ៏ប្រសើរ ៤ ប្រការ ។ បុះអរិយសច្ច សេចក្ដីពិតដ៏ប្រសើរ៤ប្រការ ដែលអ្នកទាំងឡាយនឹងតថាគត មិនដឹងច្បាស់ មិនយល់ នុះតើដូចម្ដេច ? ។ ម្នាលភិក្ខុទាំងឡាយ ? ព្រោះអ្នកទាំងឡាយក្ដី តថាគតក្ដី មិនដឹងច្បាស់ មិនយល់ នូវសេចក្ដីពិតដ៏ប្រសើរគឺទុក្ខ នូវសេចក្ដីពិតដ៏ប្រសើរគឺហេតុប្រជុំកើតឡើងនៃទុក្ខ នូវសេចក្ដីពិតដ៏ប្រសើរ គឺធម៌ជាគ្រឿងរំលត់ទុក្ខ នូវសេចក្ដីពិតដ៏ប្រសើរគឺសេចក្ដីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខ បានជាបេះតែត្រាច់ស្ដោត់ទៅ បេះតែអន្ទោលបេរិលវិលទៅ (ក្នុងពលវដ្ដសង្សារ)

អស់កាលយូរដល់ម៉្លេះដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ! អរិយសច្ច សេចក្តីពិតដ៏ប្រសើរទាំងឡាយនោះ តថាគតបានត្រាស់ដឹងហើយ បានឈ្វេងយល់សព្វហើយ ។ ភវតណ្ហា សេចក្តីប្រាថ្នាក្នុងភព តថាគតបានកាត់ផ្តាច់ផ្តិលអស់ហើយ កិរិយានាំទៅកាន់ភពថ្មីទៀតគឺអស់ប៉ុណ្ណឹងហើយ ឥឡូវនេះ តថាគតមិនមានភពថ្មីទៀតឡើយ ។

មហាវារៈ សំ. ១៩-៤០-១៦៩៩

ព្រះតថាគតមិនត្រាស់ដឹងក្នុងលោកត្រឹមណា សេចក្តីងងឹតសូន្យសុង នៃលោកនៅមានត្រឹមនោះ ។

ម្នាលភិក្ខុទាំងឡាយ! ព្រះចន្ទនិងព្រះអាទិត្យមិនកើតឡើងក្នុងលោកអស់កាលត្រឹមណា សេចក្តីប្រាកដនៃពន្លឺភ្លឺស្វាងដ៏ក្រៃលែង ក៏មិនមានអស់កាលត្រឹមនោះដែរ! ក្នុងកាលនោះមានតែសេចក្តីងងឹតអ័ព្ទសូន្យសុង ដូចសេចក្តីងងឹតនៃបុគ្គលកែកខ្វាក់ ថ្ងៃ ខែ បក្ស រដូវនិងឆ្នាំ ក៏មិនមានប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ! កាលណាព្រះចន្ទនិងព្រះអាទិត្យកើតឡើងក្នុងលោក កាលនោះ សេចក្តីប្រាកដឡើងនៃពន្លឺភ្លឺស្វាងរុងរឿងដ៏ក្រៃលែងទើបកើតប្រាកដឡើង, សេចក្តីងងឹតអ័ព្ទសូន្យសុងដូចសេចក្តីងងឹតនៃបុគ្គលកែកខ្វាក់ ក៏មិនមានក្នុងកាលនោះ ថ្ងៃ ខែ បក្ស រដូវ ឆ្នាំ ក៏បានប្រាកដឡើង; សេចក្តីនេះមានឧបមាយ៉ាងណា ។

ម្នាលភិក្ខុទាំងឡាយ! សេចក្ដីនេះមានឧបមេយ្យដូចគ្នាដែរថា ដរាបអស់កាលត្រឹមណា ព្រះតថាគតអរហំសម្មាសម្ពុទ្ធមិនត្រាស់ដឹងឡើងក្នុងលោក, អស់កាលត្រឹមនោះ សេចក្ដីប្រាកដនៃពន្លឺភ្លឺស្វាងរុងរឿងដ៏ក្រៃលែងក៏មិនកើតឡើង, ក្នុងកាលនោះមានតែសេចក្ដីងងឹតអ័ព្ទសូន្យសុន្ធដូចសេចក្ដីងងឹតនៃបុគ្គលកែកខ្វាក់ មិនមានការប្រាប់គ្នា, ការសំដែងពន្យល់, សេចក្ដីបញ្ញត្តិ, ការតាំងទុក, ការបើកបង្ហាញ, ការចែករំលែកឲ្យមានសេចក្ដីពក់ នូវសេចក្ដីពិតដ៏ប្រសើរទាំងឡាយ ៤ ប្រការនេះឡើយ, ម្នាលភិក្ខុទាំងឡាយ កាលណា ព្រះតថាគតអរហំសម្មាសម្ពុទ្ធត្រាស់ដឹងឡើងក្នុងលោក សេចក្ដីប្រាកដនៃពន្លឺភ្លឺស្វាងរុងរឿងដ៏ក្រៃលែងក៏កើតឡើង, ក្នុងកាលនោះ មិនមានសេចក្ដីងងឹតអ័ព្ទសូន្យសុន្ធ ដូចសេចក្ដីងងឹតនៃបុគ្គលកែកខ្វាក់, ក្នុងកាលនោះ ទើបមានការប្រាប់គ្នា, សំដែងពន្យល់, សេចក្ដីបញ្ញត្តិ, ការតាំងទុក, ការបើកបង្ហាញ ការចែករំលែកឲ្យមានសេចក្ដីពក់ នូវសេចក្ដីពិតដ៏ប្រសើរ ៤ ប្រការនេះឡើង ។

មហាវារៈសំ.១៩-៥៥៣-១៧២១

អរិយសច្ច ៤ ជាធម៌មិនប្រែប្រួល

ម្នាលភិក្ខុទាំងឡាយ! មានធម្មជាតិ ៤ យ៉ាង នៅតែទៀងដដែល មិនផ្លាស់ប្ដូរពីដដែល មិនប្រែប្រួលទៅជាយ៉ាងដទៃ ។ ធម្មជាតិ ៤

យ៉ាងនោះតើដូចម្តេច? ម្នាលភិក្ខុទាំងឡាយ! ធម្មជាតិទាំង ៤ យ៉ាងនោះគឺ: ទុក្ខនេះ ១, ហេតុប្រជុំកើតឡើងនៃទុក្ខនេះ ១ ធម៌ជាគ្រឿងរំលត់ទុក្ខនេះ ១ សេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខនេះ ១ នៅតែទឹងដដែល មិនផ្លាស់ប្តូរពីដដែល មិនចេះប្រែខុសទៅជារូបដទៃ ៗ ម្នាលភិក្ខុទាំងឡាយ! ធម្មជាតិទាំងឡាយ ៤ ប្រការនេះ នៅតែទឹងដដែល មិនផ្លាស់ប្តូរពីដដែល មិនចេះប្រែខុសទៅជារូបដទៃទេ ៗ ម្នាលភិក្ខុទាំងឡាយ! ព្រោះហេតុនោះ អ្នកទាំងឡាយគប្បីធ្វើសេចក្តីព្យាយាមដើម្បីឲ្យដឹងថា: "នេះទុក្ខ នេះហេតុប្រជុំកើតឡើងនៃទុក្ខ នេះធម៌ជាគ្រឿងរំលត់ទុក្ខ នេះសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខ" តែប៉ុណ្ណោះឯងចុះ ៗ

ឧបការៈ សំ.១៩-៥៣៩-១៦៩៣

សេចក្តីសុខដែលសត្វលោកគួរខ្លាច និងមិនគួរខ្លាច

ពាក្យនេះតថាគតបានពោលរួចហើយថា: "បុគ្គលគប្បីចេះវិនិច្ឆ័យសេចក្តីសុខ លុះចេះវិនិច្ឆ័យសេចក្តីសុខហើយ គប្បីប្រកបសេចក្តីសុខប៉ែកក្នុងសន្តានឲ្យរឿយៗទៅ ៗ ពាក្យដែលតថាគតពោលហើយនុ៎ះ តើព្រោះអាស្រ័យសេចក្តីដូចម្តេច? ម្នាលភិក្ខុទាំងឡាយ! កាមគុណមាន ៥ យ៉ាងគឺ: រូបដែលបុគ្គលគប្បីដឹងដោយភ្នែក សំឡេងដែលបុគ្គលគប្បីដឹងដោយត្រចៀក ក្លិនដែលបុគ្គលគប្បីដឹងដោយច្រមុះ

រសដែលបុគ្គលគប្បីដឹងដោយអណ្ដាត ផោដ្ឋព្វៈដែលបុគ្គលគប្បីដឹងដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពជាទីស្រឡាញ់ប្រកបដោយកាម ឈ្ពក់ក្នុងសេចក្ដីត្រេកអរ ។ ម្នាលភិក្ខុទាំងឡាយ! សេចក្ដីសុខនិងសោមនស្សឯណាដែលកើតឡើង ព្រោះអាស្រ័យនូវកាមគុណទាំង ៥ នេះ សេចក្ដីសុខសោមនស្សនោះ តថាគតហៅថាជាសុខកាមគុណ ជាសេចក្ដីសុខរបស់បុថុជ្ជន ជាសេចក្ដីសុខខាងមេថុនធម្ម មិនមែនសេចក្ដីដ៏ប្រសើរទេ, តថាគតពោលថា: “សេចក្ដីសុខបែបនេះបុគ្គលមិនគួរសេពមិនគួរចំរើន មិនគប្បីធ្វើឲ្យច្រើន ព្រោះជាសុខគួរខ្លាច” ។

ម្នាលភិក្ខុទាំងឡាយ! ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយបានសម្រេចបឋមជ្ឈាន . . . ទុតិយជ្ឈាន . . . តតិយជ្ឈាន . . . ចតុត្ថជ្ឈាន ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ នេះតថាគតហៅថា នេក្ខមសុខ សេចក្ដីសុខកើតអំពីការចេញចាកកាម, បវិវេកសុខ សេចក្ដីសុខកើតអំពីសេចក្ដីស្ងាត់ចាកកាមនិងអកុសលធម៌, ឧបសមសុខ សេចក្ដីសុខកើតអំពីរម្ងាប់នីវរណធម៌ជាដើម និងសម្ពោធិសុខ សេចក្ដីសុខប្រព្រឹត្តទៅដើម្បីត្រាស់ដឹងមគ្គផលនិព្វាន តថាគតពោលថា: “សេចក្ដី

សុខបែបនេះ បុគ្គលគួរគប្បីសេពគប់ទៅ គួរធ្វើឲ្យចំរើន គួរធ្វើឲ្យច្រើនឡើង ព្រោះជាសុខមិនគួរខ្លាចទេ" ។

ពាក្យឯណាដែលតថាគតពោលរួចហើយថា: "បុគ្គលគប្បីបេះវិនិច្ឆ័យសេចក្ដីសុខ លុះបេះវិនិច្ឆ័យសេចក្ដីសុខហើយ គប្បីប្រកបសេចក្ដីសុខប៉ែកខាងក្នុងសន្ដានឲ្យរឿយៗទៅ", ពាក្យនេះតថាគតពោលហើយ ព្រោះអាស្រ័យសេចក្ដីនេះឯង ។

ឧបរិ. ម. អរណវិភង្គសូត្រ ២៨-១៥៦-១៣៦.

សេចក្ដីមាំមួនរបស់ស្រុកទេសមិនមែនជាភាពនៃសេចក្ដីប្រសើរ

ម្នាលភិក្ខុទាំងឡាយ ក្នុងពួកជនបទខាងត្បូងទាំងឡាយ មានជនបទឈ្មោះ គោវន:, នៅក្នុងជនបទនោះ មានស្រា មានចំណី មានគ្រឿងបន្ទំ មានគ្រឿងបរិភោគ មានរបស់គួរភ្លក់ មានរបស់គួរផឹក មានរបាំ មានចំរៀង មានគ្រឿងប្រគំតូរ្យតន្ត្រី ។ ម្នាលភិក្ខុទាំងឡាយ ជនបទឈ្មោះគោវន:ជាប្រទេសមានទ្រព្យសម្បត្តិមែន មិនមែនតថាគតនិយាយថាមិនមានទេ តែជាជនបទឈ្មោះគោវន: នោះជាប្រទេសថោកទាប ជារបស់អ្នកស្រុក គួរដល់បុថុជ្ជន មិនប្រសើរ មិនប្រកបដោយប្រយោជន៍ មិនប្រព្រឹត្តទៅដើម្បីនឿយណាយ ដើម្បីប្រាសចាកតម្រេក:

ដើម្បីសេចក្ដីរលត់ទុក្ខ ដើម្បីសេចក្ដីស្ងប់រម្ងាប់ ដើម្បីសេចក្ដីដឹង ដើម្បីត្រាស់ដឹង នឹងដើម្បីព្រះនិព្វានទេ ។

ម្នាលភិក្ខុទាំងឡាយ! តថាគតនឹងសំដែង ឋានៈដ៏ប្រសើរ ដែលប្រព្រឹត្តទៅដើម្បីនឿយណាយតែម្យ៉ាងចំណែក ដើម្បីប្រាសចាករាគៈ ដើម្បីរំលត់ទុក្ខ ដើម្បីសេចក្ដីរម្ងាប់ទុក្ខ ដើម្បីសេចក្ដីដឹង ដើម្បីត្រាស់ដឹង នឹងដើម្បីព្រះនិព្វាន (ព្រោះថា) សត្វទាំងឡាយដែលមានជាតិជាធម្មតា បានអាស្រ័យឋានៈនោះហើយ ក៏រួចស្រឡះអំពីជាតិបាន, សត្វទាំង-ឡាយដែលមានជរាជាធម្មតា បានអាស្រ័យនូវឋានៈនោះហើយ នឹងរួចស្រឡះអំពីជរាធម៌បាន, សត្វទាំងឡាយ ដែលមានព្យាធិជាធម្មតា បានអាស្រ័យនូវឋានៈនោះហើយ ក៏រួចស្រឡះអំពីព្យាធិបាន, សត្វទាំងឡាយ ដែលមានមរណៈជាធម្មតា បានអាស្រ័យនូវឋានៈនោះហើយ ក៏រួចស្រឡះអំពីមរណៈបាន, សត្វទាំងឡាយដែលមានសេចក្ដីសោក យំសង្រេងសង្រៃ ទុក្ខលំបាក ទោមនស្សតូចចិត្ត តានតឹងក្នុងចិត្តជាធម្មតា បានអាស្រ័យនូវឋានៈនោះហើយ ក៏រួចស្រឡះអំពីសេចក្ដីសោក យំសង្រេងសង្រៃ ទុក្ខលំបាក ទោមនស្សតូចចិត្ត តានតឹងក្នុងចិត្តបាន ។ ភិក្ខុទាំងឡាយចូរស្ដាប់ពាក្យនេះ ចូរធ្វើទុកក្នុងចិត្តឲ្យល្អ តថាគតនឹងសំដែង ។ (មានត)

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា នឹងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា: ព្រះគ្រូបញ្ញាលិក្ខិត កៅ-ស៊ុម អ្នកត្រួតត្រា
សិស្ស នៅសាលាបាលីជាន់ខ្ពស់

## បញ្ជីរឿង

*ផ្នែកអក្សរសាស្ត្រ* ទំព័រ

ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម . . ប្រវត្តិសាស្ត្រប្រទេសចិន "ពាក្យផ្ដើម" . . . ១១៣

ឃុនឧត្តមប្រីជា ជាប-ពិន . . អធិប្បាយសុភាសិត . . . . . . . . . . ១២៦

ឃុនបញ្ញាសោភ័ន គាំ-ឌុម . . ព័ត៌មាន ថ្លែងសេចក្ដីកាលទៅដឹកនាំយក ពុទ្ធរូបនឹងបល្ល័ង្ក នៅឃុំអង្គរបូរី ស្រុកព្រៃកប្បាស (តនឹងចប់) . . . . . . . . . ១៣៨

*ផ្នែកសាសនា*

លោកគ្រូអាចារ្យ ជាំង-ខាត់ . អរិយសច្ចជាពុទ្ធភាសិត (តមក) . . . . . ១៥៦

ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម . . ឯកភ្លូកនៃមិលិន្ទប្បញ្ហា (តមក) . . . . . ១៦៦

# ពាក្យដើម

រឿងប្រវត្តិសាស្ត្រប្រទេសខ្មែរនេះ យើងបានផ្តើមចុះផ្សាយសេចក្តីខាងដើមមកខ្លះហើយក្នុងទស្សនាវដ្តីកម្ពុជសុរិយា ឆ្នាំ ១៩៤០ តែមានហេតុចាស់ប្រការខ្លះ នាំឲ្យយើងរាំងខានមិនបានចុះផ្សាយរហូតមកជាវេលាយូរឆ្នាំ ៗ ឥឡូវប្រទេសខ្មែរបានទទួលឥស្សរភាពជាប្រទេសឯករាជ្យដោយកំឡាំងកងទ័ពនៃមហានគរជប៉ុន ហេតុនេះទំនងកិច្ចការទាំងឡាយក្នុងស្រុក ក៏ត្រូវតែប្រែប្រួលជាថ្មីខ្លះ ដើម្បីតម្រូវទៅតាមកាលសម័យនៃនយោបាយរបស់មហាអាស៊ីបូព៌ាទិស ដែលមានមហានគរជប៉ុនជាប្រមុខទុកដូចជាអ្នកនាំប្រជាជាតិផ្សេងៗ នៅអាស៊ីទិសខាងកើតទៅកាន់សេចក្តីចំរើនរុងរឿងថែមថ្មីៗ ។

ហេតុដូច្នេះ ទស្សនាវដ្តី កម្ពុជសុរិយាតាំងពីលេខ ៣-៤-៥ ៗលៗ ឆ្នាំ ១៩៤៥ ទៅ គួរតែមានការប្រែប្រួលខ្លះ គឺយើងត្រូវប្រមូលយករឿងល្អៗ ដែលជាប្រយោជន៍ដល់ខេមរជាតិទាំងខាងគតិលោក ទាំងខាងគតិធម៌ សម្រាប់ចុះផ្សាយក្នុងទស្សនាវដ្តីនេះរាល់ៗខែរៀងទៅ ។ តែគួរឲ្យទឹកស្តាយពន់ពេក ចំពោះសន្តានចិត្តរបស់ជាតិយើង ច្រើនតែមិនសូវយកចិត្តទុកដាក់សិក្សារៀនសូត្រអារ្យធម៌ – វប្បធម៌ – អក្សរសាស្ត្ររបស់ជាតិខ្លួនឡើយ បណ្តោយឲ្យរឿងរ៉ាវសាបសូន្យអស់ទៅជាច្រើន ៗ នៅវេលាដែលប្រទេសខ្មែរនៅក្រោមអំណាចបារាំងសែសនោះ

អក្សរសាស្ត្រខ្មែរបានសាបសូន្យទៅជាច្រើន គួរឲ្យទឹកស្តាយណាស់ ដល់មកសម័យឥឡូវនេះ យើងត្រូវតែផ្លាស់នយោបាយថ្មី ដើម្បីជួយជ្រោមជ្រែងអក្សរសាស្ត្រនិងសិល្បការរបស់ជាតិឲ្យបានចំរើនឡើងវិញ គឺត្រូវប្រកាន់ថា ភាសាខ្មែរជាភាសាប្រសើរបំផុត សម្រាប់ជាតិខ្មែរ អក្សរសាស្ត្រខ្មែរជារបស់ល្អបំផុត សម្រាប់ជាតិខ្មែរ ។ ខ្មែរត្រូវប្រើនិយាយតែភាសារបស់ជាតិខ្លួន ខ្មែរត្រូវសរសេរតែអក្សររបស់ជាតិខ្លួន ក្នុងការនិយាយឬសរសេរសំបុត្រទៅរកបងប្អូនរួមជាតិជាមួយគ្នា នេះជាឧបាយរក្សាជាតិឲ្យបានគង់ទ្រង់ ១ ផ្លូវដែរ

សេចក្តីខាងលើនេះ យើងមិនត្រូវនាំយកមកនិយាយក្នុងទីនេះទេ ព្រោះសេចក្តីខាងមុខជាពាក្យផ្តើមអំពីប្រវត្តិសាស្ត្រចិន គួរតែសារសព្ទចំពោះរឿងរ៉ាវសោកោរបស់ចិន ៗ ឯប្រវត្តិសាស្ត្រខាងដើមរបស់ចិននេះ យើងបានដកស្រង់យកមកអធិប្បាយដោយសង្ខេប ៗ អោយយល់អោយស្តាប់ ដើម្បីជាគ្រឿងប្រដាប់សតិបញ្ញារបស់ខេមរជាតិក្នុងកម្ពុជខេមររដ្ឋនេះ ។ ក្រៅអំពីនេះ យើងនឹងព្យាយាមប្រមូលយកភូមិសាស្ត្រ និងប្រវត្តិសាស្ត្ររបស់នានាជាតិ រួបរួមជាមួយនឹងខេមរជាតិយើងនេះ សម្រាប់ចុះផ្សាយក្នុងទស្សនាវដ្តី កម្ពុជសុរិយានេះជាលំដាប់តទៅ ។

បណ្ណាធិការ

# ប្រវត្តិសាស្ត្រប្រទេសចិន

## ភាគទី ១

## វគ្គទី ១

## អំពីជាតិកំណើតចិន

ដែនដីដែលចិនតាំងនៅក្នុងសព្វថ្ងៃនេះ មិនមែនក្នុងប្រទេសដើមរបស់ចិនទេ គឺជាដែនដីដែលចិនបានមកដោយការច្បាំងតស៊ូជាយូរអង្វែងនឹងម្ចាស់ស្រុកជាន់ដើម ដោយរើរុករានទន្ទ្រានយកបន្តិចម្តងៗ ត្រាតែបានជាសម្បត្តិរបស់ចិនយ៉ាងខ្ជាប់ខ្ជួនរហូតមក ។ ចុះដើមកំណើតជាតិចិននៅទីតំបន់ណា? ប្រស្នានេះអ្នកប្រាជ្ញទាំងឡាយខាងប្រវត្តិសាស្ត្រ នៅជជែកប្រកែកគ្នាមិនទាន់ដាច់ស្រេច គឺខ្លះនិយាយថា ពួកចិនចេញមកពីស៊ីបេរី ខ្លះថាមកពី អ៊ីរ៉ង់ ខ្លះថាមកពីមេសូប៉ូតាមី ជាពូជជាតិសីលដេ ។ តែដែលពោលត្រូវគ្នាដោយច្រើននោះ ថាពួកជាតិចិនចេញមកពីទន្លេសាបកាស្ពៃយ៉ែន ។ ឫសគល់កំណើតដើមរបស់ចិននៅភាគតំបន់ទន្លេសាបកាស្ពៃយ៉ែននេះ ប្រហែលក្នុងឆ្នាំ ១៩០០ មុនពុទ្ធសករាជ (២៤៤៣ ឆ្នាំមុនគ្រិស្តសករាជ) ។ ពួកចិនបាននាំគ្នាលើកចេញមកពីទន្លេសាបកាស្ពៃ-យ៉ែន ចូលមកតាំងនៅក្នុងតំបន់ កប-តារី ហើយលើកចេញពី កប-តារី មកតាំងនៅក្នុងដែនដីដែលហៅថា ប្រទេសចិនសព្វថ្ងៃនេះ ។ ឯស្រុកដែលចិនចូលទៅតាំងទីលំនៅជាឡាក់ហាន ក្នុងគ្រាដំបូងនោះ ខេយល់

ថាជាស្រុកកាន់-ស៊ុនឹងប៉េចិលី តមកទើបពង្រីកអាណាខេត្តចេញទៅដល់ចេន-ស៊ី, ហ៊ូ-ណាន និងឆាន-ទុង ដែលតាំងនៅទិសខាងជើង នៃទន្លេហ្វាង-ហូ ហើយទើបឆ្លងទន្លេហ្វាង-ហូចូលមកតាំងនៅចន្លោះទន្លេហ្វាងហូ និងយ៉ាង-សេ ត្រង់តំបន់នេះហើយ ដែលជាទីមានដីជាតិល្អណាស់ ។

តាមទំនងនោះ ដែនដីទាំងឡាយដែលចិនលើកមក តាំងនៅថ្មីនេះ មិនមែនជាទីឥតមនុស្សនៅទេ សឹងតែមានមនុស្សជាតិផ្សេងៗ នៅមកមុនហើយគ្រប់តំបន់ ហើយបានមកតាំងនៅមុនចិនជាច្រើនឆ្នាំ ជាម្ចាស់ភូមិប្រទេសគេស់នោះ ។ ឯពួកមនុស្សជាម្ចាស់ដែនដី ដែលពួកចិនរុកចូលមកនោះ គឺពួកជាតិទីបេតាំង កាលបើត្រូវពួកចិនបៀតបៀន ក៏នាំគ្នាថយទៅទិសខាងត្បូង ហើយក្លាយទៅជាជាតិឥណ្ឌូស៊ីន, មន, ខ្មែរ, ភូមា, ភូឡា, ថៃ, យួន ។

ឯដែនដីនៅទិសខាងលិចឆៀងខាងជើងនោះ ជាន់ដើមមានពួកជាតិស៊ីងតាំងនៅមុន ជនពួកនេះជាពួកអ្នកចម្បាំងកាន់លំពែងនិងធ្នូ ដែលជាអាវុធសំខាន់ក្នុងសម័យបុរាណ ដែនដីចំណែកនេះជាទីតាំងនៃស្រុកចេន-ស៊ី កាលដែលពួកចិនដណ្តើមយកស្រុកចេន-ស៊ីទៅបាន ពួកស៊ីងក៏ក្លាយទៅជាសត្រូវយ៉ាងសំខាន់របស់ចិន លុះដល់មកក្នុងឆ្នាំមុនពុទ្ធសករាជ ៤៤៧ ពួកស៊ីងក៏ចាប់តាំងប្រទុស្សរាយពួកចិន ទាល់តែចិន

ទ្រាំមិនបានគេក៏ផ្លាស់ទីក្រុងចេញពីស្រុកចេន - ស៊ី មកតាំងក្រុងនៅស្រុកហូ- ណាន់ ។ ចំណែកឯផែនដីដែលមានដីជាតិល្អ នៅត្រង់ចន្លោះកណ្ដាលនៃទន្លេ ២ ហើយមានស្រុកដ៏ស្ដុកស្ដម្ភហៅថា ហូ - ប៉េនោះពីដើមមកជាស្រុករបស់ជាតិថេ - ថៃ ។ កាលពួកចិនរុករានទន្ទ្រានចូលមកដល់តំបន់នេះហើយ ពួកថេ ថៃក៏ថយទៅខាងទន្លេយ៉ាំង - សេ ទឹងខាងខែត្រកែនហូ - ណាន់បានតាំងនៅក្នុងផែនដីអស់នេះ ហើយតមកជាច្រើនឆ្នាំ ទើបរុះមកតាំងនៅក្នុងខែត្រដែលយុន - ណាន់ហៅថាអាណាចក្រណង់- ចៅ ។ ឯផែនដីដ៏ធំក្នុងក្រុងលម៉យដែលពួកចិនរុករានទន្ទ្រានមកនោះ ជាដើមជាផែនដីរបស់ជាតិយួន ។ ជាម្ចាស់ស្រុកលើផែនដីចំណែកនេះ រហូតដល់ពុទ្ធសករាជ ៤៣២ ។

ពួកចិនដែលចូលរុករុយយកផែនដីនេះ ពេញទៅដោយចម្បាំងកំរិតដល់កាប់សម្លាប់គ្នាយ៉ាងសំបើម ហើយទន្ទ្រានចូលមកបានយ៉ាងយឺតៗមានអ្នកប្រាជ្ញប្រវត្តិសាស្ត្រគិតប្រមាណថា តាំងអំពីចិនលើកចេញអំពីកប - គារ៉ មកតាំងនៅក្នុងផែនហាន់ - ស៊ី ជារយៈវេលា ៦០០ ឆ្នាំ ទើបតាំងនៅខាប់ខ្ជួនក្នុងផែនហាន់ - ស៊ី កាលប្រមាណមុនព្រះពុទ្ធសករាជ ១៨០០ ឆ្នាំ រួចមកតាំងនៅក្នុងផែនហ៊ូ - ណាន់ រវាងមុនព្រះពុទ្ធសករាជ ១៧០០ ឆ្នាំ ប្រមាណ ៥០ ឆ្នាំតមកទៀត ទើបចិនមានអំណាចរាយរាត់អាណាខេត្តបាក់ស្រុកផ្សេង ៗ នៅទិសខាងត្បូងទន្លេលឿង (គឺ

ចន្ទហ្វាង-ហូ ) ។ សករាជអស់នេះគ្រាន់តែជាការប្រមាណ បើចាប់តាំងពីចិនលើកទៅតាំងនៅសាំងហាយ កាលមុនព្រះពុទ្ធសករាជ ៥៧៩ ហើយតមកទៀតប្រហែល ៤០០ ឆ្នាំ គឺក្នុងរាជ្យពុទ្ធសករាជ ១៧០ ហើយចន្ទយ៉ាំងសេទៅបានរហូតដល់ពុទ្ធសករាជ ៣០០ ឆ្នាំ ទើបចិនលុកលុយទន្ទ្រានយកបានរហូតដែនដីដែលហៅថា ប្រទេសចិនសព្វថ្ងៃនេះ ។

ក្នុងរយៈវេលាដែលកន្លងមកនេះ មានមនុស្សសំខាន់ ៦ ដែលមានឈ្មោះប្រាកដក្នុងពង្សាវតារ គឺ ហ៊្វូ-អ៊ី ជាអ្នកគិតបង្កើតអក្សរចិនឡើង ចិន-នុង ជាអ្នកគិតធ្វើយានមានកង់ឡើង រ៉ាំង-ទី ជាអ្នកសាងគម្រាតារាសាស្ត្រឡើង ហើយមានមហាក្សត្រដែលមានរិទ្ធិអំណាច ៣ ព្រះអង្គព្រះនាមយៅ, ជុន, យូ ដែលគួរទុកជាមហាក្សត្រ ៣ ព្រះអង្គដំបូងក្នុងពង្សាវតារចិន ។

## ស្រុកចិនកើតអ្នកប្រាជ្ញសីលធម៌

ក្នុងសម័យដែលប្រទេសចិន កើតអ្នកប្រាជ្ញខាងសីលធម៌នោះ របៀបគ្រប់គ្រងស្រុកទេស ជារបៀបស្តេចត្រាញ់គ្រប់គ្រងនគរតូច ៗ ដាច់ដោយឡែកពីគ្នា ឯព្រះមហាក្សត្រដ៏ជាធំនោះ គ្រាន់តែជាប្រមុខដូចជារូបអ្នកតា មិនមានអំណាចត្រួតត្រាស្រុកទេសរហូតដែនដីរបស់ព្រះអង្គបានទេ ទើបមិនមានរឿងសំខាន់ៗ កើតមកអំពីព្រះមហាក្សត្រ

ឡើយ ។ ហេតុសំខាន់ដែលកើតឡើង គឺកើតអ្នកប្រាជ្ញខាងស៊ីលធម៌ មានឈ្មោះថា ខុងជឺ ជាដើម ។

ពាក្យថា "ខុងជឺ, ខុងជូ, កុងសឺ ឬ កុងភូស៊ី" ជាឈ្មោះអ្នកប្រាជ្ញចិនម្នាក់ជាដំបូងបំផុតដែលបានតាក់តែងរៀបចំស៊ីលធម៌ ខ្លួនានប្រែជាប្រជាជនជាតិចិន លោកអ្នកប្រាជ្ញនេះម្នាក់ហៅថា "កុងហ្វូស៊ីយុស" ។ កើតឡើងបានអាយុ ៨ ឆ្នាំ ទើបព្រះពុទ្ធជាម្ចាស់បរិនិព្វានទៅ គឺកើតមុនព្រះពុទ្ធបរិនិព្វាន ៨ ឆ្នាំ ស្រុកកំណើតរបស់លោកជាភូមិមួយតូច ក្នុងខែត្រ ចាន់-ទុង ឬ សង់-ទុង ជាចំណុះអាណាចក្រលូ ចាប់ផ្តើមរៀនសូត្រតាំងពីអាយុបាន ១៥ ឆ្នាំ ដល់មានអាយុ ២២ ឆ្នាំ ទើបតាំងខ្លួនជាគ្រូបាអាចារ្យបង្រៀនពួកអ្នកមហាជនរហូតដល់អាយុ ៥១ ឆ្នាំ ទើបបានទទួលនាទីជាចៅហ្វាយស្រុក រួចមកបានឡើងឋានៈសក្តិជាទី អគ្គមហាសេនាបតី (សេនាបតីទី ១) នៃអាណាចក្រលូ ។ មានសេចក្តីដំណាលថា ខុង ជឺ បានប្រាបប្រាមពួកអាមាត្យមន្ត្រីទុច្ចរិត (ដែលធ្លាប់មានតែរឿយៗ ក្នុងពង្សាវតារចិន) ចេញអស់ជាច្រើន ។ តមកព្រះមហាក្សត្រនៃអាណាចក្រលូ ទ្រង់ជឿស្តាប់ពាក្យញុះញង់របស់ព្រះស្នំឯករបស់ទ្រង់ ទើបមិនយកព្រះទ័យទុកដាក់នឹងពាក្យសំដីរបស់ ខុង-ជឺ តាំងមិនសព្វព្រះទ័យឲ្យ ខុង-ជឺ ជួយទំនុកបំរុងទ្រង់តទៅទៀតផង ទើប ខុង-ជឺ ភៀសដោះខ្លួនចេញទៅយ៉ាងស្ងាត់ៗ ឯស្រុកវេគឺ ហើយបានចាប់

ផ្តើមសរសេរតម្រាប់តម្រាសំដែងពីលទ្ធិរបស់លោក ទុកជាកេរ្តិ៍មត៌កមក រួចលោកត្រឡប់មកកាណាចក្រលូវិញ ហើយក៏និក្ខមទៅ ក្នុងជន្មាយុកំណត់ ៧៩ ឆ្នាំ ។

លទ្ធិរបស់ខុង-ជឺនេះ មានប្រជាជនជាតិចិននៅគោរពរាប់អាន តាំងពីយុគណាកាលរហូតមកដល់សព្វថ្ងៃនេះ ទើបគួរចាត់លោកអ្នកប្រាជ្ញនេះជាមហាបុរស ១ របស់ទ្វីបអាស៊ី ព្រោះលោកបានរៀបចំសីលធម៌ ទុកជារបៀបរៀបរយនីតិទៀតចាត់ល្អណាស់ ។ លទ្ធិរបស់លោកមានគោលសំខាន់សំដែងថា "បើអ្នកមិនត្រូវការឲ្យអ្នកដទៃធ្វើដល់អ្នកយ៉ាងណា កុំអ្នកធ្វើដល់គេយ៉ាងនោះ អ្នកត្រូវការឲ្យអ្នកដទៃធ្វើដល់អ្នកយ៉ាងណា អ្នកត្រូវធ្វើដល់គេយ៉ាងនោះ គប្បីស្រឡាញ់អ្នកដទៃដូចជាខ្លួនរបស់អ្នក" គោលសីលធម៌នេះ ស្តាប់មើលក៏ឃើញជាងាយ ៗ មិនមែនជាល្អិតជ្រាលជ្រៅអ្វីឡើយ ប៉ុន្តែប្រសិនបើមនុស្សលោកប្រតិបត្តិតាមគ្រប់ ៗ គ្នាហើយ ពិភពលោកនឹងប្រកបដោយសេចក្តីសុខក្សេមក្សាន្ត ជាងសព្វថ្ងៃនេះជាប្រែនយោគ ។ បើពិនិត្យមើលតាមប្រវត្តិរបស់លោក ហាក់ដូចជាលោកមិនមានលក្ខណៈជាអ្នកបង្កើតសាសនាថ្មី ដូចជាសាស្តាទាំង-ឡាយ ព្រោះគោលសីលធម៌របស់ខុងជឺ មិនមែនខុងជឺជាអ្នកបញ្ញត្តតាំងឡើង ឬគិតរកឃើញបានដោយខ្លួនឯងទេ គ្រាន់តែជាអ្នកប្រមូលក្បឹងរួមរំនៀមទម្លាប់, ប្រវេណី, ដំបូន្មាន, សុភាសិតទំនិតគតិគួរ

របស់អ្នកប្រាជ្ញចាស់ៗ មុនសម័យខុងជឺឡើងទៅ ហើយយកមកចងក្រងទុកជាក្បួនច្បាប់តមក ។ ខុងជឺជាអ្នកប្រាជ្ញដែលមិនពោលអាងដល់ឋានសួគ៌ឡើយ ហើយបើមានគេពោលសួគ៌លោកអំពីរឿងឋានសួគ៌លោកតបថា "សូម្បីតែរឿងរ៉ាវនៅលើផែនដី កម្រនឹងដឹងបានសព្វគ្រប់ទៅហើយ ទំនងដឹងដល់ទៅរឿងរ៉ាវក្នុងឋានសួគ៌ដូចម្ដេចបាន" ។ ប្រការមួយទៀត ខុងជឺមានលក្ខណៈវិសេសមួយយ៉ាង ខុសពីលក្ខណៈរបស់គណាចារ្យអ្នកបង្កើតលទ្ធិសាសនាទាំងឡាយ គឺខុងជឺមិនដឹងការអ្វី ក៏ពោលត្រង់ៗមកថាមិនដឹង ទាំងប្រកាន់ភាក្យសត្យប្រចាំខ្លួនលោកថា "ការអ្វីដែលដឹង, ត្រូវពោលថាដឹង, ការអ្វីដែលមិនដឹង, ត្រូវពោលថាមិនដឹង; នេះហើយដែលហៅថាជាអ្នកដឹងតាមពិត" ។ ប្រសិនបើទុកជាពាក្យប្រៀនប្រដៅរបស់ខុងជឺ មិនមានវង់ធំទូលាយដូចជាសាស្ដាឯទៀតៗ ក៏ដោយ តែអ្នកប្រាជ្ញទាំងឡាយសឹងមានយោបល់យល់ត្រូវគ្នាថា ខុងជឺជាមហាបុរសមួយរបស់ទ្វីបអាស៊ី ដោយបានរៀបចំគោលសីលធម៌យ៉ាងប្រពៃទុកឲ្យចិន ហើយបានផ្សាយបេញទៅក្រៅប្រទេសចិនផង ។

អំណើះកាលតមក ខុងជឺអនិច្ចកម្មទៅបាន ១០០ ឆ្នាំ មានអ្នកប្រាជ្ញចិនម្នាក់ កើតឡើងថ្មីហៅថា "ម៉េងស៊ុ" ដែលគួររាប់ថាជាសាវ័កសំខាន់មួយរបស់ខុងជឺ តែមិនទាន់បានឃើញខុងជឺទេ ព្រោះម៉េង-ស៊ុ កើតក្នុងពុទ្ធសករាជ ១៣១ នៅក្នុងអាណាចក្រលូដែរ ម៉េង-ស៊ុបាន

សិក្សាលទ្ធិរបស់ខុងជឺទីងហៅខុងជឺ ហើយបានប្រកាសផ្សាយលទ្ធិនេះឲ្យកាន់តែរីកចំរើនឡើងទៀត ម៉េង-ស៊ឺបានទទួលតំណែងក្នុងរាជការជាអគ្គមហាសេនាដូចជាខុងជឺដែរ ។ ឯឱវាទដំបូន្មានរបស់ម៉េង-ស៊ឺ មានទំនងខុសគ្នានឹងខុង-ជឺបន្តិច គឺម៉េង-ស៊ឺយកចិត្តទុកដាក់ទូន្មានខាងគោលវិជ្ជាការផែនដីច្រើនជាងច្បាប់សីលធម៌ ។ ម៉េង-ស៊ឺ នេះមានអាយុយឺនជាងខុង-ជឺ ៤ ឆ្នាំ គឺមានអាយុ ៨១ ឆ្នាំទើបអនិច្ចកម្ម ។

ក្រៅអំពីលទ្ធិខុង-ជឺដែលពោលមកនេះ នៅមានលទ្ធិមួយទៀតដែលចិនមានសេចក្ដីគោរពរាប់អាន រហូតមកដល់សព្វថ្ងៃនេះគឺលទ្ធិតៅ-អ៊ីស្ទ លោកអ្នកប្រាជ្ញដែលបង្កើតលទ្ធិនេះគេហៅថា ឡៅ-ស៊ឺ កើតមុនខុង-ជឺ ៥៣ ឆ្នាំ គឺមុនពុទ្ធសករាជ ៦១ ឆ្នាំ ។ លទ្ធិតៅអ៊ីស្ទនេះប្រកាន់ថា មានព្រះជាធំបំផុតនៅលើឋានសួគ៌ត្រូវធ្វើពិធីបន់ស្រន់បួងសួងអង្វរ ទើបព្រះជាម្ចាស់ទ្រង់ប្រោសប្រាណ តមកលទ្ធិនោះក្លាយទៅជារាប់អានខ្មោចបិសាចទេវតានិងអ្នកតា ដែលពួកចិនជាប់រាប់អានតមកដល់សព្វថ្ងៃនេះ ។

នៅសម័យដែលប្រទេសចិនកំពុងសំបូរដោយអ្នកប្រាជ្ញខាងសីលធម៌ ស្ទើរតែសេចក្ដីចំរើនខាងផ្លូវសតិបញ្ញា និងចាត់របៀបសីលធម៌ដល់ប្រជាជនជាតិចិននោះ ប្រទេសចិនបានបែកខ្ញែកទៅជាច្រើនអាណាចក្រ សឹងមានក្សត្រគ្រប់គ្រងដាច់ដោយឡែក ៗ ទើបបណ្ដាលកើត

ទៅជាចម្បាំងកាំងដល់ឥតស្រាក បណ្ដាអាណាចក្រតូច ១ ក៏រលំរលាយ ចូលទៅក្នុងអាណាចក្រធំ ១ នៅទីបំផុតសល់ត្រឹម ២ អាណាចក្រធំ ១ ដែលមានទីក្រុងនៅឃ្លាតឆ្ងាយអំពីគ្នា អាណាចក្រ ១ ទៀតហៅថា ចិន (ជិន,ស៊ុន) តាំងទីក្រុងនៅស្រុកចេន-ស៊ី អាណាចក្រ ១ ទៀតហៅថា ជូ (ចូ,ស៊ូ) តាំងទីក្រុងនៅហ៊ូ-ប៉េ ។ អាណាចក្រទាំង ២ នេះបានច្បាំងគ្នាយ៉ាងយូរអង្វែង នៅទីបំផុតពួកចិនមានជ័យជំនះ ព្រះមហាក្សត្រចិនទ្រង់ព្រះនាមហ៉ាំង-ឈិង ទ្រង់ជាព្រះរាជាធិរាជគ្រប់គ្រងមហាណាចក្រចិនទាំងមូល កាលពីពុទ្ធសករាជ ២៩៧ មានព្រះនាមថាវ៉ុង-ទី ដែលជាតំណែងប្រហែលនឹងសេសាររបស់ក្រុងរ៉ូម ។ ឯព្រះរាជវង្សរបស់ព្រះអង្គហៅថារាជវង្ស ជិនឬចិន ទីក្រុងរបស់ព្រះរាជាធិរាជព្រះអង្គនេះតាំងនៅស្រុកហៀន-ហ៊ុង នៅខាងកើតនៃស្រុកស៊ី-ង៉ាន ក្នុងនៃក្រចេន-ស៊ី ។

វ៉ុង-ទីព្រះអង្គនេះ ជាអ្នកគ្រប់គ្រងរាជអាណាចក្រជាមេទ័ព ទ្រង់បានគ្រប់គ្រងរាជអាណាចក្រចិនទាំងមូល ដែលត្រូវរាប់ថាជាសេសារអង្គដំបូងនៃទ្វីបអាស៊ីទិសខាងកើត ។ ទ្រង់បានគ្រប់គ្រងរាជសម្បត្តិ ៣៦ ឆ្នាំ គឺតាំងពីពុទ្ធសករាជ ២៩៧ ដល់ពុទ្ធសករាជ ៣៣៣ តាមដោយពិតរាជ-អាណាចក្រថ្មីនេះមិនមែនជារូបភូមិប្រទេសថ្មីទេ ព្រោះតាំងពី ២៥០ ឆ្នាំមក ហើយខុង-ជឺបានព្យាយាមកែប្រែទំនៀមទម្លាប់បុរាណ ហើយប្រកាស

ទូន្មានផ្សាយសីលធម៌ទុកមកជាច្រើនណាស់ហើយ ទើបធ្វើឲ្យលទ្ធិខុងជឺនៅជាប់ស្អិតក្នុងចិត្តរបស់ពួកមហាក្សត្រ (ស្តេចត្រាញ់) និងចិត្តគំនិតរបស់ប្រជាជនទាំងឡាយ ដោយពួកបុត្របុរសបានទទួលដំបូន្មានផ្ទាល់មកអំពីខុងជឺ ហើយទទួលអប់រំទៀតតាមបែបមហាក្សត្រមកអំពីបុរាណកាល ។ - ព្រះបាទស៊ុង-ទីទ្រង់មិនសព្វព្រះទ័យឲ្យមានក្សត្រគ្រងនគរតូចៗតទៅទៀត ប៉ុន្តែបើទ្រង់កែប្រែវេលាណាក៏តែងតែត្រូវពួកអាមាត្យរបស់ទ្រង់ទទឹងទាស់មិនយល់ព្រមផង ដោយអាងពល់លទ្ធិរបស់ខុង-ជឺជាមហាអ្នកប្រាជ្ញរបស់ចិនជានិច្ច ។ ឯព្រះបាទស៊ុង-ទីទ្រង់ស្អប់លទ្ធិខុងជឺនេះណាស់ ព្រោះជាហេតុធំទាស់នឹងប្រសាសនោបាយរបស់ព្រះអង្គ ហើយទ្រង់មិនសព្វព្រះទ័យឲ្យអ្នកណាមួយកាន់កាប់តាមលទ្ធិនេះតទៅទៀត ទើបទ្រង់ឲ្យដុតបំផ្លាញក្បួនខ្នាតនិងសៀវភៅផ្សេងៗជាច្រើន ដែលពួកអ្នកប្រាជ្ញអស់នោះបានតែងទុកមក ។ រឿងដុតបំផ្លាញក្បួនខ្នាតនេះ ជារឿងសំខាន់មួយក្នុងប្រវត្តិសាស្ត្ររបស់ចិន ព្រោះពួកតែប្រជាជនជាតិចិនទូទៅមានសេចក្តីគោរពខ្លាចព្រះតេជានុភាពព្រះមហាក្សត្រលះបង់លើកលែងគោរពកាប់កាន់លទ្ធិខុង-ជឺ បែរជាទំងទឹងព្រះមហាក្សត្រហើយនាំគ្នាកាន់តែគោរពបូជាលទ្ធិខុងជឺច្រើនឡើងទៀត ទើបនាំគ្នាបះបោរកាប់សម្លាប់គ្នារីកដល់អស់បុណ្យព្រះមហាក្សត្រនេះហើយ លទ្ធិខុងជឺត្រឡប់ចំរើនរុងរឿងឡើងវិញ ដោយព្រះមហាក្សត្រក្រោយៗមក ទ្រង់ជួយឧបត្ថម្ភដោយប្រពៃ ។

ក្នុងសម័យដែលពួកចិនតាំងឡាក់ឋានបានខ្ជាប់ខ្ជួន ហើយមានសេចក្តីចំរើនរុងរឿងឡើងដូច្នោះ ពួកហ្វូនឬពួកមន្ទុលក៏ចាប់ផ្តើមរុករានទន្ទ្រានរកទីតាំងនូវសម្រាប់តាំងឡាក់ឋានខ្លះដែរ ៗ កាលពីក្នុងរជ្ជសម័យព្រះបាទវ៉ុង-ទី. ពួកហ្វូនដែលចិនហៅថា ហាង-នូ ឬ ហៀង-នូ នោះ បានលុកលុយយកដែនដីខាងសមុទ្រជប៉ុន ព្រះបាទវ៉ុង-ទីទ្រង់ធ្វើចម្បាំងតស៊ូនឹងពួកនេះជាវេលាយូរ នៅទីបំផុតទ្រង់បានកសាងកំពែងយ៉ាងធំសម្បើមឡើង សម្រាប់ការពារស្រុកចិន កាលពីពុទ្ធសករាជ ៣២៩ ជារយៈវែងដល់ ៣.៣០០ គីឡូម៉ែត្រ គួរចាត់ជាការកសាងយ៉ាងសម្បើមបំផុត ដែលមានជាប់តរហូតមកដល់ឥឡូវនេះ ៗ ឯដែនដីនៅកណ្តាលទ្វីបអាស៊ី ក៏ត្រូវពួកហ្វូនរុករានទន្ទ្រានចូលទៅ ត្រាតែពួកយូរេជីជាម្ចាស់ស្រុកកោន៍ថយចូលទៅក្នុងប្រទេសឥណ្ឌា ទើបតែដែនមន្ទុលក៏ធ្លាក់ទៅនៅក្រោមអំណាចពួកហ្វូនទាំងអស់ ៗ

(មានត)

## អធិប្បាយសុភាសិតខ្មែរ

# ឃុនឧត្តមប្រីជា ឋាប-ពិន និពន្ធបណ្ឌិត

នៅពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ រៀបរៀង

១- បន្ទាមុត យកបន្ទាដោះ

២- សេះដាច់ យកសេះតាម

៣- ភ្លើងឆេះ ដុតភ្លើងតប

— ប្រទេសខ្មែរយើង តាំងពីបុរាណមក បណ្ដាជនដែលជាវោហារកោសល មានប្រតិពលខាងផ្លូវនិយាយ, កាលបើគេនិយាយពីរឿងអ្វី ដែលសេចក្ដីគង់ផ្លូវរឿងមានទំនងគួរដល់សុភាសិតណា គេតែងយកសុភាសិតនោះមកបញ្ចូលត្រង់ចន្លោះៗនោះៗ ដើម្បីបញ្ជាក់សេចក្ដីឲ្យច្បាស់លាស់ឲ្យងាយស្ដាប់ ។ សុភាសិតខ្មែរ មានច្រើនបទ តែមិនបានស្រង់យកគ្រប់បទទាំងអស់មកអធិប្បាយទេ, ស្រង់យកតែ ៣ បទ ដូចបានតាំងទុកជាមាតិកាខាងដើមនេះ មកអធិប្បាយ ។ សុភាសិត ៣ បទនេះ កាលបើមានទំនងហើយអ្នកនិយាយគេតែងដាក់ថា "បន្ទាមុត យកបន្ទាដោះ" ឬថា "សេះដាច់យកសេះតាម" ឬក៏ថា "ភ្លើងឆេះ ដុតភ្លើងតប"; ប៉ុន្តែអ្នកនិយាយជួនកាលគេយកតែមួយដាក់ ជួនកាលគេយកតែពីរ ជួនកាលគេយកទាំងបី ព្រោះសេចក្ដីជាមួយគ្នា ។

សុភាសិតទាំង៣បទនេះ មានសេចក្ដីជាមួយគ្នាក៏ពិតមែន ប៉ុន្តែមានអធិប្បាយជា ២យ៉ាង គឺអធិប្បាយត្រង់ ១យ៉ាង អធិប្បាយប្រៀប១យ៉ាង ។

## អធិប្បាយត្រង់

១- ធម្មតាបន្លា ជារបស់មានសណ្ឋានស្រួច តែងមុតចូលទៅក្នុងសាច់មនុស្សនិងសត្វនានា, កាលបើគេដឹងថាបន្លាមុតហើយ គេតែងយកបន្លាដូចគ្នា ឬវត្ថុដែលមានមុខស្រួចដូចបន្លា មកដោះ ទើបបន្លានោះរង្គោះចេញមក, បើមិនដូច្នោះ បន្លានោះ មិនរបូតចេញមកឡើយ ។

២- ធម្មតាសេះ ជាសត្វមានល្បឿនលឿនជាងសត្វជើង ៤ ជើង ២ គ្រប់យ៉ាង, កាលបើគេដឹងថាសេះដាច់ហើយ គេតែងយកសេះដូចគ្នាជិះទៅតាម ទើបទាន់, បើមិនដូច្នោះ មិនងាយទាន់ឡើយ ។

៣- ធម្មតាភ្លើង វេលាខែប្រាំង តែងឆេះព្រៃរាលទៅក្នុងទីផ្សេងៗ អ្នកដែលមានខ្ទមឬវត្ថុអ្វីនៅក្នុងព្រៃនោះ កាលបើគេដឹងថាភ្លើងឆេះរាលតម្រង់មករកទីកន្លែងឬវត្ថុរបស់គេ គេតែងឆ្ការព្រៃជុំវិញខ្ទម ឬវត្ថុរបស់គេឲ្យស្រឡះ ហើយគេដុតព្រៃជុំវិញទីដែលគេឆ្ការនោះ ឲ្យឆេះតបទៅរកភ្លើងព្រៃ មុនវេលាដែលភ្លើងព្រៃឆេះមកដល់ ដើម្បីបង្ការមិនឲ្យអន្តរាយ, ធ្វើបែបនេះ ទើបភ្លើងព្រៃមិនឆេះខ្ទមឬវត្ថុផ្សេងៗ; សូម្បីក្នុងវិន័យពុទ្ធសាសនា ក៏មានពុទ្ធានុញ្ញាតឲ្យភិក្ខុអ្នកនៅក្នុងព្រៃ ដុតភ្លើងតបបែបនេះបង្ការខ្លួនបាន ឥតមានទោសឡើយ ។

# អធិប្បាយប្រៀប .

បើមានហេតុកើតឡើងចំពោះបន្ទ ចំពោះសេះ ឬចំពោះក្បួនគេតែងធ្វើ ដូចពោលមកខាងដើម, សេចក្ដីនេះយ៉ាងណា, ឧបាយដែលនឹងខ្ជាន់មនុស្សក៏ដូចគ្នា គឺបើមានមនុស្សទុជ៌ន មកប្រើឧបាយបោកប្រាស់ដោយសេចក្ដីវៀចវេចណាមួយ គេត្រូវកេឧបាយប្រហែលគ្នានោះទៅផ្ចាញ់ផ្ចាល់ឲ្យទល់ពិស ទើបត្រឡប់ជាត្រង់ត្រូវទៅតាមសេចក្ដីពិតវិញបាន ដូចរឿងនិទានដែលពោលខាងមុខនេះ :

ក្នុងកាលកន្លងលើសទៅយូរហើយ មានស្រុក ១ ឈ្មោះ ចិត្តលិក្រាម; ក្នុងស្រុកនោះ មានអាកម ១ ឈ្មោះ អម្ពលដ្ឋាន, មានកុដុម្ពិកម្នាក់ឈ្មោះសុចិ ជាញោមអាកម, ក្នុងអាកមនោះ មានសមណ ១ រូបឈ្មោះ សុទត្ត ៗ ថ្ងៃ ១ សុទត្តសមណៈ មានការទៅសួរញាតិញោមឯភូមិឆ្ងាយ បានផ្ញើហិប ១ នឹងសុចិកុដុម្ពិក, ក្នុងហិបនោះ មានមាសជាច្រើនដំឡើងនៅខាងក្រោម ឬសលើសម្បកឈើជាថ្នាំនៅខាងលើ ៗ កាលកុដុម្ពិកយកហិបទៅទុកឯផ្ទះ បើកមើលឃើញមាស ក៏ត្រេកអរ ហើយយកទង់ដែងមានទម្ងន់ស្មើគ្នាមកប្តូរយកមាសទុកជារបស់ខ្លួន ៗ លុះសុទត្តសមណៈត្រឡប់មកដល់អាកមវិញ ឲ្យសុចិកុដុម្ពិកយកហិបមក, លុះកុដុម្ពិកទៅផ្ទះផុតទៅ លោកបើកហិបមើលឃើញសុទ្ធតែទង់ដែង ក៏ដឹងច្បាស់ថាកុដុម្ពិកលួចប្តូរ តែលោកគិតថា "បើអញសួរ

ដេញដោលគេ កាលណាគាត់នឹងទទួលថាប្ដូរ បើដូច្នេះ ចាំអញធ្វើ ឧបាយកលឲ្យទល់ពិសនឹងគាត់វិញ ទើបជា", ថ្ងៃក្រោយលោកឲ្យហៅ កុដុម្ពិកនោះមកប្រាប់ថា អាត្មាត្រូវការទៅសួរញាតិញោមឯភូមិឆ្ងាយ ទៀត ចូរញោមអនុគ្រោះឲ្យកូនប្រុសតូចរបស់ញោមជូនអាត្មាទៅ ហឹប នេះអាត្មាសុំផ្ញើនឹងញោម ។ កុដុម្ពិកយកហឹបទៅទុកឯផ្ទះ ដោយឥត សង្ស័យយកកូនឲ្យទៅតាមលោក ។ ឯសុទត្តសមណៈទៅដល់ផ្ទះញាតិ ញោមក៏ពយដំណើរប្រាប់អស់បងប្អូនសព្វគ្រប់, ផ្ញើកូនក្មេងនោះទុក ហើយឲ្យគេចាប់ស្វាក្នុងព្រៃមកបង្ហឹកឲ្យចេះមាយារបស់មនុស្ស រួចនាំមក ឯអាពម, លុះដល់ហើយក៏ហៅកុដុម្ពិកមកប្រាប់ថា "កាលដែលអាត្មា យកកូនញោមទៅតាមនោះ លុះទៅដល់ក្នុងព្រៃ កូនញោមរត់ទៅបេះ ស៊ឹកឈើផ្លែឈើស៊ី ក៏ស្រាប់តែមានរូបរាងខុសប្រក្រតីទៅ, នេះហើយ ជាកូនរបស់ញោម" ។ កុដុម្ពិកជឿថា កូនរបស់ខ្លួនដូច្នោះមែន ក៏តូច ចិត្តផ្លូលសន្ធប់បាត់ស្មារតី លុះដឹងខ្លួនឡើងវិញ ទើបអង្វរសុទត្តសមណៈ ឲ្យជួយរកគ្រូពេទ្យមកព្យាបាល ។

កាលដែលអ្នកទាំងពីរកំពុងនិយាយគ្នានោះ គ្រាវេលាដែល ព្រះបាទសុរូបបរមពោធិសត្វ ទ្រង់ចេញចាកព្រៃនគរហើយប្រាថ្នានឹងទៅ ទ្រង់ព្រះផ្នួសជាឬសីក្នុងព្រៃហិមពាន្ត ស្ដេចមកដល់អាពមនោះដែរ លុះ ទ្រង់បានឮសំឡេងសុបិកុដុម្ពិកយំសោកនឹងកូន ទ្រង់ចូលទៅនមស្សការ

សុទត្តសមណៈ។ យល់លក្ខណៈពោធិសត្វ ក៏ស្គាល់ថាជាអ្នកប្រាជ្ញ អាចពិភាក្សាសេចក្ដីរបស់លោកបាន លោកក៏សូមឲ្យពោធិសត្វជួយពិភាក្សា ពោធិសត្វទ្រង់សង្កេតសួរយកចម្លើយអំពីគូវិវាទទាំងពីរនាក់, លុះបានជ្រាបច្បាស់សេចក្ដីពិតដោយប្រាជ្ញាហើយ ក៏ទ្រង់ប្រកាសសេចក្ដីថា "បើផ្លូវត្រង់មនុស្សដើរក៏ត្រង់ ផ្លូវវៀចមនុស្សដើរក៏វៀច, បើមាសនព្វគុណក្លាយទៅជាទង់ដែង កូនក្មេងក៏ក្លាយទៅជាស្វា ព្រោះអំពើវៀចនោះឯង", ទ្រង់ប្រកាសសេចក្ដីនេះហើយ ទើបសួរកុដុម្ពិកថា "ឥឡូវយើងស្គាល់មុខមនុស្សកំណាចអន្ធពាលច្បាស់ហើយ អ្នកឯងចេះគម្ពមន្តឬទេ? បើចេះត្រូវស្រោចទង់ដែងឲ្យក្លាយជាមាសទៅ, យើងនឹងសែកស្វាឲ្យទៅជាមនុស្សវិញបាន, បើអ្នកឯងសែកទង់ដែងឲ្យទៅជាមាសពុំបានទេ យើងក៏សែកស្វាឲ្យទៅជាមនុស្សពុំបានដែរ" ៕

សុចិត្តកុដុម្ពិកបានស្ដាប់ហើយក៏វិលទៅផ្ទះ ប្រាប់ប្រពន្ធតាមដំណើរនោះ, ប្រពន្ធក៏យំសោកអាណិតកូនក្រៃពេក; កាលអ្នកទាំងពីរប្រឹក្សាគ្នាក៏ដឹងថា "ហេតុនេះ ច្បាស់ជាកើតមកពីអំពើដែលយើងលួចប្ដូរមាសសុទត្តសមណៈ, បើដូច្នេះត្រូវយើងយកទង់ដែងចេញ យកមាសដាក់ប្រគេនលោកវិញ, ទើបកូនយើងត្រឡប់ជាមនុស្សដូចដើម", កុដុម្ពិកក៏យកមាសដាក់កន្សែងហើយ លីយកទៅប្រគេនលោក, សុទត្តសមណៈ បើកព្រិចមើលឃើញមាសរបស់លោក ជាមាសសុទ្ធដូចដើម. ទើបលោក

ពោលថា "អើហ្ន៎! មាសក្លាយជាខ្ទង់ដែងដោយអំណាចអំពើវៀច, ខ្ទង់ដែងក្លាយជាមាស ដោយអំណាចអំពើត្រង់" ។

ចំណែកបរមពោធិសត្វ ទ្រង់ពិភាក្សាសេចក្ដីនោះហើយ ទ្រង់លាសុទត្តសមណៈ ធ្វើដំណើរឆ្ពោះទៅព្រៃហិមពាន្ត ។

សុទត្តសមណៈ ក៏នាំយកស្វាទៅលែងក្នុងព្រៃធំ ហើយទៅឯស្រុកញាតិញោម យកកូនមកឲ្យសុបិកុដុម្ពិកវិញ ។

រឿងនេះ សមនឹងសុភាសិតដែលពោលមកខាងដើមថា "យកបន្លាដោះបន្លា យកសេះតាមសេះ, ដុតភ្លើងគប់ភ្លើង" នោះឯង គឺសុបិកុដុម្ពិកមានចិត្តវៀចលួចបោកសុទត្តសមណៈ ។ យកឧបាយដែលមានសភាពស្រដៀងគ្នា ទៅដោះ ទៅតាម ទៅតប នឹងសុបិកុដុម្ពិកវិញ ឲ្យទល់ពិសគ្នា ទើបធ្វើសុបិកុដុម្ពិកឲ្យទៀងត្រង់ទៅវិញបាន ។

ការធ្វើឲ្យទល់ពិសគ្នានេះ ដូចកាលមនុស្សវៀចតាំងពីដើម ធ្វើកលវៀចដាក់គ្នាទៅវិញទៅមក ដល់ដឹងគំនិតគ្នា ត្រឡប់ដាយកគ្នាជាគ្រឿងម្រាក់ទៅវិញក៏មាន; ដូចនិទានតាខ្វិលអាខ្វូច ដែលពោលខាងមុខនេះ:

ក្នុងកាលកន្លងរំលងទៅយូរហើយ មានបុរសម្នាក់ នៅស្រុកស្រែ ជាមនុស្សខ្ជិលច្រអូស មិនគិតប្រឹងរកស៊ីធ្វើការដូចអ្នកទាំងពួងឡើយ អ្នកស្រុកគេហៅថា "អាខ្វូច" អានោះរបរតែអង្គុយត្រដោមក្បាល ផ្គន់វិះរកឧបាយទំនើងហោកប្រាសអ្នកស្រុក; វេលាមួយ វាយកកាំបិតស្ពា

កំបាក់តូច ១ ដាក់ក្នុងស្រោមដាវដ៏វែង ហើយកាន់ស្ពាយដើរចុះមកឯស្រុកកំពង់ រកប្ដូរអើកាំទនឹងអ្នកដែលឆោត ។ ។

ក្នុងវេលាជំណាលគ្នានោះ មានបុរសម្នាក់ទៀត នៅស្រុកកំពង់មាត្រ តូចតាបកន្ទិល ខុសខ្នាត អ្នកផងគេហៅថា "អាឋិល" ជាមនុស្សកម្ជិល គិតរកតែ។បាយឆបោកអ្នកស្រុក ដូចគ្នានឹងអាខ្វិច, អានោះកាន់យកពាង ២ ដាក់ដីខ្សាច់ពេញ ៗ ហើយយកប្រហុក ១ ខ្ទប់ មកលាយបន្តិច ៗ ពីលើមាត់ពាងនេះ បិទមាត់ជិតហើយរែកចេញពីស្រុកកំពង់ឡើងទៅឯស្រុកស្រែលើ ដើររក។បាយបោកបញ្ឆោតប្ដូរអើកាំទនឹងអ្នកស្រុកដូចគ្នា ។

លុះអ្នកទាំងពីរនោះ ដើរមកដល់ពាក់កណ្ដាលផ្លូវ ប្រទះគ្នាក៏សុំប្ដូររបស់គ្នាទៅវិញទៅមក, ចំណែកអាខ្វិច ដែលយកកាំបិតស្នាកំបាក់បន្ទំធ្វើដាវ កាលបើឃើញពាងក៏នឹកស្មានថា ប្រហុកពេញ ៗ ដល់មាត់ពាងមែន ត្រេកអរណាស់ ដោយគិតថា កាំបិតអញកំបាក់តូចខ្ទិះសោះ ហើយមកបានប្រហុក ២ ពាងពេញ ៗ យ៉ាងនេះ ជាលាភប្រសើរណាស់". ឯអាឋិលដែលយកប្រហុក ១ ខ្ទប់បិទពីលើមាត់ពាងដីខ្សាច់នោះ កាលបើឃើញស្រោមដាវវែង ក៏សំគាល់ថាជាដាវមែន ៗ នឹកអរណាស់ គិតថា "ប្រហុកអញតែ ១ ខ្ទប់សោះ ហើយមកបានដាវវែងលៃបែបនេះ ជាភ័ព្វធំណាស់ តាំងពីអញកើតមកមិនដែលបានប្រទះលាភបែបនេះទេ"

អ្នកទាំងពីរក៏ប្តូររបស់ទៅវិញទៅមក, តែដុនទីងប្រុស្ទូតែហាមគ្នាថា "កុំអាលបើកមាត់ពាង - ហូតដាវមើលភ្លាម", ដូរស្រេចហើយ ក៏ញញឹមញញែម ញាក់មុខញាក់មាត់ដាក់គ្នា លាគ្នាចេញទៅតាមផ្លូវរៀងខ្លួន, លុះទៅដល់ពាក់កណ្តាលផ្លូវអាខិលដកដាវមើល ឃើញកាំបិតស្វាក់ប៉ាកតូចខ្លី ក៏គិតថា "យើ! គាត់នេះ មានឧបាយមុនអញដែរតើ" ក៏ដើរត្រឡប់មករកអាខូចវិញ ដោយគិតថា "ទីងយកគ្នាជាក្លើ" ចំណែកអាខូចក៏ហែកកញ្ចប់មាត់ពាងមើល ឃើញប្រហុកលាបៗ ពីលើមាត់ពាងខាងក្រោមសុទ្ធតែដីខ្សាច់ ក៏គិតថា "អើហ្ន៎! អញស្មានថា ក្នុងស្រុកនេះមានតែអញមួយទេ ដែលមានឧបាយបែបនេះ ឥឡូវនេះ មានគេដូចអញដែរ" ក៏ត្រឡប់មករកអាខិលវិញ ដោយគិតថា "ទីងយកគ្នាជាក្លើ" ដូចគ្នា ៖ ដល់អ្នកទាំងពីរមកប្រទះគ្នានៅទី ១ ក៏សើចកាច់កកាច់ស្រង់រកគ្នា ហើយយកគ្នាជាមិត្រកេស៊ីចិញ្ចឹមជីវិតដោយផ្លូវបោកបញ្ឆោតអ្នកស្រុកតទៅ ។

អាខិល អាខូច ប្រើឧបាយខិលខូចតបគ្នាទៅវិញទៅមក ទល់ពិសគាយក្នុងគ្នាជាក្លើដូចពោលមកហើយ, រឿងនេះ ដូចជាសមនឹងសុភាសិតដែលពោលមកខាងដើមនោះដែរ, ប៉ុន្តែតាមគោលសេចក្តីតក្នុងសុភាសិតនោះ ដែលអ្នកប្រាជ្ញបុរាណលោកចង់ទុកមក ប្រហែលជាសំដៅដល់ការប្រើឧបាយក្នុងផ្លូវល្អ ដែលជាឧបាយទូន្មានមនុស្សខូច ឲ្យទៅជា –

មនុស្សជាដូចជាសុទត្តសមណៈ ប្រើឧបាយផ្ចាញ់ផ្ចាល់ ឲ្យទល់ពិសនិង អំពើវៀចរបស់សុចិក្ខដម្ពីក៍ ធ្វើសុចិក្ខដម្ពីក៍ឲ្យជាមនុស្សទៀងត្រង់វិលង មានពុតត្បុតនោះឯង ។

សេចក្តីទាំងឡាយដែលអធិប្បាយមកពីខាងលើនេះ សុទ្ធតែជាគតិ-លោកទាំងអស់, បើជាគតិធម៌វិញ ត្រង់សុភាសិតថា "បន្លាមុត យកបន្លាដោះ" នោះមានអធិប្បាយថា: បើមនុស្សណា មានសេចក្តីស្រឡាញ់ថា ខ្លួនមានរូបល្អឆើតលើសគេ ឥតមានអ្នកណាល្អដូច ហើយប្រកាន់តាមហេតុនោះ រល់តែនឹងការថែទាំរូបនោះពេក ឥតគិតដល់ការមិនទៀង ជាទុក្ខ ជាអនត្តាសោះ, បើដូច្នោះត្រូវយកមនុស្សដែលមានរូបល្អជាង មកផ្ចាញ់ ទើបលះសេចក្តីស្រឡាញ់នោះបានខ្លះ; ដូចកាលព្រះសម្មាសម្ពុទ្ធទ្រង់ទូន្មាននាងរូបនន្ទាថេរី ដែលកាលនៅគ្រហស្ថ គេហៅថា "នាងជនបទកល្យាណី" ល្អឆើត ជាងគេក្នុងជនបទ, ដល់នាងបួសជាសមណី ក៏នៅតែមានសេចក្តីស្រឡាញ់រូប មិនចំប្រព្រឹត្តសមណធម៌, វេលាមួយនាងបាននៅស្តាប់ធម៌ទេសនា ដោយសារភិក្ខុនីឯទៀតនាំទៅ, ទៅហើយមិនហ៊ានអង្គុយចំពោះមុខព្រះភក្ត្រព្រះអង្គទេ ខ្លាចព្រះអង្គសំដែងធម៌ផ្ចាញ់ផ្ចាល់រូប អង្គុយពីខាងក្រោយបំបាំង ១ នឹងគេ ប្រុងស្តាប់ធម៌, ព្រះសម្មាសម្ពុទ្ធទ្រង់ជ្រាបហេតុនោះ ទ្រង់គិតថា "ថ្ងៃនេះ នាងរូបនន្ទាមកស្តាប់ធម៌ហើយ គួរតថាគតយកធម៌ដែលប្រៀប

ដូចយកបន្ទាដោះបន្ទា មកសំដែងឲ្យខានស្លាប់" ហើយទ្រង់និម្មិតជាស្ត្រីមានរូបល្អឆើតជាងនាងនោះទៀត ឲ្យអង្គុយបក់ផ្លិតថ្វាយ នាងរូបនន្ទាឃើញរូបនិម្មិតនោះ ល្អដូចកូនហង្ស មើលមកខ្លួនឯងឃើញអាក្រក់ដូចមេក្អែក គិតថា "ឱអើ! មានគេល្អជាងអញដែរហ្ន៎" ព្រះអង្គទ្រង់សំដែងព្រះត្រៃលក្ខណៈផង ទ្រង់ផ្លាស់រូបនិម្មិតនោះ ឲ្យឃើញជាចាស់បន្តិចម្ដងៗ ផង, មិនយូរប៉ុន្មាន ក៏ទ្រង់ធ្វើឲ្យរូបនិម្មិតនោះ ដួលស្លាប់មានដង្កូវពុះត្រកត្រាកក្រអឺនោះ; នាងរូបនន្ទាសង្វេគខ្លាំង តាំងស្មារតីស្ដាប់ធម៌ក៏បានសម្រេចមគ្គផល លះការស្រវឹងរូបក្នុងផ្លូវចិត្តបាន គ្រាន់តែថែទាំដោយផ្លូវកាយតាមធម្មតាប៉ុណ្ណោះ មិនមានការជាប់ចិត្តក្នុងរូបឡើយ ។

រឿងដែលពោលមកនេះ គឺយករូបល្អ ផ្លាញ់រូបល្អ ដូចយកបន្ទាដោះបន្ទា ។

មានរឿង ១ ទៀតថា: កាលព្រះសម្មាសម្ពុទ្ធគង់ព្រះជន្មនៅឡើយ មានព្រះថេរៈ ១ រូប ឈ្មោះឆន្នៈ ខាងមានះប្រកាន់ខ្លួនថា ត្រាច់លើជាងគេ ក៏រឹងត្អឹង មិនចុះលំទោនទៅរកព្រះថេរៈចាស់ៗ រំឭកដាស់តឿនពុំបាន ព្រោះយល់ខុសថា "មានតែខ្លួនម្នាក់ទេ ដែលជូនព្រះមហាសត្វចេញទ្រង់ព្រះផ្នួស គ្រានោះ មិនឃើញលោកណាមួយជូនដំណើរព្រះអង្គទេ, ម្ដេចឡើយក៏លោកទាំងនោះហ៊ានមកស្ដីប្រដៅខ្ញុំ មិន

ព្រមស្តាប់ទេ ខ្ញុំស្តាប់តែព្រះអង្គ ១" ។ ព្រះសម្មាសម្ពុទ្ធក៏ទ្រង់ពុំស្តី ប្រដៅអ្វីឡើយ ដោយទ្រង់ជ្រាបថានិស្ស័យធម៌ពុំទាន់ដល់ ទើបទ្រង់ស្ងៀមៗ ចាំនិស្ស័យ ម្ល៉ោះហើយព្រះឆន្នៈ ក៏ចេះតែក្អេងក្អាងដាក់ព្រះថេរៈចាស់ៗ ដែលជាវិន័យធរពហុស្សុត ស្តីរំឮកដាស់តឿនអ្វីបន្តិចបន្តួចពុំបាន ។ លុះព្រះសម្មាសម្ពុទ្ធទៀបបរិនិព្វាន ទ្រង់មានព្រះពុទ្ធដីកាទឹងព្រះអានន្ទថា "អំណើះពីតថាគតទៅ ត្រូវអ្នកទាំងឡាយ ឲ្យព្រហ្មទណ្ឌដល់ឆន្នៈចុះ ទើបឆន្នៈលះអំពើមានះចេញបាន" ។ កាលព្រះអង្គបរិនិព្វានហើយភ្លាម ព្រះសង្ឃបានដាក់ព្រហ្មទណ្ឌដល់ព្រះឆន្នៈ គឺមត់គ្នា សូម្បីតែ ១ រូបក៏គ្មានលោកណានិយាយរកសោះឡើយ, ព្រះឆន្នៈទៅឯណាក៏គ្មានលោកណានិយាយរក លោកទាំងអស់សុទ្ធតែសំដែងមានះគប់ព្រះឆន្នៈគ្រប់រូប ។ កាលបើដូច្នោះ ព្រះឆន្នៈក៏នឹកសង្វេគថា "ឱ! អញដល់ម្ល៉េះទេ, គ្រាន់តែឥតពីព្រះដ៏មានបុណ្យទៅភ្លាម អញត្រូវមាបតែម្នាក់ឯង, ឱ! អំពើនេះព្រោះតែអញជាមនុស្សរឹងត្អឹងពេក បានជាដូច្នេះ" លុះដឹងខ្លួនហើយ ក៏លះមានះចេញ បន្ទន់ខ្លួនឱនលំទោនទៅរកសង្ឃតាមលំដាប់ចាស់ខ្ចីលំឱនដល់ព្រះថេរៈជាវិន័យធរ ពហុស្សុត សុំខមាទោសចំពោះអំពើដែលប្រព្រឹត្តល្មើសមកពីដើម ព្រះសង្ឃទាំងពួងក៏ជួយដាស់តឿនក្រើនរំឮកបន្តិចៗ ៦ រូប ព្រះឆន្នៈមានសេចក្តីសង្វេគ គេចចេញចាកពួកទៅចំរើនសមណធម៌ ក៏បានសម្រេចមគ្គផល ។

ដំណើរការ ប្ដូរបៀបឲ្យព្រហ្មទណ្ឌដូចពោលមកហើយនេះ ក៏បាន ជាគតិមួយយ៉ាងប្រសើរដែរ ឈ្មោះថា "ឲ្យមានៈគបមានៈ" ត្រឡប់ជា ផ្ចាញ់មានៈបាន, ត្រូវគ្នានឹងសុភាសិតថា "ភ្លើងឆេះ ដុតភ្លើងគប" ដូច ពោលមកខាងដើម ។

---

# ព័ត៌មានថ្លែងសេចក្ដី

## កាលទៅដឹកនាំយកព្រះពុទ្ធរូបនិងបល្ល័ង្ក

## នៅឃុំគន្ធបុរី ស្រុកព្រៃកប្បាស (តាកែវ)

## ឃុនបញ្ញាសោភ័ន គាំ-ឌុម

(រៀបរៀងតាមកំណត់)

## អំពីយកព្រះពុទ្ធរូបវត្តកំពង់ហ្លួង (អង្គរបុរី)

គ្រាំចំណាមនុស្សទាំងមកជួបជុំគ្នាច្រើន លុះរួចស្រេចកិច្ចបុណ្យកាលណា ខ្ញុំករុណាទាំងសុំនិមន្តព្រះពុទ្ធរូបពីក្នុងព្រះវិហារទៅដាក់លើទូក សូមព្រះតេជព្រះគុណអភ័យទោស សូមអនុញ្ញាតឲ្យមាន ១ ទៀតសូមឲ្យព្រះតេជព្រះគុណប្រាប់អ្នកស្រុកជើងវត្តឲ្យជួយឈើធ្នាលផង ព្រមទាំងទូកសួរបញ្ជាក់ថា ក្រៅអំពីព្រះពុទ្ធរូបក្នុងវិហារនៅ ពជការមានសុំអ្វីខ្លះទៀតដែរឬ ? ១ ទៀតព្រះតេជព្រះគុណ សព្វព្រះទ័យឲ្យខ្ញុំករុណាយកអ្វីខ្លះទៀតមានដែរឬ ?- ចំពោះពជការបានសុំអាត្មាភាពតែព្រះពុទ្ធរូបបុរាណក្នុងវិហារ ១ អង្គប៉ុណ្ណោះ ក្រៅពីនោះមិនត្រូវសុំអ្វីទៀតទេ តែការនេះស្រេចនៅលើចៅចុះ បើជីត្រូវការយកទាំងអស់តាមចុះពជការអាត្មាភាពក៏មិនដឹងធ្វើដូចម្ដេច ប៉ុន្តែអាត្មាភាពសុំឲ្យទុកព្រះពុទ្ធរូបមុខ ៤ ដែលធ្វើអំពីឈើ ១ រូបគោ (គោនន្ទិ) ១ រូបមនុស្សអង្គុយក្បែររូបគោដែលអ្នកស្រុក

ហៅថាតាមោ៉ង ១ កុំឲ្យស្រស់រលីងពីវត្តពេក មួយទៀតដល់ថ្ងៃនិមន្តព្រះពុទ្ធរូប សូមឲ្យបីតាក់តែងចុះចំណែកអាក្លាភាពពុំហ៊ានទៅជិតព្រះអង្គទេ ។

លុះដល់ថ្ងៃ ១៧ សេបតមប្រ៊ែ ត្រូវនឹងថ្ងៃ ១៥ កើតខែភទ្របទជាថ្ងៃភ្ជុំបិណ្ឌ ជួបជុំអ្នកស្រុកជើងវត្ត ពួកខ្ញុំក៏បានតាក់តែងជញ្ជូនយករូបកំណាត់តូចធំទីងតារ៉ែកអក្សរ ១ ផ្ទាំងផងដាក់ក្នុងទូកជាមុនស្រេច ដល់ទេសនាចូនបង្ហើយបុណ្យភ្ជុំបិណ្ឌរួចហើយ វេលាម៉ោង ៣ រសៀល ខ្ញុំក៏តាក់ឲ្យមេឃុំរកមនុស្សគ្រាស់ព្រះពុទ្ធរូបរំកិលចុះពីបល្ល័ង្កនិមន្តទៅដាក់ក្នុងទូករួចជាស្រេចក្នុងវេលាម៉ោង ៧ ល្ងាចដោយមានក្មេងសៀមទីងនៃឃុំហែហាមផង ។

ប្រមូលបុរាណវត្ថុដែលយកពីវត្តកំពង់ហ្លួងក្នុងពេលនោះទាំងប៉ុន្មានគឺព្រះពុទ្ធរូបធំក្នុងវិហារ ១ អង្គ, កំណាត់ខ្ទននាងសាសនាព្រាហ្មណ៍ ៣, ព្រះកេសព្រះពុទ្ធរូបតូច ១, ព្រះកេសនាងសាសនាព្រាហ្មណ៍ ១, កំណាត់សសរទ្រូងម្ចាស់ទ្វារ ១, កំណាត់ដៃ-ជើងនិងកំណាត់ចង្កេះផ្សេងទៀត ៣៤, កំណាត់ដៃចង្កេះធ្វើអំពីសំរឹទ្ធគាស់បានមកពីក្រោមក្តួចខាងក្រោយព្រះពុទ្ធរូបធំក្នុងវិហារទម្ងន់ ២៣០ ក្រាម ១ នឹងកំណាត់ដែនប្រាក់ចំនួន ១៣ កំណាត់ផង, កំណាត់ចុងជើងយកពីទួលក្តិតូច ១, ព្រះកេសព្រះពុទ្ធរូបយកពីទួលវត្តកោតាន់ត្រី ១, មានកំណាត់ខ្ទនតូចៗ ២ កំណាត់និងកំណាត់ចុងជើង ១ ដែលបានមកពីក្នុងវត្តជ្ងទវត្សង ដោយលោកគ្រូកុង អៀកម៉ាបានឲ្យមកពីថ្ងៃមុនផង ។

ការយកព្រះពុទ្ធរូបវត្តកំពង់ហ្លួងនេះបានដោយពិបាកបន្តិច ព្រោះមនុស្សទាំងប៉ុន្មានគ្មានអ្នកណាមួយហ៊ានគាស់រំលើងបល្ល័ង្កយកព្រះពុទ្ធរូបនោះឡើយ សង្កេតមើលទៅមកពីខ្លាចបាញ់បារមីព្រះពុទ្ធរូបនោះក្រែងធ្វើខ្លួនឲ្យស្លាប់ឬឲ្យឈឺថ្កាត់ពុំនោះឲ្យវិនាសអន្តរាយផ្សេងៗ លុះតែគេជួលជាងជាតិយួនម្នាក់ឲ្យគាស់ទើបសម្រេចបាន អ្នកកាន់ព្រះពុទ្ធសាសនាក្នុងស្រុកខ្មែរ ប្រែងតែគោរពកោតខ្លាចព្រះពុទ្ធរូបតាមទំនងដែលនិយាយខាងលើនេះឯង មានតែខ្លះខ្លាចព្រះពុទ្ធរូបរហូតដល់ទៅមិនហ៊ានបោសសំអាតបល្ល័ង្កឬទីវិហារឲ្យស្អាតល្អឡើយ ទុកឲ្យនៅស្មុគស្មាញដោយដើងពួបគរពក់កយទឹងសំរាមធូលីគ្របរុំព្រះពុទ្ធរូបនិងទីវិហារ រកតែកន្លែងលម្ហឲ្យអង្គុយថ្វាយបង្គំព្រះពុទ្ធរូបគ្មាន ប្រសិនបើព្រះពុទ្ធព្រះអង្គជាមនុស្សកាចធ្វើសត្វឲ្យស្លាប់ឲ្យឈឺឬឲ្យអន្តរាយផ្សេងៗ មែន តើអ្នកណាគេនឹងគោរពប្រណិប័តន៍ ហើយសង្វាតកសាងព្រះពុទ្ធរូបបិទមាសយ៉ាងល្អទាំងចំណាយប្រាក់រាប់ម៉ឺនធ្វើវិហារដ៏ធល់ទៀតជាប្រយោជន៍អ្វី ? យើងគោរពប្រណិប័តន៍ព្រះពុទ្ធរូបប្រយោជន៍យកបុណ្យ ដែលហៅថាបុណ្យគឺសេចក្តីល្អបរិសុទ្ធដែលយើងបានធ្វើដោយកាយវាចាចិត្តចំពោះព្រះពុទ្ធ; ឯពាក្យថាកាច, ធ្វើឲ្យស្លាប់ឬឲ្យអន្តរាយជាអំពើបាបអាក្រក់ ចុះបើយើងថ្វាយបង្គំព្រះពុទ្ធរូបឬពុំហ៊ានបោសសំអាត ដោយយកពាក្យអាក្រក់មកគិតថាព្រះអង្គកាច ធ្វើឲ្យស្លាប់ឲ្យអន្តរាយហើយ តើនឹងឲ្យឈ្មោះថាបាន

បុណ្យមកពីណា? ឯការខ្វេះកកាយព្រះពុទ្ធរូបនោះ លុះតែធ្វើដោយចេតនាប្រឹងនឹងបំផ្លាញចោល ទើបគួរឲ្យខ្លាចមែន ចុះបើខ្វេះកកាយដោយកុសលចេតនា ប្រឹងនឹងជួសជុលឲ្យល្អឡើងវិញ ឬរំកិលផ្លាស់ទីកន្លែងប៉ុណ្ណោះ តើអ្នកប្រាជ្ញខាងពុទ្ធសាសនាណា ហ៊ានកាត់សេចក្ដីថាបាបបាន? ។

រឿងនេះ ខ្ញុំបានទូលលោកគ្រូចៅអធិការនឹងអ្នកស្រុកជើងវត្តខ្លះ តាមផ្លូវធម៌ដើម្បីបន្ទន់ចិត្តអ្នកស្រុកថា ការដែលយើងស្រឡាញ់ព្រះពុទ្ធរូប ហើយទុកសម្រាប់គោរពថ្វាយបង្គំតែម្នាក់ឯង ឬចំពោះតែស្រុកមួយៗ ឈ្មោះថាយើងកំណាញ់បុណ្យ ព្រោះពជការស្រឡាញ់ព្រះពុទ្ធរូបដែលជាបុរាណវត្ថុណាស់ កំពុងតែគេប្រមូលយកទៅទុកនៅសារមន្ទីរភ្នំពេញ · ដើម្បីរក្សាទុកឲ្យបានគង់នៅល្អផង សម្រាប់ឲ្យសាធារណជនថ្វាយបង្គំយកបុណ្យផង ពេលបើយើងជូនទៅពជការហើយទុកដូចជាបានធ្វើបុណ្យនឹងពជការឬចំពោះនឹងអ្នកនគរទាំងមូល ព្រោះពជការយកទៅនឹងដំកល់ទុកក្នុងសារមន្ទីរភ្នំពេញ ដែលមានមនុស្សចេញចូលមួយថ្ងៃៗរាប់រយនាក់ កាលបើបានឃើញព្រះពុទ្ធរូបរបស់យើង ហើយគេនឹងលើកដៃថ្វាយបង្គំគ្រប់គ្នា ចំណែកបុណ្យវិញក៏នឹងកើតមាន ដល់យើងជាម្ចាស់រាល់ៗមនុស្សដែលថ្វាយបង្គំ តបើ ១ ថ្ងៃមានគេថ្វាយបង្គំ ១០០ ដង បុណ្យនឹងបានដល់យើង ១០០ ដងក្នុងថ្ងៃនោះដែរ ។

ចំណែកព្រះពុទ្ធរូបបើយើងជូនដល់ការគោរពដោយចិត្តជ្រះថ្លា យើងនឹងបានបុណ្យពីកជការផង បានបុណ្យអំពីមនុស្សណាដែលទៅថ្វាយបង្គំព្រះពុទ្ធរូបរបស់យើងផង១ទៀតជាហេតុនាំឲ្យយើងមានឱកាសធ្វើបុណ្យចំណាយប្រាក់ កសាងព្រះពុទ្ធរូបដទៃទៀតជំនួសឡើងសម្រាប់ថ្វាយបង្គំយកបុណ្យតទៅទៀតផង ឯការសោកស្តាយនោះគឺដោយសេចក្តីយល់ខុសជាប្រាកដ បើតាមពិតវិញនោះត្រូវយល់ថា ស្រុកអង្គរបុរីនេះដែលកជការត្រូវការចេញចូលញឹកញយតាំងបានរៀបរយ បន្តិចឡើងនេះ អាស្រ័យដោយគុណដុំឥដ្ឋដុំថ្មនឹងរូបដែលជារបស់ពីបុរាណប៉ុណ្ណោះ អស់លោកអស់អ្នកទាំងឡាយត្រូវយល់តទៅទៀតថា អំណើះតទៅមុខទៀត ប្រសិនបើកជការមករៀបចំតាក់តែង ស្រុកនេះឲ្យថ្កុំថ្កើងរុងរឿងមានរបៀបរៀបរយសម្បូណ៌សប្បាយឡើងនោះ ក៏អាស្រ័យដោយសារគុណដុំឥដ្ឋដុំថ្មអំបែងភាជនៈ ឬខ្ទួលនឹងរូបថ្មបុរាណដែលជាមរតកនៃបុព្វ-បុរសរបស់យើងបានសាងទុកជាសម្បត្តិឲ្យសុខដល់យើង ដោយកជការបានមកប្រមូលយករូបនឹងចារឹកអក្សរជាដើមទៅទុកនៅសារមន្ទីរភ្នំពេញ ហើយពិនិត្យរកពង្សាវតារទៅឃើញថា គួរនឹងរៀបចំធ្វើឲ្យទៅជាទីរមណីយដ្ឋានល្អឡើង ។ កាលដែលខ្ញុំនិយាយយ៉ាងនេះទៅវិញនោះ អ្នកស្រុកខ្លះដែលបានឮហើយចូលចិត្តស្តាប់បានច្រើនដែរ ប៉ុន្តែមិនដាច់ចិត្តនៅតែអាល័យមមៃមមាញឹកនឹកពុំភ្លេច ។

# អំពីផ្ទាំងបល្ល័ង្កធំដែលមានសិលាចារឹកនៅទួលសែនស្មុត

ដល់ថ្ងៃ ១៨ សេបតេម្ប្រ៍ ត្រឡប់ទៅយកបល្ល័ង្កធំ ១ ទំហំ ១ ជ្រុង ១ ម. ៥០ កំពស់ ០ ម. ៨៥ មានសិលាចារឹកនៅជ្រុងទាំង ៣ ដែលនៅជាប់នឹងទួលសែនស្មុតត្រង់ទីអង្គរបុរីខាងត្បូងមាត់ស្ទឹងបន្ទាយប្រហែល ១០០ ម. ដែលបានកំកាយយកពីថ្ងៃ ១៥ នឹង ១៦ សេបតេម្ប្រ៍ ២ ថ្ងៃមុនហើយ ប៉ុន្តែដោយហេតុថ្មនោះធំធ្ងន់ណាស់ ទាំងមនុស្សអ្នកធ្វើការក៏ទៀបហត់ កាលពីធ្វើបុណ្យនោះផង មិនបានជួបជុំគ្នាច្រើន បានជាកំកាយមកបានដោយយឺតយូរបន្តិច ២ ថ្ងៃបានឃ្លាតពីកន្លែងដើមជាងពាក់កណ្ដាលទីប៉ុណ្ណោះ ហើយក៏បន្ទន់ទុកសិន បានត្រឡប់ទៅយកព្រះពុទ្ធរូបវត្តកំពង់ហ្លួងវិញ ព្រោះថ្ងៃ ១៧ សេបតេម្ប្រ៍ជាថ្ងៃភ្ជុំបិណ្ឌ អ្នកស្រុកមកជួបជុំច្រើន ឯបល្ល័ង្កធំនោះបម្រុងជាទីឯកទៅដាក់ក្នុងទូកឲ្យហើយស្រេចក្នុងថ្ងៃ ១៨ សេបតេម្ប្រ៍តែម្ដង លុះដល់កាត់ស្ពានស្រាប់តែបិនម្ចាស់ទូក ឃើញថ្មនោះធំពេកក៏ប្រកែកពុំព្រមឲ្យដាក់ ក្រែងធុះធ្លាយទូក ឲ្យបិននោះរកជួលទូកដទៃទៀតក៏រកពុំបាន ឲ្យមេឃុំអង្គរបុរីរកជួលទៀតក៏ពុំបានដែរ ព្រោះតែខ្លាចថ្មនោះពុំហ៊ានជួលទូកឲ្យដាក់សោះ ម្ល៉ោះហើយទាំងខ្ញុំអស់សង្ឃឹមថានឹងរកបានទៀត បានជាខ្ញុំនិងលោកគី-គិមស៊ីរ ចេញទៅតាកែវក្នុងថ្ងៃ ១៩ សេបតេម្ប្រ៍ ដើម្បីជំរាបដល់ព្រះបាទម្ចាស់ចៅហ្វាយខេត្រតាកែវ

នឹងនិយាយទូរសព្ទជំពប់ដល់លោកអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ ឯភ្នំពេញឲ្យបានជ្រាបផង បើយ៉ាងហ្នឹងគេនឹងធ្វើដូចម្តេច ចំណែកព្រះបាទម្ចាស់ចៅហ្វាយខែត្រតាកែវ ឃើញខ្ញុំចូលទៅដល់សួរដឹងសេចក្តីហើយលោកមានអធ្យាស្រ័យមិនសប្បាយសោះ ទើបលោកអញ្ជើញចូលទៅជួបនឹងលោកឡឺរេស៊ីដង់ ជំពបតាមដំណើរហើយក៏សរសេរសំបុត្រ ១ ច្បាប់បង្គាប់ទៅមេឃុំនឹងសេហ៍ប៉ុស្តិ៍ឲ្យចាំខ្វល់ខ្វាយរកទូកដាក់ថ្មនោះឲ្យបានទើបសមគួរតាមផ្លូវរាជការ ហើយឲ្យខ្ញុំនឹងលោកគី-គឹមស៊ីត្រឡប់ទៅអង្គរបុរីវិញ ។

ថ្ងៃ ២០ សេបតម្ប៊ែរវេលាម៉ោង ៨ ព្រឹកខ្ញុំនឹងលោកគី-គឹមស៊ីក៏ចេញពីតាកែវត្រឡប់ទៅអង្គរបុរីវិញ ម៉ោង ៣ រសៀលទើបបានដល់អង្គរបុរីហើយយកសំបុត្រទៅជូនមេឃុំនឹងលោកសេហ៍ប៉ុស្តិ៍បានមើលសព្វគ្រប់ហើយទើបមេឃុំទៅជួលទូកចិនម្នាក់ នៅអង្គរបុរីដែលកាលពីដើមមិនហ៊ានយកមកដាក់ថ្មនោះដោយយល់ថាតូចពេក លុះជួលបានហើយក៏ប្រគល់ឲ្យជាងយួនម្នាក់ជាមេទូលរៀបចំដាក់ថ្មក្នុងទូកនឹងនាំរហូតដល់ភ្នំពេញផង ក្នុងវេលាម៉ោង ៧ កន្លះល្ងាចថ្ងៃ ២០ សេបតម្ប៊ែរនោះក៏បានចាត់ចែងដាក់ថ្មក្នុងទូកហើយជាស្រេច ការយកព្រះពុទ្ធរូបនឹងបល្ល័ង្កអស់ត្រឹមប៉ុណ្ណេះ ។

## អំពីដំណើរចេញពីអង្គរបុរី

ថ្ងៃ ២១ សេបតម្ប្រ៍ វេលាម៉ោង ១១ ព្រឹកខ្ញុំបានអាហាររួច ហើយលោកមេឃុំបានឲ្យគេនាំក្មេងសៀមថ្វាយព្រះពុទ្ធរូប ជូនដំណើររួច ទើបឲ្យទូកចាំង ៣ ចេញអំពីអង្គរបុរីចុះទៅបូដុក ( ចាក់ជ្រូក ) ដើម្បីទៅចាំសណ្ដោងកប៉ាល់ពីទីនោះមកក្រពេញ ព្រោះទឹកហូរខ្លាំងវែងព្រៃស ទឹកពុំរួច ឯលោក អ៊ុក-សេន និង សៅ-សឿង បានឲ្យមកជាមួយនឹងទូកដើម្បីរក្សាបុរាណវត្ថុដែលនាំមកទាំងអស់ ចំណែកខ្លួនខ្ញុំនិងលោក គី-គីមស៊ីវ ក៏ចេញពីអង្គរបុរី ត្រឡប់មកតាកែវវិញ ក្នុងពេលជាមួយគ្នានោះឯង ដោយមានការត្រូវបង្ហួសទៅពិនិត្យមើលសិលាចារឹកនៅប្រាសាទភ្នំបាយង់ (ស្រុកគិរីវង្សគេទៅទៀត) លុះបានទៅដល់តាកែវចូលទៅផ្ទះ ប្រាប់បាទម្ចាស់ទៅហ្វាយវៃ ត្រូវតាមដំណើរសព្វគ្រប់ហើយលោកមានចិត្តសោមនស្សរីករាយសប្បាយច្រើនណាស់ ដោយលោកបានខ្វល់ខ្វាយចាត់ការនាំបុរាណវត្ថុ បានសម្រេចដោយចេស្ដានុភាពរបស់លោក រួចទើបលោករៀបចំដំណើរឲ្យទៅភ្នំបាយង់ក្នុងថ្ងៃស្អែកទៀត ។

## អំពីដំណើរទៅភ្នំបាយង់ស្រុកគិរីវង្ស ( តាកែវ )

ថ្ងៃ ២២ សេបតម្ប្រ៍ វេលាម៉ោង ៧ ព្រឹកខ្ញុំនិងលោកគី-គីមស៊ីវ បានចេញដំណើរពីតាកែវសំដៅទៅស្រុកគិរីវង្សដោយរ៉ឺម៉ក រសៀលម៉ោង ១ បានទៅដល់ផ្សារទន្លាប់ចម្ងាយផ្លូវពីតាកែវទៅ ៤០ គីឡូម៉ែត្រ

ឈប់សម្រាកទទួលទានបាយហើយខ្ញុំក៏ទុកលោក ត-គឹមស៊ីវ ឲ្យនៅចាំនឹងផ្សារទន្ទាប់ ម៉ោង ៣ រសៀលខ្ញុំក៏ចេញពីនោះបន្តរទៅសាលាស្រុកគិរីវង្ស ចម្ងាយផ្លូវ ១៤-គីឡូម៉ែត្រទៀត ដើម្បីទៅជួបនឹងលោកចៅហ្វាយស្រុកតាមបណ្ដាំចៅហ្វាយខេត្ត លុះរសៀលម៉ោង ៤ កន្លះ បានទៅដល់សាលាស្រុកគិរីវង្សយកសំបុត្រ ១ ច្បាប់ ដែលចៅហ្វាយខេត្តផ្ញើទៅៗ ជូនលោកចៅហ្វាយស្រុកៗ មើលរួចហើយ ក៏ជូនខ្ញុំត្រឡប់មកផ្សារទន្ទាប់វិញភ្លាម ដោយលោកមានដំណើរទៅយកប្រាក់ទៅដាក់ឃ្លាំងនៅតាកែវក្នុងវេលានោះផង លោកបាននាំខ្ញុំទៅជួបនឹងលោកមេឃុំៗព្រះបាទជាន់ជុំ នឹងលោកគ្រូស៊ុក-ហាង់ មេគណវត្តក្រោម (វត្តឧត្តម) តែពេលនោះលោកគ្រូមេគណមិននៅនិមន្តទៅស្រុករមេញ ទើបលោកចៅហ្វាយស្រុកផ្ញើសំបុត្រ ១ ច្បាប់ផ្ញើទៅលោកគ្រូមេគណឲ្យបានជ្រាបដោយខ្លួន ១ ដែលមកពីស្រុកនោះ បានប្រគល់កិច្ចការរបស់ខ្ញុំចំពោះលោកមេឃុំឲ្យជួយខ្វល់ខ្វាយរួចហើយ ព្រឹកឡើងទើបលោកអញ្ជើញមកតាកែវ ។

## អំពីដំណើរមើលវត្តលើ (វត្តពោធិវង្ស)

ថ្ងៃ ២៣ សេបតម្ប៊ែ ពេលព្រឹកម៉ោង ៩ បានទៅមើលសិលាចារឹក ២ ផ្ទាំងនៅវត្តលើ មានលោកមេឃុំនឹងប៉ូលិសម្នាក់ឈ្មោះរៀនដែលបានធ្លាប់ស្គាល់មកយូរហើយជូនទៅជាមួយផង លុះទៅដល់វត្តនោះ លោក

គ្រូចៅអធិការមិននៅ ទើបខ្ញុំទៅដល់ផ្ទះបាសក ឃើញនៅតែលោកគ្រូសូត្រឈ្មោះមាស បានធ្វើបដិសណ្ឋារៈទទួលរាក់ទាក់ឲ្យក្មេងរះជូនឲ្យទទួលទានទឹកដូងហើយ ទើបលោកនាំមើលអស់ទាំងថ្មជាបុរាណតែប៉ុន្មានដែលមានក្នុងវត្តនោះ ខ្ញុំបានពិនិត្យមើលសព្វឃើញក្រៅអំពីចារឹកអក្សរ ២ ផ្ទាំងទៅនៅមានផែនថ្មជាគ្រឿងប្រដាប់ប្រាសាទ មានថ្មមេទ្វារជាដើមចំនួន ១៧, មានទ្រនាប់ជើងជណ្ដើរ ១ បល្ល័ង្ក ១ ស្នានព្រៃណី ឬទម្ភាយោនី ១ រូបសិង្ហ ៣ ក្បាច់ក្បាលនាគសម្រាប់បន្តុបលើជ្រុងដែងប្រាសាទមាន ២, និងមានផែនថ្ម ៣ ទៀតកាត់មូលទ្រវែងបណ្ដោយ ១ ម.២៨ ទទឹង ០ ម. ៧២ កំរាស់ ០ ម. ០៨ ផ្ទៃខាងលើជុំវិញអមខាងមានលករូងជ្រៅខ្លះរាក់ខ្លះមានសណ្ឋានផ្សេងៗគ្នា អ្នកស្រុកហៅថាថ្មព្រះបាទជាន់ជុំ ខ្លះថា ជើងប្រជុំ ដោយសំគាល់ថាជាស្នាមជើងដែលជាន់ជុំវិញ ទាំងឈ្មោះឃុំទៀតក៏ឲ្យឈ្មោះតាមថ្មនោះដែរ ( ឃុំព្រះបាទជាន់ជុំ ) ប៉ុន្តែខ្ញុំបានសង្កេតមើលថ្មនោះសព្វហើយ មិនឃើញមានទំនងល្មមឲ្យសំគាល់បានថាជាស្នាមជើងអ្វីសោះ ដែលហៅដូច្នោះប្រហែលជាដោយសន្មតរបស់អ្នកស្រុកទេដឹង? ថ្មនោះសព្វថ្ងៃបែកជា ៦ កំណាត់គ្រាន់តែផ្គុំទល់គ្នាទុកនៅលើសាលាវត្តនោះ ខ្ញុំឃើញហើយនឹកស្ដាយណាស់ក្រែងតទៅនឹងវិនាសបង់ដោយគ្មានគេថែរក្សា ព្រោះកន្លែងដែលទុកដាក់សព្វថ្ងៃក៏មិនបានសមគួរដែរ ចំណែកថ្មបុរាណក្រៀមដែលជាគ្រឿងប្រដាប់ប្រាសាទ

បុរាណក៏នៅសល់ច្រើន តែមានខ្លះទើបនឹងធ្វើជាន់ក្រោយ ក្នុងវិហារមាន ព្រះពុទ្ធរូបធ្វើអំពីថ្ម ៤ អង្គដែលជាស្នាដៃពីបុរាណ ត្រង់ទីវិហារជាតន្ទន់ របស់ប្រាសាទបុរាណ ១ លុះដើរមើលសព្វហើយទើបបានទៅថ្វាយបង្គំ លោកគ្រូចៅអធិការដែលទើបនឹងនិមន្តមកពីផ្ទះឧបាសក វេលាដែលលា លោកត្រឡប់វិលវិញ លោកប្រគល់ស្រ្តីកចាស់បានឲ្យរូបស្វាហនុមាន ១ ធ្វើអំពីសំរិទ្ធជារូបឈរពេញជើងដៃផ្ទុំមានកំពស់ ០ ម. ១៦ ទម្ងន់ ១០៣២ ក្រាមបានមកអំពីទួលអ្នកតាកំពែងធំ ដោយឧបាសកម្នាក់ឈ្មោះ ប៉ាយ-ជ្រែក បានកាប់ដីក្បែរទួលនោះ, នៅចុងផ្លូវដែលបុរាណដែលលើក ជាប់ពីប្រាសាទភ្នំបាយ៉ង់ ធ្វើជាជើងសណ្ដកបានឃើញរូបនោះហើយ ក៏យកទៅប្រគេនលោកឲ្យរក្សាទុក ។

## អំពីដំណើរទៅជួបនឹងលោកគ្រូមេគណវត្តក្រោម

ក្នុងវេលាល្ងាចថ្ងៃ ២៣ នោះ លោកគ្រូមេគណបាននិមន្តពីស្រុករមេញ (ឈ្មោះអណ្ដែត) វិញ ខ្ញុំក៏បានទៅថ្វាយបង្គំទូលលោកតាមដំណើរថា ខ្ញុំករុណាដែលមកនេះដោយមានសំបុត្រ ១ ច្បាប់ពីលោកឡឺរេស៊ីដង់តាកែវ ទៅជំរាបលោកអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ ថាព្រះតេជព្រះគុណបានជំរាបលោកឡឺរេស៊ីដង់ថា បានឃើញសិលាចារឹក ២ ផ្ទាំងនៅកណ្ដាលប្រាសាទភ្នំបាយ៉ង់ កប់នៅក្នុងដីគ្មាននរណាដែលឃើញទេ ឥឡូវនេះលោកអគ្គលេខាធិការពុទ្ធសាសនបណ្ឌិត្យចាត់

ឲ្យខ្ញុំករុណាមកពិនិត្យអក្សរចារឹកនោះហើយឲ្យថតយកទៅផង ប្រសិនជាមានមែន មានសេចក្ដីរៀបរាប់ល្អពេកទំនងប្រហែលនឹងផ្ញើទៅដល់ព្រះតេជគុណ ដ៏លោកគ្រូមហាគណ ក៏មានព្រះពុទ្ធដីកាតបមកខ្ញុំវិញថា កាលដែលអាត្មាភាពជាមួយលោកឡើងទៅរុករកអក្សរនោះពុំមែនបានឃើញសិលាចារឹកទេ អាត្មាភាពគ្រាន់តែបានឮពាក្យថា នៅកណ្ដាលប្រាសាទភ្នំបាយ៉ង់មានថែនថ្ម ២ ផ្ទាំង គ្មាននរណាដែលអាចមើលទេ ប្រហែលជាមានរបស់អ្វីនៅខាងក្រោមថែវដឹង?

## អំពីទៅមើលប្រាសាទលើភ្នំបាយ៉ង់

លុះដឹងថាមិនពិតដូច្នោះហើយ ខ្ញុំក៏នៅតែមិនទាន់អស់ចិត្តបង់ទៅមើលឲ្យឃើញច្បាស់ដោយខ្លួនឯង លោកគ្រូមគណឃាត់ខ្ញុំកុំឲ្យទៅ បានជួបតែត្រឹមលោកប៉ុណ្ណឹងបានសេចក្ដីហើយ ព្រោះផ្លូវឡើងទៅមើលប្រាសាទលើភ្នំបាយ៉ង់នោះ ផ្លូវនេះពិបាកឡើងទៅណាស់ព្រៃឈើឬស្សីព្រៃបន្លាទ្រនាប់ត្រដុះការពារផ្លូវបង្អៀតអស់ ប្រែកមិនចុះ ១ ទៀតក៏ក្រែងប្រទះទៅជាន់លើសំបុកសត្វតុកកែ ព្រោះសត្វនោះវាតែងខាំហើយសូម្បីតែ ១ ក៏អាចធ្វើឲ្យគ្រុនបាន ឯសត្វពស់អាសិរពិសក៏ក្នុងផ្លូវនេះច្រើនសម្បូរណាស់ដែរ តាមផ្លូវពណ្ណរាបច (ផ្លូវបុរាណ) នោះចោតណាស់ រលេះរលើកអស់ហើយ គ្មាននរណាដែលហ៊ានឡើងទេ ចំណែកខ្លួនខ្ញុំគេ-តមស៊ីឲ្យនៅទីសាលាឃុំដោយមិនដាក់ខ្លួន ក៏សុំខ្លួនទៅមើលឲ្យឃើញច្បាស់

ដោយព្រួយបារម្ភណា សាំក្រែងនាយចៅហ្វាយ៉ះបន្ទោសថាទៅដល់ហើយ ម្ដេចក៏មិនទៅមើលឲ្យជាក់ច្បាស់ដោយខ្លួនឯងផង ដោយខ្លួនខ្ញុំបង់ទៅមើលបុកណាវត្ថុដែលមិនទាន់បានឃើញផង ។

ថ្ងៃ ២៤ សេបតមប្រ៍វេលាម៉ោង ៧ ព្រឹកខ្ញុំក៏ចេញពីសាលាឃុំនៅផ្សារទន្ទាប់ទៅជាមួយនឹងអ្នកស្រុក ៣ នាក់ ដែលមេឃុំគាត់ឲ្យជូនទៅ ចម្ងាយពីផ្សារទន្ទាប់ទៅដល់ជើងភ្នំ ៣០០០ ម. ឡើងពីជើងភ្នំទៅដល់ប្រាសាទតាមផ្លូវដែលគេធ្វើបត់ចុះឡើងចម្ងាយប្រហែល ៣០០០ម. ទៀត ប៉ុន្តែដើរកាត់ផ្លូវតាមផ្លូវញាតស្បាតខ្លះ ក៏ជំពាក់ដែលឡើងភ្នំបង់ឆាប់ទុកជាមេឃស្រទំហើយមានឈើមស្រែបផង ក៏នៅតែបែកញើសហូរស្រក់ជោគខោអាវទៅជាងនឹងមុខបង់ខ្យល់ចាប់ ទឹកស្មានថាប្រហែលជាទៅមិនដល់តែដោយបុណ្យកុសលប្រឹងដើរបន្តិចទៅបានដល់ទីកបស្ដូ ១ ជាកន្លែងដែលគេធ្វើសាលាមួយសម្រាប់សំណាក់យកខ្យល់អាកាស លើភ្នំនោះខាងឆាយប្រាសាទភ្នំបាយង់ចម្ងាយប្រហែល ៦០០ម. ឯសាលានោះគ្លើងព្រៃគេះអស់ ហើយនៅសល់តែសសរ ខ្ញុំក៏ឈប់សម្រាកនៅទីនោះបន្តិចបានត្រៃខ្យល់អាកាសត្រជាក់មានកំឡាំងស្រួលខ្លួនហើយក៏ខំប្រឹងឡើងទៅទៀត ដើរបន្តិចទៅបានឃើញប្រា-សាទ ១ ធ្វើអំពីឥដ្ឋទំហំ ៤ ម. ៥០ បួនជ្រុងទៀនខាងក្រោមតប្ងំនៅក្នុងដីឈមមុខផ្ទោះទៅកេប្រាសាទភ្នំបាយង់ ដែលនៅលើកំពូលភ្នំខាងទិស

ពាយ័ព្យ ប្រាសាទនោះគង់នៅក្នុងព្រៃស្ងាត់ជិតឈើង អ្នកស្រុកហៅថា
ប្រាសាទព្រះគោ ខ្ញុំបានចូលទៅមើលតែមិនមានវត្ថុវិសេសអ្វីល្មមគត់ទុក
ជាសំគាល់បានទេ ១ ទៀតព្រៃដុះស្និទ្ធជិតណាស់មិនអាចនឹងប្រៀតជ្រែក
គេមើលឲ្យឃើញច្បាស់បានឡើយ រួចហើយក៏ឡើងបន្តសទៅទៀតដល់
ប្រាសាទលើកំពូលភ្នំបាយង់ វេលាម៉ោង ១០ ព្រឹក ឯទីជុំវិញប្រាសាទ
ដែលបានកាប់ឆ្កាគាស់កកាយចេញម្តងហើយនោះ ឥឡូវនេះឈើនឹង
ទន្ទ្រានខែត្រដុះស្និទ្ធជិតឡើងវិញ តែនៅល្មមរកឈ្លោកគេមើលដោយ
កន្លែងបានខ្លះ ចំណែកប្រាសាទនោះធ្វើអំពីថ្មទំហំបណ្តោយ ១០ ម.
ទទឹង ៧ ម. ៨០ បែរមុខទៅខាងទិសអាគ្នេយ៍ ត្រង់កណ្តាលផ្ទៃប្រាសាទមាន
រៀបជាបន្ទប់ ១ តូចមានទំនងដូចជាប្រាសាទតូច ១ ដែលធ្វើជាយូរហើយ
ដល់តមកខាងក្រោយធ្វើប្រាសាទ ១ ធំគ្របពីលើទៀត តែគេមិនបានរុះ
រើប្រាសាទមុនចោលទុកឲ្យនៅធ្វើជាបន្ទប់ខាងក្នុង ខាងមុខមានរៀបជា
មង្គ្រាប្តូយ៉ាតផាប់មកពីតួប្រាសាទសងខាង មានវៃវេតប៉ែនផង ឯការធ្វើ
ខាងក្រៅតាំងប៉ុន្មានសុទ្ធតែធ្វើអំពីថ្មបាយក្រៀមតាំងអស់ ហើយរលំ
រលើងតាំងអស់នៅសល់តែសសរទើងជញ្ជាំងខ្លះប៉ុណ្ណោះ ត្រង់កណ្តាល
បន្ទប់ក្នុងផ្ទៃប្រាសាទនោះមិនឃើញមានផែនថ្ម ២ ផ្ទាំងដូចលោកគ្រូមេគណ
និយាយទេ មានតែថ្មបាយក្រៀមធំៗទំហំប្រហែល ០ ម. ៥០ បួនជ្រុង
ច្រើនដុំក្រាលត្រង់កណ្តាល ហើយមានកំណាត់ក្បាច់នឹងកំណាត់រូបជា

ច្រើននៅត្រង់កន្លែងនោះមានផែនថ្មខៀវ ៗ ផ្ទាំងដាក់តគ្នាពីមាត់ទ្វារខាងក្រៅចូលទៅបន្ទប់ខាងក្នុង ខាងមុខប្រាសាទមានបល្ល័ង្ក ២, កំណាត់ចុងជើងឈរជាប់នឹងទ្រនាប់ ១ រូបស្រី ១ នៅតែពីត្រឹមកទៅជើងបញ្ឈរជាប់នៅលើបល្ល័ង្ក ក្បាលនិងដៃទាំងពីរបាក់បាត់ នៅថែវខាងលិចឃើញមានក្បាច់ខ្លោងទ្វារ (linteau) ១ ។

នៅទីប្រាសាទនោះ បើបានឡើងទៅដល់ហើយគួរឲ្យសប្បាយរីករាយណាស់ព្រោះក្រឡេកមើលទៅទិសបល្ល៍ សានឥតខាងកើត ឃើញតែវាលទឹងបឹងស្មើស្ទឹងល្ហល្ហេវមើលដាច់កន្ទុយភ្នែក បើមើលទៅទិសដទៃទៀតឃើញតែខ្នងភ្នំជាប់គ្នាជួរតាមទាបខ្លះខ្ពស់ខ្លះ ឃើញតែចុងឈើ និងស្មៅប្រែងប្រាងមិនឃើញដល់ដីទាបទេ ហើយបណ្ដាលចិត្តឲ្យស្រណោះស្រណោចខ្លោចផ្សាទឹកលើកដល់វត្ថុបុរសណាដែលកសាងប្រាសាទនោះ ដូចវត្ថុចម្ងាយដែលធ្វើរណតាពទៅ ទុកតែស្នាដៃវិសេសឲ្យកូនមើលដល់មតិចនោះខូចខាតទៅ កូនមិនអាចនឹងធ្វើដូចម្ដេចឲ្យបានដូចដើមវិញ ។ ១ ទៀត នៅលើកំពូលត្រង់ប្រាសាទបាយ័នមានខ្យល់អាកាសស្រួលណាស់ មានពពកសជាត់មកដោយខ្យល់ទាំងដុំ ៗ ធ្វើឲ្យត្រជាក់ជ្រួតជ្រាបសព្វសាច់រហូតដល់ឆ្អឹងប្រមាត់បេះដូង នាំឲ្យស្រួលខ្លួនមានកំឡាំងបាត់ឃ្លានអាហារ ។

លុះខ្ញុំដើរមើលទីងទៅសម្រាកប្រហែលជាង ១ ម៉ោងដល់ម៉ោង ១១ កន្ទះព្រឹកខ្ញុំក៏ត្រឡប់ចុះមកវិញ ទៅព្រៃភ្នំនោះសម្បូណ៌ដោយផ្លែព្រលទុំក្រហមពាសពេញព្រៃ អ្នកស្រុកទាំង ៣ នាក់ដែលជូនខ្ញុំទៅប្រញាយគ្នាបេះទទួលទានហើយបងបាច់ទាំងចង្កោម ១ ផ្ញើកូនប្រពន្ធ ខ្ញុំក៏បានទទួលទានខ្លះដែរ ផ្លែព្រលមានរសជាតិជូរឯម ហើយត្រជាក់ស្រួលណាស់បរិភោគទៅកាលណាមិនឲ្យពោសទេ. ដោយចុះពីលើភ្នំផ្លូវដើរស្រួលហើយប្រើនតែដើរកាត់ដំរង់ផង ម៉ោង ២ រសៀលក៏បានដល់ទៅសាលាឃុំនៅផ្សារទន្ទាប់ . ទទួលទានបាយរួចចូលទៅលាលោកគ្រូមេគណវត្តក្រោម វេលានោះលោកបានឲ្យត្រាប់កាំភ្លើងធំ ៣ មានទម្ងន់ ១.០១២ ក្រាម ជីកបានមកពីកន្លែងនៅទីវត្តនោះ ឲ្យយកមកជូនលោកអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យទុកជាសម្បត្តិនៃសារមន្ទីរខ្មែរភ្នំពេញ ។ រួចហើយខ្ញុំសរសេរសំបុត្រ ១ ច្បាប់ទុកឲ្យមេឃុំផ្ញើទៅជូនលោកចៅហ្វាយស្រុក រាប់រៀបអំពីការ ដែលខ្ញុំបានទៅមើលទីងអំណោយដែលបានទទួលអំពីលោកគ្រូមេគណវត្តក្រោមនិងលោកគ្រូសូត្រវត្តលើ រួចស្រេចកាលណាទើបខ្ញុំនិងលោកគី-គីមស៊ីជួលរ៉ឺម៉ក ១ វេលាម៉ោង ៤ រសៀលចេញពីផ្សារទន្ទាប់ត្រឡប់មកដល់ផ្សារតាកែវពេលម៉ោង ៧ ល្ងាច បានចូលទៅជួបនឹងព្រះបាទម្ចាស់ចៅហ្វាយខេត្តតាកែវនៅគេហស្ថានរបស់លោក ដើម្បីលាលោកត្រឡប់មកភ្នំពេញវិញផងនិងជំរាបអំពីដំណើរដែលទៅមើលភ្នំបាយង់ផង

ប៉ុន្តែត្រង់រូបស្វាហនុមាន ១ នឹងត្រាប់កាំភ្លើងធំ ១ ដែលបានមកអំពីវត្តទាំង ២ នោះគេពុំបានបង្ហាញនឹងដកបឲ្យជ្រាបផងសោះ លុះនឹកឃើញថាខាងក្រោយមានសេចក្តីព្រួយបារម្ភដែរ ប៉ុន្តែដោយមានសង្ឃឹមមាំព្រោះបានសរសេរសុំបុត្រជូនទៅដកបលោកចៅហ្វាយស្រុកគិរីវង្សហើយ ។

## អំពីដំណើរមកភ្នំពេញវិញ

ថ្ងៃ ២៥ សេបតេម្ប្រ៍ពេលម៉ោង ៧ ព្រឹក ខ្ញុំនឹងលោកគី - គឹមស៊ុំ បានចេញដំណើរអំពីតាកែវត្រឡប់ចូលមកភ្នំពេញវិញ ដោយរថយន្តឈ្នួល វេលាម៉ោង ១១ កន្លះព្រឹកក៏បានមកដល់ភ្នំពេញដោយសួស្តី ។

ចំណែកលោកអ៊ុក-សេន នឹងលោកសៅ-សឿនដែលមកជាមួយនឹងទូកនាំព្រះពុទ្ធរូបចេញអំពីអង្គរបុរីពីថ្ងៃ ២១ នោះក៏បានមកដល់ភ្នំពេញនៅវេលាម៉ោង ១២ យប់ក្នុងថ្ងៃ ២៥ នោះដែរ ចាប់ពីព្រឹមពេលម៉ោង ២ រសៀលថ្ងៃ ២៦ រៀងទៅមានការត្រូវដញ្ជូនយកព្រះពុទ្ធរូបនឹងបល្ល័ង្កជាដើម ឡើងពីទូកដែលចតនៅមុខផ្សារស៊ីញ៉ែកទៅទុកនៅសារមន្ទីរហូតដល់ថ្ងៃ ២៩ ទើបហើយជាស្រេច ដោយអ្នកទោស ៣០ នាក់នឹងពួកគូលីនៅសារមន្ទីរព្រួតគ្នាជួយដញ្ជូន ។

លុះបានរៀបទុកដាក់ក្នុងសារមន្ទីរជាស្រេចហើយ គន្ទងមកខាងក្រោយគឺនៅវេលាថ្ងៃ ១៨ ឧកតូប្រ៍ ១៩៤៨ ពេលម៉ោង ៨ ព្រឹក លោកឡឺរេស៊ីដង់ស៊ុបេរីយើរ (គោរព) អញ្ជើញទៅទស្សនាការម្តង, ដល់

ថ្ងៃ ២១ ឧកតូប៊្រ វេលាម៉ោង ៩ ព្រឹក ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម-សីហនុ ទ្រង់ស្តេចយាងទៅទតម្តង, ដល់ថ្ងៃ ២៣ ឧកតូប៊្រ វេលាម៉ោង ១១ ព្រឹក លោកគូវែរណឺរហ្សេណេរ៉ាល់ប្រទេសឥណ្ឌូស៊ីន (ហ្សង់-ដឺគូស៍) អញ្ជើញទៅមើលម្តងទៀត មានលោករ៉េស៊ីដង់សុបេ-រីយើរនិងមន្ត្រីបារាំងជាច្រើនទៅជាមួយផង ។

ឯមហាបុរសទាំង ៣ បានឃើញបុណ្យវត្តទាំងនោះ សឹងសំដែងសេចក្តីសោមនស្សរីករាយជាច្រើន ឯបណ្តាស្ត្រីខ្មែរចិនយួនវិញដែលចូលទៅមើលរាល់ថ្ងៃច្រើនជាអនេកនឹងពណ៌នាពុំបានឡើយ ។

ទីបំផុតនេះខ្ញុំមានចិត្តត្រេកអរដ៏ពន្លឹកឥតឧបមា សរសើរដល់បេស្តានុភាពនៃព្រះបាទម្ចាស់ចៅហ្វាយខេត្រតាកែវ ហើយនឹកគុណពុំភ្លេចអំពីកិច្ចដែលលោកបានចាត់ការឲ្យខ្ញុំបានសម្រេចដោយស្រួលក្នុងការដឹកនាំបុណ្យវត្តនេះផង សូមអរគុណចំពោះលោក ម៉ី-ឈឹម មេឃុំ អង្គរបុរី ដែលបានជួយខ្នះខ្នែងក្នុងការនេះ ដោយកំឡាំងកាយនឹងវាចារហូតដល់សម្រេចព្រមទាំងលោកសេហ៊ុប៉ុស្តិ៍ផង សូមអរគុណចំពោះលោកគ្រូយួនទីងជាតិយួននៅក្តា-ក្តុះ ខេត ដែលបានជួយខ្វល់ខ្វាយទទួលបដិ-សណ្ឋារៈស្មោះស្ម័គ្រដោយទឹកតែជាដើមផង អាយុ វណ្ណៈ សុខៈ ពលៈ សូមឲ្យសម្រេចជាប្រាកដដល់អស់លោក-អ្នកទាំងអស់កុំបីឃ្លាត ។

ភ្នំពេញថ្ងៃ ១៩ ណូវែមប្រ៏ ១៩៤៨ យុគបញ្ញាសោភ័ន គាំ-ឌុម

លោកគ្រូព្រះអាចារ្យ ប៉ាង-ខាត់ ប្រែនិងរៀបរៀង

(តទៅ)

(ត្រង់នេះទ្រង់សំដែងអសេខធម៌ ១០ ប្រការគឺ សម្មាទិដ្ឋិៈ សម្មាសង្កប្ប, សម្មាវាចា, សម្មាកម្មន្ត, សម្មាអាជីវ, សម្មាវាយាម, សម្មាសតិ, សម្មាសមាធិ, សម្មាញាណ, សម្មាវិមុត្តិ ) ។

ទសក-អំ- ២៤-២៣១ ១០៣

## អ្នកដែលជាប់នឹងចំណីលោក ចូលចិត្តស្តាប់រឿងកាមគុណ មិនចូលចិត្តស្តាប់រឿងស្ងប់ទេ ។

ម្នាលសុនក្ខត្តៈ! កាមគុណទាំង ៥ យ៉ាងនោះគឺ រូបដែលបុគ្គលដឹងដោយភ្នែក សំឡេងដែលបុគ្គលដឹងដោយត្រចៀក ក្លិនដែលបុគ្គលដឹងដោយច្រមុះ រសដែលបុគ្គលដឹងដោយអណ្តាត ផ្សព្វៈដែលបុគ្គលដឹងដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម ជាទីតាំងនៃសេចក្តីត្រេកអរ ។ ម្នាលសុនក្ខត្តៈ! នេះឯងឈ្មោះថា កាមគុណ ៥ ប្រការ ។

ម្នាលសុនក្ខត្តៈ! ហេតុនេះជាបាន: មានទំនងឲ្យអ្នកផងគេថាបាន មានបុរិសបុគ្គលពួកខ្លះក្នុងលោកនេះ មានអជ្ឈាស្រ័យឱនទៅរកចំណី

លោក (គឺកាមគុណ ៥ យ៉ាង) ពាក្យសំដីបុរសបុគ្គលដែលមានអធ្យា-ស្រ័យនូវទៅរកចំណីលោក តែតាំងនិយាយឡើងតែងប្រមៀលសេចក្តីទៅរកកាមគុណ ពេញចិត្តត្រិះរិះនឹងពិចារណារឿយ ៗ រកហេតុដែលអនុលោមទៅតាមកាមគុណ ចូលចិត្តសេពគប់នូវបុរសកាមគុណ គោរពគប់គាន់បុរសកាមគុណ ៗ រីឯពាក្យសំដីដែលគេនិយាយប្រកបដោយសេចក្តីដែលញាប់ញ័រ (ដោយកាមគុណ) បុរសបុគ្គល (ដែលជាប់នឹងចំណីលោក) នោះ មិនចូលចិត្តស្តាប់ មិនផ្ទៀងត្រចៀកស្តាប់ មិនតាំងចិត្តដើម្បីនឹងស្តាប់ មិនគប់រកបុគ្គលនោះផង មិនគោរពបុគ្គលនោះផង ៗ ម្នាលសុនក្ខត្តៈ! ដូចជាបុរសម្នាក់ ទានដំណើរចេញអំពីស្រុកឬនិគមរបស់ខ្លួនដែលជាទីឆ្ងាយនៅយូរយារហើយ, កាលបើបានឃើញបុរសណាម្នាក់ដែលគេទើបនឹងចេញអំពីស្រុកឬនិគមរបស់ខ្លួននោះ តែងសាកសួរដំណឹងអំពីស្រុកឬនិគមរបស់ខ្លួន អំពីសេចក្តីក្សេមក្សាន្ត អំពីមានភិក្ខា-ហារងាយរកបាន ឬពុំនោះអំពីមានជម្ងឺជកាត់, ឯបុរសនោះក៏ប្រាប់តបវិញ (តាមដំណើរ) ៗ ម្នាលសុនក្ខត្តៈ! អ្នកចូលចិត្តសេចក្តីនេះជាដូចម្តេច? តើបុរសអ្នកដំណើរនោះស្តាប់ពាក្យបុរសនោះ (អ្នកទើបមកថ្មី) ដោយប្រតិតាំងចិត្តស្តាប់ ដើម្បីដឹងពេញចិត្តនឹងបុរសនោះផង គោរពបុគ្គលនោះផង ឬទេ? ៗ

## សត្វដែលជាប់ទំនៃកាមគុណ តែងវង្វេងឈ្លក់ក្នុងកាមថាជាសុខ

ម្នាលមាគណ្ឌិយៈ! អ្នកសំគាល់សេចក្តីនោះដូចម្តេច? ភ្លើងនោះមានសម្ផស្សជាទុក្ខក្តៅក្រហាយខ្លាំង ពេលពលខ្លាំង តែក្នុងកាលឥឡូវនេះទេឬ ឬកាលពីអតីតដូច្នេះដែរ? បពិត្រព្រះគោតមដ៏ចំរើន! ក្នុងកាលឥឡូវនេះក្តី ភ្លើងនោះក៏មានសម្ផស្សជាទុក្ខ ក្តៅក្រហាយខ្លាំង ពេលពលខ្លាំង កាលពីអតីតសោតក៏ដូចគ្នាដែរ, រីបុរសឃ្លង់ ដែលមានខ្លួនដំបៅ មានខ្លួនហើមស្អុល ដង្កូវទាំងឡាយកំពុងជញ្ជក់ស៊ី, ខ្វារមុខដំបៅដោយក្រចកទាំងឡាយមានឥន្ទ្រិយស្គមគ្រោត ក៏មានសេចក្តីសំគាល់ខុសយកភ្លើងដែលមានសម្ផស្សក្តៅជាទុក្ខ (នោះ) ថាជាសុខស្រួលវិញ ។

ម្នាលមាគណ្ឌិយៈ! យ៉ាងហ្នឹងមែនហើយ ក្នុងអតីតកាលយូរអង្វែងមកហើយ កាមទាំងឡាយក៏មានសម្ផស្សជាទុក្ខ ក្តៅក្រហាយខ្លាំងពេលពលខ្លាំង, ក្នុងអនាគតដែលមិនទាន់មានមក ក៏ក្តៅដូចគ្នា, ក្នុងកាលបច្ចុប្បន្នឥឡូវនេះសោតក៏ដូចគ្នាដែរ។ (មិនមែនភ្លើងក្តៅពេលពលខុសគ្នាទេ) ម្នាលមាគណ្ឌិយៈ! សត្វទាំងនេះ ដែលមិនទាន់ប្រាសចាកតំរេកក្នុងកាមទាំងឡាយ ដែលកាមតណ្ហាកំពុងទំពាស៊ី ពេលពលដោយសេចក្តីក្តៅក្រហាយព្រោះកាម មានឥន្ទ្រិយដែលគាមបៀតបៀនហើយ ក៏នៅតែមានសេចក្តីសំគាល់ខុសក្នុងកាមទាំងឡាយ ដែលមានសម្ផស្សក្តៅជាទុក្ខ សំគាល់ថាជាសុខស្រួលវិញ ។

ម-ម- មាគណ្ឌិយសូត្រ ២៤ - ៣៦ - ៤៥

លុះកាលណាប្រាជ្ញាកើតឡើង ទើបសត្វលោកស្គាល់
សេចក្តីសុខពិត ។

ម្នាលមាគណ្ឌិយៈ! ប្រៀបដូចបុរសខ្វាក់អំពីកំណើត មិនដែលបាន ឃើញរូបពណ៌ខ្មៅនិងស ខៀវ លឿង ក្រហម ហង្សបាទ មិនដែល ឃើញទីរាបស្មើនិងមិនស្មើ មិនដែលឃើញរូបផ្កាយ ព្រះចន្ទ ព្រះអា-ទិត្យ បុរសខ្វាក់ពីកំណើតឮបុរសមានភ្នែកភ្លឺនិយាយថា: "អ្នកដ៏ចំរើន! យីអើ សំពត់សស្អាតបរិសុទ្ធ ឥតមានមន្ទិលអ្វីទេ ។ បុរសខ្វាក់អំពីកំ-ណើតនោះ ក៏ដើរស្វែងរកសំពត់ស ។ មានបុរសម្នាក់យកសំពត់ក្រាស់ ដែលធ្វើដោយរោមចៀមទៅ. ប្រលក់ដោយមែងក្លែងលាយប្រេងមក បញ្ឆោតបុរសនោះថា: "នែបុរសដ៏ចំរើន! នេះសំពត់សល្អស្អាត ឥតមាន មន្ទិលសៅហ្មងអ្វីទេ" ។ បុរសខ្វាក់ភ្នែកអំពីកំណើតទទួលយកសំពត់នោះ យកទៅដណ្តប់ ហើយនិយាយបែបញញឹមថា: "យីអើ សំពត់សល្អ ស្អាតបរិសុទ្ធ ឥតមានមន្ទិលកី" ។ មិត្រអាមាត្យញាតិលោហិត របស់ បុរសខ្វាក់អំពីកំណើតនោះ ឲ្យពេទ្យវះថែរក្សា ពេទ្យអ្នកវះថែរក្សាក៏ បានផ្សំថ្នាំឲ្យ គឺថ្នាំធ្វើឲ្យក្អួត ថ្នាំបញ្ចុះ ថ្នាំបន្តក់ ថ្នាំលាង ថ្នាំហិត បុរស ខ្វាក់អំពីកំណើតបានអាស្រ័យថ្នាំនេះហើយ ក៏បានញ៉ាំងចក្ខុឲ្យកើតឡើង ឲ្យភ្លឺឡើង បុរសនោះក៏មិនពេញចិត្តនឹងសំពត់សាច់ក្រាស់ ដែលធ្វើ

ដោយរោមចៀមខ្មៅ ដែលក់ដោយមែនគ្រឿងលាយប្រេង ហើយ លះបង់ចោលក្នុងពេលដែលបានភ្នែកភ្លឺឡើងវិញ ហើយទុកបុរសដែលបញ្ឆោតខ្លួននោះថាមិនមែនជាមិត្តផង ថាជាសត្រូវផង ឬក៏នោះក៏យល់ថាត្រូវសម្លាប់ចោលក៏សឹងតែបាន ដោយគិតឃើញថា: "ឱបុរស. នេះ យកសំពត់មានសាច់ក្រាស់ដែលធ្វើដោយរោមចៀមខ្មៅ ដែលក់ដោយមែនគ្រឿងលាយប្រេង មកបោកបញ្ឆោតប្រលោមអញថាជារបស់សប្បុរសអស់កាលយូរហើយ" (សេចក្តីនេះមានឧបមាយ៉ាងណាមិញ) ម្នាលមាគណ្ឌិយ: តថាគតគួរទិនសំដែងធម៌ដល់អ្នកថា: 'នេះជាសេចក្តីមិនមានរោគ នេះជាព្រះនិព្វាន' ក៏មានឧបមេយ្យដូច្នោះដែរ ។ អ្នកកម្សត់ដឹងសេចក្តីមិនមានរោគ ឃើញនូវព្រះនិព្វាន; ចក្ខុក ឯណាក្នុងខណៈបានកើតទាំង ៥ ឧក្កឥនោះនៅលះបង់ចោលក្នុងពេលដែលកើតចក្ខុឡើង មួយទៀត អ្នកត្រូវត្រិះរិះយ៉ាងនេះថា: "ឱហ្ន៎ ចិត្តនេះ បោកបញ្ឆោតប្រលោមភាគ្នាអញអស់កាលយូរមកហើយ បាន ជាភាគ្នាអញកាលប្រកាន់ ក៏ប្រកាន់ចំពោះរូបហ្នឹងឯង ចំពោះវេទនាហ្នឹងឯង ចំពោះសញ្ញាហ្នឹងឯង ចំពោះសង្ខារហ្នឹងឯង ចំពោះវិញ្ញាណហ្នឹងឯង ភពដែលកើតឡើងដល់ភាគ្នាអញនោះ ព្រោះបានឧបាទានជាបច្ច័យ ជាតិកើតឡើង ព្រោះមានភពជាបច្ច័យ ជរាមរណៈ សេចក្តី

ខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្ដីក្ដៅផ្សាចិត្តកើតឡើង ព្រោះមានជាតិជាបច្ច័យ ការដែលកើតឡើងនៃកងទុក្ខទាំងអស់នេះ រមែងកើតឡើងដោយការប្រកាន់យ៉ាងនេះឯង ។

ឧ-ម-អាគណ្ហិយសូត្រ ៦៤-៨៥-៩១

## បទទី ២

# ជីវិតមនុស្ស និងចតុរារិយសច្ច

## មនុស្សទាំងឡាយច្រើនគ្នា ប្រកាន់យកទីពឹងខុស

មនុស្សទាំងឡាយច្រើនគ្នាណាស់ ដែលមានភ័យគំរាមកំហែងហើយ តែងរត់ទៅជ្រករកទីពឹងភ្នំក្រំខ្លះ ព្រៃព្រឹក្សាខ្លះ សួនច្បារខ្លះ រុក្ខចេតិយខ្លះ ការរត់ទៅជ្រករកទីពឹងទាំងអស់នេះ មិនមែនជាទីពឹងដ៏ក្សេមក្សាន្តទេ មិនមែនជាទីពឹងដ៏ឧត្ដុង្គឧត្ដមទេ, មនុស្សទាំងឡាយ ដែលអាស្រ័យទីពឹងទាំងនេះ មិនរួចស្រឡះចាកទុក្ខទាំងពួងបានឡើយ ។

អ្នកឯណាមួយ យកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹងពំនាក់ហើយ ឃើញច្បាស់នូវអរិយសច្ចទាំងឡាយ ៤ ប្រការ ដោយប្រាជ្ញាដ៏មុះមុត គឺ ឃើញទុក្ខ ឃើញហេតុប្រជុំកើតឡើងនៃទុក្ខ ឃើញការកន្លងបង់នូវទុក្ខ ឃើញមគ្គប្រកបដោយអង្គ ៨ ប្រការដ៏ប្រសើរ ដែលជាធម៌នាំឲ្យរម្ងាប់បង់នៃទុក្ខ ។ ទីពឹងនេះឯងជាទីពឹងដ៏ក្សេមក្សាន្តជាទី

ពឹងដ៏ឧត្តម, រីអ្នកនោះឯង ដែលបានអាស្រ័យនូវទីពឹងនេះហើយ តែងរួចស្រឡះចាកទុក្ខទាំងពួងបានហោង ។

ខុទ្ទ. ខុ. ២៥-៤០-២៦.

## អ្នកដែលមិនដឹងអរិយសច្ច ឈ្មោះថាកសាងអន្លង់នៃសេចក្តីទុក្ខឲ្យខ្លួនឯងទៅ ។

ម្នាលភិក្ខុទាំងឡាយ! បុគ្គលឯណាមួយជាសមណៈឬជាព្រាហ្មណ៍ ដែលមិនដឹងច្បាស់តាមសេចក្តីពិតថា: "នេះទុក្ខ នេះហេតុប្រជុំកើតឡើងនៃទុក្ខ នេះធម៌ជាគ្រឿងរលត់ទុក្ខ នេះសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរលត់ទុក្ខ ដូច្នេះ" បុគ្គលទាំងឡាយនោះ តែងអភិរម្យត្រេកអរក្នុងសង្ខារទាំងឡាយ ដែលតាក់តែងប្រព្រឹត្តទៅដើម្បី ជាតិ ជរា ព្យាធិ មរណៈ សេចក្តីសោក យំខ្សឹកខ្សួល ទុក្ខកាយ ទុក្ខចិត្ត និងចង្អៀតចង្អល់ចិត្ត ។ បុគ្គលទាំងឡាយនោះឯង ដែលត្រេកអរភិរម្យក្នុងសង្ខារទាំងឡាយ ដែលតាក់តែងមានការតាក់តែងជាតិជាដើមបែបនោះៗ ហើយ ឈ្មោះថា កសាងនូវសង្ខារទាំងឡាយជាគ្រឿងតាក់តែង ដែលប្រព្រឹត្តទៅដើម្បី ជាតិ ជរា ព្យាធិ មរណៈជាដើមនោះៗ លុះបុគ្គលទាំងឡាយ កសាងនូវសង្ខារទាំងឡាយមានជាតិជាដើមបែបនោះៗ ហើយក៏ធ្លាក់ក្នុងទៅក្នុងអន្លង់នៃជាតិ ជរា ព្យាធិ មរណៈ សេចក្តីសោក យំខ្សឹកខ្សួល សេចក្តីទុក្ខកាយ ទុក្ខចិត្ត និងចង្អៀតចង្អល់ចិត្ត នោះឯង ។ ពួកគេពោលទុក

ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ទាំងសេចក្ដីខ្វាយផ្សាចិត្តកើតឡើង ព្រោះមានជាតិជាបច្ច័យ ការដែលកើតឡើងនៃកងទុក្ខទាំងអស់នេះ រមែងកើតឡើងដោយការប្រកាន់យ៉ាងនេះឯង ។

ខ-ម-មាគណ្ឌិយសូត្រ ៦៤-៨៥-៩១

បទទី ២

## ជីវិតមនុស្ស និងចតុរារិយសច្ច

## មនុស្សទាំងឡាយច្រើនគ្នា ប្រកាន់យកទីពឹងខុស

មនុស្សទាំងឡាយច្រើនគ្នាណាស់ ដែលមានភ័យគំរាមកំញើញ ហើយ តែងរត់ទៅជ្រករកទីពឹងភ្នំខ្លះ ព្រៃព្រឹក្សខ្លះ សួនច្បារខ្លះ រុក្ខចេតិយខ្លះ ការរត់ទៅជ្រករកទីពឹងទាំងអស់នេះ មិនមែនជាទីពឹងដ៏ក្សេមក្សាន្តទេ មិនមែនជាទីពឹងដ៏ឧត្ដុង្គឧត្តមទេ, មនុស្សទាំងឡាយ ដែលអាស្រ័យទីពឹងទាំងនេះ មិនរួចស្រឡះចាកទុក្ខទាំងពួងបានឡើយ ។

រីអ្នកឯណាមួយ យកព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹងពំនាក់ហើយ ឃើញច្បាស់នូវអរិយសច្ចទាំងឡាយ ៤ ប្រការ ដោយប្រាជ្ញាដ៏មុះមុត គឺ ឃើញទុក្ខ ឃើញហេតុប្រជុំកើតឡើងនៃទុក្ខ ឃើញការកន្លងបង់នូវទុក្ខ ឃើញមគ្គប្រកបដោយអង្គ ៨ ប្រការដ៏ប្រសើរ ដែលជាធម៌នាំឲ្យរម្ងាប់បង់នៃទុក្ខ ។ ទីពឹងនេះឯងជាទីពឹងដ៏ក្សេមក្សាន្តជាទី

ពឹងដ៏ឧត្តុងឧត្តម, រីអ្នកនោះឯង ដែលបានអាស្រ័យនូវទីពឹងនេះហើយ តែងរួចស្រឡះចាកទុក្ខទាំងពួងបានហោង ។

ធម្មបទ ។ ខុ. ២៥ - ៤០ - ២៦.

## អ្នកដែលមិនដឹងអរិយសច្ច ឈ្មោះថាកសាងអន្លង់នៃសេចក្តីទុក្ខឲ្យខ្លួនតទៅ ។

ម្នាលភិក្ខុទាំងឡាយ! បុគ្គលឯណាមួយ ជាសមណៈឬជាព្រាហ្មណ៍ ដែលមិនដឹងច្បាស់តាមសេចក្តីពិតថា: "នេះទុក្ខ នេះហេតុប្រជុំកើតឡើងនៃទុក្ខ នេះធម៌ជាគ្រឿងរលត់ទុក្ខ នេះសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរលត់ទុក្ខ ដូច្នេះ" បុគ្គលទាំងឡាយនោះ តែងអភិរម្យត្រេកអរក្នុងសង្ខារទាំងឡាយ ដែលគាត់តែងប្រព្រឹត្តទៅដើម្បី ជាតិ ជរា ព្យាធិ មរណៈ សេចក្តីសោក យំខ្សឹកខ្សួល ទុក្ខកាយ ទុក្ខចិត្ត និងចង្អៀតចង្អល់ចិត្ត ។ បុគ្គលទាំងឡាយនោះឯង ដែលត្រេកអរអភិរម្យក្នុងសង្ខារទាំងឡាយ ដែលគាត់តែងមានការតាក់តែងជាតិជាដើមបែបនោះៗ ហើយ ឈ្មោះថាកសាងនូវសង្ខារទាំងឡាយជាគ្រឿងតាក់តែង ដែលប្រព្រឹត្តទៅដើម្បី ជាតិ ជរា ព្យាធិ មរណៈជាដើមនោះៗ លុះបុគ្គលទាំងឡាយ កសាងនូវសង្ខារទាំងឡាយមានជាតិជាដើមបែបនោះៗ ហើយក៏ធ្លាក់ក្នុងទៅក្នុងអន្លង់នៃជាតិ ជរា ព្យាធិ មរណៈ សេចក្តីសោក យំខ្សឹកខ្សួល សេចក្តីទុក្ខកាយ ទុក្ខចិត្ត និងចង្អៀតចង្អល់ចិត្ត នោះឯង ។ តថាគតពោលទុក

ថា: "បុគ្គលទាំងឡាយនោះ មិនរួចស្រឡះអំពីជាតិ ជរា ព្យាធិ មរណៈ យំខ្សឹកខ្សួល សេចក្ដីទុក្ខកាយ ទុក្ខចិត្ត និងចង្អៀតចង្អល់ចិត្តនោះទេ ឈ្មោះថាមិនរួចស្រឡះអំពីទុក្ខទេ" ។

អ្នកដែលដឹងច្បាស់នូវអរិយសច្ច ឈ្មោះថាមិនកសាងអន្លង់ទុក្ខឲ្យខ្លួនទេ ។

រីឯបុគ្គលឯណាមួយជាសមណៈឬជាព្រាហ្មណ៍ ដែលដឹងច្បាស់តាមសេចក្ដីពិតថា: "នេះទុក្ខ នេះហេតុប្រជុំកើតឡើងនៃទុក្ខ នេះធម៌ជាគ្រឿងរំលត់ទុក្ខ នេះសេចក្ដីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខ ដូច្នេះ" បុគ្គលទាំងឡាយនោះ មិនអភិរម្យត្រេកអរក្នុងសង្ខារទាំងឡាយជាគ្រឿងតាក់តែង ដែលប្រព្រឹត្តទៅ ដើម្បី ជាតិ ជរា ព្យាធិ មរណៈ សេចក្ដីសោកយំ ខ្សឹកខ្សួល ទុក្ខកាយ ទុក្ខចិត្ត និងចង្អៀតចង្អល់ចិត្តទេ ។ បុគ្គលទាំងឡាយនោះ ដែលមិនអភិរម្យត្រេកអរក្នុងសង្ខារទាំងឡាយជាគ្រឿងតាក់តែងមានការតាក់តែងជាតិជាដើមរបស់នោះៗ ហើយ ឈ្មោះថាមិនកសាងនូវសង្ខារទាំងឡាយជាគ្រឿងតាក់តែងដែលប្រព្រឹត្តទៅ ដើម្បីជាតិ ជរា ព្យាធិ មរណៈ ជាដើមនោះៗ, លុះបុគ្គលទាំងឡាយនោះមិនកសាងសង្ខារទាំងឡាយជាគ្រឿងតាក់តែង មានការតាក់តែងជាតិជាដើមនោះៗ ហើយ ក៏មិនធ្លាក់ក្នុងចុះទៅក្នុងអន្លង់គឺ ជាតិ ជរា ព្យាធិ មរណៈ សេចក្ដីសោក យំខ្សឹកខ្សួល ទុក្ខកាយ ទុក្ខចិត្ត និងចង្អៀត

បន្ធូលចិត្តទៀតទេ ។ តថាគតពោលទុកថា: “បុគ្គលទាំងឡាយនោះ រួចស្រឡះអំពីជាតិ ជរា ព្យាធិ មរណៈ សេចក្តីសោក យំខ្សឹកខ្សួល ទុក្ខកាយ ទុក្ខចិត្ត និងចង្អៀតចង្អល់ចិត្ត ឈ្មោះថារួចស្រឡះអំពីសេចក្តីទុក្ខបាន” ។ ម្នាលភិក្ខុទាំងឡាយ! ព្រោះហេតុនោះ អ្នកទាំងឡាយ គប្បីធ្វើសេចក្តីព្យាយាម ដើម្បីឲ្យដឹងច្បាស់ថា: “នេះទុក្ខ នេះហេតុប្រជុំកើតឡើងនៃទុក្ខ នេះធម៌ជាគ្រឿងរំលត់បង់នូវទុក្ខ នេះសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខដូច្នេះ” ។

មហាវារៈ សំ. ១៩. ៥៦០. ១៧២៩

## គ្រាន់តែផ្តើមដឹងច្បាស់អរិយសច្ចប៉ុណ្ណោះ សេចក្តីទុក្ខដែលអស់ទៅច្រើនជាងដែលសល់ ។

ម្នាលភិក្ខុទាំងឡាយ ! អ្នកទាំងឡាយសំគាល់សេចក្តីនេះថាដូចម្តេច? ដីឯណាច្រើនជាងឯណា ? គឺដីបន្តិចដែលដាក់នៅចុងក្រចកតថាគត និងមហាប្រថពីនេះ? បពិត្រព្រះអង្គដ៏ចំរើន! មហាប្រថពីច្រើនសែនច្រើន ដីបន្តិចដែលទ្រង់ផ្ទេះដាក់នៅចុងក្រចកព្រះហស្តនេះជារបស់តិចណាស់ ស្មើតែមិនគួររាប់ និងមិនគួរយកមកផ្ទឹម មិនបានមួយចំណិតនឹងមិនគួរប្រៀបផ្ទឹមនឹងមហាប្រថពីឡើយ ។ ម្នាលភិក្ខុទាំងឡាយ! ខាងឧបមាយ៉ាងណា ឧបមេយ្យដូចជា សេចក្តីទុក្ខរបស់បុគ្គលជាអរិយសាវក[១]

១ សោតាបន្នបុគ្គលជាន់សត្តក្ខត្តុំបរមជាអរិយបុគ្គលជាន់ទាបក្នុងពួកសោតាបន្នបុគ្គល ។

លោកបរិបូណ៌ដោយកិរិយាឃើញ លោកដឹងច្បាស់លាស់ហើយ, ដែលអស់ទៅហើយ ទឹងសាបសូន្យទៅហើយនុ៎ះ ច្រើនសែនច្រើន ឯទុក្ខដែលសល់នៅ ជារបស់តិចណាស់ ស្ទើរតែមិនគួររាប់មិនគួរយកមកផ្គូរគ្នា មិនបានមួយចំណិត ទឹងមិនគួរប្រៀបផ្ទឹមទឹងទុក្ខដែលអស់ទៅសាបសូន្យទៅឡើយ ។ ព្រះអរិយបុគ្គលនោះ លោកត្រាស់ដឹងតាមពិតថា: "នេះទុក្ខ នេះហេតុប្រជុំកើតឡើងនៃទុក្ខ នេះធម៌ជាគ្រឿងរំលត់ទុក្ខ នេះសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខ" ។ ម្នាលភិក្ខុទាំងឡាយ! ព្រោះហេតុនោះ អ្នកទាំងឡាយគប្បីធ្វើព្យាយាមដើម្បីឲ្យដឹងច្បាស់ថា: "នេះទុក្ខ នេះហេតុប្រជុំកើតឡើងនៃទុក្ខ នេះធម៌ជាគ្រឿងរំលត់ទុក្ខ នេះសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់-ទុក្ខដូច្នេះចុះ" ៕

ចហាវិ៖ សំ. ១៩ - ៥៣២ - ១៧៤៣.

## អ្នកដែលមិនដឹងច្បាស់នូវអរិយសច្ច ឈ្មោះថាធ្លាក់ទីងងឹតគឺទុក្ខ

ម្នាលភិក្ខុ! បុគ្គលឯណានីមួយ ជាសមណៈឬជាព្រាហ្មណ៍ មិនដឹងច្បាស់តាមពិតថា: "នេះទុក្ខ នេះហេតុប្រជុំកើតឡើងនៃទុក្ខ នេះធម៌ជាគ្រឿងរំលត់ទុក្ខ នេះសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខ ។

(មានត)

## ឯកាភាគនៃមិលិន្ទបញ្ហា

## ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម រួបរួមប្រែ

(តមក)

### ពួកមានអង្គ ៥

### អង្គ ៥ របស់មាន់

១ – បៀតព្រឹកនៅយប់ងងឹត ក៏ពួនក្នុងសំបុកឬទ្រុង មិនទាន់ចុះទៅស្វែងរកអាហារទេ ៗ

២ – លុះព្រឹកភ្លឺហើយ ទើបចុះដើរដើររកអាហារ ៗ

៣ – ទីងចឹកស៊ីអាហារ តែងយកជើងកកាយដីទើបចឹកស៊ី ៗ

៤ – ក្នុងវេលាថ្ងៃ សូម្បីមានភ្នែកភ្លឺមើលឃើញច្បាស់ ដល់វេលាយប់បែរជាស្រវាំងងងឹតដូចភ្នែកខ្វាក់ ៗ

៥ – ទុកជាគេយកដុំដីចោលឬចោលទំងំណាក់ឈើឬដេញមិនឲ្យមកចូលទ្រុង ក៏មិនព្រមលះបង់ចោលទ្រុងរបស់ខ្លួនឡើយ ៗ

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ៥ ប្រការ គឺ:

១ – កាលជិតព្រឹកនៅយប់ងងឹត ក៏បោសប្រាសសំអាតទីបរិវេណ រៀបចាត់តាំងគ្រឿងប្រើប្រាស់ចាត់ឲ្យមានរបៀបរៀបរយល្អ ងូតទឹកជម្រះកាយឲ្យស្អាតហ្មត់ចត់ហើយ ក៏ចូលក្រាបសំពះបូជនីយវត្ថុ ជានិច្ចវត្តប្រចាំខ្លួន ៗ

២ – លុះព្រឹកក្រោកឡើង ក៏ធ្វើការណ៍យកកិច្ចមានកសិកម្មជាដើមតាមមុខក្រសួង តាមភេទរបស់ខ្លួន ។

៣ – ពិចារណាជាមុនហើយនេះទើបប្រកបការងារនោះផង ៖

៤ – ក្រោកមិនទាន់ ក៏ធ្វើដូចជាទាន់ គឺទុកជានៅក្នុងទីណានីមួយ ក៏តាំងចិត្តស្រើមស្រ្ទើយ កុំឲ្យត្រេកអរក្នុងអារម្មណ៍ដែលគួរប្រាថ្នា ជាទីតាំងនៃតម្រេក កុំឲ្យអន់ចិត្តក្នុងអារម្មណ៍មិនជាទីប្រាថ្នា ដែលជាទីតាំងនៃកំហឹងនឹងការស្អប់ខ្ពើម ។

៥ – ទុកជាធ្វើអ្វីៗក៏ដោយ ក៏មិនត្រូវលះបង់យោនិសោមនសិការ ដូចជាមាន់មិនត្រូវលះបង់ទ្រនំរបស់ខ្លួន ។

## អង្គ ៥ របស់អណ្តើក

១ – ជ្រែបនៅក្នុងទឹក អាស្រ័យនៅក្នុងទឹក ។

២ – មុជនៅក្នុងទឹក កាលងើបក្បាលមកលើទឹកបានឃើញអ្វីៗ ក៏ត្រឡប់មុជទៅវិញ មិនឲ្យនរណាមើលឃើញខ្លួនឡើយ ។

៣ – លុះងើបពីទឹកមកហើយ មិនឃើញមានអ្វី ក៏ហាលសំដិលកាយនៅក្នុង[illegible] ។

៤ – ដកជើងខ្លួនពួនទៅក្នុងស្នូក ។

៥ – កាលត្រាច់ដើរទៅ បើបានឃើញមនុស្សប្រុសស្រីៗ មួយឬ

បានឮសំឡេងអ្វី ក៏ពង្រួញអវយវៈទាំង ៥ គឺជើង ៤ ក្បាល ១ ចូលទៅក្នុងស្នូករបស់ខ្លួន ប្រយ័ត្នខ្លួនស្ងៀមនៅ ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ៥ ប្រការគឺ:

១ — ផ្សាយមេត្តាចិត្តជ្រាក់ តាំងចិត្តឲ្យជាប្រយោជន៍ដល់សត្វលោកទូទៅ មិនមានព្យាបាទអាឃាតចងពៀរ តាំងចិត្តភ្ជាប់ខ្លួននៅក្នុងព្រហ្មវិហារ ។

២ — កាលកិលេសកើតឡើង ក៏ទំអត់សង្កត់សង្កិនឲ្យលិចចុះទៅក្នុងអារម្មណ៍ដូចដាក់ទ្រនិចតាប់យកអារម្មណ៍មនុស្សឲ្យខ្ជាប់ មិនឲ្យពួកកិលេសហៀរចូលមកគ្របសង្កត់សន្តានចិត្តបាន ។

៣ — នាំចិត្តចេញចាកឥរិយាបថ ដេក, ដើរ, ឈរ, អង្គុយ, ហើយឲ្យប្រកបក្នុងសម្បជាន ។

៤ — រលាស់ចោលលាភសក្ការៈ នឹងពាក្យពោលសរសើរ ហើយគប្បីចូលទៅនៅសម្ងំក្នុងទីស្ងប់ស្ងាត់ ។

៥ — កាលបើទ្វារទាំង ៦ ធ្លាក់ទៅនៅក្នុងកាមារម្មណ៍ ដែលជាទីតាំងនៃតម្រេកត្រេកត្រអាល ក៏បិទទ្វារដោយឥន្ទ្រិយសំវរៈ សង្កត់ចិត្តឲ្យមានសំវរៈ ជាអ្នកមានសតិសម្បជញ្ញៈអង្គុយចំរើនកុសលធម៌ ។

(មានត)

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ
បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅពុទ្ធសាសនបណ្ឌិត្យ
បណ្ណាធិការ ផ្នែកដំណឹងសាសនាៈ ព្រះគ្រូបញ្ញាលិក្ខិត កៅ-ស៊ុម អ្នកគ្រូគ្រាសិស្ស នៅសាលាបាលីជាន់ខ្ពស់

## បញ្ជីរឿង

*ផ្នែកអក្សរសាស្ត្រ* — *ទំព័រ*

ឃុនឧត្ដមប្រីជា បាប-ពិន . . អធិប្បាយសុភាសិតខ្មែរ (តាមលំដាប់អក្សរ) . . ១៦៩
ព្រះគ្រូសទ្ធាវិទូ ពាង-សុខ . . សុភាសិតបាលីប្រែជាពាក្យខ្មែរ . . . . . . . ១៨២
ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម . . ប្រវត្តិសាស្ត្រប្រទេសចិន (តមក) . . . . . . ១៨៦

*ផ្នែកសាសនា*

លោកគ្រូអាចារ្យ ប៉ាង-ខាត់ . អរិយសច្ចជាពុទ្ធភាសិត (តមក) . . . . . ១៩៦
ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម . . ឯកកាគមិលិន្ទប្បញ្ហា (តមកនឹងចប់) . . . ២១០
អាចារ្យ ញ៉ែម-នៅ . . . . ប្រវត្តិសង្ខេបរបស់ឧបាសក ហួត-ទិន . . . ២២២

# អធិប្បាយសុភាសិតខ្មែរ

(តាមលំដាប់អក្សរ)

## យុន ឧត្តមប្រិជា ហប-ពិន

បណ្ឌិតនៃពុទ្ធសាសនបណ្ឌិត្យ    នៅមន្ទីរស្ដីការសេនាបតីក្រសួងធម្មការ

### ពាក្យផ្ដើម

បទពាក្យប្រាំពីរ

ប្រទេសនានានៅក្នុងលោក
តែងមានបណ្ឌិតប្រាជ្ញប្រពោក  អញ្ជោគផ្គួបផ្ដើមដើមគំនិត ។
ប្រមូលពាក្យពេចន៍របស់ជាតិ  ល្អ ៗ ស្អាត ៗ មកប្រឌិត
ឲ្យឈ្មោះហៅថា "សុភាសិត"  គ្រាន់ទូន្មានចិត្តជនទាំងឡាយ ។
នៅក្នុងប្រទេសរបស់ខ្លួន  ឲ្យល្អមាំមួនប្រើនសុសសាយ
ពាក្យនោះខ្លី ៗ តែអធិប្បាយ  បានឆ្ងាយទូលាយមានថ្លៃ ។
ប្រទេសខ្មែរយើងកាលត្រង់នាយ  ដែលសុខសប្បាយថ្កើងថ្កានក្រៃ
ក៏មានអ្នកប្រាជ្ញអាចកែកៃ  បានតែងជាពាក្យសុភាសិត ។
សម្រាប់ប្រដៅដូនសព្វជាន់  ឲ្យល្អគ្រប់គ្រាន់ប្រពៃពិត
អស់យើងជាន់ក្រោយស្ដាប់ពិនិត្យ  ពុះហើយគង់គិតទុកកោតក្រែង ។

សុភាសិតនោះនៅកក់ឃ  ដោយអ្នកនិយាយអ្នកសំដែង
ធ្លាយៗពីគ្នាប្រែនកន្ទែង  អ្នកណាប្រឹងប្រែងទើបដឹងបាន ។
តែគ្មានអ្នកប្រាជ្ញអធិប្បាយទុក  ឲ្យចប់គ្រប់មុខយ៉ាងចំណាន
ពោលតែខ្លីៗជាឡាក់ឋាន  គតាមពាំអាចគ្នាប៉ុណ្ណោះ ។
ខ្លួនខ្ញុំស្រឡាញ់សុភាសិត  ដែលប្រាជ្ញប្រឌិតយ៉ាងពិរោះ
ទើបបានអធិប្បាយភាសិតនោះ  ដោយគិតសង្គ្រោះយុវជន ។
មុនតែងខ្ញុំរួបរួមភាសិត  ឲ្យបានប្រៀនពិតបើយគិតគន់
បរិយាយសេចក្ដីតាមស្រាលធ្ងន់  ឲ្យយុវជនងាយស្ដាប់បាន ។
ដំណើររបៀបខ្ញុំរៀបតែង  មិនវែងមិនខ្លីល្មមប្រមាណ
តាមដោយយោបល់របស់ប្រាណ  យល់បានត្រឹមណាថាត្រឹមនោះ ។
ខ្ញុំសូមអភ័យពីអស់លោក  អ្នកបេះប្រាជ្ញព្រោកស្មោះចំពោះ
សូមលោកគន់មើលដោយអនុគ្រោះ  ចំពោះខ្លួនខ្ញុំអ្នកតែងហោង ។

ថ្ងៃពុធ ១៥ កើតខែផល្គុន ព.ស. ២៤៨៧

យុន ឧត្តមប្រីជា ចាប-ពិន

## អធិប្បាយសុភាសិត

### បទពាក្យប្រាំពីរ

### ១- ភក់ភក់ក៏ទាយ, មេម៉ាយក៏ស្រី

សុភាសិតនេះពោលបន្ទន់
គំនិតអ្នកចង់បានប្រពន្ធ ឲ្យទន់ទន្ទ្រោរបត្តគំនិត ។
ថាជម្ពាស្រីជាភរិយា ទុកជាមេម៉ាយក៏ល្អពិត
បើជាក្រមុំគស់ពិចិត្ត គំនិតមិនបានក៏មិនស្រួល ។
ប្រុស ៗ កំឡោះទានកំឡាំង នៅតាំងក្មេងវ័យក្មេងស្រួលបួល
បើបាន មេម៉ាយ យ៉ាងទំនួល ក៏គួរទទួលជាភរិយា ។
ដូចអ្នកត្រូវការដោយភោជន សម្រន់សេចក្តីឃ្លានវេទនា
បើបានបាយកកក៏ល្អជា ព្រោះជាភោជនដូចគ្នាដែរ ។

### ២- ការប៉ុនភ្នំមិនកើត, នៅកើតឯស្តួរតាំបែកមាត់

សុភាសិតនេះលោកប្រែត
ឲ្យយើងស្តាប់ហើយមានគំនិត បេះគិតការធំតាំងឡាយ ។
ដូចពេលកំពុងធ្វើការណា មានអ្នកចរចាអធិប្បាយ
ជាពាក្យលេះលោះនាំរំសាយ ឲ្យក្លាយព្យាយាមការធំនោះ ។
មនុស្សណាដែលពោលពាក្យបរិយាយ ឲ្យគេសាយការដូច្នោះ
អ្នកប្រាជ្ញលោកហៅមនុស្សលោះលោះ មិនបេះអនុគ្រោះការមុឺងម៉ាត់ ។

ពេលណាដែលធ្វើការប៉ុនក្តី    មិនគិតខិតខំដោយមធ្យ័ត
ទៅគិតឯស្គរតែបែកមាត់    ឲ្យភ្លាត់ពេលការមានប្រយោជន៍ៗ

៣- កាប់បំពង់រង់ទឹកភ្លៀង

សុភាសិតនេះប្រាជ្ញបុរាណ
ពោលជាប្រស្នាតាមលំនាំ    នៃអ្នកដែលបានចម្រើនចិត្ត ៗ
ផ្គងចាំការដោះផងតាំងឆ្ងាយ    ដែលនៅឆ្ងាយៗ មិនទាន់គិត
គ្រាន់តែទឹកបង់ក្នុងគំនិត    តែនៅផឹកពុំទាន់ទៀង ៗ
ពុំទាន់ប្រាកដនៅក្នុងស្ថាន    ទើបប្រាជ្ញបុរាណពោលសំនៀង
ថា "កាប់បំពង់រង់ទឹកភ្លៀង"    ទឹកភ្លៀងជាបានទេនៅឡើយ ៗ

៤- កោកៗ សឹកតែមាត់ត្រដោកក្អែកពោះក្រពី

សុភាសិតនេះបុរាណ
លោកពោលប្រៀបធៀបបែបប្រស្នា    ក្នុងរឿងពិតអ្នកសំដែង ៗ
អធិប្បាយការណាឲ្យគេស្តាប់    យ៉ាងល្អបំណាច់ផុតថ្លឹងថ្លែង
តែអ្នកអធិប្បាយមិនប្រឹងប្រែង    ប្រព្រឹត្តខ្លួនតែមិនចេះសោះ ៗ
ឥតមានប្រយោជន៍ដល់ខ្លួនទេ    ឯគេអ្នកស្តាប់ធ្វើតាមនោះ
គេបានប្រយោជន៍ចំណែកនោះ    ពីព្រោះគេប្រឹងឥតប្រណី ៗ
បែបនេះលោកពោលថា "កោកៗ    សឹកតែមាត់ត្រដោកក្អែកក្រពី"
បានខាងអ្នកបានតែសំដី    មិនធ្វើការខ្លួនឯងឡើយ ៗ

៥- កំពង់មិនដែលស្ងាត់, មាត់អ្នកដែលស្ងៀម

សុភាសិតនេះត្រង់មិនប្រស្នា
យើងក៏ធ្លាប់ដឹងធ្លាប់ឃើញថា
ធម្មតាកំពង់មិនដែលស្ងាត់ ។
ដោយមានមហាជនគេទៅមក
រករកចុះឡើងផ្លាស់ប្រែគ្នាត់
នេះជាសភាពធម្មតាពាត់
មិនឲ្យមានស្ងាត់គ្រប់កន្លែង ។
ហេតុនេះអ្នកប្រាជ្ញបុរាណ
ប្រៀបធៀបចាប់យកយ៉ាងច្បាស់ថ្លែង
ថាដូចជាមាត់យើងនេះឯង
ក៏តែងតែពោលនូវកថា ។
មិនដែលស្ងៀមស្ងាត់បាត់យូរទេ
បើទុកជាគេឃាត់យ៉ាងណា
ឈប់តែបន្តិចក៏ពោលថា
កើតជាពាក្យផ្សេងទៀតឡើង ។

៦- កំភ្លាញស្លាប់ពីព្រោះមាត់, ខ្លែងស្លាប់ពីព្រោះអាចម៍

សុភាសិតនេះបោកណា
លោកពោលត្រង់ ១ ទីងប្រស្នា
ទៅតាមធម្មតាការប្រព្រឹត្ត ។
ថាត្រីកំភ្លាញរមែងភ្លាត់
ស្លាប់ព្រោះតែមាត់ឥតគំនិត
ឲ្យពួកនេសាទបានឃើញពិត
ទើបគេរួបរឹតចាប់បានមក ។
មួយទៀតធម្មតាព្រានចាក់ផង់
តែងរង់ចាំមើលក្នុងទីជ្រក
កាលឃើញអាចម៍ខ្លែងទើបគេយក
ផង់មកចាក់ពាយត្រង់ទីនោះ ។
ឯពួកសត្វខ្លែងអាប់ប្រាជ្ញា
តែជុះត្រង់ណា មកត្រង់នោះ
រមែងជាប់ផង់ជាបាបគ្រោះ
ពីព្រោះតែជុះទុកជាផាន ។

នេះជាគតិនៃធម្មតា ដូចមនុស្សឯណាចិត្តហៅហាន
និយាយសំដីឥតប្រមាណ ទៅតាមតែបានប្រទះមាត់ ។
ពិតតែពីពោលថាប្បវ មិនគិតខុសត្រូវបេះតែផ្ដាត់
អ្នកនោះតែងបានទោសព្រោះមាត់ ដែលផ្ដាត់មិនគិតមុខក្រោយឡើយ ។

## ៧ – កំឡាំងនៅស្រមោច, ឫទ្ធិនៅខ្មោច,
## អំណាចនៅក្មេង

ពាក្យនេះមិនមែនជាប្រស្នា
ជាពាក្យពោលត្រង់តាមធម្មតា បើពិចារណាគង់ឃើញពិត ។
ដូចយ៉ាងស្រមោចផងទាំងឡាយ វាមានរូបកាយតូចល្អិតៗ
តែមានកំឡាំងខ្លាំងយ៉ាងស្និទ្ធ គេបានឃើញពិតពេលវាពាំ ។
អីវ៉ាន់ណាមួយដោយសាមគ្គី ព្រួតជួយគ្នាគ្នីយ៉ាងមួនមាំ
វាអាចដញ្ជូនអាចដឹកនាំ វត្ថុធំៗលើសខ្លួនបាន ។
ឯខ្មោចបិសាចអសុរកាយ វាបេះក្ដិតក្លាយឫទ្ធិសាមាន្យ
មនុស្សយើងឃើញហើយស្ញើបវាបាន ដោយខ្មោចវាមានឫទ្ធិមួនមាំ ។
ចំណែកឯពួកក្មេងតូចៗ ដំណួចតែត្រឹមពីរបីឆ្នាំ
អស់ពួកចាស់ៗតែងថែទាំ ទម្រាំធំដូចគេឯង ។
កាលវានៅតូចនោះធ្វើខុស គំហុសដោយល្ងង់មិនគោរពក្រែង
ដល់ម្ដាយឪពុករបស់ឯង សំដែងអំណាចវាយ៉ាងណា ។

ក៏ចាស់មិនយកទោសកំហុស　　ដែលទៅធ្វើខុសនោះម្ដងម្ដា
ហេតុនេះបុរាណលោកពោលថា　　ដូចមាតិកាពោលខាងដើម ។

៨- កុំប្រកាស៊ីផ្លែល្វា, រម្លុសកានា, ដក្ដិតឈ្មួស

ពាក្យនេះអ្នកប្រាជ្ញបុរាណ
លោកពោលត្រង់ៗនឹងប្រស្នា　　តាមគោលធម្មតាដែលធ្លាប់ចាត់ ។
ថាសត្វកំប្រុកតែងគោក្កា　　ស៊ីទុំផ្លែល្វាពេញៗធាត់
សត្វពាធរីងហើយទន់ក្អាត់　　ធម្មតាតែងពាក់ឲ្យមូលបាន ។
សត្វឈ្មួសបើដុះហើយកាលណា　　រមែងក្ដៅផ្ក្ដិតពុំក្សន្ត
នេះជាធម្មតាពុំដែលខាន　　អ្នកផងដឹងបានតាំងប្រុសស្រី ។
ពាក្យនេះបើពោលជាប្រស្នា　　បានតាំងអ្នកណាធ្វើខុសអ្វី
តែគេបេះកៅប្រសេចក្ដី　　ឲ្យខុសបះចៀសពីខ្លួនគេទៅ ។
ដោយគេបេះលើគេបេះទម្លាក់　　ពោលនោះឲ្យធ្លាក់ទៅបិតនៅ
លើមនុស្សណាមួយដែលចោតខ្លៅ　　ឲ្យទៅជាមានទោសដូចស្មន ។
កើតមកជាមនុស្សត្រូវខំសង្វាហ៍　　រៀនសិក្សាវិជ្ជាប្រែនពួកគង
កុំឲ្យចោតខ្លៅខុសទំនង　　ប្រយ័ត្នក្រែងស្លូងទោសដូចឈ្មួស ។

៩- កុំជិលអៀនប្រៀន បួសហើយមិនរៀនបន្ទោសថាពៀ

ពាក្យនេះលោកពោលខាងបព្វជិត
ឯណាដែលបួសហើយមិនគិត　　ពិនិត្យរៀនសូត្រសីលសិក្ខា ។

ដល់ពេលដែលមានពួកបរិស័ទ　　គេមកប្រពក៏ប័តន៍គាល់ត្រៀបត្រា
ហើយគេសាកសួរសោកប្ល　　ពេកកមានប្រាជ្ញាលោកសំដែង ។
ធម៌អាជីវិន័យតែសិក្សា　　ឲ្យគកល់គ្នាស្ដាប់ច្បាស់ទង
បានលោកជាច្រើនលើសខ្លួនឯង　　ក៏គិតស្ងប់ស្ងៀមគេណាស់ណា ។
ត្រឡប់បន្ទោសមកខ្លួនឯង　　ថាដែនៈព្រោះខ្ញុំអប្បប្រាជ្ញា
បួសហើយក៏ដិលមិនសិក្សា　　រៀនតែសិក្សាទើបបានៈខ្ញុំ ។

## ១០ កុំទុំមុនស្រគាល

　　　　　　　　　　សុភាសិតនេះប្រាជ្ញបុរាណ
ប្រដៅមហាជនគ្រប់គន្ធប្រាណ　　ឲ្យបានប្រើធំប្រៀនរៀនសិក្សា ។
រៀនអ្វីត្រូវចាំកុំអៀនប្រៀន　　ត្រូវរៀនឲ្យរះបះស្ទាត់ណាស់ណា
ប៉ើបះស្ទើរៗ កុំអាលថា　　"ខ្លួនបានសិក្សាបះស្ទាត់ណាស់" ។
រៀនការណាមួយត្រូវកំណត់　　ឲ្យបេះហ្មត់ចត់ប្រាកដច្បាស់
បើមិនទាន់បេះកុំអាលផ្ដាស់　　ត្រឡាស់ពេលមុនគេក្រោយផុនៗ
ដូចរៀនអក្សរជ. ដើមគាថ　　ត្រូវចាំសង្កាត់ឲ្យម៉ាំមួន
ដកបបេះបប់គ្រប់សំនួន　　សឹមសំគាល់ខ្លួនថាប្រៀវប្រាល ។
បុរាណប្រដៅបរិស័ទតូចធំ　　ថា "កុំឲ្យទុំមុនស្រគាល"
គឺបើចំណេះនៅព្រៃព្រាល　　កុំអាលលះបង់កណ្ដាលគារ ។

## ១១- កុំឡើងពីចុង, ត្រូវឡើងពីគល់

សុភាសិតៈខេមរោភណា

លោកពោលតាមគោលនៃធម្មតា អ្នកដែលចេះស្ទុះឡើងគ្រឿងខ្ពស់ ៗ
ថាត្រូវចាប់ឡើងពីគល់ទៅ មិនត្រូវឡើងពីចុងបង្អស់
បើឡើងពីចុងនឹងមានថ្លស់ ធ្លាក់ពីខ្ពស់នោះពុំខាន ៗ
ពាក្យនេះលោកពោលជាពាក្យប្រៀប គឺធៀបនឹងអ្នកដែលចង់បាន
ចំណេះវិជ្ជាទាំងប៉ុន្មាន ចំណាប់ចំណានល្អយ៉ាងថ្នើម ៗ
ត្រូវរៀនឲ្យរៀងតាមលំដាប់ គឺចាប់សិក្សាពីខាងដើម
ដូចជីកដំឡូងពីគល់ដើម ទើបចេះសម្បើមដូចប្រាថ្នា ៗ
បើរៀនចាប់ចុងព្រយុះគល់ នាំឲ្យវិលវល់ការសិក្សា
តែងមិនសម្រេចដូចចិន្តា ទើបថា "ត្រូវឡើងពីគល់ទៅ" ៗ

## ១២- កុំធ្វើតាមខ្យល់, កុំខ្វល់តាមលោក

ពាក្យថា "កុំធ្វើតាមខ្យល់" នេះ
ជាពាក្យអ្នកប្រាជ្ញមានចំណេះ លោកចេះប្រឌិតឲ្យមានផល ៗ
គឺលោកប្រដៅឲ្យចេះអត់ អំណត់ចិត្តថ្លើមឲ្យក្រៃពល់
បើថ្លឹងតាមធម៌ព្រះសុគត បានដល់ការអត់ត្មោះស៊ង ៗ
លើក, ដាក់, បញ្ជោរ, បង្អាប់ នាំឲ្យអ្នកស្តាប់ភាន់ស្មារតី
ទោរទេរតាមធម៌ជាលោកិយ ដែលជនប្រុសស្រីគួរប្រយ័ត្ន ៗ

## ១៣- កុំជឿដោយខ្យល់, កុំខ្វល់ដោយស្រី

សុភាសិតលោកហាមឃាត់
កុំឲ្យជឿជាក់តាមខ្យល់មាត់ នៃអ្នកដែលភ្លាត់ពោលផ្ដេសផ្ដាសៗ
និងឃាត់កុំឲ្យមានចិត្តខ្វល់ អំពល់ដោយស្រីដែលមិនឈ្លាស
ព្រោះធម្មតាស្រីតែងទីសពាស ពីសពាសពាក្យពេចន៍សាំសាក ៗ
នាំប្រុសកំលោះទៅឥតប្រាជ្ញ ឲ្យលុះអំណាចកាមតណ្ហា
ប្រុសច្រើនមានគ្រោះដល់អាត្មា ទើបលោកឃាត់ថា "កុំឲ្យខ្វល់" ៗ

## ១៤ – កុំពត់ស្រឡៅ, កុំប្រដៅស្រីខូច

នេះជាបុរាណសុភាសិត
អ្នកប្រាជ្ញលោកពោលតាមគោលពិត នៃការប្រព្រឹត្តិរបស់ស្រី ៗ
ដែលលុះអំណាចតាមតណ្ហា ទប់ទៅផ្លូវណាទោះជេរស្ដី
ខ្លួនធ្លាប់ប្រដៅយ៉ាងណាក្ដី ក៏ពត់ឲ្យស្រីត្រង់ពុំបាន ៗ
ដូចឈើស្រឡៅនៅក្នុងព្រៃ សាប់រីងស្រួយក្រៃកន្លងប្រមាណ
ពត់ឲ្យខ្ទេរខ្ទង់ទៅពុំបាន ធ្វើបានតែគៀងណាត្រង់ៗ ៗ
រឿងនេះលោកពោលប្រៀបប្រដូច ចំពោះស្រីខូចកាចទ្រនង់
មិនពោលសាធារណ៍ទៅទាំងស្រុង ស្រីល្អក៏គង់មានច្រើនពិត ៗ
លោកពោលចំពោះតែស្រីណា ដែលកាមតណ្ហាបណ្ដាលចិត្ត
នាំកាយឲ្យខូចខុសចរិត ទើបឥតនរណាប្រដៅបាន ៗ

## ១៥ — កុំយកករទៅលអន្ទាក់

សុភាសិតនេះប្រាជ្ញប្រឹក
ហាមប្រាមមិនឲ្យយើងប្រព្រឹត្ត ការឥតប្រយោជន៍នាំកើតទុក្ខ ។
ដូចមានអ្នកម្នាក់កើតរឿងអ្វី ដែលជាសេចក្ដីនាំផលយុគ
ហើយមានអ្នកម្នាក់នៅសុខៗ គិតទៅស៊ុកឡុកនឹងគេផង ។
ចូលរួមចំណោះដែលខ្លួនបះ គះម្រះខ្លួនមានល្អចំនួន
ឥតមាននរណាគេដឹងផង ក៏ពោលឆ្លើយជូនឲ្យគេដឹង ។
គ្រាក្រោយបើគេមានទុរ: គេមកតវ៉ះពាក់ព័ន
ឲ្យធ្វើការងារដែលខ្លួនដឹង ខ្លួនត្រូវតែប្រឹងខានពុំបាន ។
ទើបលោកហាមឃាត់ជាការល្អ ថា "កុំយករបស់ប្រាណ
ទៅលអន្ទាក់" នាំទាន នឹងបានលំបាកឥតអំពើ ។

## ១៦ — កុំធ្វើស្រែប្រវាស់, កុំសង់ផ្ទះចូលគ្នា

សុភាសិតនេះពោលត្រង់ៗ
បើយើងពិនិត្យដោយថ្លឹងថ្លង់ ក៏គង់ឃើញជាក់ប្រាកដណាស់ ។
ដែលបានជាលោកឃាត់អំពើ នៃការដែលធ្វើស្រែប្រវាស់
ព្រោះធ្វើវែនច្រើនតែទាស់ ទំនាស់នាំកើតទុក្ខវេទនា ។
មួយទៀតការសង់ផ្ទះសម្បែង ចូលគ្នាក៏តែងតែទាស់គ្នា
ហេតុនេះទើបលោកហាមឃាត់ថា "កុំធ្វើចូលគ្នាឲ្យសោះឡើយ" ។

## ១៧- កុំទុកចិត្តមេឃ-ទុកចិត្តផ្កាយ[១]

ពាក្យនេះលោកពោលជាទូទៅ

ឲ្យយើងចេះប្រើប្រាជ្ញាស្អាត កុំឲ្យប្រមាទធ្វេសគំនិត ។
ហេតុណាមិនគួរកុំបីជឿ កុំទាន់ជំនឿថាជាពិត
មនុស្សណាមិនស្រួលកុំទុកចិត្ត កុំស្និទ្ធកុំស្នាលកុំអាលគប់ ។
ទោះបីមនុស្សល្អដែលជាមិត្ត ក៏កុំទុកចិត្តឲ្យស្និទ្ធស៊ប់
ប៉ុន្តែត្រូវយកជាសម្ភព សេពគប់ជាមិត្តឲ្យមាំមួន ។
ត្រូវប្រឹងស្មារតីជាប់ជានិច្ច ឲ្យដឹងកលកិច្ចសព្វសំនួន ។
កុំបីជឿគេដល់ក្លួចខ្លួន ដូចក្បួនភាសិតពោលខាងដើម ។

## ១៨- កុំកាច់ទួសប្រកួតដំរី, គោតក្ដាំកុំប្រកួត ដីដទៅក្រោម

ពាក្យនេះអ្នកប្រាជ្ញពោលឃាត់ខាង

មិនឲ្យមនុស្សយើងប្រព្រឹត្តតាំង ប្រណាំងទាស់នានឹងដំរី ។
ពីព្រោះដំរីជាសត្វកាច មានចិត្តកំណាចខ្លាំងផុតបី
ក្នុងពេលណាមួយមានដំរី កុំបីកាច់ទទះប្រកួត ។
កាលបើប្រកួតដំរីកាច ពិតអាចនឹងត្រូវផ្ដួលឲ្យមរណា
ហេតុនេះបុរាណលោកពោលថា កុំហ៊ានតតាំងនឹងសត្វធំ ។
ពាក្យនេះអ្នកប្រាជ្ញលោកស្រដី ថាដូចកូនក្ដីជាដំណាំ ▬

---

១ ន័យខ្លះថា កុំជឿមេឃកុំជឿផ្កាយ កុំជឿកូនថាគ្មានគេរាភាយ កុំជឿម្ដាយថាគ្មានបំណុល ។

ត្រូវកុំប្រកួតនឹងចៅក្រម គឺលោកអ្នកធំជាប្រធាន ។
កុំរឿងក្តីក្តាំរបស់ខ្លួន ត្រូវសួរចិត្តលោកកុំឈ្លានពាន
តែមិនត្រូវខ្លាចត្រូវតែហ៊ានខ ពោលរឿងខ្លួនមានឲ្យច្បាស់លាស់ ។

១៩– កុំកាត់មុខជើង , កុំទទឹងមុខសឹក

ព្រោះណាលោកហាមឃាត់យ៉ាងតឹង
"ថាកុំឲ្យកាត់វែងមុខជើង ឬកុំទទឹងវែងមុខសឹក" ។
ពីព្រោះទំនៀមនៃថ្លៃជើង ជាដែកយោងវែងមុតសន្ទឹក
ដែលមនុស្សអ្នកចាំងកំពង់ទឹក រលឹកតម្រង់ទៅត្រង់ណា ។
ដាំធម្មជាតិកាត់មិនបាន តែកាត់ខូចប្រាណបង់អាត្មា
ទើបប្រាជ្ញបុរាណលោកពោលថា កុំកាត់កុំការមុខជើង ។
មួយទៀតធម្មតាអ្នកធ្វើសឹក តែងទឹកក្នុងចិត្តយ៉ាងរឹងប៉ឹង
តែងធ្វើដោយចិត្តក្រេវក្រោធខឹង ទៅនឹងអ្នកខាងជាសត្រូវ ។
ឯយើងជាមនុស្សមិនធ្វើសឹក កុំនឹកតាខ្លួនបង់ដើរទៅ
ទទឹងមុខសឹកឲ្យបើកផ្លូវ នោះទៅមុខជាស្លាប់អន្តរាយ ។
រឿងនេះជាពិតឥតខានទាន ទើបប្រាជ្ញបុរាណលោកប្រៀបប្រាយ
ដូចកូនទីងសិស្សផងទាំងឡាយ កុំកាត់មុខម្តាយឪពុកគ្រូ ។
នឹងប្រៀបដូចពួកមនុស្សពាលា ចិត្តពាលតែងប៉ងជាសត្រូវ
ចំពោះបណ្ឌិតនាំអាស្រូវ កុំទៅសេពគប់នឹងពាលឡើយ ។

(មានត)

# សុភាសិតបាលី ប្រែ

ក្នុងឧបាហនវគ្គវណ្ណនា

ព្រះគ្រូសង្ឃវិជ្ជ ពាង-សុខ ក្រុមជំនុំព្រះត្រៃបិដកប្រែនិងរៀបរៀង

សន្ធុស្សេយ្យេវ សមេន្ត អសន្ធុដ្ឋា ច តេន យោ
តម្ហាយិតរំ លាតិ សវេ បច្ចាធុតប្បតិ ។

ប្រែ

ជនត្រូវតែសន្តោស កុំឲ្យទើសដោយទ្រព្យមាន ឯជនដែលឈ្លានពាន ទ្រព្យខ្លួនមានមិនស្កប់ចិត្ត ៗ លះបង់កិច្ចចំណាប់ ស្រេកទាក់កិច្ចមិនពិត តែងតែឈ្លាយនិទិត ក្តៅក្តួលចិត្តទុកស្តាយក្រោយ ។

## អសិតាភូជាតក

ក្នុងកាលដែលកន្លងទៅហើយ កាលដែលព្រះបាទព្រហ្មទត្ត សោយរាជ្យក្នុងក្រុងពារាណសី ព្រះពោធិសត្វបានបួសជាឥសី ញុំាំងអភិញ្ញានិងសមាបត្តិឲ្យកើតហើយនៅក្នុងប្រទេសហិមពាន្ត ៗ ក្នុងកាលនោះ ព្រះរាជាក្នុងក្រុងពារាណសី បានទតឃើញបរិវារសម្បត្តិ នៃព្រហ្មទត្តកុមារ ដែលជាបុត្ររបស់ព្រះអង្គ ហើយកើតសេចក្តីរង្កៀស ទើបនិរទេសបុត្រចាកដែន ៗ

ព្រះរាជបុត្របានយកនាងទេវីរបស់ខ្លួនឈ្មោះអសិតាភូ ចូលទៅប្រទេសហិមពាន្តហើយសោយ ត្រី-សាច់ និងផ្លែឈើតូច-ធំ នៅក្នុង

បណ្ណសាលា ព្រះរាជបុត្រនោះបានឃើញកិន្នរីមួយ មានចិត្តប្រតិព័ទ្ធ គិតយកកិន្នរីនោះជាភរិយា លែងរាប់រកនាងអសិតាភូ ហើយទៅតាមដានដើរតាមកិន្នរីនោះ ។ នាងអសិតាភូ បានឃើញព្រះរាជបុត្រដើរតាមកិន្នរីដូច្នោះក៏គិតថា "ព្រះរាជបុត្រនេះលែងអើពើនឹងអញ គិតតែដើរតាមកិន្នរី អញមានប្រយោជន៍អ្វីនឹងព្រះរាជបុត្រនេះ" គិតហើយក៏មានចិត្តសោយ ចូលទៅគាល់ពោធិសត្វ ថ្វាយបង្គំហើយអារាធនាពោធិសត្វឲ្យសំដែងកសិណបរិកម្មដល់ខ្លួន នាងរមិលមើលកសិណ ក៏បានញ៉ាំងអភិញ្ញានិងសមាបត្តិឲ្យកើត ថ្វាយបង្គំពោធិសត្វ ហើយមកឈរជិតទ្វារបណ្ណសាលារបស់ខ្លួន ។ ឯព្រហ្មទត្តកុមារដើរតាមកិន្នរី ចេះតែដើរទៅៗ លែងឃើញសូម្បីតែផ្លូវដែលកិន្នរីនោះទៅ ក៏អស់សង្ឃឹមហើយមានមុខឈមមករកបណ្ណសាលាវិញ ។ នាងអសិតាភូបានឃើញព្រះរាជបុត្រនោះដែលកំពុងមក ក៏ហោះទៅឯអាកាស អណ្តែតត្រសែតនឹងនៅឯផ្ទៃអាកាស ដែលប្រដាប់ពណ៌ផ្កាពណ៌កែវមណី នាងពោលថា (បពិត្រព្រះអយ្យបុត្រ (១) ខ្ញុំម្ចាស់បានសេពក្តីសុខក្នុងឈាននេះ ព្រោះតែការ-ព្រាត់ប្រាសនឹងទ្រង់) ថាហើយក៏ពោលគាថាទី ១ នេះ

ត្វមេវ ទានិមករិ យំ កាមោ ព្យគមា តយិ
សោយំ អប្បដិសន្ធិកោ ខរឆិន្នំវ រេណុកំ ។

១ ព្រះអង្គម្ចាស់ ។

ឥឡូវនេះព្រះអង្គ បានឃើញត្រង់ទម្រនេះឯង ចិត្តខ្ញុំក៏ប្រាសលែង មានចំណង់ចំពោះទ្រង់ ចំណង់មិនកាចក មានដំណើរទៅបាត់បង់ ដូចគុក កាត់ផ្តាក់ ដោយពេលណាដាច់ស្រឡះ ៗ

នាងអសិតាភូបានពោលគាថាយ៉ាងនេះហើយ ខណៈដែលព្រះរាជបុត្រកំពុងឈរ ក៏ហោះឡើងទៅក្នុងទីដទៃ ៗ ព្រះរាជបុត្រនោះក៏ខ្សឹកខ្សួលក្នុងកាលដែលនាងអសិតាភូនោះទៅហើយ ទើបបានពោលគាថាទី ២ នេះថា

អត្រិច្ឆំ អតិលោភេន អតិលោភមទេន ច
ឯវំ ហាយតិ អត្ថម្ហា អហំវ អសិតាភុយា ៗ

ជនដែលចង់បានហួស តែងតែប្រែប្រយោជន៍ខ្លួន ព្រោះលោភហួសចំនួន និងលោភហួសការបង្អែក ៗ សេចក្តីស្រវឹងថា រីអាត្មាប្រែសចេត ដូចអញមាកក់ណើត ឥតទីតក ព្រាត់ប្រពន្ធ ៗ

ព្រះរាជបុត្រនោះ លុះខ្សឹកខ្សួលដោយគាថាយ៉ាងនេះហើយ ក៏នៅក្នុងព្រៃតែឯង ៗ

លុះអំណោះអំពីព្រះវរបិតា ទើបត្រឡប់ទៅយករាជ្យវិញ ៗ

អសិតាភូជាតក ចប់ ។

ជម្ពូសរជ្ជកកាព្យ

ឲ្យព្រះរាជបុត្រ រូបស្រស់ជាតិសុទ្ធ មិនទាន់ស្កប់ចិត្ត បានឃើញ កិន្នរី ឃ្លាតខ្ទីតាមដើត លុះតាមអស់ចិត្ត ទើបត្រឡប់មក ៗ តែនាង

ទេវី ជាតិជានារី បណ្ឌូលពន្លក ដែលសោយចិត្ត រិះគិតទៅគេ គុណបានទើបមក ឡើតឡើយទៅវិញ ។

## សារណាកថា

ព្រោះហេតុនោះ ពួកជនអ្នកមិនបង់ប្រាសឃ្លាតបាតកវត្ត ដែលខ្លួនបានហើយ មិនត្រូវជាអ្នកបង់ឆ្ងានហួស មិនត្រូវជាអ្នកលោភហួស ស្រវឹងជាអញ្ញជាប្រុស ត្រូវតែជាអ្នកស្ងប់ចិត្តគន្ធវត្ត ដែលល្អមត្រូវបាន; បើមិនដូច្នោះទេ តែនឹងតែជាអ្នកប្រាសឃ្លាតបាតកវត្ត ដែលខ្លួនបានហើយ ដូចជាព្រហ្មទត្តកុមារ ដែលព្រាត់ប្រាសបាតកនាងអសិតកុជាទេពីរបស់ខ្លួនអោះឯង ។

---

# ប្រវត្តិសាស្ត្រប្រទេសចិន

(តមក)

## វគ្គទី ២

## ចិននឹងហ្វូន

កាលអស់បុណ្យព្រះចៅអធិរាជវ៉ុង-ទិហើយ រាជវង្សចិនក៏មិនបាន គង់នៅភ្ជាប់ខ្ជួនប៉ុន្មាន ដោយហេតុកើតបះបោរចលាចលឡើងខាងក្នុង ស្រុក ទើបជាហេតុបើកឱកាសឲ្យពួកហ្វូនលុកលុយចូលមកស្រុកចិន ខាងជើង ប្រទេសចិនក៏កើតវឹកវរឡើងជាខ្លាំង រហូតដល់តែបាន មេទ័ពពូកែម្នាក់ ឈ្មោះលៀវ-ប៊ុង រួបរួមស្រុកចិនឡើងវិញបាន ហើយ បណ្តេញពួកហ្វូនឲ្យថយខ្ចាត់ខ្ចាយអស់ទៅ ។

មុនលៀវ-ប៊ុងឡើងគ្រងរាជសម្បត្តិនោះ ត្រូវច្បាំងតស៊ូនឹងហៀង-យូ ដែលមានលក្ខណៈកាចសាហាវដូចសត្វព្រៃ ផ្ទុយគ្នានឹងលក្ខណៈរបស់ លៀវ-ប៊ុង ដែលជាមនុស្សស្លូតសុភាពរាបសាជាប្រក្រតី ។ សង្គ្រាម គ្រានោះជំបូង លៀវ-ប៊ុងទន់កម្លាំងជាងហៀង-យូជាច្រើន តែនៅទី បំផុតត្រឡប់ទៅជាមានជ័យជំនះ ហើយហៀង-យូក៏ស្លាប់ទៅនៅក្នុង ពុទ្ធសករាជ ៣៤២ ។ លុះលៀវ-ប៊ុងមានជ័យជំនះហៀង-យូហើយ ក៏នាំស្រុកឡើងទៅការពារខែត្រដែនតាន់-ស៊ី ដ្បិតមានពួកហ្វូន លុកលុយឡើងមកតាមផ្លូវនោះបណ្ដាំគ្រានោះ លៀវ-ប៊ុង ស្ទើរតែ

អស់សង្ឃឹមទៅហើយក៏ស្រាប់តែកើតគំនិតលៃបន្លាយឡើង គឺជ្រើសរើសបានស្រីរូបស្រស់ម្នាក់ ក្នុងពួកប្រពន្ធរបស់ខ្លួនធ្វើជានុយឲ្យទៅមេទ័ពរបស់ពួកហ្វូន ជាហេតុនាំឲ្យពួកហ្វូនលើកលែងច្បាំង ហើយថយទ័ពត្រឡប់ទៅស្រុកវិញ ក្នុងពុទ្ធសករាជ ៣៤៣ ។ របៀបលើកស្រីរូបល្អទៅបំបន់ឲ្យសឹកសត្រូវឲ្យឈប់រុករានទន្ទ្រានដែនដីនោះ ជាវិធីដែលចិនចូលចិត្តធ្វើណាស់ ហើយច្រើនតែបានសម្រេចរួចបំណងផង ។

តកំពីនោះមក ល្បៀវ-ប៉ុងបានប្រកាសតាំងខ្លួនជាព្រះចៅរាជាធិរាជនៃប្រទេសចិនចាត់ជាបឋមក្សត្ររបស់ពួកហាន ទុកជារាជវង្សសំខាន់ ១ ដែលបានគ្រប់គ្រងដែនដីរបស់ចិនរហូតមកបានដល់ ៤ សតវត្សរ៍ គឺតាំងពីពុទ្ធសករាជ ៣៤៤ ដល់ពុទ្ធសករាជ ៧៦៣ ក្នុងសម័យនៃរាជវង្សហាននេះ ទីក្រុងរបស់ចិនជាន់ដើមតាំងនៅស៊ី - អាន់ក្នុងខែត្រសេន - ស៊ី ជាវេលា ២០៧ ឆ្នាំ គឺតាំងពីពុទ្ធសករាជ ៣៤៦ ដល់ ៥៤៩ តពីនោះផ្លាស់មកតាំងនៅឯលោ - យ៉ាំងឬឡុក - អៀងក្នុងខែត្រហូ - ណាន់ ។ ក្សត្ររាជវង្សល្បៀវ - ប៉ុងមួយអង្គ ទ្រង់ព្រះនាមថារូ - ទី ដែលទ្រង់បានគ្រប់គ្រងប្រទេសចិនរហូតដល់ពុទ្ធសករាជ ៤៥៦ បានពង្រីករាជអាណាខែត្រចុះទៅភាគត្បូង បានច្បាំងឈ្នះទ័ពស្គ្គន់ នៅទិសខាងកើតទៀតផង ។

នៅក្នុងរវាងពុទ្ធសករាជ ៣០០ ឆ្នាំនោះ នៅខាងទន្លេស៊ី-កៀង (ជាទន្លេសំខាន់មួយរបស់ចិនភាគខាងត្បូង) ក្នុងដែនក្វាង-ទុងនោះមានអាណាចក្រមួយ មានគណៈមេដឹកនាំទីនស្រុកកុងកង ឈ្មោះជាអាណាចក្រណានយួយ (ប្រជាជនជាតិយួន តែរាជវង្សក្សត្រត្រួតត្រង់ ដែនដីជាតិចិន ៗ ដល់មកពុទ្ធសករាជ ៤៣៦ ចិនលុកលុយវាយបញ្ចូលអាណាចក្រនេះ ទៅក្នុងមហាអាណាចក្រចិនទាំងអស់ ៗ លុះតទៅ ៣ ឆ្នាំតមក ចិនបានលើកទៅវាយយកស្រុកកេស-ឈូងបានទៀត ដែនដី ដែលយើងហៅថា ប្រទេសចិននោះ វៀតណាមកែយុនណាន់មួយចេញ ស៊ីនបានរួមចូលទៅក្នុងការគ្រប់គ្រងរបស់មហាអាណាចក្រចិនទាំងអស់ ៗ

ក្នុងសម័យនេះ ជាសម័យដែលមានការប្រែប្រួលយ៉ាងសំខាន់មួយនៃប្រវត្តិសាស្ត្ររបស់ពួកបូព៌ាប្រទេស ៗ បូរតិត មីលកុះថា កាលរវាងពុទ្ធសករាជ ៣០០ ឆ្នាំនោះ អាណាចក្ររបស់ចិនមិនធំសំបើម ដល់ជាក្លាយទៅជាប្រទេសធំបំផុត ក្នុងកំណត់រយៈវេលា ១០០ ឆ្នាំប៉ុណ្ណោះទេ ៗ មួយវិញទៀត ព្រះបាទវូ-ទី ទ្រង់អាចពង្រីកអាណាខេត្តឲ្យរីកចេញទៅយ៉ាងសំបើម រហូតទៅដល់តាក់កណ្ដាលទ្វីបអាស៊ី តំបន់ស្ដង់នោះ ជារឿងដែលគួរជឿងឆ្ងល់សរសើរ សេចក្ដីខ្លាំងពូកែរបស់ចិនជាច្រើន ដូចមានសេចក្ដីសារសំខាន់តទៅនេះ

# រឿងអាមាត្យឆាង-កៀន

ផែនដីដែលហៅថា ពាក់កណ្ដាលទ្វីបអាស៊ីនោះ ពីដើមនៅក្នុងអំណាចពួកហួន យើងបានដឹងពីខាងដើមមកខ្លះហើយថា ពួកហួនបានលុកលុយទន្ទ្រានផែនដីចិន ជាច្រើនលើកច្រើនគ្រាមកហើយ ទុកជាចិនខំកសាងកំពែងយ៉ាងធំសំបើម ខូចខាតប្រាក់ណាស់ ទាំងជីវិតមនុស្សជាអនេកអនន្តក៏ដោយ ក៏នៅតែមិនអាចការពារភ័យអន្តរាយរបស់ពួកហួនបានឡើយ ។ ព្រះបាទវូ-ទី នៃព្រះរាជវង្សហានដែលទើបបានតាំងព្រះទ័យយ៉ាងមុតមាំ ក្នុងការធ្វើចម្បាំងតទល់នឹងពួកហួនឲ្យជាការដាច់ស្រេច មិនបណ្ដោយឲ្យពួកហួនលើកទ័ពចូលមក គង់តែធ្វើដូចគ្រាមុនៗទៀត ទើបទ្រង់កំណត់គ្រោងការលើកទ័ពទៅបង្ក្រាបហួនដល់ស្រុកទេសរបស់ពួកហួនតែម្ដង តែមានហេតុទាស់ ព្រោះពួកចិនមិនសូវស្គាល់ច្រកផ្លូវនិងភូមិប្រទេសច្បាស់លាស់ល្អ ទើបទ្រង់ជ្រើសរើសតាំងបញ្ជូនអាមាត្យដែលមានសតិបញ្ញាឈ្លាសវៃយ៉ាងចំណាប់ម្នាក់ឈ្មោះឆាង-កៀន ៗ បានចេញធ្វើដំណើរទៅ ក្នុងឆ្នាំពុទ្ធសករាជ ៤០៩ ដើម្បីពិនិត្យច្រកផ្លូវនិងត្រួតមើលភូមិប្រទេស ឲ្យបានស្គាល់ជាក់ច្បាស់ ។ ឆាង-កៀន បានចេញដំណើរផ្លូវកាត់ហួសនៃផែនមុង-លិ, ហៃ-តាន, កប-តារ, ទួរស្គង់ និងអាហ្វ៉ានក្នុងវេលាដែលធ្វើដំណើរទៅតាមផ្លូវនោះ ។ ឆាង-កៀន ត្រូវពួកហួនចាប់ខ្លួនយកទៅឃុំឃាំងជាវេលារាល់ ១០ ឆ្នាំ ទើបបានលបលួច

គេចូលទៅកងវៃត្រវែន ត្រង់សាកសៀនដែលជាដែនដីរបស់ពួកយូអេជី ចាង-គៀនបានតាំងខ្លួនជាមិត្រយ៉ាងល្អរបស់យូអេជីហើយបានជួយពួកយូអេជីច្បាំងនឹងពួកក្រិកនៅបាក់ត្រៀនផង នៅទីបំផុតបានត្រឡប់ចូលមកស្រុកចិនតាមស្រុកទីបេត ។ បើគិតតាំងពីវេលាដែលចាង-គៀនចេញពីស្រុកចិនទៅរហូតដល់បានត្រឡប់មកវិញ ជាវេលាដល់ ៤ ឆ្នាំ ហើយបានស្គាល់ស្ទាត់ច្បាស់ផ្លូវភូមិប្រទេស តាមតំបន់អស់នោះយ៉ាងជាក់ច្បាស់ សមដូចព្រះរាជបំណងរបស់ព្រះបាទវូ-ទី ទើបទ្រង់រៀបចំធ្វើចម្បាំងធំនឹងពួកហ៊ូន ឲ្យជាការដាច់ស្រេចទៅតែម្ដង ។

ប្រសិនបើយើងពិនិត្យមើលរជ្ជបុរសទាំងពីរ គឺព្រះបាទវូ-ទីនឹងអាមាត្យចាង-គៀន នឹងឃើញថា ព្រះបាទវូ-ទីមានព្រះនិស្ស័យសន្ដានរឹងប៉ឹងមិនចេះរសាយ ព្រោះរាជបំរើដែលគាត់ឲ្យទៅធ្វើការ ជាវេលាជាង ១០ ឆ្នាំដូចជាចាង-គៀននោះ ប្រសិនបើជាអ្នកដទៃវិញគង់លែងខកនានឹងធ្វើចម្បាំងកំហឹងជល់អ្វីតទៅទៀត តែព្រះបាទវូ-ទីទ្រង់តាំងព្រះទ័យមុតមាំណាស់ ទើបទ្រង់ធ្វើការបានសម្រេច ។

ឯអាមាត្យចាង-គៀន គួរជាត់ជាមន្ត្រីសុចរិតស្មោះត្រង់បំផុត ចំពោះព្រះមហាក្សត្ររបស់ខ្លួន ហើយថែមទាំងមានបញ្ញាឈ្លាសវៃ មានសេចក្ដីក្លាហាននឹងព្យាយាមមាំណាស់ ព្រោះចាង-គៀនបានត្រួតត្រាមើលភូមិប្រទេសយ៉ាងហ្មត់ចត់ លួចរៀនយុទ្ធវិធីទ័ពរបៀបចាត់ទ័ពរបស់

ពួកហ្វូនសម្រាប់យកមកបង្ហាត់បង្រៀនទាហានចិន ហេតុនេះ បានជា ក្នុងឆ្នាំពុទ្ធសករាជ ៤២៤ កងទ័ព ២ កងមានចំនួនពលទាំងសែនលើកចេញទៅពីស្រុកចិន ដោយមានមេទ័ពពូកែ២ ពីរនាក់ឈ្មោះហ៊ូ-កៀវ-ពិងនិងវៃ-ចុងជាអ្នកនាំទ័ព បានច្បាំងរុកលុកលុយបំផ្លាញជីវិតជាតិហ្វូនជាច្រើនពាន់ហើយក៏វាយយកបានដែនទូរស្គង់ផង ។ គ្រប់ ១ តំបន់ដែលកងទ័ពលើកចូលទៅតែងតែមានជ័យជំនះគ្រប់អន្លើ ក្រៅពីទូរស្គង់ កងទ័ពរបស់ព្រះបាទវូ-ទី បានរុកឡើងទៅទិសឦសាន ក៏យកបានដែនលៀវ-តុងនិងដែនកៅ-លី កាលពីពុទ្ធសករាជ ៤៣៤ ដោយហេតុនេះគួរយល់ថា ព្រះបាទវូ-ទី ក្នុងរាជវង្សហាននេះ គួរបានទទួលកិត្តិយសថាជាអ្នកបណ្ដាលឲ្យអាណាខេត្តរីកធូលាយចេញទៅយ៉ាងសំបើម ។

លុះព្រះបាទវូ-ទីសោយព្រះទិវង្គតទៅ សេចក្ដីចំរើនរុងរឿងរបស់ចិនក៏ថយខ្សោយតិចទៅ ក្នុងឆ្នាំពុទ្ធសករាជ ៤៥៣ ។ ឯលី-កួង-លីជាមេទ័ពពូកែបំផុតរបស់ចិនមួយ ដែលត្រឡប់ជាបរាជ័យដាញ់ពួកហ្វូនទៅវិញ តាំងពីនោះមកចិនក៏ឈប់ផ្សាយអំណាចពង្រីកអាណាខេត្ត រហូតមកដល់សម័យព្រះបាទស៊ុ-កួន-ទី ដែលទ្រង់បានគ្រប់គ្រងប្រទេសចិនជាវេលា ២៥ ឆ្នាំ គឺតាំងពីពុទ្ធសករាជ ៤៧០ ដល់ ៤៩៤ ចិនត្រឡប់មានកំឡាំងខ្លាំងពូកែឡើងវិញ មានមេទ័ពចិនពូកែម្នាក់ឈ្មោះពាង-ហ្វូយបានធ្វើការប្រាបប្រាមពួកហ្វូនបានសម្រេច ។ គ្រានោះ បណ្ដា

ប្រទេសទាំងឡាយ នៅទ្វីបអាស៊ីកណ្តាល សឹងធ្លាក់ទៅនៅក្នុងអំណាចរបស់ព្រះចៅអធិរាជនៃប្រទេសចិន តាំងតែពីកាលណោះរហូតមកដល់ពួកកិក-ម៉េងមានអំណាច ។

ព្រះមហាក្សត្ររាជវង្សហាននេះ ទ្រង់ទំនុកបំរុងកំលាំងទាហានយ៉ាងមឹងម៉ាត់ ព្រមទាំងចាត់ការត្រួតត្រាស្រុកទេសឲ្យមានរបៀបរៀបរយល្អឡើងជាច្រើន ទ្រង់បានធ្វើទីក្រុងឲ្យជាទីប្រជុំត្រួតត្រានៃត្រៃក្រៅទូទៅ ព្រះបាទវូ-ទី ទ្រង់មានស្រុកផ្សេងៗ ជាចំណុះព្រះអង្គ ១០០ ស្រុក ។ ពីដើមមកអ្នកដែលមានដំណែងត្រួតត្រាស្រុកបាននោះ លុះតែជាមនុស្សកើតក្នុងត្រកូលជាន់ខ្ពស់ ឯព្រះបាទវូ-ទីជាមហាក្សត្រដំបូង ដែលទ្រង់ប្រកាសលើកលែងលទ្ធិទំនៀមនេះ ហើយទ្រង់ជ្រើសរើសយកមនុស្សគ្រប់ជាន់គ្រប់ថ្នាក់ដែលមានចំណេះចេះដឹងល្អឲ្យចូលមកធ្វើរាជការ ។ ឯព្រះមហាក្សត្រជាលំដាប់តៗមក ក្នុងព្រះរាជវង្សរបស់ព្រះអង្គ សឹងព្យាយាមបន្ថយអំណាចរបស់ពួកមហាក្សត្រ ត្រាតែស្រុកផ្សេងៗក្នុងអាណាចក្រចិនមកឡើងផ្ទាល់ព្រះអង្គទាំងអស់ ព្រះបាទស៊ី-អួន-ទី ទ្រង់ឲ្យកាត់កពួកត្រកូលជាន់ខ្ពស់ជាច្រើននាក់ ដែលប្រឆាំងទទឹងនឹងព្រះរាជអាជ្ញា ។

## វ៉ាំង-ម៉ាំងឡើងគ្រងរាជ្យ

របៀបរាជការដែលពោលមកនេះ ជាហេតុនាំឲ្យពួកត្រកូលជាន់ខ្ពស់ស្អប់ខ្ពើមរាជវង្សហានជាច្រើន ដល់មកក្នុងពុទ្ធសករាជ៥៥២ សេនា-

បតីដែលមានចិត្តរំលោភម្នាក់ឈ្មោះ រ៉ុង-ម៉ុង បានក្បត់ព្រះមហាក្សត្ររាជវង្សហាន់បេញពីរាជបល្ល័ង្ក ហើយតាំងខ្លួនឯងជាព្រះរាជាធិរាជឡើងនៃរ៉ុង-ម៉ុងធ្វើដូច្នេះ បណ្តាលឲ្យកើតចលាចលក្នុងស្រុកឡើងយ៉ាងសំ-បើម ៗ មានមនុស្សមួយពួកហៅថា "ពួកចិញ្ចើមក្រហម" បង្កការចលាចលឡើងក្នុងស្រុកពាន់-ទុង (ហ៊ូ-សង់-ទុង) ព្រះរាជាធិរាជដែលទើបគ្រងរាជ្យថ្មី មិនអាចប្រាបប្រាមឲ្យស្ងប់ស្ងាប់បាន ហើយពួករាជវង្សចាស់ត្រឡប់មានកំឡាំងឡើងវិញ មានព្រះអង្គម្ចាស់ក្នុងរាជវង្សហាន់មួយអង្គ ព្រះនាម "លៀវ-សៀវ" ជាប្រមុខ ទើបជាហេតុឲ្យកើតចម្បាំងកាន់ដល់យ៉ាងសំបើម នៅទីបំផុតក្សត្ររាជវង្សចាស់មានជ័យជំនះ ហើយចាប់រ៉ុង-ម៉ុងទៅឃុំខ្លួនក្នុងស្រុក ស៊ី-អាំង កាលពីពុទ្ធសករាជ ៥៦៦ ដូច្នេះ ទើបឃើញថា រាជវង្សចាស់ដែលទើបនឹងសាបសូន្យទៅ ១ គ្រា រវាងវេលា ១៥ ឆ្នាំនោះ ក៏ត្រឡប់តាំងឡើងជាថ្មីវិញបាន ហើយព្រះអង្គម្ចាស់លៀវ-សៀវ ក៏បានឡើងគ្រងរាជ្យជាព្រះរាជាធិរាជទ្រង់ព្រះនាមព្រះបាទក្វាង-វូទី កាលពីពុទ្ធសករាជ ៥៦៨ ហើយទ្រង់គ្រប់គ្រងប្រទេសចិន រហូតដល់ពុទ្ធសករាជ ៦០០ ។

## ពួកហ្វូនបែកសាមគ្គី

លុះព្រះមហាក្សត្ររាជវង្សហាន់ ត្រឡប់តាំងឡើងវិញបានហើយ ទើបទ្រង់ចាប់ផ្តើមរៀបរយការណ៍ក្នុងប្រទេសឡើងវិញ ទ្រង់ផ្លាស់ទីក្រុង

ពីស្រុកស៊ុ — ឆាំងទៅនៅលោយ៉ុង ដើម្បីជាប្រយោជន៍ក្នុងការត្រួតត្រាទៅត្រង់ដែនបានដោយងាយផង ជាទីការពារក្រុងតាមផ្លូវយុទ្ធសាស្ត្រផង ហើយទ្រង់ចាត់ការប្រាបប្រាមពួកចំពោះក្រោមឲ្យស្ងប់កបទាប រួចស្ដេចចេញទៅប្រាបប្រាមស្រុកឯទៀត ៗ នៅទីបំផុតវាយបានស្រុកសេ-ឆ្នួនក្នុងពុទ្ធសករាជ ៥៧៩ ។ ក្រៅពីនេះ ព្រះបាទក្វាង់វ៉ូ-ទីបែរទៅប្រាបប្រាមអាណាទេក្តុងឥមាន ដែលធ្លាប់ជាចំណុះចិនអំពីដើម ទើបតែមករឹងទទឹងមិនព្រមចំណុះក្នុងខណៈដែលស្រុកចិនកំពុងកើតចលាចល ។

មានមេទ័ពចិនពូកែម្នាក់ឈ្មោះ ម៉ា-យួន វាយបានស្រុកតុង កឹងទឹងកោះហៃ-ណាំ (ហៃឡាំ) កាលពីពុទ្ធសករាជ ៥៨៥ ។ គ្រានេះចិនមានជោគល្អឡើងច្រើន នឹពួកហួនដែលជាសត្រូវចាស់របស់ចិន ដោះធម្មជាតិនោះ ក៏កើតបែកសាមគ្គីគ្នាជាពីរពួក គឺពួកហួនទិសខាងកើតនៅចំណែកខាងស្រុកម៉ុងហ្គូលីមួយពួក ពួកហួនទិសខាងលិច ចំណែកខាងស្រុកអ៊ីលីតែ ៦ ពួក ។ គ្រានេះចិនកើតគំនិតខ្សែបខាយឡើង គឺគ្រាន់តែចាំការពារកំផែងមិនឲ្យពួកហួនទាំងពីរពួកទៅមករកគ្នាបាន ទើបចាត់តាំងឋានទ័ពត្រង់ទីសំខាន់ៗ ទុកដូចជាក្វ-ប៊ី, ប៉េ-ចិលី នៅភាគខាងជើងហើយនៅឯតាតុង, ឯឡាន-ចៀវ, ឯគួន-ហួន ទឹងហាមី ។ មេទ័ពឈ្មោះម៉ាំ-យួន ជាអ្នកបញ្ជាការទ័ពនៅឡុងចៀវ បានធ្វើគំរូទុកយ៉ាងល្អដោយការបំនុកបំរុងភូមិប្រទេសឲ្យបានចំរើនឡើង គឺចិនយកទាហាន

ទៅតាំងធ្វើរបររកស៊ីចិញ្ចឹមជីវិតក្នុងទឹកដីនោះ មានទំនងដូចជាក្រុងពេម បានរៀបចំរក្សាស្រុកចំណុះរបស់ខ្លួន ។ តាំងពីពេលនោះមក ពួកហ្វូនក៏រួបរួមគ្នាមិនដាច់អស់មួយគ្រា ។

តែទុកជាយ៉ាងណាក៏ដោយ ការត្រួតត្រាខេត្តដែនទួរគីស្តង់ និងគ្រប់គ្រងពួកហ្វូននៅទិសខាងកើតនោះ មិនបានទទួលសេចក្ដីលំបាកវេទនាខ្លះដែរ ។

ទួរគីស្តង់ភាគខាងកើតនោះ ក្នុងសម័យដែលមិនមានអំណាចត្រួតត្រា ជាទីមានដីជាតិល្អ មានចំនួនប្រជាជនច្រើនក្នុងវេលានោះ ហើយបានចែកបំបែកគ្នាចេញទៅជាច្រើនភាគ ដូចជា ខូ-តាន, កប-តាវ, យ៉ារកេន្ត, ហើយមានស្រុកពីរ ដែលជាស្រុកស្តុកស្តម្ភជាងគេ គឺស្រុកកុលជា និងស្រុកកាក៉តារ ។

ស្រុកកុលជា ជាស្រុកស្តុកស្តម្ភហើយមានអំណាចរហូតមកក្នុងសម័យបុរាណកាល ស្រុកនេះជាស្រុកបានទទួលអារ្យធម៌របស់អឺរុបនិងឥណ្ឌាផ្សំគ្នា ភាសាដែលប្រើក្នុងស្រុកនេះហៅថា ភាសាតុក្ការៀន មានទំនងប្រហែលទៅនឹងភាសាអឺរុប ។ អារ្យធម៌របស់អឺរុបផ្សាយចូលមកក្នុងស្រុកនេះច្រើនជាងស្រុកឯទៀតៗ ក្នុងដែនទួរគីស្តង់ទាំងអស់ ហើយស្រុកកុលជានេះឯងជាស្ពានចម្លងសម្រាប់បើកផ្លូវ ឲ្យព្រះពុទ្ធសាសនាចេញពីឥណ្ឌាមកស្រុកចិនបាន ។

## អរិយសច្ច ជាពុទ្ធភាសិត

## លោកគ្រូព្រះអាចារ្យប៉ាង-ខាត់ ប្រែនិងរៀបរៀង

(តទូក)

បុគ្គលទាំងឡាយនោះ តែងអភិរម្យត្រេកអរក្នុងសង្ខារទាំងឡាយ ដែលប្រព្រឹត្តទៅដើម្បី ជាតិ ជរា ព្យាធិ មរណៈ សេចក្ដីសោក យំខ្សឹកខ្សួល សេចក្ដីទុក្ខកាយ ទុក្ខចិត្ត និងចង្អៀតចង្អល់ចិត្ត ។ បុគ្គលទាំងឡាយនោះ ដែលអភិរម្យក្នុងសង្ខារទាំងឡាយ ដែលតាក់តែងមានការតាក់តែងជាតិជាដើមនោះៗ ហើយ ឈ្មោះថាតាក់តែងសង្ខារទាំងឡាយ ជាគ្រឿងតាក់តែងដែលប្រព្រឹត្តទៅដើម្បី ជាតិ ជរា ព្យាធិ មរណៈ ជាដើមនោះៗ លុះបុគ្គលទាំងឡាយនោះ តាក់តែងសង្ខារទាំងឡាយមានជាតិជាដើមនោះៗ ហើយ ក៏ធ្លាក់លង់ផុងទៅក្នុងចំណងគឺ ជាតិ ជរា ព្យាធិ មរណៈ សេចក្ដីសោក យំខ្សឹកខ្សួល ទុក្ខកាយ ទុក្ខចិត្ត និងចង្អៀតចង្អល់ចិត្តទៀត ។ តថាគតពោលថា៖ "បុគ្គលទាំងឡាយនោះ មិនរួចស្រឡះអំពី ជាតិ ជរា ព្យាធិ មរណៈ សេចក្ដីសោក យំខ្សឹកខ្សួល ទុក្ខកាយ ទុក្ខចិត្ត និងចង្អៀតចង្អល់ចិត្តទាំងនេះទេ មិនរួចអំពីទុក្ខទេ" ។

មហាវារៈ សំ-១៩-៥៦៣-១៣៤០

## អ្នកដែលមិនដឹងអរិយសច្ច ឈ្មោះថាធ្លាក់ក្នុងភក់ភ្លើងជានិច្ច

ម្នាលភិក្ខុទាំងឡាយ! បុគ្គលឯណាមួយ ជាសមណៈឬជាព្រាហ្មណ៍

មិនដឹងច្បាស់តាមពិតថា: "នេះទុក្ខ នេះហេតុប្រជុំកើតឡើងនៃទុក្ខ នេះធម៌ជាគ្រឿងរំលត់ទុក្ខ នេះសេចក្ដីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខ" បុគ្គលទាំងឡាយនោះ តែងអភិរម្យត្រេកអរក្នុងសង្ខារទាំងឡាយ ដែលប្រព្រឹត្តទៅដើម្បីជាតិ ជរា ព្យាធិ មរណៈ សេចក្ដីសោក ខ្សឹកខ្សួល ទុក្ខកាយ ទុក្ខចិត្ត និងចង្អៀតចង្អល់ចិត្ត ។ បុគ្គលទាំងឡាយនោះ ដែលអភិរម្យត្រេកអរក្នុងសង្ខារទាំងឡាយ ដែលតាក់តែងមានការតាក់តែងជាតិជាដើមបែបនោះៗ ហើយ ឈ្មោះថាតាក់តែងសង្ខារជាគ្រឿងតាក់តែង ដែលប្រព្រឹត្តទៅដើម្បីជាតិ ជរា ព្យាធិ មរណៈជាដើមនោះៗ លុះបុគ្គលទាំងឡាយនោះ តាក់តែងនូវសង្ខារទាំងឡាយមានជាតិជាដើមបែបនោះៗ ហើយ ក៏ក្ដៅក្រហល់ក្រហាយ ពលកល ដោយជាតិ ជរា ព្យាធិ មរណៈ សេចក្ដីសោក ខ្សឹកខ្សួល ទុក្ខកាយ ទុក្ខចិត្ត និងចង្អៀតចង្អល់ចិត្តទៀត ។ តថាគតពោលទុក្ខថា: "បុគ្គលទាំងឡាយនោះ មិនរួចស្រឡះអំពីជាតិ ជរា ព្យាធិ មរណៈ សេចក្ដីសោក ខ្សឹកខ្សួល ទុក្ខកាយ ទុក្ខចិត្ត និងចង្អៀតចង្អល់ចិត្តនុះទេ មិនរួចអំពីទុក្ខទេ" ។

មហាវារ សំ. ១៩-៥៦៣-១៧៣៣

## បុគ្គលត្រាស់ដឹងអរិយសច្ច ទុកជាគោលក្នុងចិត្តហើយ មិនរំភើបញាប់ញ័រដោយខ្យល់គឺវាទៈ[1] ដូចសសរថ្ម"

១ វាទៈ នេះសំដៅពោលដេញដោលយកចាញ់ឈ្នះ ដោយអាងសំដីថ្វីមាត់រៀងខ្លួន ។

ម្នាលភិក្ខុទាំងឡាយ! ភិក្ខុឯណាមួយដឹងតាមពិតថា: "នេះទុក្ខ នេះហេតុប្រជុំកើតឡើងនៃទុក្ខ នេះធម៌ជាគ្រឿងរំលត់ទុក្ខ នេះសេចក្ដីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខ ។ បើទុកជាមានសមណៈឬព្រាហ្មណ៍ជាអ្នកត្រេកអរដោយវាទៈ ជាអ្នកស្វែងរកគូវាទៈ មកអំពីទិសខាងកើត ឬទិសខាងលិច, មកអំពីទិសខាងជើង ឬទិសខាងត្បូង ដោយប្រកាសខ្ទនថា: "ខ្ញុំនឹងលើកវាទៈ(១) របស់ភិក្ខុនោះចេញ ដូច្នេះ" ។ សេចក្ដីដែលសមណៈ ឬព្រាហ្មណ៍នោះ នឹងធ្វើភិក្ខុនោះឲ្យកំរើកឲ្យញាប់ញ័រឬឲ្យរំកើបដោយគន្លងធម៌នោះ មិនមែនជាឋានៈឡើយ ។

ម្នាលភិក្ខុទាំងឡាយ! ប្រៀបដូចសសរថ្មប្រវែង ១៦ ហត្ថ កប់កន្លដី ៨ ហត្ថ ផុតឡើងលើដី ៨ ហត្ថ បើទុកជាមានខ្យល់ព្យុះគ្រៀងគ្រាំងក្លា មកពីទិសខាងកើតឬទិសខាងលិច មកពីទិសខាងជើង ឬខាងត្បូង (យ៉ាងណាក៏ដោយ) ក៏សសរថ្មនោះមិនកំរើក មិនញាប់ញ័រ មិនរំកើបទៅបានឡើយ ។ សេចក្ដីនេះ ព្រោះហេតុអ្វី? ព្រោះសសរថ្មនោះគេកប់ជ្រៅផង ហើយមាំមួនផង ។

ឧហាភិរ: តាំ. ១៩-៥៥៥-១៣២.

---

១ ពាក្យដែលឲ្យទាល់តែភិក្ខុនោះចុះចាញ់ខ្លួន ។

## បុគ្គលប្រកបដោយអវិជ្ជា គឺបុគ្គលមិនដឹងអរិយសច្ច ៤ ប្រការ

ភិក្ខុនោះ អង្គុយក្នុងទីដ៏សមគួរមួយអន្លើ បានក្រាបទូលសួរពាក្យនេះ ចំពោះព្រះដ៏មានព្រះភាគថា: "បពិត្រព្រះអង្គដ៏ចំរើន! ព្រះអង្គតែងទ្រង់សំដែងថា: "អវិជ្ជា អវិជ្ជា" ដូច្នេះ, តើអវិជ្ជានុះដូចម្ដេច? ដោយហេតុដូចម្ដេច បុគ្គលទើបឈ្មោះថាប្រកបដោយអវិជ្ជា?" ។ ម្នាលភិក្ខុ! កិរិយាមិនដឹងឯណានីមួយ គឺកិរិយាមិនដឹងក្នុងទុក្ខ កិរិយាមិនដឹងក្នុងហេតុប្រជុំកើតឡើងនៃទុក្ខ កិរិយាមិនដឹងក្នុងធម៌ជាគ្រឿងរំលត់ទុក្ខ កិរិយាមិនដឹងក្នុងសេចក្ដីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខ នេះតថាគតហៅឈ្មោះថា: "អវិជ្ជា"; ឯបុគ្គលប្រកបដោយអវិជ្ជានុះ គឺបុគ្គលមិនដឹងសេចក្ដីពិតមានប្រមាណប៉ុណ្ណោះឯង ។ ម្នាលភិក្ខុ! ព្រោះហេតុនោះ អ្នកគប្បីធ្វើសេចក្ដីព្យាយាម ដើម្បីឲ្យដឹងថា: "នេះទុក្ខ នេះហេតុប្រជុំកើតឡើងនៃទុក្ខ នេះធម៌ជាគ្រឿងរំលត់ទុក្ខ នេះសេចក្ដីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខ" នេះចុះ ។

មហាវារៈ សំ ១៩-៤៣៨-១៦៩៤

## កុំគិតរឿងលោក តែប្រូវគិតរឿងអរិយសច្ច.

ម្នាលភិក្ខុទាំងឡាយ! ក្នុងអតីតកាលមានរឿងរ៉ាវដំណាលថា:- មានបុរសម្នាក់តាំងចិត្តថា: "អាត្មាអញនឹងគិតនូវរឿងលោក (ផែនដីពផែនដី) ដូច្នេះ" ហើយដើរចេញអំពីក្រុងរាជគ្រឹះចូលទៅកាន់ស្រះបោក្ខរណីឈ្មោះ

សុមាគធា ហើយអង្គុយគិតនៅទៀបឆ្នេរស្រះនោះ ៗ ម្នាលភិក្ខុទាំង-ឡាយ! បុរសនោះបានឃើញនូវសេនាទាហាន ប្រកបដោយអង្គ ៤ (គឺ: ពលដំរី. ពលសេះ. ពលរថ. ពលថ្មើរជើង) នៅឆ្នេរស្រះបោក្ខរណីឈ្មោះ សុមាគធានោះ កំពុងយាត្រាទ័ពចូលទៅតាមគល់ឈូក ៗ លុះបុរសនោះមើលឃើញដូច្នោះហើយ ក៏មានសេចក្តីត្រិះរិះក្នុងខ្លួនឯងថា: "អាត្មាអញឈ្មោះថាឆ្កួតហើយ អាត្មាអញឈ្មោះថាខូចចិត្តហើយ របស់ឯណាដែលមិនមានក្នុងលោក អញឃើញរបស់នោះហើយ" ដូច្នេះ ៗ ម្នាលភិក្ខុទាំងឡាយ! ពេលនោះ បុរសនោះក៏ត្រឡប់ចូលទៅកាន់នគរវិញ ហើយដើរនិយាយប្រាប់ពួកមហាជនថា: "នែអ្នកទាំងឡាយ! ខ្ញុំឈ្មោះថាឆ្កួតហើយ ខ្ញុំឈ្មោះថាខូចចិត្តហើយ ព្រោះថា របស់ឯណាដែលមិនមានក្នុងលោកខ្ញុំបានឃើញរបស់នោះហើយ" ដូច្នេះ ៗ អ្នកផងទាំងពួងសួរឈ្លួនទៀតថា "នែបុរសដ៏ចំរើន! ចុះអ្នកឆ្កួតដោយហេតុអ្វី អ្នកខូចចិត្តដោយហេតុអ្វី? របស់ឯណាមួយដែលមិនមានក្នុងលោក អ្នកបានឃើញរបស់នោះហើយឬ? ៗ បុរសនោះ និយាយប្រាប់តាមដំណើរដែលឃើញគ្រប់ប្រការ, អ្នកទាំងពួងនិយាយតរំពន់ថា: "នែបុរស! មែនហើយ អ្នកឆ្កួតហើយ មែនហើយ អ្នកខូចចិត្តហើយ របស់នេះមិនមានក្នុងលោកទេ ហើយអ្នកបានឃើញរបស់នោះហើយ ៗ ម្នាលភិក្ខុទាំងឡាយ! ដោយពិតបុរសនោះបានឃើញពិតដូច្នោះមែន មិនមែនឃើញរបស់មិនពិតទេ ៗ

ម្នាលភិក្ខុទាំងឡាយ! រឿងក៏ធ្លាប់មានមកក្នុងកាលពីដើមហើយ កាលនោះមានសង្គ្រាមពួកទេវតានឹងពួកអសុរ ដេញប្រកិតគ្នាមកហើយ ។ សង្គ្រាមនោះពួកទេវតាជាផ្នែកឈ្នះ ពួកអសុរជាផ្នែកចាញ់, លុះពួកអសុរចាញ់ហើយ ក៏ភ័យណាស់បបួលគ្នារត់ចូលទៅកាន់អសុរបុរីវិញ តាមគល់នៃគុម្ពឈូក ដោយគិតបំភាន់ពួកទេវតាកុំឲ្យរកផ្លូវខ្លួនឃើញ ។ ម្នាលភិក្ខុទាំងឡាយ! ព្រោះហេតុនោះ អ្នកទាំងឡាយចូរកុំគិតរឿងលោក ដោយន័យថា: "លោកទៀងដូច្នេះក្តី លោកមិនទៀងដូច្នេះក្តី លោកមានទីបំផុតដូច្នេះក្តី លោកមិនមានទីបំផុតដូច្នេះក្តី ជីវិតនោះក៏គឺសរីរៈនោះដូច្នេះក្តី ជីវិតដទៃសរីរៈដទៃដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតដូច្នេះក្តី សត្វស្លាប់ហើយមិនកើតទៀតដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតក៏មាន មិនកើតទៀតក៏មានដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះក្តី" ។ ព្រោះហេតុអ្វី? ម្នាលភិក្ខុទាំងឡាយ! ព្រោះកិរិយាគិតនោះ មិនប្រកបដោយប្រយោជន៍ មិនមែនជាដើមនៃព្រហ្មចរិយៈមិនមែនប្រព្រឹត្តទៅដើម្បីនឿយណាយ, ដើម្បីប្រាសចាករាគៈ ដើម្បីរលត់, ដើម្បីស្ងប់រម្ងាប់, ដើម្បីដឹងច្បាស់, ដើម្បីត្រាស់ដឹងនឹងដើម្បីព្រះនិព្វានទេ ។

ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយគិត គប្បីគិតដូច្នេះវិញថា: "ដូច្នេះទុក្ខ ដូច្នេះគឺហេតុប្រជុំកើតឡើងនៃទុក្ខ ដូច្នេះគឺធម៌ជា

គ្រឿងរំលត់ទុក្ខ ដូច្នេះគឺសេចក្ដីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខ" ។ ព្រោះហេតុអ្វី? ព្រោះហេតុថា កិរិយាគិតនេះប្រកបដោយប្រយោជន៍ ជាខាងដើមនៃព្រហ្មចរិយធម៌ ប្រព្រឹត្តទៅដើម្បីសេចក្ដីនឿយណាយចាកទុក្ខ ដើម្បីប្រាសចាករាគៈ ដើម្បីសេចក្ដីរំលត់ ដើម្បីសេចក្ដីស្ងប់រម្ងាប់ ដើម្បីសេចក្ដីដឹងច្បាស់ ដើម្បីសេចក្ដីត្រាស់ដឹង និងដើម្បីព្រះនិព្វាន ។

មហាវារៈ សំ. ១៩-៥៥៩- ១៧២៩.

## កុំនិយាយរឿងប្រណាំងប្រជែងបែកកន្លែកគ្នា ចូរនិយាយ តែសេចក្ដីដែលរួចចាកទុក្ខ.

ម្នាលភិក្ខុទាំងឡាយ! អ្នកទាំងឡាយកុំនិយាយវិគ្គាហិកកថា គឺពាក្យសំដីបែកកន្លែកគ្នាថា: "អ្នកមិនចេះដឹងធម៌វិន័យនេះច្បាស់លាស់ទេ ខ្ញុំទើបចេះដឹងធម៌វិន័យនេះប្រាកដ អ្នកធ្វើដូចម្ដេចនឹងចេះដឹងធម៌វិន័យនេះច្បាស់លាស់បាន អ្នកប្រតិបត្តិខុស ខ្ញុំទើបប្រតិបត្តិត្រូវ ពាក្យដែលគេគួរនិយាយមុន អ្នកទៅជានិយាយក្រោយ, ពាក្យដែលគួរគេនិយាយក្រោយ អ្នកទៅជានិយាយមុន, ពាក្យខ្ញុំទើបមានប្រយោជន៍ ពាក្យអ្នកមិនមានប្រយោជន៍ទេ, ពាក្យអ្នកដែលធ្លាប់ហាត់ចាំមកហើយ ឥឡូវប្រែប្រួលទៅអស់ហើយ ពាក្យរបស់អ្នកត្រូវខ្ញុំលើកឡើងបានហើយ, (គឺខ្ញុំសំគាល់ខុសបានហើយ) អ្នកត្រូវខ្ញុំផ្ចាញ់ផ្ចាលបានហើយ ដើម្បីឲ្យអ្នកដោះសាពាក្យខុសអ្នកចោលចេញ, បើពុំនោះ អ្នកល្បងស្ទួរមកមើលចុះ"

ដូច្នេះ ៗ អ្នកទាំងឡាយមិនគួរពោលរឿងនោះៗ ព្រោះហេតុអ្វី? ព្រោះថា កិរិយាពោលនោះៗ មិនមែនជាប្រយោជន៍ទេ មិនមែនជាខាងដើមនៃព្រហ្មចរិយធម៌ទេ មិនប្រព្រឹត្តទៅដើម្បីនឿយណាយ ដើម្បីប្រាសចាករាគៈ ដើម្បីសេចក្តីរំលត់ ដើម្បីសេចក្តីស្ងប់រម្ងាប់ ដើម្បីសេចក្តីដឹងច្បាស់ ដើម្បីសេចក្តីត្រាស់ដឹងដើម្បីព្រះនិព្វានទេ ៗ

ម្នាលភិក្ខុទាំងឡាយ! កាលបើអ្នកទាំងឡាយនិយាយ អ្នកទាំងឡាយគប្បីនិយាយថា: "សេចក្តីទុក្ខដូច្នេះៗ ហេតុប្រជុំកើតឡើងនៃទុក្ខដូច្នេះៗ ធម៌ជាគ្រឿងរំលត់ទុក្ខដូច្នេះៗ សេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខដូច្នេះៗ ព្រោះហេតុអ្វី? ព្រោះហេតុថាកិរិយានិយាយនោះ ជាការនិយាយប្រកបដោយប្រយោជន៍ ជាខាងដើមនៃព្រហ្មចរិយធម៌ ប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ ដើម្បីប្រាសចាករាគៈ ដើម្បីសេចក្តីរំលត់ ដើម្បីសេចក្តីស្ងប់រម្ងាប់ ដើម្បីសេចក្តីដឹងច្បាស់ ដើម្បីសេចក្តីត្រាស់ដឹងដើម្បីព្រះនិព្វាន ៗ

មហាវារៈ សំ. ១៩- ៥២៥- ១៦៦២.

## កុំនិយាយរឿងឥតប្រយោជន៍ តែចូរនិយាយរឿងរួចចាកទុក្ខ

ម្នាលភិក្ខុទាំងឡាយ! អ្នកទាំងឡាយចូរកុំនិយាយរឿងតិរច្ឆានកថា ឥតប្រយោជន៍ច្រើនប្រការ ៗ រឿងតិរច្ឆានកថា ដូចម្តេចខ្លះ? គឺ: រឿង

ស្តេច រឿងចោរ រឿងមហាមាត្យ រឿងសេនា រឿងផែលគួរភ័យ រឿងចម្បាំង រឿងបាយ រឿងទឹក រឿងសំពត់ រឿងដេក រឿងផ្កាកំរង រឿងគ្រឿងក្រអូប រឿងញាតិ រឿងយាន រឿងស្រុក រឿងនិគម រឿងនគរ រឿងជនបទ រឿងស្រី រឿងប្រុស រឿងមនុស្សក្លៀវក្លា រឿងផ្លូវដើរ រឿងកំពង់ដងទឹក រឿងបុព្វប្រេត រឿងផ្សេង ៗ រឿងលោក រឿងសមុទ្រ រឿងសេចក្តីរុងរឿង រឿងសេចក្តីទ្រុឌទ្រោម ទាំងអស់នេះ ។ ព្រោះហេតុអ្វី? ព្រោះថា កិរិយាពោលនោះ ៗ មិនប្រកបដោយប្រយោជន៍មិនជាខាងដើមនៃព្រហ្មចរិយធម៌ មិនប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ ដើម្បីប្រាសចាកតម្រេក: ដើម្បីសេចក្តីរំលត់ ដើម្បីសេចក្តីស្ងប់រម្ងាប់ ដើម្បីសេចក្តីដឹងច្បាស់ ដើម្បីសេចក្តីត្រាស់ដឹង និងដើម្បីព្រះនិព្វានទេ ។

ម្នាលភិក្ខុទាំងឡាយ! កាលបើអ្នកត្រូវនិយាយ គប្បីនិយាយថា: "សេចក្តីទុក្ខដូច្នេះ ៗ ហេតុប្រជុំកើតឡើងនៃទុក្ខដូច្នេះ ៗ ធម៌ជាគ្រឿងរំលត់ទុក្ខដូច្នេះ ៗ សេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខដូច្នេះ ៗ វិញ ព្រោះហេតុអ្វី? ព្រោះថា កិរិយានិយាយនោះ ៗ ប្រកបដោយប្រយោជន៍ ជាខាងដើមនៃព្រហ្មចរិយធម៌ ប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ ដើម្បីប្រាសចាកតម្រេក: ដើម្បីសេចក្តីរំលត់ ដើម្បីសេចក្តីស្ងប់រម្ងាប់ ដើម្បីសេចក្តីដឹងច្បាស់ ដើម្បីសេចក្តីត្រាស់ដឹង និងដើម្បីព្រះនិព្វាន ៗ ។

មហាវ; សំ. ១៩- ៥២៦ -១៦៦៣.

ចូរបួសដើម្បីសេចក្តីស្ងប់រំងាប់ទុក្ខ ដូចអ្នកបួសវិន័យទាំងឡាយ

ម្នាលភិក្ខុទាំងឡាយ ៖ កុលបុត្រទាំងឡាយឯណាមួយ ក្នុងអតីតកាលកន្លងយូរលង់ណាស់ហើយ ចេញអំពីផ្ទះហើយបួសក្នុងអនាគារិយវិន័យដោយត្រឹមត្រូវ, កុលបុត្រទាំងឡាយនោះ បួសហើយដើម្បីកិរិយាត្រាស់ដឹងតាមពិត នូវអរិយសច្ចទាំងឡាយបួន ។ ម្នាលភិក្ខុទាំងឡាយ! កុលបុត្រទាំងឡាយឯណាមួយ ក្នុងអនាគតកាលអស់កាលយូរលង់ នឹងចេញបួសក្នុងអនាគារិយវិន័យ ដោយត្រឹមត្រូវ កុលបុត្រទាំងឡាយនោះនឹងបួសដើម្បីកិរិយាត្រាស់ដឹងតាមពិត នូវអរិយសច្ចទាំងឡាយបួន ។ ម្នាលភិក្ខុទាំងឡាយ! កុលបុត្រទាំងឡាយឯណានីមួយ បួសក្នុងបច្ចុប្បន្នកាលនេះចេញចាកផ្ទះបួសក្នុងអនាគារិយវិន័យ ដោយត្រឹមត្រូវ, កុលបុត្រទាំងឡាយនោះ បួសដើម្បីកិរិយាត្រាស់ដឹងតាមពិត នូវអរិយសច្ចទាំងបួន ។ អរិយសច្ចទាំងឡាយបួននោះតើដូចម្តេច? អរិយសច្ចទាំងឡាយបួននោះគឺ៖ សេចក្តីពិតដ៏ប្រសើរគឺទុក្ខ ១ សេចក្តីពិតដ៏ប្រសើរគឺហេតុប្រជុំកើតឡើងនៃទុក្ខ ១ សេចក្តីពិតដ៏ប្រសើរគឺធម៌ជាគ្រឿងរំលត់ទុក្ខ ១ សេចក្តីពិតដ៏ប្រសើរ គឺសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខ ១ ។

ម្នាលភិក្ខុទាំងឡាយ! កុលបុត្រទាំងឡាយឯណានីមួយ ក្នុងអតីតកាលកន្លងយូរលង់ណាស់ហើយ ចេញចាកផ្ទះហើយបួសក្តី នឹងបួសក្តី

(កុងអនាគតកាល) ឬស (កុងបច្ចុប្បន្នកាល) ក្តី កុងអនាគតវិយនៃយ ដោយត្រឹមត្រូវ, កុលបុត្រទាំងឡាយនោះ សុទ្ធតែបួសដើម្បីកិរិយាត្រាស់ដឹងតាមពិត នូវអរិយសច្ចទាំងឡាយបួន ៗ ម្នាលភិក្ខុទាំងឡាយ! ព្រោះហេតុនោះ អ្នកទាំងឡាយគប្បីធ្វើសេចក្តីព្យាយាមដើម្បីឲ្យដឹងថា: "នេះទុក្ខ នេះហេតុប្រជុំកើតឡើងនៃទុក្ខ នេះធម៌ជាគ្រឿងរលត់ទុក្ខ នេះសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរលត់ទុក្ខ" — នេះបុះ ៗ

មហាវ: សំ. ១៩ - ឬ២១ - ១:៨៦

## បើមិនដឹងអរិយសច្ចតថាគតមិនសន្មតថា ជាសមណៈឬជាព្រាហ្មណ៍ ក្នុងវិន័យតថាគតទេ

ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំងឡាយឯណាមួយ ជាសមណៈឬជាព្រាហ្មណ៍ មិនដឹងច្បាស់តាមពិតថា: "នេះទុក្ខ នេះហេតុប្រជុំកើតឡើងនៃទុក្ខ នេះធម៌ជាគ្រឿងរំលត់ទុក្ខ នេះសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរលត់ទុក្ខ" ដូច្នេះ, ម្នាលភិក្ខុទាំងឡាយ! សមណៈទាំងឡាយនោះក្តី ព្រាហ្មណ៍ទាំងឡាយនោះក្តី តថាគតមិនសន្មត (មិនទទួលស្គាល់) ថាជាសមណៈក្នុងពួកសមណៈទាំងឡាយនោះទេ មិនសន្មត (មិនទទួលស្គាល់) ថាជាព្រាហ្មណ៍ក្នុងពួកព្រាហ្មណ៍ទាំងឡាយនោះទេ, ព្រោះអ្នកទាំងឡាយនោះ មិនបានធ្វើឲ្យជាក់ច្បាស់ នូវប្រយោជន៍នៃខ្លួនជាសមណៈឬជាព្រាហ្មណ៍ ដោយប្រាជ្ញាដ៏ក្រៃលែងក្នុងបច្ចុប្បន្នហើយសម្រេចនៅ ៗ

ម្នាលភិក្ខុទាំងឡាយ! រីឯបុគ្គលឯណាមួយ ជាសមណៈ ឬជាព្រាហ្មណ៍ដឹងតាមពិតថា: "នេះទុក្ខ នេះហេតុប្រជុំកើតឡើងនៃទុក្ខ នេះធម៌ជាគ្រឿងរំលត់ទុក្ខ នេះសេចក្ដីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខ" ដូច្នេះ, ម្នាលភិក្ខុទាំងឡាយ! សមណៈទាំងឡាយនោះឯងក្ដី ព្រាហ្មណ៍ទាំងឡាយនោះឯងក្ដី ទើបតថាគតសន្មត (ទទួលស្គាល់) ថាជាសមណៈក្នុងពួកសមណៈទាំងឡាយ ថាជាព្រាហ្មណ៍ក្នុងពួកព្រាហ្មណ៍ទាំងឡាយ, ព្រោះអ្នកទាំងឡាយនោះ បានធ្វើឲ្យជាក់ច្បាស់នូវប្រយោជន៍នៃខ្លួនជាសមណៈឬជាព្រាហ្មណ៍ ដោយប្រាជ្ញាដ៏ក្រៃលែងក្នុងបច្ចុប្បន្នកាលនេះ ហើយសម្រេចនៅ ។

ធម្មបទ. ១. ២៥ - ៣១០ - ២៨៣

## បើលោកនៅចាំចង់ដឹងរឿងដែលមិនជាប្រយោជន៍ហើយ ក៏ស្លាប់ទៅចោល ដែរទេ

ម្នាលមាលុង្ក្យបុត្រ! បុគ្គលឯណានិយាយយ៉ាងនេះថា: "ខ្ញុំមិនទាន់ប្រ-ព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះដ៏មានព្រះភាគទេ ព្រោះព្រះដ៏មានព្រះភាគមិនទាន់សំដែងទិដ្ឋិ ១០ ប្រការដល់ខ្ញុំព្រះអង្គថា: "លោកទៀងដូច្នេះក្ដី លោកមិនទៀងដូច្នេះក្ដី លោកមានទីបំផុតដូច្នេះក្ដី លោកមិនមានទីបំផុតដូច្នេះក្ដី ជីវិតនោះក៏គឺសរីរៈនោះដូច្នេះក្ដី ជីវិតដទៃសរីរៈក៏ដទៃដូច្នេះក្ដី សត្វស្លាប់ហើយកើតទៀតដូច្នេះក្ដី សត្វស្លាប់ហើយមិនកើតទៀត

ដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតក៏មានមិនកើតទៀតក៏មានដូច្នេះក្តី សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះក្តីឬអ្វី? ម្នាលមាលុង្ក្យបុត្រ! តថាគតសំដែងដំណើរនោះឲ្យមិនទាន់ទេ បុគ្គលនោះមុខជានឹងធ្វើមរណកាលទៅ (មុនសំដែង) ដោយពិត" ៗ ម្នាលមាលុង្ក្យបុត្រ! ដូចជាបុរសត្រូវសរ (របស់សេនានៃស្តេចដទៃ) ដែលលាបប្រឡាក់ដោយថ្នាំពិសៈក្រាស់ មិត្រអាមាត្យញាតិសាលោហិតរបស់បុ-រសនោះ ក៏ចូលទៅរកពេទ្យជាអ្នកវះ ៗ បុរសនោះនិយាយយ៉ាងនេះថា "ខ្ញុំមិនទាន់ឲ្យដកព្រួញនេះទេ ព្រោះខ្ញុំមិនទាន់ស្គាល់បុរសដែលបាញ់ខ្ញុំនោះ ជាក្សត្រឬព្រាហ្មណ៍ជាវេស្សៈឬសុទ្ទៈនៅឡើយទេ...មិនទាន់ស្គាល់នាមគោត្រ ... ខ្ពស់ទាបឬកណ្តាល ខ្មៅ សណ្តែកបាយឬប្រផេះ . . . ស្រុកឬនិគម ឬនគរឯណា ៗ ... មិនទាន់ស្គាល់ធ្នូដែលបុគ្គលនោះបាញ់ជាកាំភ្លើងឬស្នា . . . មិនទាន់ស្គាល់ខ្សែធ្នូនោះជាសម្បកពក់ឬពន្លៃឬសរ្សៃជាសរសៃសត្វឬសម្បកខ្លុងពណ៍ ឬល្មើទឹកដោះ ... មិនទាន់ស្គាល់ព្រួញជាព្រួញឈើព្រៃ ឬព្រួញឈើដែលគេដាំ សៀតដោយស្លាបសត្វត្មាតឬប្រមង់ ខ្លែង ក្ងោក ឬទុង ...រុំដោយសរសៃគោឬក្របី ឬសីហៈខ្លាឬស្វា ... មានមុខរដូល. សំបែកដូចកាំបិតអានដៀង ឬមុខស្រោបដែកមានមុខដូចពុតន្ទាក ធ្វើពីទ្រនុងជាងព្រាង ៗ ម្នាលមាលុង្ក្យបុត្រ! បុរស

នោះចាំជីនជំណើរនោះមិនទាន់ទេ មុខជាបុរសនោះ ទំនងធ្វើមរណកាលពេលនៅពុំបាន ។ ម្នាលមាលុង្ក្យបុត្រ! បុគ្គលឯណានិយាយយ៉ាងនេះថា: "ខ្ញុំមិនទាន់ប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងសំណាក់ព្រះដ៏មានព្រះភាគទេ ព្រោះព្រះដ៏មានព្រះភាគមិនទាន់សំដែងទិដ្ឋិ ១០ ប្រការ មានលោកទៀងដូច្នេះក្ដីជាដើម ដល់ខ្ញុំព្រះអង្គ, ម្នាលមាលុង្ក្យបុត្រ! តថាគតនឹងសំដែងជំណើរនោះឲ្យមិនទាន់ទេ បុគ្គលនោះមុខជាធ្វើមរណកាលទៅ (មុខសំដែង) ពុំបាន មានឧបមេយ្យដូចជាបុរសដែលត្រូវសរមុតនោះឯង ។

ម្នាលមាលុង្ក្យបុត្រ! កាលបើមានទិដ្ឋិ ១០ ប្រការ សេចក្ដីយល់ឃើញថា: "លោកទៀងដូច្នេះក្ដី លោកមិនទៀងដូច្នេះក្ដី លោកមានទីបំផុតដូច្នេះក្ដី លោកមិនមានទីបំផុតដូច្នេះក្ដី ជីវិតនោះក៏គឺសរីរៈនោះដូច្នេះក្ដី ជីវិតដទៃ សរីរៈក៏ដទៃដូច្នេះក្ដី សត្វស្លាប់ហើយកើតទៀតដូច្នេះក្ដី សត្វស្លាប់ហើយមិនកើតទៀតដូច្នេះក្ដី សត្វស្លាប់ហើយកើតទៀតក៏មាន មិនកើតទៀតក៏មានដូច្នេះក្ដី សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះក្ដី ហើយការប្រព្រឹត្តព្រហ្មចរិយធម៌ក៏មិនមាន តែជាតិក៏មាន ជរាក៏មាន ព្យាធិក៏មាន មរណៈក៏មាន សេចក្ដីសោក សេចក្ដីខ្សឹកខ្សួល សេចក្ដីលំបាកកាយ សេចក្ដីតូចចិត្ត សេចក្ដីក្រៀមក្រំចិត្ត ក៏មានជាធម៌ដែលតថាគតបញ្ញត្ត ថាជាសេចក្ដីវិនាសក្នុងបច្ចុប្បន្ន ។

(មានត)

# ឯកសារគម៉ល់ឆ្លបញ្ញា

## ហង្ឋនិពន្ធមន្ត្រី ញ៉ុក-ថែម រួបរួមប្រែ

( តមកនឹងចប់ )

## អង្គ ៥ របស់សមុទ្រ

១– មិនរួមប្រឡូកប្រឡល់ដោយសាកសស្អុក ។

២– ជាទីប្រជុំនៃកែវមុក្តា កែវពៃទូរ្យ កែវប្រពាឡ កែវផលិក មានប្រការផ្សេងៗ មិនឲ្យខ្ចាត់ខ្ចាយកក់ឃាទៅក្រៅ ។

៣– ដ៏ជ្រៅជ្រាលទៅដោយមហាត្ដូតជាច្រើន ។

៤– ដ៏ពេញប្រៀបដោយទឹកថ្មី ដែលហូរចូលមកអំពីទន្លេតូច-ធំទាំងឡាយ និងទឹកដែលធ្លាក់ចុះមកពីក្នុងអាកាស ប៉ុន្តែមិនដែលហៀរហួសពីមាត់ច្រាំងសមុទ្រឡើយ ។

៥– មិនចេះឆ្អែតស្កប់ស្កល់ពេញប្រៀបដល់មាត់ច្រាំងដោយទឹកដែលហូរមកពីទន្លេទាំងពួងនិងទឹកដែលធ្លាក់ចុះមកពីអាកាស ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអដ្ឋសម្បត្តិ ៥ ប្រការគឺ:

១– មិននៅរួមនឹងកិលេសជាគ្រឿងសៅហ្មង មានរាគៈ ទោសៈ មោហៈ ជាដើម ។

២– ទ្រទ្រង់ទុកនូវកែវ គឺគុណវិសេសផ្សេងៗ មានមគ្គផលនិព្វានជាដើម ហើយរក្សាទុកតែខាងក្នុងមិនឲ្យសាយចេញទៅខាងក្រៅ ។

៣ - នៅអាស្រ័យទំនិសព្រហ្មចារី ដែលជាកល្យាណមិត្ត ជាអ្នកទ្រទ្រង់នូវគុណធម៌មានប្រាជ្ញាគិត សន្តោស មានខ្មាស មានសីលជាទីស្រឡាញ់ជាដើម ។

៤ - មិនក្តែងល្មើសសិក្ខាបទ ព្រោះហេតុតែលាភយសសរសើរ សុខក្តី ព្រោះហេតុតែការចិញ្ចឹមជីវិតក្តី ។

៥ - ទុកជាបានស្តាប់ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ជានិច្ច ក៏មិនបេះដូងធ្ងន់សោះឡើយ ។

## អង្គ ៥ របស់ផែនដីៈ

១ - ទុកជាគេចាក់ពោយកយវត្ថុ-អាក្រក់ច្រើនយ៉ាងច្រើនប្រការ គឺ កប្បូរ ពុំសែន ក្រស្នា ក្រពេះបូចច័ន្ទន៍ មាន់ហាមជាដើមក្តី ស្លេស្ម ឈាម ខ្ទាញ់ ទឹកសម្បោរ បន្ទោបង់ទុច្ចារៈបស្សាវៈជាដើមក្តី ក៏ផែនដីនៅដដែលមិនត្រេកអរ មិនអន់ចិត្តសោះឡើយ ។

២ — ប្រាសចាកការគាក់តែងដោយគ្រឿងប្រដាប់ប្រដានិងលាប ស្រឡាបដោយគ្រឿងក្រអូបផ្សេងៗ ។

៣ — មិនមានឧបៈន្ធាះ មិនមានរន្ធ មិនមានប្រហោង មានសាច់ណែនគាន់ជាផ្ទាំងមួយ ។

៤— ទ្រទ្រង់នូវសព្វសារពើផ្សេងៗជាដើម គឺ ភូមិ ស្រុក នគរ ជនបទ ដើមឈើ ភ្នំ ស្ទឹង ទន្លេ ព្រែក ស្រះ សត្វទ្វិបាទ ចតុប្បាទ

សត្វបក្សី គឺជាមនុស្សប្រុស-ស្រី មិនមានសេចក្តីវិលប្រួសបញ្ញាទាន់សោះឡើយ ។

៤— ប្រាសចាកសេចក្តីត្រេកអរប្លែកចិត្ត ឥតគិតបៀតបៀនសត្វដទៃឲ្យលំបាកឡើយ ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ៥ ប្រការ គឺ:

១— ទន់ខ្លួនទាបខ្លួន មិនសំដែងការខ្ពស់ទាប មិនត្រេកអរ មិនអន់ចិត្ត ក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ។

២ ប្រាសចាកការប្រដាប់តាក់តែងដោយគ្រឿងប្រដាប់ដែលមិនសមគួរដល់ភេទរបស់ខ្លួន តែងអង្គខ្លួនដោយគ្រឿងក្រអូបគឺសីល ។

៣ — មានសីលបរិសុទ្ធ មិនមានទោស មិនដាច់មិនធ្លុះ មិនមានប្រហោង ណែនណាន់ខ្ជាប់ខ្ជួន ។

៤— មិនខ្ជិលច្រអូស ខំស្វាហាប់ប្រកបករណីយកិច្ចទាំងឡាយឲ្យសមនឹងមុខក្រសួងរបស់ខ្លួន ឲ្យសមនឹងភេទរបស់ខ្លួនសព្វៗកាលទៅ ។

៥— ផុតចាកសេចក្តីត្រេកអរនិងអន់ចិត្ត មានចិត្តស្មើដោយផែនដី

## អង្គ ៥ របស់ធម្មជាតិទឹក

១— នឹងស្ងៀម មិនរំជួយ មិនសៅហ្មង ថ្លាស្អាតជាប្រក្រតី ។

២— មានលក្ខណៈត្រជាក់ជានិច្ច ។

៣— ជម្រះលាងរបស់ស្មោកគ្រោកឲ្យស្អាតបាន ។

៤— ជាទីប្រាជ្ញដ៏ក្រៃលែង នៃមនុស្សសត្វទាំងពួង ។

៥— មិនយករបស់ឥតប្រយោជន៍ចូលទៅឲ្យដល់អ្នកឯណាទីមួយឡើយ គឺសម្រេចប្រយោជន៍ដល់អ្នកផងគ្រប់គ្នា ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ៥ ប្រការគឺ:

១— មិននិយាយកុហក មិននិយាយឃោះផ្តេសប៉ះ ស្វែងរកតែហេតុ ជាអ្នកមានមារយាទល្អ បរិសុទ្ធជាប្រក្រតី ។

២— បរិបូណ៌ដោយមេត្តា ខន្តី សោរច្ចៈ អហិង្សាជាប្រក្រតី ស្វែងរកតែប្រយោជន៍ មានសេចក្តីអនុគ្រោះដល់សព្វសត្វទាំងឡាយ ។

៣— ទុកជានៅកន្លែងណាៗ ក៏ដោយ ក៏គប្បីធ្វើកិច្ចដែលជាប្រយោជន៍ដល់មនុស្សគ្រប់ជាន់ ។

៤— មានប្រាជ្ញាគិត សន្តោស គេចទៅពួនក្នុងទីស្ងាត់ ប្រតិបត្តិខ្លួនជាទីប្រាជ្ញារបស់សត្វលោកផងគ្នាជានិច្ច ។

៥— មិនបង្កការបែកបាក់ សំណោះ ប្រកួតប្រកាន់វិវាទ ចុះស្រាឲ្យកើតឡើង មិនធ្វើអំពើអាក្រក់ដោយកាយ វាចាចិត្តឡើយ ។

## អង្គ ៥ របស់ភ្លើង:

១— ដុតស្មៅ ឈើ ស្លឹកឈើ ចំបើង ។

២— មិនអាណិត មិនអាសូរដល់គេដែលឆេះភ្លើងនោះឡើយ ។

៣— ជាគ្រឿងកំចាត់ងងឹតចេញបាន ។

៤- ឲ្យកើតសេចក្ដីកក់ក្ដៅហាំងក្រៃលែង ។

៥- កំចាត់ងងឹតឲ្យភ្លឺឡើងបាន ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ៥ ប្រការ គឺ:

១- ដុតកំដៅកិលេស ទាំងខាងក្នុង ទាំងខាងក្រៅដោយភ្លើងគឺញាណ ។

២- មិនមានចិត្តអាណិតអាសូរ ក្នុងកិលេសទាំងឡាយឡើយ ។

៣- ញុំាងភ្លើងជាគ្រឿងដុតបំផ្លាញ គឺវិរិយៈឲ្យកើតឡើងដើម្បីកំចាត់បង់នូវគងកិលេសទាំងពួង ។

៤- ប្រាសចាកសេចក្ដីត្រេកអរនិងអន់ចិត្ត និងបដិឃៈ រមែងមានចិត្តស្មើដោយភ្លើង ។

៥- កំចាត់ងងឹត គឺអវិជ្ជា បង្កើតពន្លឺ គឺបញ្ញាញាណ ។

## អង្គ ៥ របស់ខ្យល់

១- បក់ផាត់ក្លិនក្រអូបនៃផ្កាឈើទាំងឡាយឲ្យផ្សាយផ្សប់ទៅក្នុងដងព្រៃ ។

២- បក់បោកព្រៃព្រឹក្សាឲ្យបាក់ខ្ទេចខ្ទី និងដកឫសរំលើងគល់រហូតដល់ឫសកែវ ។

៣- តែងបក់ផាត់ទៅក្នុងអាកាស ។

៤- ផ្សាយក្លិនអប់ផ្សប់ផ្សាយទៅ ។

៥- មិនមានអាល័យ មិនមានលំនៅ ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ៥ ប្រការគឺ :

១- ត្រេកអរក្នុងអារម្មណ៍ ដូចជននៅព្រៃដែលមានផ្កាឈើរីកទាំងក្រគ្រប់ដើមក្រៃលែងគឺវិមុត្តិ ។

២- ពិចារណាសង្ខារ ដូចខ្យល់ដែលបក់ទៅក្នុងដងព្រៃដើម្បីបំផ្លាញកិលេសទាំងឡាយ ។

៣- ញ៉ាំងចិត្តឲ្យត្រាច់ទៅក្នុងលោកុត្តរធម៌ទាំងឡាយ ។

៤- ហិតស្រូបក្លិនដ៏ក្រអូបឈ្ងុយឈ្ងប់ គឺសីលរបស់ខ្លួន ។

៥- មិនមានអាល័យ មិនមានលំនៅ ជាអ្នករួចផុតជ្រះស្រឡះ ។

## អង្គ ៥ របស់ភ្នំ

១- មិនរញ្ជួយ មិនកំរើក មិនញាប់ញ័រ ។

២- ជារបស់រឹងប៉ុន មិនប្រឡូកប្រឡំដោយវត្ថុណាមួយឡើយ ។

៣- ដំណាំមិនដុះនៅលើកំពូលថ្មសុទ្ធនោះឡើយ ។

៤- ខ្ពស់ឡើងទៅជាលំដាប់ ។

៥- មិនងើកងោកទៅមក ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ៥ ប្រការ គឺ:

១- មិនត្រេកអរ មិនអន់ចិត្តក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍

មិនស្រឡាញ់ មិនរីង មិនរវើង ក្នុងអារម្មណ៍ជាទីតាំង នៃសេចក្តីត្រេកអរ មិនរីងមិនរវើង មិនញាប់ញ័រ មិនព្រួយដូចជាភ្លឺ ។

២ — មិនប្រចូកប្រចល់ដោយសង្ខារ ដែលជាទីកកើតនៃកិលេសគ្រឿងសៅហ្មងចិត្ត ។

៣ - មិនបើកឱកាសចន្លោះ ឲ្យកិលេសទាំងឡាយកើតឡើងក្នុងចិត្តរបស់ខ្លួន ។

៤ — ជាអ្នកប្រសើរវិសេសដោយប្រាជ្ញាញាណ ។

៥ — កាលបើមានឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ មកប៉ះពាល់ចិត្ត ក៏មិនមានសោមនស្ស និងទោមនស្សឡើយ ។

## អង្គ ៥ របស់អាកាស

១ - ទោះអ្នកណាទីមួយ កាន់កាប់កក្រោងទុកមិនបានទាំងអស់ ។

២ - ជាទីត្រាច់ទៅនៃពួកឫសីតាបស និងសត្វបក្សីទាំងឡាយ ។

៣ - មានផ្ទុកបន្ទារ ។

៤ - មិនមានទីបំផុត គណនាមិនបាន ប្រមាណមិនត្រូវ ។

៥ — មិនមានជាប់ជំពាក់ មិនមានទីតាំងមិនមានអាល័យ ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ៥ ប្រការ គឺ:

១ — មិនបើកឱកាសចន្លោះឲ្យកិលេសទាំងឡាយ ចូលមកប្រើត ដោយប្រការទាំងពួង ។

២ — ញ៉ាំងចិត្តឲ្យត្រូវទៅក្នុងសក្ការទាំងឡាយ ដោយពិចារណាទៅតាមព្រះត្រៃល័ក្ខណ៍ ។

៣ — ភ័យៈស្បើកក្នុងការទៅចាប់បដិសន្ធិក្នុងភពទាំងពួង ព្រោះសេចក្តីសុខក្នុងភពមានឧបមាដូចផ្ទះផ្គររន្ទះ ។

៤ — មានសទ្ធិនិងធារៈដាំងដ៏បរិសុទ្ធនេះហើយ មិនមានទីបំផុតមានញាណដ៏ចាស់ក្លាប្រាជ្ញាណាមិនស្មាន ។

៥ — ជាអ្នកមិនជាប់ជំពាក់ ចំនួនអំណាច មិនមានសេចក្តីអាល័យក្នុងបច្ច័យនិងកិលេសទាំងពួង ។

## អង្គ ៥ របស់ព្រះបុត្រ

១ — ក្នុងសុគតកុចឡើងប្តូរត្រូវត្រង់ដ៏ក្រៃលែង ។

២ — ជាធំដ៏ក្រៃលែង ។

៣ — អណ្តែតត្រៃសក្នុងវេលាកាត្រី ។

៤ — មានវិមានជាទីជ័យ ។

៥ — មនុស្សលោកនាំគ្នាអង្វរសុំឲ្យចុះពន្លឺនៅជានិច្ច ។

ប្រៀបដូចអ្នកព្រាតបត្តិបែកបះដោយអង្គសម្បត្តិ ៥ ប្រការ គឺ:

១ — បំភ្លឺនឿងៗក្នុងកុសលធម៌ទាំងពួង ។

២ — មានធនៈជាអធិបតីដ៏ឧឡារិក ។

៣- មានកាយរាបចិត្ត ប្រកបដោយសេចក្តីស្ងប់ត្របទៅ ។

៤- មានសីលជាទង់ជ័យ ។

៥- កាលត្រកូលចូលមកសូមអារាធនានិមន្ត ក៏ចូលទៅកាន់ត្រកូលទាំងឡាយតាមសេចក្តីត្រូវការប្រាថ្នារបស់គេ ។

## អង្គ ៥ របស់ដំរី

១- ត្រេចចូលទៅក្នុងព្រៃ តែងយកជើងឈូសផែនដី ។

២- សំឡឹងមើលតែសព្វកាយខ្លួន មិនមើលរេមើលទៅកាន់ទិសផ្សេងៗឡើយ ។

៣- មិនដេកប្រចាំនៅទីកន្លែងជានិច្ចឡើយ ចេញទៅស្វែងរកអាហារបាននៅទីណា ក៏ចូលទៅអាស្រ័យនៅទីនោះ មិនអាល័យទីលំនៅ ។

៤- ទីចុះងូតទឹក ក៏ច្រើនតែចុះក្នុងស្រះឈូកដ៏ធំទូលាយ មានទឹកថ្លាស្អាត មិនកករល្អក់ ដំដេរដាសទៅដោយមើមឈូក ទីផ្កាឈូកក៏ច្រើន ហើយតែងចុះលេងទឹកតាមដំណើរដំរី ។

៥- ទីលើកជើងក៏មានស្មារតី ទីដាក់ជើងចុះក៏មានស្មារតី ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ៥ ប្រការ គឺ:

១- ពិចារណាតែក្នុងកាយ ដើម្បីបំផ្លាញកិលេសទាំងឡាយ ។

២- ពិតពិលមើលតែសព្វកាយ មិនសំឡឹងមើលទៅទិសទាំងឡាយ

មិនងើយមើលលើ មិនឈោកមើលក្រោម ឈោះក្លែកក្រឡេកមើល ទៅត្រឹមរយៈ ១ នឹមរទេះ ។

៣ - មិនមានលំនៅប្រចាំជានិច្ច មិនមានអាល័យត្រេចទៅណា ជាទីភ្ជាប់ចិត្តនឹងសមគួរ គិតូលទៅឯស្រ័យទីនោះ មិនជាប់ចិត្តអាឡោះអាល័យលំនៅ ។

៤ - ចំរើនមហាសតិបដ្ឋាន ដែលមានទំនងដូចជាស្រះបោក្ខរណី (ស្រះឈូក) ដ៏គេញប្រៀបទៅដោយធម៌ដ៏ប្រសើរ ត្រជាក់មិនកករល្អក់ ថ្លាស្អាតប្រាសចាកមន្ទិល ដ៏ដេរដាសដោយមើមឈូកនឹងផ្កាឈូកគឺវិមុត្តិ ពិចារណាវិញកសង្ខារដោយញាណ ។

៥ - មានសតិសម្បជញ្ញៈនៅគ្រប់ឥរិយាបថ ។

## អង្គ ៥ របស់ព្រៃ

១ - បិទបាំងវុកច្ចូវមនុស្សអិទស្អាត ។

២ — ជាទីទំនេរ ផុតមនុស្សត្រេចទៅៈត្រេចមក ។

៣ — ជាទីស្ងប់ស្ងាត់ ។

៤ — ជាទីស្ងប់ម្ងាប់ដ៏បរិសុទ្ធ ។

៥ — ជាទីដែលព្រះអរិយៈតាំងឡាយតែងៈសេពគប់ ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ៥ ប្រការគឺៈ

១ – បិទបាំង មិនបើកផ្សាយប្រកាសទោស សេចក្តីក្តាំងក្តាត់ ការសម្ងាត់របស់ជនដទៃ ។

២ – សាបសូន្យចាកកិលេសទាំងឡាយ មានរាគៈ ទោសៈ មោហៈ ជាដើម ។

៣ – ស្ងប់ស្ងាត់ចាកអកុសលបាបធម៌ទាំងឡាយ ។

៤ – ជាអ្នកស្ងប់រម្ងាប់ដ៏បរិសុទ្ធ ។

៥ – ជាអ្នកដ៏ព្រះអរិយបុគ្គលគប្បីសេពគប់សមាគម ។

## អង្គ ៥ របស់មេឃ

១ – រម្ងាប់ធង់ហុយធូលីលើផែនដី ។

២ – រំលត់កំដៅនៅផែនដីឲ្យត្រជាក់ ។

៣ – ញ៉ាំងដំណាំគ្រប់យ៉ាងឲ្យដុះលូតលាស់ល្អ ។

៤ – ជាកំណើតនៃទឹក ហើយតែងធ្លាក់ចុះមកតាមរដូវកាលតែង រុក្ខគុម្ពោត ដើមឈើ វល្លិ៍ជាដើមឲ្យដុះលូតលាស់ល្អ ។

៥ – បង្អុរចុះមកកន្លែងទីផ្សេងៗមានស្ទឹងទន្លេ ស្រះបោក្ខរណី អណ្តូង ត្រពាំងបឹងបួជាដើម ញ៉ាំងទីទាំងនោះឲ្យពេញទៅដោយទឹក ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ៥ ប្រការគឺ :

១ – រម្ងាប់កិលេសដូចជាធង់ហុយធូលី ដែលកើតឡើង ឲ្យអស់ទៅទាល់តែផុតពូជ ។

២ — ចំរើនមេត្តាករុណា ដែលអាចរម្ងាប់កំហឹងរបស់មនុស្សនិងទេវតាទាំងឡាយ ធ្វើឲ្យត្រជាក់បាន ។

៣ — ញុំាងសទ្ធា ដែលទុកដូចជាពូជរបស់សព្វសត្វឲ្យចំរើនលូតលាស់ល្អ ក្នុងសម្បត្តិទាំង ៣ គឺសម្បត្តិរបស់មនុស្ស សម្បត្តិរបស់ទេវតា និងសម្បត្តិ គឺព្រះនិព្វាន ។

៤ — ញុំាងយោនិសោមនសិការៈឲ្យកើតឡើងហើយរក្សាសមណធម៌ដោយយោនិសោមនសិការៈនោះ ព្រោះកុសលធម៌ទាំងពួង សឹងមានយោនិសោមនសិការៈជាមូលហេតុ ។

៥ — ញុំាងភ្លៀង គឺបរិយត្តិ បដិបត្តិ បដិវេធ ឲ្យបង្អុរចុះមក ហើយញុំាងចិត្តរបស់អ្នកប្រាថ្នាបដិវេធឲ្យបានពេញលេញឡើង ។

---

# ប្រវត្តិសង្ខេបរបស់ឧបាសក ហួត - ធិន
## ឃុំឆ្លូង ស្រុកឆ្លូង ខេត្តក្រចេះ

ឧបាសក ហួត - ទិន ជាបុត្រឧញ៉ាបេកញូក និងឧបាសិកា នាង កើតនៅថ្ងៃ ៣ ។ ៦ ឆ្នាំមមែ ក្នុងឃុំឆ្លូង ស្រុកឆ្លូង ខេត្តក្រចេះ ។ កាលពីកុមារបានសិក្សារៀនសូត្រអក្សរខ្មែរ និងបួសរៀននៅវត្តឆ្លូង បាន ៤ វស្សា លាចាកសិក្ខាបទក្នុងវ័យអាយុ ២០ ឆ្នាំ បានរួមសមរស និងនាងស្រីខែ ជាបុត្រីលោកអ្នកឧកញ៉ាសោ និងអ្នកស្រីថោង ។

កាលស្វាមីភរិយាគូនេះនៅរួមសុខទុក្ខជាមួយគ្នាទៅ ក៏បង្កើតបាន កូនប្រុស - ស្រីដល់ ៨ នាក់ (ប្រុស ៤ ស្រី ៤) គួរពប់ថាជាគ្រួសារមាន កូនស្គុកស្គម្ភមួយ ហើយបានរៀបចំឲ្យកូនទាំងនោះមានស្វាមី - ភរិយា តាមប្រពៃណីលោកទាំងអស់គ្នា ។ ឧបាសកហួត - ទិន និងឧបាសិកាខែ ជាអ្នកមានសទ្ធាជ្រះថ្លាមាំមួន ក្នុងព្រះពុទ្ធសាសនា នៅឱកាសដែល កំពុងចំរើនដោយសម្បត្តិធនធាន បានធ្វើបុណ្យទានផ្សេង ៗ ជាច្រើន យ៉ាង ដូចបុណ្យកឋិនទានជាដើម ។ ហើយបើយកចំពោះការកុសលធំ ៗ ដែលឧបាសកហួត - ទិន បានសាងជាមួយនិងគ្រួសារគឺ (១) សាង ចេតិយ ១ ធ្វើដោយបេតុងអារម៉េ ទំហំជើងកោស ៧ ម៉ែត្រកន្លះ កំពស់ ១៨ ម៉ែត្រ អស់ចំនួនធនធាន ៧,០០០រ ០០ សម្រាប់ជាទីបញ្ចុះអដ្ឋិធាតុ របស់មាតាបិតាបង្កើត និងមាតាបិតាក្មេកនៅក្នុងវត្តសិលានទីឆ្លូងក្រោ ។

(២) បានបុណ្យបច្ច័យជួយកសាងវិហារវត្តសិលាននៅនោះ ចំនួន ២.១០០៛០០ (៣) បានថវាព្រះត្រៃបិដកដែលពុទ្ធសាសនបណ្ឌិត្យបោះពុម្ពផ្សាយចំនួន ១ចប់ ដំឡៃ ៥៤០៛.០០ ។

ឧបាសក ហួត-ទិន បានប្រកបការរកស៊ីដោយសម្មាអាជីវៈ រួមរួមជាមួយនឹងគ្រួសារ ជាសុខសប្បាយរហូតដល់អាយុ ៦០ មានរោគាពាធកាន់តែរឿតរឿនខ្លាំងឡើងជានិច្ច ទើបពិចារណាយល់ឃើញជាមរណភ័យកាន់តែខ្លួនចូលមកជិតជិតគាត់ហើយ ។ បណ្ដាកូនចៅប្រុស-ស្រីក៏នាំគ្នាមកជួបជុំពុំឃ្លាតឆ្ងាយ ហើយបាននិមន្តព្រះសង្ឃមកសូត្រស្វាធ្យាយជាប់រាល់ ៗ យប់ ដរាបដល់ថ្ងៃសៅរ៍ឆ្នាំមមែបញ្ចស័ក ត្រូវនឹងថ្ងៃ ១៤ ស៊ីយេត ឆ្នាំ ១៩៤៤ វេលាយប់ម៉ោង ១១ ឧបាសកហួត-ទិន ក៏អនិច្ចកម្មទៅដោយស្រួល នៅចំពោះមុខកូនប្រុស-ស្រីនិងញាតិមិត្តជិតខាងស័ក្តិអន្ទិយនៅជួបជុំគ្រៀបគ្រា ។ ក្នុងខណៈនោះ គេបានឮសូរ យំសោកស្រណោះអាឡោះអាល័យនៃបុត្របុត្រានិងញាតិមិត្តលាន់ឮកងរំពង គួរឲ្យអាណោចអាធ័មណាស់ចាប់ពីនោះ ពួកយោគីក៏ចាត់ចែងធ្វើកិច្ចសព្វគ្រប់តាមរបៀបប្រពៃណី ។

លុះដល់ថ្ងៃពុធ ១២ កើតខែអាសាឍជាថ្ងៃគំរប់ ៨ ពេលម៉ោង ១០ ព្រឹក ពួកកូនចៅ ទាំងប្រុសទាំងស្រី ព្រមទាំងពួកញាតិមិត្តទាំងចិន ទាំងខ្មែរ

បានមកជួបជុំព្រមមុខគ្នា ពួកគាថាប្រយោគកំភ្លិលសព បុះបាកគេ-ហាស្ពានផ្លែទៅមានក្រុងចិន ក្រុងខ្មែរជាច្រើនដង ប្រគំពូស្បូរផ្គួរឲ្យស្រេង៖ស្រអោបពន់ពេកដកបះទៅដល់វត្តបិលានទី (ត្នងក្រៅ) ហើយនិមន្តព្រះសង្ឃបំសុកូល រូបកិលសេពបញ្ចុះទៅក្នុងវេហ៍យ នៅវត្តនោះឯង ។

* *
*

ទុក្ខទិច្ចាសង្ខារសព្វសត្វ កើតឡើងហើយតែងខ្ចាត់ព្រាត់ព្រាសគ្នាជាធម្មតា ព្រះពុទ្ធដីកាខានសំដែងទុកថា សត្វលោកទាំងអស់ តែងមានជាតិ (កំណើត) ជាខាងដើម មានជរាព្យាធិ (ចាស់, ឈឺ) នៅកណ្ដាល មានមរណៈ (សេចក្ដីស្លាប់) នៅទីបំផុត ហើយជីវិតសត្វលោកតែងជាប់ជំពាក់នៅក្នុងវដ្ដព្រះត្រៃលក្ខណ៍ គឺអនិច្ចំ ទុក្ខំ អនត្តា ជាដរាប មិនអាចគេចវេះចៀសរួចឲ្យផុតទៅបានឡើយ ។

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនាៈ ព្រះគ្រូបញ្ញាសិក្ខិត កៅ-ស៊ុម អ្នកគ្រូគ្រូ
សិស្ស នៅសាលាបាលីជាន់ខ្ពស់

## បញ្ជីរឿង

*ផ្នែកអក្សរសាស្ត្រ* ទំព័រ

ខកញ៉ា ទេពពិទូ-ក្រសេម.... វណ្ណគតិ រឿងទាវយណ៍ ទសាវតារ.... ២២៥

ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម.. រឿងរ៉ាវរបស់លោកធុតង្គជាតិចិន ១ រូបឈ្មោះ
ហ្វូន-ឆាង (តមក)......... ២៣៣

" " " ពង្សាវតារប្រទេសចិន (តមក)..... ២៤៤

ឃុនឧត្តមប្រឹជា ចាប-ពិន.. អធិប្បាយសុភាសិត (តមក).... ២៥២

*ផ្នែកសាសនា*

លោកអាចារ្យ មៀវ-ឧត្ត.... សាសនាវតារ សង្ខេប.......... ២៦៤

ព្រះអាចារ្យ ប៉ាង-ខាត់.... អរិយសច្ចជាពុទ្ធភាសិត (តមក).... ២៧៥

ឆ្នាំទី ១៧ — លេខ ៥ ខែម៉េ ឆ្នាំ ១៩៤៥ — ដំឡៃជាវៈ ១ ឆ្នាំ ១៥ រៀល ។

វណ្ណកតិ

# នារាយណ៍ ទសាវតារ

## គឺនារាយណ៍ បែងភាគ ដប់គ្រា

ឧកញ៉ា ទេពពិទូ ក្រសេម គន្ថបណ្ឌិត នៅពុទ្ធសាសនបណ្ឌិត្យ រៀបរៀង

---

ព្រះជាម្ចាស់ក្នុងលទ្ធិវៃសយ មាន ៣ អង្គ រួមហៅថា ត្រិមិតិ,(១) គឺបានដល់ព្រះព្រហ្មអ្នកសាងលោក ១ ព្រះវិស្ណុ អ្នកថួមបរិហារលោក ១ ព្រះសិវៈ អ្នកចំលាយលាងលោក ១ ។ ពាក្យសម្រាប់ពេញព្រះនាម ព្រះជាម្ចាស់ទាំង ៣ នេះ គេប្រើត្រឹមមួយម៉ាត់គឺ ឱ ប្រកបដោយអក្សរ ៣ តួ បើនឹងញែកចេញគង់បានជារូបគឺ អ.ឧ.ម. ទាំង ៣ ម៉ាត់នេះ ជាពាក្យជំនួសព្រះនាមនៃព្រះទាំង ៣ អង្គ ឬជាត្រៃសរណគមន៍ក្នុងលទ្ធិ វៃសយ ។ លទ្ធិឬសាសនារបស់ព្រះជាម្ចាស់ទាំង ៣ ហៅថា "វៃសយ" ប្រែថា „លទ្ធិដ៏ប្រសើរ" ពប់ថាជាលទ្ធិធំទីងចាស់ជាងគេនៅក្នុងលោកនេះ ពួកជនជាតិព្រាហ្មណ៍ជាអ្នកទទួលកាន់កាប់លទ្ធិនេះ តាំងអំពីដើមមក ។

---

១ ត្រិមិតិក្នុងលទ្ធិវៃសយមិនមែនមានតែព្រះជាម្ចាស់ប៉ុណ្ណោះ សូម្បីព្រះទេវីក៏មានដែរគឺព្រះសរស្វតី (ព្រះកាយសម្បុរស) ព្រះលក្ស្មី (ព្រះកាយសម្បុរក្រហម) ព្រះភគវតី (ព្រះកាយសម្បុរខ្មៅ) ។ ក្នុងគម្ពីរ វរាហបុរាណៈ ពោលថា ដែលព្រះទេវីមានសម្បុរព្រះកាយ ស ក្រហម-ខ្មៅ ដូច្នេះប្រព្រឹត្តទៅតាមវេលាកាល គឺអតីតកាល បច្ចុប្បន្នកាលនិងអនាគតកាល ។ រឿងត្រិមិតិក្នុងលទ្ធិគ្រិស្តក៏មានដែរ គឺបានដល់ព្រះយេហូវ៉ា ១ ព្រះបិតា ១ ព្រះយេស៊ូ ១ ទាំង ៣ នេះរួមជា ១ អង្គជាមួយគ្នា ។

មានសេចក្ដីដំណាលក្នុងនេះថា វណ្ណៈ ៤ គឺព្រាហ្មណ៍កើតចេញអំពីព្រះឧស្ឋព្រះព្រហ្ម, ព្រះរាជាទឹងព្រះរាជទីកើតចេញមកអំពីព្រះហស្តស្តាំ-ខាងនៃព្រះព្រហ្ម, វេស្សៈ កើតចេញអំពីព្រះឩរុព្រះព្រហ្ម, សូទ្រៈ កើតចេញអំពីខ្នងព្រះបាទព្រះព្រហ្ម ។ ដោយហេតុពួកព្រាហ្មណ៍កើតអំពីព្រះឧស្ឋដូច្នេះ ព្រះព្រហ្មទើបទ្រង់ព្រះមេត្តាប្រោសឲ្យជាអ្នកទទួលកាន់កាប់លទ្ធិសៃវយទាំងមូល, ឯពួកក្សត្រទឹង ពួកវេស្សៈ នោះនឹងរៀនសូត្រគម្ពីរព្រះវេទ ឬចូលកាន់លទ្ធិសៃវបាន រីឯតែពួកសូទ្រៈដែលជាមនុស្សជាន់ទាប នឹងស្ត្រីគ្រូចូលសិក្សាគម្ពីរព្រះវេទមិនបាន ។

ព្រះជាម្ចាស់ទាំង ៣ នេះ ទោះបីជាវិនិយមរាប់អានរបស់ពួកជនជាតិហិណ្ឌូទៅ តែចំពោះព្រះព្រហ្មឃើញដូចជាគ្រាន់តែជាអ្នកសាងលោកប៉ុណ្ណោះ មិនបានគិតគត់គាត់ជណ្ដើមអំណាចដូចព្រះពីរអង្គក្រៅនេះ ឯអភិនិហារសេចក្ដីស័ក្ដិសិទ្ធិនៃព្រះវិស្ណុ នឹងព្រះសិវៈនោះសោត ឃើញស្រេចហើយតែពួកអ្នករាប់អាន គឺបើជាសៃវនិកាយ ក៏រាប់អានព្រះសិវៈថាជាធំជាងគេ បើជាវៃស្ណវនិកាយក៏រាប់អានព្រះវិស្ណុថាជាឯកអគ្គជាងគេ ជួនកាលដល់ទៅមានបង្អាប់គ្នាថា ព្រះឥសូរចាញ់ឫទ្ធិព្រះនារាយណ៍ក៏មាន ដូចយ៉ាងគ្រាមួយនោះ ពួកទេពនិករមិនចុះសម្រុងគ្នាថា ព្រះជាម្ចាស់ទាំងពីរនេះ អង្គណាជាធំជាងអង្គណា? គេទើបអញ្ជើញព្រះទាំងពីរអង្គមកប្រឡងឫទ្ធិគ្នា ព្រះឥសូរទ្រង់គេចផុតឫទ្ធិនឹងចាញ់ព្រះនារាយណ៍ ។

ស្រែកសន្ធាប់តែមួយម៉ាត់ គេនាំគ្នាក៏ចង់ក្រពេកត្រូវក់ដូចជាក្រមួនត្រូវថ្ងៃ ពួកទេពតិកទើបសម្រេចសន្និដ្ឋានថា ព្រះនារាយណ៍ទ្រង់ឫទ្ធិជាងព្រះឥសូរ ។ រឿងព្រះនារាយណ៍មានឫទ្ធិជាងព្រះឥសូរ គេលើកគួយ៉ាងឲ្យឃើញមួយទៀត ដូចយ៉ាងគ្រាមួយព្រះឥសូរប្រទានពរឲ្យពួកអសុរមានឫទ្ធិដូចភ្លើង កាលយកដៃចង្អុលអ្នកណា ក៏កើតជាភ្លើងឆេះវិនាសទៀងពួកអសុរចង់លងគ្រមើល លើកដៃទៀងប្រឆាំងនឹងព្រះឥសូរ។ ខាងឫទ្ធិដៃភ្លើងក៏ស្ងួតទៅ; គ្រានោះក្តៅដល់ព្រះនារាយណ៍ ។ ក៏គោរមកជួយកម្រាបពួកអសុរ ។ ជួនកាលជាជនទៅឲ្យព្រះឥសូរគោរពព្រះនារាយណ៍ក៏មាន ។

មុនដែលទឹងសំដែងរឿងក់ព្រះនារាយណ៍ចែងការគមកកម្រាបសឹកសត្រូវក្នុងយុគនោះ។ សមគួរនឹងចំណែកយុគឲ្យបានយល់ចូលចិត្តជាមុនសិន ។ ការចំណែកយុគនេះ មានរបៀបគ្នាជា ២ យ៉ាង គឺចំណែកតាមប្រវត្តិសាស្រ្ត និងចំណែកតាមសេចក្តីជឿពប់អានរបស់ព្រាហ្មណ៍ ។

តាមប្រវត្តិសាស្រ្តនោះលោកចំណែកទុកជា ៤ យ៉ាង គឺ:

១– យុគព្រះវេទ ឬត្រៃវេទ មានព្រះគម្ពីរ ៣ ភាគ គឺ:

ក– ឫគវេទ (Rigaveda) ជាគម្ពីរតែងជាលំនាំពាក្យធម៌ សម្រាប់សូត្រស្តុតិសរសើរព្រះជាម្ចាស់ ។

ខ– សាមវេទ (Sàmaveda) ជាគម្ពីររបៀបមន្តភ្លេងសម្រាប់ស្តុតិទេវតាក្នុងវេលាធ្វើពិធីបូជាយញ្ញ ។

គ- យជុវេទ (Yajurveda) ជាគម្ពីរពណ៌នាសរសើរទេវតាដែលគេប្រមូលឡើងខាងក្រោយ ។

តមកកើតគម្ពីរវេទ ១ ទៀត ហៅថា អថវ៌វេទ (Atharvaveda) ជាគម្ពីរបញ្ចុះពេញដោយគាថាមន្តអាគមស្នេហ៍ សម្រាប់ធ្វើឲ្យមូលមកម្ដឲ្យព្រាស់ទៅ ។

២- យុគគម្ពីរព្រាហ្មណ៍ ក្នុងយុគនេះសេចក្ដីជឿកាន់យកក្នុងការធ្វើពិធីជារបស់សំខាន់ក្រៃលែង, ពពួកជនទើបនាំគ្នាកប់អានព្រាហ្មណ៍ថាជាអ្នកថ្លៃថ្នាជាងវណ្ណក្សត្រ ព្រោះព្រាហ្មណ៍ជាម្ចាស់យញ្ញកម្មទាំងពួង, ពួកអរិយកៈបាននាំគ្នាចុះមកនៅក្នុងភូមិភាគប៉ែកខាងត្បូង បានប៉ះនឹងពួកទស្យុ ក៏កើតជាសង្គ្រាមឡើង ឬសីវាឲ្យមិគិបានទិពទួមហាកាព្យ គឺរាមាយណៈដ៏ជាដើមរឿងពម៉ាកេរ្តិ៍ ។

៣- យុគឧបនិស័ទៈ ក្នុងយុគនេះ ព្រាហ្មណ៍គេកាន់ថាព្រះព្រហ្មជាព្រះម្ចាស់តែ ១ អង្គ (ប្រហែលទំនងសេចក្ដីគិតឃើញរបស់ពួកឧរុបក្នុងមធ្យមសម័យ ដែលបានទំលាយសេចក្ដីជឿផ្សេងៗចេញ ឲ្យគង់នៅតែរូបព្រះយេស៊ូ ១ ប៉ុណ្ណោះ) ទាំងកាន់ថាជាអាត្មន (atman) របស់លោក ជាអរូបកទេព ទើបបានកើតមានអ្នកទទឹងទាស់សាសនាព្រាហ្មណ៍ឡើង ដូចយ៉ាងពួកសំខ្យៈជឿថា មនុស្សកើតមកតោងទទួលទល់ទុក្ខវេទនាគ្មានទីបំផុត

ទើបគិតកែខៃរកផ្លូវឲ្យរួចចាកសង្សារវដ្ដ បាននាំនូវជាសាស្ដ្រប្រដៅលទ្ធិ, ធម៌តាមគាប់ចិត្តខ្លួន ដូចសុប្បិយបរិញ្វាជក និងមក្ខលិគោសាលជាដើម ។

៤- យុគពុទ្ធកាល ដ៏ជាផលរបស់ការប្រតិបត្តិលទ្ធិព្រាហ្មណ៍ ។

យុគ ១ យ៉ាងទៀតចែកជា ៤ គឺ

| | | | | |
|---|---|---|---|---|
| ក្ឫតយុគ | = ៤៨០០ | ឆ្នាំសួគ៌ | = ១,៧២៨,០០០ | ឆ្នាំមនុស្ស |
| ត្រេតាយុគ | = ៣៦០០ | " | = ១,២៩៦,០០០ | " |
| ទ្វាបរយុគ | = ២៤០០ | " | = ៨៦៤,០០០ | " |
| កលិយុគ | = ១២០០ | " | = ៤៣២,០០០ | " ។ |

មួយឆ្នាំមនុស្សស្មើនឹងមួយថ្ងៃសួគ៌ ហើយក្នុង ១ ឆ្នាំមាន ៣៦៥ ថ្ងៃដូចគ្នា ។ ទាំង ៤ យុគនេះរួមជា ១ មហាយុគគឺ ១២,០០០ ឆ្នាំសួគ៌ ឬគិតជា ៤,៣២០,០០០ ឆ្នាំមនុស្ស, មួយពាន់មហាយុគជា ១ ថ្ងៃរបស់ព្រះព្រហ្មសិងហៅថាកល្ប[1] យប់នឹងថ្ងៃរបស់ព្រះព្រហ្មវែងស្មើគ្នា ។

ក្នុងយុគទាំង៤នេះមានហេតុកើតផ្សេងៗគ្នាដូចមានប្រាកដក្នុងគម្ពីរមហាភារតៈ ។

---

១ តាមសេចក្ដីនិយមជឿរបស់ពួកព្រាហ្មណ៍ថា មានវេលាស្មើនឹង ១២,០០០,០០០ ឆ្នាំសួគ៌ កល្បនេះចែកចេញជា ១.០០០ ភាគ ក្នុង ១ ភាគហៅថា មហាយុគគឺ ១២,០០០ ឆ្នាំសួគ៌ តាមក្នុងត្រៃភូមិកា ត្រង់ដែលនិយាយដោយនរកភូមិ ក្នុងមួយកល្បនោះប្រមាណថាមានភ្នំ ១ កំពស់ ១ យោជន៍ទំហំ ៣ យោជន៍ ក្នុងវេលាប្រមាណ ១០០ ឆ្នាំ មានទេវតាយកសំពត់ដ៏ទន់មកបោសភ្នំនោះម្ដង កាលភ្នំនោះរាបស្មើនឹងផែនដីក៏សំគាល់ថា ១ កល្ប ។

ក្ឫតយុគ ជាយុគដែលមានសត្យធម៌ខ្ពង់ខ្ពស់បំផុត មានព្រះព្រហ្ម ជាទីគោរពកប់អានរបស់នរជនតែ ១ អង្គ, មនុស្សទាំងពួងប្រាសចាក អគតិនូវកិលេសទាំងពួង សុទ្ធតែតាំងនៅក្នុងសត្យធម៌ស្មើគ្នាទាំងអស់ ព្រះព្រហ្មជាទីពឹងនៃយោគីទាំងឡាយ, ព្រះនាកយណ៍ដ៏ជាវិញ្ញាណនៃ សត្វទាំងពួង មានព្រះកាយសបរិសុទ្ធ មានព្រះវេទតែត្រឹម ១ គឺឫគវេទ ។

ត្រេតាយុគ សត្យធម៌ថយទៅ ១ ភាគក្នុង ៤ ភាគព្រះកាយរបស់ ព្រះនាកយណ៍ក្លាយជាសម្បុរក្រហម ពួកមនុស្សនៅគង់នៅក្នុងសេចក្តី សុចរិត តែកើតចិត្តប៉ុនប៉ងយកផលានិសង្ស ទីងការបំពេញតាន ដើម្បីសុំតព្រះជាម្ចាស់ ឲ្យខ្លួនបានរបស់វិសេសដែលមិនធ្លាប់មាន ក្នុងលោក ។

ទ្វាបរយុគ សត្យធម៌ថយទៅពាក់កណ្តាល ព្រះវរកាយរបស់ព្រះ នាកយណ៍ក្លាយជាសម្បុរលឿង ព្រះវេទកើតមានដល់ទៅ ៤ (គឺ ឫគ វេទ, សាមវេទ, យជុវេទ និងអថវ៌វេទ) មនុស្សសិក្សាព្រះវេទក្លាយទៅ ផ្សេងៗ មិនស្មើគ្នា ពិធីផ្សេងៗ ក៏មានច្រើនឡើង មនុស្សអ្នកតាំងនៅ ក្នុងសុចរិតធម៌មានតិច តណ្ហាចូលគ្របសង្កត់ដួងចិត្ត ធ្វើអ្នកប្រព្រឹត្តទៅ ក្នុងផ្លូវបៀតបៀនគ្នា ។

កលិយុគ សត្យធម៌គង់នៅតែ ១ ភាគ ក្នុង ៤ ភាគ ព្រះកាយរបស់ ព្រះនាកយណ៍ក្លាយជាសម្បុរខ្មៅ ៖ ប្រតិបត្តិទាំងពួងក៏មាននៅក្នុងគម្ពីរ

ព្រះវេទថយទៅ កុសលកម្មនិងបុញ្ញកម្មថយទៅ ពួកមនុស្សត្រាស់ទៅដោយកំលេស[1] ។

ក្នុងយុគទាំង ៤ នេះ ព្រះវិស្ណុនៅព្រះធំក្រៃលែង ជាទីគោរពគប់អានរបស់ជនទាំងឡាយ ដែលដូច្នេះ ព្រោះពួកវៃស្ណវៈ (គឺពួកអ្នកគប់អានព្រះវិស្ណុ អ្នកកាន់គម្ពីរនេះ) ប្រដៅថា ដើមឡើយមានព្រះជាម្ចាស់តែ ១ ព្រះអង្គ គឺព្រះបរព្រហ្ម, តែគម្ពីរវរាហបុរាណៈថា ព្រះនារាយណ៍គឺព្រះបរព្រហ្មជាអរូបកទេព ទ្រង់រំពឹងដល់កាលដែលសាងលោកហើយ ក៏ត្រូវតែទំនុកបម្រុងរក្សាតទៅ ទើបបែងភាគជារូបកទេព ជាទេវរាជ ដែលមានកំណើតមិនដូចទេវតានិងមនុស្សទាំងឡាយ ហើយប្រទានពរដល់ព្រះនារាយណ៍អង្គថ្មីនេះ ឲ្យជាអ្នកសាងសព្វគ្រប់ទាំងពួង និងជាអ្នកបរិហារត្រៃលោកឲ្យមានអំណាចជាធំលើសលែងអ្នកទាំងពួង ។

តែមកក្នុងបទ្មបុរាណៈពោលថា កាលសាងសកលលោក ព្រះវិស្ណុបំណងនឹងសាងសព្វគ្រប់ទាំងពួង ទើបបែងភាគជា ៣ គឺព្រះអ្នកសាង (ព្រហ្ម), ព្រះអ្នកបរិហារ (វិស្ណុ) និងព្រះអ្នកទំលាយ (សិវៈ) ហេតុនោះព្រះទាំង ៣ នេះទើបមិនផ្សេងគ្នា (ដូចគ្នានឹងត្រីរត្នរបស់ពួក

---

១ វេលានេះនៅក្នុងកលិយុគ អ្នកកាន់សៃវសាស្ត្រផ្ដើមរាប់អានកលិយុគ តាំងពី ១៨ កុម្ភាព័ន្ធ មុនពុទ្ធសករាជ ២៥៥៩ ដល់ ព. ស. ២៤៨៥ នៅគង់សល់ទៀត ៤២៦,៩៥៦ ឆ្នាំ ក៏នឹងផុតកលិយុគ លោកថានឹងកើតមហាភ័យដល់លោកធាតុ គឺនឹងមានភ្លើងម្រល័យកល្បឆេះលោកអស់ម្ដង ។

រូបដូចពោលហើយ ) គឺក្នុងការនេះព្រះអង្គបានសាងព្រះព្រហ្មអំពីឆ្អឹងជំនីខាងស្តាំ ព្រះវិស្ណុអំពីឆ្អឹងជំនីខាងឆ្វេង និងព្រះសិវមហាកាលអំពីព្រះឧរ, ប្រហែលជាដោយហេតុនេះ ព្រាហ្មណ៍ខាងវៃស្ណវៈទើបអាងគម្ពីរបុរាណៈថា ព្រះអង្គគឺត្រិមិតិ ដូចពោលហើយ ។

ក្នុងគម្ពីរវិស្ណុបុរាណៈថា ព្រះវិស្ណុជាអ្នកឲ្យកំណើតលោកព្រះអង្គជាហេតុនៃសេចក្តីកើត និងសេចក្តីសាបសូន្យនៃលោក ហេតុនោះព្រះអង្គគឺលោក ។

— ក្នុងសម័យព្រះវេទនោះ ព្រះឥន្ទ្រជាព្រះរាជានៃព្រះជាម្ចាស់ទាំងពួង តមកក្នុងយុគគម្ពីរព្រាហ្មណៈ មានព្រះជាម្ចាស់ដែលមានអំណាចខ្ពស់ជាងព្រះឥន្ទ្រ ក៏គឺព្រះអវតារនៃបឋមហេតុ (អនន្ត), ជនជាតិហិណ្ឌូប្រមាណ ១ ភាគ បែរមករាប់អានព្រះវិស្ណុ ដូចអវតារចុះចាកសួគ៌មកជាវិញ្ញាណនៃភូមិកត តែក៏គង់នៅមានពួកខ្លះរាប់អានព្រះសិវៈតមករហូតដល់សម័យពុទ្ធកាល ក៏នៅរាប់អានព្រះជាម្ចាស់ទាំង ២ នេះ ក្នុងទស្សនាវដ្តីវិទ្យាចារ្យថៃថា ពួកក្រិកនៅក្នុងឥណ្ឌា ប្រមាណក្នុង ព.ស. ២៣១-២៤០ ។

(មានត)

# រឿងរ៉ាវរបស់លោកធុតង្គជាតិចិន ១រូប

## ឈ្មោះហ្វួន-ឆាង

## ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម

[ស្រង់និងប្រែចេញអំពីសៀវភៅ Religieux et Pèlerins en terre d'Asie

របស់លោក Goloubew សមាជិក សាលាបារាំងសែសចុងបូព៌ាប្រទេស

(តមក)

ទីក្រុងបាមយ៉ាននោះ ឥឡូវនេះជារបស់អាហ្វខាន នៅលើផ្លូវធំដែលភ្ជាប់ស្រុកប៉ាក់ទ្រីយ៉ានទៅប្រទេសឥណ្ឌា ។ លោកអ្នកដំណើរដ៏មានសទ្ធាជ្រះថ្លា ក៏ធ្វើដំណើរទៅតាមផ្លូវនោះ លុះដល់ទៅស្រុកកបិសៈ (Kapiça) លោកហ្វួន-ឆាង ក៏បានឈប់សំចតជាយូរ ។ ទីក្រុងនោះមិនមានអ្វីសេសសល់ដល់មកឥឡូវនេះទេ វៀរលែងតែតួបាក់បែកកំទេចកំទីប៉ុណ្ណោះ ។ ប៉ុន្តែខាងដើមសម័យកណ្តាល មុនពួកមោហាម៉ែតចូលលុកលុយយកស្រុកនោះបាន ទីក្រុងនោះជាទីប្រជុំខាងសាសនាយ៉ាងសំខាន់ មានកេរ្តិ៍ដំណែលពុទ្ធសាសនាគុះករជាច្រើន ។ នៅទីនោះលោកហ្វួន-ឆាង បានឃើញបានមើលរបស់ (ថ្លៃៗ) ជាច្រើន បានសាកសួរមនុស្សទាំងឡាយជាច្រើន ។ ហើយលោកក៏ជឿថាខ្លួនលោកដល់ប្រទេសឥណ្ឌាហើយ ។ លោកបានសម្រេចអំពីបំណងនៃការធ្វើដំណើររបស់លោក ហើយមិនបាច់នឹកស្តាយបន្តិច អំពីការដែលមិនបាន

ជឿស្តាប់បង្គាប់ព្រះរាជបញ្ញត្តិ របស់ព្រះរាជាធិរាជព្រះនាមតៃ-ធុង (ដែលបានហាមឃាត់មិនឲ្យលោកចេញមក) ហើយនឹងការដែលលោកបានចេញពីស្រុកចិនមក ដោយការធ្វើដំណើរយ៉ាងលំបាកវេទនាជាទីបំផុតនោះផង ។

— ៣ —

មុនចុះទៅតាមច្រកភ្នំខៃបេរ ចូលទៅក្នុងទំនាបទន្លេឥណ្ឌុស លោកហួន-ចាង បានចូលមើលភូមិប្រទេស ៤ ដ៏ល្បីល្បាញ ដែលមានពួកអ្នកជុតគ្គពុទ្ធសាសនាតែងចូលមើលរាល់គ្នា ព្រោះនៅទីនោះមានរឿងរ៉ាវជាប់ទាក់ទងនឹងរឿងរ៉ាវ របស់ព្រះមនុស្សពុទ្ធជាន់ក្រោយបំផុត ។ មានរអាងភ្នំ ១ ដែលព្រះដ៏មានព្រះភាគស្តេចគង់នៅ ក្រោយដែលបានផ្ចាញ់ស្តេចនាគកំណាចឲ្យចុះចាញ់ព្រះអង្គ ហើយព្រះអង្គទុកព្រះឆាយា (ព្រះស្រមោល) របស់ព្រះអង្គជិតជាប់នៅទីនោះ ។ លោកហួន-ចាង បានចូលទៅក្នុងទីនោះតែមួយអង្គឯង ក្រោយដែលលោកបានប្រាប់ពួកអ្នកដំណើររួមផ្លូវជាមួយនឹងលោក ឲ្យរង់ចាំលោកនៅខាងក្រៅ ។ ឯខាងក្នុងរអាងភ្នំនោះងងឹតឈឹង ហើយមុនដំបូង លោកមើលអ្វីមិនឃើញសោះ ។ លោកមានចិត្តប្រកបដោយសទ្ធាជ្រះថ្លាមុតមាំណាស់ ទើបលោកនមស្សការរាប់រយដង បែរមុខទៅទិសខាងកើត តាំងស្វាធ្យាយព្រះសូត្រទាំងឡាយ ។ វេលានោះ លោកសង្កេតទៅ

ឃើញនៅទីជញ្ជាំងរអាងក្នុងនោះ មានពន្លឺយ៉ាងចំឡែកអស្ចារ្យ ១ ហើយស្រាប់តែរលត់ទៅវិញភ្លាម ។ លោកក៏តាំងក្រាបថ្វាយបង្គំទៀត ហើយពន្លឺក៏តាំងកើតប្រាកដឡើងទៀត ។ កន្លងមួយរំពេចនុះឯង រអាងក្នុងនោះក៏កើតមានពន្លឺស្រស់ព្រាលទ្រាលឡើង ហើយព្រះឆាយារបស់ព្រះពុទ្ធសាក្យមុនី ក៏ប្រាកដឡើងនៅចំពោះមុខភិក្ខុដែលកំពុងតែមានបីតិត្រេកអរជាខ្លាំង ៗ បើនឹងនិយាយឲ្យពិតទៅនោះ មិនមែនជាព្រះឆាយារបស់ព្រះអង្គទេ គឺជាពន្លឺស្រស់អ្វីមួយកើតប្រាកដឡើង... ។ ព្រះកាយរបស់ព្រះដ៏មានព្រះភាគ ទិនស្បង់ចីពររបស់ព្រះអង្គនោះមានពណ៌ក្រហមទុំ ទ្រង់ត្រាយព្រះកក្ររបស់ព្រះអង្គ ទ្រង់មានអំណាចហើយទ្រង់ញញឹមផង មើលទៅឃើញជាក់ច្បាស់សព្វគ្រប់ព្រមទាំងព្រះលក្ខណៈដែលមាននៅសព្វព្រះកាយរបស់ព្រះអង្គ មានតែផ្កាឈូក ១ ទេដែលជាបល្ល័ង្កនោះ ហាក់ដូចជាងងឹត ។ លោកហួន-ធាងក៏ក្រាបថ្វាយបង្គំដោយសេចក្ដីគោរព ហើយសូត្រសរសើរព្រះពុទ្ធគុណព្រមទាំងបាចបូជាផ្កាភ្ញីនឹងគ្រឿងក្រអូបទាំងឡាយផង ។ ឯពន្លឺស្រស់ដ៏អស្ចារ្យនោះ ក៏រលត់បាត់ទៅវិញបន្តិចម្ដងៗ ។ ទើបលោកភិក្ខុហួន-ធាងក្រាបថ្វាយបង្គំលាត្រឡប់ចេញមកវិញ ។ ឯព្រាហ្មណ៍ដែលធ្វើជាមគ្គុទ្ទេសក៍ ហើយដែលរង់ចាំលោកនៅមាត់ទ្វាររអាងក្នុងនោះ ក៏បាននិយាយប្រាប់លោកថា "លោកគ្រូ, ប្រសិនបើលោកគ្មានសទ្ធាសុចរិត

ស្មោះត្រង់ព្រមទាំងពោលពាក្យបួងសួងយ៉ាងខ្លាំងក្លាទេ មុខជាលោកត្រូវមិនបានឃើញនិមិត្តចំឡែកអស្ចារ្យដូច្នេះទេ" ។

— ៨ —

យើងមិនបាច់ពោលពណ៌នា អំពីដំណើរដើរផ្លូវដ៏វែងលន្លង់ខ្លោចឆ្លងកាត់ប្រទេសឥណ្ឌា របស់លោកពុទ្ធគ្គហួន-ឆាង ដោយសព្វគ្រប់ទេ ។ អ្នកឯណាមួយដែលមានគំនិតចង់គិតសើរើរឿងនេះឡើង រហូតដល់ទៅសេចក្ដីល្អិតល្អោចបន្តិចបន្តួច អំពីការធ្វើដំណើររបស់អ្នកពុទ្ធគ្គដែលល្បីឈ្មោះនោះ ត្រូវអ្នកនោះមើលរឿងរ៉ាវដែលលោក រ៉ុនគ្រូសេត៍ ជាអ្នកប្រាជ្ញពង្សាវតារដ៏ល្បីល្បាញ ប៉ែកខាងឥណ្ឌានិងចុងបូព៌ាប្រទេស បានតែងទុកក្នុងសៀវភៅរបស់លោកហៅថា Sur les traces du Bouddha (អំពីកេរ្ដិ៍ដំណែលរបស់ព្រះពុទ្ធ) នោះចុះ ។

លោកហួន-ឆាង មិនបានគង់នៅក្នុងប្រទេសឥណ្ឌាតិចជាង ១១ ឆ្នាំឡើយ (៦៣០ – ៦៤១) ។ ក្រោយដែលលោកបានសំចតនៅជិតពីរឆ្នាំក្នុងប្រទេសកស្មីរ និងប្រទេសសិន្ធុនោះហើយ លោកក៏ធ្វើដំណើរចូលទៅប្រទេសឥណ្ឌាខាងជើងនោះពីមួយទៅមួយ គ្មានភ្លេចគ្មានខ្វះចន្លោះកន្លែងណាមួយឡើយ គឺគ្រប់ៗតំបន់ដែលព្រះពុទ្ធសាក្យមុនីទ្រង់ធ្លាប់គង់នៅ និងធ្លាប់ទ្រង់សំដែងព្រះធម៌ទេសនា ។ លោកបានកត់ត្រាទុកដោយសព្វគ្រប់ អស់ទាំងទំនៀមទម្លាប់និងរឿងព្រេង ដែល

មានដំណាលទៅក្នុងស្រុក ។ ពួកអ្នកស្រុកដែលលោកបានសាកសួរ ក៏នាំគ្នានាំលោកទៅរកមើលវិហារទាំងឡាយ ដែលគេបោះបង់ចោលមក ជាច្រើនសតវត្សរ៍ ហើយគេបង្ហាញប្រាប់ព្រះស្តូបដែលចាស់គ្រាំគ្រា ខូចខាតអស់ទៅដល់ពាក់កណ្ដាលហើយ ហើយលោកក៏ធ្វើប្រទក្សិណ ព្រះស្តូបនោះដោយស្ងប់ស្ងាត់ ។ ជួនកាលលោកទៅគង់នៅមាត់ឆ្នេរ ស្រះស្រង់ ដែលមានទឹកនឹងថ្កល់ឥតកម្រើក សឹងមានផ្កាឧប្បលច្រើន ដេរដាសពាសពេញ នាំឲ្យនឹកដល់ស្តេចនាគរាជ្ជ៖ ដែលមានសទ្ធា ជ្រះថ្លា (ទីងសាសនា) ។ នៅសារណាថជិតក្រុងពេនារេស នោះ លោកបានឃើញសួនម្រឹគទាយវ័ន ដែលព្រះពុទ្ធជាម្ចាស់បានត្រាស់ ព្រះបឋមទេសនា ។ នៅនគរកុសិនារា គេបានចង្អុលបង្ហាញព្រៃ របោះមួយមានម្លប់ត្រជាក់ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់ចូលបរិនិព្វាន ហើយនៅជិតទីនោះ គេធ្វើពិធីបូជាព្រះសព ព្រះសរីរកាយរបស់ព្រះអង្គ ក្នុងមឈូសដែលស្រោចស្រប់ ដោយគ្រឿងក្រអូបនានា ។ ក្នុងទីបំផុត នៅពុទ្ធគយាលោកបានធ្វើសក្ការបូជា ដើមពោធិព្រឹក្សដែលព្រះអង្គបាន ត្រាស់នោះ ដោយយកម្រងផ្កានិងគ្រឿងក្រអូប ហើយលោកឱនក្រាប ថ្វាយបង្គំនៅខាងមុខព្រះរតនបល្ល័ង្ករបស់ព្រះអង្គ ។ លោកមានសេចក្ដី រន្ធត់ស្លុតចិត្តជាខ្លាំង ទប់ទឹកភ្នែកមិនឲ្យហូរចេញមកនោះពុំបានឡើយ ។ តាមទំនងនេះ លោកជាភិក្ខុភូមាមិនអាចនឹករលឹកឃើញ ដល់ជាតិខ្លួន

ដែលកន្លងទៅហើយនោះបានឡើយ ។ ប៉ុន្តែលោកអាចដឹងតាមទម្ងន់កំហុសនឹងអំពើបាបដែលខ្លួនធ្វើហើយក្នុងសង្សារវដ្តនេះ ចុះលោកបានសម្រេចមគ្គផល ដល់ថ្នាក់ឈានសមាបត្តិណាមួយដែរឬទេ? លោកឥតគិតនឹកនាអំពីសេចក្តីនឿយហត់សោះឡើយ ទាំងសេចក្តីលំបាកគោកយ៉ាកនានា ដែលលោកទំអត់ធន់ទ្រាំទ្រមកក្នុងការធ្វើដំណើរយ៉ាងឆ្ងាយបំផុត នោះក៏ឥតមានគ្រោះថ្នាក់អ្វីក្នុងរវាងផ្លូវ តែមានជាច្រើនដង ដែលលោកបានចៀសវាងរួចផុតពីគ្រោះថ្នាក់ទៅ បានដោយមានហេតុដ៏អស្ចារ្យ ៗ នៅវេលាដែលលោកកំពុងពិនិត្យពិចារណាមើលដើមព្រៃដ៏មានផ្ការយ៉ាងយ៉ាងៗមាំនឹងទន់ភ្លន់ មានដើមសម្បុរដូចជាខៀន មានសន្លឹកពណ៌បៃតងនឹងក្តីផ្ដុំជានិច្ចនោះ លោកគ្រប់មានគំនិតគិតឃើញហាក់ដូចជាជាក់ស្តែងណាស់ នៅឱកាសដែលកងទ័ពមារធ្វើអំពើផ្តាល-ផ្តាញព្រះពោធិសត្វ នៅវេលាដែលព្រះអង្គតាំងព្រះទ័យស្ងឹងស្ងាធយ៉ាងវិសេស ហើយទ្រង់បានទំទ្រាំទ្រតទល់នឹងកងទ័ពរបស់មារាធិរាជ... ៗ ចូរយើងមើលក្នុងសេចក្តីរាយការរបស់លោកថាដូច្នេះ កាលនោះ ក្រុងមារាធិរាជបានដំណឹងថា ព្រះពោធិសត្វនឹងបានសម្រេចនូវប្រាជ្ញាញាណដ៏បវរបូណ៌ ក៏ទំរេកខ្ញាយប៉ុនប៉ងបំផ្លាញ ហើយធ្វើឲ្យព្រះទ័យព្រះអង្គរំភើបរញ្ជួយ ៗ វេលានោះ មារមានសេចក្តីសោយសោកខ្លាចក្រែងហើយស្ទើររេកខ្ញាយគិតគ្រប់យ៉ាង ទើបក្រុងមាររកណ្ហាពលបិសាចរៀប

បំផ្លាញកងទ័ពមារ កាន់សព្វគ្រឿងអាវុធលើកជាកងទ័ពចេញទៅ ដើម្បីបំភិតបំភ័យព្រះបរមពោធិសត្វ ។ នៅក្នុងវេលាគ្រានោះ មានខ្យល់ព្យុះយ៉ាងខ្លាំងបក់មក ហើយមានភ្លៀងធ្លាក់ចុះមកគគ្រុកគគ្រេក ផ្គរលាន់កឹកកងជាខ្លាំងលើផ្ទៃអាកាស ទាំងរន្ទះក៏ជាលប្រាក់ទៅសព្វទិសាក្នុងទីកាល័យដ៏ងងឹត ។ ខណៈនោះ មានបាញ់ភ្លើងបាញ់ផ្សែង ភ្លៀងខ្សាច់ទឹកគ្រាប់ព្រិលជាដុំថ្ម បាចសាចស្រោចស្រប់ចុះមកជំនួសលំពែងទីងវែលហើយទឹងធ្នូ-សរ-ស្នា ។ នៅវេលាកំពុងប្រយុទ្ធនោះ ព្រះពោធិសត្វមានព្រះទ័យយាងចុះស៊ប់សួនក្នុងព្រះមហាករុណា ។ អស់ទាំងគ្រឿងអាវុធរបស់ពួកខ្មាំងសត្រូវ ក៏ប្រែក្លាយទៅជាផ្កាឈូក ។ កងទ័ពមារក៏មានសេចក្តីភិតភ័យតក្កមា ហើយនាំគ្នារត់ទៅយ៉ាងប្រញាប់ប្រញាល់បាត់អស់ទៅក្នុង ៗ រំពេចនុះឯង ។

— ៩ —

លោកហ្វូន-ឆាង បានសំណាក់នៅក្នុងតំបន់ពុទ្ធគយា ជាវេលា ១ សប្តាហ៍ជាងបន្តិច ។ រួចលោកចេញទៅនៅស្រុកនាលន្ទា ដែលជាទីក្រុងសិក្សាយ៉ាងល្បីល្បាញក្នុងដែនបេង្គាល់ នៅទីនោះមានពួកគ្រូវិសេស ៗ បង្ហាត់បង្រៀនលទ្ធិមហាយាន ដែលពួកលោកសង្ឃក្មេង ៗ និងពួកឧបាសក-ឧបាសិកា ដែលអាស្រ័យសិក្សារៀនសូត្រនៅទីនោះ មានចំនួនរាប់ពាន់ ៗ រូបរាល់ ៗ ឆ្នាំ ។ នៅវេលាក្រោយភ្លៀងក្នុង

ផ្លូវក្តៅ ជាផ្លូវកំផងក្រៀងនោះ លោកក៏ឈប់បង្អង់ការសិក្សាជាមួយនឹងពួកភិក្ខុនាលន្ទាទាំងនោះ ដើម្បីចេញដំណើរទៅកាន់ក្រុងរាជគ្រឹះ ដែលជាទីក្រុងចាស់នៃរាជអាណាចក្រមគធៈ ។

នៅពេលដែលលោកទៅដល់នោះ ទីក្រុងនោះក្លាយជាទីក្រុងស្ងាត់នៅកណ្ដាលព្រៃធំ ជាទីអាស្រ័យនៅនៃសត្វខ្លាឃ្មុំដំរីព្រៃទាំងឡាយ ។ លោកហ៊ួន ឆាង ក៏ដើរជុំវិញទីបរិវេណដ៏ធំទូលាយនោះ រួចលោកដើរទៅតាមស្នាមកំពែងដែលបាក់បែកខ្ទេចខ្ទីទាំងនោះ ។ ចំណែកឯទីក្រុងក៏មានទំនងដូចគ្នាដែរ គឺរៀវពេយតូចទៅជាភូមិមួយយ៉ាងតូច នៅកណ្ដាលស្មៅខ្ពស់ៗ មានផ្លូវដើរមួយតូច សម្រាប់ដើរចូលទៅកាន់ទីនោះៗ លោកពុទ្ធជាតិចិនបានពោលបញ្ជាក់ថា "គ្រប់ទិសទាំងអស់នៅទីនោះគេមើលទៅឃើញតែព្រៃឈើកនកៈ ដែលមានតែផ្ការីកស្គុះស្គាយរាល់ដើមឆ្នាំ ហើយមានស្រទាប់ផ្កាក្រហមព្រាលដូចសម្បុរមាស" ។

នៅក្នុងសម័យដែលក្រុងរាជគ្រឹះ ជាទីប្រជុំកុះករនៃពុទ្ធសាសនិកជនដ៏មានសទ្ធាជ្រះថ្លានៅឡើយនោះ មានរឿងទំនៀមពីបុរាណមួយដំណាលទុកមក ដែលលោកហ៊ួន ឆាង បានពោលសារស័ព្ទក្នុងសេចក្ដីកយការរបស់លោកថាៈ "នៅទិសខាងលិចទីក្រុងមានភ្នំវិបុល ។ តាមរឿងរ៉ាវដែលអ្នកស្រុកដំណាល អំពីរឿងភ្នំនោះដូច្នេះៈ នៅទិសខាងជើងប្រែបជើងភ្នំ ត្រង់ទិសនិរតីនៃភ្នំនោះ ពីដើមមកធ្លាប់មានជ្រោះទឹក

ក្តៅចំនួន ៥០០, ដល់មកឥឡូវនេះ នៅសល់តែត្រឹម ៤-១០ ប៉ុណ្ណោះ ប៉ុន្តែជ្រោះខ្លះត្រជាក់អស់ហើយ ជ្រោះខ្លះនៅក្តៅឧណ្ហៗ មិនមានជ្រោះណាមួយនៅក្តៅស្ពុះពោះឡើយ ។ ជ្រោះទាំងនោះហូរចេញមកអំពីស្រះអនោតត្តៈ នៅខាងជើងមហាបពិតហិមាលយា ហើយហូរចូលទៅតាមក្រោមដីហូតដល់កន្លែងនេះ ។ ទឹកជ្រោះទាំងនោះថ្លាហើយស្អាត មានរសជាតិដូចទឹកស្រះជាដើមចម្ទុះឯង ។ ក្នុងខ្សែទឹកនោះដេរដាសដោយគាបទរក មានចំនួន ៥០០ រណ្តៅ ។ អំណាចភ្លើងនៅពីក្រោមដី មានអំណាចភ្លើងឆាបឆួលទឹកទាំងនោះឲ្យក្តៅឡើង ។ នៅគ្រប់ៗរន្ធប្រហោង ដែលមានទឹកជ្រោះហូរចេញមកទាំងប៉ុន្មាននោះ គេបានយកថ្មចម្លាក់ដាក់ខ្ទប់មាត់ទឹក ។ ចួនកាលគេធ្វើជារូបក្បាលសិង្ហ ឬក្បាលដំរី ចួនកាលគេយកថ្មមកធ្វើជាទបង្ហូរទឹកសម្រាប់ឲ្យទឹកហូរចេញទៅតាមទថ្មនោះក៏មាន ។ នៅពីខាងក្រោមទទឹកទាំងនោះ គេបានសាងជាអាងថ្មឡើង ។ មានមនុស្សចេញមកពីគ្រប់ៗប្រទេស ដើម្បីទៅចុះងូតទឹកក្នុងអាងថ្មនោះ ។ មានមនុស្សជាចំនួនច្រើនដែលមានជម្ងឺរ៉ៃ ក្រោយដែលបានងូតទឹកនោះរួចហើយ ត្រឡប់បានសះជាពល់គ្នា" ។

☼

☼ ☼

លោកហួន-ឆាង កាលបានត្រឡប់មកស្រុកនាលន្ទាវិញ លោកក៏សំណាក់នៅទីនោះអស់វេលាយូរ ដើម្បីសិក្សារបៀបវេយ្យាករណ៍ និង

របៀបភាសាសំស្ក្រឹត ហើយលោកបានចេះដឹងបរិបូណ៌ ក្នុងក្បួនគម្ពីរ ដីកាដែលគេបានរៀបរៀងជាភាសានេះ ។ ដោយមានពួកព្រាហ្មណ៍ ដែលល្បីឈ្មោះខាងវិជ្ជាសាស្ត្រ ទីងមានសំដីថ្វីមាត់ពូកែជាអ្នកបង្ហាត់ បង្រៀន ទើបលោកមានចំណេះចេះដឹងស្ទាត់ ក្នុងបរមត្ថវិជ្ជារបស់ ឥណ្ឌា ។

កាលលោកពុទ្ធគុត្ត ដើរចេញពីស្រុកនាលន្ទាទៅនោះ លោកបាន ចូលទៅមើលទីក្រុងនឹងកំពង់មាត់សមុទ្រតាំងឡូយ ដែលនៅមាត់ពាម ទន្លេគង្គា ។ លោកមានបំណងចង់ឆ្លងទៅឡើងកោះស៊ីឡង់ ។ ប៉ុន្តែពួក លោកសង្ឃដែលមានសេចក្ដីនឿយហត់ ក្នុងការធ្វើដំណើរទៅជាមួយ នឹងលោក បាននិយាយពន្យល់លោកឲ្យធ្វើដំណើរដើរទៅតាមផ្លូវផ្សេង វិញ ។ លោកអស់នោះនិយាយនឹងលោកថា "ការធ្វើដំណើរទៅ កាន់ប្រទេសនោះ មិនចាំបាច់ធ្វើដំណើរតាមនាវាជាលោយឡូវ នៅវេលា ដែលមានខ្យល់បក់ត្រាសមក មានរលកធំ ៗ ហើយមានពួកបិសាច ទុច្ចរិត ចាំធ្វើឲ្យលោកមានអន្តរាយតាំងពាន់យ៉ាងនោះឡើយ ។ គួរតែ លោកចេញដើរទៅកោះព្រោយទៅផ្នែកទិសអាគ្នេយ៍ នៃប្រទេសឥណ្ឌា ខាងត្បូងវិញ តាមផ្លូវទំនងនេះ យើងនឹងអាចទៅដល់កោះស៊ីឡង់តាម ជើងទឹក ក្នុងរយៈវេលាតែត្រឹម ៣ ថ្ងៃ ។ តែបើលោកត្រូវការ ឡើងគោក ដើរកាត់ព្រោះប្រកក្អយ៉ាងណាក្ដី លោកអាចនឹងធ្វើដំណើរទៅ

បានដោយសុខសប្បាយ ឥតមានអន្តរាយអ្វីឡើយ" ។ លោកហ្វូន-ឆាង ក៏ទទួលស្តាប់ពាក្យទូន្មានដ៏សុចរិតនោះ ហើយក៏ចាប់ដើរផ្លូវទៅក្នុងប្រទេសឥណ្ឌាខាងត្បូង ដោយបានដើរកាត់ប្រទេសជាច្រើនដែរ ទៅដល់មាត់សមុទ្រ ។ ក្នុងវេលានោះ មានកើតចលាចលនៅកោះស៊ីឡង់ ។ ទើបលោកគ្រូហ្វូន-ឆាង លះបង់គំនិតដើមគ្រប់ប៉ុណ្ណោះ ហើយលោកត្រឡប់មកតាមផ្លូវដដែលវិញ ។

— ៧០ —

រឿងរ៉ាវដែលលោកហ្វូន-ឆាង បានពោលពីការធ្វើដំណើររបស់លោកទុកមកឲ្យយើងនេះ គួរកប់រួមក្នុងពួករឿងបែបច្បាប់សម្រាប់អក្សរ-សាស្ត្រចិនបាន អក្សរសាស្ត្រនេះមានដំឡៃថ្លៃថ្នូរ ព្រមទាំងជាក្បួនខាងភូមិសាស្ត្រសាសនា ហើយជាក្បួនវចនានុក្រមយ៉ាងធំទូលាយបរិបូណ៌ដោយរឿងរ៉ាវគ្រប់មុខ ។ លោកឥតសាវ័ន្ធបានពោលទុកថា: "លោកហ្វូន - ឆាង នោះគេអាចហៅថាជាលោកប៉ៅសានទ្យាស របស់ឥណ្ឌាក៏បាន; ការពិត លោក (ហ្វូន-ឆាង) បានដើរទៅសព្វទីគឺពីទិសខាងលិចទៅខាងកើត, ពីខាងជើងរហូតទៅដល់ចុងខាងត្បូងតំបន់ណាដែលលោកមិនបានចូលទៅមើលដោយខ្លួនលោក លោកក៏បានពោលទុកតាមទំនងដែលមានសាក្សីគួរជឿបាន ដែលលោកបានពិគ្រោះសួរផង, គេទុកលោកជាអ្នកប្រាជ្ញមគ្គុទ្ទេសក៍នៃជនជាតិឥណ្ឌាទាំងពួង

(មានត)

# ពង្សាវតារប្រទេសចិន

(តមក)

ក្នុងកាសាតក្កាវៀននេះឯង មានក្បួនខ្នាតសៀវភៅដែលពោលពីរឿងកំណែវាងព្រះពុទ្ធសាសនាជាច្រើន អ្នកប្រាជ្ញប្រវត្តិសាស្ត្រទើបនឹងស្រាវជ្រាវគិតគូរយកចេញ មើលដឹងសេចក្ដីជាក់ច្បាស់ក្នុងកាលសម្ព័ន្ធនេះឯង ទើបឃើញមានសេចក្ដីនិយាយពីចំណោះ ក្នុងព្រះពុទ្ធសាសនាជាច្រើនៗ ភូមិប្រទេសរបស់តក្កាវៀននេះ មានអាណាខេត្តពីស្រុកកុលជា រហូតដល់ស្រុកគួន-ហ្គួង ទឹងតាំងពីស្រុកកាព៍គារ៍ដល់ស្រុកខូ-តាន តាមតំបន់អស់នេះសឹងជាថាវរវត្ថុ ដែលជាសិល្បកម្មរបស់គ្រីកលាយគ្នានឹងបែបរបស់ពុទ្ធសាសនា របៀបចនារបស់ចិនក្ដី របស់ជប៉ុនក្ដី សឹងនាំយកគំរូបែបផែនពីពួកអស់នេះជាច្រើន គឺថាពួកតក្កាវៀនក្នុងសម័យនោះ សឹងមានសេចក្ដីចំរើនរុងរឿងប្រហែលៗនឹងចិនដែរៗ

ក្នុងរវាងព្រះពុទ្ធសករាជ ៤០០ នោះ អាណាចក្រតក្កាវៀន ក្នុងទូរស្តង់គរគខាងកើតបានធ្លាក់ទៅជាស្រុកចំណុះរបស់ចិន ចំពួកដែលចិនហៅថា "ជិមកង់" គឺជាស្រុកបាត់បញ្ជូនគ្រឿងបណ្ណាការថ្វាយក្រុងចិន តែកាលដែលស្រុកចិនកើតចលាចលវរីកឡើងនៅវេលា ១៨ ឆ្នាំនោះ គឺតាំងពីពុទ្ធសករាជ ៩៥១ ដល់ពុទ្ធសករាជ ៩៦៨ ៗ ពួកអស់នេះក៏នាំគ្នាដកខ្លួនចេញពីអំណាចចិនតាំងឥស្សរៈឡើង កាលដែលព្រះបាទ

ក្វាង-វូទី ទ្រង់បានប្រាថ្នាប្រមូលតាំងអាណាចក្រចិនជាថ្មីឡើង ហើយក៏មិនបានយកព្រះទ័យទុកដាក់នឹងរឿងពួកអស់នោះ ឲ្យមកនៅក្រោមអំណាចដូចកាលពីមុនទៀត ហេតុនេះ ទើបពួកតក្កាវៀនទាំង ២ ស្រុក គឺកុលជាំនិងខូ-តាន អាស្រ័យកំឡាំងរបស់ពួកហ្វូន បានដណ្តើមយកខែត្រដែនក័ប — តារ៍មកបែងចែកគ្នា ក្នុងសម័យដែលពួកហ្វូនមានអំណាចមកនៅជាជំនួសពួកចិន ។ ឯពួកហ្វូននោះមានប្រយោជន៍ដ៏សំខាន់ ក្នុងការដែលខ្លួនផ្សាយអំណាចចេញទៅខាងផ្លូវនេះ ព្រោះវេលានោះពួកហ្វូនដែលនៅក្នុងអ័ល-ឆៃ, កិតិសេសនឹងក្ដូប ច្រើនជាទីសមុទ្រខ្សាច់ឬជាទីស្ងួតក្រៀមក្រោះ ។ ចំណែកខាងភូមិប្រទេសនៅតក្កាវៀននេះ ដូចជាតាមឆ្នេរទន្លេតារិម ជាទីមានដីជាតិល្អ អាហារត្រីសាច់ក៏មានបរិបូណ៌ ។ មួយវិញទៀត ពួកហ្វូនត្រូវការឃុំរក្សាផ្លូវថ្នល់មួយហៅថា "ថ្នល់សូត្រ" ដែលជាផ្លូវគមនាគម សម្រាប់ពួកអ្នកជំនួញនាំជំនួញចេញចូលបាន រវាងបូព៌ាទិសប្រទេស នឹងអាណាចក្រប៉ារ៉ាទីនិងមហាណាចក្ររ៉ូម ។

## រឿងមេទ័ព ប៉ុន-ចៅ

មានមេទ័ពចិនម្នាក់ឈ្មោះ ប៉ុន-ចៅ បានពោលតាមយោបល់យល់ឃើញថា ការដែលទួរគីស្តង់ធ្លាក់ទៅនៅក្នុងកណ្តាប់ដៃពួកហ្វូននោះ ប្រហែលគ្នានឹងកាត់ដៃចិនម្ខាងដាច់ចេញទៅ ទើបលោកមេទ័ព ប៉ុន-ចៅ

បានទំប្រឹងធ្វើសង្គ្រាមនឹងពួកហួនដល់ ៣០ ឆ្នាំ ដើម្បីពង្រីកអំណាចចិនឲ្យរីកធំឡើងទៀត នឹងត្រូវការរួបរួមអាណាចក្រទួរស្គង់មកចូលក្នុងផែនដីរបស់ចិនទាំងអស់ ។

មេទ័ព ប៊ុន-ទៅ កើតក្នុងត្រកូលខ្ពង់ខ្ពស់ ជាអ្នកប្រាជ្ញប្រចាំព្រះអង្គរបស់ព្រះបាទ អ៊ិង-ទី មានប្អូនស្រីម្នាក់ឈ្មោះ ប៊ុន-ហួយ-ប៊ុន ជាស្ត្រីអ្នកតែងរឿង (កវីទី) ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញជាដំបូងរបស់បូព៌ាប្រទេស ។ ចំណែកឯមេទ័ព ប៊ុន-ទៅ ចូលចិត្តប្រើជាវប្រើនជាងប្រើពិត (ប៉ាក់កាសរសេរអក្សរចិន) ក្នុងកាលនោះព្រះបាទ ក្វាង-វូទី ទ្រង់ទិវង្គតទៅហើយ តាំងពីពុទ្ធសករាជ ៦០០ ។ ព្រះមហាក្សត្រចិន ដែលគ្រងរាជ្យជាដំណតមក ទ្រង់ព្រះនាមព្រះបាទ ម៉ិង-ទី ជាក្សត្រចិនអង្គដំបូង ដែលបានចូលកាន់ព្រះពុទ្ធសាសនា ។ ក្នុងឆ្នាំពុទ្ធសករាជ ៦១៦ មេទ័ព ប៊ុន-ទៅ នឹងមេទ័ពម្នាក់ទៀតឈ្មោះ ទា-គូ បានច្បាំងឈ្នះពួកហួនក្នុងខែត្រចាក្គូល ហើយធ្វើឲ្យចិនមានអំណាចក្នុងខែត្រនេះ រួបលើកហួសចូលទៅក្នុងខែត្រ ក័ប-តារ៍ បង្គាប់បង្ខំឲ្យប្រទេស ខូ-តាន នឹង ក័ប-តារ៍ ព្រមជាចំណុះក្រុងចិន បានសម្រេចក្នុងពុទ្ធសករាជ ៦១៧ ទើបនាំឲ្យស្រុកផ្សេងៗ ក្នុងទួរស្គង់ព្រមចុះចូលឡើងមកក្រុងចិនផង ។ លុះតមកក្នុងពុទ្ធសករាជ ៦១៨ ព្រះបាទ ម៉ិង-ទី ក៏សោយទិវង្គតទៅ កាលដំណឹងនេះបានផ្សាយទៅដល់ប្រទេសទួរស្គង់ៗ ក៏រឹងទទឹងតាំងជា

ផ្សេងៗទៀត ហើយក្នុងគ្រានេះ ទួគីស្តង់បានអាស្រ័យកម្លាំងពួកហួន ជួយផង ពួកចិននឹងទួគីស្តង់ក៏តាំងចាប់ច្បាំងគ្នាឡើងយ៉ាងសាហាវ ក្នុងវេលានោះមេទ័ពប៉ុន-ចៅ មិនបាននៅក្នុងទីនោះទេ ត្រឡប់ទៅស្រុកចិនវិញ (ដោយព្រះមហាក្សត្រចិនទិវង្គតថ្មីដោយហេតុអ្វីមិនប្រាកដ) ។ ក្នុងគ្រានោះ ពួកទួគីស្តង់បានប្រមូលវាយពួកទាហានចិនឲ្យទន់ខ្សោយថយកម្លាំងទៅជាច្រើន តែលុះដល់មេទ័ពប៉ុន-ចៅ ត្រឡប់មកដល់វិញពួកទាហានចិនក៏មានកម្លាំងខ្លាំងពូកែឡើងវិញ ដើម្បីធ្វើឲ្យប្រទេសទួគីស្តង់ភាគខាងកើត ធ្លាក់ទៅនៅក្រោមអំណាចចិនយ៉ាងកប់មួយសាទៀត ។

ជ័យជំនះអស់នេះ ស្រុកចិនបានមកសឹងតែមិនបាច់បង់ខាតអ្វីឡើយ ។ ពិតមែនតែមេទ័ពប៉ុន-ចៅ បានទទួលទាហានថែមៗមកទៀតក្នុងមួយគ្រាៗ អំពីទីផ្សេងៗ ក្នុងប្រទេសចិន តែពួកដែលចូលមកធ្វើជាទាហាននេះ សុទ្ធតែជាពួកអ្នកកស៊ូអន្តរាយ ដែលស្ម័គ្រចិត្តស្វែងរកទ្រព្យសម្បត្តិអំពីចម្បាំង ។ មួយទៀត មេទ័ព ប៉ុន-ចៅ ចូលចិត្តជួលជនអ្នកស្រុកឆាយមកធ្វើជាទាហាន ដោយមានគំនិតគិតឃើញថា ការប្រើមនុស្សព្រៃឲ្យច្បាំងតស៊ូនឹងមនុស្សព្រៃ ជាយុទ្ធវិធីល្អបំផុត ។ មួយវិញទៀតក្នុងខេត្តយ៉ា-កេនត៍ ខេត្តកថ-គារ៍ត៍ មានភូមិប្រទេសស្រស់បស់ធំទូលាយហើយមានជីជាតិល្អផង ការដែលយកកងទាហានទៅទុកនៅទីនោះ ក៏មិនជាការបង់ខាតសោហ៊ុយប្រទេសចិនប៉ុន្មានឡើយ ។ ក្រៅពី

នេះមេទ័ព ប៊ុន-ចៅ បានប្រើវិធី នាំយកពួកទាហានឈ្លើយមួយពួក ទៅតស៊ូនឹងពួកឯទៀតៗ ព្រោះពួកជនអស់នោះមានពួកខ្លះមានការស្អប់ចង់អាឃាតគ្នាទៅវិញទៅមក ហើយស្រ័តចិត្តនឹងហែកសាច់គ្នាស៊ីទៅវិញទៅមកផង ។ វិធីរបស់មេទ័ព ប៊ុន-ចៅនេះ នៅមានប្រទេសធំៗដែលមានស្រុកចំណុះច្រើនៗ និយមយកមកប្រើដល់សម័យសព្វថ្ងៃនេះៗ មេទ័ពប៊ុន-ចៅ បាននាំកងពលទាហាន ខូ-គាន ទៅច្បាំងប្រហារជីវិតក្សត្រកឹប-គារ៍ ដែលបានតាំងឥស្សរៈរឹងទទឹងតស៊ូនឹងមេទ័ព ប៊ុន-ចៅ ហើយតមកក្នុងឆ្នាំពុទ្ធសករាជ ៦៣១ មេទ័ព ប៊ុន-ចៅ យកកំឡាំងទាហានកឹប-គារ៍ ទៅវាយយកស្រុកយ៉ាកេន្ទ ។ ចំណែកឯព្រះចៅផែនដីយូ-អេជីខាងប្រទេសឥណ្ឌា បានធ្វើស្ពានមេត្រីយ៉ាងជិតស្និទ្ធនឹងមេទ័ពពូកែនេះៗ ដោយផ្លូវស្ពានមេត្រីយ៉ាងល្អនេះ ជាហេតុឲ្យព្រះចៅផែនដីយូ-អេជីមួយអង្គ ចាត់រាជទូតទៅសុំក្សត្រីក្រុងចិនក្នុងរាជវង្សហាន់យកមកអភិសេក តែពួករាជសំណាក់លោ-យ៉ាំងមិនព្រមឲ្យ ពួកយូ-អេជី ក៏ទំនងនឹងក្រុងចិនជាខ្លាំង ទើបកើតសង្គ្រាមទ្បើងក្នុងពុទ្ធសករាជ ៦៣១ កងទ័ពយូ-អេជីមានមេទ័ពឈ្មោះ “ សា-ហ៊ី ” បានលើកចូលទៅច្បាំងនឹងទ័ពចិន ។ ចំណែកខាងមេទ័ពប៊ុន-ចៅ បានប្រើឧបាយយុទ្ធវិធីឲ្យខ្មាំងសត្រូវអត់បាយស្លាប់នៅលើភ្នំខ្ពស់មួយ ហើយកងទាហាន យូ-អេជី ក៏ដល់នូវសេចក្តីវិនាសខ្ទេចខ្ទីអស់ទៅ ។ តាំងពីនោះមក ពួកមហាកជាទៅ

(ប្រទេសឥណ្ឌា) ដែលហាមឃាត់ពួកឈ្មួញចិនតទៅទៀត ហើយប្រែត្រឡប់ជាចងស្ពានមេត្រីនឹងចិន ឲ្យកាន់តែស្និទ្ធស្នាលថែមឡើងទៀត ។ មេទ័ព ប៉ុន-ហៅ តាំងទ្រាក់ហាននៅស្រុកកុលជា ជាអ្នកសម្រេចរាជការនៅប្រទេសទួគីស្ថង់ ហើយបានចាត់ឲ្យនាយទាហានរបស់ខ្លួនម្នាក់ទៅត្រួតត្រាប្រចាំស្រុកក័ច-គារ៍ ។ គ្រានោះនៅមានក្សត្រអង្គមួយ ក្នុងតំបន់នោះ នៅរឹងទទឹងនឹងអំណាចចិន គឺព្រះចៅផែនដីស្រុកកាពីគារ លុះក្នុងឆ្នាំពុទ្ធសករាជ ៦៣៧ ទើបមេទ័ព ប៉ុន-ហៅ នាំយកទាហានកុលជាទៅច្បាំងតទល់នឹងក្សត្រអង្គនោះ ដល់ទៅធ្វើគត់ព្រះជន្មក្សត្រនោះបានផង ។ មានសេចក្តីដំណាលថា ពួកទាហានរបស់មេទ័ព ប៉ុន-ហៅ បានសម្លាប់ពួកមនុស្សរបស់ក្សត្រកាពគារដល់ចំនួន ៥០០០ នាក់ ហើយចាប់យកទៅធ្វើជាឈ្លើយបានដល់ ១.៥០០០ នាក់ ។

នៅគ្រានេះ អាណាចក្រទួគីស្ថង់ ត្រូវកងទ័ពចិនប្រាបប្រាមយ៉ាងកាចបាបទៅគ្រប់អន្លើ ហើយនៅតាមដងទន្លេតារីមនឹង យ៉ុល-ឌុល នោះ មិនថាក្សត្រ ចៅ ឬសេដ្ឋីអ្នកមានអ្នកក្រទេ សឹងធ្លាក់ទៅនៅក្នុងអំណាចនៃព្រះចៅក្រុងចិនទាំងអស់ ។ ព្រះចៅអធិរាជក្រុងចិនទ្រង់ព្រះនាម ហ៊ូ-ទី គ្រងរាជ្យនៅក្រុង ឈោ-ឃ៉ាំង ជាវេលា ១៧ ឆ្នាំ គឺតាំងពីពុទ្ធសករាជ ៦៣២ ដល់ពុទ្ធសករាជ ៦៤៨ ជាមហាក្សត្រាធិរាជដែលមានឫទ្ធិអំណាចធំបំផុត មិនធ្លាប់មានក្សត្រចិនអង្គណាមានអំណាចស្មើ

អធិប្បាយសុភាសិត

# ឃុនឧត្ដមប្រីជា ជាប-ពិន

រៀបរៀង (តមក)

## ២០- កុំឈ្លោះនឹងស្រី កុំក្ដីនឹងគ្នា[១]

ពាក្យនេះលោកពោលជាពាក្យឃាត់

កុំឲ្យប្រុសៗ ធ្វើក្អាំងក្អាត់ ទាស់មាត់ទាស់កឈ្លោះវិវាទ ។
ដ្បិតលោកចាត់ស្រីទៅជាយេវ៉ែក ចំឡែកពីប្រុសដោយធម្មជាតិ
ទាំងចិត្តគំនិតឫកមារយាទ សំងឃ្លាតពីប្រុសមិនដូចគ្នា ។
ធម្មតាស្រីៗ ចិត្តមិនទទឹង ច្រើនធ្លាប់ទេវខឹងតែធ្លាប់ជា
ប្រុសណាធ្លាប់ខឹងទទឹងប៉ះពារ ឈ្លោះទាស់ទែងគ្នាជាមិនខាន ។
ទើបលោកថា "កុំឈ្លោះនឹងស្រី" កាប់សួស្ដីដល់ខ្លួនប្រាណ
មិនបានជាការអ្វីប៉ុន្មាន បានតែរំខានចិត្តអាត្មា ។
មួយទៀតទុកជាប្រុសឬស្រី មិនត្រូវកើតក្ដីអ្វីនឹងគ្នា
ព្រោះក្ដីតែងខូចខាតទ្រព្យា ទាំងអស់ទាំងគ្នា-ទាំងឈ្នះចាញ់ ។
អ្នកឈ្នះក៏ដាច់ទ្រព្យធនធាន នាំឲ្យរំខានចិត្តខ្វល់ខ្វាញ់
ចំណែកខាងឯអ្នកដែលចាញ់ ខូចទ្រព្យកើតខ្វាញ់យ៉ាងក្រៃលែង ។

---

១ ន័យខ្លះថា "កុំឈ្លោះនឹង ស្រី កុំក្ដីនឹងចិន" ។ ពាក្យនេះត្រូវមិនគ្រប់សម័យទេ ។

២១- គ្និតម៉ងសម នៅប្រមាទជិះឋរនេះគោលៀន

ពាក្យនេះលោកពោលជាពាក្យឡក

ជាពាក្យបន្ទោសប្តូចអក    ឲ្យស្តកគំនិតអ្នកប្រមាទ ។
គឺមនុស្សអ្នកតូចអ្នកលង់ខ្លៅ    តែចង់ក្អេងក្អាងគិតវាយអាច
ចង់បានយសសក្តិធំហួសមាឌ    ទីងខាតកម្លាំងនាំខាន ។
ហេតុនេះអ្នកប្រាជ្ញចាស់លោកស្តី    ថា "អ្វីហួសមាឌកុំចង់បាន"
តែខំបរបេសហួសប្រមាណ    នឹងខូចខ្លួនប្រាណឥតអំពើ ។

២២- គ្និតតែអង្គុយ គានុយតែជាក់

ពាក្យនេះលោកប្រៀបយ៉ាងចំហុត

តាមភាពនៃមនុស្សមានពុតត្បុត    ដើម្បីស្គាល់ពុតមនុស្សចិត្តវៀច ។
គឺមនុស្សមុយៗបែបម៉ឺសៗ    អង្គុយក្អឹសៗទន់ពក្អៀច
សំដីល្អកល្អិនល្អល្អៀចៗ    តែមានចិត្តកៀចកលឧបាយ ។
មនុស្សបែបយ៉ាងនេះក៏សឹងមាន    យើងបានឃើញហើយកុំមើលងាយ
ត្រូវតែប្រយ័ត្នការសម្លាយ    កុំបីពាយងាយមនុស្សនេះឡើយ ។

២៣- ក្មេងអាងយំ ពាលអាងប្រដំ ចាស់អាងស្លាប់(១)

ពាក្យនេះលោកពោលតាមធម្មតា

ដែលយើងធ្លាប់គិតពិចារណា    គឺឃើញថាពិតឥតកុហក ។

---

១ ម្យ៉ាងទៀតថា ពាលអាងកាប់ ចាស់អាងស្លាប់ ក្មេងអាងយំ ។

ទំនៀមក្មេងតូចដែលនៅខ្ចី　បើកើតមួយមកករល្អក
ទឹងរឿងអ្វីមួយតែងខ្ជិចខ្ជក់　ផ្ទុះផ្ទក់ក្នុងចិត្តឥតគណនា ។
ច្រើនអាងតែយំដាក់ជាមុខ　រំអុកឲ្យចាស់លោមលួងព
រឿងនេះតែងមានជាធម្មតា　កូនក្មេងណាៗក៏មិនខាន ។
ឯពួកមនុស្សពាលមិនអាងយំ　អាងតែប្រជំទាត់ដាក់ប្រាន
ចាក់កាប់សម្លាប់យ៉ាងក្លាហាន　ដោយចិត្តសាមាន្យរបស់វា ។
ឯមនុស្សចាស់ៗចំណាស់ហើយ　មិនដូច្នោះឡើយព្រោះដក
ច្រើនតែប្រជុំនិយាយគ្នា　អាងតែមរណាដាក់ជាមុខ ។

## ២៤- ក្របីស្នែងកោក　មនុស្សស្រលៀងក្អែក កុំឲ្យដើរចូល

ពាក្យនេះបោរាណលោកឧបមា
ជាពាក្យប្រៀបធៀបបែបប្រស្នា　ឲ្យយើងពល់គ្នាទំលះបង់ ។
ពាក្យថា "ក្របីមានស្នែងកែក" គឺមនុស្សចិត្តបែកមិនទៀងត្រង់
មិនកាន់តាមធម៌ព្រះពុទ្ធអង្គ　លោកឲ្យលះបង់កុំចូលជិត ។
ពាក្យថា "មនុស្សកែកក្អែកស្រលៀង" គឺមនុស្សលំអៀងចាកការពិត
ចិត្តកៀចវៀចវេរធ្វើទុច្ចរិត　ហាមកុំដើរជិតកុំដើរចូល ។

២៥- ក្រអឺចំណោះ ក្រកៅស្នូងតិះ ពឹងឈប់ទីទុយ

ពាក្យនេះជាពាក្យពោលចំអន់

ក្នុងពេលណាមួយដែលបានគ្រាន់ ព្រោះខ្លួនឃើញទាន់ធ្វើកើតត្រូវ ។
ដែលក្នុងចំណោមគេទាំងឡាយ កំពុងខ្វល់ខ្វាយមិនឃើញផ្លូវ
ហើយខ្លួនតែម្នាក់គិតឃើញត្រូវ ក្នុងផ្លូវការងារឬគម្រោះ ។
អ្នកដែលបានឃើញឬធ្វើកើត តែងពោលបន្តើតថាដូច្នេះ
គឺថា "ក្រអឺទឹងចំណោះ- ក្រកៅស្នូងតិះទប់ទឹទុយ" ។

២៦- ក្រមុំដណ្ដឹងម្ដាយ មេម៉ាយដណ្ដឹងចិត្ត

ពាក្យនេះលោកពោលតាមធម្មតា

នៃស្ត្រីដែលនៅជាកញ្ញា គឺថាក្រមុំព្រហ្មចារី ។
អ្នកណាចង់បានជាភរិយា ត្រូវតែនាំគ្នាចូលទៅស្ដី
ដល់ម្ដាយឪពុកទើបគប្បី តាមផ្លូវលោកិយពីព្រេងនាយ ។
ព្រោះស្រីក្រមុំតូចទ្រលុក នៅក្នុងបន្ទុកឪពុកម្ដាយ
មិនអាចសម្រេចលើរូបកាយ ចាត់ចាយខ្លួនឯងពុំទាន់បាន ។
បើដល់ទៅចាស់ជាមេម៉ាយ ទើបអាចចំណាយរៀបខ្លួនប្រាណ
តាមខ្លួនពេញចិត្តល្មមប្រមាណ ព្រោះគេធ្លាប់បានរៀបមុខម្ដង ។
អ្នកដែលដណ្ដឹងត្រូវស្រួលចិត្ត បញ្ជាក់ឲ្យពិតតាមចំណង់
កុំបីរំលោភហួសវេលង បើគេស្ម័គ្រផងសឹមយកចុះ ។

## ២៧- ក្រមុំមិនដែលស្ងុត ចង្កូតមិនដែលធំជ

ពាក្យនេះលោកពោលតាមធម្មតា

ស្ត្រីក្រមុំជាកញ្ញា　　តែងមានចិន្តាបែបខ្ជិបខ្ជក់ ។
ឆាប់ទឹងឆាប់ជាមួយរំពេច　　បានស្រួលបន្តិចៈគេចង្អុលឯក
បើស្តីបន្ទោសតែងតក់ម៉ក់　　ខ្ជិបខ្ជក់ខេះខឹងអតបើគិត ។
មិនទាន់មានប្តីត្រូវប្រយ័ត្ន　　ការពារទុំងមាត់អស់ពីចិត្ត
កុំបីបណ្តោយធ្លោយគំនិត　　ខ្លាចក្រែងប្រព្រឹត្តក្បត់លោកិយ ។
ម្តាយនិងឪពុកឬមេបា　　គេថ្នមគ្រាត្រាប្រណី
លំបាកដូចគេថែកូនខ្ចី　　ទម្រាំមានប្តីទើបរបូត ។
ហេតុនេះបុរាណទើបពោលថា　　ក្រមុំកញ្ញាមិនដែលស្ងុត
លោកប្រៀបគួរនាដូចចង្កូត　　នឹកផ្អាកធ្ងកៗ មិនដែលស្ងៀម ។

## ២៨- ក្អែកក្អួយ ជាក្អែកជប់

នេះជាពាក្យចាស់មិនមែនថ្មី

ដែលប្រាជ្ញបុរាណលោកបានស្តី　　ប្រាប់ដល់ប្រុសស្រីផងទាំងឡាយ ។
គឺជាពាក្យប្រៀបធៀបប្រឌិត　　ពីការប្រព្រឹត្តការបរិយាយ
នៃពាក្យសំដីតែងប្រែក្លាយ　　វេងឆ្ងាយដោយពោលតៗទៅ ។
ធម្មតាអ្នកដឹងឮរឿងអ្វី　　យករឿងពីៗ ស្ទាត់ជ្រៅៗ
បែងចាក់បិទពុំជិតនៅ　　ដោយចង់ប្រាប់ទៅអ្នកដទៃ ។

បើខប់បិទបាំងរឿងប្លែកៗ　ក្នុងទ្រង់ស៊ើរបែកសព្វកក្រៃ
ខប់ណាស់បានត្រឹមតែបីថ្ងៃ　សម័យណាមួយគង់ភ្លាត់បាន ។
តែពោលចេញហើយមានតែល្អៀង　មិនទៀងឃ្មៀងឃ្លាតបាកដើមដាន
ប្លែកៗ គិតៗ ម្ដងពុំខាន　មិនយូរប៉ុន្មាន ១ ជា ១០ ។
រឿងនេះសឹងមាននិទានពិត　សម័យអតីតលោកប្រាព្ធ
អំពីក្អែក ១ ជាក្អែក ១០　ដែលខប់ឲ្យនៅគិតពុំបាន ។
ថាមានបុរសឈ្មោះចៅជា　នាងសុខសោភាល្អកល្យាណ
ទើបរៀបការថ្មីដោយក្សេមក្សាន្ដ　មិនយូរប៉ុន្មានចៅជានោះ ។
ទៅក្នុងព្រៃក្រៅផ្ទះបន្តិច　ដោយកិច្ចធុរៈគឺទៅជុះ
បានឃើញការុងប្រាក់នៅនោះ　ដែលគេដាក់ចុះលើផែនដី ។
ប្រាក់នោះសាវិលទឹងអាខ្ចប　ជាមនុស្សកំហូចឥតផ្ទុំបី
ក៏ទើបបោកគេបានថ្មីៗ　មកសូន្យសញ្ញាស្លាប់នៅនោះ ។
ចៅជាបានឃើញការុងប្រាក់　ដែលធ្លាក់នៅដីប្រែបព្រៃជុះ
ក៏ជីកកប់ទុកក្នុងទីនោះ　ហើយដើរបំពោះទៅផ្ទះវិញ ។
ក៏ប្រាប់នាងសុខប្រពន្ធនោះ　ថាអញទៅជុះអម្បាញ់មិញ
បានឃើញក្អែក ១ ក៏ហើរចេញ　ពីទ្វារជុះមិញចូលក្នុងព្រៃ ។
ប្រពន្ធក្មេងហើយព្រួលក្នុងចិត្ត　ទោះបើឲ្យបិទបាំងខ្ទាំងក្រៃ
បិទទុកមិនបានប៉ុន្មានថ្ងៃ　សម័យខាងក្រោយភ្លាត់ប្រាប់ម្ដាយ ។

ថាក្អែក ២ ចេញពីប្ដីមក ឯម្ដាយក៏យកទៅបរិយាយ
ប្រាប់ឪពុកថា ៣ កាន់តែក្លាយ ដល់គេនាំឆ្ងាយក្លាយជា ១០ ។
ដំណឹងនោះប្លែកកើតអស្ចារ្យ ទាល់តែរាជការស៊ើបសួរសព្វ
រកចុងរកដើមសាត្រឡប់ មកជួបបញ្ចប់លើចៅជា ។
សួរថាហេតុម្ដេចក៏ដូច្នោះ ឯចៅជានោះឆ្លើយប្រាប់ថា
ខ្ញុំពោលនេះឯងជាប្រស្នា ព្រោះថាខ្ញុំរើសការុងប្រាក់ ។
នៅក្នុងទីព្រៃមួយកន្ទង ខ្ញុំក្រែងគេថាឯងលួចលាក់
ទើបខ្ញុំមិនប្រាប់គេថាប្រាក់ ខ្ញុំជីកកប់ដាក់នៅមួយជុំ ។
ហើយខ្ញុំបង្កើតពាក្យឲ្យប្លែក ថាក្អែក ១ ចេញពីខ្លួនខ្ញុំ
ដើម្បីធ្វើរឿងឲ្យសុខុម គ្រាក្រោយទើបខ្ញុំនិយាយដោះ ។
រាជការបានជ្រាបដូច្នោះឯង ក៏បែងរំលែកបែកប្រាក់នោះ
ឲ្យទៅចៅជាដោយសង្គ្រោះ ពីព្រោះគាត់ប៉ិនរក្សាទ្រព្យ ។
ហេតុនេះទើបប្រាជ្ញបុរាណ ពោលថា "ក្អែក១ ជាក្អែក ១០"
ដោយយករឿងនេះមកប្រាព្ធ ប្រសព្វនឹងពាក្យមនុស្សគ្នា ។

## ២៩ – ទឹងចាំអត់, ទ្រត់ទំរកា

សុភាសិតនេះប្រាជ្ញបុរាណ
លោកពោលប្រដៅយើងគ្រប់ប្រាណ ឲ្យមានសន្ដានចិត្តសន្ដោស ។
កាលបើកើតទំនាស់ពីរឿងអ្វី គប្បីប្រយ័ត្នកុំឲ្យថ្លោស

តែខឹងក្នុងក្តាំងហួសកំណោស រមែងកើតទោសទុក្ខពាន់ពាន់ ។
ខឹងខុសខូចខាតប្រមាថខុស រែងធ្វើកំហុសជាច្រើនលន់
ហេតុនេះលោកថាត្រូវអត់ធន់ ធ្វើចិត្តឲ្យធ្ងន់ទើបបានសុខ ។
ការខ្សត់ការទាល់ក្រគោកយ៉ាក រមែងពិបាកពុំស្រណុក
ពិបាកស្បៀកពាក់ចាយស៊ីចុក កើតទុក្ខច្រើនយ៉ាងមិនមែនតិច ។
បើខ្លាចក្រខ្សត់ត្រូវលៃលក ប្រឹងរៀនប្រឹងរកធ្វើការកិច្ច
បានទ្រព្យសម្បត្តិទោះច្រើនតិច ត្រូវគិតដូចម្តេចឲ្យបានគង់ ។
កុំចាយផ្តេសផ្តាសឥតបើគិត ត្រូវក្បិតត្រូវក្បៀតប្រៀតការង់
ឲ្យទ្រព្យធនធានបានគង់ទ្រង់ ពេញវង្សតាមវគ្គអ្នកខំរក ។

## ៣០- ខ្លាពឹងព្រៃ, ព្រៃពឹងខ្លា

ពាក្យនេះពោលត្រង់ទឹងប្រស្នា

បុរាណប្រៀបធៀបរៀបឧបមា ឲ្យយើងគ្រប់គ្នាដឹងតាមពិត ។
ថាធម្មតាខ្លាតែងប្រស្រ័យ ពួនពឹងទីងព្រៃធំជិតស្និទ្ធ
ជាទីជ្រកខ្លួនពួនបាំងបិទ រក្សាជីវិតរាជសត្វ ។
ពួកខ្លាអាស្រ័យនៅព្រៃណា ព្រៃនោះមុខជាជាទីស្ងាត់
ដោយមនុស្សមិនដើរទៅមកកាត់ ព្រោះខ្លាចពួកសត្វសាហាវក្រៃ ។
ព្រៃនោះសុខព្រោះមនុស្សមិនកាប់ ជាព្រៃមានភ័ព្វមិនមានភ័យ
ហេតុនេះបុរាណដ៏ឈ្លាសវៃ ថា "ខ្លាពឹងព្រៃ, ព្រៃពឹងខ្លា" ។

រឿងនេះជារឿងពិតប្រាកដ　ប្រាជ្ញលោកកំណត់តាមធម្មតា
នៃមនុស្សនិងសត្វគ្រប់ភាសា　គោងពឹងពាក់គ្នាទៅទើបបាន ។
អ្នកតូចគោងពឹងនឹងអ្នកធំ　អ្នកធំពឹងតូចទើបសុខសាន្ត
នឹងនៅម្នាក់ឯងពេលពុំបាន　ពុំសុខសាន្តត្រាណដូចពឹងឡើយ ។

### ៣១- ខ្លាមិនខ្លាច, ខ្លាចអាចម៍ខ្លា

ពាក្យនេះជាពាក្យពោលបញ្ឆិត

ជាស់តៀនពួកអ្នកឆ្លាយគំនិត　ដែលគិតកោតខ្លាចខុសទំនង ។
ដូចម្ដាយឪពុកឬគ្រូបា　រក្សាកូនសិស្សដោយស្មូនត្រង់
កូនសិស្សគោរពកុំឲ្យឆ្គង　រំលងរំលោភលើលោកណា ។
ប្រសិនបើកូនសិស្សកោងកាច　ពុំខ្លាចគ្រូ-មាតាបិតា
ទៅខ្លាចឯអ្នកក្រៅមេបា　ហៅខ្លាចអាចម៍ខ្លា, ខ្លាមិនខ្លាច ។
កូនសិស្សបែបនេះមានជំនៀល　តិះដៀលលុអំពីសំណាក់ប្រាជ្ញ
ដូច្នេះត្រូវកូនសិស្សគោរពខ្លាច　អំណាចមេបាគ្រូប្រដៅ ។

### ៣២- ខ្លួនជាប់ទ្រព្យលាញ, ខ្លួនរស់របស់បាន

ពាក្យនេះជាពាក្យពោលត្រង់ ៗ

ដើម្បីឲ្យមនុស្សមានចំណាំ　នឹកចង់ថែទាំជីវិតប្រាណ ។
កុំពេលឈឺថ្កាត់គ្រុនរងា　ខំមើលឲ្យជាឲ្យស្មោះស្មាន
ដើម្បីជីវិតសុខក្សេមក្សាន្ត　នឹងបានរក្សាទ្រព្យសម្បត្តិ ។

ប្រសិនខ្លួនឆាប់ទ្រព្យទាំងឡាយ  មុខជាអន្តរាយខូចខ្ចាយខាត
លុះតែខ្លួនរស់ទើបប្រយ័ត្ន  ថែទាំសម្បត្តិឲ្យគង់បាន ។

## ៣៣ - ខ្លៅរែងស្អប់ប្រាជ្ញ

ពាក្យនេះពោលត្រង់មិនប្រស្នា

តាមរឿងដែលពិតជាធម្មតា  នៃមនុស្សពាលខ្លៅអប្រិយ ។
ថាមនុស្សដែលខ្លៅឆោតគំនិត  តែងគិតក្អាត់ក្អាំងគាំងស្មារតី
យកខុសជាគាប់មិនគប្បី  មិនស្ដាប់សេចក្ដីប្រាជ្ញទូន្មាន ។
ទោះស្ដាប់ក៏មិនឲ្យជឿជាក់  មិនយកទុកដាក់ក្នុងសន្ដាន
ប្រាជ្ញណាសន្ដោសចំពោះប្រាជ្ញណា  ប្រាជ្ញនោះច្រើនបានទោសពីខ្លៅ ។
ព្រោះខ្លៅសាមាន្យសន្ដានកាច  រមែងស្អប់ប្រាជ្ញដែលប្រដៅ
តែប្រាជ្ញមែនពិតគំនិតជ្រៅ  មិនតបតទាំងខ្លៅឡើយ ។

## ៣៤ - គាប់ជិតស្រាជាជិតចាយ

ពាក្យនេះជាពាក្យដាស់ស្មារតី

ដល់អ្នកដែលកើតមានការអ្វី  គប្បីពឹងគេឲ្យជួយផង ។
បើអ្នកណាមួយមានការណា  លុះត្រាតែអ្នកនោះប្រឹងចង
ចិត្តគេអ្នកជួយច្រើនកន្លង  ឲ្យសមរំពឹងតាមការនោះ ។
គឺផ្គាប់ដោយគ្រឿងដ៏គាប់ចិត្ត  ទើបគេអាណិតដោយចិត្តស្មោះ
ខ្វល់ខ្វាយ ប្រឹងប្រែងជួយសង្គ្រោះ  ការនោះឲ្យបានដូចប្រាថ្នា ។

បើមិនជួបោះគស់លោកអ្នក　　ដែលជួយចុះមិនមេត្តា
ហេតុនេះបោកណាទើបពោលថា　　"មនុស្សគាប់ទឹងស្រាជាទឹងបាយ" ។

## ៣៥- គេស៊ីពង, ឯងរងសំបក

ពាក្យនេះជាពាក្យល្អវិសេស

ដាស់តឿនកុំឲ្យសែះពាក្យ　　ប្រហែសក្នុងកិច្ចការទាំងឡាយ ។
បើមានកិច្ចការណាទាក់ទង　　ជាមួយអ្នកផងត្រូវខ្វល់ខ្វាយ
ប្រយ័ត្នក្រែងលោកើតអន្តរាយ　　មានទុក្ខដល់កាយឥតអំពើ ។
ដោយមានអ្នកណាគេមានល្បិច　　តែគេបលើកទោសខ្ញុំម្នាក់លើ
ខ្លួនគេបានលាភល្អត្រាន់បើ　　អាក្រក់ខាតទើរលើរូបខ្លួន ។
ដូចគេស៊ីពងពេញបន្ទុក　　សល់តែសំបកមិនមាំមួន
ទើបឲ្យឯងរងពេញសំនួន　　ព្រោះខ្លួនប្រហែសមិនបេះគល់ ។

## ៣៦- គោលឿនសីកាកា, ស្រែល្អសីកាកូន

សុភាសិតនេះជាវាចា

បោពណាប្រៀបធៀបប្រៀបឧបមា　　អំពីផ្គាមនុស្សទាំងឡាយ ។
ដែលមានបំណោះបេះការណា　　ថ្លៃថ្លាត្រាន់បើប្រសើរសាយ
អ្នកផងច្រើនជែកមកអភិប្រាយ　　ពឹងឲ្យខ្វល់ខ្វាយធ្វើការនោះ ។
ការពឹងនោះចួនក៏មានផល　　ចួនកាលនាំខ្វល់អំពល់ស្មោះ
តែត្រូវតែធ្វើដោយសគ្រោះ　　ចំពោះឈ្មោះអ្នកដែលមកពឹង ។

ម្លោះហើយលំបាកដូចគោល្ងឿន មានល្បឿនបោលល្បីថ្លីជើងវែង
ដែលគេច្រើនប្រើឲ្យបោលវែង ត្រូវតែខំប្រឹងពាល់សក់ក ។

៣៧- គោផ្អើលមិនគិត, គិតតែធាសំភ្លា

សុភាសិតនេះប្រែពិត

ពោកណាលោកពោលជាប្រឌិត ឲ្យមនុស្សពេះគិតខាតចំរើន ។
លោកថាការណាល្អប្រសើរ គួរធ្វើដំណើរឲ្យបានកើន
ការមិនឧត្តមកុំក្រវើន ក្រកើនទិតគួរឲ្យយូរពេល ។
ការណាល្អស្អាតខ្ទបខាតទៅ នោះត្រូវគិតតែលៃគ្នាន់គ្នេរ
ឲ្យដឹងកលកិច្ចល្បិចដើងកេល រកពេលបំពេញឡើងវិញពិត ។
កុំគិតជំទាស់ឲ្យផ្លាស់ការ ដ៏មានខ្លឹមសារឲ្យវិបរិត
បើរឿងពោកណាថាប្រឌិត "គោផ្អើលមិនគិត ៗតាសំភ្លា" ។

៣៨- គោខ្មៅដំបៅខ្នង ក្អែកការហើរវិលជំរំសាយកន្ទុយ

ពាក្យនេះជាពាក្យពោលប្រឌិត

ចំពោះពួកអ្នកដែលមានចិត្ត ជាមជិតរង្កៀសរអៀសខ្លួន ។
គឺដូចអ្នកណាកើតរឿងអ្វី ហើយមានគេស្តីបែបរុះគួន
ជារឿងផ្សេងទៀតប្រធួន លើរឿងនៃខ្លួនផ្ទួនជិតៗ ។
អ្នកនោះតែងមានចិត្តរង្កៀស រអៀសរំភើបស្ញើបភ័យភិត
ដោយរឿងក៏វខ្លួនផ្ទួនគ្នាពិត ទើបគិតរអាររអៀសឯង ។

(នៅមានត)

សាសនាចារ

សង្ខេប

# លោកអាចារ្យ មៀវ-ឆន្ទ ឆន្ទត្ថេរ

មហាបរិយត្តិឧត្តមរដ្ឋវត្តបន្ទាយមៀន ឃុំមៀន កោះសុទិន កំពង់ចាម

បានរៀបរៀងជាពាក្យកាព្យ

## រឿងសាសនា

សូមរៀបរាប់រួបរួមរឿងសាសនា ព្រះបមកពប់កិនជិនសីហា ជាសាស្តាចារ្យស្តែងថែងប្រត្យក្ស ៗ ជាគ្រូសព្វគ្រប់សាសន៍ក្រាស់ សីលសុទ្ធ ជាពជបុត្រផុតផែនដែនសក្យៈ ពូជចំបង់បង់បានជាស្តេចច័ក្រ សមអន័គ្ឃស័ក្តិអនន្តកណ្តាលដី ៗ រិទ្ធិរឿងរុងខ្ពង់ខ្ពស់យសអនេក អភិសេកឯកអគ្គទ្រង់សួស្តី បានជាក្សត្របាត់ខ្សត់រតនពង្ស តែដប់បីឆ្នាំ គត់តែពេលស្មាន ៗ បំពេញផ្សងបួសក្ខករកៀនក- ពង់ពេកគ្រា គ្រានាំខាន កុំឲ្យមកផ្ទែតពៀតបៀតបៀនបាន ស្រួលសំកនស្រាន្ត ស្រស់អស់តណ្ហា ៗ ក្លួបចំណោះបេះឯងថែងជាក់ច្បាស់ បំបាត់ចាស់ ឈឺចាប់ស្លាប់សោកា សំដែងធម៌ល្អស្តាប់ច្បាប់សាសនា ថាសាស្តាស្តុក ស្តុកចំណានស្រស់ ៗ ជនទាំងពាន់ជាន់នោះលុះលង់ជឿ ពេលជំនឿ ជានចាស់ផុតស់ចេញអស់ ប្រព្រឹត្តព្រះសាសនាមហាបុរស ថែរបង់ ចោះថែបព្រាហ្មណ៍តាមធម្មតា ៗ

កាលព្រះពុទ្ធនិព្វានមានសាវក ប្រាជ្ញប្រច័ក្សចេះចប់សព្វសាសនា ប្រព្រឹត្តតែងប្រឹងតងមិចរិយា ជាតទ្រោតទ្រោមប់ច្បាប់បាលី ។ និព្វាន ទៅនូវពារអង្គារព្រឹក ព្រលឹមល្ងឹតងឹតចែងសែងសុរិយ៍ ខែពិសាខឆ្នាំ ម្សាញ់ពេញបូណ៌មី ចូលអាសាឍមាសបីខែធួន ។ ទើបព្រះសង្ឃ សីលសុទ្ធបុត្រសក្យៈ ព្រះកស្សបៈជាអាទិ៍ឆ្ពោតមាំមួន សឹងចូបចុលដំ-នុំជុំទៀងខ្លួន រាប់ចំនួនប្រាំរយរូបអរហន្ត ។ ស្ដេចអជាតសត្តតាំងតាក់តែង ទីកន្លែងថ្វាយសង្ឃក្នុងតម្បន់ ជិតគុហានាមាសត្តបណ្ណ តាត់ជាមណ្ឌបាជាមធោមធេតឆាយ ។ ទៀបភ្នំវេភារមគធរដ្ឋ មតមូលមាត់មន្ទសង្ឃបន្ទំថ្វាយ ឲ្យគង់គិតប្រិតប្រៀបរៀបចែកចាយ ធម៌ទាំងឡាយក្លាយឃ្លៀងឃ្លៀងជម្រង់ ។ ព្រោះព្រះពុទ្ធជម្រាស់ត្រាស់សំដែង ច្រើនកន្លែងច្រើនស្ថានបានបាត់បង់ មិនទាន់មានគម្រោងផ្ចិតផ្ចង់ជំនុំសង្ឃចាំចប់សព្វសេចក្ដី ។ ទាំង ៥០០ រូបសង្ឃអង្គអរហន្ត ព្រះអានន្ទចាំមាត់ស្ទាត់ល្ងាញល្បី កស្សបត្ថេរៈអធិបតី ឧបាលិស្ទាញស្ទាត់បទបញ្ញត្តិ ។ ព្រះកស្សបៈជាក់ពាក្យសាកសួរសេប អានន្ទតបប្រាប់ក៏ប់រងកាត់ អាងបានទាន់បណ្ដាំចាំត្អានបាត់ ចំណែកអត្ថបាត់ធម៌ពណ៌នា ។ ឧបាលីថ្លីមាត់ស្ទាត់វិន័យ ឆ្លើយប្រពៃលេឡាក់បាត់ជាឃ្លា ក្រុមជំនុំជុំចូបរូបរួមគ្នា សម្រេចជាបែបមួយជួយថែថួន ។ សូត្របញ្ចុះស្រុះស្រួបអបអានត្រៃ-បិដកថ្ងៃថ្ងៃក្រោយឲ្យខ្ជាប់ខ្ជួន លើកវិន័យលៃវគ្គជាក់

ដោយខ្លួន គិតចំនួនគម្ពីរវិន័យប្រាំ ៗ ព្រះសូត្រសោតដោតក្រងបង់
ដោយឡែក ប្រាំបំណែកគម្ពីរចំណាំ បរមត្ថតាក់ចិត្តល្អិតប្រញ៉ាំ គម្ពីរ
ប្រាំពីរប៉ែកថែកជាក្បួន ៗ សន្ធាយនាជាភាសាបាលី បិដកបីលៃ
បទកត់ចំនួន ប្រាំបីម៉ឺនបួនពាន់ខន្ធដោយខ្លួន បប់សព្វសួនផ្ទួនសាំប្រាំ
ពីរទេ ៗ ថែបចំណាខបានចាំចំណាំស្ទាត់ រៀនពីមាត់តគ្នាជាហូរហៃ
គោលសំខាន់កាន់ប្រិតឥតប្រួលប្រែ មិនហ៊ានកែប្រែបង់សន្ធាយនា ៗ

កាន់យ៉ាងនោះលុះលង់យង់យូរឆ្ងាយ កំរែក្រោយរយោបល់យល់ខុស
គ្នា មួយរយឆ្នាំពីព្រះលះជន្មា បង្កើតជាវិវាទឃ្លាតច្បាប់ចាស់ ៗ ភិក្ខុអក
នៅក្នុងក្រុងវជ្ជី ពោលអំពីបញ្ញត្តិកាត់ចោលខុះ កែបន្ទប់ ១០ យ៉ាងកាង
បុរាចាស់ សឹងមានច្បាស់ក្នុងច្បាប់ប្រាប់គ្រប់សព្វ ៗ ព្រះយសត្ថេរលី-
លា ត្រាជឹងដល់ គោឡាហលកលកែប្រែទាំងដប់ មិនពេញចិត្តគិតពាំង
ពាំងឲ្យស្ងប់ ទើបត្រឡប់ពៃរលកកកើសគ្នា ៗ បាន ១ ក្រុមធំក្រៃលដែល
គ្រប់គ្រង ត្រូវចំនងតាមត្រូយូរវេលា ប្រាំពីររយរូបអង្គសន្ធាយនា
ក្នុងវត្តពំឡូកាជាអារាម ៗ ប្រប្រុងវេសាលីប្រាំបីខែ កាត់ពាក្យកែរលំពុំ
យកតាម រៀងបំថ្មើសលើសខ្ទុះត្រូវឃាត់ហាម មិនឲ្យជាមជាបជរត
ទៅឆ្ងាយ ៗ ពជសម្បត្តិជ្ជបាលកាលក្សត្រា នាមកាឡាសោកពជរិទ្ធី
សាយ ព្រះអង្គព្រមជាមួយជួយខ្វល់ខ្វាយ ខាងនិកាយជាន់ចាស់ផ្សះ
ផ្សាគ្នា ៗ សមាគមជំរះលះរឿងថ្មី រៀងបាលីកយរៀបរបៀបឃ្លា

សូត្រសម្រេចអាចមានបាននាមា ហៅថា គ្រាទីពីរសង្គីតិ ។ ឯពួកខាងវជ្ជី ពីកាលនោះ ក៏វង្វេះសំខាន់កាន់ទិដ្ឋិ មិនព្រមប្រែបតបប្រែះរណ៍ កើតអស្មិមានាផាំពួកបក្ខ ។ ទើបព្រះសង្ឃសងខាងគាងនិកាយ ក៏ដើរផ្សាយធម៌អាថ៌សាសនៈ វង្វេងយោបល់ខ្វល់ខ្វាយក្លាយបែកបាក់ ជាគណៈពីរក្រុមធំក្រាស់ក្រួន ។ ពួកវជ្ជីបាននាមតាមគេដាក់ ឧត្តរនិកាយផ្សាយច្បាប់ក្បួន ទៅឧត្តរខ្វះខ្វាយថ្វាយមាំមួន ផល់ចិនយួនមង្គោះបច្ចូលកៅ-លី ។ ទីងទីបេតហើយវៃឯបូពា៌ ផល់ភាគផប៉ុនសីបេរី ចំណែកទិសបស្ចិមត្រឹមប៉ុសឺ សឹងជាទីសំខាន់កាន់សាសនា ។ ឯពួកសង្ឃត្រង់គ្រាប់ច្បាប់សាវក ទក្ខិណនិកាយប្រាយប្រាជ្ញ ប្រព្រឹត្តគ័ងប្រឹងគធម៌ចរិយា ទៅទិសាខាងត្បូងហ្វូងវែងឆ្ងាយ ។ ព្រះសង្ឃផងសងខាងសាងសាសនា គ្រាច់យាត្រាណាយឡូវខ្វល់ខ្វាយ ពួកឯនាយឆ្ងាយមកកេខាងអាយ ខាងឯងផ្សាយណាយគេផ្ទួរចម្រុះ ។

លុះវេលាគ្រាក្រោយខ្សោយសាមគ្គី ពួកទាំងឡី(១) មិនកែតែប៉ុណ្ណោះ ក្នុងនិកាយដូចគ្នាឃ្លាឃ្លាតខុស ក្លាយសាយសុសកុះកើនប្រែចឥតគណ៍ ៗ ពួកឧត្តរក៏គិតកែតបំរែក្ ធម៌វិន័យនាំប្លែកបែកបាក់ជួន រឹងពិរុធពុទ្ធឧស្ដុកុះ តាមចិត្ត ទៅជាមន្តបន្សាបអាបឧទ្ធព្រាយ ។ ឯមគធជាទីពីដើមគ្រាន់ លុះជំនាន់ជាន់ក្រោយខ្សោយកយមាយ មិនព្រមព្រៀងទៀងទាត់កក់ពេញពេកយ ប្រឡែលាយលទ្ធិគ្រន្ថក្រាស់ ។ សកកផរពេជផាងពីរយេ

---

១ ពីរ ។

រំភើបញយញាប់ញ័ករំភើរផ្កាស    បនព្រះសង្ឃបង់សត្យបាត់សង្វាស
សង្វេគណាស់នាំឲ្យខ្សោយស្រេកស្រេក ។

សម័យមួយក្សត្រក្សាន្តមានបារមី ត្រង់បុរីវង្សាបាដលីបុត្ត ជាស្តេចដែនមគធៈជាក់ចំហុត ព្រះចមមកុដផុតកិតទ្វីពល ។ នាមអសោក-រាជាក្លាតេជះ ជ័យជំនះឈ្នះលុបកពមណ្ឌល សឹកញញើតខ្មៅតខ្មាតឃ្លាតឃ្លាបជល់ ទីងតទល់យល់តឹងប្រឹងមិនបាន ។ ព្រះភូធរនោនាថ.ជាតិបណ្ឌិត ព្រះទ័យគិតជឿជាក់ស្ម័គ្រស្មោះស្មាន ប្រព្រឹត្តធម៌ព្រះពុទ្ធផុតគពស្ថាន ទ្រង់កប់អានឥតឯបែរបង់ចោះ ។ សាសនូបត្ថម្ភបំរុងពស្ត្រ ប៉ាជ្ញាឈ្លាសឆ្លាតឆ្លៀវស្រៀវស្រេចស្រស់ ត្រាព្រះសង្ឃស្ងួនឲ្យត្រឹត្យល្អិតល្អោចអស់ ព្រះអង្គដោះទុក្ខព្រួយជួយដំរង់ ។ សព្វព្រះទ័យតាមលោកមោគ្គលីបុត្ត សីលវិសុទ្ធឧត្តមសំដីត្រង់ ប្រោសប្រទានតាំងជានាយកសង្ឃ បំបាត់បង់សង្ឃបាបសាបសូន្យសៀង ។ ភិក្ខុ-សង្ឃបង់សាគពាក្យរាំទី ព្រះមោគ្គលីចោទចាប់ស្តាប់ផ្ទាត់ផ្ទៀង ភិក្ខុណាជាខុសបុះលំអៀង មិនទាត់ទៀងតាមច្បាប់អាប់សាសនា ។ បរមក្សត្រចាត់ដាក់ទំទន់ គឺឲ្យគ្រងស្រៅសាសន៍ផ្កាសសោក មកបួសក្នុងស្វែងលាភពាបពុទ្ធដីកា ដាក់អាជ្ញាដកចេញដេញចោលអស់ ។ ភិក្ខុណាបរិសុទ្ធបុគ្គសក្យៈ ធ្វើយមិនអាក់ស័ក្តិសមចំឥតខ្ចោះ ទ្រង់មេត្តាត្រាទុកមុខស្រស់បស់ កប់អានស្មោះចំពោះព្រោះសត្ថា ។ លុះកំចាត់បាត់

បង់សង្ឃក្លែងក្លាយ ទាំងនិកាយថេរៈគាត់តែងជា ទីប្រជុំធំធៀបរៀប
សភា សង្គាយនាវេលាត្រាទីបី ។ ក្នុងអសោការាមតាមដំណើរ ក្សត្រ
ប្រសើរសូមសុំក្រុមការី ព្រះមោគ្គលីបុត្តអធិបតី កែសេចក្តីបដគគក់
ចាស់ខុស ។ សមាជិកភិក្ខុសុបញ្ញា សាកច្ឆាសំរេចផ្តាច់កំហុស យល់
ព្រមព្រៀងរៀងប្រាណអានបញ្ចុះ ឲ្យស្រួលស្រុះស្របគ្នាជាបែបមួយ ។
ស្តេចអសោកសិទ្ធិស័ក្តិចក្រពត្រា ផ្សាយសាសនាកក្រើកលើកជំនួយ មាន
ព្រះសង្ឃសោភាជាជំនួយ ចេញទៅជួយចែកធម៌ថ្លៃថ្លា ។ ឯអសោក
ភូមិន្ទពិនរៀងជ័យ ជាប់ព្រះទ័យជឿស៊ុងក្នុងសាសនា ស្រឡាញ់លុប
ទ្រព្យធនជន្ទដីក៏ ជាងជីវិតកាយាសរពើផង ។ កំពុងត្រេងកដ្យមេ្យតុំ
ការង់ ចេញទៅទង់ព្រះផ្នួសបួសបានម្តង លះសិក្ខាណាគេចចេតនាបង់
បំពេញកងកុសលផលបុណ្យទាន ។ វិន័យធម៌ខ្ជូរខ្ជួប់គ្រប់នគរ ព្រះ
ភូធរនរនាថឃ្លាតរុករាន ចាត់បណ្ឌិតគិតជ្រៅទៅទូន្មាន ធម៌ជាយាន
យោងសត្វបាត់បង់បាប ។ ព្រះពុទ្ធពេចន៍លេចលាន់ជាន់នោះណាស់
ល្អត្រចះរឿងរុងគង់ដរាប បរិស័ទស័លសុទ្ធលុតឱនក្រាប មិនឲ្យសាប
ជាបដុនបុណ្យសាស្តា ។

ទីងលើកឡាត់កាត់កោលពោលស្រួតរូត រឿងកដចួតតាំងឡាយ
ផ្សាយសាសនា ក្នុងជុំនវែនវែនកោណឈប់ចរតា ពោករចំះពោះលង្កាកោះ
ស្រស់ស្រាយ ។ មហិន្ទ្រគេកេនុរសក្សត្រ ទទួលបាត់ដំរៀផ្លូវផ្គាំងឆ្ងាយ

ដល់លក្ខសារស័ព្វប្រាប់ចើតតាយ ជនទាំងឡាយឲ្យឥតស្និទ្ធស្នេហា ៗ ទទួលស្តាប់ត្រាប់ត្រងចងជឿជាក់ ទាំងខត្តិយៈជ្ញាក់ពាសពកស្ត្រធម្មតា ខ្វះ ក៏បួសបង់ផ្ទះលះកាមា ទាំងទ្វីបត្រាត្រៀបពៀបពោរពេញ ៗ កាលព្រះសង្ឃកើតកើនច្រើនដល់ម្ល៉ោះ ក៏ស្រួលស្រុះចុះចិត្តប្រិតទន្ទេញ បិដកបីថ្វី មាត់ស្ទាត់ជុំវិញ ពេលនោះម៉ឹញពេញប្រថុងឡើងអស្ចារ្យ ៗ ព្រះមហាទូតេរ មេគណៈ រួមមិត្តភក្តិរៀបរៀងផ្ទៀងធម៌អាថ៌ សូត្រឲ្យសមចំស័ព្ទស្ទាប់វោហារ ទុកជាការទៀងទាត់វត្តប្រតិបត្តិ ៗ លុះកន្លងវេលាជាចំណេរ ពួកព្រះថេរធំៗក្រុមបរិស័ទ សមាគមជំរះព្រះបរិយត្តិ ហើយថែងតាត់តាក់ ដាក់ស៊ុកវិត ៗ តាំងពីព្រះទិញានគ្មានសាស្ត្រា សាសនាចាំស្ទាត់មាត់បណ្ឌិត ទើបព្រះសង្ឃលក្ខតារពិនិត្យ ដោយការគិតត្រូវបំដំបូងដៃ ៗ ពួកបណ្ឌិតមិត្តភក្តិអ្នកប្រាជ្ញប្រាយ អធិប្បាយបាលីបិដកត្រ័យ ពាក្យបង្អៀតច្រៀតតែងថែងកែរ ឧបមេយ្យឧបមាត្រាស្តាប់បាន ៗ ហៅអដ្ឋកថាតារជាច្បាប់ ទុកសម្រាប់រៀនហាត់ស្វាធ្យាយអាន ទើបទិព្វជាន់ក្រោយដោយសណ្ឋាន បែបចំណានពីកេះឈ្មោះដីកា ៗ ត្រូវបិដកបីភាគពាក្យបាលី ពីរថែបច្ចសំដីសីហឡា ទុកជាសូលបណ្តូលគោលសាសនា សូត្រសិក្សាតារ៉ិកហ៊ឹកហ៊ឺនហាត់ ៗ លុះកន្លងវេលាយារយូរណាស់ វស្សៈទ័១០កប់រៀបកាត់ ដែលឥណ្ឌៀដេរជាសត្រាស់បរិស័ទ តែវិបត្តិក្បួនច្បាប់អាប់អួនអស់ ៗ មានបុរសស្រស់ចើតកើតនៅនា ស្រុកពុទ្ធគយា

គ្រាកំឡោះ លះសន្តានស្តានស្តិតឥតស្រណោះ បួសដោយស្មោះដោះ
កាយថ្វាយសាសនា ។ នាមពិរោះឈ្មោះពុទ្ធឃោសៈ ប្រាជ្ញចាក់ចេះ
ចប់សព្វសាស្ត្រា ក៏បានចូលសំពៅទៅលង្កា យកដម្រាបាលីបិដកត្រៃ ។
ទៅផ្ទៀងនឹងបាលីសីហឡា ពួកលង្កាសាទរអរពេកក្រៃ សឹងព្រមគ្នា
ជាមួយជួយពួតដៃ លុបកែខពាក្យខុសគុះហ្គក់ហ្គង ។ ទើបព្រះពុទ្ធ-
ឃោសាចារ្យថែងតាក់ គូតចាំងអដ្ឋកថាដីកាផង ច្បាប់បំណានបាន
ការចារចំឡង ច្បាប់ក្លាយចូលមិនសុទ្ធដុតគ្មានសល់ ។ ហើយប្រែពី
បាលីសីហឡៈ ជាមគធភាសិតឥតសំណល់ នាំមួយចប់ឡប់យកមក
ដំកល់ ដំកើងដល់បុរីដីមគធៈ ។

សាធពេនពេទជន ដែលជាប់ពន្ធដៀពិតគិតបញ្ជាក់ ចូរសង្កេត
រកកាន់គន្ធុរៈ មានលោកអ្នករៀបរៀងទៀងប្រពៃ ។ ឯខ្មែរយើង
ដើងចាស់សាសន៍បុរាណ ប្រើនកប់អានអ្នកតាក្យក្រៃពៃ ព្រាយ
បិសាចក្មូចណាស់ខ្លះគិតភ័យ ខ្មោចទ័ទៃលលកមេកធ្វើគ្នា ។ គ្រៀង
សក្ការស្មាគុមព្រមបាយសី ទំចំណីថ្លុំថ្លោងគោងបូជា លើកអារក្សដាក់
ពោះធ្វើគ្រូគ្រា ខ្មោចបានជាទៅហ្មាយកាយប្រួសស្រី ។

លុះវេលាជាព្រាហ្មណ៍ទាមភារស្រុក ធ្វើអុកឡុកលុកចូលផល្លូមដី
ខ្មែរក៏បែរផ្ទះថ្វាសាជាថ្មី តាមសំដីពួកថ្លាគ្រានោះឯង ។ កាន់ដម្រាប់
ដម្រាសាសនាព្រាហ្មណ៍ គោរពនាមព្រះព្រហ្មចំបំពែង ព្រះឥសូរ

អង់អាចកាចគួរស្ញែង នារាយណ៍តែងស្រោចស្រង់សង្គ្រោះសត្វ ។ ព្រះទាំង ៣ ថ្វីដៃថ្លៃថ្លាស្រស់ ជួយប្រោសប្រស់រំដោះគ្រោះកាចក្ដាត់ ឲ្យសះស្បាងវេតាជាជំកាត់ ស្ងប់វិបត្តិស្ងាត់ភ័យជ័យមង្គល ។

នៅឆ្នាំប្រាំពីររយក្រោយសកកជ មានអ្នកប្រាជ្ញពុទ្ធសាសន៍ផ្លាស ប្រែដំពល សាសន៍ឥណ្ឌាស្យេនបែកជ្រែកជ្រែកទល់ ក្រៀតពន្យល់សាស-នាមហាមុនី ។ ចេតនិកាយក្លាយហៅថា ជាមហាយានៈជាក់ពេញទី សឹង មានមកយូរយារគ្រាកាលពី ទុតិយសង្គីតិនោះឯង ។ នាំឲ្យខ្មែរបែរ បាក់ស្ម័គ្រចិត្តពាស នាហ៊ឺនកស្ដុកប៉ស៊ីប់គ្រប់តំបន់ កន្លងកាល វេលាជាអង្វែង ចាំងស្ដេចស្ដេងចក្រពង្សព្រែងកាន់ផង ។

សកកជរាំងជាងពាន់ឆ្នាំ ទើបនិកាយទក្ខិណៈបាក់មកម្ដង មាន គេជឿជាក់ស្ញាន់កាន់គឹកកង ព្រោះហ្នត់ហ្នងផ្លូវផង់ត្រង់ត្រូវស្អាត ។ ជានិកាយខាងត្បូងហ្វូងថេរ ឬហៅថាហីនយានមានក្រិតខ្នាត ជាពួក ពិតឥតល្អៀងទៀងសុទ្ធសាធ មិនខុសខាតផ្លាតប្លែកបែកបែបចាស់ ។ តែមិនទាន់កើតមានកនសាស្ត្រា ជាដម្រាម៉ាមួនខ្លួនខ្ជាប់ណាស់ រៀនពី គ្នាយារយូរគ្រប់ចាស់ៗ មិនសូវច្បាស់ខ្វះលើសរើសផ្សេងផ្សំ ។

សកកជ ១ ពាន់កាន់ផុតឆ្នាយ ប្រាំពីររយឆ្នាំឆ្ងាយក្សត្រឧត្ដម គ្រង ដែនដីសីហឡៈអ្នកឧបត្ថម្ភ រើរៀបចំចាត់ចែងតែងសាសនា ។ និមន្ត ព្រះកស្សបៈគណៈសង្ឃ ឲ្យជំរង់រៀបរៀងផ្ទៀងសាស្ត្រា សមស្រេច

ស្រេចស្រស់ស្រស់សង្ហា ក៏រេបមាចាររៀងច្រើនជាថ្មី ។ សីហឡទ្ធំបា
មហាច្រើនច្កាន គេរៀបំណានខ្ចរខ្ចាយសាយសំដី សត្វនរខ្វូរខ្វប់លុបព្ទ
ល្បី មកសូមខ្ចីសាស្ត្រាចារជាច្បាប់ ។

ព្រះសង្ឃកម្ពុជាព្យាយាមក្រៃ គ្មានអាល័យជីវិតគិតខ្លាចស្លាប់
ធ្វើដំណើរដើរថ្វាយកាយយ៉ាកយ៉ាប់ ព្រោះចិត្តចាប់ចង់យល់គល់សា-
សនា ។ ចេញចាកពដនាទីទីដែនខ្មែរ ព្រះកត្រៃបរចំពោះកោះលង្កា
រៀនចំណេះចេះស្ដាប់ស័ព្ទភាសា ក្បួនធម្មាមកបែរប្រែខ្មែរបាន ។
ហើយចំឡងចងចារសរសេរច្បាប់ វិលត្រឡប់នាំយកមកវិញថ្កាន ជន
ទាំងឡាយស្មោះសរអរគ្រប់ប្រាណ ប្រឹងរាប់អានគោរពគ្រប់កាយា ។
ឯព្រះសង្ឃអង្គខ្លះឈ្លាសសេចក្ដី ប្រែបាលីនានាជាខេមរ ដូចយើងធ្លាប់
ឃើញស្រាប់ច្បាប់វេទនា ជាសាស្ត្រានិពន្ធជាន់បុរាណ ។ ពីដើមជា
ភាសាបាលីសុទ្ធ កុលបុត្រជាតិខ្មែរប្រែមិនបាន អាស្រ័យបែបបកប្រែ
តែគ្រប់ប្រាណ សំរប់អានមើលមៀងជៀងពុទ្ធដីកា ។

កម្ពុជាបុរីដ៏បុរាណ គេរាប់អានសំខាន់កាន់សាសនា ចំណាយទ្រព្យ
រាប់លានមានប្រាថ្នា ឲ្យមហាជនចៀសកៀសផុតភ័យ ។ សាងអារាម
តាមស្ថានបានស្ថិតស្ថេរ ទុកជាគ្រឿងវរល្អប្រពៃ ជួយវិចិត្រស្អិតស្អាង
សាងវៀងជ័យ ជាស្ថាននៃវេទនាមហាជន ។ ដូចពដ់ការជាន់ចុំថ្ងៃដែស្រស់

តាំងរបស់នានាជាគំនរ សំរាប់មើលកំសាន្តបានសាទរ ឲ្យខ្ទរខ្ទួ ះគ្ដិរឈ្មោះពិរោះឆ្ងាយ ។ ចិញ្ចឹមសត្វចាត់ បួនក្បួនវេទា សួនបុប្ផាសារគាព កបកើតផាយ ចំណាយទ្រព្យរាប់លានគ្មានទឹកស្តាយ ឲ្យសប្បាយដល់ កស្ត្រតាសទូទៅ ។ ធរណីទ័វត្តពុទ្ធសីមា ជាសាលាសិក្សាជាលំនៅ បណ្ណាល័យលោកតាំងក្រាំងសៀវភៅ ច្បាប់ភក់ជ្រៅជ្រាមផែងវែង ផ្ទះថ្វា ។ ក្មេងទីទៃវ័យតិចកិច្ចត្រូវហាត់ មានសម្បត្តិឬទ័លពល់កាយា ឲ្យតែប្រុសទោះអ្នកអនាថា ក៏សិក្សាតាមចិត្តឥតបេញថ្ងៃ ។ កស្ត្រីអ្នក ស្រុកសុខចិត្តឥតនឿយណាយ ជួយចំណាយបាយទឹកព្រឹកល្ងាចថ្ងៃ ទីជំរំណាកដេកដាក់ស្នាក់អាស្រ័យ ជួយកែខៃឲ្យជាតិឃ្លាតល្ងង់ខ្លៅ ។ របៀបកិច្ចរបិចការស្មោធ្យាយទ៌ រៀននិយាយសមគួរសួរញាតិផៅ រៀន សរសេរកំណត់កត់សំញោ ពាក្យប្រដៅផ្លូវលោកយោគធម៌អារ្យ ។ ខ្ទរ បុកណៈបានពឹងនឹងទ័វត្ត រៀនចេះស្ទាត់បានព្រមល្មមប្រើការ វត្តទទួល ផប់លៀងស្បៀងអាហារ គ្រូអាចារ្យមិនបាច់ជាប់ប្រាក់ខែ ។ ទីអារាម តាមរៀបចៀបដោយពិត ដូចដិតែដ៏រពីឪម៉ែ ផ្ទុកច្បាប់ក្បួនជូនថ្នប់គ្រប់ គ្រឹនថៃ កុំបានតែប៉ុណ្ណោះម្ល៉េះសមស្លាត់ ។ ខ្ទរមួយផ្ទុកប៉ែកពួងរងបាប គ្រោះ ហេតុពីព្រោះគ្មានវត្តភ្ជាត់វិបត្តិ អក្ខរៈលាក់ឈើប្រើបញ្ញត្តិ បញ្ញាកាត់គិតស្មានអានផ្សែផ្សំ ។

(នៅមានត)

# លោកគ្រូអាចារ្យប៉ាង-ខាត់ ប្រែនិងរៀបរៀង

(តមក)

ម្នាលមាលុង្ក្យបុត្រ! ព្រោះហេតុនោះ អ្នកទាំងឡាយចូរចាំទុកនូវសេចក្តីដែលតថាគតមិនបានសំដែងហើយ (ព្យាករណ៍) តាមសេចក្តីដែលតថាគតមិនបានសំដែង (ព្យាករណ៍) ហើយទាំងចូរចាំទុកនូវសេចក្តីដែលតថាគតបានសំដែងហើយ (ព្យាករណ៍) តាមសេចក្តីដែលតថាគតបានសំដែង (ព្យាករណ៍) ហើយៈនោះចុះ ។ ម្នាលមាលុង្ក្យបុត្រ! តថាគតមិនបានសំដែងសេចក្តីដូចម្តេចខ្លះ? ម្នាលមាលុង្ក្យបុត្រ! តថាគតមិនបានសំដែងថា "លោកទៀង លោកមិនទៀង លោកមានទីបំផុត លោកមិនមានទីបំផុត ជីវិតនោះក៏គឺសរីរៈនោះ ជីវិតដទៃសរីរៈក៏ដទៃ សត្វស្លាប់ហើយកើតទៀត សត្វស្លាប់ហើយមិនកើតទៀត សត្វស្លាប់ហើយកើតទៀតក៏មាន មិនកើតទៀតក៏មាន សត្វស្លាប់ហើយកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ។ ម្នាលមាលុង្ក្យបុត្រ! ព្រោះទិដ្ឋិនោះមិនប្រកបដោយប្រយោជន៍ មិនមែនជាខាងដើមនៃព្រហ្មចរិយធម៌ មិនប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ ដើម្បីប្រាសចាករាគៈ ដើម្បីសេចក្តីរលត់ទុក្ខ ដើម្បីសេចក្តីស្ងប់រម្ងាប់ ដើម្បីសេចក្តីដឹងច្បាស់ ដើម្បីសេចក្តី

ត្រាស់ដឹង ដឹងដើម្បីព្រះនិព្វាន ព្រោះហេតុនោះ បានជាតថាគតមិនសំដែងទិដ្ឋិនោះ ។

ម្នាលមាលុង្ក្យបុត្រ! ចុះសេចក្ដីដូចម្ដេច ដែលតថាគតតែងសំដែង, ម្នាលមាលុង្ក្យបុត្រ! តថាគតតែងសំដែងថា "នេះទុក្ខ នេះហេតុប្រជុំកើតឡើងនៃទុក្ខ នេះធម៌ជាគ្រឿងរំលត់ទុក្ខ នេះសេចក្ដីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខ" ។ ម្នាលមាលុង្ក្យបុត្រ! ព្រោះហេតុដូចម្ដេចបានជាតថាគតសំដែងពាក្យនុ៎ះ ម្នាលមាលុង្ក្យបុត្រ! ព្រោះថាពាក្យនុ៎ះប្រកបដោយប្រយោជន៍ ជាខាងដើមនៃព្រហ្មចរិយធម៌ ប្រព្រឹត្តទៅដើម្បីសេចក្ដីនឿយណាយ ដើម្បីប្រាសចាករាគៈ ដើម្បីសេចក្ដីរំលត់ទុក្ខ ដើម្បីសេចក្ដីស្ងប់រម្ងាប់ ដើម្បីសេចក្ដីដឹងច្បាស់ ដើម្បីសេចក្ដីត្រាស់ដឹង ដឹងដើម្បីព្រះនិព្វាន ។

ម. ម. មាលុង្ក្យសូត្រ ២៣-២៥៣-១៥០

## កុំប្រកាន់ខ្ជាប់ក្នុងធម៌ តែប្ដូរប្រើគ្រាន់តែជាគ្រឿងសម្រាប់ឆ្លង

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា "ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសដើរផ្លូវឆ្ងាយ បុរសនោះឃើញនូវអន្លង់ទឹកដ៏ធំ មានត្រើយខាងអាយប្រកបដោយសេចក្ដីរង្កៀស ប្រកបដោយភ័យ មានត្រើយខាងនាយក៏ក្សេម ប្រាសចាកភ័យ តែថាទូកក្បូន ឬស្ពានសំរាប់ឆ្លងពីត្រើយអាយទៅត្រើយនាយ មិនមានដល់បុរសនោះឡើយ, បុរសនោះមានសេចក្ដី

ត្រិះរិះយ៉ាងនេះថា "អន្លង់ទឹកដ៏ធំនេះ មាត់ត្រើយខាងអាយប្រកបដោយសេចក្ដីរង្កៀសទីងភ័យ មានត្រើយខាងនាយដ៏ក្សេម ប្រាសចាកភ័យ ទូកក្បូនឬស្ពានសម្រាប់ឆ្លង ពីត្រើយខាងអាយទៅត្រើយខាងនាយក៏គ្មាន បើដូច្នោះមានតែអាត្មាអញប្រមូលស្មៅ កំណាត់ឈើ មែកឈើ នឹងចម្បើងយកមកចងធ្វើជាក្បូន ហើយអាស្រ័យនូវក្បូននោះ ព្យាយាមដោយដៃនឹងជើង ឆ្លងទៅកាន់ត្រើយខាងនាយដោយសួស្ដីបាន ។ ម្នាលភិក្ខុទាំងឡាយ! បុរសនោះក៏ធ្វើតាមគំនិតនោះ ហើយឆ្លងទៅកាន់ត្រើយខាងនាយបានដោយសួស្ដី កាលបុរសនោះឆ្លងទៅដល់ត្រើយខាងនាយហើយ ក៏មានសេចក្ដីត្រិះរិះយ៉ាងនេះថា "ក្បូននេះមានឧបការៈច្រើនដល់អាត្មាអញ, អញបានអាស្រ័យនូវក្បូននេះ ព្យាយាមដោយដៃនឹងជើងឆ្លងមកដល់ត្រើយដោយសួស្ដីបាន បើដូច្នោះមានតែអាត្មាអញលើកក្បូននេះទូលលើក្បាល ឬលើកលីដើរចេញទៅកាន់ទីគួរតាមប្រាថ្នា" ។ ម្នាលភិក្ខុទាំងឡាយ! អ្នកទាំងឡាយសំគាល់សេចក្ដីនោះថាដូចម្ដេច? បុរសនោះធ្វើយ៉ាងនេះ បានឈ្មោះថា ជាអ្នកធ្វើសេចក្ដីសមគួរដល់ក្បូននោះឬទេ? ។ បពិត្រព្រះអង្គដ៏ចំរើន! ហេតុនោះមិនមែនដូច្នោះទេ ។ ម្នាលភិក្ខុទាំងឡាយ! ចុះបុរសនោះធ្វើដូចម្ដេច ទើបបានឈ្មោះថាធ្វើសេចក្ដីសមគួរដល់ក្បូននោះ ។ ម្នាលភិក្ខុទាំងឡាយ! បុរសនោះឆ្លងដល់ត្រើយកន្ទើងណោះ គួរតែត្រិះរិះយ៉ាងនេះថា "ក្បូននេះមានឧបការៈច្រើន

ដល់អាត្មាអញ អញបានអាស្រ័យនូវក្បូននោះហើយ ព្យាយាមដោយដៃទាំងជើងឆ្លងមកដល់ត្រើយនាយបានដោយសួស្តី បើដូច្នោះមានតែអាត្មាអញ លើកក្បូននេះដាក់លើគោកឬពន្លិចទៅក្នុងទឹក ហើយដើរចេញទៅកាន់ទីគួរតាមប្រាថ្នា" ។ ម្នាលភិក្ខុទាំងឡាយ! បុរសនោះដែលធ្វើយ៉ាងនេះបាន ឈ្មោះថាជាអ្នកធ្វើសេចក្តីសមគួរដល់ក្បូននោះ ។ ម្នាលភិក្ខុទាំងឡាយ! ធម៌ឧបមាដូចជាក្បូនដែលតថាគតសំដែងហើយ ដើម្បីឲ្យរលាស់ខ្លួនចេញមិនមែនដើម្បីឲ្យនៅប្រកាន់ជាប់ឡើយ, ម្នាលភិក្ខុទាំងឡាយ! កាលបើអ្នកទាំងឡាយដឹងច្បាស់នូវធម៌ មានឧបមាដូចជាក្បូនដែលតថាគតសំដែងហើយ គប្បីលះបង់ធម៌ទាំងឡាយទ៊ុះចេញ[1] ទីងតាំបាច់ពោលទៅដល់អកុសលធម៌ ។

ម. មូ. អលគទ្ទូបមសូត្រ ២១- ៤៥- ១៨

## ប្រៀបអ្នករៀនអរិយសច្ច ដោយកណ្ដុរបួនពួក

ម្នាលភិក្ខុទាំងឡាយ! កណ្ដុរ ៤ ពួកគឺ កណ្ដុរធ្វើរន្ធតែមិននៅ ១, កណ្ដុរនៅតែមិនធ្វើរន្ធ ១, កណ្ដុរមិននៅផងមិនធ្វើរន្ធផង ១, កណ្ដុរធ្វើរន្ធផងហើយនៅផង ១; ម្នាលភិក្ខុទាំងឡាយ! នេះកណ្ដុរ ៤ ពួក ។ ម្នាលភិក្ខុទាំងឡាយ! បុគ្គលទាំងឡាយដែលឧបមាដូចជាកណ្ដុរទាំងឡាយ ក្នុងលោកនេះក៏មាន ៤ ពួកយ៉ាងនោះដែរ, បុគ្គល ៤ ពួកនោះតើដូចម្ដេច? គឺ

---

១ សមថនឹងវិបស្សនា គឺឲ្យលះឆន្ទរាគៈ ក្នុងសមថនឹងវិបស្សនានោះឯង ។

បុគ្គលផ្គើរន្ទតែមិនទៅ ១, បុគ្គលទៅតែមិនផ្គើរន្ទ ១, បុគ្គលមិនទៅផង មិនផ្គើរន្ទផង ១, បុគ្គលផ្គើរន្ទផងហើយទៅផង ១ ។

១- ម្នាលភិក្ខុទាំងឡាយ ! បុគ្គលផ្គើរន្ទតែមិនទៅនោះតើដូចម្តេច? ម្នាលភិក្ខុទាំងឡាយ! បុគ្គលពួកខ្លះ ក្នុងលោកនេះ រៀនបរិយត្តិធម៌ប្រកបដោយអង្គ ៩ ប្រការ គឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ តែបុគ្គលនោះមិនដឹងច្បាស់តាមពិតថា "នេះទុក្ខ នេះហេតុប្រជុំកើតឡើងនៃទុក្ខ នេះធម៌ជាគ្រឿងរំលត់ទុក្ខ នេះសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខដូច្នេះ" ម្នាលភិក្ខុទាំងឡាយ! បុគ្គលពួកនេះ ផ្គើរន្ទតែមិនទៅយ៉ាងនេះឯង, ម្នាលភិក្ខុទាំងឡាយ! តថាគតសំដែងប្រៀបបុគ្គលពួកនោះថាដូចជាកណ្តរដែលផ្គើរន្ទតែមិនទៅ ។

២- ម្នាលភិក្ខុទាំងឡាយ! បុគ្គលទៅតែមិនផ្គើរន្ទនោះតើដូចម្តេច? ម្នាលភិក្ខុទាំងឡាយ! បុគ្គលពួកខ្លះក្នុងលោកនេះ មិនរៀនបរិយត្តិធម៌ប្រកបដោយអង្គ ៩ ប្រការមានសុត្តៈជាដើមទុះទេ តែបុគ្គលពួកនោះដឹងច្បាស់តាមពិតថា "នេះទុក្ខ នេះហេតុប្រជុំកើតឡើងនៃទុក្ខ នេះធម៌ជាគ្រឿងរំលត់ទុក្ខ នេះសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខដូច្នេះ" ម្នាលភិក្ខុទាំងឡាយ! បុគ្គលពួកនេះទៅតែមិនផ្គើរន្ទយ៉ាងនេះឯង, ម្នាលភិក្ខុទាំងឡាយ! តថាគតសំដែងប្រៀបបុគ្គលពួកនោះថា ដូចជាកណ្តរដែលទៅតែមិនផ្គើរន្ទ ។

៣ — ម្នាលភិក្ខុទាំងឡាយ! បុគ្គលដែលមិននៅផង មិនធ្វើទុក្ខផង នោះតើដូចម្តេច? ម្នាលភិក្ខុទាំងឡាយ! បុគ្គលពួកខ្លះក្នុងលោកនេះ មិនរៀនបរិយត្តិធម៌ ប្រកបដោយអង្គ ៩ ប្រការ មានសុត្តៈជាដើមខ្លះផង មិនដឹងច្បាស់តាមពិតផងថា "នេះទុក្ខ នេះហេតុប្រជុំកើតឡើងនៃទុក្ខ នេះធម៌ជាគ្រឿងរំលត់ទុក្ខ នេះសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខដូច្នេះ" ម្នាលភិក្ខុទាំងឡាយ! បុគ្គលពួកនេះមិននៅផងមិនធ្វើទុក្ខផងយ៉ាងនេះឯង, ម្នាលភិក្ខុទាំងឡាយ! តថាគតសំដែងប្រៀបបុគ្គលពួកនោះថា ដូចជាកណ្តុរដែលមិននៅផង មិនធ្វើទុក្ខផង ។

៤— ម្នាលភិក្ខុទាំងឡាយ! បុគ្គលដែលធ្វើទុក្ខផងហើយនៅផងនោះ តើដូចម្តេច? ម្នាលភិក្ខុទាំងឡាយ! បុគ្គលពួកខ្លះក្នុងលោកនេះ រៀនបរិយត្តិធម៌ប្រកបដោយអង្គ៩ ប្រការ មានសុត្តៈជាដើមខ្លះផង ដឹងច្បាស់តាមពិតផងថា "នេះទុក្ខ នេះហេតុប្រជុំកើតឡើងនៃទុក្ខ នេះធម៌ជាគ្រឿងរំលត់ទុក្ខ នេះសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខដូច្នេះ" ម្នាលភិក្ខុទាំងឡាយ! បុគ្គលពួកនោះធ្វើទុក្ខផងហើយនៅផងយ៉ាងនេះឯង; ម្នាលភិក្ខុទាំងឡាយ ! តថាគតសំដែងប្រៀបបុគ្គលពួកនោះថាដូចជាកណ្តុរដែលធ្វើទុក្ខផង ហើយនៅផង ។

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនាៈ ព្រះគ្រូបញ្ញាលិក្ខិត កៅ-ស៊ុម អ្នកត្រួតត្រាសិស្ស នៅសាលាបាលីជាន់ខ្ពស់

## បញ្ជីរឿង

ទំព័រ

*ផ្នែកអក្សរសាស្ត្រ*

ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម . . . ជម្ពុ ឬ ជម្ពូ សព្ទនេះប្រែថាអ្វី ? . . . . . ២៨១

ខុនញាណ ទេពពិទូរ-ក្រសេម. . . . វណ្ណគតិ រឿងតារាយណ៍ ទសាវតារ(តមក) . . ២៩០

ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម . . . រឿងរ៉ាវរបស់លោកធុតង្គជាតិចិន ១ រូបឈ្មោះ ហ្វូន-ឆាង (តមកនឹងចប់) . . . . . . ២៩៣

" " " ពង្សាវតារប្រទេសចិន (តមក) . . . . . . ៣១១

ឃុនឧត្តមប្រីជា បាប-ពិន . . . អធិប្បាយសុភាសិត (តមក) . . . . . ៣១៦

*ផ្នែកសាសនា*

ព្រះធម្មឡាត់ពោធិភម យូរ-ប៉ុណ្ណ សម្ពុលាជាតក . . . . . . . . . . . . ៣២១

ព្រះអាចារ្យ ប៉ាង-ខាត់ . . . . អរិយសច្ចជាពុទ្ធភាសិត (តមក) . . . . . ៣២៣

លោកអាចារ្យ មៀវ-ឧន្ទ. . . . សាសនាវតារ សង្ខេប (តមកនឹងចប់) . . . ៣៣៤

ឆ្នាំទី ១៣ — លេខ ៦ ខែហ្ស៊ុំង ឆ្នាំ ១៩៤៥ — ដំឡៃជាវៈ ១ ឆ្នាំ ១៥ រៀល ។

ជម្ពុ ឬ ជម្ពូ សព្ទនេះប្រែថាអ្វី?

បើប្រែតាមវចនានុក្រមផ្សេងៗ ដូចមានន័យតទៅនេះ:

ชมฺพุรี: ផ្លែព្រីង, ផ្លែជម្ពូ.

ชมฺพู, ชามฺพู: ដើមព្រីង

ชมฺพู: ផ្លែព្រីង, ផ្លែជម្ពូ.

បាលីលិបិក្រម បាលី-ថៃ ។

ชมฺพุ, ชมฺพู: ជម្ពូ, ព្រីង.

បាលី-ស្យាមអភិធាន ។

ชมฺพุ, ชมฺพู: ជម្ពូទ្វីប, ដើមជម្ពូ.

ชมฺพุผลํ: ផ្លែជម្ពូ.

សំស្ក្រឹត-ថៃ-អង់គ្លេសអភិធាន ។

ព្រឹង (หว้า): ជម្ពរ, ជម្ពូ, ជវណ្ណ ។

វចនានុក្រម ថៃ-បាលី ។

ชมฺพู: ន. (សំ.ម. ជម្ពុ ឬ ជម្ពូ) ព្រីង ។

កើតមានព្រោះផ្លែព្រីងប្រចាំទ្វីបល្មួយជាទីក

ឈ្មោះស៊ុំមួយ

ហូរព្រោះ . . . . . . . ។

**ជម្ពូទ្វីប**: ន. (សំ. ម. ជម្ពុទ្វីប ឬ ជម្ពូទីប) ប្រទេសដែលរុងរឿងត្រដែតត្រដឹម ដោយមានដើមព្រីងធំសំបើមដុះនៅនាក្នុងសុមេរុ ជាគោលចារឹកហៅថាព្រីងប្រចាំទ្វីប, មានផ្លែធំៗ កាលបើទុំជ្រុះចុះមក, លុះដល់រលួយទៅជាទឹកហូរហ្រោះកើតទៅជាស្ទឹងមួយហៅថា ស្ទឹងជម្ពូ; កករដីក្បែរខាងតាំងពីជ្រោះបទឹកផ្លែព្រីងនោះ, លុះត្រូវខ្យល់បក់យូរៗ ទៅក៏ខះស្ងួតក្លាយជាមាសវិសេសមួយយ៉ាងហៅថា មាសជម្ពូនទ ។

**ជម្ពូផល**: ន. (សំ. ម. ជម្ពុផល, ជម្ពូផល) ផ្លែព្រីង, ផ្លែជម្ពូ ។

**ជម្ពូព្រឹក្ស**: ន. (សំ. ជម្ពុវ្ឫក្ស, ជម្ពូវ្ឫក្ស ម. ជម្ពុរុក្ខ, ជម្ពូរុក្ខ) ដើមព្រីង, ដើមជម្ពូ ។

វចនានុក្រមខ្មែរ ។

## ការស្រាវជ្រាវ

តាមវចនានុក្រមផ្សេងៗ ដែលយើងបានស្រង់សេចក្ដីប្រែមកពោលអាងខាងលើនេះ ច្រើនតែមានសេចក្ដីប្រែជាពីរយ៉ាង គឺប្រែថាជម្ពូផង ព្រីងផង វៀរលែងតែវចនានុក្រមពីរ ដែលមានសេចក្ដីប្រែផ្ទុយគ្នា គឺវចនានុក្រមថៃ-បាលី ប្រែថា ព្រីង ១ មុខ មិនប្រែថាជម្ពូទេ ហើយមានវចនានុក្រម ១ ទៀត គឺសំស្ក្រឹត-ថៃ-អង់គ្លេស អភិធាន ប្រែថា ជម្ពូ ១ មុខ មិនប្រែថា ព្រីង ទេ បើដូច្នេះតើ ជម្ពុ ឬ ជម្ពូ សព្ទនេះត្រូវប្រែថាអ្វីជាប្រាកដ?

មុនដំបូងយើងត្រូវស្គាល់លក្ខណៈសណ្ឋាន នៃរុក្ខជាតទាំងពីរប្រភេទនេះ ឲ្យជាក់ច្បាស់សិន គឺៈ

ជម្ពូ : ជាជាតិឈើមានទំហំដើមយ៉ាងកណ្ដាល មានសាច់រឹង មានខ្លឹម ផ្លែប្រើជាអាហារ ជាពូជឈើដំណាំស្រុក មិនមែនជាជាតិឈើព្រៃឬឈើភ្នំទេ មានសំបកដើមសំប៉ុស្រគាប់ស្មើរខ្មៅ ស្លឹកមូលទ្រវែងស្រួចចុងបន្តិចរលើងស្អាត សណ្ឋានស្លឹកស្វាយ តែធំជាងខ្ទើងរលើងស្អាតជាងបន្តិច ។ ពូជឈើនេះ នៅស្រុកខ្មែរមានច្រើនយ៉ាង គឺ ជម្ពូស, ជម្ពូសព្រឿង, ជម្ពូខៀវ, ជម្ពូល័ខ, (មានផ្កាសសុទ្ធ), ជម្ពូក្រហម ជម្ពូជ្រលក់ខាងក្រោយនេះ ជាពូជជាតិឈើតូច ប្រើគ្រាប់សម្រាប់បុកជ្រលក់សំពត់អាវ មានពណ៌ក្រហមព្រឿងៗ ដែលហៅថា ពណ៌សីជម្ពូ ។

ព្រីង : ជាជាតិឈើធំ សាច់រឹង មានខ្លឹម, ផ្លែប្រើជាអាហារ, សំបកដើមក្រាស់ សំបកក្រៅសំប៉ុរស សំបកក្នុងក្រហម ទំហំស្លឹកមូលទ្រវែងតែខ្លីជាងស្លឹកជម្ពូ ហើយរលើងស្អាតដូចគ្នា មានផ្លែតូចៗមូលទ្រវែងបន្តិច ផ្លែខ្ចីសំប៉ុរខៀវ ផ្លែទុំសំប៉ុរខ្មៅរលោង ច្រើនដុះនៅព្រៃនៅវាលស្រែទីងដើងក៏ នៅជិតភូមិជិតផ្ទះអ្នកស្រុកក៏មានខ្លះដែរ ពូជព្រីងនេះមានច្រើនយ៉ាង គឺព្រីងជ័ន្ទន៍, ព្រីងចង្កុះ, ព្រីងជោះក្របី, ព្រីងបាយ..... ។

បើយើងស្រាវជ្រាវរកមើលគម្ពីរដីកា ជាភាសាបាលីទាំងឡាយ ក៏មិនឃើញកន្លែងណា និយាយបញ្ជាក់រឿងនេះឲ្យជាក់ច្បាស់សោះ ។ ប៉ុន្តែ បើតាមពិនិត្យពិចារណាមើលតាមឧទាហរណ៍ នៃជម្ពុ ឬជម្ពូសក្តុ ដែលមានពោលអាងក្នុងគម្ពីរដីកាផ្សេងៗ នោះ ទើបឃើញសេចក្តី ៣-៤ អន្លើ ល្មមបញ្ជាក់យកជាការបានខ្លះ (ដោយកំណត់ទៅតាមរបៀបពៃព្រឹក្សា នៅស្រុកខ្មែរ) ដូចមានឧទាហរណ៍ជាគ្រឿងសំអាងខាងក្រោមនេះ :

## ឧទាហរណ៍ទី ១ :

ក្នុងគម្ពីរវិសុទ្ធិមគ្គ អភិញ្ញានិទ្ទេស ភាគ ២ ទំព័រ ៨២០ បន្ទាត់ ១៥:

" យទា ហិ សោមនស្សចិត្តំ បវត្តតិ, តទា រត្តំ និគ្រោធបក្កសទិសំ ហោតិ ។ ទោមនស្សចិត្តំ បវត្តតិ តទា កាឡកំ ជម្ពូបក្កសទិសំ" ។

"កាលណា ចិត្តសោមនស្សកើតឡើង កាលនោះ ចិត្តនោះមានសំបុរក្រហមបីដូចផ្លៃជ្រៃទុំ ។ (កាលណា) ចិត្តទោមនស្សកើតឡើង កាលនោះ ចិត្តនោះមានសំបុរខ្មៅ បីដូចផ្លៃព្រីងទុំ" ។

ត្រង់ស័ព្ទថា "ជម្ពូបក្កសទិសំ" ក្នុងទីនេះ យើងប្រែថា "បីដូចផ្លៃព្រីងទុំ" មិនប្រែថា "បីដូចជម្ពូទុំ" ទេ ព្រោះផ្លៃជម្ពូទុំនៅស្រុកខ្មែរយើងនេះ ឃើញមានតែសម្បុរស, ក្រហម, ខៀវ ។ ឯផ្លៃព្រីងទុំ

មានតែពណ៌ខ្មៅ ១ មុខ ទុកជាព្រីងប្រភេទណាក៏ដោយ តែទុំជារហើយ រមែងមានពណ៌ខ្មៅរលោងជាដរាប ។

## ឧទាហរណ៍ទី ២:

ក្នុងជម្ពុខាទកជាតក តិកនិបាត ជាតកដ្ឋកថា:

« អតីតេ ពារាណសិយំ ព្រហ្មទត្តេ រជ្ជំ ការេន្តេ ពោធិសត្តោ អញ្ញតរស្មិំ ជម្ពុវនសណ្ឌេ រុក្ខទេវតា ហុត្វា និព្វត្តិ ។ តត្រេកោ កាកោ ជម្ពុសាខាយ និសិន្នោ ជម្ពុបក្កានិ ខាទតិ ។ អថេកោ សិគាលោ អាគន្ត្វា ឧទ្ធំ ឱលោកេន្តោ កាកំ ទិស្វា យន្នូនាហំ ឥមស្ស អភូតគុណកថំ កថេត្វា ជម្ពុបក្កានិ ខាទេយ្យន្តិ ឥមស្ស វណ្ណំ កថេន្តោ ឥមំ គាថមាហ.... ។

« ក្នុងកាលកន្លងមកយូរហើយនោះ ព្រះបាទព្រហ្មទត្តគ្រងរាជ-សម្បត្តិនៅក្រុងពារាណសី ព្រះពោធិសត្វបានទៅកើតជារុក្ខទេវតា នៅក្នុងដងព្រៃព្រីងមួយ ៗ មានក្អែកមួយ ហើរមកទំលើមែកព្រីងនៅដងព្រៃនោះ ហើយចឹកស៊ីផ្លែព្រីងទុំ ៗ ; គ្រានោះមានសត្វចចកមួយដើរមកដល់ (ទីនោះ) ងើបមើលទៅលើឃើញក្អែក (កំពុងស៊ីផ្លែព្រីង)

ក៏គិតថា គួរអញនិយាយបញ្ឆោតក្អែកយកផ្លែព្រីងទុំស៊ីវិញ ហើយតាំងនិយាយសរសើរក្អែកនោះ ពោលជាគាថាដូច្នេះ . . . . ។

និទាននេះបញ្ជាក់ថា ក្អែកធ្លាប់ស៊ីផ្លែព្រីងមកហើយ សូម្បីក្អែកនៅស្រុកខ្មែរយើងសព្វថ្ងៃនេះ ក៏ចូលចិត្តស៊ីផ្លែព្រីងទុំដែរ ។ ហេតុនេះត្រង់ស័ព្ទថា "ជម្ពុវនសណ្ឌេ" ប្រែថា នៅក្នុងដងព្រៃព្រីង ។ "ជម្ពុសាខាយ" ប្រែថា មែកព្រីង ។ "ជម្ពុបក្កានិ" ប្រែថា ផ្លែព្រីងទុំ (មិនប្រែថា ជម្ពុទុំទេ) ។

## ឧទាហរណ៍ទី ៣ៈ

ក្នុងសទ្ធម្មប្បជោតិកា ខុទ្ទកនិកាយ មហានិទ្ទេស និងក្នុងមង្គលត្ថទីបនី ភាគ ៣ ទំព័រ ៦៣៤ បន្ទាត់ ៨ៈ

"ជម្ពុបានន្តិ ជម្ពុផលេហិ កតបានំ" ។

"«គ្រឿងផឹកដែលហៅថា "ជម្ពុបាន" គឺគ្រឿងផឹកដែលគេធ្វើដោយផ្លែព្រីង (ទុំ) ទាំងឡាយ ។

ពាក្យថា "ជម្ពុបាន" ក្នុងទីនេះ ជាឈ្មោះទឹកបាន ១ យ៉ាង ក្នុងចំនួនទឹកបាន ៨ យ៉ាង ទម្លាប់មាត់ហៅថា ទឹកអដ្ឋបាន ។ ជាទឹកធ្វើដោយផ្លែឈើ ដែលព្រះពុទ្ធទ្រង់អនុញ្ញាតឲ្យភិក្ខុសាមណេរឆាន់បានក្នុងវេលាវិកាល គឺវេលាថ្ងៃជ្រៀងជ្រេពីត្រង់ទៅ ។ តាមទំនៀមស្រុកអ្នក

កាន់ពុទ្ធសាសនា គេតែងយកផ្លែឈើធំៗផ្សេងៗ មានផ្លែស្វាយ បេក ស្រគំ ជាដើម ច្របាច់យកទឹកត្រងលាយស្ករធ្វើជាគ្រឿងផឹក សម្រាប់ប្រគេនភិក្ខុសាមណេរឆាន់ក្នុងវេលាល្ងាច ហៅថាទឹកអដ្ឋបាន ។ ឯ "ជម្ពុបានៈ" គេតែងយកផ្លែព្រីងធំ ច្របាច់យកទឹកលាយស្ករ ផ្សំនឹងទឹកធម្មតាតាមសមគួរ ប្រគេនព្រះសង្ឃឆាន់ តាំងពីបុរាណកាលមករហូតដល់មកសព្វថ្ងៃនេះ ទម្លាប់មាត់អ្នកស្រុកហៅថា "ទឹកអដ្ឋបានផ្លែព្រីង" ។ (ឯផ្លែជម្ពូធំនឹងយកមកធ្វើជាទឹកអដ្ឋបានពុំកើត ព្រោះពុំសូវមានទឹកជារសឆ្ងាញ់ពិសាដូចផ្លែព្រីងធំ) ។

## ឧទាហរណ៍ទី ៤ៈ

ក្នុងអដ្ឋកថា អង្គុត្តរនិកាយ ឯកនិបាត កែស័ព្ទ "ជម្ពុទីប" ថាដូច្នេះ "ជម្ពុទីបេតិ ជម្ពុយា បញ្ញាតោ បាកដោ ទីបោតិ ជម្ពុទីបោ ។ ឥមស្ស គិរ ទីបស្ស បញ្ញាណភូតោ យោជនសតុព្វេធោ បណ្ណាសយោជនសាខា បញ្ចទសយោជនវដ្តក្ខន្ធា ហិមវន្តបព្វតេ ជាតា កប្បដ្ឋាយិនី មហាជម្ពូ នាម អត្ថិ ។ តាយ អយំ ទីបោ ជម្ពុទីបោតិ វុច្ចតិ" ។

ត្រង់ស័ព្ទថា "ជម្ពុទីប" សំដៅយកទ្វីបដែលកើតប្រាកដឡើងដោយមានដើមព្រីង (ជាគោល) ហៅថា "ជម្ពុទ្វីប" ។ មានសេចក្ដីដំណាល

ថា ទ្វីបនេះមានដើមព្រីងធំ (មហាជម្ពូ) មានកំពស់ ១០០ យោជន៍ មានមែក (និមួយៗ) ៥០ យោជន៍ មានទំហំដើម ១៥ យោជន៍ ដុះនៅក្នុងហេមពាន្តជាឈើតាំងនៅរហូតអស់កប្ប ។ ដោយហេតុមានដើមព្រីងធំជាគោលនេះ បានជាលោកសន្មតហៅទ្វីបនេះថា "ជម្ពូទ្វីប" ។

តាមទំនៀមទម្លាប់ប្រទេសឥណ្ឌា ប្រហែលជាកំណត់យកជាតិឈើធំជាពូជឈើក្នុ មានសាច់រឹង មានខ្លឹម មានអាយុវែង ទុកជាដើមឈើប្រចាំទ្វីប ។ ប្រហែលជាមិនមែនកំណត់សន្មតយកដើមជម្ពូ ជាជាតិឈើតូច ពូជឈើដំណាំស្រុកនោះទុកជាដើមឈើប្រចាំទ្វីបទេ?

តាមទំនងនេះ ពាក្យថា "ជម្ពូទ្វីប" គួរប្រែថា "ទ្វីបមានដើមព្រីងជាគោលប្រចាំទ្វីប" មិនមែនប្រែថា "ទ្វីបមានដើមជម្ពូជាគោលប្រចាំទ្វីប" ទេ ។

## សរុបសេចក្តី

តាមឧទាហរណ៍ ដែលយើងបានស្រង់យកមកពោលអាងតាំងប៉ុន្មានខាងលើនេះ ល្មមជាគ្រឿងសន្និដ្ឋានបញ្ជាក់បានថា "ជម្ពុ" ឬ "ជម្ពូ" ស័ព្ទនេះគួរប្រែថា "ព្រីង" មិនមែនប្រែថា "ជម្ពូ" ទេ, "ជម្ពូរុក្ខ" ដើមព្រីង, "ជម្ពូផល" ផ្លែព្រីង; ព្រោះប្រការ (១) ដើមព្រីងជាជាតិឈើធំ-

ឈើក្ទី - សាច់វែង - មានខ្ទឹម - សំបកក្រាស់ - អាយុវែង សមជាដើមឈើប្រចាំទ្វីបមែន ។ (២) ផ្លែព្រីងទុំមានសម្បុរខ្មៅ ល្មមយកទៅធៀបនឹងចិត្តទោមនស្សគឺថ្នាំងថ្នាក់អាក់អន់ឬខឹងឃោរ ថាជាចិត្តមានពណ៌ខ្មៅដូចជាផ្លែព្រីងទុំបាន ។ (៣) តាមទំនៀមទម្លាប់ខ្មែរពីបុរាណរៀងមក គេតែងធ្វើទឹកអដ្ឋបាននឹងផ្លែព្រីងទុំ មិនដែលប្រើផ្លែជម្ពូទេ ។ (៤) ក្អែកចូលចិត្តស៊ីផ្លែព្រីងទុំមិនស៊ីផ្លែជម្ពូទុំទេ សមដូចនិទានក្នុងជម្ពូខាទកជាតក ។

ញ-បៃម

បណ្ឌិត នៅពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ.

## រឿងនារាយណ៍ទសាវតារ

# ឧកញ៉ាទេពពិទូរ ក្រសេម រៀបរៀង

(តមក)

បានលិខិតក្នុងសៀវភៅ តាឥន្ទិកៈ (Taindika) ថា ព្រះសិវៈនិងព្រះវិស្ណុនេះជាព្រះរុងរឿងបំផុត, ព្រះសិវៈស្ថិតនៅកំពូលភ្នំ ព្រះវិស្ណុស្ថិតនៅទន្លេគង្គា ។

---

ក្នុងឫគវេទ ព្រះវិស្ណុជាម្ចាស់នៃសេចក្ដីមេត្តាករុណា គេកប់ថា ព្រះជាទ់រងគ្រាន់តែជាអន្ដតំណាងនៃដួងព្រះអាទិត្យ, និយាយរឿងបីជំហានដែលប្រាកដក្នុងពាក្យឆន្ទ សរសើរព្រះជាម្ចាស់ និងក្នុងគម្ពីរព្រាហ្មណ៍សសំដែងឲ្យឃើញថា ក្នុងយុគឫគវេទ គ្រាន់តែជាព្រះនៃសេចក្ដីរុងរឿងនិងអំណាច ក្នុងយជុវេទ ព្រះវិស្ណុរុងរឿងជាង ក្នុងយុគឫគវេទ គឺជាព្រះអង្គរុងរឿងពាល់តែទៅជាវិញ្ញាណនៃសាកលភពដ៏សក្ដិសិទ្ធិ ប្រៀបដូចព្រះព្រហ្មក្នុងគម្ពីរមហាភារតៈ ក្នុងទ័ន្ទះពោលថាព្រះអង្គជាឫសគល់ដើមនៃកំឡាំងនូវសេចក្ដីក្លាហាននៃព្រះឥន្ទ្រ មើលទៅឃើញដូចជាបានទទួលយកឧបនិស្ស័យរបស់ព្រះវរុណៈម្ចាស់នៃការរំដោះបាបចូលផង ទាំងព្រះសិវៈ ទាំងព្រះវិស្ណុជាព្រះកំពូលផុតចិត្តព្រាហ្មណ៍

និងរិះគន់ហើយបានជាទីគោរពរាប់អានរបស់ព្រាហ្មណ៍យ៉ាងស្មោះពិត ប្រាកដ តែគេញែកសេចក្ដីរាប់អានជាពីរពួក គឺ សៃវនិកាយ ពួករាប់ អានព្រះសិវៈ, និងវៃស្ណវនិកាយ ពួករាប់អានព្រះវិស្ណុ ។

កាលដើមឯណោះ ព្រះវិស្ណុជាអរូបទេព ជាម្ចាស់នៃសេចក្ដីល្អ និងមេត្តា បាននាមជាព្រះនារាយណ៍ក្នុងយុគគម្ពីរព្រាហ្មណ៍ ហើយបាន ជាទីរាប់អានដូចអព្សុត, ក្នុងទីខ្លះថា ព្រះអង្គកើតអំពីផ្កាឈូកតាំងនៅ សន្មតថា ស្ដេចស្ថិតផ្ទំលើសេសនាគរាជ ដែលជាភាគ ១ របស់ព្រះអង្គ សេសនាគរាជនេះនៅលើភូមិ (អណ្ដើក) ដ៏ជាភាគ ១ ទៀត វេលាដែល អណ្ដើករម្រើកខ្លួន ជាសំឡេងស្ដេចនាគតើនបន្ទំ ក៏កើតផែនដីញ័រ អ្នក ខ្លះថា ព្រះព្រហ្មកើតអំពីផ្កាឈូក ដែលផុះចេញអំពីនាភី (ផ្ចិត) របស់ ព្រះហរិ, ព្រះសិវៈ កើតអំពីព្រះនលាដៈ ។ តមក សេចក្ដីជឿក្នុងព្រះ ជាម្ចាស់ដ៏ខ្ពស់បំផុតនេះ ក៏ក្លាយមកជារូបទេព ប្រហែលមនុស្សពួក វៃស្ណវនិកាយ, ឯព្រះវិស្ណុពោះអវតារ (បែងភាគ) មកក្នុងមនុស្សលោក ដូចព្រះរាម, ព្រះក្ឫស្ណៈ, ព្រះពលរាម ។

ក្នុងប្រទេសជ្វា សេចក្ដីរាប់អានព្រះវិស្ណុមានតិចជាងព្រះសិវៈ ទោះ បីដូច្នោះក្ដី ក្សត្រជ្វាអង្គខ្លះ ក៏នៅតែជឿថាព្រះអង្គអវតារ មកអំពីព្រះវិស្ណុ, ក្នុងប្រទេសចាមក៏ដែរ រាប់អានព្រះសិវៈនិងព្រះឧមាជាងព្រះវិស្ណុ, និងព្រះ លក្ស្មី, ចំណែកក្នុងប្រទេសកម្ពុជារាប់អានព្រះវិស្ណុជាងព្រះសិវៈ ដែល

ថាដូច្នេះដោយបានសង្កេតឃើញរូបព្រះហរិហរៈ ដែលខ្មែរសាងក្នុងជាន់ដើមសម័យនគរភ្នំ និងនាមព្រះមហាក្សត្រទាំងឡាយ ក៏ច្រើនតែទាក់ទាមដោយនាមព្រះវិស្ណុ (នារាយណ៍) ជាច្រើន, ពួកជាងច្រើនសាងព្រះវិស្ណុជាអនុស្សាវរីយ៍ ស្ថិតនៅលើស្តេចអនន្តនាគរាជ ។

រូបចម្លាក់នៅប្រាសាទវិស្ណុលោក (នគរវត្ត) ដែលទាក់ទាមដោយរឿងព្រះនារាយណ៍មានច្រើនរឿង ដូចយ៉ាងរឿងចម្បាំងរវាងព្រះក្ឫស្ណៈនិងពាណាសូរ; ព្រះក្ឫស្ណៈគង់លើគ្រុឌ, ក្នុងខណៈដែលពាណាសូរទៀបនឹងត្រូវព្រះក្ឫស្ណៈសម្លាប់ ហើយព្រះសិវៈក៏ស្តេចចូលជួយជីវិតពាណាសូរ ដោយត្រាស់ថា ព្រះអង្គទ្រង់ជ្រាបហើយថាព្រះវិស្ណុនោះមានអំណាចខ្ពស់បំផុត គ្មានអ្នកណាអាចឈ្នះបាន តែហាក់ទ្រង់បានសន្យានឹងពាណាសូរថា នឹងជួយឲ្យរស់រួចជីវិត ទើបសូមឲ្យលែងអសុរនោះសិនចុះ កុំឲ្យព្រះវាចារបស់ព្រះអង្គលត់ឥតផលឡើយ ព្រះក្ឫស្ណៈទើបព្រមលែងដោយស្រួលដោយគិតថា ព្រះក្ឫស្ណៈនិងព្រះសិវៈនោះជាអង្គជាមួយគ្នាមិនមែនផ្សេងគ្នាឡើយ ។

ស្ថានសួគ៌ដែលជាទីស្ថិតនៃព្រះវិស្ណុហៅថា "វៃកុណ្ឋៈ" កាលណាលោកមានទុក្ខធុរៈក្តៅក្រហាយជាទម្ងន់ សឹងមិនមានអ្នកណាជួយបំបាត់បាន, ក្នុងឋានដែលព្រះអង្គជាអ្នកបរិហារ ក៏តោងអវតារ (ចែងភាគ) ចុះមកលត់សេចក្តីក្តៅក្រហាយនោះ ស្រេចហើយស្តេចត្រឡប់ឋានវៃកុណ្ឋៈដូច

ដើមវិញ, ការហៅអវតារនេះ ក្នុងគាសាចិនហៅថា អវុប៉ាតោលោ មាន ចំនួនផ្សេងៗគ្នា មិនបានទៀងទាត់ អ្នកខ្លះក៏ថាមាន ២០ ឬ ៣០ តាម បែបដែលនិយម តែដោយច្រើនថា ១០ គ្រា អ្នកប្រាជ្ញខ្លះបុថាមាន ១០ គ្រាក៏ពិត តែដោយខ្វះយកមកអំពីបករណៈក្នុងយុគព្រះវេទមកបំពេញ ចំនួន ដែលកប់ថាមានមែនៗនោះ ក៏គឺព្រះអវតារមកជាមត្ស្យៈ, វរាហៈ នឹងកូម៌ប៉ុណ្ណោះ តាមដែលនិយមដោយច្រើនថាមាន ១០ គ្រា នោះមាន មកហើយ ៩ គ្រា នឹងមានតទៅ ១ គ្រា :

| | | |
|---|---|---|
| ក្នុងកឫតយុគ | ១ | មត្ស្យាវតារ |
| | ២ | កូម៌ាវតារ |
| | ៣ | វរាហាវតារ |
| | ៤ | នរសិង្ហាវតារ |
| ក្នុងត្រៃតាយុគ | ៥ | វាមនាវតារ |
| | ៦ | បរសុរាមាវតារ |
| ក្នុងទ្វាបរយុគ | ៧ | រាមចន្ទ្រាវតារ |
| | ៨ | កឫស្ណាវតារ |
| ក្នុងកលិយុគ | ៩ | ពុទ្ធាវតារ |
| | ១០ | កល្កិយាវតារ |

តាមច្បាប់ហោព្រះសមុតរបស់សៀម មានដែរ ២ ឈ្មោះគឺ

មហិន្ទ្រាគារ ជាត្រីបីត្រៃ ទី៨អប្សរាគារ ជានាងទេពអប្សរទៅកម្រាប់ នន្ទក តែគ្មាន ២ គ្រា គឺបរសុរាមាគារ ទី៩កលក្យាគារ ដូច្នេះគង់ មាន ១០ គ្រាដដែល ៗ

មត្យាគារ = បានមកអំពីភាគវតបុរាណ: មានសេចក្តីថា កាលចុងកល្បមុននេះ មានមហាប្រល័យកើតឡើងព្រោះព្រះព្រហ្មផ្តួលក់ បណ្តាសត្វទាំងឡាយក្នុងលោក ទើបលិចស្លាប់ក្នុងមហាសមុទ្រដ៏ធំផែង ដោយហេតុកាលនោះ ព្រះព្រហ្មលោកងងុយដំ ទ្រង់ប្រាថ្នាទីងសម្រាក ព្រះកាយក្នុងកាលដែលយុគទាំងឡាយកន្លងទៅហើយម្តង ៗ គ្រានោះអសុរអ្នកមានមហាឫទ្ធិឈ្មោះ ហយគ្រីព បានមកជិតព្រះអង្គហើយ លួចយកព្រះវេទ ដែលហូរចេញអំពីព្រះឱស្ឋរបស់ព្រះអង្គ ព្រះហរិ កាលទ្រង់ជ្រាបដូច្នោះ ក៏អវតារព្រះអង្គជាត្រីតូចឈ្មោះសផរិ ទទួល គ្រានោះព្រះមហាក្សត្រទ្រង់ព្រះនាម សត្យព្រត ជាឱរសព្រះសុរិយាទិត្យ ដែលប្រាកដនាមថា វៃវស្វ័ត (វៃវស្វ័ត=ព្រះអាទិត្យ) ជាស្តេចគ្រប គ្រងផែនដី ក្រវិរ: សង្ឃជាព្រះមនុក្នុងកល្បនេះ បានទ្រង់ដងយកត្រី សផរីដាក់ក្នុងផ្តាំង ក្នុងមួយយប់តមកត្រីនោះក៏រីកធំខុសប្រក្រតី ទើប ទ្រង់ផ្ទេរដាក់ក្នុងអាង ខណៈនោះត្រីក៏បណ្តាលឫទ្ធិធំពេញទាំងអាង ទើប ទ្រង់ចាប់យកទៅដាក់ក្នុងស្រះ ទន្ទេក្នុងទីបំផុតទ្រង់យកទៅលែងក្នុង មហាសមុទ្រ ត្រីនោះក៏រីកធំមហិមា ហើយពោលទូលព្រះសត្យព្រតថា

គទៅខាងមុខ ៧ ថ្ងៃទៀតទឹកនឹងលិចលោកទាំងមូល បណ្ដាមនុស្សសត្វនិងព្រឹក្សាជាតិនឹងស្លាប់អស់គ្មានសល់ សូមឲ្យទ្រង់យកកេក្រោដ៏ធំ ១ ទៅទទួលយក សប្តឫសី[1] និងសត្វផ្សេងៗ ក្នុងមួយមុខ ១ គូ នូវពូជព្រឹក្សជាតិគ្រប់យ៉ាងដាក់ឲ្យពេញក្នុងកេក្រោធំនោះ ទុកសម្រាប់ធ្វើពូជ កាលទឹកធំលិចមកដល់ ឲ្យយកនាគជាខ្សែចងកេក្រោសណ្ដោងនឹងស្នែងត្រី (សង្ការ) នោះ ៗ កន្លងមក ៧ ថ្ងៃទឹកក៏លិចមកមែនដូចត្រីថា ត្រីបាននាំកេក្រោធំឲ្យផុតអំពីគ្រោះអន្តរាយទៅបាន ៗ សប្តឫសី (ឫសីទាំង៧) បានសុំពរព្រះហរិនឹងព្រះព្រហ្មឲ្យជួយប្រោសផែនដី លុះទឹកស្រកហើយព្រះវិស្ណុនឹងព្រះព្រហ្ម ក៏ផុះឡើងអំពីមហាណ្ណពព្រមគ្នា ត្រីសង្ការក៏មុជចុះទៅ, បាតសមុទ្រ ដើម្បីស្រាវជ្រាវរកព្រះវេទបានប្រទះនឹងហយគ្រីព ក៏កើតដណ្តើមព្រះវេទគ្នាឡើង កក្រើកបាតសមុទ្រ ក្នុងទីបំផុតអសុរបរាជ័យ ព្រះវិស្ណុទើបបាននាំយកព្រះវេទឡើងមកថ្វាយព្រះព្រហ្ម រួចស្ដេចត្រឡប់ឋាននៃវៃកុណ្ឋៈ ព្រះព្រហ្មបានឲ្យពរ ឲ្យព្រះមនូជាជនករបស់លោក ជាអ្នកសាងសត្វទាំងពួង ជាបឋមបុរសក្នុងលោក ៗ

---

១ ម្យ៉ាងទៀតហៅថា ប្រជាបតី ជាមានសបុត្ររបស់ព្រះព្រហ្មដោយព្រះអង្គនោះឲ្យកំណើតដោយចិត្ត មិនបានកើតអំពីគភ៌យ៉ាងទេវតានិងមនុស្សផងទេ, ប្រាកដនៅក្នុងផ្ទៃមេឃជាផ្កាយ ៧ ដួង ដែលខ្មែរហៅថាផ្កាយក្ញពើ, បារាំងសែសហៅថា Pleiades ដែលមកក្នុងសតវត្សទី ១៦ បានក្លាយទៅជាឈ្មោះសមាគមអ្នកនិពន្ធ មាន Ronsard ជាអធិបតី ៗ

ព្រះមនុដែលពោលនេះជាអង្គទី ៧, អង្គទី ១ នោះព្រះស្វយម្ភូវៈក្នុងគម្ពីរមានវេទមិពោលថា - កាលព្រះអាត្មាមានព្រះរាជឫទ័យប្រាថ្នានឹងសាងសត្វផ្សេងៗទាំងពួងនោះបានទ្រង់សាងទឹកមុន ហើយបណ្ដុះពូជដែលកើតជាពង ព្រះអង្គឯងក៏បានកំណើតនៅក្នុងពងនោះជាព្រះព្រហ្ម ហើយទើបបានសាងលោកតទៅ ។ ចំណែកឯក្នុងគម្ពីរព្រហ្មបុរាណៈពោលថា កាលចេញអំពីពងមកហើយ ចែកចេញជា ២ ភាគគឺបុល្លិង្គនឹងឥត្ថីលិង្គ ។ ជួយគ្នាសាងព្រះវិស្ណុ, ព្រះវិស្ណុទើបសាងបុរសទី ១ គឺវិរាជ, វិរាជបានសាងព្រះមនុស្វយម្ភូវៈ, ក្នុងមត្ស្យបុរាណៈពោលថា ព្រះព្រហ្មបានសាងនាង ១ អង្គទៀតឈ្មោះសតរូបា (សរស្វតី) ហើយបានបបួលគ្នាសាងសត្វមានជីវិតគ្រប់ប្រភេទឡើង ទាំងពីរអង្គនៅក្នុងទីរហោឋានជាមួយគ្នា ១០០ ឆ្នាំសួគ៌ ទើបបានកើតព្រះមនុទី ១ គឺស្វយម្ភូវៈនឹងវិរាជ ។ ក្នុងរឿងនារាយណ៍ស៊ុបប៉ាន់របស់សៀម មានពោលដល់រឿងព្រះបរមេស្វរ ទ្រង់សំលេះយកព្រះមង្សៈ (សាច់) ក្នុងព្រះឧរៈចេញមកហើយទ្រង់បណ្ដាលឲ្យក្លាយទៅជាផែនដី យកព្រះចុឡាមណីជោតជាភ្នំព្រះសុមេរុនឹងសាងទេវតា, តមកព្រះឥស្វរក៏ទ្រង់សាងវៃត្រកព, ទេវតាសាងយានពាហនៈ, ព្រះព្រហ្មធាតាប្រដៅព្រះវេទ, ព្រះនារាយណ៍ប្រដៅ

(នៅមានត)

## រឿងរ៉ាវរបស់ស្មលាគាធុតង្គជាតិចិន ១រូប

### ឈ្មោះ ហ្វួន - ឆាង

# ហ្យួងតិពគួមត្រៃញ៉ាក - ប៊ិម

[ស្រង់និងប្រែចេញអំពីសៀវភៅ Religieux et hélerins en terre d'Asie របស់លោក goloubev សមាជិកសាលាបារាំងសែស ចុងបូព៌ាប្រទេស

(តមកនិងចប់)

គឺដោយសារលោកនេះហើយ ទើបគេអាចចាត់ចៀបរៀបចំបានខ្លះ បំភ្លឺត្រង់កន្លែងខ្វះខាតក្នុងពង្សាវតារ និងភូមិសាស្ត្ររបស់ឥណ្ឌា នៅសត-វត្សរ៍ទី ៧ បានខ្លះទៀតផង" ។

ពួកជនជំនាន់លោក ហ្វួន-ឆាង បានពោលសរសើរប្រាប់យើងថា "លោកជាមនុស្សមានរាងកាយខ្ពស់ មានឫកពាជាអ្នកអង់អាចមានក្លា-ហាន ។ ទ្រង់ទ្រាយរបស់លោកនោះឆើតឆាយថ្លៃថ្លា ។ សូរស័ព្ទសំឡេងលោកស្អាតផ្ចិតផ្ចាច ចូលទៅក្នុងត្រចៀករបស់អ្នកស្ដាប់ សំដីលោកនិយាយចេញមកនោះថ្លៃថ្លាគួរជ្រះថ្លា ទាំងក្រោះក្រាយហើយពីរោះស្ដាប់ តាប់ត្រចៀកអ្នកផង ពួកអ្នកស្ដាប់មិនដែលនឿយណាយធុញទ្រាន់នឹងស្ដាប់សំដីរបស់លោកឡើយ.... ។ លោកគាប់ចិត្តប្រើតែសំពត់អម្បោះ មានសរសៃឆ្មារដែលសមរម្យនឹងរាងកាយរបស់លោក ឯដំណើរដើររបស់លោកនោះសុភាពរៀបរយស្រួលបួលជានិច្ច លោកតែងក្រឡេកមើលត្រង់ទៅខាងមុខ មិនដែលគោលក្លែកក្រឡេកមើលឆ្វេងស្ដាំសោះឡើយ ។

លោកជាមនុស្សច្រើនរុងរឿងណាស់ ដូចមហាគង្គាដែលព័ទ្ធឡោមហោម ជុំវិញដោយពសុធា លោកជាអ្នកស្ងប់ស្ងាត់ ហើយលេចត្រដែតឡើង ដូចជាផ្កាឈូក ដែលដុះដុះទៅកណ្ដាលភក់ ... ។ ប្រសិនបើយើងនឹករលឹកទៅនឹងឃើញថា ពួកជនជាតិហិណ្ឌូទាំងឡាយ មានចិត្តចាប់ភ្លឹកនឹកជ្រះថ្លាស្រឡាញ់ចំពោះបុគ្គលិកលក្ខណៈ ដ៏មានអំណាចរបស់លោកជាមិនខាន ទើបគេមិនបាច់ងឿងឆ្ងល់ពីការដែលលោកហ្វូន-ឆាង បានទទួលកិត្តិយសជាគ្រូមោគ្រប់ៗ ក្រុងក្នុងប្រទេសឥណ្ឌានោះឡើយ គឺនៅគ្រប់ៗតំបន់ ដែលល្បីល្បាញថាមានមហាវិទ្យាល័យពុទ្ធសាសនា ឬដែលមានកេរ្តិ៍ដំណែលជាប់ទាក់ទងនឹងពុទ្ធប្បវត្តិ ។ ព្រះមហាកជាឥណ្ឌាទាំងឡាយ ទោះបីព្រះមហាក្សត្រអង្គណាដែលមិនបានប្រតិបត្តិតាមធម៌របស់ព្រះពុទ្ធជាម្ចាស់ ក៏គង់តែខ្វល់ខ្វាយដណ្ដើមគ្នាទទួលលោកដើម្បីជាកិត្តិយស ព្រមទាំងប្រគេនគ្រឿងសក្ការបូជានឹងសំដែងសេចក្ដីគោរពដ៏ស្មោះស្ម័គ្រចំពោះលោកផង" ។

ក្នុងចំណោមព្រះមហាក្សត្រអស់នោះ មានព្រះមហាក្សត្រ ១ អង្គមានវិទ្ធានុភាពច្រើនជាងគេ ក្នុងកាលនោះ គឺព្រះបាទហស្សសី-លាទិត្យៈ ដែលទ្រង់បានគ្រប់គ្រងលើភាគផែនដីធំ នៃប្រទេសឥណ្ឌាខាងជើង ។ កាលទ្រង់បានជ្រាបថា លោកហ្វូន-ឆាង បាននិមន្តចូលទៅប្រទេសអស្សាំ ហើយជិតចេញពីប្រទេសឥណ្ឌា ដោយមិនបានទៅ

កាត់ទ័ពក្រុងរបស់ទ្រង់ដូច្នោះទ្រង់ក៏ហាត់ព្រះរាជសារឲ្យនាំទៅទីមន្ទីរលោក មកចូលក្នុងព្រះនគររបស់ព្រះអង្គដោយខានពុំបាន ។ លោកហ្វូន-ឆាង ក៏ទិមន្ទ្រប្រាសទឹកឡើងទៅតាមដងទន្លេគង្គា រហូតដល់ស្រុកកានោជនិង ប្រយាគ (អល្លាហាបាត) ដោយលោកគង់លើក្បូនខ្ទូខ្នាតតូច ១ ក្បូន នាំលោកឡើងទៅ ។ មានក្បូនហែយ៉ាងធិចធិនដោយដំរី ហែលោកឡើង ទៅតាមបណ្ដោយដងទន្លេ ។ នៅវេលាដែលព្រះបាទហស្សិសីលាទិត្យ នឹងលោកហ្វូន-ឆាងជួបប្រទះគ្នានោះត្រូវជាពេលព្រលប់យប់សន្ធ្យា ទើប មានចន្លុះអុជបំភ្លឺជាច្រើនពាន់ ភ្លឺឆ្លុះទៅក្នុងទឹកព្រះគង្គាដែលមានខ្សែទឹក ហូរសន្សឹមៗ ។ នៅសព្វទិសទីតំបន់ នៅតែឮបាទ្យត្រូវរាយស្គរតូច-ធំនឹង ទ្រហឹងអឺងកង ។ ព្រះមហាក្សត្រទ្រង់ក្រាបថ្វាយបង្គំដល់ដីដោយសេចក្ដី គោរព រួចទ្រង់ "បាចបុប្ផាផ្កានៅខាងមុខលោក ហើយទ្រង់ទតលោក ដោយព្រះទ័យបីតិរីករាយជាទីបំផុត ហើយទ្រង់ថ្លែងព្រះឱស្ឋសរសើរ លោកដោយអនេកបរិយាយ" ។ លោកហ្វូន-ឆាង បានគង់នៅជិតព្រះ មហាក្សត្រពេលជាច្រើនខែ ។ ដើម្បីជាកិត្តិយសដល់ការនិមន្តលោក មកនោះ ព្រះបាទហស្សិសីលាទិត្យៈទ្រង់បំណាយចាយចែកព្រះរាជទ្រព្យ ព្រះរាជទានជាព្រះរាជកុសល អស់វេលាមិនតិចជាង ៧៥ ថ្ងៃឡើយ ។ ព្រះអង្គទ្រង់ខំខ្វល់ខ្វាយធ្វើទាននោះ ទាល់តែព្រះរាជទ្រព្យទាំងអស់ ដែលបានសន្សំទុកមកអស់វេលា ៥ ឆ្នាំ ក្នុងព្រះឃ្លាំងនោះ ត្រូវដកហូត

យកមកចែកចាយចំណាយព្រះរាជទានអស់ហើយ ។ ព្រះរាជទ្រព្យទាំងនោះ នៅសល់តែដី, សេះ, និងគ្រឿងអាវុធយុទ្ធភណ្ឌ ដែលជារបស់សម្រាប់ការពារព្រះនគរប៉ុណ្ណោះ ។ ទ្រង់បានព្រះរាជទានជាទាននោះ ហេតុដល់ទៅត្បូងពណ៌ក្រហមដ៏មានពន្លឺរស្មីនៅនឹងព្រះមាលា ទាំងព្រះពស្ត្រសម្រាប់ទ្រង់ ក៏ផ្ដាស់ចេញធ្វើជាទានហើយទ្រង់យកព្រះភូសាចាស់មកទ្រង់ជំនួសវិញ ។ លោកហួន-ឆាង ទឹកស្ងើចនឹងសទ្ធាជ្រះថ្លារបស់ព្រះមហាក្សត្រមួយអង្គនោះពន់ពេក ។ ប៉ុន្តែនៅតែលោកមិនព្រមអនុលោមតាម នៅវេលាដែលព្រះមហាក្សត្រនោះ ទ្រង់សុំអារាធនាឲ្យលោកគង់សំណាក់នៅក្នុងប្រទេសឥណ្ឌាតទៅទៀត ។ លោកបដិសេធយ៉ាងដាច់ខាត មិនព្រមទទួលយកគ្រឿងសក្ការបូជា នឹងហិបដែលពេញទៅដោយដុំមាសទាំងឡាយ ដែលក្សត្រទាំងឡាយ មកជួបជុំនៅក្នុងរាជសំណាក់ព្រះបាទហស្សសីលាទិត្យៈ នាំមកបូជាលោកនៅវេលាមុនលោកនឹងចេញដំណើរទៅ ។ លោកទទួលយកតែសំលៀកបំពាក់ ១ សម្រាប់ ធ្វើពីរោមសត្វសាច់ម៉ដ្ឋធារ ដែលស្ដេចស្រុកអស្សំបានប្រគេនលោក សម្រាប់ប្រើប្រាស់ការពារគេចលំនឹងអាកាសសើមត្រជាក់ភ្លៀងផ្គរ នៅវេលាធ្វើដំណើរដើរផ្លូវ ។

លោកហួន ឆាង កាលនឹងត្រឡប់ចូលទៅស្រុកចិនវិញ លោកបានដើរកាត់ភ្នំហិណ្ឌូ-គូស និងដែនបាមៀរម្ដងទៀត ប៉ុន្តែលោកមិនបាន

ធ្វើដំណើរទៅតាមស្តុកដ្យ៉ាន ទឹងភ្នំតៀន - ឋាន នៅខាងជើងសមុទ្រ ខ្សាច់គូប៊ី លោកត្រឡប់ដើរតាមផ្លូវទិសខាងត្បូងកាត់ស្រុក ក័ចគារ, យ៉ារកាន្ទទឹងលេម៉ូ - ឡានវិញ ។

កាលគេបានដំណឹងនៅស្រុកលោ - យ៉ាង ដែលជាទីក្រុងរបស់ ព្រះរាជាធិរាជ វ៉ង្ស - តាង ថាលោកធម្មសាមីហ្វួន - ឆាង បានត្រឡប់ មកពីប្រទេសឥណ្ឌាជាមួយទឹងកងកាក់ក់ាន មានសេះចំនួន ២២ សម្រាប់ ផ្ទុកព្រះសារីរិកធាតុនិងគម្ពីរដីការបស់ពុទ្ធសាសនាដូច្នោះ ។ ទើបមាន ប្រជុំជន ១ក្រុមធំនាំគ្នាលើកចេញទៅទទួល ដើម្បីជួបនឹងលោកព្រមទាំង ភ័ក្ត្រា,ឆត្រ ( ក្លស់ ) នឹងទង់ប៉ាក់ជាយសូត្រ ។ ជនទាំងអស់នោះ សុទ្ធតែ ស្លៀកពាក់តាមរបៀបពិធីបុណ្យ ( ពេញយស ) ទាំងអស់ ។ ពួកអ្នក តំណាងព្រះរាជាធិរាជនាំគ្នាដើរនៅខាងក្បាលក្បួនហែ ។ គេនិមន្តលោក ធុតង្គនេះឲ្យគង់នៅក្នុងទីដ៏ថ្កុំថ្កើងថៃថ្លាតឹមទូរភ័ក ដែលបាត់បម្រុងទុក សម្រាប់ពួកភជទូត នោះឯង ។ ចំណែកគម្ពីរដីកាចំនួន ៦៥៧ គម្ពីរដែល លោកបាននាំយកមកអំពីប្រទេសឥណ្ឌា ព្រមទាំងព្រះពុទ្ធរូបមាស- ប្រាក់-ឈើមានដម្លៃទាំងឡាយ (ចំនួនក្រហមជាដើម) គេនាំយកទៅ ដំកល់ទុកក្នុងវត្តប់រមសុខ ដែលនៅជិតទីក្រុងនោះឯង ។

លុះលោកបានសម្រាកល្ហមបាត់នឿយហត់ពីការធ្វើដំណើរហើយ លោកធម្មសាមីក៏និមន្តចូលទៅគាល់ព្រះរាជាធិរាជ តៃ-ធុង ដែលទ្រង់

បានទទួលលោកក្នុងព្រះរាជវាំងមន្ទីរ ដ៏មានពួកក្រុមប្រឹក្សាទីវាំងសេនាបតី អង្គុយគាល់ទ្រៀបត្រា ។ ព្រះរាជាធិរាជទ្រង់មិនបានបន្ទោសលោក អំពីដំណើរដែលចេញពីស្រុកទៅដោយឥតមានអនុញ្ញាតអំពីទ្រង់នោះទេ ទ្រង់បែរជាមានព្រះឱង្ការសរសើរលោក អំពីលោកសុំប្រថុយជីវិត ដើម្បីសិរីសួស្តីនិងសេចក្តីសុខសប្បាយដល់មនុស្សលោកទាំងមូល ។ រួចទ្រង់បានព្រះរាជទានដំណែងដ៏ខ្ពង់ខ្ពស់ដល់លោកហ្វូន-ឆាង ក្នុងរាជសំណាក់របស់ព្រះអង្គ តែលោកហ្វូន-ឆាងមិនព្រមទទួលកិត្តិយសនេះ ដ្បិតលោកទទួលសជីវិតថ្វាយក្នុងសាសនារួចស្រេចហើយ ។ លោកក្រាបទូលសុំព្រះរាជាធិរាជ ដើម្បីចំរើនប្រែប្រែគម្ពីរជាភាសាសំស្ក្រឹតដែលគេបានយកទៅដាក់ទុកក្នុងវត្តនោះ នៅវេលាដែលលោកត្រឡប់មកអំពីប្រទេសទិសខាងលិច ។ ព្រះរាជាធិរាជ ទ្រង់ព្រះអនុញ្ញាតយល់ព្រមតាមសេចក្តីសុំនោះ ហើយទ្រង់តាក់តាំងលោកសង្ឃ ១២ រូបជាជំនួយលោក សុទ្ធតែជាអ្នកចេះដឹងមុតមាំ ចេះពន្យល់សេចក្តីក្នុងគម្ពីរដីកាឲ្យមកជួយធ្វើការប្រែរួមជាមួយនឹងលោកផង ក្នុងរវាងប៉ុន្មានឆ្នាំតៗមក លោកធម្មសាមីបានតែងសេចក្តីកត់ត្រាពីការដំណើររបស់លោក អំពីប្រទេសទាំងឡាយនៅទិសខាងលិច (តាតាំងស៊ីយូគី) ដែលលោកបានកត់ត្រាទុកមកមានចំនួនដល់ ១២៨ នគរ សុទ្ធតែជាដែនដីដែលលោកបានចូលទៅមើលឃើញក្នុងវេលាធ្វើដំណើរដើរផ្លូវឆ្ងាយជាយូរអង្វែង

នោះ ឬដែលលោកបានឮគេនិយាយប្រាប់ ៗ លោកបាននិមន្តចេញទៅពីវត្តបរមសុខ នៅរជ្ជកាលព្រះរាជាធិរាជ កៅ-ធុង ជាព្រះរាជបុត្រនឹងជាតំណរាជ្យ របស់ព្រះបាទព្រះមហាថៃ-ធុង ស្ដេចចេញទៅតាំងទីក្រុងនៅស្រុកចាង-អាន (ស៊ីអាន-ហ្វូ) ៗ គេនិមន្តលោកឲ្យទៅតាមព្រះមហាក្សត្រអង្គនោះ លោកក៏បានទៅនៅសំណាក់ក្នុងវត្តធំមួយជិតទីក្រុងនោះ ដែលទើបនឹងកសាងហើយស្រេច ៗ ទីដីរបស់វត្តនេះមានទំហំជាច្រើនលី ៗ ដីវត្តនេះនៅក្បែរដើមសំបួរមាស មានជ្រោះទឹកវង់ថ្មមានលំអរដោយខ្សែទឹក ៗ គេក្រឡេកមើលពីទីនោះទៅឃើញព្រះពន្លា, ប្រាង្គ, ប្រាសាទ នឹងកេងទង ដែលមានសសរក្ដិចខ្ចៅដូចពណ៌មាស ចាំងភ្លឺភ្នែកអ្នកដែលក្រឡេកមើលទៅចំ ៗ ហើយមើលទៅឆ្ងាយទៀតទៅ ឃើញមានភូមិស្រុកជាច្រើន មានផ្សារលក់ដូរគុះគរស្នូរស័ព្ទអឺកធឹក ឃើញមានស្រែស្រូវនឹងគុម្ពស្មៅខៀវស្រងាត់ នៅទីវាលស្មៅ មើលទៅឃើញមានម្លប់ពពកស ៗ គ្របបាំងពីខាងលើទីវាលនោះ ៗ គេស្មានមើលទៅប្រហែលជា នៅទីក្រុងចិននោះមិនមានទីវត្តណាមួយ ដែលល្អនឹងថ្លៃថ្លាជាងវត្តនោះទៅទៀតឡើយ ទាំងតាក់តែងរៀបរៀបចំល្អជាងវត្តនោះក៏គ្មានដែរ ប៉ុន្តែសម្រាប់លោកហួន-ឆាង មិនមែនលោកប្រាថ្នាចង់សំណាក់នៅក្នុងកន្លែងដូច្នោះទេ ៗ លោកខំខ្វល់ខ្វាយធ្វើការនៅទីនោះ ស្ទើរតែនឿយហត់ហួសកំឡាំងសម្រាប់មនុស្សអាយុ

បំណាស់លោក មួយយ៉ាងទៀត លោកគិតថា លោកមានជីវិតរស់នៅទៀតនៅតិចឆ្នាំទេ ។ លោកបានទទួលព្រះរាជានុញ្ញាតអំពីព្រះរាជាធិរាជឲ្យនិមន្តទៅនៅជាមួយនឹងពួកសាវកនឹងពួកអ្នកចម្លងគម្ពីរដើម ក្នុងវត្តមួយដែលបានរៀបចំទុកមិនបានថ្លៃថ្នូប៉ុន្មានទេ ប៉ុន្តែលោកអាចធ្វើការបានដោយងាយស្រួលក្នុងទីវិវេកនឹងស្ងប់ស្ងាត់ដូច្នោះ ។ នៅវត្តហើយ (វត្តស្លឹកឈើណាស់សន្ទុក) ក្នុងឆ្នាំគ្រិស្តសករាជ ៦៦០ នោះ លោកបានចាប់ផ្ដើមប្រែគម្ពីរប្រាជ្ញាបារមីតា-សូត្រ ដែលជាគោលចារិកដ៏សំ-ខាន់មួយ របស់ព្រះពុទ្ធសាសនាបែកខាងមហាយាន ។ លោកបានរើរៀបទុកមកមុនហើយយ៉ាងស្អាតហ្មត់ចត់ ចំពោះគម្ពីរដើមដែលជាភាសាសំស្ក្រឹត ដោយបានចម្លងចេញជា ៣ ច្បាប់ ដែលលោកបាននាំយកមកអំពីប្រទេសឥណ្ឌា កាលពី ១៥ ឆ្នាំមុននេះ ។ "កាលណាលោកបានប្រើគំនិតគិតជ្រាលជ្រៅក៏កើតពន្លឺច្បាស់ឡើង ត្រង់កន្លែងណាដែលនៅសង្ស័យ ឬរើរៀបជាថ្មីត្រង់កន្លែងដែលបាត់បង់ទៅ គេយល់ថា ទេពតាមកប្រាប់ពន្យល់លោក ត្រង់កន្លែងណាដែលលោកខំគិតគេនោះ ។ ក្នុងវេលានោះ វិញ្ញាណរបស់លោកក៏រុងរឿងឡើង ដូចជាមនុស្សដែលនៅក្នុងទីងងឹត បានឃើញព្រះអាទិត្យទម្លុះពពកចុះមក ហើយចុះពន្លឺរស្មីព្រោងព្រាត ។ ប៉ុន្តែលោកនៅតែមិនទាន់ទុកចិត្តនឹងសតិបញ្ញារបស់លោកទេ សេចក្ដីអាថ៌កំបាំងទាំងប៉ុន្មាន លោកគិតថា

សម្រេចមកនៃអំពីព្រះពុទ្ធនឹងព្រះពោធិសត្វ" ។ នៅក្នុងខណៈនោះ លោកមានអាយុដល់ ៦៩ ឆ្នាំហើយ ។

ដំឡៃនៃការដ៏ធ្ងន់ស្មើរតែហួសវិស័យមនុស្សធម្មតា ក្នុងវេលានោះ គឺការដែលបានប្រែបញ្ចប់គម្ពីរផៃលា្ណ រួចលោកធ្វើសេចក្ដីស្នើសុំទៅក្នុងវាំង គឺសុំឲ្យព្រះរាជាធិរាជទ្រង់និពន្ធអារម្ភកថា ដាក់ក្នុងគម្ពីរដីកានោះ ដែលលោកបានទុកដូចជាកិច្ចការស្នាដៃយ៉ាងធំថ្លៃថ្លា ក្នុងជីវិតរបស់លោក ។ ព្រះមហាក្សត្រក៏ទ្រង់ទទួលយល់ព្រមតាមសេចក្ដីសុំនោះ ។

លោកហួន-ឆាង លោកបានរៀបហត់អស់កំឡាំង ដោយអត់ងងុយជាវេលាយូរ ដល់ឥឡូវនេះលោកត្រូវឈឺបង្ក្រាក ។ មានតែការអន្តរាយរបស់ពួកសាវ័កនឹងអ្នកជំនួយនោះហើយ ដែលនាំឲ្យលោកពេញចិត្តចាប់ផ្ដើមធ្វើការដោយសេចក្ដីប្រឹងប្រែងតទៅទៀត ។ ប៉ុន្តែដល់លោកខំប្រឹងចំឡងព្រះសូត្រ ១ បានប៉ុន្មានបន្ទាត់ជាអក្សរចិន ស្រាប់តែកំឡាំងលោកទន់ខ្សោយអស់ទៅ ។ ពិតសរសេររបស់ធ្លាក់ពីដៃទៅ ។ ចាប់តាំងពីខណៈនោះមក និយាយតាមប្រវត្តិរបស់លោកថា "លោកលែងប្រែគម្ពីរ លោកយកចិត្តទុកដាក់តែកិច្ចវត្តខាងសាសនាប៉ុណ្ណោះ" ។

ក្នុងរវាង ៣ ឆ្នាំតមក, ក្នុងខែទី ១ នៃរដូវរំហើយ ( ស្វឹកឈើលាស់សន្ទឹក ) ឆ្នាំលិនតេទី ១ ( ៦៦៤ ) ក្នុងថ្ងៃទី ៤ វេលាល្ងាច លោកត្រូ

( ហួន - ធាង ) ខិមក្នុងដើរកាត់ស្ពានជូនព្រែកដីកមួយ ដែលនៅខាងក្រោយកុដិលោក ស្រាប់តែលោកជួលដល់របួសបេកជើងលោក ៗ គ្រោះថ្នាក់នេះមិនជាធ្ងន់ទេ ប៉ុន្តែពកនិកាយលោកហួន - ធាង ដែលលោកបានប្រើប្រាស់មកដោយសេចក្ដីទៀងទាត់ ដែលលោកបានប្រព្រឹត្តមកអស់វេលាជាច្រើនឆ្នាំ ( នាំឲ្យទៅជាជម្ងឺធ្ងន់ ) ៗ មិនយូរប៉ុន្មានក៏មានជម្ងឺគ្រុនកើតប្រាកដឡើង លោកក៏ស៊ីងនៅតែលើគ្រែប៉ុណ្ណោះ ៗ កំឡាំងពលំលោកក៏អស់ទៅយ៉ាងឆាប់រហ័ស ៗ ក្នុងវេលាពេញ ១ថ្ងៃៗនោះ លោកស៊ីងសម្ងំទៅហាក់ដូចជាភ្លេចក្លាំងហេតុគេៗក្នុងលោកអស់ហើយ ៗ លុះដល់លោកបើកភ្នែកដឹងខ្លួនឡើងវិញ វិញ្ញាណរបស់លោកក៏ក្លាហានស្មើ ហើយហាក់ដូចជាចេះនិយាយរឿងរ៉ាវយ៉ាងចំឡែកអស្ចារ្យផង ៗ ក្នុងសុបិននិមិត្តមួយនោះលោកបានយល់សប្តិឃើញពួកមនុស្សមួយពួក សុទ្ធតែស្លៀកពាក់សំពត់បរបាប់មានដំឡៃ ដើរទៅដើរមកកាត់បន្ទប់របស់លោក ៗ កាលលោកនិមន្តចូលទៅក្នុងបន្ទប់របស់លោក ដែលលោកធ្លាប់បង្រៀនការសាសំស្ក្រឹតដល់ពួកលោកសង្ឃ នៅក្នុងវត្ត ស្រាប់តែពួកជនទាំងនោះ នាំគ្នាយករនាំងសូត្រចង់ព្យួរទីងជញ្ជាំងចាត់រៀបផ្កាដាក់លើតុ ដាក់ហឹបមាសពេជ្រនៅជិតមាងសៀវភៅទីងម្ហូរសំណៅគម្ពីរដីកា ៗ លោកក្រឡេកទៅឃើញមានកូនមួយជានព្រៃព្រឹក្សាដុះទ្រុប នៅពីខាងលើក្អមនោះ មានទង់ជាយមានព័ណ៌ក្ហូផ្លេក

បក់រវិច ព្រះចាំងបានឮស្នូរស័ព្ទតូរ្យតន្ត្រីយ៉ាងពិរោះ ប្រកបដោយបន្ទាក់ភ្លេងឮស្នូរភ្លេងល្វើយឥតគណនា ៗ ស្រាប់តែមានទេពយ៉ាងថ្លៃថ្លាបរាកដមុខលោកទៅ បន្តៗគ្នាជាជួរៗ ច្រើនជាអនេក ៗ ទេពទាំងនោះផ្ទុកសុទ្ធតែអាហារចំណីនិងភោជនាហារ ដ៏មានឱជារសឆ្ងាញ់ពិសាទាំងអស់ ៗ ជនទាំងនោះនាំគ្នានិមន្តឲ្យលោកឆាន់ ឯអាហារទាំងនោះតែលោកបានឆ្លើយតបទៅយ៉ាងម៉ឺងម៉ាត់ ដោយពាក្យសុភាពទន់ភ្លន់ថា “អាហារភោជនដ៏វិសេសអស់នេះ សមគួរតែប្រគេនលោក ដែលបានសម្រេចប្រាជ្ញាញាណដ៏ខ្ពង់ខ្ពស់ ៗ ឯហ្វូន-ចាង មិនទាន់ដល់ថ្នាក់ខ្ពស់ដូច្នោះទេ ម្ដេចក៏ហ៊ានយកអាហារទាំងនេះមកប្រគេន?” ៗ

មានកាលមួយនោះ លោកភ្ញាក់រលឹកឡើងយ៉ាងឆាប់ ហើយស្រែកថា “នៅខាងមុខខ្ញុំ មានផ្កាឈូកយ៉ាងធំមួយផុះឡើង ហើយ មានសម្បុរស្រស់ហើយស្អាតបរិសុទ្ធឥតសៅហ្មងផង” ៗ កាលលោកបានដឹងថា: លោកជិតដល់មរណៈហើយ ទើបលោកនិយាយសុំឲ្យសាវ័ករបស់លោក ១ រូបដែលលោកពេញចិត្តគឺលោកគ្រូគេ - ចាង សុំឲ្យលោកគ្រូនោះ សរសេរកត់ឈ្មោះសៀវភៅនិងគម្ពីរដីកាផ្សេងៗ ដែលលោកស្វែងរកបានមក នៅវេលាដែលលោកធ្វើដំណើរយ៉ាងវែងឆ្ងាយនោះ ហើយដែលលោកបានប្រែ ក្រោយដែលលោកត្រឡប់ចូលមកស្រុកចិនវិញ ៗ តាមដែលកត់នោះ បញ្ជីរាយឈ្មោះក៏ឡាយវែងទៅឆ្ងាយណាស់

ពីព្រះបញ្ជីនោះមានចំនួនគម្ពីរ៧៤០ឈ្មោះ ចែកចេញជាផ្នែកៗ ទៅមានចំនួនច្រើនជាង ១៣៣០ ក្បាលឬផ្នែក ។ លោកហ៊ួន-ចាង បានរាប់ចំនួនព្រះរូបទាំងឡាយ ដែលលោកបានបង្គាប់ឲ្យពួកជាងរចនាដែលពូកែៗ ខាងគំនូរនិងខាងឆ្លាក់ធ្វើឡើង ដើម្បីថ្វាយដល់ព្រះជយពុទ្ធនិងព្រះពោធិសត្វមៃត្រីយ នឹងអ្នកស្រោចស្រង់ពិភពលោក ។ ឯចំនួនព្រះរូបទាំងនោះ មានចំនួនជាច្រើនម៉ឺនរូប ។

កាលធ្វើបញ្ជីគម្ពីរដីការួចសព្វគ្រប់ហើយ លោកក៏ឲ្យអានឡើងឲ្យឮខ្លាំងៗដល់ពួកភិក្ខុដែលមកប្រជុំស្តាប់ដោយស្ងប់ស្ងាត់ ដៃទប់ដើមទ្រូង ។ ហើយគេបានចែកអាហារភោជនដល់ពួកអ្នកទីទាល់ក្រហើយគេបានចែកទានផ្សេងៗទៀតផង ។ លោកហ៊ួន-ចាង កាលលោកនិងពោលលាពួកសាវករបស់លោកនោះ លោកហាមសាវកមិនឲ្យយំសោកនឹងមរណភាពរបស់លោក លោកសុំឲ្យមានចិត្តរីករាយពលគ្នាទុកដូចជាមានហេតុជាទីត្រេកអរមួយ ដែលជាឱកាសដ៏ប្រកបដោយសិរីសួស្តី ។ ក្រោយនោះបន្តិច លោកចូលក្នុងសេចក្តីត្រិះរិះពិចារណា (ចំរើនភាវនា) លោកសន្សឹមៗរលត់(ខន្ធ)ទៅ ឥតមានទុក្ខព្រួយវេទនាអ្វីឡើយ នៅវេលាដែលលោកដកដង្ហើមកាន់តែញាប់ញឹកឡើង ហើយថយខ្សោយទៅវិញនោះ ទើបពួកសាវកលោកដែលចាំយាមមើលលោកកំពុងមរណៈនោះ ផ្ទៀងទៅរកលោកសួរថា "លោកគ្រូ ដោយផលបុណ្យ

កុសលរបស់លោក តើលោកបានទទួលបំណាច់ទៅកើតក្នុងឋានសួគ៌ជាន់តុសិត ដែលជាឋានថ្កុំថ្កើងរុងរឿងរបស់ព្រះមៃត្រីយៈឬទេ?" ។ លោកហ៊្មួន-ធាង ឆ្លើយតបមកវិញយ៉ាងច្បាស់ថា "អើ" ។ ពាក្យនេះជាបច្ឆិមវាចារបស់លោក ៕

ឞ

*   *

ព្រះរាជាធិរាជ កាវ-ធុង ទ្រង់សោកស្ដាយសោកច្រើនជាពន្ទឹកណាស់ ចំពោះមរណភាពរបស់លោក ដែលទ្រង់ទុកដូចជាមិត្រជំនិត និងជាទីប្រឹក្សាដ៏ប្រសើរ ១ របស់ព្រះអង្គ ។ ទ្រង់បានចេញប្រកាសថា ដំឡៃសោហ៊ុយបង់ខាតក្នុងពិធីសពរបស់លោក ត្រូវប្រទេសចេញទាំងអស់ ហើយទ្រង់ឲ្យបញ្ឈប់ធ្វើការងារជាច្រើនថ្ងៃ ដើម្បីកាន់ទុក្ខលោក ។ ក្រៅអំពីនេះ ទ្រង់បានចេញប្រកាស ១ អនុញ្ញាតឲ្យពួកភិក្ខុនិងភិក្ខុនី នៅក្នុងវិត្តនោះចេញទៅហែសពលោក ព្រមដោយទង់ជ័យនិងក្លស់ រហូតដល់ផ្នូររបស់លោក ។ ក្នុងព្រះរាជប្រកាសនោះមានសេចក្ដីថា "លោកធម្មសាមី រុងរឿងថ្លៃថ្លាដោយសេចក្ដីប្រព្រឹត្តដ៏ឧត្តម និងគុណសម្បត្តិដ៏ប្រសើរ ត្រូវទុកលោកជាបដិមាករដ៏ជាទីគោរពនៅក្នុងកម្ពង់សតវត្សរ៍នេះ ។ ហេតុដូច្នេះ បានជាត្រូវតែខំធ្វើកុសលជាខ្សោរក ដើម្បីជាកិត្តិយសដល់វិញ្ញាណក្ខន្ធរបស់មនុស្ស ដែលមិនធ្លាប់មានក្នុងកាលដែលកន្លងមកហើយ" ។

សពរបស់លោកហួន - ឆាន់នោះ ពួកសាវកនាំគ្នាដង្ហែចូលទៅក្នុងក្រុង ហើយពួកដែលទទួលស្ដាប់បង្គាប់បណ្ដាំរបស់គ្រូលោក ក៏បាននាំគ្នាដាក់សពលោកលើគ្រែស្នែង ក្រាលកន្ទួលធម្មតាប៉ុណ្ណោះ ៗ មានចំនួនលោកសង្ឃនឹងឧបាសកឧបាសិកាច្រើនជាង ៣ ហ្មឺន ដែលនាំគ្នាមកជួបជុំក្នុងពិធីបុណ្យសពនោះ ៗ លុះ ២ - ៣ ឆ្នាំតមក ទើបមានព្រះរាជប្រកាស ១ ឲ្យដង្ហែមឈូសលោកយកទៅដំកល់ទុកក្នុងភូមិប្រទេសយ៉ាងល្អ ១ ដែលមានដាំសុទ្ធតែដើមឈើល្អ ៗ នៅជិតច្រកភ្នំហាន់ - ចួន ៗ ពួកអ្នកដំណើរដែលបានចូលទៅមើលច្រកភ្នំនោះនិយាយថា: គេនៅមើលឃើញមានប្រាង្គ ១ ប្រាំពីរជាន់ ដែលគេសាងឡើងដើម្បីជាទីរលឹកដល់លោកពុគ្គ ហួន - ឆាន់ ៗ

---

ហ្លួងនិពន្ធមន្ត្រី ញុក-ថែម ប្រែនិងរៀបរៀង

(តមក)

## ប្រទេសចិនក្នុងសម័យសាមកុក

តាមន័យដែលពោលមកនេះ មហាណាចក្រចិនក៏ចំរើនរុងរឿងបំផុតក្នុងរាជវង្សហាន ដល់ទៅព្រះបាទមាំគុសអ៊ូរលិយុសមហាក្សត្រសំខាន់ក្នុងពេល ១ គត្តុ ដូចយើងបានពោលមកហើយក្នុងពង្សាវតារពេមនោះបានកាត់កងទូតទៅចំរើនស្ពានមេត្រីដល់ព្រះមហាក្សត្រក្រុងចិន ។ មានហេតុការសំខាន់មួយយ៉ាងទៀតក្នុងព្រះរាជពង្សាវតារចិន គឺនៅក្នុងរជ្ជសម័យនៃព្រះរាជវង្សនេះឯង ប្រទេសចិនចាប់ផ្ដើមកាន់ព្រះពុទ្ធសាសនាដោយព្រះមហាក្សត្រចិនទ្រង់ព្រះនាមថា មិង-ទី បានប្រកាសព្រះអង្គជាពុទ្ធសាសនិកជន កាលពីពុទ្ធសករាជ ៦០៧ ហើយតាំងពីកាលនោះមក ប្រទេសឥណ្ឌានិងចិនក៏មានស្ពានមេត្រីនឹងគ្នាយ៉ាងមាំមួនដោយអាស្រ័យព្រះពុទ្ធសាសនាជាមូលហេតុ ។

ក្នុងរវាងពុទ្ធសករាជ ៧០០ តមក មេទ័ពបុន-ចៅក៏លះបង់លោកនេះទៅបរលោកនាយហើយ ក្សត្ររាជវង្សហានក៏ចាប់ផ្ដើមសាំសោយមិនរឹងប៉ឹងដូចដើមទៀត ហើយតមកក្នុងពុទ្ធសករាជ ៧២៧ មានមនុស្សមួយពួកដែលហៅតាមភាសាសាមកុកថា ចោរជ្លូតសំពត់លឿងបានបង្ក

ការចលាចលឡើងនៅស្រុកចិ-លី ហើយរុករានទ្រានចូលមកដល់ស្រុក ហូ-ណាន ។ ឯមូលហេតុដែលកើតពួកចោរជួតសំពត់លឿងនេះបណ្ដាល មកពីរឿងលទ្ធិសាសនា គឺពួកកាន់លទ្ធិតៅអ៊ីស្ដ ដូចពោលមកហើយនោះ ក៏តាំងផ្ដើមប្រទូសរ៉ាយៈបៀតបៀនពួកអ្នកកាន់ព្រះពុទ្ធសាសនា ។ លុះ កើតចោរភ័យដូច្នេះហើយ ព្រះចៅរាជាធិរាជក្រុងចិនក៏បានអាស្រ័យកំ-ឡាំងទាហាន សម្រាប់ប្រាបប្រាមពួកចោរឲ្យបានស្ងប់ទៅហើយ តែព្រះ រាជវង្សហានត្រឡប់ជាកាន់តែលំបាកឡើងទៀត ពោលគឺពួកមេទ័ពដែល ទទួលយកអាសាទៅប្រាប់ប្រាមពួកចោរជួតសំពត់លឿងនោះ លុះបាន ធ្វើការសម្រេចហើយ ត្រឡប់ជារឹងទទឹងតាំងខ្លួនឯងឡើង ធ្វើជានាយ ចៅហ្វាយធំក្នុងស្រុកចិន មិនគោរពកោតខ្លាចដល់រាជអំណាចរបស់ព្រះ ចៅរាជាធិរាជក្រុងចិន ចំពោះមេទ័ពដែលអង់អាចទឹងខ្លាំងពូកែមាន ១ នោះឈ្មោះថា ចូឆូ ដែលជាអ្នកចំប្រឹងប្រែងខ្នះខ្នែងជាងមេទ័ពឯទៀត ១ ក្នុងការប្រាបប្រាមពួកចោរជួតសំពត់លឿងហើយចូលទៅនៅឯក្រុងលោ-យ៉ាំងជាអ្នកជិតស្និទ្ធនឹងព្រះចៅរាជាធិរាជ ដែលទ្រង់ព្រះនាមថា ព្រះបាទ ហៀន-តេ (ឈ្មោះនេះហៅតាមរឿងរ៉ាវក្នុងសាមកុក) ។ ចូឆូជា មនុស្សខ្លាំងពូកែហើយឆ្លៀតឆ្លាតផង បានប្រមូលយកកំឡាំងទាហាន មកទុកក្នុងដៃ ទើបអាចតាំងខ្លួនជាអ្នកសំរេចរាជការដាច់ស្រេចតែម្នាក់ឯង ដែលហៅថា ឌិកតាទ័រ តែក្នុងសាមកុកហៅថា មហាឧបរាជ ។

ក្នុងសម័យដែលបូប្បមានអំណាចតាំងខ្លួនឡើងជាឱកតាត់ក្នុងពុទ្ធ-សករាជ ៧៣៧ នោះ ព្រះបាទហៀន-តេ ប្រៀបបីដូចជារូបតុក្កតា ស្រេចតែបូប្បនឹងចាប់បង្វិលទៅខាងណាក៏បានតាមចិត្ត ទើបបូប្បធ្វើជានាយហៅ-ហ្វាយធំផ្សាយអំណាចរហូតដល់ប្រទេសចិនភាគខាងជើង ។ នៅក្នុងសម័យនេះឯង មានមេទ័ពពូកែម្នាក់ទៀត ដែលមានចំណែកប្រាបប្រាមពួកចោរជួតសំពត់លឿងដែរ ឈ្មោះថាស៊ុន-គួន ។ ក៏បានតាំងខ្លួនឡើងជាធំនៅស្រុកចិនភាគខាងត្បូង បូប្បបានធ្វើការប្រាបប្រាមស៊ុន-គួនជាវេលាយូរ ក៏នៅតែមិនសម្រេច តមកទៀតទើបមានមេទ័ពម្នាក់ទៀតបានចំប្រឹងតាំងខ្លួនឡើងដែរជាពួកទី ៣ ហៅថា ឡៅ-ពី ។

ឡៅ-ពី មានឈាមក្សត្រជាប់តមកពីរាជវង្សហាន បានតាំងខ្លួនជាអ្នកគ្រប់គ្រងស្រុកសេឆួនឡើងក្នុងពុទ្ធសករាជ ៧៥៧ ឡៅ-ពីនោះប៉ុនខាងរកមនុស្សពូកែៗ មកទុកជាបក្សពួករបស់ខ្លួន ។ អាណាចក្រទាំង ៣ បានច្បាំងតស៊ូគ្នារហូតដល់ពុទ្ធសករាជ ៧៦៣ ឯចូ-ភីជាកូនរបស់បូប្ប បានលុបលាងរាជវង្សហានចេញ ហើយតាំងខ្លួនឯងឡើងជាព្រះចៅកជាធិរាជ ហៅរាជវង្សដែលខ្លួនតាំងឡើងថា រាជវង្សវេ-អ៊ុប៊ុវី" ប៉ែកខាងស៊ុន-គួននឹងឡៅ-ពី ក៏បានតាំងខ្លួនជាក្សត្រឡើងដែរ វង្សរបស់ស៊ុន-គួនហៅថា រាជវង្សវូ វង្សរបស់ឡៅ-ពីហៅថា រាជវង្សហានជាដំណាក់តមក្សត្របុរាណ ហេតុនេះ ទើបឃើញជាក់ច្បាស់ថា អាណា-

បក្រចិនបែងចែកចេញជា ៣ ភាគ ភាគ ១ គឺអាណាចក្រវេ-អ៊ុយ តាំងនៅទិសខាងជើងតំបន់ទន្លេហួង-ហូ ទីក្រុងនៅឡោយ៉ាង ។ អាណាចក្រវូ តាំងនៅភាគខាងត្បូង នៅតំបន់ទន្លេយ៉ាំង-សេ ទីក្រុងនៅស្រុកអ៊ូ-ចាំង (ហូ-ប៉េ) តមកក្រោយផ្លាស់ទៅតាំងនៅឯណាំ-កាំង ឬណានកិង ។ រាជវង្សហ៊ានតវង្សរបស់ឡេវ-ពី តាំងនៅក្នុងខេត្តស៊េ-ឈួន មានក្រុងជិងទូជាទីក្រុង ។

ក្នុងខណៈដែលប្រទេសចិនបែកខ្ញែកគ្នាជា ៣ ក្រុមដូច្នោះ គំនិតរបស់ចិនប្រែត្រឡប់ជាយកចិត្តទុកដាក់ ក្នុងការប្រមូលអាណាចក្រជាថ្មីឡើងវិញជានិច្ច តែបើយ៉ាង ៣ ក្រុមក៏ច្បាំងកាប់សម្លាប់គ្នាមិនមានស្រាក ហើយជាវេលាយូរដែរ តែមិនបានសម្រេចប្រយោជន៍អ្វីឡើយ ព្រោះមិនមានក្រុមណាមានកំឡាំងល្មមនឹងបង្ក្រាប ក្រុមមួយទៀតបានសម្រេច-រៀងរាបដរាបមកដល់ផ្លាស់រាជវង្សក្សត្រថ្មីហៅថា រាជវង្ស ស៊ុម៉ា ។ វង្សស៊ុម៉ានេះ ប្រចាំនៅក្នុងរាជសំណាក់ជាអ្នករាជការធំ របស់រាជវង្សវេ-អ៊ុ មកហើយ លុះដល់ក្នុងឆ្នាំពុទ្ធសករាជ៨០៦ ពួកវង្សស៊ុម៉ាម្នាក់ឈ្មោះស៊ុម៉ា-ចៀវ បានកំចាត់បំផ្លាញរាជវង្សហ៊ានចេញ ហើយបានប្រមូលយកអាណាចក្រខាងសេ-ឈួនមកបញ្ចូល នឹងអាណាចក្រចិនភាគខាងជើង ។ ការធ្វើការបានសម្រេចក្នុងគ្រានេះ ធ្វើឲ្យពួកស៊ុម៉ាមានចិត្តលោភលន់កាន់តែច្រើនឡើង លុះពីឆ្នាំតមកស៊ុម៉ា-យេន ជាកូនរបស់ស៊ុម៉ា-ចៀវ ក៏បាន

កំចាត់រាជវង្សវែ-អ៊ុចេញហើយចាត់តាំងរាជវង្សក្សត្រឡើងជាថ្មី ហៅថា រាជវង្សស៊ិន (ចិន-ជីង) ក្នុងឆ្នាំពុទ្ធសករាជ ៨០៨, ហើយក្នុងឆ្នាំពុទ្ធសករាជ ៨២៣ ស៊ុម៉ា យេន បានរួបរួមអាណាចក្រវ៉ូបានមកមួយទៀត ទើបមហាណាចក្រចិនក៏បានរួបរួមគ្នាឡើងវិញមួយគ្រាទៀត ។

សម្ប៊ូរាជវង្សស៊ិន បានគ្រប់គ្រងប្រទេសចិនទាំងមូលហើយ ពួកក្សត្រចាស់របស់រាជវង្សហាន់ ក៏នៅតែខំប្រឹងព្យាយាមដណ្តើមរាជ-សម្បត្តិ-ប្រទេសចិនមកវិញតែមិនសម្រេច ។ ឯរាជវង្សស៊ិនក៏មិនអាចនាំសេចក្តីចំរើនរុងរឿងមកឲ្យប្រទេសចិនបានច្រើន ប្រហែលនឹងសេចក្តីចំ-រើនដែលរាជវង្សហាន់បានផ្តើមកហើយនោះឡើយ ហើយតាំងពីពេលនោះមក ស្រុកចិនក៏បែរតែថយចុះទៅជានិច្ចៗ ។ សេចក្តីទ្រុឌទ្រោមសាបសូន្យរបស់ចិនក្នុងគ្រានោះមិនខុសនឹងសេចក្តីទ្រុឌទ្រោមសាបសូន្យរបស់ក្រុងរ៉ូមឡើយ ពោលគឺសីលធម៌និងកិរិយាមារយាទរបស់មនុស្សជាន់នោះ ចាប់ផ្តើមសាបសូន្យទៅជាមុន មនុស្សទាំងឡាយច្រើនតែគិតប្រយោជន៍ផ្ទាល់ខ្លួន ហើយគិតតែខាងសប្បាយរករាយបំរើកាមតណ្ហាកាន់តែច្រើនឡើង ខាងពួកទាហានក៏មានចិត្តទៀយណាយនឹងចម្បាំងកាំងជល់ឥតស្រាកនោះពន់ពេក ហើយនៅទីបំផុត ពួកហ៊ូនក៏រុកលុកលុយស្រុកចិនទៀត ហើយប្រទេសចិនខាងជើងក៏ធ្លាក់ទៅនៅក្នុងអំណាចរបស់ហ៊ូន ដែលជាសត្រូវចាស់របស់ចិននោះឯង ។ (មានត)

## អធិប្បាយសុភាសិត

ឃុន ឧត្តមប្រជា បាច-ពិន រៀបរៀង

(តមក)

ដូចកល់សត្វគោដំបៅខ្នង    ក្អែកហើរលែងប្រែនស្រប់ស្បែង
ពោលត្រង់តន្ទុយដោយគិតក្រែង    រអែងក្អែកចោះដំបៅខ្លួន ។

### ៣៩ - គ្នាច្រើនអន្សមខ្លោច    គ្នាដូចស្រមោចអន្សមឆ្អិន

ពាក្យនេះលោកពោលបែបបន្ទោស

ពួកមនុស្សដែលខ្ជិលហួសកំណោស    ត្រូវគោសឲ្យកើតឧស្សាហ៍ ។
ដូចយ៉ាងកិច្ចការឯណាមួយ    មានមនុស្សជួយមិនត្រៀបត្រា
ប៉ុន្តែមិនសូវមានឧស្សាហ៍    ស្រក់ស្រទំញ៉ះធ្វើការឡើយ ។
ចាំអៀកទម្រន់ប្រចាំគ្នា    អោកមិនធ្វើឲ្យឆាប់ហើយ
ដោយហេតុគំនិតគិតតើយៗ    នេះហើយគ្នាច្រើនឥតប្រយោជន៍ ។
ហេតុនេះទើបប្រាជ្ញបុរាណ    លោកថា "គ្នាច្រើនអន្សមខ្លោច"
ដោយមិនធ្វើការឲ្យល្អិតល្អោច    "គ្នាដូចស្រមោចអន្សមឆ្អិន" ។

### ៤០ - ឃ្លានឆ្ងាញ់, ស្រឡាញ់ល្អ

ពាក្យនេះលោកពោលតាមការពិត

អំពីសភាពនៃដួងចិត្ត    ដែលធ្លាប់ប្រព្រឹត្តជាធម្មតា ។

ពេលណាដែលកើតសេចក្ដីឃ្លាន   តែងមានចំណង់ចង់ភោគា
ពោះម្ហូបអាក្រក់មិនថ្លៃថ្លា   ក៏ក្លាយទៅជាមានរសឆ្ងាញ់ ។
មនុស្សណាជាទីគាប់ចិត្តខ្លួន   ទោះបីរុកកួនក៏ឥតខ្ញាញ់
អ៊ីៗ មិនល្អក៏ស្រឡាញ់   ឥតមានគិតគាញ់ថាម្ដេចម្ដា ។
ទោះរូបមិនល្អក៏សរសើរ   ថាមានដំណើរគួរជ្រះថ្លា
ពុំមានអាក្រក់ត្រង់ណា   ព្រោះមានស្នេហាទើបថាល្អ ។

### ៤១ - ឃ្លានកុំអាលស៊ី

សុភាសិតនេះប្រាជ្ញបុរាណ
លោកពោលប្រដៅឲ្យយើងបាន   ដល់ហានជាអ្នកចេះអត់ទ្រាំ ។
ក្នុងការរៀនសូត្រឬការធ្វើ   ដែលជាអំពើល្អមួនម៉ាំ
បើចេះព្រលៗ នៅព្រលាំ   ត្រូវខំអត់ទ្រាំកុំលះបង់ ។
ធម្មតាមនុស្សលោកគ្រប់ទាំងអស់   តែងចង់បានយសសក្ដិខ្ពស់ខ្ពង់
កំពុងតែរៀនបើនឹកចង់   កុំបង់ចំណេះព្រោះសក្ដា ។
ថារៀនឲ្យចប់ឲ្យចេះឆ្អិន   ស្រួលបួលទៅសិនកុំសាវា
កុំលុះអំណាចក្ដីប្រាថ្នា   ខំលះតណ្ហាសិនទៅចុះ ។
ពីព្រោះចំណេះដែលចំណាន   បើគេរៀនបានគ្រប់ថ្នាក់នោះ
ផលនៃការរៀនតែងសង្គ្រោះ   ឲ្យបានយសនោះជាពុំខាន ។
៩ បើការសិក្សានៅសើៗ   អ្នករៀនសើរើគិតចង់បាន

តំណែងសក្តិខ្ពស់ហើយឈប់ខាន    ទើងបានថ្នាក់ទាបមិនសូវខ្វល់ ៗ
ហេតុនេះអ្នកប្រាជ្ញលោកទូន្មាន    ថា "ឃ្លានកុំអាលស៊ីតាមចង់"
បើស៊ីតាមឃ្លានតាមចំណង់    ទើងបង់កេរ្តិ៍យសមិនខ្ពស់ឡើយ ៗ

## ៤២ — ឃ្លោកលិច, អំបែងអណ្តែត

ពាក្យនេះបោកណាលោកប្រឌិត.

ប្រដូចប្រៀបធៀបរៀបពិនិត្យ    តាមគោលដ៏ពិតតែផ្ទុយគ្នា ៗ
ឯឃ្លោកជាគ្រឿងស្រាលពេកក្រៃ លើសគ្រឿងដទៃផងនានា
ម្តេចឡើយក៏បែរត្រឡប់ជា    លិចក្នុងគង្គាគួរឆ្ងល់ណាស់ ៗ
ធម្មតាអំបែងជាគ្រឿងធ្ងន់    យើងធ្លាប់គយគន់បានឃើញច្បាស់
ម្តេចឡើយអណ្តែតលើអាកាស    គួរណាស់តែឆ្ងល់ពេកមហិមា ៗ
ឃ្លោកបានដល់មនុស្សត្រកូលខ្ពស់ ប្រសើរលើសអស់ជននានា
ប៉ុន្តែមិនបានរៀនវិជ្ជា    ទើងគ្មានវិរិយាកេទ្រព្យធន ៗ
អំបែងបានដល់មនុស្សមានភាព    ត្រកូលថោកទាបអំណាចទន់
ប៉ុន្តែបានរៀនវិជ្ជាមន្ត    ទើងចំណតធនកេទ្រព្យផង ៗ
អ្នកទាំងពីរពួកកាលជួបជុំ    ក្នុងទីជំនុំការប្រឡង
ទើងយកត្រកូលទៅប៉ុនប៉ង    ប្រឡងយកលេខពុំបានទេ ៗ
កូនអ្នកកំសត់តែខំប្រឹង    រៀនសូត្រចេះដឹងច្រើនជាងគេ
ព្រោះឃ្លោកដែលជាប់ច្រើនឆ្នាំភរ    រត់មករកគេឲ្យជាប់ឆ្ងាយ ៗ

## ៤៣ - ជប់នឹងល្បែងតែងហិនហោច

ពាក្យនេះជាពាក្យប្រាជ្ញប្រឌិត

តាមគោលចារឹកដ៏មែនពិត ដែលយើងធ្លាប់គិតដឹងឮស្គាល់ ។
ឯល្បែងនោះលោកថាមានបី ល្បែងស្រី, ល្បែងស្រា, និងល្បែងភ្នាល់
អ្នកជប់នឹងល្បែងតែងប៉ះពាល់ លើចាល់លើគ្រហោចហិនហៃ ។
ពោះបើទ្រព្យធនថ្កស័ក្ដិយស ក៏ខូចចាំងអស់កុំសង្ស័យ
ដូចសេដ្ឋីបុត្រប្រសើរថ្លៃ មានទ្រព្យច្រើនក្រៃល្អត្រកាល ។
ដល់ទៅ ១៦០ កោដិ តែចាញ់បញ្ឆោតពួកមិត្តពាល
ដែលកលល្បួងល្បែងបណ្ដាល ឲ្យក្រកត្រអាលដោយការល្បែង ។
មិនយូរប៉ុន្មានទ្រព្យសម្បត្តិ ជាច្រើនពេកក្កាក់ក៏ហួតហែង
វិនាសខូចខាតដាច់សង្វែង ត្រឡប់ជាស្ទួងដើរសុំទាន ។
ហេតុនេះអ្នកប្រាជ្ញលោកប្រឌិត ជាសុភាសិតទុកទូន្មាន
ឲ្យជនគ្រប់គ្នាសង្វាទាន កុំឲ្យឈ្លានពានលេងល្បែងឡើយ ។

## ៤៤ - ចពើងចង់លាភ ត្រូវធាត់ជនទៅ

សុភាសិតនេះប្រាជ្ញទូន្មាន

កុំឲ្យមនុស្សយើងលោភឈ្លានពាន ខ្នានណាស់ទៅក្រោតក្រោ ។
ធម្មតាមនុស្សលោភតែងលោភជ្រុល លុះតាមធម៌ពុលគឺតណ្ហា

មិនគិតបាបបុណ្យគុណសាសនា គិតយកអាត្មាតែមួយប្រាណ ។
ខ្វះលោកក្ខាហ្ន៎ទូមិនបានគិត ពិនិត្យតាមធម៌ព្រះទ្រង់ញាណ
គិតមួយតែខានមានខានបាន ទោសខុសប៉ុន្មានក៏មិនថា ។
ប្អូនកាលលោកលន់ចង់បានលាភ ខុសតាសន៍ទីភាពពជគាថា
ត្រូវលក់ពិន័យដល់អាត្មា ខូចខាតទ្រព្យាជាទុរន់ ។
ហេតុនេះលោកថា "កុំបើនមើន, បបើនចង់លាភរែងបាត់ធន"
ឲ្យយើងតាំងខ្លួយខំគិតគន់ កុំបីលោភលន់ខ្វាំងពេកឡើយ ។

៤៥-ចង់ផ្កាញ់ត្រូវការអន្ទាក់ ចង់ស្រណុកត្រូវរៀនដើយ

ពាក្យនេះបុកណបានប្រែថា

ប្រដៅមហាជនឲ្យរេះគិត តាមគោលល្អពិតគំនិតបុន ។
អ្នកណាប្រាថ្នាស្រណុកខ្លួន ត្រូវប្រឹងមាំមួនខ្វាំងកន្ទួន
សិក្សាវិជ្ជាគេទ្រព្យផង ទើបធ្លងតាកទុក្ខស្រណុកប្រាណ ។
ដូចអ្នកត្រូវការពីសារទ្ទាញ់ ឲ្យមានបម្ញាញ់យ៉ាងគេស្រមក្សាន្ត
ត្រូវរកគន្ទុកដបំណាន ទើបបានផ្ទាញ់មាត់ប្រាកដស្ដែង ។
ដូច្នេះយើងគួរគិតរៀយ ។ ត្រូវធ្វើឲ្យនៀយជាមុនឯង
ទើបក្រោយស្រណុកសុខក្រៃលែង ដូចប្រាជ្ញសំដែងថ្លែងប្រាប់មក ។

(មានត)

សម្ពុលាជាតក

តិំសតិនិបាត សត្តមភាគ

# ព្រះបាឡាត់ពោធិរាម យូរ-ប៊ុណ្ណ

ក្រុមជំនុំព្រះត្រៃបិដក ប្រែ រៀបរៀង

ព្រះសាស្តាគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវនាងមល្លិកាទេវី ហើយសំដែងធម្មទេសនាថា កា វេធមានា ជូប្ជះជាដើម ។

រឿងនេះមានសេចក្តីពិស្តារក្នុងកុម្មាសបិណ្ឌិកជាតកឯណោះ ។

មានសេចក្តីដំណាលថា នាងមល្លិកាទេវីបាននូវភាពជាអគ្គ-មហេសីនៃព្រះរាជាកោសលក្នុងថ្ងៃនោះ គឺបានដោយអានុភាពនៃនាងថ្វាយនូវនំកុម្មាស ៣ ដុំចំពោះព្រះតថាគត ហើយជាស្រីប្រកបដោយកល្យាណធម៌ច្រើនយ៉ាង ធ្លាប់បានទំនុកបម្រុងព្រះពុទ្ធពីបុព្វជាតិមក ជាស្រីបរិបូណ៌ដោយញាណ ស្គាល់កិច្ចការគ្រប់យ៉ាងជារបស់យកវាស ជាពុទ្ធឧបដ្ឋាយិកាក្នុងបច្ចុប្បន្ននេះ ទើបបានឈ្មោះថាជាបតិទេវតា ។ ឯអានុភាពនៃនាងដែលបានឈ្មោះថាជាបតិទេវតានោះ ក៏ល្បីឮសុសសាយប្រាកដទៅក្នុងដែនទាំងមូល ។

ថ្ងៃមួយភិក្ខុទាំងឡាយប្រជុំគ្នាក្នុងរោងធម្មសភា ពោលសរសើរគុណនាងមល្លិកាទេវីថា ម្នាលភិក្ខុទាំងឡាយ នាងមល្លិកាទេវីនេះ ជាស្រីបរិបូណ៌ដោយវត្ត ប្រកបដោយកល្យាណធម៌ច្រើនយ៉ាង ចៀវឈ្លាស

មានប្រាជ្ញាច្រើន ប៉ុន្តែរបស់ខាងការធ្វើកិច្ចទាំងពួង មានធ្វើកុសលជាដើម ជាពុទ្ធុបដ្ឋាយិកា បានឈ្មោះថាជាបតិទេវតា ព្រូព្យាស់ប្រាកដទៅ ក្នុងផែនដីទាំងមូល យើងទាំងឡាយអត់ទ្រាំទីងសរសើរមិនបាន ។ ចួន ជាពេលនោះ ព្រះដ៏មានព្រះភាគ ស្ដេចយាងមកដល់ ទើបទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អ្នកប្រជុំគ្នានិយាយពីការអ្វី ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះករុណាទាំងឡាយប្រជុំគ្នានិយាយសរសើរគុណនាងមល្លិកាទេវី ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ នាងមល្លិកាទេវីនេះ មានគុណមិនតែក្នុងវេលានេះទេ ក៏លពីព្រេងនាយមក ក៏ជាស្រីបរិបូណ៌ដោយវត្តប្រកបដោយកល្យាណធម៌ច្រើនយ៉ាង ឆ្លៀវឈ្លាស មានប្រាជ្ញាជាពុទ្ធុបដ្ឋាយិកា ទើបបានឈ្មោះថាជាបតិទេវតាដែរ ។ ទើបព្រះអង្គទ្រង់នាំរឿងអតីតជាតិមកថា អតីតេ ។ ល ។

ម្នាលភិក្ខុទាំងឡាយ ក្នុងកាលថ្ងៃលកន្លងទៅហើយមានក្សត្រមួយអង្គទ្រង់ព្រះនាមថាសោត្ថិសេន ជាបុត្រព្រះបាទព្រហ្មទត្តក្នុងនគរពារាណសី លុះបានព្រះជន្មាយុចំរើនឡើងហើយ ព្រះវរបិតាឲ្យទៀងតាំងទីជាឧបរាជនៃលើតនាងសម្ពុលា ជាស្រីមានរូបល្អ មានពណ៌ដូចជាអណ្តាតភ្លើងចង្កៀង ឲ្យធ្វើជាអគ្គមហេសី ។ លុះកន្លងយូរបន្តិចទៅមក សោត្ថិសេនឧបរាជ ក៏កើតកើតឃ្លង់ពេញទាំងសរីរៈ ពួកគ្រូពេទ្យទាំងព្យា-

បាលពេកនោះណាស់តែមិនអាចនឹងកំចាត់បង់ភេទនោះបានឡើយ ចេះតែកូលផាលច្រើនឡើង សោក្តសេនៗបាជ ក៏មានសេចក្តីអៀនខ្មាសដល់ពួកញាតិមិត្ត ក៏គិតថា អញប្រយោជន៍អ្វីនឹងនៅក្នុងលោកនេះ សូម្បីពួកមន្ត្រីតូចធំ ទ្បឹងជាភក្រ្តត្រូវធ្លាប់លេងជាមួយគ្នា ក៏គេធ្វើតោះតើយមិនសូវរួបរំកដូចពីដើមទៀតមក តាំងពីកន្លែងដែលធ្លាប់លេងសប្បាយក៏មានបានសប្បាយ ចាប់តាំងពីថ្ងៃនេះតទៅ ខ្ញុំអញអស់មានកិច្ចការឯណាមួយដែលនាំឲ្យកើតសេចក្តីរីករាយដល់ចិត្តនោះឡើយ ណ្ហើយចុះអាត្មាអញមិនត្រូវការនឹងរាជសម្បត្តិ សូវលះកាត់ដើរចេញពីទីនេះ ទៅនៅក្នុងព្រៃជាកន្លែងឥតទីពឹង ធ្វើរួមធ្វើក្រុមនឹងសត្វតិរច្ឆានវិញប្រសើរជាងលុះគិតហើយ ទើបហៅនាងសម្ពុលាមកប្រាប់ថា ម្នាលនាងសម្ពុលាចូរនាងឯងនៅក្រោយខ្ញុំឲ្យបានសេចក្តីសុខ - ចំរើន តាំងរក្សាទុកព្រះវរមាតុបិតា នឹងពួកខត្តិយត្រកូលជាញាតិមិត្តរបស់បង នឹងប្អូនឲ្យបានសេចក្តីសុខ-ចំរើនផងចុះ ដើម្បីនឹងឲ្យស្រឡាញ់រាប់រកដូចពីដើមរៀងមកបងនឹងសូមលាប្អូនទៅនៅក្នុងព្រៃ ទោះស្លាប់ទោះរស់ផ្សេងតាមយថាកម្មសព្វថ្ងៃនេះ ខ្ញុំបងមិនទាន់ស្លាប់ទេ តែហាក់ដូចជាស្លាប់ទៅហើយនែប្អូន បងសូមលាហើយ ចូរប្អូននៅឲ្យសុខចុះ ។ នាងសម្ពុលាលុះឮពាក្យស្វាមីមានព្រះបន្ទូលយ៉ាងនេះហើយ ហាក់ដូចជាគេយកដាវលំពែងមកចាក់កណ្តាលដើមទ្រូងឈឺផ្សាចុកសៀតវណ្ណនគាំងស្មើតែនឹង

និយាយមិនរួច ទើបទូលតបវិញថា បពិត្រព្រះស្វាមី ព្រះអង្គមានព្រះបន្ទូលដូចម្តេចយ៉ាងនេះ សូមព្រះអង្គកុំទៅណាឡើយ ខ្ញុំម្ចាស់នឹងធានាបីបាច់ថែរក្សាព្យាបាល ដរាបដល់រម្ងាប់រោគនោះបាន ស៊ូស្លាប់រស់ជាមួយនឹងព្រះអង្គ បើព្រះអង្គយាងទៅហើយ ខ្ញុំម្ចាស់ឥតទីពឹងពាក់អាស្រ័យទេ ។ សោត្ថិសេនតបវិញថា បងមិននៅទេ បើទុកជាយ៉ាងណាក៏ទៅដែរ សូមប្អូននៅឲ្យសុខចុះ, នាងឃាត់យ៉ាងណាក៏មិនព្រម ទើបទូលថា បើព្រះស្វាមីមិនព្រមទៅទេ ខ្ញុំម្ចាស់នឹងតាមព្រះអង្គទៅ ស៊ូស្លាប់រស់ជាមួយគ្នា ។ សោត្ថិសេនទបាជ ក៏ចូលទៅក្រាបបង្គំទូលព្រះវរមាតាបិតាថា ខ្ញុំព្រះអង្គមិនត្រូវការនៅក្នុងនគរប្រាថ្នារាជសម្បត្តិទេ ខ្ញុំព្រះអង្គសូមក្រាបបង្គំលាទៅនៅក្នុងព្រៃដែលជាកន្លែងឥតទីពឹងឯណោះវិញប្រសើរជាង ទោះបីស្លាប់រស់តាមយថាកម្មរបស់ខ្ញុំព្រះអង្គចុះ ។ ព្រះវរបិតាឃាត់ថា ម្នាលកូនសំឡាញ់ កូនកុំទៅឡើយ ថ្វីបើកើតរោគប៉ុណ្ណឹង សឹមបិតារកពេទ្យឲ្យព្យាបាលដរាបដល់រម្ងាប់រោគនោះបាន ឬមួយបើរោគនោះមិនបានរម្ងាប់ទេ ទោះស្លាប់រស់ ក៏បិតាមិនលះបង់កូនឡើយ ស៊ូស្លាប់រស់ជាមួយនឹងកូន បើចេញពីស្រុកទៅនៅព្រៃជាទីរហោឋាន ឥតមានមនុស្សម្នាខ្ញុំកំដរ មានតែពួកម្រឹគបក្សីបក្សា តើនឹងបានអ្នកណាជាទីពឹង នែកូនកុំទៅ អាណិតតែមាតាបិតាចុះ ។ ទបាជទូលថា សូមឲ្យព្រះបិតាអាណិតកូនវិញ បើទុកជានៅក្នុងទីនេះក៏

ស្លាប់ ចេញទៅក៏ស្លាប់ សព្វថ្ងៃនេះទុកដូចជាស្លាប់ទៅហើយ កុំឲ្យព្រះបិតាមាតាព្រួយព្រះទ័យចំពោះកូនឡើយ ទូលសព្វគ្រប់ហើយ ក៏ក្រាបទៀបបាទាព្រះបិតាមាតា ទឹកនេត្រហូរស្រក់ ក្រោកដើរចេញពីព្រះបរមកដកំនូរទៅតាំងខ្សឹកខ្សួល ។ ឯនាងសម្ពុលាជាមហេសី ក៏សោយសោកដើរទៅជាមួយនឹងស្វាមី ។ ឯព្រះវរមាតាបិតាមានសេចក្តីសោកស្រណោះអាឡោះអាល័យកូនពន់ពេកណាស់ ក៏ស្រែកផ្តាំថាបើកូនបានជាពេកពេលណា សូមឲ្យកូនត្រឡប់មកនគរវិញកុំខាន ។ គ្រានោះក្សត្រទាំងពីរអង្គចេញពីនគរសំដៅទៅកាន់ព្រៃធំមួយ ជាព្រៃឆ្ងាយពីស្រុកទេស ជាទីស្ងប់ស្ងាត់មានតែពួកម្រឹគបក្សីបក្សា មិនមានមនុស្សម្នាណានឹងដើរទៅមកបាន ។ លុះបានទៅដល់ទី ១ ជាទីមានឈើធំ ៗ សម្បូណ៌ទៅដោយផ្លែផ្កានឹងរម៉ម សុទ្ធតែជាឈើផ្លែមានរសឆ្ងាញ់ នឹងជ្រោះមានទឹកថ្លាល្អគួរជាទីរីករាយដល់ចិត្ត ទើបចាត់ចែងធ្វើអាស្រមនៅក្នុងទីនោះ មិនមានព្រួយបារម្ភឡើយ ។ ចាប់តាំងពីថ្ងៃដែលទៅនៅក្នុងព្រៃពេលណា នាងសម្ពុលាយកចិត្តទុកដាក់បម្រើស្វាមីមិនឲ្យអាក់ខានដល់ទៅអាក់អន់ព្រះទ័យឡើយ ។ ឯកិច្ចវត្តដែលនាងបម្រើនោះគឺពេលព្រឹកឡើង នាងបោសសំអាតទីកន្លែងសព្វអន្លើ បម្រើទឹកក្តៅទឹកត្រជាក់ពេលស្រង់ទឹកនាងដុសលាងញើសក្អែលដោយដៃខ្លួនឯង ហើយយកថ្នាំមកលាបស្រឡាបពេកទៀត ពេលសោយនាងរើសយកផ្លែឈើមានរស

ផ្កាញៀមកញ្ចុំឃែ សោយហើយនាងយកទឹកក្នុងព្រះឧស្សទនាងឈើស្លឹកមក ថ្វាយ រួចទើបនាងសោយជាខាងក្រោយ រួចរៀបចំទុកដាក់មានរបៀបរៀបរយល្អ ៗ លុះពេលនាងនឹងចេញទៅព្រៃ ក៏ចូលទៅថ្វាយបង្គំទូលថា សូមព្រះអង្គកុំធ្វេសប្រហែសយាងទៅណាមកណាឡើយ ខ្ញុំម្ចាស់នឹងទៅស្វែងរកផ្លែឈើមើមឈើចម្អិនដល់ពេលព្រឹក លុះត្រឡប់មកវិញកាន់ក្អមយកទៅដងទឹកមកដាក់ពេញពាងតូចធំសម្រាប់ប្រើប្រាស់ ៗ ពេលចូលជុំនាងទៅតាប់តក់ប្រចាំ ៗ ឯកិច្ចដែលនាងគោរពចំពោះស្វាមីយ៉ាងនេះ រាល់ថ្ងៃឥតធុញទ្រាន់ដល់ចិត្តឡើយ ៗ

មានកាលថ្ងៃមួយ នាងចូលទៅក្នុងព្រៃបេះផ្លែឈើជិតជ្រោះកំមួយ ឯជ្រោះនោះមានទឹកថ្លាត្រជាក់ល្អ នាងក៏ចុះទៅងូតដើម្បីនឹងជម្រះញើសក្អែល រួចហើយនាងក៏ស្លៀកពាក់រៀបចំខ្លួនប្រាណជាត់មេញ្ញមានមុខស្រស់បោះល្អដូចស្រីក្នុងក្រុង មានពន្លឺរស្មីផ្សាយចេញពីសរីរៈខ្លួនទៅក្នុងព្រៃគួរឲ្យមានសេចក្ដីរីករាយចំពោះរូបនាងនោះណាស់ ៗ

ពេលនោះ ចួនជាមានទានវយក្ស(១) មួយ ដើរស្វែងរកអាហារក្នុងព្រៃភ្នំនោះដែរ ក៏បានចួបប្រទះនឹងនាងសម្ពុលាមានរូបល្អដូចទេវតា មានចិត្តស្រឡាញ់នាងនោះណាស់ អត់ទ្រាំមិនបានក៏ស្ទុះថា ៖ (មានត)

---

១ អសុរអាស្រ័យនៅលើកំពូលភ្នំនោះ ។

លោកគ្រូព្រះអាចារ្យ ប៉ាង-ខាត់ រៀបរៀង

(តមក)

## បទទី ៣

## ព្រះពុទ្ធអង្គនិងចតុរារិយសច្ច

ព្រះពុទ្ធអង្គដូចជាអ្នកបង្ហាញផ្លូវ ព្រះធម៌ដែលមានអរិយសច្ចជា ខ្ញុមជាគូផ្លូវ ព្រះអរិយសង្ឃនោះគឺអ្នកដែលបានដើរតាមផ្លូវនោះហើយ , សត្វលោកដែលមានអវិជ្ជាគ្របសង្កត់ឲ្យលិចជាប់នៅក្នុងកណ្តាលវាលនៃ ទយសង្សារ កំពុងត្រូវការរកផ្លូវនោះ ។ កាលបើណាសត្វលោកសិក្សារៀនសូត្រ ពាល់តែឲ្យស្គាល់ច្បាស់ព្រះពុទ្ធអង្គយ៉ាងហ្មត់ចត់ជ្រាលជ្រៅដល់ទីបំផុត ដូចកូនស្គាល់បិតា, កាលនោះ ទើបសត្វលោករកផ្លូវនោះឃើញ ហើយដើរទៅតាមស្នាមគន្លងរបស់អរិយបុគ្គលដែលដើរទៅហើយនោះបាន ។ បើចូលចិត្តមិនទាន់គ្រប់គ្រាន់ទេ ដូចយល់ឃើញថាព្រះពុទ្ធអង្គជាព្រះម្ចាស់សួគ៌តែប៉ុណ្ណោះ ក៏នឹងមានសេចក្តីសំគាល់នឹងការតាំងប្រតិស្ឋានខុសទំនងដល់ទីបំផុតក៏មិនបានសម្រេចផល ៖ ព្រោះសេចក្តីពិត ព្រះពុទ្ធអង្គគ្រាន់តែជាអ្នកបង្ហាញផ្លូវប៉ុណ្ណោះទេ ។

ព្រះពុទ្ធអង្គគឺអ្នកដែលបង្ហាញឲ្យស្គាល់ច្បាស់នូវសេចក្តីទុក្ខ

ម្នាលភិក្ខុទាំងឡាយ ! ប្រៀបដូចបុរសម្នាក់លោតហែលទៅតាមខ្សែ

ទឹកស្ទឹង ព្រោះត្រេកអររបស់ដែលខ្លួនស្រឡាញ់និងពេញចិត្ត ។ មានបុរសម្នាក់មានភ្នែកគឺប្រាជ្ញា ឈរនៅមាត់ច្រាំង ឃើញបុរសនោះហើយ ស្រែកឡើងថា "នែអ្នកដ៏ចំរើន អ្នកលោតហែលទៅតាមខ្សែទឹកស្ទឹងនេះ ព្រោះត្រេកអររបស់ដែលអ្នកស្រឡាញ់ដ៏ពេញចិត្ត ក៏ពិតមែនហើយ តែថានៅខាងក្រោម មានសមុទ្រប្រកបដោយរលកធំៗ មានទឹកគួច មានយក្ស មានអារក្សទឹក នែអ្នកដ៏ចំរើន! បើអ្នកហែលសោត់ទៅដល់សមុទ្រនោះហើយ អ្នកនឹងស្លាប់ ឬពុំនោះ បានទុក្ខលំបាកស្ទើរតែនឹងស្លាប់" ។ ម្នាលភិក្ខុទាំងឡាយ! រីឯបុរសនោះ លុះឮសំឡេងស្រែកហៅនៃបុរសមានភ្នែក (គឺប្រាជ្ញា) នោះហើយ ក៏ខំព្យាយាមហែលច្រាសខ្សែទឹកដោយដៃផងដោយជើងផង (ត្រឡប់មកវិញ) ។ ម្នាលភិក្ខុទាំង-ឡាយ! ពាក្យឧបមានេះតថាគត ប្រតិស្ឋឲ្យកើតឡើង គ្រាន់តែនឹងឲ្យយល់ដល់សេចក្តីក្នុងរឿងនេះ គឺពាក្យថាខ្សែទឹកក្នុងស្ទឹង ជាឈ្មោះនៃតណ្ហា, ពាក្យថា របស់ជាទីស្រឡាញ់ជាទីពេញចិត្ត ជាឈ្មោះនៃអាយតនៈ ៦ ប្រការខាងក្នុង, ពាក្យថាស្ទឹងធំខាងក្រោម ជាឈ្មោះនៃឱរម្ភាគិយសំយោជនៈទាំងឡាយ ៥, ពាក្យថា រលកធំ ជាឈ្មោះនៃសេចក្តីក្រោធនឹងសេចក្តីចង្អៀតចង្អល់ចិត្ត, ពាក្យថា ទឹកគួច ជាឈ្មោះនៃកាមគុណ ៥, ពាក្យថា មានយក្ស មានអារក្សទឹក ជាឈ្មោះនៃមាតុគ្រាម, ពាក្យថា ច្រាសខ្សែទឹក ជាឈ្មោះនៃនេក្ខម្ម, ពាក្យថា ព្យាយាមដោយ

ដៃដោយជើង ជាឈ្មោះនៃសេចក្ដីប្រារព្ធព្យាយាម, ពាក្យថា ចុះសែ មាន់ក្អែក (គឺប្រាជ្ញា) ឈរនៅលើមាត់ច្រាំង ជាឈ្មោះតថាគតជាអរហន្តសម្មាសម្ពុទ្ធ ដូច្នេះ ។

តតិ. ១ .២៥-៣១៦-២៤៩-

ព្រះពុទ្ធអង្គទ្រង់បង្ហាញទុក្ខនិងផ្លូវរំលត់ទុក្ខបាន ព្រោះព្រះអង្គទ្រង់ឈ្វេងយល់ជាក់ច្បាស់ល្អ ហើយទ្រង់អាចធ្វើឲ្យព្រះអង្គរួចស្រឡះខ្លួនព្រះអង្គបាន, ឯសេចក្ដីទុក្ខដែលមិនចេះចប់នៃលោកនោះ ព្រះពុទ្ធអង្គទ្រង់រួចស្រឡះអស់ហើយ តាំងយ៉ាងគ្រោតគ្រាត យ៉ាងកណ្ដាលនិងយ៉ាងល្អិត, ចាប់ពីយ៉ាងធ្ងន់ដល់ទុក្ខយ៉ាងគ្រោតគ្រាតតូចៗ ដែលយើងទាំងអស់គ្នាកំពុងលិចអណ្ដែតក្នុងបច្ចុប្បន្នកាលនេះ សូមលើកឧទា-ហរណ៍ទោសតូចៗ ដែលព្រះពុទ្ធអង្គទ្រង់សំដែងចំពោះនឹងសតិព្រាហ្ម-ណ៍ម្នាក់ដូចសេចក្ដីតទៅនេះ

ជ្រងសេចក្ដីទុក្ខតែបន្តិចក៏ព្រះពុទ្ធអង្គមិនមាន

ម្នាលព្រាហ្មណ៍! គោបំរើ ១៤ នៃតថាគត, បាត់ទៅអស់ ៦០ ថ្ងៃហើយរកមិនឃើញ ក៏ឥតអង្គីមាន, ម្នាលព្រាហ្មណ៍! ព្រោះហេតុនោះ តថាគតទើបប្រកបដោយសេចក្ដីសុខ ។

ម្នាលព្រាហ្មណ៍! ដើមល្ងទាំងឡាយ ក្នុងស្រែដ៏អាក្រក់នៃតថា-គតមានតែត្រឹម ២-៣សន្ទឹកក្ដី ក៏ឥតអង្គីមាន, ម្នាលព្រាហ្មណ៍! ព្រោះ

ហេតុនោះ តថាគតទើបប្រកបដោយសេចក្ដីសុខ ។

ម្នាលព្រាហ្មណ៍! គណៈទាំងឡាយ លោះកំលេងក្នុងផ្នែកខាងនៃតថាគត ក៏ឥតអង្គីមាន, ម្នាលព្រាហ្មណ៍! ព្រោះហេតុនោះ តថាគតទើបប្រកបដោយសេចក្ដីសុខ ។

ម្នាលព្រាហ្មណ៍! ទីដេកនៃតថាគតទុកហាលអស់ ៧ខែ (មិនបានបោសសំអាតព្រោះមិនមានពេលទំនេរគ្រប់គ្រាន់) ដេរដាសដោយសត្វល្អិតទាំងឡាយ ក៏ឥតអង្គីមាន, ម្នាលព្រាហ្មណ៍! ព្រោះហេតុនោះ តថាគត ទើបប្រកបដោយសេចក្ដីសុខ ។

ម្នាលព្រាហ្មណ៍! បុត្រធីតាទាំងឡាយនៃតថាគតនៅពោះម៉ាយមានកូន ១ ខ្លះ ពីរខ្លះ ក៏ឥតអង្គីមាន, ម្នាលព្រាហ្មណ៍! ព្រោះហេតុនោះ តថាគតទើបប្រកបដោយសេចក្ដីសុខ ។

ម្នាលព្រាហ្មណ៍! ពេកស្គមលឿងនៃតថាគតប្រឡាក់ដោយត្រាប់ល្ងហើយគេទះគប់ដោយដើង ក្នុងពេលដែលតថាគតកំពុងដេកលក់ ក៏ឥតអង្គីមាន, ម្នាលព្រាហ្មណ៍! ព្រោះហេតុនោះ តថាគតទើបប្រកបដោយសេចក្ដីសុខ ។

ម្នាលព្រាហ្មណ៍! មេបំណុលទាំងឡាយ មកគំរាមកំហែងពីព្រលឹមថា "ចូរឲ្យមក ចូរឲ្យមក" ដូច្នេះ នៃតថាគត ក៏ឥតអង្គីមាន, ម្នាលព្រាហ្មណ៍! ព្រោះហេតុនោះ តថាគតទើបប្រកបដោយសេចក្ដីសុខ ។

តែការដែលព្រះពុទ្ធអង្គទ្រង់អាចបង្ហាញទុក្ខនិងសេចក្ដីរលត់ទុក្ខបានក៏ព្រោះព្រះអង្គទ្រង់គិតគន់ឃើញយ៉ាងពិតប្រាកដ មិនមែនបានដោយការជឿរង់ចាំឲ្យកើត ឬពុំនោះដោយការស្ដាប់ឬរៀនដោយខ្ជីខ្ជាបន្តិចបន្តួចនោះក៏ទេ ។ ព្រះពុទ្ធអង្គទ្រង់នឿយណាយចាកកាម ទើបខំប្រឹងប្រែងយ៉ាងម៉ឺងម៉ាត់ ព្រោះកិរិយាយល់ឃើញខុស ប្រឡំទុក្ខថាជាសុខវិញ ទាល់តែវិលវល់ក្នុងសង្សារវដ្ដមិនឈប់ឈរ ហើយបណ្ដោយវេលានៃជីវិតឲ្យខូចទៅទទេឥតប្រយោជន៍អស់កាលយូរ ។

## ទ្រង់ស្វះស្វែង

ម្នាលរាជកុមារ! កាលតថាគតនៅជាពោធិសត្វ មិនទាន់បានត្រាស់ដឹងនៅឡើយ មុនអំពីការត្រាស់ដឹង តថាគតមានសេចក្ដីត្រិះរិះយ៉ាងនេះថា "សេចក្ដីសុខបុគ្គលមិនគប្បីបានដោយសេចក្ដីសុខទេ សេចក្ដីសុខបុគ្គលគប្បីបានដោយសេចក្ដីទុក្ខ" ។ ម្នាលរាជកុមារ! សម័យខាងក្រោយមក តថាគតនោះនៅជាកំលោះមានសក់ខ្មៅស្រិល ប្រកបព្រមដោយវ័យដ៏ចំរើនកាលមាតានិងបិតាមិនចង់ (ឲ្យបួស) មានមុខទទឹកហើយដោយទឹកភ្នែក កំពុងទួញយំ ក៏បានកោរសក់និងពុកមាត់ពុកចង្កា ស្លៀកដណ្ដប់សំពត់កាសាយៈ ចេញចាកផ្ទះចូលមកបួស ។

កាលតថាគតនោះបានបួសដូច្នោះហើយ ក៏ស្វះស្វែងរកនូវកុសល សន្តិវរបទដ៏ប្រសើរបានចូលទៅរកអាឡារតាបសកាលាមគោត្រ . . .

បានចូលទៅរកឧទកតាបសរាមបុត្រ . . . . បានសិក្សារៀនធម៌នោះៗ ដោយឆាប់រហ័សមិនយូរឡើយ . . . . កើតសេចក្តីដឹងច្បាស់ថា "ធម៌នេះ មិនប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ ដើម្បីប្រាសចាកតម្រេក ដើម្បីសេចក្តីរលត់ទុក្ខ ដើម្បីសេចក្តីស្ងប់ ដើម្បីសេចក្តីដឹងច្បាស់ ដើម្បីត្រាស់ដឹង និងដើម្បីព្រះនិព្វានទេ គ្រាន់តែប្រព្រឹត្តទៅដើម្បីកើតក្នុងអាកិញ្ចញ្ញាយតន និងនេវសញ្ញានាសញ្ញាយតនភពប៉ុណ្ណោះឯង ៗ ម្នាលរាជកុមារ! តថាគតនោះឯង មិនពេញចិត្តនឹងធម៌នោះ បានជាគេចចេញចាកធម៌នោះហើយចៀសចេញទៅ ៗ

ម្នាលរាជកុមារ! តថាគតនោះឯង កាលស្វះស្វែងរកកុសលសន្តិវរបទដ៏ប្រសើរ ត្រាច់ទៅកាន់ចារិកក្នុងដែនមគធៈដោយលំដាប់ សំដៅទៅឯឧរុវេលប្រទេសសេនានិគម ៗ ក្នុងទីនោះ តថាគតបានឃើញនូវភូមិភាគគួរជាទីត្រេកអរផង នូវដងព្រៃដ៏ត្រជាក់ត្រជុំផង នូវស្ទឹងកំពុងហូរមានទឹកដ៏ត្រជាក់មានកំពង់រាបស្មើគួរជាទីរីករាយផង ទាំងគោចរគ្រាមក៏តាំងនៅដោយជុំវិញ ៗ ម្នាលរាជកុមារ! តថាគតនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា: "ឱ! ភូមិភាគនេះគួរជាទីត្រេកអរណាស់ហ្ន៎! ដងព្រៃក៏ត្រជាក់ត្រជុំ ទាំងស្ទឹងដែលកំពុងហូររមេៗ មានទឹកដ៏ត្រជាក់ មានកំពង់រាបស្មើគួរជាទីរីករាយ ទាំងគោចរគ្រាមក៏តាំងនៅដោយជុំវិញ,

ទាំងនេះល្មមតាំងសេចក្តីព្យាយាមរបស់កុលបុត្រ អ្នកមានប្រយោជន៍ ដោយសេចក្តីព្យាយាមដូច្នេះ" ។

ម. ម. ពោធិរាជកុមារសូត្រ ២៤ ! ៣៥៩ ! ២៥០

## ទ្រង់ឬបពោធិញ្ញាណ —

តថាគតនោះ កាលបើចិត្តតាំងនៅល្អ បរិសុទ្ធ ផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការនាកម្ម មិនមានញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ តថាគតក៏បង្អោនចិត្តទៅដើម្បីអាសវក្ខយញ្ញាណ ។ តថាគតនោះ បានដឹងច្បាស់តាមពិតថាៈ "នេះទុក្ខ នេះហេតុប្រជុំកើតឡើងនៃទុក្ខ នេះធម៌ជាគ្រឿងរំលត់ទុក្ខ នេះសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់ទុក្ខ"; បានដឹងតាមពិតថាៈ "នេះជាអាសវៈ នេះហេតុប្រជុំកើតឡើងនៃអាសវៈ នេះធម៌ជាគ្រឿងរំលត់អាសវៈ នេះសេចក្តីប្រតិបត្តិជាដំណើរទៅកាន់ទីរំលត់អាសវៈ" ។ កាលតថាគតដឹងយ៉ាងនេះឃើញយ៉ាងនេះ ចិត្តរបស់តថាគតក៏រួចចាកកាមាសវៈផង ភវាសវៈផង អវិជ្ជាសវៈផង កាលចិត្តរួចស្រឡះហើយ សេចក្តីដឹងក៏កើតប្រាកដថាៈ "ចិត្តផុតស្រឡះហើយ ជាតិអស់ហើយ ព្រហ្មចរិយធម៌បាននៅចប់ហើយ កិច្ចដែលត្រូវធ្វើក៏ធ្វើស្រេចហើយ ឥតមានកិច្ចដទៃប្រព្រឹត្តទៅដើម្បីកិច្ចនេះទៀតឡើយ" ។ ម្នាលរាជកុមារ នេះឯងជាវិជ្ជាទី ៣ ដែលតថាគតបានហើយ ក្នុងបច្ឆិមយាមនៃរាត្រី

(មានត)

# លោកគ្រូអាចារ្យ ម៉ៀវ-ឆន្ទ រៀបរៀង

(តមក និង ចប់)

សម័យក្រោយពជការមហានគរ ក្សត្រកូនទ្រង់យសខ្ពស់ឧត្តម សាងសាលាបង្ហាត់ហាត់រៀបចំ ឧបត្ថម្ភសិល្បសាស្ត្រផ្សាសំប្លែកឡើង ។ នាំឲ្យការស្វាធ្យាយន៍ឆាយស្រណុក នាំឲ្យស្រុកក្រោមក្សាន្តបានថ្កុំថ្កើង មានក្បួនតាស់ខ្វះដែរតែស្ដួចស្ដើង ស្ដេចដំកើងគិតកែប្រែសម័យ ។ ឲ្យបានស្រស់ខ្ពស់ស្របដូចស្រុកគេ ឲ្យបែរបេរកទីស៊ីវិល័យ សឹងចំរើនកើនលឿនជឿនពល់ថ្ងៃ ដោយស្នាដៃកលកិច្ចល្បិចពជការ ។ ឯទីវត្តអារាមតាមដែនដី មានសេចក្ដីស្មោះសរអរស្នារ្យ ចូលជាមួយជួយគាំនាំកុមារ ឲ្យអាហារគ្រឿងស៊ីទីសំណាក់ ។ តាំងសាលាធ្វើទានមានកុសល ចិត្តប្រតិព័ទ្ធក្នុងការអាណាចក្រ តាំងជាទីស្វាធ្យាយន៍រាយតាមថ្នាក់ សង្ឃសមណៈធ្វើគ្រូស៊ីឃ្លាតខ្លី ។ កិច្ចសង្ឃបង្រៀនប្រៀនកុមារតាមពជការបញ្ញត្តតាត់សេចក្ដី ចិញ្ចឹមក្មេងធំតូចដូចកូនខ្លី មិនយកអ្វីពីកជាវង្វាន់ ។ ប្រឹងតែស្ទួយជួយជនពន្យល់ជាតិ ឲ្យខ្លីឃ្លាតរៀនសូត្រស្រូតរូសរាន់ សិស្សប្រឹងឡើងបានជាប់កប់រយពាន់ តាមជំនាន់ជាន់តាបតាតបេះតិច ។

ធម៌ព្រះពុទ្ធសុទ្ធតែណែនាំក្រៅ បង្ហាញផ្លូវស្អាតល្អប្រកបកិច្ច មិន

ឲ្យរៀបគៀបក្បួចល្បួចល្បក់ល្បិច ការដូចម្តេចឥតទោសព្រោសឲ្យទំ ៗ
នាំមនុស្សម្នាសាមញ្ញបញ្ញាខ្សោយ ហាមមិនឲ្យជឿព្រាវព្រាវមិនចំ ពាក្យ
មិនពិតឥតគោលពោលបន្ទំ កុំផ្សេផ្សំនាំផ្សាយក្វាយក្វែងស្តី ៗ សាសនា
បវរប្រយោជន៍ច្រើន កើតចំរើនកើនផលដល់បុរី ជាគុណតាប់កប់ថា
ឋានលោកិយ ទោះយោបីជាតិមុខទុក្ខសោយ ៗ ព្រះបរមបមក្សត្រខត្តិយា
ព្រះចិន្តាថ្លាយធំទ្រង់ឈ្លងឆ្ងាយ សព្វព្រះទ័យវៃលលករក់ៗធ្លាយ ទីង
ថែកតាយចូលជួយស្ហួយសាសនា ៗ តាំងមន្ទីរហាត់ហ្វឹកសិក្សាថ្មី រៀន
បាលីកល់ធ្លាំដព្រំបញ្ញា ច្បាប់បញ្ញត្តិបរិសុទ្ធពុទ្ធដីកា គិតត្រិះត្រាឲ្យ
ត្រូវផ្លូវទៀងទាត់ ៗ អ្នកប្រតិបត្តិលទ្ធិវិសេសសុទ្ធ ច្បាប់ព្រះពុទ្ធទ្រង់
ញាណមានគ្រប់គ្រា សឹងចុះចូលម្ចាស់មិត្តចិត្តប្រដិព័ទ្ធ ព្រមមូលមាត់
តាមសាលាបាលី ៗ ព្រោះជាកិច្ចកុជការមហាក្សត្រ ព្រះអង្គបាត់
បំរុងកង់ផែនដី ជាប្រទីបទីពួទេងវែងរង្សី ជនប្រុសស្រីស្រុះស្រអវេក
អាក់ ៗ ព្រះបមពង្សទ្រង់តាំងបណ្ណាល័យ ប្រសើរថ្លៃឧត្តមសមសួរ
ស័ក្តិ ច្បាប់គម្ពីរគ្រប់មុខទុកតាមថ្នាក់ ដំកល់ដាក់ត្រាន់បានគានឲ្យ
ច្បាស់ ៗ តែឯអ្នកកាន់កាប់ច្បាប់ឧត្តម សឹងប្រឡំនិយមទំនៀមចាស់
សែនស្ងួមគារស័ក្តិសិទ្ធិព្រឹទ្ធព្រាហ្មណ៍ខ្ទះ មិនបានផ្លាស់ដំនៀវជឿខ្មោច
ព្រៃ ៗ ចំណែកអ្នកដាក់ចិត្តឥតក្រឡាប់ ជឿតែច្បាប់ព្រះអង្គគ្រង់ប្រពៃ
មិនគ្រាធចិត្តឥតក្រោញសាញហទ័យ សុខទុក្ខភ័យវៃលករតដើមអាទ៍ ៗ

មិនកក្កុំកនឹកកើនគិតការពិត ប្រឹងប្រព្រឹត្តប្រុងត្រៃផ្ទុំល្អស្អាត រីឯ
វិសេសវេះហួសផ្ទៃសក្បួនខ្នាត នាំឲ្យវាគង់ទៅគេមិនស្តាប់ ៗ មិនជឿ
ត្រូវស័ក្តិសិទ្ធិគិតក្លាយក្លែង អ្នកខ្លួនឯងពូកែតែខុសច្បាប់ អាងអាងមហេ
មន្តយន្តក្តុតធាប់ ប្រើសំពប់បោកប្រាសនាំវេះបោរ ៗ យ៉ាងអ្នកបោកបែប
ខ្ទុំឈ្នាសចុរ្បាយ ប្រើលបខាយតាយេតាក់ហាក់ដូចបោរ ខ្លះជាអ្នកជួ
ជាតិមារយកទទោរ ធ្វើជាគោរសក់ខ្ទីខ្ទីគេទសន្សំ ៗ ខ្លះតីព្រៃងកើងចាស់
ក្រាសំអាងជឿ ជាប់ជំនឿវិបរិតឥតទៀងត្រង់ ទៀសម្បត្តិខ្ចាត់
ខ្ចាយអន្តរាយបង់ ព្រោះតែចង់ចូលចិត្តមិត្តក្លែងក្លាយ ៗ អ្នកប្រកាសសា-
សនាមហាមុនី ប្រាប់អំពីខុសត្រូវផ្លូវអន្តរាយ នាំឲ្យកើតគំនិតគិតវែង
ឆ្ងាយ តាមជម្រាយជម្រាបច្បាប់លោកិយ ៗ នាំឲ្យជនស្រីប្រុសពុទ្ធ
ជាតក ជាគុណូបង់បេះចំណេះថ្មី ជាប្រយោជន៍ដល់ជាតិដល់ទឹកដី តាម
សេចក្តីប៉ុនប៉ងព្រះរាជា ៗ ព្រះបរមបពិត្រនរបតី ប្រោសប្រណីចាត់
វិធីតែងសកា សាសនបណ្ឌិត្យមិត្តមេធា ឲ្យនាំគ្នាតាន់គ្រវេះគិត ៗ
បកប្រាណីជាខ្មែរកែសម្រាយ ដែលឃ្លាតក្លាយផ្លាយវែងក្លែងមិនពិត វាជ-
បំរើស្តុទ្ធសិទ្ធប្រឹងពិនិត្យ ទំនែបរិតមិតយោងប្រជាងសាមនា ៗ តែង
វក្បួនច្បាប់សម្រាប់ស្តាប់មើលអាន ដូចក្បួនត្រៃក្បាន្តប្រាប់ប្រាសព្រះជា
ឆ្លៀប់ប្រុណីពោរពាសពេញស្ទៀមក សឹងផ្ទះថ្នាពេកណាស់ព្រះគុណថ្លៃ ៗ
ព្រះករុណាមេត្តាប្រោសប្រណី ចាត់ការឲ្យប្រែបិដកត្រៃ ជាសម្រាយ

ផ្សាយចេញពេញច្រើនក្រៃ កុំសង្ស័យមានពុម្ពជ្រាមដែនដោះ ។ ប្រយោជន៍ដល់ប្រុសស្រីឥឡូវនេះ ដែលមិនចេះភាសាបាលីសោះ គង់មើលកើតស្ដាប់បានអានត្រូវអស់ ពាក្យរបស់ខ្មែរពិតគិតងាយយល់ ។

ហៃសាធុសប្បុរសផងទាំងឡាយ ដែលខ្វល់ខ្វាយគោរពព្រះទស-ពល ត្រៃបិដកសោភាជាឫសគល់ ល្អនិម្មលមានខ្លឹមត្រឹមនេះឯង ។ សាសនិកជនជូនខាងគិត ចូរពិនិត្យឲ្យជាក់អ្នកប្រាជ្ញផ្ទៃពេង ជាច្បាប់ដើមផ្ដើមធម៌ល្អបិទញែង គួរប្រឹងប្រែងស្វែងប្រាជ្ញាបកគិតខុស ។ បើមានរឿងឡើងឆ្ងល់ខ្វល់ពាក់ព្រៀវ បើកសៀវភៅមើលភ្លាមតាមចិត្តប៉ុះ អក្សរយើងពាក្យខ្មែរប្រែសព្វស្រុស គង់តែចុះចុះធ្លាយងាយយល់បាន ។ បើទើសពាល់ឆ្ងល់ខ្ទាំងតាំងចិន្តា រកអ្នកណាមិនមួយជួយគិតអាន ធ្វើជួបប្រះម្ល៉េះសមថ្កុំថ្កើងថ្កាន មិនប៉ុន្មានបានជាមេធាវី ។ ស្រុកពីដើមក្រក្រអក្សរសាស្ត្រ ខ្សត់ក្រជាសខ្វះពុម្ពបំពេញទី ដូចព្រលប់យប់ងងឹតឥតអគ្គី ឃ្លាតអំពីចង្កៀងទៀនតែសូន្យ ។ ធម៌ព្រះពុទ្ធទ្រង់ឧបុះគុះទាបណាស់ វិបល្លាសដុនដាបសាបរាបអួន គេគាន់ស្មានបានត្រាប់ច្បាប់តាដូន ឥតដំបូន្មានល្អតពីព្រះ ។ កាលប្រទេសរុងរឿងលឿងព្រះឈ្មោះ ធម៌ពី-រោះខ្ពស់ឡើងថ្កើងតេជះ ដូចអាទិត្យទិព្វខែងថែងបវរ ពន្លឺលះលេចលុបកងដែនដាន ។ អ្នកប្រឹងប្រឡាញ់សាសនាថាល្អពិត គួរប្រព្រឹត្តជួយជាតិញាតិភូមិស្ថាន ទើបសាសនាប្រណីតស្ថិតស្ថេរបាន យើងគ្រប់

ប្រាណគួរព្រួតពួតជួយគ្នា ៗ កុំឲ្យជាតិឃ្លាតចុះគុះទាបទៅ ឲ្យស្ថិត ទៅគង់គេក្ដិបវរវេលា ឲ្យបរិបូណ៌ធនធានមានគោគា ចេះវិជ្ជាជាន់ថ្មីល្បី សុសសាយ ៗ កុំឲ្យបាត់សាសនាការកាន់ក្រិត្យ កាន់ឲ្យស្ថិតស្ថេរលន់ យង់យូរឆ្ងាយ ជាកិច្ចល្អតជាប់តាប់គួរស្ដាយ ជាធម៌ផ្សាយពាយផល ផលទេគារ ៗ ប្ដូរតាំងចិត្តស្មោះត្រង់អង្គចក្រ ម្ចាស់ផែនដីជួនចិត្តគិត ថ្វាយពារ សូមឲ្យសុខក្សេមក្សាន្តបានសាទរ ព្រះភូធរទ្រទ្រង់វង្សខេ- មរ ៗ ត្រង់កស្ដ្ររដ្ឋទាត់ទៀនវៀនកល់ថ្ងៃ ព្រះទ័យថ្លៃក្រសោបគោប សីមា ទ្រង់ពិនិត្យគិតធៀបរៀបសាសនា ឲ្យថ្ងៃថ្លាភ្លាក់ផ្ទរក្រើរត្រើមត្រង់ ៗ

រឿងសរសេរបែបសាសនាវិភារ ខន្ធាវារខ្ញុំបែងតែងផ្ចិតផ្ចង់ លើត តែគោលពោលឡាក់កាត់កង់ៗ សូមបង្អង់បុណ្ណោះស្ទើះទុកអើយ ៗ (ចប់)

ម. ខន្ធាវារ

៣